# បកិណ្ណកវិនយកថា

វត្តនិគ្រោធវ័ន

រៀបរៀងដោយ

ភិក្ខុ វិនយធរោ គុន-ប៊ុនសាយ

ព.ស. ២៥៥៥

(សម្រាប់ជាធម្មទាន)

# បកិណ្ណកវិនយកថា

## ពុទ្ធមណ្ឌលមហាសតិប្បដ្ឋាន
## វត្តនិគ្រោធវ័ន "គល់ទទឹង"


## រៀបរៀងដោយ
## ភិក្ខុ វិនយធរោ


## ព.ស. ២៥៥៥

## (សម្រាប់ជាធម្មទាន)

# គម្ពីរជាឧបករណ៍ ក្នុងការរៀបរៀងសៀវភៅនេះ

- ព្រះត្រៃបិដក
- ព្រះអដ្ឋកថា សមន្តប្បាសាទិកា
- កង្ខាវិតរណី អដ្ឋកថាបាតិមោក្ខ
- វិនយសង្គហដ្ឋកថា
- ខុទ្ទកសិក្ខា
- វជិរពុទ្ធិដីកា
- សារត្ថទីបនីដីកា
- វិមតិវិនោទនីដីកា
- វិនយវិនិច្ឆយដីកា
- វិនយាលង្ការដីកា
- បាចិត្យាទិយោជនា
- កង្ខាវិតរណីអភិនវដីកា
- ខុទ្ទកសិក្ខាបុរាណដីកា
- វចនានុក្រមខ្មែរ ២

*ឈ្មោះសៀវភៅ* **បកិណ្ណកវិនយកថា**

*រៀបរៀងដោយ* ភិក្ខុ វិនយធរោ តុន_ប៊ុនសាយ

*ជួយកែសំរួលដោយ* ភិក្ខុ សុវណ្ណជោតោ ភួង_សុវណ្ណ

ភិក្ខុ ជឹម_ផល្លី

ភិក្ខុ ឆឿប_ឆ្លាម

ភិក្ខុ វី_សាឈឿត

*កាលបរិច្ឆេទ* ព.ស ២៥៥៥

*ស្ថានទីធ្វើ* វត្តនិគ្រោធវ័ន "គល់ទទឹង"

ភូមិកោះក្របី សង្កាត់ព្រែកថ្មី ខ័ណមានជ័យ

រាជធានី ភ្នំពេញ

# អារម្ភកថា

សៀវភៅ **បកិណ្ណកវិនយកថា** នេះជាសៀវភៅមួយដែលសម្ដែងសេចក្ដីពន្យល់នៅក្នុងវិន័យផ្សេងៗ ។

ខ្ញុំព្រះករុណា បានខិតខំប្រឹងប្រែង ដកស្រង់នូវសេចក្ដីដែលមានមកក្នុងបិដក អដ្ឋកថា និងដីកាចារ្យជាដើម យកមកដាក់នៅក្នុងសៀវភៅនេះ ដើម្បីបានជាចំណេះដឹង ដល់សិក្ខាកាមទាំងឡាយ ដែលជាអ្នកប្រាថ្នានូវការសិក្សាព្រះវិន័យ របស់ព្រះមានព្រះភាគ, ប៉ុន្តែថា ក្នុងសៀវភៅនេះ ក៏មិនអាចជួយឱ្យសិក្ខាកាមទាំងឡាយ ចេះដឹងសព្វគ្រប់បានទេ, ព្រោះក្នុងសៀវភៅនេះ ខ្ញុំព្រះករុណា បានដកយកតែសេចក្ដីខ្លះៗ ដែលមានមកក្នុងបិដកនិងអដ្ឋកថាជាដើមប៉ុណ្ណោះ, មិនបានដកមកឱ្យពិស្ដារទេ, ដូច្នេះ សិក្ខាកាមទាំងឡាយ ដែលជាអ្នកប្រាថ្នានូវការសិក្សា ក្នុងព្រះវិន័យ ឱ្យបានចេះដឹងទូលំទូលាយ ត្រូវតែខិតខំស្រាវជ្រាវដោយខ្លួនឯងផងចុះ ។

ចំណែកឯនៅក្នុងសៀវភៅនេះ បើមានការខុសទាស់ត្រង់ណា ខ្ញុំព្រះករុណាក៏សូមអភ័យទោស អំពីសំណាក់អ្នកប្រាជ្ញទាំងឡាយ ព្រោះថា ការធ្វើអ្វីនីមួយរមែងមានខុសខ្លះ

ត្រូវខ្លះជាធម្មតា, ការខុសទាំងអស់នោះ ជួនកាលខុសដោយការភាន់ច្រឡំ ក៏មាន, ជួនកាលខុសដោយការប្រហែសធ្វេសមិនបានពិនិត្យឱ្យបានសព្វគ្រប់ ក៏មាន, ឬខុសដោយការចេះមិនដល់ក៏មាន, ការខុសទាំងអស់នោះ សូមផ្ញើរនូវការកែសម្រួលដល់លោកអ្នកប្រាជ្ញទាំងឡាយ,សូមលោកជួយកែតម្រូវ ដោយកុសលចេតនាផងចុះ ។ ដោយមហាកុសលចេតនា ដែលកើតអំពីធម្មទាននេះសូមឧទ្ទិសនូវសៀវភៅនេះ ជាគ្រឿងសក្ការបូជាចំពោះព្រះរតនត្រ័យ និងសូមឱ្យបានសម្រេចនូវលោកុត្តរធម៌ក្នុងកាលខាងមុខនេះកុំបីខានឡើយ ។ ម្យ៉ាងទៀត សូមបុណ្យកុសលនេះ បានសម្រេចដល់ញាតិទាំងឡាយរបស់ខ្ញុំ មួយអន្លើដោយសព្វសត្វទាំងអស់ ព្រមទាំងបរិវាររបស់ខ្លួនផង និងអ្នកដែលបានសិក្សា នូវព្រះវិន័យ របស់ព្រះសាស្ដាផងដែរ ។

សូមអនុមោទនាបុណ្យ !!!!!!

វត្តនិគ្រោធវ័ន "គល់ទទឹង"

ថ្ងៃ ៦ រោច ខែ ស្រាពណ៍ ឆ្នាំ ថោះ ព.ស. ២៥៥៥

**ភិក្ខុ វិនយធរោ គុន-ប៊ុនសាយ**

# បញ្ជីមាតិកា

**មាតិកា** *ទំព័រ*

## បកិណ្ណកវិនយកថា

**១-អនាមាសវិនិច្ឆយកថា** ........................................................១

*អធិប្បាយវត្ថុដែលជាអនាមាស* ..................................៥

*អនាមាសវត្ថុប៉ះដោយវត្ថុជាប់ដោយកាយគួរ* ................៩

*វត្ថុជារបស់ភិក្ខុដែលគួរដល់ការបរិភោគ មិនគួរដើម្បីប៉ះ..១២*

*ផ្លែឈើមិនគួរប៉ះពាល់* ...................................................១៣

*សេចក្ដីផ្សេងគ្នានៃទុរុបចិណ្ណ និងអនាមាស...................១៦*

*ការប៉ះពាល់សាច់ឆៅ ត្រីឆៅ និងស្រូវ មិនគួរ............១៦*

*រតនៈ ១០ ប្រការ.........................................................១៧*

*ភិក្ខុអ្នកទំនុកបម្រុងព្រះចេតិយ គួរប៉ះវត្ថុអនាមាសបាន...២១*

*ការប៉ះវត្ថុអនាមាសជាសចិត្តកៈ......................................៣១*

**២-វិញ្ញត្តិវិនិច្ឆយកថា** ........................................................៣៣

*ព្រះរដ្ឋបាលពោលជាមួយបិតាថាៈ..................................៣៣*

*ការបេញមាត់សូម...........................................................៣៥*

*ឆ្លើយនឹងពាក្យដែលគេសួរ មិនជាវិញ្ញត្តិ........................៤១*

*វត្ថុដែលកើតពីវិញ្ញត្តិមិនគួរ សូម្បីដល់សហធម្មិកទាំង៥...៤៤*

ការសូមក្តី ការទទួលក្តីនូវវត្ថុដែលជាអកប្បិយមិនគួរ......៤៧
របស់ដែលគេមិនហួងហែងសូមមិនជាវិញ្ញត្តិទេ...............៥០
ការធ្វើនូវនិមិត្តកម្មជាដើម.................................................៥២
**៣-បព្វជ្ជាកថា** ........................................................................៥៨
ការបួសជាសាមណេរគឺ ត្រូវបរិសុទ្ធទាំង២ចំណែក .....៦២
ការឱ្យជាអនុនាសិកន្តៈត្រូវឱ្យជាប់គ្នា ..........................៦៧
សិក្ខាបទដែលសាមណេរត្រូវសិក្សា ...........................៦៩
បព្វជ្ជាមានអង្គ ៣...........................................................៧៤
ភិក្ខុកំលោះបំបួសជំនួសព្រះឧបជ្ឈាយ៍ .......................៧៥
អ្នកបួសជាភិក្ខុមិនកោរសក់ និងពុកមាត់ ក៏បួសឡើងដែរ...៧៩
**៤-ភណ្ឌុកម្មកថា** ............................................................៨៤
ការប្រាប់ភណ្ឌុកម្ម .......................................................៨៤
ការបួសជាសាមណេរ ជាកម្មស្រាល .......................៨៦
ស្លៀកសម្ពត់ដោយខ្លួនឯងបួសមិនឡើង .....................៨៨
**៥-នាសនង្គកថា** ...............................................................៩១
នាសនង្គៈ ១០ របស់សាមណេរ..................................៩១
ការវិនាសមាន ៣ ប្រការ ....................................៩២
សាមណេរដាច់ត្រៃសរណគមន៍ នៅសល់តែភេទ.........៩៣

សាមណេរដាច់ត្រៃសរណគមន៍ ត្រូវរាប់វស្សាជាថ្មី ....៩៥
សាមណេរក៏ត្រូវចូលវស្សាដែរ....................................៩៧
សិក្ខាបទស្មុរបស់សាមណេរជាសចិត្តកៈ....................៩៩
ទណ្ឌកម្មរបស់សាមណេរ...............................................១០១
សាមណេរពោលតិះដៀលព្រះរតនត្រ័យ ...................១០៣
**៦-បណ្ឌកកថា** ..........................................................................១០៩
**៧-ថេយ្យសំវាសកកថា** .........................................................១២១
ថេយ្យសំវាសមាន ៣ យ៉ាង..........................................១២១
សូម្បីការរាប់វស្សារបស់សាមណេរ ក៏ជាថេយ្យសំវាសដែរ...១២៣
ការកាន់យកភេទដោយចិត្តបរិសុទ្ធ ..............................១២៤
ការកាន់យកភេទដោយបំណងលេង ..........................១២៦
សូម្បីមិនស្គាល់ឈ្មោះថេយ្យសំវាសក៏ជាការលួចភេទដែរ...១២៩
ការកាន់យកភេទជាអ្នកបួសទៅបញ្ឆោតគ្រហស្ថ .........១៣២
សាមណេរប្រាថ្នាទៅជាគ្រហស្ថស្លៀកដូចជាគ្រហស្ថមិនគួរ..១៣៩
សាមណេររាប់វស្សាកោងជាមួយសាមណេរ.................១៤១
**៨-អនុបជ្ឈាយកាទិវត្ថុកថា** ....................................................១៤២
ការបួសជាភិក្ខុសូម្បីមិនមានឧបជ្ឈាយ៍ ក៏បួសឡើង.....១៤២

ការឱ្យសាមគ្គីក្នុងកម្មមិនប្រកបដោយធម៌......................១៤៥
ព្រះឧបជ្ឈាយ៍សូធ្យកម្មវាចាឱ្យសទ្ធិវិហារិករបស់ខ្លួនក៏គួរ.......១៤៧
មុននឹងសូត្រកម្មវាចាត្រូវឱ្យកាន់យកឈ្មោះសិន...........១៤៨
ក្នុងកម្មសន្មតទាំង ១៣ ខ្លួនឯងសន្មតដោយខ្លួនឯងក៏បាន.....១៥២
ឧបសម្បទាបេក្ខៈនៅក្នុងហត្ថបាសសង្ឃទើបបួសឡើង...១៤៣
**៩-អនាចិត្តិក្ខមន្តរាយិកកថា** ..................................................១៥៥
ការមិនដឹងនូវបទបញ្ញត្តិនិងមិនដឹងនូវវត្ថុហើយប្រព្រឹត្តកន្លង.....១៥៩
បុគ្គលដែលមានអាបត្តិស្លាប់ទៅកើតជានរក និងតិរច្ឆាន..១៦០
**១០-ខ្ទនកុក្ខេបសីមាកថា** ......................................................១៦២
សូម្បីមិនសាចទឹក ក៏មានឧទកុក្ខេបសីមាដែរ...............១៦៣
**១១-ឆន្ទបារិសុទ្ធិកថា** ...........................................................១៦៨
ភិក្ខុមានអាបត្តិឱ្យបារិសុទ្ធិរមែងត្រូវអាបត្តិ...................១៦៩
ពាក្យប្រាប់នូវឆន្ទៈនិងបារិសុទ្ធិ .................................១៧១
ពាក្យឱ្យនូវឆន្ទៈ.........................................................១៧១
ការឱ្យនូវបារិសុទ្ធិធ្វើបានតែឧបោសថកម្មប៉ុណ្ណោះ .....១៧២
កាលបើសង្ឃមាន លោកធ្វើបារិសុទ្ធិឧបោសថបាន....១៧៥
ការឱ្យបារិសុទ្ធិ ជាប់តគ្នាមិនគួរ ................................១៧៩
កាលសូធ្យញត្តិចប់ហើយ កម្មមិនខូចទេ ..................១៨០

ភិក្ខុនៅក្នុងហត្ថបាសសង្ឃ មិនត្រូវឱ្យឆន្ទៈនិងបារិសុទ្ធិទេ....១៨៤
**១២.សង្ខិត្តេន បាតិមោក្ខុទ្ទេសកថា** .......................................១៨៨
បាតិមោក្ខុទ្ទេសមាន ៥ យ៉ាង ....................................១៨៨
ការសម្តែងនូវបាតិមោក្ខុទ្ទេសសង្ខេប............................១៨៩
អន្តរាយ ១០ យ៉ាង..................................................១៩០
មិនមានអន្តរាយតែអាចសូត្របាតិមោក្ខដោយសង្ខេបបាន..២០១
**១១.អាបត្តិទេសនាកថា** ..........................................................២០៥
វិធីសម្តែងអាបត្តិតែមួយ..................................................២០៥
វិធីសម្តែងអាបត្តិថុល្លច្ច័យ២ .......................................២០៨
វិធីសម្តែងអាបត្តិថុល្លច្ច័យច្រើន.....................................២០៩
វិធីសម្តែងអាបត្តិបាចិត្តិយ ១ .......................................២១០
វិធីសម្តែងអាបត្តិបាចិត្តិយច្រើន ..................................២១០
វិធីសម្តែងអាបត្តិបាដិទេសនីយ.......................................២១១
វិធីសម្តែងអាបត្តិទុក្កដច្រើន ១ ....................................២១២
វិធីសម្តែងអាបត្តិទុក្កដច្រើន ..........................................២១២
វិធីសម្តែងអាបត្តិទុព្ភាសិត ............................................២១២
វិធីសម្តែងអាបត្តិថុល្លច្ច័យ ២ មានវត្ថុផ្សេងគ្នា .........២១៣
ការសម្តែងអាបត្តិដោយភាសាណាមួយ ក៏បាន...........២១៦

ការសម្តែងអាបត្តិមិនដាច់..........................................២១៧
ការសម្តែងអាបត្តិ ២-៣ រូបក្នុងទីជាមួយគ្នាបាន.........២២០
នៅក្នុងសីមាផ្សេងគ្នាសម្តែងអាបត្តិ មិនដាច់ទេ............២២២
ភិក្ខុសម្តែងអាបត្តិប្រាថ្នាឱ្យត្រូវទៀតមិនដាច់ទេ..............២២៤
ដីការវិមតិប្រាប់អចិត្តកសិក្ខាបទក្នុងខន្ធកៈ.......................២២៦
ការសម្តែងអាបត្តិជាសភាគៈគ្នា ជាអចិត្តកៈសិក្ខាបទ....២២៨
ការបើកអាបត្តិជាលហុកាបត្តិដែលជាសភាគៈគ្នា...........២៣៤
មិនមែនរូបផុតចាកអាបត្តិ ដោយការសឹកទេ................២៣៨
**១៤-វស្សូបនាយិកកថា** .......................................................២៤០
ក្នុងថ្ងៃបវារណាក៏ដោយត្រូវតែលើកសត្តាហៈទៅ...........២៥០
**១៥-ឧបាហនកថា** ..........................................................២៥៣
ពន្យល់ពាក្យថា ស្បែកជើង និង ទ្រនាប់ជើង............២៥៣
បាទុកាដែលធ្វើមកអំពីស្បែក ក៏មានដែរ......................២៥៤
ភិក្ខុមិនត្រូវពាក់ស្បែកជើងចូលទៅក្នុងស្រុកទេ.............២៥៥
ពាក់ស្បែកជើង ២-៣ ជាន់មិនគួរទេ ត្រឹមតែ១ជាន់គួរ........២៥៦
ភិក្ខុមិនឈឺអាចពាក់ស្បែកជើងក្នុងអារាមបាន..............២៥៩
ស្បែកជើងអកប្បិយ ជូតមិនចេញក៏អាចប្រើបាន .......២៦៣
**១៦-កប្បិយភូមិកថា** .......................................................២៦៦

កប្បិយភូមិមានទាំងអស់ ៥ ព្រោះថែម ១ ទៀត......២៧២
មុខសន្និធិ តែជាអាបត្តិទុក្កដ ....................................២៧៥
សត្តាហកាលិកជាដើមចំអិនលាយនឹងអាមិសមិនគួរ.....២៧៦
កប្បិយកុដិឈ្មោះគោនិសាទិកា.....................................២៧៧
បើគ្មានកប្បិយភូមិទេ ត្រូវឱ្យដល់សាមណេរ...............២៧៨
**១៧-អកប្បិយសមានចេតព្វកថា** ..........................................២៨១
**១៨-បល្លង្កាសនកថា** .......................................................២៨៤
របសត្វសាហាវដែលឆ្លាក់ជាប់នឹងជើងគ្រែក៏មិនគួរ.......២៨៨
**១៩-កាលិកសំសដ្ឋកថា**.......................................................២៩០
ភិក្ខុមានហេតុឆាន់យាមកាលិក និង សត្តាហកាលិកជាដើម...៣០០
ក្នុងបុរេភត្ត មិនពិចារណានូវគិលានប្បច្ច័យ មិនជាអាបត្តិ ..៣០៥
**២០-សាមណេរានិសង្សកថា** ..................................................៣០៩
បើឧបចារផ្សេងគ្នាត្រូវក្រាលកឋិនផ្សេងគ្នា ..................៣១២
ពាក្យថា អានិសង្សរបស់កឋិន.......................................៣
លាភនៃការចាំវស្សាសូម្បីមិនបានក្រាលកឋិន ក៏បានដែរ.....៣១៩
ភិក្ខុមិនបានក្រាលកឋិន បានអានិសង្សត្រឹមតែ៤..........៣២១
ភិក្ខុប្រាប់ពេលទាយកសួរពីការថ្វាយកឋិនចីវរ..............៣២១
**២១-សទ្ធាទេយ្យវិនិបាតនកថា** ................................................៣២៥

ភិក្ខុដាក់អាហារក្នុងភាជនៈរបស់សង្ឃហើយឱ្យដល់មាតា.....៣២៦

ពាក្យថា អនាមដ្ឋបិណ្ឌបាត ..........................................៣២៧

ភិក្ខុមិនត្រូវឱ្យអាហារជាដើមដល់ជន ដែលព្រះមិនអនុញ្ញាតទេ....៣៣០

ការពោលជាមួយជនមិនមែនជាញាតិជាសទ្ធាទេយ្យ.....៣៣៣

**២២-អារាមនច្ចាទិទស្សនកថា** .................................................៣៣៧

ការមើល និងការស្តាប់ចម្រៀងក្នុងអារាម ..................៣៤៣

អចិត្តកសិក្ខាបទព្រោះការស្តាប់ចម្រៀង........................៣៤៧

សិក្ខាបទនេះមានអង្គ៣..................................................៣៤៨

**២៣-ឯកភាជនាទិកថា** ...........................................................៣៤៩

ការឆាន់ផ្លែឈើក្នុងភាជនៈតែមួយជាមួយគ្នា មិនគួរ ...៣៤៩

ការដេកលើគ្រែតែមួយជាមួយគ្នា.................................៣៥១

ការដេកលើកម្រាលតែមួយជាមួយគ្នា...........................៣៥២

**២៤-លោមសំហរកថា** ..............................................................៣៥៥

រោមក្នុងទីបង្កៀតនាំចេញដោយខ្លួនឯងមិនគួរ.................៣៥៧

**២៥-អវន្ទិយវន្ទិយកថា** .........................................................៣៥៨

អវន្ទិយបុគ្គល ១០ ពួក...................................................៣៥៨

វន្ទិយបុគ្គល ៣ ពួក.......................................................៣៥៩

បុគ្គលដែលភិក្ខុមិនគួរសំពះមាន ២៥ ប្រភេទ ..........៣៥៩

វន្ទិយបុគ្គលមាន ៥ ពួក..............................................៣៦៦

ភិក្ខុខីជាងថ្វាយបង្គំបាទាភិក្ខុចាស់ជាង..........................៣៦៧

ការថ្វាយបង្គំប្រកបដោយអង្គ ៥ តាមដីកាវិនយា........៣៦៩

ការថ្វាយបង្គំប្រកបដោយអង្គ ៥ ដែលមកតាមប្រវេណី ៣៧០

ការថ្វាយបង្គំប្រកបដោយអង្គ៥ តាមន័យក្នុងបរមត្ថទីបនី ៣៧៣

**២៦_បដិភាណចិត្តកម្មកថា** ......................................................៣៧៥

គូររូបព្រះសម្មាសម្ពុទ្ធ ដោយខ្លួនឯងមិនគួរទេ.............៣៧៦

**២៧_សេនាសនកថា** ..............................................................៣៧៩

អង្គុយលើគ្រែ និង តាំងជាមួយគ្នាបានតែ ២ រូប ...៣៨៣

ការផ្លាស់ប្តូរថាវរវត្ថុ និង ថាវរវត្ថុ ............................៣៨៥

ការផ្លាស់ប្តូរដោយថេយ្យចិត្ត ជាបារាជិក.....................៣៨៧

ភិក្ខុយកកុដិមានតម្លៃច្រើន ដូរជាមួយផ្ទះគ្រហស្ថ.........៣៨៨

ការទទួលគ្រែអកប្បិយដែលគេថ្វាយចំពោះវិហារ គួរ...៣៨៨

បាត្រជាដើមដែលជាលហុភណ្ឌ គួរចែកបាន .............៣៩៣

ការប្រើប្រាស់ជារបស់សង្ឃ និងរបស់បុគ្គល.............៣៩៥

វត្ថុជារបស់សេនាសនៈគួរគ្រប់យ៉ាង ........................៣៩៧

ការផ្ទេរកនឹងជញ្ជាំងដែលគេបូកលាប ជាអចិត្តកៈ........៤០៥

ការយកកម្រាលរបស់សង្ឃ មកក្រាលសឹងមិនគួរ ...៤០៦

**២៨-លិង្គនានាសំវាសកកថា** ........................................................៤១០

*ភូមិនៃភិក្ខុមានសំវាសផ្សេងគ្នាមាន ២ យ៉ាង*..............៤១០

*ការធ្វើកម្មជាមួយភិក្ខុដែលផ្សេងគ្នាដោយលិទ្ធិត្រូវទុក្កដ*...៤១២

**២៩-អបលោកនកម្មកថា** ...........................................................៤២២

*អបលោកនកម្មដល់នូវឋាន ៥ យ៉ាង*..........................៤២២

*សីមាដែលត្រូវធ្វើអបលោកនកម្ម*...........................................៤២៥

*មិនត្រូវអបលោកន៍ជាប់ដោយអំណាចសង្ឃទេ*.............៤៣៣

*ការសន្មតភិក្ខុច្រើនអង្គក្នុងទីជាមួយគ្នាតែម្តងក៏បាន*.........៤៣៧

*សេនាសនគ្គាហាបកៈភិក្ខុកាន់យកសេនាសនៈ*

*ដោយខ្លួនឯងមិនគួរទេ*.................៤៣៨

*សង្ឃជួយដោះបំណុលភិក្ខុអ្នកមានសីលដោយអបលោកន៍* ៤៤០

*បាលីអបលោកន៍ចង្អាន់តាមន័យនៅក្នុងអដ្ឋកថាបរិវារៈ*

*ភិក្ខុ ៤ ឬ ៥ រូប ធ្វើអបលោកនកម្ម*.........................៤៤៣

*ភិក្ខុ ១ រូប ធ្វើកតិកា*..................................................៤៤៤

*ភិក្ខុ ២ ឬ ៣ រូប ធ្វើកតិកា*.......................................៤៤៤

*បាលីអបលោកចង្អាន់មួយបែបទៀត* ..........................៤៤៥

*អបលោកនកម្ម វិបត្តិដោយអាការ ៣ យ៉ាង* ............៤៤៦

*ភិក្ខុធ្វើការចែកសប្បិរបស់សង្ឃឱ្យទៅជាបុគ្គល*............៤៤៦

ភិក្ខុធ្វើការចែកចីវរ ......................................................៤៤៧
ភិក្ខុធ្វើការអធិដ្ឋានចីវរជារបស់សង្ឃឱ្យទៅជាបុគ្គល......៤៤៧
ភិក្ខុ១ រូបអាចអធិដ្ឋានចីវររបស់សង្ឃក្នុងចន្លោះស្រុកបាន ៤៤៨
**៣០-អលជ្ជិបុគ្គលកថា** ........................................................៤៥០
អលជ្ជីដោយហេតុ ៣ យ៉ាង........................................៤៥៣
ការធ្វើកម្មជាមួយអលជ្ជី តែមិនត្រូវទោស..................៤៥៦
ប្រើបុគ្គលជាអលជ្ជីឱ្យធ្វើហត្ថកម្មឱ្យមិនគួរ...................៤៥៩
ពាក្យថា ទុស្សសីល និងពាក្យថាអលជ្ជី .................៤៦១
ការបរិភោគ ៤ យ៉ាង ..................................................៤៦៣
ការដឹងថាលោកជាអលជ្ជីហើយមិនគួរបរិភោគជាមួយ ៤៦៦
ភិក្ខុលជ្ជីពោលសរសើរភិក្ខុអលជ្ជីមិនគួរ........................៤៧០

**ៜ ចប់ ៜ**

### នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

# បកិណ្ណកវិនយកថា

## ១~អនាមាសវិនិច្ឆយកថា

*ក្នុងវិនយបិដកភាគ ២ ទំព័រ៨១ ព្រះអង្គត្រាស់ថាៈ*

*សម័យនោះឯងភិក្ខុ ១ រូបចាប់ពាល់មាតា ដោយសេចក្ដីស្រលាញ់មាតា ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យថា អញត្រូវអាបត្តិសង្ឃាទិសេសទេដឹង ។ ទើបក្រាបទូលព្រះមានព្រះ-ភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវសង្ឃាទិសេសទេ ត្រូវត្រឹមអាបត្តិទុក្កដ ។*

*ភិក្ខុចាប់ពាល់ប្អូនស្រី... ។*

*ភិក្ខុចាប់ពាល់កូនស្រី... ។*

*ភិក្ខុចាប់ពាល់តិរច្ឆានញី... ។*

*ភិក្ខុចាប់ពាល់រូបឈើធ្វើជារូបស្រី ។ ភិក្ខុនោះ មានសេចក្ដីសង្ស័យ ។ល ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ អ្នកមិនត្រូវសង្ឃាទិសេសទេ ត្រូវត្រឹមអាបត្តិទុក្កដ ។*

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>

ក្នុងព្រះបាលីនោះ ព្រះមានព្រះភាគពិន័យអាបត្តិទុក្កដដូចគ្នាទាំងអស់ ដល់ភិក្ខុដែលចាប់ពាល់ ដោយសេចក្ដីស្រឡាញ់អាស្រ័យផ្ទះថា "អ្នកនេះជាមាតារបស់យើង នេះជាធីតារបស់យើង នេះជាបងប្អូនស្រីរបស់យើង" ព្រោះដែលឈ្មោះថាមនុស្សស្រីសូម្បីទាំងអស់ ទោះជាមាតាក៏ដោយ ជាធីតាក៏ដោយ ជាសត្រូវដល់ព្រហ្មចរិយៈទាំងអស់ ។ ក៏កាលភិក្ខុរលឹកដល់ព្រះអាជ្ញា របស់ព្រះមានព្រះភាគនេះ បើសូម្បីថាឃើញមាតាត្រូវក្រសែទឹកបន្សាត់ទៅ មិនគួរចាប់ពាល់ដោយដៃឡើយ ។ តែភិក្ខុដែលឆ្លាតគប្បីនាំទូក ឬបន្ទះក្ដារ ឬកំណាត់ដើមចេក ឬកំណាត់ឈើចូលទៅឱ្យ កាលទូកជាដើមនោះមិនមាន សូម្បីសំពត់កាសាវៈ ក៏គួរនាំទៅដាក់ទុកខាងមុខតែមិនគួរពោលថា **"ចូរចាប់ត្រង់នេះ"** ។ កាលមាតាចាប់ហើយគប្បីទាញមក ដោយធ្វើក្នុងចិត្តថា "យើងទាញបរិក្ខារមក" ។ ក៏បើមាតាខ្លាចគប្បីទៅខាងមុខៗ ហើយលួងលោមថា "កុំខ្លាច" បើមាតាត្រូវទឹកបន្សាត់ទៅ ប្រញាប់ឡើង-ក ឬចាប់ត្រង់ដៃរបស់ភិក្ខុដែលជាបុត្រ ភិក្ខុកុំរលាស់ ឬពោលថា "ចៀសចេញទៅស្រីចាស់" ដូច្នេះឡើយ, គប្បីនាំទៅឱ្យដល់លើគោក ។

កាលមាតាជាប់ល្បាប់ភក់ក្តី ធ្លាក់ចុះទៅក្នុងអណ្តូងក្តី ក៏មានន័យដូចគ្នានេះ ។ អធិប្បាយថា ភិក្ខុគប្បីបោះខ្សែ ឬសំពត់ទៅក្នុងភក់ ឬអណ្តូង ដឹងសភាពដែលមាតាយកដៃចាប់ហើយ គប្បីទាញគាត់ឡើង តែកុំគប្បីចាប់ពាល់ឡើយ ។

<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:</u>

★ នទីសោតេន វុយ្ហមានំ មាតរន្តិ ឧក្កដ្ឋបរិច្ឆេទ-ទស្សនត្ថំ វុត្តំ, អញ្ញាសុបិ បន ឥត្ថីសុ ការុញ្ញាធិប្បា-យេន មាតរិ វុត្តនយេន បដិបជ្ជន្តស្ស នេវត្ថិ ទោសោតិ វទន្តិ ។ ពាក្យថា មាតាត្រូវក្រសែទឹកបន្សាត់ទៅ ដូច្នេះ គឺលោកពោលហើយ ដើម្បីសម្តែងការកំណត់យ៉ាងឧក្រិដ្ឋ ។ ក៏អាចារ្យទាំងឡាយពោលថា កាលភិក្ខុបដិបត្តិតាមន័យដែលពោលទុកក្នុងមាតា ដោយសេចក្តីប្រាថ្នាអាណិតករុណា ក្នុងស្ត្រីសូម្បីពួកដទៃ ក៏មិនមានទោសដូចគ្នា ។

"មាតរ"ន្តិ វុត្តត្តា អញ្ញាសំ ន វដ្ដតីតិ វទន្តាបិ អត្ថិ ។ ព្រោះភាវនៃលោកអាចារ្យពោលថា មាតា ដូច្នេះ សូម្បីមនុស្សទាំងឡាយ និយាយថា "មិនគួរដល់ស្រីពួកដទៃ" រមែងមាន ។

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

★ **ឯត្ថ គណ្ហាហីតិ ន វត្តព្វាតិ** គេហសិតបេមេន កាយប្បដិពទ្ធេន ផុសនេ ទុក្កដំ សន្ធាយ វុត្តំ ។ ពាក្យថា មិនគប្បីពោលថា ចូរចាប់ត្រង់នេះ ដូច្នេះ គឺលោកពោលសំដៅយកអាបត្តិទុក្កដ ក្នុងកិរិយាពាល់ត្រូវ ដោយវត្ថុជាប់នឹងកាយ ព្រោះសេចក្តីស្រឡាញ់អាស្រ័យផ្ទះ ។

★ ការុញ្ញេន បន វត្វាធិ គហេតុំ អសក្កោន្តី "គណ្ហា"តិ វទន្តស្សាបិ អវសេសភាវប្បត្តំ ឧទកេ និមុជ្ជន្តី ការុញ្ញេន សហសា អនាមាសន្តិ អចិន្តេត្វា កេសាទីសុ គហេត្វា មោក្ខាធិប្បាយេន អាកឌ្ឍតោបិ អនាបត្តិយេវ ។ តែជាអនាបត្តិពិត ដល់ភិក្ខុសូម្បីពោលទៅកាន់មាតា កាលមិនអាចដើម្បីចាប់នូវសំពត់ជាដើម ដោយសេចក្តីករុណាថា "អ្នកចូរចាប់" ដូច្នេះ និងជាអនាបត្តិដល់ភិក្ខុ កាលមិនបានគិតថាជាអនាមាស ហើយចាប់ត្រង់សក់ទាំងឡាយជាដើម ដោយរហ័ស ព្រោះសេចក្តីករុណានូវមាតាដែលដល់នូវសភាវមិនមានអំណាចលិចចុះទៅក្នុងទឹក ហើយទាញមក ដោយបំណងឱ្យរួច ។

★ ន ហិ មីយមានំ មាតរំ ឧក្ខិបិតុំ ន វដ្តតិ ។

អញ្ញាតិកាយ ឥត្ថិយាបិ ឯសេវ នយោ ។ ឧក្កដ្ឋាយ មាតុយាបិ អាមាសោ ន វដ្ដតីតិ ឥទម្បនេត្ថ "មាតរ"ន្តិ វុត្តំ ។ ពិតមែន ភិក្ខុមិនគួរដើម្បីលើកមាតា ដែលកំពុងដល់សេចក្ដីស្លាប់ ក៏ទេដែរ ។ ន័យសូម្បីក្នុងពួកស្រីដទៃ ក៏មានន័យនេះដូចគ្នា ។ លោកអាចារ្យពោលថា "មាតា" ដូច្នេះ ដើម្បីសម្ដែងថា អាមាសវត្ថុ គឺវត្ថុដែលគួរប៉ះ សូម្បីដល់ចំពោះមាតាដោយឧក្រិដ្ឋ ក៏មិនគួរដែរ ។

### អធិប្បាយវត្ថុដែលជាអនាមាស

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា</u> :

☆ មិនមែនតែរាងកាយរបស់មាតុគ្រាមតែម៉្យាងប៉ុណ្ណោះទេ, ដែលជាអនាមាស សូម្បីសំពត់ស្លៀកនិងសំពត់ដណ្ដប់ក្ដី វត្ថុជាគ្រឿងប្រដាប់ក្ដី ដោយហោចទៅ សូម្បីកម្រងស្មៅក៏ដោយ ចិញ្ចៀនស្លឹកត្នោតក៏ដោយ ក៏ជាអនាមាសទាំងអស់ ។ ក៏ឯសំពត់ស្លៀក និងសំពត់ដណ្ដប់នោះ តាំងទុកដើម្បីត្រូវការប្រើជាគ្រឿងប្រដាប់ប៉ុណ្ណោះ ។ ក៏ប្រសិន បើមាតុគ្រាមដាក់សំពត់ស្លៀក **ឬសំពត់ដណ្ដប់ទុកក្នុងទីជិតជើង** ដើម្បីត្រូវការឱ្យផ្លាស់ប្ដូរជាចីវរ សំពត់នោះ សមគួរ ។ ក៏បណ្ដាគ្រឿងប្រដាប់

ភណ្ឌៈដែលជាកប្បិយ មានគ្រឿងប្រដាប់សីសៈជាដើម ដែលមាតុគ្រាមប្រគេនថា “លោកម្ចាស់ សូមលោកម្ចាស់មេត្តាទទួលវត្ថុនេះចុះ” ភិក្ខុគួរទទួលទុក ដើម្បីជាគ្រឿងប្រើប្រាស់ មានស្រោមកាំបិតកោរនិងម្ជុលជាដើម ។ ចំណែកភណ្ឌៈដែលធ្វើដោយមាសប្រាក់ និងកែវមុក្តាជាដើម ជាអនាមាសពិត, សូម្បីគេប្រគេនក៏មិនគួរទទួល ។ មួយទៀត មិនមែនតែគ្រឿងប្រដាប់ដែលតាក់តែងរាងកាយ របស់ស្រីទាំងនោះ តែម្យ៉ាងប៉ុណ្ណោះទេ ដែលជាអនាមាស ។ សូម្បីជារូបឈើក្តី រូបភ្លុកក្តី រូបដែកក្តី រូបលោហៈក្តី រូបសំណក្តី **រូបគំនូរក្តី** (រូបថតក្តី) រូបដែលសម្រេចដោយរតនៈគ្រប់យ៉ាងក្តី **ដែលគេធ្វើសណ្ឋាននៃស្រី** ដោយហោចទៅ សូម្បីរូបដែលសូនដោយម្សៅ ក៏ជាអនាមាសទាំងអស់ ។ តែបើភិក្ខុបានរបស់ដែលគេប្រគេនថា “វត្ថុនេះចូរជារបស់លោកម្ចាស់” វៀររបស់ដែលសម្រេចដោយរតនៈគ្រប់យ៉ាង **ទម្លាយរូបដ៏សេស** បង្អោនយកវត្ថុដែលគួរជាគ្រឿងឧបករណ៍ ចូលក្នុងគ្រឿងឧបករណ៍ និងវត្ថុដែលគួរប្រើប្រាស់ ចូលក្នុងរបស់សម្រាប់ប្រើប្រាស់ ដើម្បីប្រយោជន៍ដល់ការប្រើប្រាស់ គួរ ។

*<u>ក្នុងគម្ពីរសារត្ថទីបនី និងវិមតិវិនោទនីដីកា ពោលថាៈ</u>*

☆ **បរិវត្តេត្វាតិ** អត្តនោ និវាសនបារុបនភាវតោ អបនេត្វា, ចីវរត្ថាយ អបនាមេត្វាតិ វុត្តំ ហោតិ ។ **ចីវរត្ថាយ ធាទមូលេ ឋបេតិ វដ្ដតីតិ** ឥទំ និទស្សនមត្តំ បច្ចត្ថរណវិតានានិ អត្ថម្បិ វដ្ដតិយេវ, បូជានិ អត្តំ តាវ-កាលិកម្បិ គហេតុំ វដ្ដតិ ។ *ពាក្យថា* ***ឱ្យផ្លាស់ប្តូរ*** *ដូច្នេះ លោកពោលថា គឺនាំចេញចាកអំពីភាពជាគ្រឿងស្លៀកដណ្តប់របស់ខ្លួន, ហើយបង្អោនចូលទៅដើម្បីប្រយោជន៍ជាចីវរ ។*

*ពាក្យថា ទុកក្នុងទីជិតជើងដើម្បីប្រយោជន៍ជាចីវរគួរ ដូច្នេះ ពាក្យនេះ ត្រឹមតែជានិទស្សនៈប៉ុណ្ណោះ, សូម្បីប្រយោជន៍មានកម្រាល និងពិដានជាដើម ក៏គួរពិត ។ ភិក្ខុគួរដើម្បីកាន់យក (ឬដើម្បីប៉ះពាល់)នូវសម្ពត់សូម្បីជារបស់ខ្ចីដើម្បីបូជាជាដើមបាន ។*

*<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថាៈ</u>*

☆ **ឥត្ថិសណ្ឋានេន កតន្តិ** ឯត្ថ ហេដ្ឋិមបរិច្ឆេទតោ ធាភជិករត្តុភូតតិរច្ឆានគតិត្ថីនម្បិ អនាមាសភាវតោ តា-ទិសំ ឥត្ថិសណ្ឋានេន កតំ តិរច្ឆានគតរូបម្បិ អនាមាសន្តិ ទដ្ឋព្វំ ។ *ក្នុងពាក្យថា ដែលគេធ្វើសណ្ឋាននៃស្រី ដូច្នេះ*

មានសេចក្ដីថា សូម្បីរូបសត្វតិរច្ឆានញីដែលគេធ្វើហើយ ដោយសណ្ឋាននៃស្រីមានសភាពដូច្នោះ បណ្ឌិតគប្បីជ្រាបថា ជាវត្ថុអនាមាស ព្រោះភាពជាអនាមាស សូម្បីដល់សត្វតិរច្ឆានញីដែលជាវត្ថុនាំឱ្យកើតអាបត្តិបារាជិក ដោយការកំណត់យ៉ាងទាប ។

★ **ភិក្ខុនិត្ថាតិ** ឯត្ថ ហត្ថេន អគ្គហេត្វាវ កេនចិ ទេវ ទណ្ឌាទិនា ភិន្ទិតព្វំ ។ ឯត្ថ ច "អនាមាសម្បិ ហត្ថេន អបរាមសិត្វា ទណ្ឌាទិនា កេនចិ ភិន្ទិតុំ វដ្ដតី"តិ ឥធ វុត្តត្តា "បំសុកូលំ គណ្ហន្តេន មាតុគាមសរីរេបិ សត្ថាទីហិ វណំ កត្វា គហេតព្វន្តិ វុត្តត្តា ច គហិតមណ្ឌូកសប្បិនីទណ្ឌាទីហិ និប្បីឡេត្វា មណ្ឌូកំ វិស្សជ្ជាបេតុំ វដ្ដតិ ។

ពាក្យថា ទម្លាយ ដូច្នេះ មានសេចក្ដីថា ភិក្ខុមិនគប្បីកាន់យកដោយដៃទេ, ហើយគប្បីទម្លាយដោយវត្ថុណាមួយ មានដំបងជាដើម ។ ក៏ក្នុងពាក្យនេះមានសេចក្ដីថា កាលដែលភិក្ខុបៀតបៀនទូវសត្វពស់ញីដែលចាប់កង្កែប ហើយឱ្យលែងសត្វកង្កែប រមែងគួរ ព្រោះលោកពោលទុកក្នុងទីនេះថា "ភិក្ខុមិនប៉ះពាល់សូម្បីនូវវត្ថុអនាមាសដោយដៃ, ហើយគប្បីទម្លាយដោយវត្ថុណាមួយ មានដំបងជាដើម រមែងគួរ" និងព្រោះលោកពោលថា ភិក្ខុកាលកាន់យកសម្ពត់បង្សុកូល ត្រូវធ្វើសូម្បីនូវសរីរៈរបស់

មាតុគ្រាម ឱ្យជាជំពៅដោយសស្ត្រាជាដើម ហើយសិនសឹមកាន់យក" ។

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា :</u>

★ **ពោត្ថករូបន្តិ** សុធាទីហិ កតំ, ធាភជិក-វត្ថុភូតានំ តិរច្ឆានគតិត្ថីនំ សណ្ឋានេន កតម្បិ អនា-មាសមេវ ។ ពាក្យថា *រូបគំនូរ* ដូច្នេះ គឺបានដល់ រូបគំនូរដែលគេធ្វើដោយបាយអរជាដើម, សូម្បីរូបគំនូរដែលគេធ្វើហើយដោយសណ្ឋាននៃសត្វតិរច្ឆានញី ដែលជាវត្ថុនាំឱ្យកើតអាបត្តិបារាជិក, ជាអនាមាសពិត ។

<u>ក្នុងគម្ពីរវិមតិវិនោទនី និងសារត្ថទីបនីដីកា ពោលថា:</u>

★ ឥត្ថិរូបាទីនិ ឧស្សេត្វា កតំ វត្ថភិត្តិអាទិញ្ច ឥត្ថិរូបំ អនាមសិត្វា វឡញ្ជេតុំ វដ្ដតិ ។ ក៏វត្ថុមានសំពត់និងជញ្ជាំងជាដើម ដែលគេធ្វើបង្ហាញនូវរូបស្រីជាដើម ភិក្ខុមិនប៉ះនូវរូបចំឡាក់ស្រី ហើយប្រើប្រាស់ គួរ ។

## អនាមាសវត្ថុប៉ះដោយវត្ថុជាប់ដោយកាយគួរ

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

ឯវរូបេហិ អនាមាសេ កាយសំសគ្គរាគេ អសតិ

កាយប្បដិពទ្ធេន អាមសតោ ទោសោ នត្ថិ ។ កាលបើកាយសំសគ្គរាគៈ ក្នុងវត្ថុអនាមាស មិនមានដោយវត្ថុមានសភាពយ៉ាងនេះ ទោសរមែងមិនមាន ដល់ភិក្ខុកាលស្ទាបអង្អែលដោយវត្ថុជាប់ដោយកាយ ។

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថាៈ</u>

មួយទៀត សូម្បីធញ្ញជាតិ ៧ ប្រភេទ ក៏ជាអនាមាសដូចគ្នា នឹងរូបស្ត្រី ដូច្នោះ ។ ព្រោះដូច្នោះ កាលដើរទៅតាមវាលស្រែ កុំដើរបាច់ពាល់គ្រាប់ធញ្ញជាតិ សូម្បីដែលកើតនៅក្នុងវាលស្រែ នោះទៅបណ្តើរ ។ បើមានធញ្ញជាតិ ដែលគេហាលទុកក្បែរទ្វារផ្ទះ ឬក្បែរផ្លូវ និងផ្នែកខាងៗ (បើ)មានផ្លូវដើរកុំដើរជាន់ ។ កាលផ្លូវដើរមិនមាន **គប្បីអធិដ្ឋានឱ្យជាផ្លូវហើយ** ដើរទៅចុះ ។ **មនុស្សទាំងឡាយ ក្រាលអាសនៈប្រគេន** លើគំនរធញ្ញជាតិ ក្នុងផ្ទះនឹងអង្គុយក៏គួរ ។ ជនពួកខ្លះ ចាក់ធញ្ញជាតិគរទុកក្នុងរោងឆាន់ បើអាចនឹងឱ្យនាំចេញបាន ក៏គប្បីឱ្យនាំចេញ បើមិនអាចកុំជាន់ធញ្ញជាតិ គប្បីដាក់នូវតាំងក្នុងទីមួយ ហើយអង្គុយចុះ ។ បើមិនមានឱកាស ពួកអ្នកស្រុកក្រាលអាសនៈប្រគេននៅលើគំនរធញ្ញជាតិនុ៎ះឯង គប្បីអង្គុយចុះ ។ សូម្បីក្នុងធញ្ញជាតិ ដែលនៅលើទូក ក៏មានន័យយ៉ាងនេះដូចគ្នា ។

សូម្បីអបរណ្ណជាតិ មានសណ្តែកបាយ និងសណ្តែករាជមាស ជាដើមក្តី ផ្លែឈើមានត្នោត និងខ្នុរជាដើមក្តី **ដែលកើតក្នុងទីនោះ ភិក្ខុមិនគួរចាប់លេង** ។ សូម្បីក្នុងអបរណ្ណជាតិ និងផ្លែឈើ ដែលអ្នកស្រុកប្រមូលជាគំនរទុក ក៏មានន័យនេះដូចគ្នា ។ តែការដែលភិក្ខុកាន់យកផ្លែឈើដែលជ្រុះអំពីដើម ក្នុងព្រៃដោយតាំងចិត្តថា **"នឹងឱ្យដល់ពួកអនុបសម្បន្ន"** គួរ ។

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

★ **មគ្គំ អធិដ្ឋាយាតិ** "មគ្គោ អយ"ន្តិ មគ្គសញ្ញំ ឧប្បាទេត្វាតិ អត្ថោ ។ ពាក្យថា **គប្បីអធិដ្ឋានឱ្យជាផ្លូវ** ដូច្នេះ មានសេចក្តីអធិប្បាយថា ភិក្ខុញុំាងសញ្ញាថាជាផ្លូវ ឱ្យកើតឡើងថា "នេះជាផ្លូវ" ។

★ **បញ្ញបេត្វា ទេន្តីតិ** ឥទំ សាមីចិវសេន វុត្តំ, គេហិ បន អាសនំ អបញ្ញបេត្វាវ និសីទថាតិ វុត្តេ សយមេវ បញ្ញបេត្វា និសីទិតុម្បិ វដ្ដតិ ។ **តត្ថ ជាតកានីតិ** អច្ឆិន្ទិត្វា ភូតគាមភាវេនេវ ឋិតានិ ។ ពាក្យថា **មនុស្សទាំងឡាយ ក្រាលអាសនៈប្រគេន** ដូច្នេះ ពាក្យនេះលោកពោលហើយ ដោយអំណាចសាមីចិកម្ម, តែបើមនុស្សទាំងឡាយ មិន

ក្រាលអាសនៈឱ្យសោះ ហើយនិមន្តថា សូមលោកម្ចាស់អង្គុយ ភិក្ខុគួរដើម្បីក្រាលដោយខ្លួនឯងប៉ុណ្ណោះ ហើយសឹមអង្គុយ ។

ពាក្យថា **កើតក្នុងទីនោះ** ដូច្នេះ បានសេចក្តីថា គេមិនបានកាត់ទេ, ហើយតាំងនៅដោយភាពជាភូតគាមប៉ុណ្ណោះ ។

**វត្ថុជារបស់ភិក្ខុដែលគួរដល់ការបរិភោគ មិនគួរដើម្បីប៉ះ**

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

☆ **កាឡន្តេណាតិ** វុត្តត្តា សតិ បច្ចយេ អាមសន្តស្ស អនាបត្តិ ។ ភិក្ខុសន្តកំ បន បរិភោគារហំ សព្វថា អាមសិតុំ ន វដ្ដតិ ទុរុបចិណ្ណត្តា ។ កាលបើមានហេតុជាអនាបត្តិ ដល់ភិក្ខុកាលពាល់ត្រូវ ព្រោះលោកពោលថា ដោយការលេង ដូច្នេះ ។ តែវត្ថុជារបស់ភិក្ខុ ដែលគួរដល់ការបរិភោគ មិនគួរដើម្បីប៉ះដោយប្រការទាំងពួង ព្រោះជាវត្ថុទុរុបចិណ្ណៈ (ការសន្សំអាក្រក់) ។

<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:</u>

☆ **កាឡន្តេណាតិ** ឥធំ គិហិសន្តកំ សន្ធាយ វុត្តំ ភិក្ខុសន្តកំ បន យេន កេនចិ អធិប្បាយេន អនាម-

សិតព្វមេវ ទុរុបចិណ្ណភាវតោ ។ ពាក្យថា ដោយការចាប់លេង ដូច្នេះ ពាក្យនេះ គឺលោកពោលសំដៅយកវត្ថុ ដែលជារបស់គ្រហស្ថ, តែចំពោះវត្ថុរបស់ភិក្ខុវិញ គឺមិនគប្បីចាប់ពាល់ទេ ទោះបីដោយបំណងយ៉ាងណាមួយក៏ដោយ ព្រោះភាពជាទុរុ-បចិណ្ណៈ (ការសន្សំអាក្រក់) ។

## ផ្លែឈើមិនគួរប៉ះពាល់

| | | | |
|---|---|---|---|
| ១-តាល | ផ្លែត្នោត | ៦-អលាតុ | ផ្លែឃ្លោក |
| ២-បនស | ផ្លែខ្នុរ | ៧-កុម្ភណ្ឌ | ផ្លែល្ពៅ |
| ៣-នាឡិកេរ | ផ្លែដូង | ៨-បុស្សផល | ផ្លែឪឡឹក |
| ៤-លពុជ | ផ្លែខ្នុរសម្ល | ៩-ឯឡាលុក | ផ្លែត្រឡាច |
| ៥-តិបុស | ផ្លែត្រសក់ | | |

★ យថាវុត្តជលានំយេវ ចេត្ថ កីឡាធិប្បាយេន អាមសនំ ន វដ្តតីតិ វុត្តត្តា ធាសាណសក្ខរាទីនិ កីឡា-ធិប្បាយេនបិ អាមសិតុំ **ន វដ្តតិ** ។ ក៏ក្នុងទីនេះ ព្រោះលោកពោលថា "ការប៉ះពាល់ផ្លែឈើទាំងឡាយ តាមដែលពោលហើយប៉ុណ្ណោះ ដោយបំណងលេង រមែងមិនគួរ" ដូច្នេះ ភិក្ខុមិនគួរប៉ះពាល់នូវវត្ថុទាំងឡាយ មានថ្ម និងគ្រួសជាដើម សូម្បីដោយបំណងលេងទេ ។ (តែច្បាប់ភូមាពោលថា វដ្តតិ : គួរ)

*កុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:*

★ **អនុបសម្បន្នានំ ទស្សាមីតិ** ឥទំ អប្បដិគ្គហេត្វា គហណំ សន្ធាយ វុត្តំ ។ អត្តនោបិ អត្ថាយបដិគ្គហេត្វា គហណេ ទោសោ នត្ថិ អនាមាសត្តាភាវា ។

*ពាក្យថា អញនឹងឱ្យដល់អនុបសម្បន្ន ដូច្នេះ គឺលោកពោលសំដៅយកនូវកិរិយាដែលភិក្ខុមិនទទួលប្រគេន ហើយកាន់យកទៅ ។ ទោស រមែងមិនមាន(ដល់ភិក្ខុ) ក្នុងការទទួលដើម្បីប្រយោជន៍ សូម្បីដល់ខ្លួនហើយកាន់យកទៅ ព្រោះភាវនៃផ្លែឈើនោះ មិនមែនជាវត្ថុអនាមាស ។*

*តែក្នុងគម្ពីរវិនយវិនិច្ឆយ ពោលថា:*

★ តត្ថជាតផលំ ខជ្ជំ, មុគ្គាទី តត្ថជាតកំ, ធញ្ញានិ បន សព្វានិ, អាមសន្តស្ស ទុក្កដំ ។ *ជាអាបត្តិទុក្កដដល់ភិក្ខុកាលពាល់ត្រូវនូវផ្លែឈើ ដែលបុគ្គលគប្បីទំពា ដែលកើតនៅក្នុងទីនោះផង, សណ្ដែកបាយជាដើម ដែលកើតក្នុងទីនោះផង, និងធញ្ញជាតិទាំងអស់ផង ។*

<u>*ក្នុងគម្ពីរវិនយវិនិច្ឆយដីកា ពន្យល់ថា:*</u>

✯ **ឥត្តជាតផលំ ខជ្ជន្តិ** រុក្ខេ ឋិតំ ខាទិតព្វំ បនសនាឡិកេរាទិផលញ្ច មនុស្សេហិ រាសិកតំ បរិ-កុញ្ជិតព្វផលញ្ច"មនុស្សេហិ រាសិកតេសុបិ ឯសេវ នយោ"-តិ អដ្ឋកថាយំ វុត្តត្តា អនាមាសន្តិ ឧបលក្ខណតោ ឥមិនាវ គហេតព្វំ ។ អរញ្ញេ រុក្ខតោ បតិតំ ផលំ "អនុបសម្បន្នស្ស ទស្សាមី"តិ គហេតុំ វដ្ដតិ ។

*ពាក្យថា **នូវផ្លែឈើដែលបុគ្គលគប្បីទំពារ ដែលកើតនៅក្នុងទីនោះ** ដូច្នេះនេះ មានសេចក្ដីថា ក៏ផ្លែឈើមានផ្លែខ្នុរ ដូងជាដើម ដែលបុគ្គលគប្បីទំពា ដែលតាំងនៅលើដើមឈើផង និងផ្លែឈើដែលគប្បីឆាន់ ដែលមនុស្សទាំងឡាយ ធ្វើឱ្យជាគំនរផង, បណ្ឌិតគប្បីកាន់យកពាក្យនេះឯង ដោយឧបលក្ខណន័យ **ថាជាវត្ថុអនាមាស** ដូច្នេះ ព្រោះលោកពោលទុកក្នុងអដ្ឋកថា ថា "សូម្បីផ្លែឈើដែលមនុស្សទាំងឡាយ ធ្វើឱ្យជាគំនរទុក ក៏មានន័យនេះដូចគ្នា" ។ តែផ្លែឈើដែលធ្លាក់អំពីដើមឈើ នៅក្នុងព្រៃ ភិក្ខុកាន់យកដោយគិតថា "យើងនឹងឱ្យដល់អនុបសម្បន្ន" ដូច្នេះ រមែងគួរ ។*

## សេចក្តីផ្សេងគ្នានៃទុរូបចិណ្ណ និងអនាមាស

★ ភិក្ខុពាល់ត្រូវគនៈ ១០ ប្រការ, ស្រូវ ៧ ប្រការ រូបដែលធ្វើជាមនុស្សស្រី ឬតិរច្ឆានញី និងគ្រឿងអាវុធជាដើម ឈ្មោះថា **អនាមាសទុក្កដ** ។

★ ទុក្កដដែលព្រះអដ្ឋគ្រាស់ប្រាប់ ដល់ភិក្ខុដែលពាល់ត្រូវផ្លែឈើទាំងឡាយ ដែលកើតនៅក្នុងទីនោះ មានផ្លែចេក ផ្លែខ្នុរ ជាដើម ឈ្មោះថា ទុរូបចិណ្ណៈទុក្កដ ។ (អដ្ឋកថាបារាជិក)

## ការប៉ះពាល់សាច់ឆៅ ត្រីឆៅ និងស្រូវ មិនគួរ

<u>ក្នុងអដ្ឋកថា ព្រហ្មជាលសូត្រពោលថា:</u>

★ **អាមកធញ្ញបដិគ្គហណាតិ** សាលិវីហិយវគោធូម-កង្គុវរកកុទ្រូសកសង្ខាតស្ស សត្តវិធស្សាបិ អាមកធញ្ញ-ស្ស,បដិគ្គហណា ។ ន កេវលញ្ច ឯតេសំ បដិគ្គហណមេវ **អាមសនម្បិ ភិក្ខូនំ ន វដ្តតិយេវ** ។

ពាក្យថា ទទួលនូវធញ្ញជាតិស្រស់ ដូច្នេះ មានសេចក្តីថា ត្រូវវៀរចាកការទទួលនូវស្រូវស្រស់សូម្បីទាំង ៧ ប្រការ ពោលគឺ ស្រូវសាលី, ស្រូវខ្សាយ, ស្រូវដំណើប, ស្រងែ ថ្គាំ, ស្គួយ, និងស្មៅគែលលក ។ មិនមែនការទទួលតែម្យ៉ាងទេ ដែលមិនគួរដល់ភិក្ខុទាំងឡាយនោះ, **សូម្បីតែប៉ះពាល់ក៏មិនគួរ**

*ដល់ភិក្ខុទាំងឡាយដែរ ។*

★ **អាមកមំសបដិគ្គហណាតិ** ឯត្ថ អញ្ញត្រ ឱទិស្ស អនុញ្ញាតា អាមកមំសមច្ឆានំ បដិគ្គហណមេវ ភិក្ខូនំ ន វដ្ដតិ, នោ អាមសនំ ។

*ពាក្យថា **ទទួលនូវសាច់ឆៅ** ដូច្នេះ មានសេចក្ដីថា ការទទួលសាច់ឆៅ និងត្រីឆៅ រមែងមិនគួរដល់ភិក្ខុទាំងឡាយ, ការប៉ះពាល់ក៏មិនគួរដល់ភិក្ខុទាំងឡាយ, វៀរលែងតែការដែលទ្រង់អនុញ្ញាតទុកចំពោះ ។*

*<u>ក្នុងដីកាព្រហ្មជាលសូត្រ ពោលថា:</u>*

★ *ក្នុងពាក្យថា **ការទទួល** ដូច្នេះ បានដល់ ការទទួល ៣ ប្រការ គឺដោយកាយ១, ដោយវាចា១, ដោយចិត្ត១ ។ ការទទួលនេះ មានន័យដូចក្នុងការទទួលនូវមាស និងប្រាក់ដែរ ។*

### រតនៈ ១០ ប្រការ

*<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>*

*បណ្ដារតនៈ ១០ ប្រការទាំងនេះ គឺ មុត្តា មណី ពិទូរ្យ ស័ង្ខ (ស័ង្ខដែលកើតនៅក្នុងសមុទ្រ) សិលា (សិលាពណ៌ខ្មៅជាដើម) ប្រវាឡ ប្រាក់ មាស ទទឹម (មណីក្រហម) មរកត, មុត្តា តាមធម្មជាតិមិនទាន់បានច្នៃ និងបោះ ភិក្ខុចាប់ពាល់*

បាន ។ អាចារ្យពួកខ្លះពោលថា រតនៈដ៏សេស ជាអនាមាស តែក្នុងមហាបច្ចរីលោកពោលថា មុក្តា ដែលច្នៃហើយក្តី ដែល មិនទាន់ច្នៃក្តី ជាអនាមាស, និងភិក្ខុទទួលដើម្បីប្រយោជន៍ជាមូល-តម្លៃនៃវត្ថុ រមែងមិនគួរ, តែទទួលដើម្បីជាថ្នាំដល់អ្នកកើតរោគឃ្លង់ (ជាដើម) រមែងគួរ ។

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

★ យាវ បន តា មុត្តា រតនរូបេន តិដ្ឋន្តិ, តាវ អាមសិតុំ ន វដ្ដតិ ឯវ ។ ឯវំ អញ្ញម្បិ រតនបាសាណំ បិសិត្វា ភេសជ្ជេ យោជនត្ថាយ គហេតុំ វដ្ដតិ ឯវ ជាតរូបរជតំ បន បិសិត្វា យោជនភេសជ្ជត្ថាយបិ សម្ប-ដិច្ឆិតុំ ន វដ្ដតិ ។ គហដ្ឋេហិ យោជេត្វា ទិន្នម្បិ យទិ ភេសជ្ជេ សុវណ្ណាទិរូបេន តិដ្ឋតិ ។ វិយោជេតុញ្ច សក្កា តាទិសំ ភេសជ្ជម្បិ ន វដ្ដតិ ។ តំ អព្វោហារិកត្តំ គតំ ចេ វដ្ដតិ ។ តែបើកែវមុក្តានោះ ឋិតនៅជារូបរតនៈដ៏រាបណា ភិក្ខុ មិនគួរប៉ះពាល់ដ៏រាបនោះឯង ។ កាលដែលភិក្ខុកិនទូវប្ញរតនៈ សូម្បីដទៃយ៉ាងនេះ ហើយកាន់យកដើម្បីប្រកប ក្នុងភេសជ្ជៈ រមែងគួរពិត ។ តែកាលដែលភិក្ខុកិនទូវមាស និង ប្រាក់ហើយ ទទួលយក សូម្បីដើម្បីប្រយោជន៍ប្រកបក្នុងភេសជ្ជៈ រមែងមិនគួរ ។

ប្រសិនបើសម្បីគ្រហស្ថ គេប្រកបផ្សំហើយថ្វាយ រមែងតាំងនៅដោយរូបមានមាសជាដើមក្នុងភេសជ្ជៈ ។ ភិក្ខុអាចដើម្បីមិនប្រកបបាន, សូម្បីភេសជ្ជៈមានសភាពដូច្នោះ ក៏មិនគួរ ។ តែបើមាសនិងប្រាក់នោះ ដល់ហើយនូវភាពជាអព្វោហារិក រមែងគួរ ។

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>

មណីប្រភេទពណ៌ខៀវ និងលឿងជាដើម សូម្បីទាំងអស់ ដោយហោចទៅសូម្បីកែវផលិកធម្មជាតិ ដែលគេខាត់ ច្នៃ និងក្រឡឹង ហើយជាអនាមាស ។ តែមណីតាមធម្មជាតិ ផុតអំពីអណ្តូង លោកពោលថា ភិក្ខុនឹងទទួលយកទុក ដើម្បីជាមូលតម្លៃនៃវត្ថុមានបាត្រជាដើម គួរ (ការប៉ះពាល់ក៏គួរ) ។ សូម្បីមណីនោះ លោកហាមទុកក្នុងមហាបច្ចរី ។ កញ្ចក់កែវ ដែលគេស្លធ្វើទុកតែម៉្យាងប៉ុណ្ណោះ លោកពោលថា គួរ ។ សូម្បីក្នុងពិទូរ្យ ក៏មានវិនិច្ឆ័យដូចគ្នា និងកែវមណី ។ ស័ង្ខ នឹងជាស័ង្ខសម្រាប់ផ្លុំក្តី ដែលគេខាត់ និងច្នៃហើយក្តី ប្រដាប់ដោយរតនៈ (ស្រេះដោយរតនៈ) ក្តី ជាអនាមាស ។ ស័ង្ខសម្រាប់ដួសទឹកផឹក ដែលខាត់ហើយក្តី មិនទាន់បានខាត់ក្តី ជារបស់គួរចាប់ពាល់បានពិត ។ មួយទៀត ស័ង្ខដ៏សេស (វៀរលែងតែស័ង្ខ ដែលលាយដោយរតនៈចេញ) ភិក្ខុទទួលទុកដើម្បីប្រើជាថ្នាំបន្តក់ភ្នែកជាដើមក្តី ដើម្បីជា

មូលតម្លៃនៃវត្ថុក្តី គួរ ។ សិលាដែលខាត់ និងច្នៃហើយ ប្រដាប់ដោយរតនៈ មានពណ៌ដូចសណ្តែកបាយប៉ុណ្ណោះ ជាអនាមាស ។ សិលាដ៏សេស ភិក្ខុកាន់យកមកដើម្បីប្រើជាថ្ម សំលៀងកាំបិតជាដើម ក៏បាន ។

កែវប្រវាឡដែលខាត់និងច្នៃហើយ ជាអនាមាស ។ កែវប្រវាឡដ៏សេសជាអាមាស(គួរចាប់ពាល់បាន) និងភិក្ខុទទួលទុកដើម្បីចាយវាយជាមូលតម្លៃនៃវត្ថុ គួរ ។ តែក្នុងមហាបច្ចរីពោលថា កែវប្រវាឡដែលខាត់ហើយក៏ដោយ មិនបានខាត់ក៏ដោយ ជាអនាមាសទាំងអស់ នឹងទទួលទុក មិនសមគួរ ។ មាសនិងប្រាក់ សូម្បីគេធ្វើជារូបពណ៌គ្រប់វត្ថុគ្រប់យ៉ាង ជាអនាមាស និងជារបស់មិនគួរទទួលទុក ចាប់ផ្តើមតាំងពីនៅជារ៉ែ ។ បានឮថា ឧត្តរាជឱរសឱ្យសាងព្រះចេតិយមាស បញ្ជូនទៅប្រគេនព្រះមហាបទុមត្ថេរ ។ ព្រះថេរៈហាមថា មិនគួរ ។ ផ្កាឈូកមាស និងផ្កាយមាសជាដើម មាននៅត្រង់ទីលានព្រះចេតិយ, សូម្បីវត្ថុទាំងនោះក៏ជាអនាមាស, តែពួកភិក្ខុដែលទំនុកបម្រុងព្រះចេតិយ តាំងនៅក្នុងឋានៈ ជាអ្នកបោលរូបិយៈ ព្រោះហេតុនោះ លោកទើបពោលថា ភិក្ខុទាំងនោះ នឹងស្ទាបអង្អែលមើលក៏គួរ ។ តែពាក្យនោះ លោកហាមទុកក្នុងកុរុន្ទី ។

*លោកអនុញ្ញាតត្រឹមតែប៉ុណ្ណោះថា នឹងសម្អាតសំបុកពីងពាងលើព្រះចេតិយមាសគួរ ។*

*ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:*

☆ **សុវណ្ណចេតិយន្តិ** ធាតុករណ្ឌកំ ។ **បដិក្ខិបីតិ** "ធាតុដ្ឋបនត្ថាយ, គណ្ហថា"តិ អវត្វា "តុម្ហាកំ គណ្ហថា"តិ បេសិតត្តា បដិក្ខិបិ ។ *ពាក្យថា* **ចេតិយមាស** *បានដល់ ព្រះកោដ្ឋសម្រាប់តម្កល់ព្រះសារីរិកធាតុ ។*

*ពាក្យថា* ***ហាម*** *បានដល់ ការហាម ព្រោះគេមិនបានពោលថា "លោកម្ចាស់ចូរទទួលទុក ដើម្បីប្រយោជន៍ដល់ការតម្កល់ទុកនូវព្រះសារីរិកធាតុ" តែគេពោលថា ចូរទទួលទុកសម្រាប់លោកម្ចាស់ ។*

*ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:*

☆ **ថេរោ ន កប្បតីតិ** "តុម្ហាកំ បេសិត"ន្តិ វុត្តត្តា ។ "ចេតិយស្ស បូជំ ករោថា"តិ វុត្តេ វដ្ដតិ កិរ ។ *ពាក្យថា* ***ព្រះថេរៈពោលថា មិនគួរ*** *ដូច្នេះនេះ មានសេចក្ដីថា ព្រោះភាវនៃព្រះកោដ្ឋមាស គឺគេបញ្ជូនទៅដើម្បីលោក ។ បានឮថា កាលបើគេពោលថា "សូមលោកម្ចាស់ធ្វើការបូជាព្រះចេតិយ" ដូច្នេះ រមែងគួរ ។*

ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:

★ **បដិក្ខិបតីតិ** សុវណ្ណមយធាតុករណ្ឌកស្ស, ពុទ្ធរូ-
បាទិស្ស ច អត្តនោ សន្តកករណោ និស្សគ្គិយត្តា វុត្តំ ។

ពាក្យថា ហាម ដូច្នេះ គឺលោកពោលហើយព្រោះភាវៈនៃ
ព្រះកោដ្ឋតម្កល់ព្រះធាតុ សម្រេចពីមាសផង ព្រោះព្រះពុទ្ធរូប
ជាដើមផង ជាវត្ថុនិស្សគ្គិយ ដែលគេធ្វើឱ្យជារបស់នៃខ្លួន ។

★ "រូបិយឆឌ្ឌកដ្ឋានេ"តិ វុត្តត្តា រូបិយឆឌ្ឌកស្ស
ជាតរូបរជតំ អាមសិត្វា ឆឌ្ឌេតុំ វដ្ដតីតិ សិទ្ធំ ។
ព្រោះភាវនៃពាក្យដែលលោកអាចារ្យពោលថា ក្នុងឋានៈជា
អ្នកចោលរូបិយ ដូច្នេះ លោកសម្រេចថា ភិក្ខុអ្នកចោលរូបិយ
គួរដើម្បីនឹងប៉ះពាល់នូវមាស និងប្រាក់ហើយចោលបាន ។

## ភិក្ខុអ្នកទំនុកបម្រុងព្រះចេតិយ គួរប៉ះវត្ថុអនាមាសបាន

ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:

★ **កចវរមេវ ហរិតុំ វដ្ដតីតិ** ចេតិយគោបកា វា
ភិក្ខូ ហោន្តុ អញ្ញេ វា ហត្ថេនបិ បុញ្ឆិត្វា កចវរំ អប-
នេតុំ វដ្ដតិ មលម្បិ បមជ្ជិតុំ វដ្ដតិយេវ ។ ពាក្យថា នាំ
ចេញនូវសំរាមគួរ ដូច្នេះនេះ សេចក្ដីថា ភិក្ខុអ្នកទំនុកបម្រុង

ព្រះចេតិយក្តី ភិក្ខុជទៃក្តី ចូរលើកទុកចុះ, សូម្បីយកដៃជូត (នូវផ្កាឈូកមាស និងប្រអប់មាសជាដើម ក្នុងព្រះចេតិយ) នាំយកសម្រាមចេញ រមែងគួរ ។ សូម្បីខាត់នូវស្នឹម (ច្រេះ) គួរពិត ។

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

★ **កចវរមេវ ហរិតុំ វដ្តតីតិ** គោបកា វា ហោន្តុ អញ្ញេ វា, ហត្ថេន បុញ្ឆិត្វា កចវរំ អបនេតុំ វដ្តតិ មលម្បិ បមជ្ជិតុំ វដ្តតិ ឯវាតិ វទន្តិ ។ ពាក្យថា នាំចេញនូវសំរាមតែម្យ៉ាងគួរ ដូច្នេះ អាចារ្យទាំងឡាយពោលថា ភិក្ខុអ្នកទំនុកបម្រុងព្រះចេតិយក្តី ភិក្ខុជទៃក្តី ចូរលើកទុកចុះ រមែងគួរដើម្បីយកដៃជូត (នូវផ្កាឈូកមាស និងប្រអប់មាសជាដើម ក្នុងព្រះចេតិយ) ហើយនាំយកសម្រាមចេញបាន ។ សូម្បីខាត់នូវស្នឹម (ច្រេះ) រមែងគួរពិត ។

តំ អដ្ឋកថាយ ន សមេតិ គេឡាយនសទិសត្តា ។ ពាក្យរបស់អាចារ្យនោះ មិនសមនឹងអដ្ឋកថាទេ ព្រោះប្រាកដដូចជាការស្ទាបអង្អែលមើលដែរ ។

<u>ក្នុងគម្ពីរវិនយាលង្ការដីកា ពោលថាៈ</u>

កថំ ន សមេតិ ? មហាអដ្ឋកថាយំ ចេតិយយរ-គោបកា រូបិយឆឌ្ឌកដ្ឋានេ ឋិតាតិ តេសំយេវ កេឡាយនំ អនុញ្ញាតំ ន អញ្ញេសំ, តស្មា "គោបកា វា ហោន្តុ អញ្ញេ វា"តិ វចនំ មហាអដ្ឋកថាយ ន សមេតិ ។ *សួរថាមិនសម ដូចម្តេចទៅ ? ឆ្លើយថា ពួកភិក្ខុដែលនៅថែទាំព្រះចេតិយតាំងនៅក្នុងឋានៈជាអ្នកបោលរូបិយៈ ព្រោះលោកអនុញ្ញាតទុកក្នុងអដ្ឋកថានូវការស្មោបអង្អែល ដល់ភិក្ខុពួកនោះប៉ុណ្ណោះ, មិនបានអនុញ្ញាតដល់បុគ្គលដទៃទេ, ព្រោះហេតុនោះពាក្យថា "ភិក្ខុអ្នកទំនុកបម្រុងព្រះចេតិយក្តី ភិក្ខុដទៃក្តី ចូរលើកទុកចុះ" ពាក្យនេះ មិនសមនឹងអដ្ឋកថា ។*

កុរុន្ទិយំ បន តម្បិ បដិក្ខិត្តំ, សុវណ្ណចេតិយេ កចវរមេវ ហរិតុំ វដ្តតីតិ ឯត្តកមេវ អនុញ្ញាតំ, តស្មា សាវធារណំ កត្វា វុត្តត្តា "ហត្ថេនបិ បុញ្ឆិត្វា"តិ ច "មលម្បិ បមជ្ជិតុំ វដ្តតិ ឯវា"តិ ច វចនំ កុរុន្ទដ្ឋកថាយ ន សមេតិ, តស្មា វិចារេតព្វមេតន្តិ ។ *តែសូម្បីពាក្យនោះលោកហាមទុកក្នុងកុរុន្ទី ។ លោកអនុញ្ញាតត្រឹមតែប៉ុណ្ណោះថា នឹងសម្អាតសំបុកពីងពាង លើព្រះចេតិយមាស រមែងគួរ ព្រោះ*

ហេតុនោះ ពាក្យថា "សូមឱ្យយកដៃជូត (នូវផ្កាឈូកមាស និង ប្រអប់មាសជាដើម ក្នុងព្រះចេតិយ) ហើយនាំយកសម្រាម ចេញបានផង" "សូមឱ្យខាត់នូវស្និម (ច្រេះ) រមែងគួរផង" រមែង មិនសមនឹងអដ្ឋកថាកុរុន្ទី ព្រោះលោកពោលធ្វើឱ្យជាសាធារណៈ ។ ព្រោះហេតុនោះ ពាក្យនោះគប្បីពិចារណា ។

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>

លោកពោលទុកក្នុងអដ្ឋកថាទាំងពួងថា សូមឱ្យស្ពាន់ដែល ប្រាកដដូចជាមាស (អារកូដលោហៈ) ក៏មានគតិដូចមាសដែរ ចាត់ជាអនាមាស ។ ចំណែកគ្រឿងប្រើប្រាស់ក្នុងសេនាសនៈ ជាកប្បិយទាំងអស់, ព្រោះដូច្នោះ គ្រឿងបរិក្ខារប្រចាំសេនាសនៈ សូម្បីគ្រប់យ៉ាងដែលធ្វើដោយមាស និងប្រាក់ ជាអាមាស (គួរចាប់ពាល់បាន) ។

<u>ក្នុងគម្ពីរវិនយាលង្ការដីកា ពោលថា:</u>

**អារកូដលោហន្តិ** សុវណ្ណវណ្ណោ កិត្តិមលោហ-វិសេសោ ។ តីណិ ហិ កិត្តិមលោហានិ កំសលោហំ វដ្ដលោហំ ។ អារកូដលោហន្តិ តត្ថ តិបុតម្ពេ មិស្សេត្វា កតំ កំស-លោហំ នាម ។ សីសតម្ពេ មិស្សេត្វា កតំ វដ្ដលោហំ ។ រសតម្ពេ មិស្សេត្វា កតំ អារកូដលោហំ នាម ។ ប្រែថា

លោហៈប្លមពិសេស មានពណ៌ដូចជាពណ៌មាស ឈ្មោះថា អារកូដ-
លោហៈ ។ ក៏លោហៈធ្វើបន្លំមាន ៣ យ៉ាងគឺ កំសលោហៈ
វដ្តលោហៈ អារកូដលោហៈ ។ បណ្តាលោហៈទាំងនោះ លោហៈ
ដែលគេធ្វើផ្សំសំណប៉ាហាំង និងស្ពាន់ ឈ្មោះថា កំសលោហៈ ។
លោហៈដែលគេធ្វើផ្សំសំណភក់ និងស្ពាន់ឈ្មោះថា វដ្តលោហៈ ។
លោហៈដែលគេធ្វើផ្សំបារ៉ត និងស្ពាន់ ឈ្មោះថា អារកូដលោហៈ ។

<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:</u>

☆ **ជាតរូបគតិកមេវាតិ វុត្តត្តា អារកូដំ សុវណ្ណ-
សទិសមេវ អាមសិតុំ ន វដ្ដតិ, អញ្ញំ បន វដ្ដតីតិ
តីសុបិ គណ្ឋិបទេសុ វុត្តំ ។ កេចិ បន "អារកូដំ
អនាមសិតព្វតោ ជាតរូបគតិកមេវាតិ វុត្តំ, តស្មា
ឧភយម្បិ ជាតរូបំ វិយ អាមសិតុំ ន វដ្ដតី"តិ វទន្តិ ។**

លោកពោលទុកក្នុងគណ្ឋិបទទាំង ៣ ថា ភិក្ខុប៉ះពាល់នូវស្ពាន់
ដែលប្រាកដដូចជាមាសប៉ុណ្ណោះ រមែងមិនគួរ, តែស្ពាន់ដទៃ
រមែងគួរ ព្រោះព្រះអដ្ឋកថាចារ្យពោលថា ស្ពាន់ដែលមានគតិ
ដូចមាសតែម្យ៉ាង ។ តែអាចារ្យពួកខ្លះពោលថា "ពាក្យដែល
លោកពោលហើយថា ស្ពាន់ដែលមានគតិដូចមាសតែម្យ៉ាង គឺ

*ភិក្ខុមិនគប្បីប៉ះពាល់, ព្រោះហេតុនោះ (ស្ពាន់) សូម្បីទាំងពីរ រមែងមិនគួរប៉ះពាល់ ដូចជាមាសដែរ ។*

*<u>ក្នុងគម្ពីរវិនយាលង្ការ និងវិមតិវិនោទនីដីកា ពោលថា:</u>*

★ តំ បន "ជាតរូបគតិក"ន្តិ វុត្តត្តា ឧគ្គណ្ហតោ និស្សគ្គិយម្បិ ហោតីតិ កេចិ វទន្តិ, រូបិយេសុ បន អគណិតត្តា និស្សគ្គិយំ ន ហោតិ, អាមសនេ សម្បដិច្ឆនេ ច ទុក្កដមេវាតិ វេទិតព្វំ ។ *ក៏អាចារ្យទាំងឡាយពោលថា ភិក្ខុកាលទទួលនូវអារកូដ លោហៈនោះ រមែងជានិស្សគ្គិយ ព្រោះលោកពោលថា មានគតិដូចជារូបិយ ។ តែបណ្ឌិតគប្បីជ្រាបថា ព្រោះលោកមិនបានកាន់យកក្នុងរូបិយទាំងឡាយ ទើបមិនជានិស្សគ្គិយទេ ។ ក៏ការទទួលក្តី ការប៉ះពាល់ក្តី ត្រូវត្រឹមតែអាបត្តិទុក្កដប៉ុណ្ណោះ ។*

**សព្ពម្បិ កប្បិយោតិ** យថាវុត្តសុវណ្ណាទិមយានំ សេនាសនបរិក្ខារានំ អាមសនគោបនាទិវសេន បរិភោគោ សព្វថា កប្បិយោតិ អធិប្បាយោ ។ តេនាហ "តស្មា"-តិអាទិ ។ *ពាក្យថា **ជាកប្បិយទាំងអស់** ដូច្នេះ អធិប្បាយថា ការប្រើប្រាស់ដោយអំណាចការប៉ះពាល់ និងការគ្រប់គ្រងជាដើម*

នៃបរិក្ខារបស់សេនាសនៈ ដែលសម្រេចអំពីមាសជាដើម តាមដែលពោលហើយ រមែងគួរទាំងអស់ ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលពាក្យថា "ព្រោះដូច្នោះ" ជាដើម ។

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថាៈ</u>

ពួកអ្នកស្រុកសាងមណ្ឌបកែវ ជាស្ថានទីសម្ដែងព្រះធម៌វិន័យ ដល់ភិក្ខុទាំងឡាយ មានសសរកែវផលិក ប្រដាប់ប្រដាដោយក្បួនកែវ ។ ការដែលភិក្ខុទាំងឡាយ នឹងថែរក្សាគ្រឿងឧបករណ៍ទាំងអស់ ក្នុងរតនមណ្ឌបនោះ គួរ ។

<u>ក្នុងគម្ពីរវិនយាលង្ការ និងវិមតិវិនោទនីដីកា ពោលថាៈ</u>

☆ **"ភិក្ខូនំ ធម្មវិនយវណ្ណនដ្ឋានេ"តិ** វុត្តត្តា សង្ឃិកមេវ សុវណ្ណាទិមយំ សេនាសនំ, សេនាសនបរិក្ខារា ច វដ្ដន្តិ, ន បុគ្គលិកានីតិ គហេតព្វំ ។ សេនាសនៈក្ដី បរិក្ខារទាំងឡាយរបស់សេនាសនៈក្ដី ដែលសម្រេចអំពីមាសជារបស់សង្ឃតែម្យ៉ាងប៉ុណ្ណោះ ទើបគួរ, ភិក្ខុមិនគប្បីកាន់យកថា ជារបស់បុគ្គលទាំងឡាយ ដូច្នេះទេ ព្រោះលោកពោលហើយថា ស្ថានទីសម្ដែងព្រះធម្មវិន័យរបស់ភិក្ខុទាំងឡាយ ដូច្នេះ ។

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថាៈ</u>

ត្បូងទទឹមនិងមរកត ដែលខាត់និងច្នៃហើយ ជាអនាមាស

ដែលនៅមិនបានខាត់និងថ្នៃក្រៅនេះ លោកពោលថាជាអាមាស ភិក្ខុនឹងទទួលទុក ដើម្បីប្រើជាមូលតម្លៃនៃវត្ថុ គួរ ។ តែក្នុង មហាបច្ចរីពោលថា ត្បូងទទឹម និងមរកត ដែលខាត់ហើយក្តី ដែលនៅមិនទាន់បានខាត់ក្តី ជាអនាមាស ដោយប្រការទាំងពួង និងភិក្ខុទទួលទុក មិនគួរ ។ អាវុធគ្រប់ប្រភេទ ជាអនាមាស សូម្បីគេប្រគេន ដើម្បីប្រយោជន៍ចំណាយជាមូលតម្លៃ នៃវត្ថុ ក៏មិនគួរទទួលទុក, ឈ្មោះថា ការលក់ដូរសស្ត្រា រមែងមិន សមគួរ ។ សូម្បីជងផ្នូសុទ្ធៗ ក្តី ខ្សែធ្នូក្តី ជន្ទញក្តី កង្វេដំរី ដោយហោចទៅ សូម្បីកាំបិត និងពូថៅជាដើម ដែលគេធ្វើសម្រាប់ ជាអាវុធ ក៏ជាអនាមាស ។ បើមានអ្នកណាៗ យកលំពែង ឬស្នរ មកដាក់ទុកក្នុងវិហារ កាលនឹងជម្រះវិហារ គប្បីបញ្ជូនដំណឹងទៅ ប្រាប់ដល់ពួកម្ចាស់របស់ថា ចូរនាំចេញទៅ ។ បើពួកគេមិននាំទៅ កុំឱ្យរបស់នោះកម្រើកហើយគប្បីជម្រះវិហារចុះ ។ ភិក្ខុឃើញដាវក្តី លំពែងក្តី ស្នរក្តី ធ្លាក់នៅក្នុងសមរភូមិប្រយុទ្ធ គប្បីយកថ្ម ឬ របស់អ្វីៗ ដំទំលាយដាវចេញហើយ កាន់យកទៅដើម្បីប្រើធ្វើ ជាកាំបិត រមែងគួរ ។ សូម្បីភិក្ខុញែករបស់ក្រៅនេះចេញ ហើយ កាន់យករបស់យ៉ាងណាមួយ ដើម្បីប្រើជាកាំបិត យ៉ាងណាមួយ ដើម្បីប្រើជាឈើច្រត់ជាដើម រមែងគួរ ។ ចំណែកគ្រឿងអាវុធ

ដែលគេប្រគេនថា "សូមលោកម្ចាស់ ទទួលអាវុធនេះទុក ភិក្ខុនឹងទទួលសូម្បីទាំងអស់ដោយតាំងចិត្តថា យើងនឹងធ្វើឱ្យវិនាសអស់ហើយធ្វើឱ្យជាកប្បិយភណ្ឌៈ ដូច្នេះ គួរ ។

ក្នុងគម្ពីរវិនយាលង្ការ និងវិមតិវិនោទនីដីកា ពោលថា:

★ **ភិន្ទិត្វាតិ** បឋមមេវ អនាមសិត្វា បាសាណាទិនា កិញ្ចិមត្តំ ភេទំ កត្វា បច្ឆា កប្បិយភណ្ឌត្ថាយ អធិដ្ឋហិត្វា ហត្ថេន គហេតុំ វដ្ដតិ ។ តេនាហ "កប្បិយភណ្ឌំ ករិស្សាមីតិ សព្វម្បិ សម្បដិច្ឆិតុំ វដ្ដតី"តិ ។

ពាក្យថា ដំទំលាយ ដូច្នេះ មានសេចក្ដីថា មុនដំបូង មិនត្រូវប៉ះពាល់ឡើយ ហើយធ្វើនូវការទំលាយ ត្រឹមតែបន្តិចដោយថ្មជាដើម ខាងក្រោយមកអធិដ្ឋាន ដើម្បីប្រយោជន៍ដល់កប្បិយភណ្ឌហើយ កាន់យកដោយដៃរមែងគួរ ។

ក្នុងគម្ពីរអដ្ឋកថា ពោលថា:

គ្រឿងចាប់សត្វគ្រប់យ៉ាង មានលបដាក់ត្រី និងអន្ទាក់ទាក់សត្វជាដើមក្ដី គ្រឿងការពារព្រួញ មានខែលនិងសំណាញ់ជាដើមក្ដី ជាអនាមាស ។ គ្រឿងតន្ត្រីមានពិណា និងស្គរជាដើម ជាអនាមាស ។ តែទទួលទុក ដើម្បីប្រើជាមូលតម្លៃនៃវត្ថុ រមែងគួរ ។ បើបានមក ដើម្បីត្រូវការនឹងប្រើប្រាស់ នឹងកាន់យកដើម្បីត្រូវការ

ធ្វើឱ្យជាបរិក្ខារនោះៗ ដោយតាំងចិត្តយ៉ាងនេះថា យើងនឹងធ្វើស្នូកពិណ និងស្នូកស្គរ ឱ្យជាភាជនៈដាក់ឈើស្ទន់ ស្បែកនឹងធ្វើជាស្រោមកាំបិត ហើយធ្វើតាមដែលតាំងចិត្តយ៉ាងនោះៗ គួរ ។

## វត្ថុអនាមាសជាសចិត្តកៈ

<u>ក្នុងគម្ពីរអដ្ឋកថាបារាជិក ពោលថា:</u>

មួយទៀត ក្នុងសាកសពសូម្បីដែលមិនបែកធ្លាយ ដោយប្រការទាំងពួង, ភិក្ខុឱ្យមនុស្សអ្នកចាំព្រៃខ្មោច កាន់យកសម្ដត់ឱ្យក៏គួរ ។

វិសភាគសរីរេ បន សតឹ ឧបដ្ឋបេត្វា សមណសញ្ញំ ឧប្បាទេត្វា សីសេ វា ហត្ថបាទបិដ្ឋិយំ វា វណំ កត្វា គហេតុំ វដ្ដតិ ។ តែក្នុងសាកសពភេទផ្ទុយគ្នា ភិក្ខុចូលទៅតាំងសតិទុក ញ៉ាំងសមណៈសញ្ញាឱ្យកើតឡើង ហើយធ្វើឱ្យដំបៅត្រង់ក្បាលឬត្រង់ខ្នងដៃខ្នងជើង រួចកាន់យកសម្ដត់រមែងគួរ ។

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

★ មតសរីរម្បិ ហិ យេន កេនចិ អាការេន សព្ពិច្ចុ ជុសន្តស្ស អនាមាសទុក្កដមេវាតិ វទន្តិ, តំ យុត្តមេវ ។

អាចារ្យទាំងឡាយពោលថា ពិតមែនអនាមាសទុក្កដ (រមែងមាន) ដល់ភិក្ខុកាលក្មេងហើយពាល់ត្រូវ សូម្បីនូវសរីរៈរបស់ស្ត្រីដែលស្លាប់ហើយ ដោយអាការយ៉ាងណាមួយ ពាក្យនោះ លោកពោលត្រឹមត្រូវហើយ ។

**អនាមាសវិនិច្ឆ័យកថាចប់ ។**

# ២-វិញ្ញត្តិវិនិច្ឆយកថា

*ក្នុងវិនយបិដកភាគ ២ ទំព័រ ១៧៩ ពោលថាៈ*

*គ្រានោះឯង ភិក្ខុនៅក្រុងអាឡវី ប្រើគេឱ្យសាងនូវកុដិទាំងឡាយ ដែលមានគ្រឿងឧបករណ៍សូមពីគេមក ដោយខ្លួនឯង ឥតមានទាយកជាម្ចាស់របស់, ចំពោះជាទីនៅរបស់ខ្លួនធំហួសប្រមាណ ។ កុដិមិនទាន់ស្រេច, ភិក្ខុនោះចេះតែសូមញឹកៗ សូមញយៗ ដោយពាក្យសូមថា "បុរិសំ ទេថ : អ្នកទាំងឡាយ ចូរឱ្យនូវបុរស, បុរិសត្ថកំ ទេថ : ចូរឱ្យគ្រឿងហត្ថកម្មរបស់បុរស គោណំ ទេថ : ចូរឱ្យនូវគោ, សកដំ ទេថ : ចូរឱ្យនូវរទេះ វាសឹ ទេថ : ... ចូរឱ្យនូវកាំបិតជាដើម, វល្លឹ ទេថ : ... ចូរឱ្យនូវវល្លិ៍ជាដើម ។*

**ព្រះរដ្ឋបាលពោលជាមួយបិតាថាៈ**

★ យាចកោ អប្បិយោ ហោតិ យាចំ អទទ-មប្បិយោ តស្មា ហន្តំ ន យាចាមិ មា មេ វិទ្ទេសនា អហូតិ ។ *ព្រះរដ្ឋបាលនិយាយថាៈ អ្នកសូមសូម រមែងមិនជាទីស្រលាញ់របស់អ្នកឱ្យ, អ្នកមិនឱ្យរបស់ដែលគេសូម ក៏មិនជាទីស្រលាញ់របស់អ្នកសូម, ព្រោះហេតុនោះ ទើបខ្ញុំមិនសូម*

អ្វីៗ នឹងអ្នក, ដោយគិតថា មិនឱ្យជាទីស្អប់ខ្ពើមដល់ខ្ញុំ ។

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>

ក្នុងពីរបទថា **សូមញឹកៗសូមញយៗនេះ** មិនមានហេតុផ្សេងគ្នា ។ ពាក្យនោះ ជាឈ្មោះរបស់ពួកភិក្ខុ ដែលសូមច្រើន ដងថា "លោកចូរឱ្យបុរស, ចូរឱ្យហត្ថកម្មដែលបុរសត្រូវធ្វើ (កម្លាំងការងារ)" ។ បណ្ដាបុរសនិងហត្ថកម្មនោះ នឹងសូមបុរស ដោយសេចក្ដីដាច់មូល មិនគួរ ។ នឹងសូមថា "ពួកលោកចូរឱ្យ បុរសដើម្បីប្រយោជន៍ដល់ការរួមដៃ, ដើម្បីប្រយោជន៍ដល់ការធ្វើ ការងារ" ដូច្នេះ គួរ, ហត្ថកម្មដែលបុរសគប្បីធ្វើ លោកហៅថា កម្លាំងការងារ, នឹងសូមកម្លាំងការងារ រមែងគួរ ។

<u>ក្នុងគម្ពីរសារត្ថទីបនី និងវិមតិវិនោទនីដីកា ពោលថា:</u>

☆ **មូលច្ឆេជ្ជាយ បុរិសំ យាចិតុំ ន វដ្ដតីតិ** បរសន្តកភាវតោ មោចេត្វា អត្តនោយេវ សន្តកំ កត្វា យាចិតុំ ន វដ្ដតិ ។ ឯវំ មូលច្ឆេជ្ជាយ អញ្ញាតកអប្បវារិ-តដ្ឋានតោ យាចន្តស្ស អញ្ញាតកវិញ្ញត្តិយា ទុក្កដំ ។

ពាក្យថា **មិនគួរសូមបុរសដោយដាច់មូល** ដូច្នេះ មាន សេចក្ដីអធិប្បាយថា មិនគួរដើម្បីសូមឱ្យផុតអំពីភាវៈជារបស់

អ្នកដទៃ ហើយធ្វើឱ្យជារបស់នៃខ្លួនតែម្យ៉ាង ។ ភិក្ខុកាលសូម អំពីជនមិនមែនជាញាតិ និងជនមិនបានបវារណា ដោយការដាច់មូលយ៉ាងនេះ រមែងត្រូវអាបត្តិទុក្កដ ព្រោះវិញ្ញត្តិ ក្នុងទីមិនមែនជាញាតិ ។

## ការចេញមាត់សូម

<u>*ក្នុងគម្ពីរអដ្ឋកថា ពោលថា:*</u>

ដែលឈ្មោះថា ហត្ថកម្ម មិនមែនជាវត្ថុយ៉ាងណាមួយ, ព្រោះហេតុនោះ ហត្ថកម្មនោះ វៀរការងារជាចំណែករបស់ពួកព្រានម្រឹគ និងអ្នកប្រមង់(នេសាទ)ជាដើមចេញ ការងារដ៏សេស ជាកប្បិយទាំងអស់ ។ កាលគេសួរថា "លោកម្ចាស់និមន្តមក មានហេតុដូចម្ដេច? មានការងារដែលអ្នកណានឹងត្រូវធ្វើឬ? " ឬថា មិនសួរនឹងសូមក៏គួរ ។ មិនមានទោស ព្រោះការសូមជាបច្ច័យ ។ ព្រោះហេតុនោះ ពួកព្រានម្រឹគជាដើម ភិក្ខុមិនគួរសូមកិច្ចការចំណែកផ្ទាល់ខ្លួនគេ **ទាំងដែលមិនបានកំណាត់ឱ្យបានពិតប្រាកដ** មិនគួរសូមថា "ពួកលោកចូរឱ្យហត្ថកម្ម" ។ ព្រោះពួកព្រានម្រឹគជាដើមនោះ ត្រូវភិក្ខុសូមយ៉ាងនេះហើយ នឹងត្រូវទទួលពាក្យថា "បានលោកម្ចាស់" ហើយនិមន្តភិក្ខុឱ្យត្រឡប់ទៅ គប្បីសម្លាប់ម្រឹគមកប្រគេនបាន ។ តែគួរសូមកំណាត់ឱ្យប្រាកដថា "ក្នុងវិហារមានកិច្ចការយ៉ាងណាមួយ

ចាំបាច់ត្រូវធ្វើ, ពួកលោកចូរឱ្យហត្ថកម្មក្នុងវិហារនោះ” ។ ការដែលភិក្ខុនឹងសូមហត្ថកម្មយ៉ាងណាមួយ ចំពោះអ្នកស្រែ ឬអ្នកដទៃសូម្បីអ្នកខ្វល់ខ្វាយ ក្នុងការងាររបស់ខ្លួន ដែលកាន់យកគ្រឿងឧបករណ៍មានផាល និងនង្គ័លជាដើម កំពុងដើរទៅដើម្បីភ្ជួរស្រែក្តីដើម្បីព្រោះក្តី ដើម្បីច្រូតក្តី សមគួរពិត ។

<u>ក្នុងគម្ពីរសារត្ថទីបនី និងវិមតិវិនោទនីដីកា ពោលថា:</u>

★ **អនិយមេត្វាបិ ន យាចិតព្វាតិ** សាមីចិទស្សនត្ថំ វុត្តំ, សុទ្ធចិត្តេន បន ហត្ថកម្មំ យាចន្តស្ស អាបត្តិ នាម នត្ថិ ។ ពាក្យថា ***ទាំងដែលមិនបានកំណត់មិនគប្បីសូម*** ដូច្នេះ គឺលោកពោលហើយ ដើម្បីសម្តែងនូវសេចក្តីសមគួរ ។ តែកាលភិក្ខុសូមនូវហត្ថកម្ម (របស់ជនទាំងឡាយ មានព្រានម្រឹគ និងអ្នកនេសាទជាដើម) ដោយចិត្តបរិសុទ្ធ ឈ្មោះថា ត្រូវអាបត្តិ រមែងមិនមាន ។

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>

ចំណែកអ្នកណាជាអ្នកស៊ីដែល ឬជាមនុស្សមិនមានការងារ អ្នកដទៃណាមួយ អ្នកដដែកគ្នាអំពីរឿងឥតប្រយោជន៍ ឬគិតតែពីខាងដេក, សូម្បីមិនសូមបុរសបែបនេះ នឹងពោលថា “នែអ្នក ឯងចូរមកធ្វើការងារនេះ ឬវត្ថុនេះ” ហើយឱ្យធ្វើការងារ

*តាមដែលត្រូវការ រមែងគួរ ។*

*ក្នុងគម្ពីរវិនយាលង្ការ និងវិមតិវិនោទនីដីកា ពោលថាៈ*

★ **យថិច្ឆកំ ការាបេតុំ វដ្ដតីតិ** "ហត្ថកម្មំ យាចាមិ ទេថា"តិអាទិនា អយាចិត្វាបិ វដ្ដតិ, សកិច្ចបសុតម្បិ ឯវំ ការាបេន្តស្ស វិញ្ញត្តិ នត្ថិ ឯវ, សាមីចិទស្សនត្ថំ បន វិភជិត្វា វុត្តំ ។ *ពាក្យថា ឱ្យធ្វើការងារតាមដែលត្រូវការគួរដូច្នេះ សេចក្ដីថា ភិក្ខុសូម្បីមិនបានសូម ដោយពាក្យជាដើមថា "អាត្មាសូមនូវហត្ថកម្ម, លោកចូរឱ្យនូវហត្ថកម្ម" ដូច្នេះ រមែងគួរ ។ សូម្បីអ្នកខ្វល់ខ្វាយក្នុងការងាររបស់ខ្លួន កាលភិក្ខុប្រើឱ្យធ្វើយ៉ាងនេះមិនមានវិញ្ញត្តិទេ, តែដើម្បីសម្ដែងសាមីចិកម្ម ទើបលោកពោលបែងចែកឱ្យផ្សេងគ្នា ។*

*ក្នុងគម្ពីរអដ្ឋកថា ពោលថាៈ*

*ក៏ដើម្បីសម្ដែងថា "ភាវនៃហត្ថកម្មជាកប្បិយគ្រប់យ៉ាង" អាចារ្យទាំងឡាយទើបពោលន័យនេះទុក ។ ក៏បើថា ភិក្ខុប្រាថ្នានឹងឱ្យសាងប្រាសាទ, គប្បីទៅកាន់ស្រុកនៃពួកជាងជាប់ថ្ម ដើម្បីត្រូវការសសរ ហើយពោលថា "ឧបាសក ការបានហត្ថកម្មគួរ" ។ កាលគេសួរថា "គួរធ្វើយ៉ាងណា លោកម្ចាស់" គប្បីប្រាប់ថា "គប្បីសែងសសរថ្មទៅប្រគេន" ។ បើពួកគេសែងទៅ*

ប្រគេន ឬប្រគេនសសរបស់ខ្លួន ដែលជញ្ជូនមករក្សាទុកហើយ គួរ ។ សូម្បីបើពួកគេពោលថា "ពួកខ្ញុំព្រះករុណា មិនមានពេលនឹងធ្វើហត្ថកម្មលោកម្ចាស់ទេ, សូមលោកម្ចាស់ឱ្យអ្នកដទៃជញ្ជូនទៅចុះ ពួកខ្ញុំព្រះករុណា នឹងឱ្យតម្លៃឈ្នួលដល់គេ" ដូច្នេះ, នឹងប្រើឱ្យអ្នកដទៃជញ្ជូនទៅហើយ គួរដើម្បីប្រាប់ថា "ពួកលោកចូរឱ្យតម្លៃឈ្នួល ដល់ពួកអ្នកជញ្ជូនសសរថ្មចុះ" ដូច្នេះ ។

<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:</u>

✯ **មូលំ ទេថាតិ វត្តុំ វដ្តតីតិ** យស្មា មូលំ ទស្សាមាតិ តេហិ បឋមំ វុត្តត្តា វិញ្ញត្តិ ន ហោតិ, យស្មា ច មូលន្តិ ភណិតំ សាមញ្ញវចនតោ អកប្បិយវចនំ ន ហោតិ, តស្មា មូលំ ទេថាតិ វត្តុំ វដ្តតិ ។

ពាក្យថា គួរដើម្បីប្រាប់ថា "ពួកលោកចូរឱ្យតម្លៃឈ្នួលដល់ពួកអ្នកជញ្ជូនសសរថ្មចុះ" ដូច្នេះនេះ មានសេចក្តីថា ព្រោះម្ចាស់នោះគេពោលទុកហើយថា "ពួកខ្ញុំព្រះករុណា នឹងឱ្យតម្លៃឈ្នួល" ព្រោះហេតុណា, ហេតុនោះទើបមិនមានវិញ្ញត្តិ,ម្យ៉ាងទៀតការពោលថា "តម្លៃឈ្នួល" ដូច្នេះ មិនមែនជាពាក្យអកប្បិយទេ ព្រោះជាពាក្យសាមញ្ញ, ព្រោះហេតុណា, ហេតុនោះ ភិក្ខុគួរដើម្បីប្រាប់ថា "ពួកលោកចូរឱ្យតម្លៃឈ្នួល" ដូច្នេះបាន ។

(ក្នុងគម្ពីរវិមតិវិនោទនីដីកា ក៏លោកពោលដោយន័យនេះដូចគ្នា)

ក្នុងគម្ពីរអដ្ឋកថា ពោលទៀតថា:

ដោយឧបាយដូចគ្នានេះ ការដែលភិក្ខុនឹងទៅកាន់សំណាក់ពួកជាងសិប្បកម្មនោះៗ ដើម្បីប្រាថ្នាគ្រប់ៗ វត្ថុដែលត្រូវការ គឺទៅកាន់សំណាក់ជាងឈើ ដើម្បីត្រូវការឈើសាងប្រាសាទ ទៅកាន់សំណាក់ជាងឥដ្ឋ ដើម្បីត្រូវការឥដ្ឋ, ទៅកាន់សំណាក់ជាងប្រក់ដំបូលផ្ទះ ដើម្បីត្រូវការប្រក់ដំបូល, ទៅកាន់សំណាក់ជាងគំនូរដើម្បីត្រូវការចិត្រកម្ម , ហើយសូមហត្ថកម្ម សមគួរ ។ សូម្បីទទួលយករបស់ដែលខ្វនបាន ដោយអំណាចការសូមហត្ថ-កម្មក្តី ដោយការបន្ថែមឱ្យតម្លៃឈ្នួល និងប្រាក់ខែ ដោយការដាច់មូលក្តី សមគួរគ្រប់យ៉ាង កាលនឹងនាំរបស់មកពីព្រៃ គួរឱ្យនាំរបស់ទាំងអស់ ដែលអ្នកណាមួយ មិនបានឃុំគ្រង (មិនបានហួងហែង) មក ។

មួយទៀត មិនមែនតែប្រាថ្នានឹងសាងប្រាសាទតែម្យ៉ាងទេ សូម្បីប្រាថ្នានឹងឱ្យធ្វើគ្រែ តាំង បាត្រ ធម្មក្រក និងចីវរជាដើម ក៏គប្បីឱ្យនាំមកបាន, ភិក្ខុបានឈើ លោហៈ និងអំបោះជាដើម ហើយ ចូលទៅរកពួកជាងសិប្បកម្មនោះៗ គប្បីសូមហត្ថកម្មដោយន័យដូចពោលនុ៎ះឯង ។ ក៏វត្ថុសូម្បីដែលខ្វនបានមកដោយ

អំណាចនៃការសូមហត្ថកម្មក្តី ដោយការបន្ថែមឱ្យតម្លៃឈ្នួល និងប្រាក់ខែ ដោយការដាច់មូលក្តី គប្បីទទួលយកទាំងអស់ ។ ក៏បើពួកអ្នកធ្វើការងារមិនប្រាថ្នានឹងធ្វើ, ចាំតែយកតម្លៃឈ្នួល និងប្រាក់ខែ, របស់ជាអកប្បិយ មានកហាបណជាដើម មិនគួរឱ្យ ។ នឹងស្វែងរកបាយជាដើម ដោយកិច្ចាចារវត្តឱ្យ រមែងគួរ ។

<u>ក្នុងគម្ពីរវិនយាលង្ការ និងវិមតិវិនោទនីដីកា ពោលថាៈ</u>

☆ **មញ្ញ... ចីវរាទីនិ កោរាបេតុកាមេណាបីតិ-អាទីសុ** ចីវរំ ការាបេតុកាមស្ស អញ្ញាតកអប្បវារិត-តន្តវាយេហិ ហត្ថកម្មយាចនវសេន វាយាបនេ វិញ្ញត្តិ-ប្បច្ចយា ទុក្កដាភាវេបិ ចីវរវាយាបនសិក្ខាបទេន យថារហំ ចាចិត្តិយទុក្កដានិ ហោន្តីតិ វេទិតព្វំ ។ ក្នុងពាក្យជាដើមថា សូម្បីប្រាថ្នានឹងឱ្យធ្វើគ្រែ តាំង បាត្រ ធម្មក្រក និងចីវរជាដើម ដូច្នេះ បណ្ឌិតគប្បីជ្រាបថា អាបត្តិទុក្កដ និងបាចិត្តិយរមែងមាន តាមសមគួរ ដល់ភិក្ខុកាលប្រាថ្នាធ្វើនូវចីវរ, ដោយចីវរវាយាបន សិក្ខាបទ (មហាបេសការសិក្ខាបទ) សូម្បីមិនមានអាបត្តិទុក្កដ ព្រោះវិញ្ញត្តិក្នុងការត្បាញដោយអំណាចការសូមហត្ថកម្ម ដោយជាងតម្បាញមិនមែនជាញាតិ និងមិនមែនជនអ្នកបវារណាក៏ដោយ ។

*<u>ក្នុងគម្ពីរសារត្ថទីបនីដីកាពោលថា:</u>*

★ **អកប្បិយកហាបណាទិ ន ធាតព្វន្តិ** កិញ្ចាបិ អកប្បិយកហាបណាទី, អសាទិយន្តេន កប្បិយវោហារតោ ធាតុំ វដ្ដតិ, តថាបិ សារុប្បំ ន ហោតិ ។ មនុស្សា ច ឯតស្ស សន្តកំ កិញ្ចិ អត្ថីតិ វិហេឋេតព្វំ មញ្ញន្តីតិ អកប្បិយកហាបណាទិ ធានំ បដិក្ខិត្តំ ។

*ពាក្យថា **របស់ជាអកប្បិយ មានកហាបណជាដើម មិនគួរឱ្យ** ដូច្នេះ មានសេចក្ដីថា កាលដែលភិក្ខុមិនត្រេកអរនូវកហាបណៈដែលជាអកប្បិយ គួរដើម្បីឱ្យដោយកប្បិយវោហារ ក៏ពិតមែន, ទុកជាដូច្នោះ សេចក្ដីមិនសមរម្យ រមែងមាន ។ ក៏មនុស្សទាំងឡាយ រមែងសំគាល់នូវភិក្ខុដែលខ្លួនគប្បីបៀតបៀនថា “ទ្រព្យណាមួយដែលជាសម្បត្តិរបស់ភិក្ខុនេះ រមែងមាន” ដូច្នេះ ព្រោះហេតុនោះ លោកទើបបដិសេធ ការឱ្យវត្ថុមានកហាបណៈជាដើម ដែលជាអកប្បិយ ។*

## ឆ្លើយនឹងពាក្យដែលគេសួរ មិនជាវិញ្ញត្តិ

*<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>*

*ភិក្ខុឱ្យជាងធ្វើបាត្រ ដោយអំណាចនៃហត្ថកម្មហើយ ឱ្យដុត*

ទំនងតែមួយដូចគ្នានោះ ហើយចូលទៅកាន់ស្រុកដើម្បីត្រូវការប្រេង លាបបាត្រដែលដុតថ្មី កាលអ្នកស្រុកយល់ថា "មកដើម្បីភិក្ខា ហើយនាំបបរ ឬបាយមក (ប្រគេន)" គប្បីយកដៃបិទបាត្រ ។ បើឧបាសិកាសួរថា "ហេតុដូចម្ដេចលោកម្ចាស់" ភិក្ខុគប្បីប្រាប់ថា "បាត្រដុតថ្មី ត្រូវការនាំប្រេងសម្រាប់លាប" ។ បើឧបាសិកាពោលថា "សូមមេត្តាឱ្យបាត្រមកចុះ លោកម្ចាស់" ហើយទទួលយកបាត្រទៅលាបប្រេង ដាក់បបរ ឬបាយឱ្យពេញហើយប្រគេន, មិនឈ្មោះថា ជាវិញ្ញត្តិទេ, នឹងទទួលគួរ ដូច្នេះឯង ។ ពួកភិក្ខុត្រាច់ទៅបិណ្ឌបាត តាំងពីព្រឹកព្រហាម ទៅដល់បន្ទប់ឆាន់មិនឃើញទីអង្គុយឈរចាំ ។ បើទីបន្ទប់ដូច្នោះ ពួកឧបាសិកាឃើញពួកភិក្ខុឈរ ក៏នាំគ្នាយកអាសនៈមក ។ ពួកភិក្ខុដែលអង្គុយហើយ កាលនឹងទៅគប្បីប្រាប់ជាមុនសិន សឹមទៅ ។ តែសូម្បីកាលពួកភិក្ខុមិនពោលលាជាមុនក៏ដោយ ហើយចេញទៅ បើមានរបស់បាត់ ក៏មិនជាសំណាងដែរ ។ តែការប្រាប់លាហើយសឹមទៅ **ជាទំនៀម** ។ បើអាសនៈជារបស់អ្នកស្រុក ដែលភិក្ខុទាំងឡាយបង្គាប់ថា "ពួកលោកចូរនាំអាសនៈមក" ទើបនាំយកមកឱ្យ, ភិក្ខុទាំងឡាយ ត្រូវតែប្រាប់លាហើយសឹមទៅ ។ កាលពួកភិក្ខុទៅមិនប្រាប់លា ជាការខូចទំនៀមនិងរបស់បាត់ ជាសំណាងផង, សូម្បីក្នុងព្រំសម្រាប់ក្រាល ក៏មាន

ន័យយ៉ាងនេះដូចគ្នាដែរ ។

<u>ក្នុងគម្ពីរសារត្ថទីបនី និងវិមតិវិនោទនីដីកា ពោលថា:</u>

☆ **វត្តន្តិ** ចារិត្តំ, អាបត្តិ បន ន ហោតីតិ អធិប្បាយោ ។ ពាក្យថា **ទំនៀម** ដូច្នេះ មានសេចក្ដីអធិប្បាយថា គឺជាវត្តដែលត្រូវប្រព្រឹត្ត តែមិនត្រូវអាបត្តិទេ ។

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>

រុយមានច្រើន គប្បីពោលថា ចូរយកផ្លិតបក់រុយមក ។ ពួកអ្នកស្រុកនាំមែកស្ពោជាដើមមកឱ្យ **គប្បីឱ្យធ្វើកប្បិយសិនសឹមទទួល** ។ ភាជន៍ទឹកក្នុងបន្ទប់ឆាន់មិនមានទឹក មិនគួរពោលថា "ចូរនាំធម្មក្រកមក" ។ ព្រោះកាលជ្រះធម្មក្រកចូលទៅក្នុងភាជនៈទទេនឹងធ្វើភាជន៍ឱ្យបែក ។ តែនឹងទៅកាន់ទន្លេ ឬបឹងហើយពោលថា ចូរនាំទឹកមករមែងគួរ, នឹងពោលថា ចូរនាំមកពីផ្ទះមិនគួរទេ ។ កុំបរិភោគទឹកដែលគេនាំមកឱ្យ ។

<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:</u>

☆ **កប្បិយំ ការាបេត្វា បដិគ្គហេតព្វានីតិ** សាខាយ លគ្គរជស្មឹ បត្តេ បតិតេបិ សាខំ ឆិន្ទិត្វា ខាទិតុកាមតាយបិ សតិ សុខបរិភោគត្ថំ វុត្តំ ។ ពាក្យថា **គប្បីឱ្យធ្វើ**

*កប្បិយសិនសឹមទទួល ដូច្នេះនេះ គឺលោកពោលទុកដើម្បីបរិភោគបានស្រួល សូម្បីកាលធូលីជាប់នៅត្រង់មែក ធ្លាក់ទៅក្នុងបាត្រ, សូម្បីការមានសេចក្តីត្រូវការទឹងកាច់មែកឈើហើយទំពា ។*

*<u>ក្នុងគម្ពីរវិនយាលង្ការ និងវិមតិវិនោទនីដីកា ពោលថា:</u>*

★ **កប្បិយំ ការាបេត្វា បដិគ្គហេតព្ពានីតិ** សាខាយ មក្ខិកពីជនេន បណ្ណាទិនេទេ ពីជគាមកោបនស្ស ចេវ តត្ថ លគ្គរជាទិអប្បដិគ្គហិតកស្ស ច បរិហារត្ថាយ វុត្តំ, តទុភយាសត្តាយ អសតិ តថា អករណេ ទោសោ នត្ថិ ។

*ពាក្យថា **គប្បីឱ្យធ្វើកប្បិយសិនសឹមទទួល** ដូច្នេះនេះ គឺលោកពោលហើយដើម្បីការពារ ដល់ភិក្ខុដែលញ៉ាំងពីជគាម ឱ្យវិនាសព្រោះការដាច់ស្លឹកជាដើម ដោយមែកឈើដែលជាផ្លិតបក់រុយផង, ដើម្បីការពារដល់ភិក្ខុ ដែលមិនបានទទួលនូវធូលីជាដើម ដែលជាប់នឹងមែកនោះផង ។ តែបើមិនមានសេចក្តីរង្កៀសទាំងពីរយ៉ាងនេះទេ ទោសក្នុងការមិនធ្វើដោយប្រការដូច្នោះរមែងមិនមាន ។*

## វត្ថុដែលកើតពីវិញ្ញត្តិមិនគួរ សូម្បីដល់សហធម្មិកទាំង ៥

*<u>ក្នុងគម្ពីរវិនយាលង្ការ និងវិមតិវិនោទនីដីកា ពោលថា:</u>*

★ នទីយាទីសុ ឧទកស្ស អបរិគ្គហិតតាយ

*"អាហរាតិ វត្តុំ វដ្ដតី"តិ វុត្តំ ។ ពាក្យថា គួរដើម្បីពោលថា ចូរនាំមក ដូច្នេះ គឺលោកពោលហើយ ព្រោះការនៃទឹកក្នុងស៊ីង ជាដើម មិនមានគេហួងហែង ។*

☆ **"ន អាហដំ បរិភុញ្ជិតុ"ន្តិ** វចនតោ វិញ្ញត្តិយា អាបន្នំ ឧុក្កដំ ធេសេត្វាបិ តំ វត្ថុំ បរិភុញ្ជន្តស្ស បុន បរិភោគេ ឧុក្កដមេវ, បញ្ចន្នម្បិ សហធម្មិកានំ ន វដ្ដតិ ។ *ដោយពាក្យថា កុំបរិភោគទឹក ដែលគេនាំមកប្រគេន ដូច្នេះ សេចក្ដីថា សូម្បីកាលភិក្ខុសម្ដែងនូវអាបត្តិទុក្កដ ដែលត្រូវព្រោះវិញ្ញត្តិហើយ កាលបរិភោគនូវវត្ថុនោះ រមែងត្រូវអាបត្តិទុក្កដម្ដងទៀតពិត ក្នុងខណៈបរិភោគ, រមែងមិនគួរ សូម្បីដល់សហធម្មិកទាំង ៥ ។*

*<u>ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:</u>*

☆ **ន អាហដំ បរិភុញ្ជិតព្វន្តិ** *"សូបោទនវិញ្ញត្តិទុក្កដំ ហោតី"តិ វុត្តំ ។ ពាក្យថា កុំបរិភោគទឹកដែលគេនាំមកប្រគេន ដូច្នេះនេះ គឺលោកពោលហើយថា ជាទុក្កដ ព្រោះសូបោទនវិញ្ញត្តិសិក្ខាបទ ។*

*<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>*

*តែការដែលភិក្ខុបង្គាប់ឱ្យគេនាំគោមក ពីស្ថានទីនៃជនមិន*

មែនជាញាតិ និងអ្នកមិនបានបវារណា រមែងមិនគួរ ។ ត្រូវអាបត្តិទុក្កដ ដល់ភិក្ខុដែលឱ្យនាំមក ។ នឹងសូមដោយដាច់មូលតម្លៃ សូម្បីអំពីស្ថានទីនៃញាតិ និងអ្នកបវារណា ក៏មិនគួរ ។ នឹងសូមដោយន័យជារបស់ខ្ចី គួរក្នុងទីទាំងពួង ។ និងគប្បីថែរក្សាគោដែលឱ្យនាំមក (ឱ្យស៊ោស៊ីជាដើម) យ៉ាងនេះ រួចស្រេចហើយ គប្បីប្រគល់ឱ្យម្ចាស់របស់វា យកទៅវិញ ។ បើជើង ឬស្នែងរបស់វាបាក់ ឬខូចទៅ, បើម្ចាស់របស់ព្រមយកវាទៅវិញ, ការព្រមទទួលនោះ ជាការល្អ, បើម្ចាស់របស់មិនព្រមទទួលទេ, ជាសំណាង ។ ប្រសិនបើម្ចាស់របស់វាពោលថា "ពួកខ្ញុំព្រះករុណាប្រគេនលោកម្ចាស់ចុះ" **មិនគួរទទួល** ។ តែកាលម្ចាស់របស់វាពោលថា "ពួកខ្ញុំព្រះករុណា ថ្វាយដល់វត្ត" គប្បីពោលថា "ពួកលោកចូរប្រាប់ ដល់បុគ្គលអ្នកធ្វើការងារវត្ត ដើម្បីប្រយោជន៍ ដល់ការចិញ្ចឹមវា" ។

<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:</u>

**✯ គោណំ បន... អាហរាបេតុំ ន វដ្តតីតិ**

អត្ថោ អត្តាយ មូលច្ឆេជ្ជវសេន អាហរាបេតុំ ន វដ្តតិ ។ ពាក្យថា *តែការដែលភិក្ខុបង្គាប់ឱ្យគេនាំគោមក... រមែងមិនគួរ* ដូច្នេះនេះ សេចក្តីថា រមែងមិនគួរដើម្បីឱ្យនាំមកដើម្បីប្រយោជន៍

*ដល់ខ្លួន ដោយអំណាចការដាច់មូលទេ ។*

★ **អាហារាបេន្តស្ស ទុក្កដន្តិ** អញ្ញាតកវិញ្ញត្តិយា ទុក្កដំ ។ អត្តនោ អត្ថាយ សាទិយនេបិ ទុក្កដមេវ "ហត្ថិគវាស្សវឡវបដិគ្គហណា បដិវិរតោ ហោតី"តិ វុត្តត្តា ។ តេនេវាហ "ញាតកបវារិតដ្ឋានតោបិ មូលច្ឆេជ្ជាយ យាចិតុំ ន វដ្ដតី"តិ ។

*ពាក្យថា ត្រូវអាបត្តិទុក្កដដល់ភិក្ខុដែលឱ្យនាំមក ដូច្នេះនេះ សេចក្ដីថា ត្រូវអាបត្តិទុក្កដ ព្រោះសូមក្នុងទីមិនមែនជាញាតិ ។ សូម្បីការត្រេកអរដើម្បីប្រយោជន៍ដល់ខ្លួន ក៏ត្រូវអាបត្តិទុក្កដ ដូចគ្នា, ព្រោះព្រះអង្គត្រាស់ថា "ជាអ្នកវៀរស្រឡះចាកការទទួលនូវដំរី គោ សេះ និងពពែ" ដូច្នេះ ។ ព្រោះហេតុនោះ ទើបលោកពោលថា "ទឹងសូមដោយដាច់មូលតម្លៃ សូម្បីអំពីស្ថានទីនៃញាតិនិងអ្នកបវារណា ក៏មិនគួរ " ។*

## ការសូមក្ដី ការទទួលក្ដីនូវវត្ថុដែលជាអកប្បិយមិនគួរ

*ក្នុងគម្ពីវិមតិវិនោទនីដីកា ពោលថា:*

★ **អាហារាបេន្តស្ស ទុក្កដន្តិ** វិញ្ញត្តិក្ខណេ វិញ្ញត្តិបច្ចយា, បដិលាភក្ខណេ គោណានំ សាទិយនបច្ចយា

ច ទុក្កដំ ។ គោណញ្ហិ អត្តនោ អត្ថាយ អវិញ្ញត្តិយា លទ្ធម្បិ សាទិតុំ ន វដ្តតិ "ហត្ថិគវស្សវឡវបដិគ្គហណា បដិវិរតោ ហោតី"តិ វុត្តត្តា ។ តេនេវាហ "ញាតិបវា-រិតដ្ឋានតោបិ មូលច្ឆេជ្ជាយ យាចិតុំ ន វដ្តតី"តិ ។ ឯត្ថ ច វិញ្ញត្តិទុក្កដាភាវេបិ អកប្បិយវត្ថុយាចនេបិ បដិគ្គហ-ណេបិ ទុក្កដមេវ ។ *ពាក្យថា* ***ត្រូវអាបត្តិទុក្កដ ដល់ភិក្ខុដែលឱ្យនាំមក*** *ដូច្នេះនេះ សេចក្តីថា ត្រូវអាបត្តិទុក្កដ ព្រោះវិញ្ញត្តិក្នុងខណៈសូមផង, និងព្រោះការត្រេកអរដល់គោទាំងឡាយ ក្នុងខណៈបានមកផង ។ ភិក្ខុរមែងមិនគួរដើម្បីនឹងត្រេកអរសូម្បីការបានមកដោយមិនមានវិញ្ញត្តិ ដើម្បីប្រយោជន៍ដល់ខ្លួន ក្នុងគោទាំងឡាយ, ព្រោះព្រះអង្គត្រាស់ថា "ជាអ្នកវៀរស្រលះចាកការទទួលនូវដំរី គោ សេះ និងពពែ" ដូច្នេះ ។ ព្រោះហេតុនោះ ទើបលោកពោលថា "នឹងសូមដោយដាច់មូលតម្លៃ សូម្បីអំពីស្ថានទីនៃញាតិនិងអ្នកបវារណា ក៏មិនគួរ" ។ ក៏ក្នុងពាក្យនេះលោកពោលថា អាបត្តិទុក្កដ(រមែងមាន)ពិត,* ***ក្នុងការសូមក្តី ក្នុងការទទួលក្តីនូវវត្ថុដែលជាអកប្បិយ*** *សូម្បីមិនមានអាបត្តិទុក្កដ ព្រោះវិញ្ញត្តិក៏ដោយ ។*

<u>ក្នុងគម្ពីរសារត្ថទីបនី និងវិនយាលង្ការដីកា ពោលថា:</u>

★ **ន សម្បដិច្ឆិតព្វន្តិ** អត្តនោ អត្ថាយ គោណោ សាទិយនស្ស បដិក្ខិត្តត្តា វុត្តំ ។ ពាក្យថា មិនគួរទទួល ដូច្នេះនេះ គឺលោកពោលហើយ ព្រោះការត្រេកអរនូវគោទាំងឡាយ ដើម្បីប្រយោជន៍ដល់ខ្លួន គឺលោកបដិសេធហើយ ។

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>

សូម្បីភិក្ខុពោលជាមួយពួកជន មិនមែនញាតិ និងមិនបានបវារណាថា "ពួកលោកចូរប្រគេនរទេះ" ដូច្នេះក្តី មិនគួរ ។ រមែងជាវិញ្ញត្តិពិត គឺត្រូវអាបត្តិទុក្កដ ។ តែក្នុងឋានៈនៃញាតិ និងអ្នកបវារណា គួរ ។ ជារបស់ខ្លី ក៏គួរ, ធ្វើការងារសម្រេចហើយ គប្បីសងវិញ ។ បើកង់ជាដើមបែកបាក់ទៅ គប្បីធ្វើឱ្យដូចដើម ហើយសងវិញ ។ កាលវិនាសអស់ជាសំណង ។ កាលម្ចាស់របស់ពោលថា "ពួកខ្ញុំព្រះករុណា ប្រគេនលោកម្ចាស់ចុះ" ធម្មតាគ្រឿងឈើគួរទទួលទុកបាន ។

<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:</u>

★ **សកដំ ទេថាតិ... ន វដ្តតីតិ** មូលច្ឆេជ្ជវសេន សកដំ ទេថាតិ វត្តុំ ន វដ្តតិ ។ ពាក្យថា មិនគួរដើម្បីពោល

ថា ពួកលោកចូរប្រែគេនរទេះ ដូច្នេះនេះ គឺមិនគួរដើម្បីពោលថា ពួកលោកចូរប្រែគេនរទេះ ដោយអំណាចការដាច់មូលទេ ។

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

☆ **ញាតិបវារិតដ្ឋានេ បន វដ្ដតីតិ** សកាជស្ស សម្បដិច្ឆិតព្វត្តា មូលច្ឆេជ្ជវសេន យាចិតុំ វដ្ដតិ ។

ពាក្យថា តែក្នុងឋានៈនៃញាតិនិងអ្នកបវារណា គួរ ដូច្នេះនេះ គឺរមែងគួរដើម្បីសូម ដោយអំណាចការដាច់មូលបាន ព្រោះរទេះ គឺភិក្ខុអាចទទួលបាន ។

## របស់ដែលគេមិនហួងហែងសូមមិនជាវិញ្ញត្តិទេ

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>

ក្នុងកាំបិត ពូថៅ ជីង ចប និងពន្លាកក្ដី ក្នុងរុក្ខជាតិ មានវល្លិ៍ជាដើមក្ដី ដែលមានម្ចាស់ហួងហែង ក៏មានន័យដូចគ្នានេះ ។ ក៏ក្នុងពួករុក្ខជាតិ មានវល្លិ៍ជាដើម(ឫស្សី ស្មៅជំណោកទន្សាយ ស្មៅយ៉ាបូង, ស្មៅធម្មតា, និងដីស្អិត) ដែលល្មមជាគរុភណ្ឌបាន ប៉ុណ្ណោះ ទើបជាវិញ្ញត្តិទាបជាងនោះ មិនជាវិញ្ញត្តិទេ ។ តែភិក្ខុនឹងឱ្យនាំយកវត្ថុណាមួយ ដែលមិនមានអ្នកហួងហែងមក គួរ ។ ព្រោះថា ក្នុងទីមានអ្នករក្សាឃុំគ្រងប៉ុណ្ណោះ លោកហៅថា វិញ្ញត្តិ ។

*<u>ក្នុងគម្ពីរវជិរពុទ្ធិដីកា និងសារត្ថទីបនីដីកា ពោលថា:</u>*

★ "កិញ្ចាបិ **គរុភណ្ឌប្បហោនកេសុតិ** វុត្តំ, តថាបិ យំ វត្ថុវសេន អប្បំ ហុត្វា អគ្ឃវសេន មហា ហរិតាលហិង្គុលិកាទិ, តំ យាចិតុំ ន វដ្ដតី"តិ វទន្តិ ។

*អាចារ្យទាំងឡាយពោលថា "ពាក្យថា* ***ក្នុងវត្ថុទាំងឡាយ ដែលល្មមជាគរុភណ្ឌបានប៉ុណ្ណោះ*** *(ទើបជាវិញ្ញត្តិ) ដូច្នេះ គឺ លោកពោលហើយក៏ពិតមែន, ទុកជាដូច្នេះ វត្ថុណាជារបស់តិច ដោយអំណាចវត្ថុ តែមានតម្លៃច្រើន មានហរិតាល និង ហង្គុលិកជាដើម* ***មិនគួរ ដើម្បីសូមវត្ថុនោះទេ*** *" ។*

*<u>ក្នុងគម្ពីរវិនយវិនិច្ឆយដីកា ពោលថា:</u>*

★ **គរុភណ្ឌប្បហោនកេតិ** វល្លិ អឌ្ឍពាហុមត្តាបី-តិអាទិនា នយេនវុត្តលក្ខណោ គរុភណ្ឌប្បហោនកេ ។

*ពាក្យថា* ***ល្មមជាគរុភណ្ឌ*** *គឺបានដល់ វត្ថុល្មមជាគរុភណ្ឌ មានលក្ខណៈ ដែលអដ្ឋកថាចារ្យពោលហើយ ដោយន័យ ជាដើមថា "វល្លិ៍ សូម្បីត្រឹមតែពាក់កណ្ដាលដើមដៃ" (ក៏ជា គរុភណ្ឌ) ដូច្នេះ ។*

## ការធ្វើនូវនិមិត្តកម្មជាដើម

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>

វិញ្ញត្តិនោះ រមែងមិនគួរក្នុងបច្ច័យទាំងពីរ (គឺ ចីវរ និង បិណ្ឌបាត) ដោយប្រការទាំងពួង ។ តែក្នុងសេនាសនបច្ច័យ ត្រឹមតែបញ្ចេញមាត់សូមថា "អាហរ, ទេហិ" "លោកចូរនាំមក, ចូរឱ្យប៉ុណ្ណោះ" មិនគួរ ។ បរិកថា ឱភាស និងនិមិត្តកម្ម គួរ ។ បណ្ដាបរិកថា ឱភាស និងនិមិត្តកម្មនោះ, ពាក្យនិយាយរបស់ភិក្ខុដែលត្រូវ ការរោងឧបោសថ បន្ទប់ឆាន់ ឬសេនាសនៈដទៃៗ ដោយន័យជាដើមថា "ការសាងសេនាសនៈបែបនេះ ក្នុងឱកាសនេះ គួរហ្ន៎ ឬ ប្រពៃហ្ន៎ ឬថា សមគួរហ្ន៎" ដូច្នេះ ឈ្មោះថា **បរិកថា** ។ ភិក្ខុសួរថា "ឧបាសកពួកលោកនៅទីណា ?" ពួកឧបាសកឆ្លើយថា "នៅឯលើប្រាសាទ លោកម្ចាស់" និយាយតទៅថា "ក៏ប្រាសាទមិនគួរដល់ភិក្ខុទាំងឡាយឬ ឧបាសក ? " ពាក្យនិយាយមានជាដើមយ៉ាងនេះ ឈ្មោះថា **ឱភាស** ។ ក៏ការធ្វើមានជាដើមយ៉ាងនេះ គឺ ភិក្ខុឃើញពួកអ្នកស្រុកហើយរឹតបន្ដឹងខ្សែ ឱ្យបោះបង្គោល កាលពួកអ្នកស្រុកសួរថា "លោកម្ចាស់នេះ ឱ្យធ្វើអ្វីហ្នឹង ?" ឆ្លើយថា "ពួកអាត្មានឹងសាងទីនៅអាស្រ័យក្នុងទីនេះ" ឈ្មោះថា **និមិត្តកម្ម** ។ ចំណែកក្នុងគិលានបច្ច័យ សូម្បីវិញ្ញត្តិ ក៏គួរ, ចាំបាច់ពោលទៅថ្វី

ដល់បរិកថាជាដើមនោះ ។

<u>ក្នុងគម្ពីរសារត្ថទីបនី និងវិមតិវិនោទនីដីកា ពោលថា:</u>

★ "សេនាសនំ សម្ពាធ"ន្តិអាទិនា បរិយាយេន កថនំ បរិកថា នាម ។ ការពោលដោយបរិយាយ មានពាក្យជាដើមថា សេនាសនៈនេះដូចជាចង្អៀត ដូច្នេះ ឈ្មោះថា បរិកថា ។

★ ឧជុកមេវ អកថេត្វា "ភិក្ខូនំ កឹ បាសាទោ ន វដ្ដតី"តិអាទិនា អធិប្បាយោ យថាវិភូតោ ហោតិ, ឯវំ ភាសនំ ឱភាសោ នាម ។ ភិក្ខុមិនពោលដោយត្រង់ទេ ហើយអធិប្បាយដោយពាក្យជាដើមថា "ប្រាសាទមិនសមគួរដល់ភិក្ខុទាំងឡាយឬ? " គេដឹងច្បាស់តាមពិត យ៉ាងណា ក៏ពោលយ៉ាងនោះ ឈ្មោះថា ឱភាស ។

★ សេនាសនាទិអត្ថំ ភូមិបរិកម្មាទិការណាវសេន បច្ចយុប្បាទាយ និមិត្តករណំ និមិត្តកម្មំ នាម ។ ការធ្វើនូវនិមិត្ត ព្រោះអាស្រ័យបច្ច័យ ដោយអំណាចកិរិយាធ្វើនូវកម្ម មានការបរិកម្មផែនដីជាដើម ដើម្បីប្រយោជន៍ដល់សេនាសនៈជាដើម ឈ្មោះថា និមិត្តកម្ម ។

*<u>ក្នុងគម្ពីរសារត្ថទីបនី និងវិនយាលង្ការដីកា ពោលថា:</u>*

★ **ឥទានិ គិលានបច្ចយេ វិញ្ញត្តិអាទិកំ សព្ពម្បិ វដ្ដតីតិ** ទស្សេន្តោ អាហ "គិលានបច្ចយេ បនា"តិអាទិ ។ តថា ឧប្បន្នំ បន ភេសជ្ជំ រោគេ វូបសន្តេ បរិភុញ្ជិតុំ វដ្ដតិ, ន វដ្ដតីតិ ? តត្ថ វិនយធរា "ភគវតា រោគសីសេន បរិភោគស្ស ទ្វារំ ទិន្នំ, តស្មា អរោគកាលេបិ បរិភុញ្ជិតុំ វដ្ដតិ, អាបត្តិ ន ហោតី"តិ វទន្តិ ។ សុត្តន្តិកា បន "កិញ្ចាបិ អាបត្តិ ន ហោតិ អាជីវំ បន កោបេតិ, តស្មា សល្លេខប្បដិបត្តិយំ ឋិតស្ស ន វដ្ដតិ, សល្លេខំ កោបេតី"តិ វទន្តិ ។

*ក្នុងកាលឥឡូវនេះ លោកអាចារ្យកាលសម្ដែងពាក្យនិយាយគ្រប់យ៉ាង មានវិញ្ញត្តិជាដើម រមែងគួរក្នុងគិលានបច្ច័យ ទើបពោលពាក្យជាដើមថា "តែគិលានបច្ច័យ" ដូច្នេះ ។ សួរថា ក៏ភេសជ្ជៈ ដែលកើតឡើងដោយប្រការដូច្នោះ កាលរោគជាសះស្បើយហើយ តើគួរឆាន់ឬមិនគួរឆាន់ទេ? ក្នុងសេចក្ដីនេះ ភិក្ខុដែលជាវិន័យធរទាំងឡាយពោលថា "ទ្វារនៃការបរិភោគដោយមានរោគជាប្រធាន គឺព្រះមានភាគឱ្យហើយ, ព្រោះហេតុនោះគួរដើម្បីឆាន់បានសូម្បីក្នុងកាលមិនមានរោគ, អាបត្តិ ក៏មិនមានដែរ" ។ តែភិក្ខុអ្នកទ្រទ្រង់ព្រះសូត្រទាំងឡាយ ពោលថា "អាបត្តិ*

មិនមានក៏ពិតមែន តែរមែងញ៉ាំងអាជីវឱ្យកម្រើក, ព្រោះហេតុនោះ រមែងមិនគួរ ដល់ភិក្ខុដែលតាំងនៅក្នុងសល្លេខប្បដិបទា, សល្លេខប្បដិបទា រមែងកម្រើក ” ។

ក្នុងអដ្ឋកថា កុលទូសកសិក្ខាបទ ពោលថា:

ក៏ប្រសិនបើធម្មកថិកណាមួយពោលថា “ម្នាលឧបាសកឧបាសិកាទាំងឡាយ ក្នុងវិហារមានផ្កាឈើជាច្រើន ពួកអ្នកចូរកាន់យកយាគូ និងភត្តជាដើម ហើយចូរទៅធ្វើការបូជាចុះ ” ។ លោកពោលទុកក្នុងមហាបច្ចរី និងកុរុន្ទីថា យាគូនិងភត្តនោះមិនគួរដល់ភិក្ខុជាធម្មកថិកនោះតែម្យ៉ាង ។ ក៏ឯនៅក្នុងមហាអដ្ឋកថាលោកពោលដោយមិនប្លែកគ្នាថា យាគូនិងភត្តជាដើមនោះ ជាអកប្បិយ មិនគួរទេ ។

ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:

✯ យាគុភត្តាទីនិ អាធាយាតិ ឥទំ ភិក្ខូនំ អត្ថាយ យាគុភត្តាទិសម្បាទនំ សន្ធាយ វុត្តំ ន វដ្ដតីតិ អវិសេសេន វុត្តំ ។ ពាក្យថា ពួកអ្នកចូរកាន់យកយាគូ និងភត្តជាដើម ដូច្នេះ ពាក្យនេះគឺលោកពោលហើយដោយសេចក្ដីមិនប្លែកគ្នាថា រមែងមិនគួរ, ព្រោះលោកពោល

សំដៅយកភិក្ខុ (ជាធម្មកថិក) ឱ្យគេចាត់ចែងយាគូនិងភត្តជាដើម ដើម្បីប្រយោជន៍ដល់ភិក្ខុទាំងឡាយ ។

ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:

☆ **អវិសេសេន វុត្តត្តា** ឥមិនា សព្វេសម្បិ ន វដ្ដតីតិ ទស្សេតិ ។ ដោយពាក្យថា លោកពោលដោយសេចក្ដីមិនប្លែកគ្នានេះ លោកអាចារ្យសម្ដែងថា រមែងមិនគួរសូម្បីដល់ភិក្ខុទាំងអស់ ។

ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:

☆ **តស្សេវ ន កប្បតីតិ** ឯត្ថ យាគុអាទីនិ អានេត្វា ទេន្តីតិ ឥច្ឆាវសេន វទតិ ចេ សព្វេសំ ន កប្បតិ, កេវលំ បន សុទ្ធចិត្តេន អត្តានំ, វា បរេសំ វា អនុទ្ទិសិត្វា ឥមេ មនុស្សា ទានំ ទត្វា បុញ្ញំ បសវន្តូតិ វទន្តស្ស តស្សេវ ន កប្បតិ យាគុអាទីនំ បច្ចយបដិសំយុត្តកថាយ ឧប្បន្នត្តា ។

ក្នុងពាក្យថា **មិនគួរដល់ភិក្ខុធម្មកថិកនោះតែម្យ៉ាង** ដូច្នេះ សេចក្ដីថា បើភិក្ខុជាធម្មកថិកនោះ ពោលដោយអំណាចនៃសេចក្ដីប្រាថ្នាដោយពាក្យថា “ចូរនាំនូវយាគូជាដើមមកប្រគេន” ដូច្នេះ អាហារនោះមិនគួរដល់ភិក្ខុទាំងពួង, តែបើភិក្ខុមានចិត្តបរិសុទ្ធ មិនចំពោះខ្លួន ឬចំពោះភិក្ខុពួកដទៃទេ កាលពោលដោយ

*ពាក្យថា "មនុស្សទាំងឡាយនេះ ឱ្យទានរួចហើយចូរជួបប្រសព្វបុណ្យចុះ" ដូច្នេះ អាហារវត្ថុនោះ មិនគួរដល់ភិក្ខុជម្មកជិកតែម្យ៉ាង ព្រោះអាហារមានយាគូជាដើម កើតឡើងព្រោះសំដីប្រកបដោយបច្ច័យ ។*

★ មហាអដ្ឋកថាយម្បិ បញ្ចន្នម្បិ សហធម្មិកានន្តិ វិសេសេត្វា អវុត្តត្តា អត្ថតោ សយមេវាតិ អបរេ ។ អាចរិយា, បន យថា មហាបច្ចរិយំ កុរុន្ទិយញ្ច តស្សេវាតិ វិសេសេត្វា វុត្តំ ឯវំ មហាអដ្ឋកថាយំ វិសេសេត្វា ន វុត្តំ សព្វេសំ ន កប្បតីតិ វទន្តិ ។ *ពួកអាចារ្យដទៃទៀត ពោលថា ដោយអត្ថ (មិនគួរ) ចំពោះខ្លួនឯងតែម្យ៉ាង, ព្រោះលោកមិនបានពោលឱ្យប្លែក សូម្បីក្នុងមហាអដ្ឋកថា ថា "(មិនគួរ) ដល់សហធម្មិក" ដូច្នេះឡើយ ។ តែអាចារ្យទាំងឡាយ ពោលថា លោកពោលឱ្យប្លែកទុកក្នុងមហាបច្ចរី និងក្នុងកុរុន្ទីថា "មិនគួរដល់ភិក្ខុជម្មកជិកតែម្យ៉ាង" ដូច្នេះ យ៉ាងណា មហាអដ្ឋកថាមិនបានពោលឱ្យប្លែកយ៉ាងនោះទេ ព្រោះហេតុនោះ* ***ទើបអាហារវត្ថុនោះ មិនគួរដល់ភិក្ខុទាំងពួង*** *។*

**វិញ្ញត្តិវិនិច្ឆយកថាចប់ ។**

# ៣_បព្វជ្ជាកថា

## វិនយបិដក ភាគ ៦ ទំព័រ ៧០ ពោលថា

★ អនុជានាមិ ភិក្ខវេ តុម្ហេវ តានិ តាសុ តាសុ ទិសាសុ តេសុ តេសុ ជនបទេសុ បព្វាជេថ ឧបសម្បាទេថ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតថា អ្នកទាំងឡាយ ចូរឱ្យបព្វជ្ជា ឱ្យឧបសម្បទា ដល់កុលបុត្រក្នុងទិសនោះៗ ក្នុងជនបទនោះៗ ក្នុងកាលឥឡូវនេះចុះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវឱ្យបព្វជ្ជា ឱ្យឧបសម្បទា យ៉ាងនេះថា :

បឋមំ កេសមស្សុំ ឱហារាបេត្វា កុលបុត្រនោះ ភិក្ខុគប្បីកោរសក់ និងពុកមាត់ឱ្យជាដំបូង ។

កាសាយានិ វត្ថានិ អច្ឆាទាបេត្វា ហើយឱ្យស្លៀកដណ្តប់សំពត់កាសាយៈទាំងឡាយ ។

ឯកំសំ ឧត្តរាសង្គំ ការាបេត្វា ភិក្ខូនំ បាទេ វន្ទាបេត្វា ឧក្កុដិកំ និសីទាបេត្វា អញ្ជលឹ បគ្គណ្ហាបេត្វា ឯវំ វទេហីតិ វត្តព្វោ ។ រូបឱ្យពាក់ចីវរឆៀងស្មាម្ខាង ឱ្យថ្វាយ

បន្ទំបាទាភិក្ខុទាំងឡាយ, ហើយអង្គុយច្រហោង ផ្គងអញ្ជលីឡើង រួចប្រាប់ថា អ្នកចូរពោលពាក្យយ៉ាងនេះ ៖

ពុទ្ធំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីរលឹក ។

ធម្មំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីរលឹក ។

សង្ឃំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីរលឹក ។

ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីរលឹក ជាគំរប់ពីរដងផង ។

ទុតិយម្បិ ធម្មំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះធម៌ ជាទីរលឹក ជាគំរប់ពីរដងផង ។

ទុតិយម្បិ សង្ឃំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីរលឹក ជាគំរប់ពីរដងផង ។

តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធ ជាទីរលឹក ជាគំរប់បីដងផង ។

តតិយម្បិ ធម្មំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា

សូមដល់នូវព្រះធម៌ ជាទីរលឹក ជាគំរប់ពីដងផង ។

តតិយម្បិ សង្ឃំ សរណំ គច្ឆាមិ ខ្ញុំព្រះករុណា សូមដល់នូវព្រះសង្ឃ ជាទីរលឹក ជាគំរប់បីដងផង ។

អនុជានាមិ ភិក្ខវេ ឥមេហិ តីហិ សរណគមនេហិ បព្វជ្ជំ ឧបសម្បទំ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត បព្វជ្ជានិងឧបសម្បទា ដោយត្រៃសរណគមន៍ទាំងឡាយនេះ ។

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>

ពាក្យថា **គប្បីឱ្យថ្វាយបង្គំបាទា** ភិក្ខុទាំងឡាយជាដើម បានសេចក្ដីថា ភិក្ខុឯណាប្រជុំគ្នាក្នុងទីនោះ, គប្បីឱ្យថ្វាយបង្គំបាទាភិក្ខុទាំងនោះហើយ, លំដាប់នោះ គប្បីអង្គុយប្រហោងផ្គងអញ្ជលីហើយប្រាប់ថា **ឯវំ វទេហិ** អ្នកចូរពោលយ៉ាងនេះ ហើយបន្ទាប់ថា **យមហំ វទាមិ តំ វទេហិ** "យើងពោលនូវពាក្យណា អ្នកចូរពោលនូវពាក្យនោះ" ដើម្បីទទួលនូវសរណៈ ។ លំដាប់នោះ ឧបជ្ឈាយ៍ អាចារ្យគប្បីឱ្យសរណៈដល់កុលបុត្រនោះ ដោយន័យជាដើមថា "**ពុទ្ធំ សរណំ គច្ឆាមិ**" ខ្ញុំព្រះករុណា សូមដល់នូវព្រះពុទ្ធជាទីរលឹក ដូច្នេះ ។ គប្បីឱ្យតាមលំដាប់ ដែលពោលហើយយ៉ាងណា ពិតមែន ភិក្ខុ

មិនគប្បីឱ្យខុសលំដាប់គ្នាឡើយ ។

★ សចេ ហិ ឯកបទម្បិ ឯកក្ខរម្បិ ឧប្បដិបាដិយា ទេតិ ពុទ្ធំ សរណំយេវ វា តិក្ខត្តុំ ទត្វា បុន ឥតរេសុ ឯកេកំ តិក្ខត្តុំ ទេតិ អទិន្នានិ ហោន្តិ សរណានិ ។

បើឱ្យខុសលំដាប់មួយបទក្តី អក្សរមួយតួក្តី, ឬឱ្យ ពុទ្ធំ សរណំ ប៉ុណ្ណោះគ្រប់ ៣ ដង, ហើយខាងក្រោយ ទើបឱ្យសរណៈក្រៅពីនេះ ក្នុងមួយបទៗ ៣ ដង, មិនបាត់ថា បានឱ្យឡើយ ។

<u>ក្នុងគម្ពីរវិនយវិនិច្ឆយ ពោលថា៖</u>

★ អញ្ជលឹ បគ្គហាបេត្វា ទាតព្វំ សរណត្តយំ បដិបាដិវសេនេវ ន ច ឧប្បដិបាដិយា ។ (ឧបជ្ឈាយ៍) គប្បីញុំាងកុលបុត្រនោះ ឱ្យផ្គងនូវអញ្ជលី ហើយគប្បីឱ្យនូវត្រៃសរណគមន៍ ដោយអំណាចតាមលំដាប់តែម្តង, តែមិនគប្បីឱ្យដោយខុសលំដាប់ទេ ។

<u>ក្នុងគម្ពីរអដ្ឋកថា ពោលទៀតថា៖</u>

★ ឥមញ្ច បន សរណគមនូបសម្បទំ បដិក្ខិបិត្វា អនុញ្ញាតឧបសម្បទា ឯកតោសុទ្ធិយា វដ្តតិ ។

ក៏ឧបសម្បទា ដែលព្រះមានព្រះភាគ ទ្រង់ហាមនូវឧប-

សម្បទា ដោយសរណគមន៍នេះ ហើយទ្រង់អនុញ្ញាត (ឧបសម្បទា) ដោយសេចក្តីបរិសុទ្ធិ ដោយចំណែកតែមួយ រមែងគួរ ។

<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:</u>

☆ **អនុញ្ញាតឧបសម្បទាតិ** ញត្តិចតុត្ថកម្មេន, អនុញ្ញាតឧបសម្បទា ។ ពាក្យថា ទ្រង់អនុញ្ញាតឧបសម្បទា ដូច្នេះនេះ បានដល់ ឧបសម្បទា ដែលព្រះមានព្រះភាគ ទ្រង់អនុញ្ញាតទុកដោយញត្តិចតុត្ថកម្មវាចា ។

**ការបួសជាសាមណេរ គឺត្រូវបរិសុទ្ធទាំង ២ ខាង**

<u>ក្នុងគម្ពីរអដ្ឋកថា ពោលទៀតថា:</u>

☆ សាមណេរបព្វជ្ជា បន ឧភតោសុទ្ធិយាវ វដ្ដតិ នោ ឯកតោ សុទ្ធិយា ។ តស្មា ឧបសម្បទាយ សចេ អាចរិយោ ញត្តិទោសញ្ចេវ កម្មវាចាទោសញ្ច វជ្ជេត្វា កម្មំ ករោតិ សុកតំ ហោតិ ។ ចំណែកសាមណេរបព្វជ្ជា បរិសុទ្ធ ទាំងពីរចំណែក ទើបគួរ, បរិសុទ្ធចំណែកតែមួយ មិនគួរទេ ។ ព្រោះហេតុនោះ ក្នុងឧបសម្បទាបើអាចារ្យធ្វើកម្មវៀរចាកទោស នៃញត្តិ និងទោសនៃកម្មវាចាហើយ, កម្មជាការធ្វើប្រពៃ ។

<u>ក្នុងគម្ពីរចុល្លគណ្ឋីមហាវគ្គ ពោលថា:</u>

ពាក្យថា **បរិសុទ្ធទាំងពីរចំណែកទើបគួរ** ដូច្នេះនេះគឺបាន តែអ្នកឱ្យតែម្នាក់ ហើយអ្នកទទួលតែម្នាក់ប៉ុណ្ណោះ ។ បើអ្នកទទួល ២-៣-៤ នាក់ឡើងទៅ **មិនឡើងទៅជាសាមណេរឡើយ** ។

<u>ក្នុងគម្ពីរវិនយវិនិច្ឆយ ពោលថា:</u>

★ ឧបសម្បទកម្មំ តុ ឯកតោសុទ្ធិយា សិយា ន ហោតិ បន បព្វជ្ជា ឧភតោសុទ្ធិយា វិនា ។

ឯឧបសម្បទាកម្ម (បួសជាភិក្ខុ) គឺគប្បីជាឯកតោសុទ្ធិ ចំណែកបព្វជ្ជា វៀរចាកឧភតោសុទ្ធិចេញហើយ រមែងមិនជាការឱ្យបព្វជ្ជាឡើយ ។

<u>ក្នុងគម្ពីរវិនយវិនិច្ឆយដីកា ពន្យល់ថា:</u>

★ **ឧភតោសុទ្ធិយា វិនាតិ** ឧភតោសុទ្ធឹ វិនា អាចរិយន្តេវាសីនំ ឧភិន្នំ តីសុ សរណាគមនគ្គហណេសុ ឧច្ចារណាសុទ្ធឹ វិនា ឯកស្សាបិ អក្ខរស្ស វិបត្តិសព្ភាវេ ន ហោតីតិ អត្ថោ ។

ពាក្យថា **វៀរចាកឧភតោសុទ្ធិ** ដូច្នេះនេះ មានសេចក្ដីថា វៀរចាកឧភតោសុទ្ធិ គឺវៀរចាកសេចក្ដីបរិសុទ្ធនៃការបញ្ចេញ

*សំលេងក្នុងការឱ្យ និងការទទួលត្រៃសរណគមន៍ ៣ ដង របស់អាចារ្យ និងអន្តេវាសិកទាំងពីររូប ព្រោះមានការវិបត្តិនៃអក្ខរៈសូម្បីតែមួយតួរ, (បព្វជ្ជា)រមែងមិនមាន ។*

<u>*ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:*</u>

★ ឧភតោសុទ្ធិយាវ វដ្ដតីតិ ឯត្ថ មហាថេរោ បតិតទន្តាទិការណតាយ អចតុរស្សំ កត្វា វទតិ ព្យត្តសាមណេរោ សមីបេ ឋិតោ បព្វជ្ជាបេក្ខំ ព្យត្តំ វទាបេតិ ។ មហាថេរេន អវុត្តំ វទាបេតីតិ ន វដ្ដតិ ។ ក្នុងពាក្យថា *បរិសុទ្ធទាំងពីរចំណែកទើបគួរ ដូច្នេះនេះ មានសេចក្ដីថា ព្រះមហាថេរ: (ដែលជាឧបជ្ឈាយ៍) ពោលត្រៃសរណគមន៍ ធ្វើមិនឱ្យមានជ្រុង ៤ ព្រោះហេតុតែខ្លួន ជាអ្នកមានធ្មេញបាក់ជាដើម, បើសាមណេរដែលឈ្លាសស្ថិតនៅក្នុងទីជិត ហើយញ៉ាំងបព្វជ្ជាបេក្ខៈដែលឈ្លាសឱ្យពោល, (ឈ្មោះថាសាមណេរដែលឈ្លាសញ៉ាំងបព្វជ្ជាបេក្ខៈដែលឈ្លាស) ឱ្យពោលនូវសរណគមន៍ ដែលមហាថេរៈមិនបានពោល, ព្រោះដូច្នោះ (ការពោលបន្ទាប់របស់សាមណេរនោះ) ទើបមិនគួរ ។*

អថ ថេរេន ចតុរស្សំ វុត្តំ បព្វជ្ជាបេក្ខំ វត្តុំ

អសក្កោន្តំ សាមណេរោ សយំ វត្វា វាចេតិ ឧភតោសុទ្ធិ ឯវ ហោតិ ថេរេន វុត្តស្សេវ វុត្តត្តា ។ ប្រសិនបើ ព្រះថេរៈ ពោលនូវជ្រុង ៤ (នៃអក្សរ) បព្វជ្ជាបេក្ខៈកាលមិន អាចដើម្បី នឹងពោលបាន សាមណេរក៏ញុំាងសាមណេរឱ្យពោលដោយ ខ្លួនឯង សេចក្ដីបរិសុទ្ធិទាំងសងខាង រមែងមានពិត, ព្រោះ បព្វជ្ជាបេក្ខៈ ពោលនូវសរណគមន៍ ដែលព្រះថេរៈពោល ហើយពិត ។

<u>ក្នុងគម្ពីរអដ្ឋកថា ពោលទៀតថា:</u>

បព្វជ្ជាយ បន ឥមានិ តីណិ សរណានិ ពុការ-ធការាទីនំ ព្យញ្ជនានំ ឋានករណសម្បទំ អហាបេន្តេនេវ អាចរិយេនបិ អន្តេវាសិកេនបិ វត្តព្វានិ ។ ចំណែកក្នុង បព្វជ្ជា, សរណៈទាំងឡាយ ៣ នេះ គឺទាំងអាចារ្យ ទាំងអន្តេ-វាសិក កាលញុំាងកិរិយាដល់ព្រមនៃឋានៈ និងករណៈរបស់ ព្យញ្ជនៈទាំងឡាយមាន ពុ អក្សរ និង ធ អក្សរជាដើម, មិនឱ្យខូចប៉ុណ្ណោះ គប្បីពោល ។

សចេ អាចរិយោ វត្តុំ សក្កោតិ អន្តេវាសិកោ ន សក្កោតិ អន្តេវាសិកោ វា សក្កោតិ អាចរិយោ ន

សក្កោតិ ឧភោបិ វា ន សក្កោន្តិ ន វដ្ដតិ ។ សចេ បន ឧភោបិ សក្កោន្តិ វដ្ដតិ ។ *បើអាចារ្យអាចដើម្បីពោលបាន តែអន្តេវាសិកមិនអាច, ឬអន្តេវាសិកអាច តែអាចារ្យមិនអាច, ឬទាំងពីរចំណែកមិនអាច មិនគួរទេ ។ តែបើទាំងពីរចំណែក អាច, (សេចក្ដីនេះ) ទើបសមគួរ ។*

*__ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:__*

★ **ឋានករណសម្បន្នន្តិ** ឯត្ថ ឧរាទីនិ ឋានានិ សំវុតាទីនិ ករណានីតិ វេទិតព្វានិ ។ *ក្នុងពាក្យថា ការដល់ព្រមនៃឋាន និងករណៈ ដូច្នេះនេះ គប្បីជ្រាបថា អវយវៈទាំងឡាយមានទ្រូងជាដើម ឈ្មោះថា ជាឋាន ។ គប្បីជ្រាបថា ការធ្វើ(សំឡេងទាំងឡាយ) មានសំវុត (គឺការពោល)យ៉ាងសង្រួមជាដើម ឈ្មោះថា ជាករណៈ ។*

*__ក្នុងគម្ពីរវិនយវិនិច្ឆយ ពោលថា:__*

★ តស្មា អាចរិយេនាបិ តថាន្តេវាសិកេនបិ

ពុទ្ធ-ធ-ភាភខយោ វណ្ណា ឋានករណសម្បទំ ។

*ព្រោះហេតុនោះ អាចារ្យក្ដី អន្តេវាសិកក្ដី (គប្បីពោល) ឱ្យដល់ព្រមនៃឋាន និងករណៈ របស់អក្ខរៈទាំងឡាយ មាន*

ពុទអក្សរ និង ធអក្សរ ជាដើមដូចគ្នា ។

★ អហាបេន្តេន វត្តព្វា បព្វជ្ជាគុណមិច្ចតា ឯក-វណ្ណវិនាសេន បព្វជ្ជា ហិ ន រូហតិ ។ ភាពនៃអាចារ្យនិងអន្តេវាសិក អ្នកប្រាថ្នានូវគុណនៃបព្វជ្ជា មិនគប្បីពោលឱ្យខូច(សេចក្ដីដល់ព្រមនៃឋាន និងករណៈឡើយ) ព្រោះថា បព្វជ្ជារមែងមិនឡើង ព្រោះតែសេចក្ដីវិនាសនៃអក្សរ សូម្បីតែមួយតួរ ។

## ការឱ្យសរណៈជាអនុនាសិកន្តៈត្រូវឱ្យជាប់គ្នា

<u>ក្នុងគម្ពីរអដ្ឋកថា ពោលទៀតថា:</u>

ឥមានិ ច បន ឥឥមាគេន ពុទ្ធំ សរណំ គច្ឆាមីតិ ឯវំ ឯកសម្ពន្ធានិ អនុនាសិកន្តានិ វា កត្វា ធាតព្វានិ ពុទ្ធម, សរណម, គច្ឆាមីតិ ឯវំ វិច្ឆិន្ទិត្វា មការន្តានិ វា កត្វា ធាតព្វានិ ។ ក៏ឯភិក្ខុកាលឱ្យសរណៈនេះ គប្បីឱ្យពោលបទ ដែលមាននិគ្គហិតជាទីបំផុត ឱ្យតជាប់ជាមួយគ្នា យ៉ាងនេះថា "ពុទ្ធំ សរណំ គច្ឆាមិ" ឬគប្បីឱ្យពោលបទដែលមាន ម អក្សរ ជាទីបំផុតឱ្យដាច់រយៈគ្នា យ៉ាងនេះថា " ពុទ្ធម, សរណម, គច្ឆាមិ " ។

## ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា៖

★ អនុនាសិកន្តំ កត្វា ធានកាលេ អន្តរា វិច្ឆេទំ អកត្វា ធាតព្វានីតិ ទស្សេតុំ ឯកសម្ពន្ធានីតិ វុត្តំ ។ *លោកអាចារ្យពោលថា* ***ឱ្យតជាប់ជាមួយគ្នា*** *ដូច្នេះនេះ ដើម្បីសម្តែងថា មិនគប្បីឱ្យធ្វើនូវការដាច់រយៈក្នុងចន្លោះ ក្នុងវេលាធ្វើឱ្យមាននិគ្គហិតជាទីបំផុត ហើយឱ្យ ( សរណៈ) ៗ*

★ **វិច្ឆិន្ទិត្វាតិ** មការន្តំ កត្វា ធានសមយេ វិច្ឆេទំ កត្វា ។ *ពាក្យថា* ***ពោលឱ្យដាច់រយៈគ្នា*** *ដូច្នេះនេះ មានសេចក្តីថា គឺ ក្នុងសម័យដែលធ្វើនូវបទមាន មអក្សរ ឱ្យជាទីបំផុតហើយឱ្យ (សរណៈ) គឺ ភិក្ខុត្រូវធ្វើឱ្យដាច់ ៗ*

## ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា៖

★ អនុនាសិកន្តំ កត្វា ឯកសម្ពន្ធំ កត្វា ធានកាលេ អន្តរា អដ្ឋត្វា វត្តព្វំ ។ *(ព្រះឧបជ្ឈាយ៍) ធ្វើនូវសំឡេងចេញតាមចុងច្រមុះហើយធ្វើឱ្យជាប់គ្នាតែមួយ មិនឈប់នៅក្នុងចន្លោះហើយគប្បីពោល ក្នុងកាលដែលឱ្យសរណៈ ៗ*

★ អនុនាសិកន្តេ ធិយ្យមានេ ខលិត្វា ពុទ្ធំ សរណំ គច្ឆាមីតិ មការេន មិស្សីភូតេ ខេត្តេ ឱតិណ្ណត្តា វដ្តតីតិ

ឧបតិស្សត្ថេរោ ។ ព្រះឧបតិស្សត្ថេរ ពោលថា ភិក្ខុកាលឱ្យជាអនុនាសិកន្ត: ភ្ជាត់ធ្លាក់ចុះក្នុងដែនដែលលាយគ្នាដោយ ម អក្សរថា “ពុទ្ធំម, សរណំម, គច្ឆាមិ ” ដូច្នេះជាដើម ក៏គួរ ។

★ មិស្សំ កត្វា វត្តុំ វដ្តតិ វចនកាលេ បន អនុនាសិកន្តានេ វិច្ឆេទំ អកត្វា វត្តព្វន្តិ ធម្មសិរិត្ថេរោ ។ ព្រះធម្មសិរិត្ថេរពោលថា ភិក្ខុពោលលាយគ្នា ក៏គួរ, តែថា ក្នុងកាលពោលកុំកាត់ក្នុងស្ថានអនុនាសិកន្ត: ហើយគប្បីពោលចុះ ។

## សិក្ខាបទដែលសាមណេរត្រូវសិក្សា

<u>ក្នុងគម្ពីរអដ្ឋកថា ពោលបន្តទៀតថា:</u>

ប្រើនបទថា អនុជានាមិ ភក្ខវេ ឥមេហិ តីហិ សរណគមនេហិ បព្វជ្ជំ ឧបសម្បទំ ដូច្នេះនេះ បានសេចក្តីថា តថាគតអនុញ្ញាតបព្វជ្ជានិងឧបសម្បទា ដោយត្រៃសរណគមន៍ទាំងឡាយនេះ ដែលពោលដោយសេចក្តីបរិសុទ្ធទាំងពីរ ចំណែកគ្រប់ ៣ ដង យ៉ាងនេះថា “ពុទ្ធំ សរណំ គច្ឆាមិ” ជាដើម ។ ក្នុងបព្វជ្ជា និងឧបសម្បទាទាំងពីរនោះ ឧបសម្បទា ព្រះមានព្រះភាគ ទ្រង់ហាមឃាត់ខាងមុខហើយ ព្រោះហេតុណា, ហេតុនោះ ឥឡូវនេះ ឧបសម្បទានោះទើបមិនឡើង ដោយត្រឹម

តែការពោលនូវសរណៈប៉ុណ្ណោះឡើយ ។ ចំណែកបព្វជ្ជា ទ្រង់អនុញ្ញាតទុកខាងមុខថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតសាមណេរបព្វជ្ជា ដោយត្រៃសរណគមន៍ទាំងអស់នេះ" ព្រោះហេតុនោះ ឥឡូវនេះ បព្វជ្ជានោះរមែងឡើងដោយត្រឹមតែពោលសរណៈប៉ុណ្ណោះ ។ មែនពិត កុលបុត្រ ឈ្មោះថា តាំងនៅក្នុងភូមិនៃសាមណេរ ដោយអាការត្រឹមតែប៉ុណ្ណេះ ។ បើសាមណេរជាអ្នកមានបញ្ញា មានជាតិជាអ្នកឈ្លាស, លំដាប់នោះ គឺភិក្ខុគប្បីសម្តែងសិក្ខាបទទាំងឡាយ ដល់សាមណេរក្នុងទីនោះតែម្តង ។

បព្វជ្ជា ហិ សរណគមនេហេវ សិទ្ធា សិក្ខាបទានិ បន កេវលំ សិក្ខាបរិបូរណត្ថំ ជានិតព្វានិ ។ មែនពិត បព្វជ្ជារមែងសម្រេចដោយសរណគមន៍ តែប៉ុណ្ណោះ ។ ចំណែកសិក្ខាបទទាំងឡាយ ដែលសាមណេរគួរដឹង ដើម្បីធ្វើសិក្ខាឱ្យបរិបូរណ៍តែម្យ៉ាង ។

តស្មា តានិ បាលិយំ អាគតនយេន ឧគ្គហេតុំ អសក្កោន្តស្ស យាយ កាយចិ ភាសាយ អត្ថវសេនបិ អាចិក្ខិតុំ វដ្តតិ ។ ព្រោះហេតុនោះ កាលសាមណេរមិនអាចនឹងរៀនសិក្ខាបទទាំងនោះ តាមន័យដែលមកក្នុងព្រះបាលីបាន, ការដែលភិក្ខុប្រាប់ដោយអំណាចនៃសេចក្តី ដោយភាសា

ណាមួយ ក៏គួរដែរ ។

សព្វមស្ស កប្បិយាកប្បិយំ អាចិក្ខិតព្វំ និវាសន-ធារុបនាទីសុ អាភិសមាចារិកេសុ វិនេតព្វោ ។ តេនាហ "អនុជានាមិ ភិក្ខវេ ទសហង្គេហិ សមន្នាគតំ សាមណេរំ នាសិតុន្តិ" ឯវំ បរតោ វុត្តានិ ទស នាសនង្គានិ អារកា បរិវជ្ជេត្វា អាភិសមាចារិកំ បរិបូរេន្តេន ទសវិធេ សីលេ សាធុកំ សិក្ខិតព្វន្តិ ។ ព្រះឧបជ្ឈាយ៍ គួរប្រាប់វត្ថុដែលជាកប្បិយ និងអកប្បិយគ្រប់យ៉ាង ដល់សាមណេរ, គួរណែនាំសាមណេរ ក្នុងអាភិសមាចារិកវត្ត មានការស្លៀកដណ្តប់ជាដើម ។ សូម្បីសាមណេរនោះ ក៏គួរវៀរឱ្យឆ្ងាយចាកនាសនង្គៈ ១០ ដែលព្រះមានព្រះភាគ ត្រាស់ទុកខាងមុខយ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុញុំាងសាមណេរដែលប្រកបដោយអង្គ ១០ ឱ្យវិនាស" ដូច្នេះ ហើយញុំាងនូវអាភិសមាចារិកវត្តឱ្យបរិបូរណ៍ គប្បីសិក្សាឱ្យល្អ ក្នុងសីល ១០ យ៉ាងនេះឯង ។

<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:</u>

✯ សព្វមស្ស កប្បិយាកប្បិយំ អាចិក្ខិតព្វន្តិ ទសសិក្ខាបទវិនិមុត្តំ បរាមាសាបរាមាសាទិភេទំ កប្បិ-

យាកប្បិយំ អាចិក្ខិតព្វំ ។ ពាក្យថា ព្រះឧបជ្ឈាយ៍គួរប្រាប់វត្ថុដែលជាកប្បិយ និងអកប្បិយគ្រប់យ៉ាង ដូច្នេះនេះ មានសេចក្ដីថា ព្រះឧបជ្ឈាយ៍គប្បីប្រាប់ ឱ្យដឹងនូវវត្ថុដែលជាកប្បិយនិងអកប្បិយ ផ្សេងដោយវត្ថុមានបរាមាសវត្ថុ (វត្ថុដែលគួរប៉ះបាន) និងអបរាមាសវត្ថុ (វត្ថុដែលមិនគួរប៉ះបាន) ជាដើម ដែលផុតចាកសិក្ខាបទទាំង ១០ ។

ក្នុងគម្ពីរសារត្ថទីបនី និងវិមតិវិនោទនីដីកា ពោលថា:

☆ **អាភិសមាចារិកេសុ វិនេតព្វោតិ** ឥមិនា សេខិយឧបជ្ឈាយវត្តាទិអាភិសមាចារិកសីលមនេន បូរេតព្វំ តត្ថ ច កត្តព្វស្ស អករណេ អកត្តព្វស្ស ច ករណេ ទណ្ឌកម្មារហោ ហោតីតិ ទីបេតិ ។ ដោយពាក្យថា គួរណែនាំលោកក្នុងអាភិសមាចារិកវត្ត ដូច្នេះនេះ លោកអាចារ្យរមែងសម្ដែងថា សាមណេរនេះ គប្បីបំពេញសីល គឺអាភិសមាចារិកវត្តមានសេខិយវត្ត និងឧបជ្ឈាយ៍វត្តជាដើម, នឹងជាអ្នកគួរដល់ការដាក់ទណ្ឌកម្ម ក្នុងព្រោះមិនធ្វើនូវវត្ថុដែលខ្លួនគួរធ្វើ និងក្នុងព្រោះការធ្វើនូវវត្ថុដែលខ្លួនមិនគួរធ្វើ ក្នុងអាភិសមាចារិកវត្តទាំងនោះ ។

☆ **អាភិសមាចារិកេសុ វិនេតព្វោតិ** ឥមិនា សេខិយ-

វត្តខន្ធកវត្តេសុ អញ្ញេសុ ច សុក្កវិស្សដ្ឋិអាទិលោកវជ្ជ-សិក្ខាបទេសុ សាមណេរេហិ វត្តិតព្វំ តត្ថ អវត្តមានោ អលជ្ជី ទណ្ឌកម្មារហោ ច ហោតីតិ ទស្សេតិ ។

*ពាក្យថា គួរណែនាំលោកក្នុងអាភិសមាចារិកវត្ត ដូច្នេះនេះ សេចក្តីថា សាមណេរទាំងឡាយ គប្បីប្រព្រឹត្តក្នុងសេខិយវត្ត ខន្ធកវត្ត (គឺខន្ធកវត្តដែលមិនជាប់នឹងការធ្វើកម្ម) និងក្នុង លោកវជ្ជៈសិក្ខាបទទាំងឡាយមានសុក្កវិស្សដ្ឋិ ជាដើមដទៃផង, សាមណេរណាកាលមិនប្រព្រឹត្ត ក្នុង(វត្តទាំងឡាយមាន សេខិយវត្តជាដើម)នោះ ឈ្មោះថា ជាអលជ្ជីផង គួរដល់ នូវទណ្ឌកម្មផង ។*

*<u>ក្នុងគម្ពីរអដ្ឋកថាបរិវារៈពោលថា:</u>*

★ **បញ្ចន្នញ្ចេវ អាបត្តីតិ** អាបត្តិ ឆាម បញ្ចន្នំ សហធម្មិកានំ ហោតិ ។ តត្ថ ទ្វិន្នំ និប្បរិយាយេន អាបត្តិយោ សិក្ខមានាសាមណេរីសាមណេរានំ បន អកប្បិយត្តា ន វដ្ដតីតិ ឥមិនា បរិយាយេន តេសំ អាបត្តិ ន ទេសាបេតព្វោ ទណ្ឌកម្មំ បន តេសំ កាតព្វំ ។ *ពាក្យថា អាបត្តិរមែងមានដល់បុគ្គលទាំង ៥*

ដូច្នេះ មានសេចក្តីថា ដែលឈ្មោះថា អាបត្តិរមែងមានដល់សហធម្មិកទាំង ៥ ។ បណ្តាសហធម្មិកទាំង ៥ នោះ បើនិយាយដោយនិប្បរិយាយ (គឺដោយត្រង់) អាបត្តិរមែងមានដល់ភិក្ខុនិងភិក្ខុនី ២ ពួកប៉ុណ្ណោះ ។ តែសម្រាប់សិក្ខមានា សាមណេរ សាមណេរី អាបត្តិរមែងមាន ដោយបរិយាយ (គឺដោយអម) នេះថា "ព្រោះវត្ថុនោះ ជាអកប្បិយ ទើបមិនគួរ" ។ ភិក្ខុមិនត្រូវឱ្យសហធម្មិកទាំង ៣ នេះ សម្តែងអាបត្តិចេញទេ, តែគប្បីដាក់ទណ្ឌកម្ម តាមកំហុសរបស់ខ្លួនដល់សហធម្មិកទាំង ៣ នោះ ។

## បញ្ជាមានអង្គ ៣

១-កេសច្ឆេទនំ ការកោរសក់

២-កាសាយច្ឆាទនំ ការឱ្យស្លៀកសំពត់កាសាយៈ

៣-ទានំ ការឱ្យសរណៈ ។

( សារត្ថទីបនីដីកា និង វិមតិវិនោទនីដីកា )

<u>ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថាៈ</u>

★ "កេសមស្សុំ ឱរោបេត្វា អកត្វា អសតិយា សរណានិ ទត្វា បព្វាជេតិ, ទុក្កដំ"តិ វទន្តិ ។

*អាចារ្យទាំងឡាយពោលថា "ភិក្ខុមិនធ្វើនូវការកោរសក់ និងពុកមាត់ហើយ ឱ្យនូវសរណៈទាំងឡាយ ដោយមិនមានសតិហើយបំបួស, (ការបំបួសនោះ) រមែងឡើងពិត" ។*

## ភិក្ខុកម្លោះបំបួសខុទ្ទិសចំពោះឧបជ្ឈាយ៍

*ក្នុងព្រះអដ្ឋកថា ពោលថា:*

សចេ ឱកាសោ ហោតិ **សយំ បព្វាជេតព្វោ** ។ សចេ ឧទ្ទេសបរិបុច្ឆាទីហិ ព្យាវដោ ហោតិ ឱកាសំ ន លភតិ ឯកោ ទហរភិក្ខុ វត្តព្វោ ឯតំ បព្វាជេហីតិ ។ *បើឧបជ្ឈាយ៍មានឱកាស គប្បីឱ្យបព្វជ្ជាដោយខ្លួនឯង ។ បើត្រូវខ្វល់ខ្វាយដោយកិច្ចការមានឧទ្ទេស និងបរិបុច្ឆាជាដើម, មិនមានឱកាស, គប្បីបង្គាប់ភិក្ខុកំលោះមួយរូបថា "លោកចូរឱ្យកុលបុត្រនេះបួសចុះ" ។*

អវុត្តោបិ ចេ ទហរភិក្ខុ **ឧបជ្ឈាយំ ឧទ្ទិស្ស បព្វាជេតិ** វដ្ដតិ ។ *បើភិក្ខុកំលោះ ដែលឧបជ្ឈាយ៍មិនបានបង្គាប់ឡើយ លោកបំបួសជំនួសឧបជ្ឈាយ៍ (ការធ្វើយ៉ាងនោះ) ក៏សមគួរ ។*

*ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:*

★ **សយំ បព្វាជេតព្វោតិ** កេសច្ឆេទនាទីនិ សយំ ករោន្តេន បព្វាជេតព្វោ ។ *ពាក្យថា* ***គប្បីឱ្យបព្វជ្ជាដោយខ្លួនឯង*** *ដូច្នេះនេះ សេចក្ដីថា ភិក្ខុកាលធ្វើការកោរសក់ជាដើមដោយខ្លួនឯង គប្បីឱ្យបព្វជ្ជា ។*

កេសច្ឆេទនំ កាសាយច្ឆាទនំ ធានត្តិ ហិ ឥមានិ តីណិ ករោន្តោ បព្វាជេតីតិ វុច្ចតិ ។ ឯតេសុ ឯកំ ទ្វេ វាបិ ករោន្តោ តថា វោហរីយតិយេវ តស្មា **ឯតំ បព្វាជេហីតិ** កេសច្ឆេទនំ កាសាយច្ឆាទនញ្ច សន្ធាយ វុត្តំ ។ *ព្រោះថា ភិក្ខុកាលធ្វើកិច្ចទាំង ៣ យ៉ាងនេះ គឺការកោរសក់ ការស្លៀកសំពត់កាសាយ: ការឱ្យសរណ: លោកហៅថា* ***ឱ្យបព្វជ្ជា*** *។ ក្នុងកិច្ចទាំង ៣ យ៉ាងនោះ កាលធ្វើកិច្ចតែមួយ ឬទាំងពីរ លោកក៏ហៅ* ***ឱ្យបព្វជ្ជាដូចគ្នា*** *។ ព្រោះហេតុនោះ ពាក្យថា* ***លោកចូរឱ្យកុលបុត្រនេះបួស*** *ដូច្នេះ គឺលោកអាចារ្យពោលសំដៅដល់ការកោរសក់ និងការឱ្យស្លៀកសំពត់កាសាយ: ។*

**ឧបជ្ឈាយំ ឧទ្ទិស្ស បព្វាជេតីតិ** ឯត្ថាបិ ឯសេវ នយោ ។ *សូម្បីក្នុងពាក្យថា* ***លោកបំបួសជំនួសឧបជ្ឈាយ៍***

*ដូច្នេះនេះ ក៏មានន័យនេះដូចគ្នា ។*

*<u>តែក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>*

★ **សយំ បព្វាជេតព្វោតិ** ឯត្ថ កេសមស្សុំ ឱហារេត្វាតិអាទិវចនតោ កេសច្ឆេទនកាសាយច្ឆាទនធានានិ បព្វជ្ជា នាម, តេសុ បច្ឆិមទ្វយំ ភិក្ខូហិ ឯវ កាតព្វំ ការេតព្វំ វា ។

★ " **បព្វាជេហី"តិ** ឥទំ តិវិធម្បិ សន្ធាយ វុត្តំ ។

*ក្នុងពាក្យថា **គប្បីឱ្យបព្វជ្ជាដោយខ្លួនឯង** គប្បីជ្រាបសេចក្ដីវិនិច្ឆ័យដូច្នេះ, ការកោរសក់ ការស្លៀកដណ្ដប់សំពត់កាសាយៈ និងការឱ្យសរណគមន៍ ឈ្មោះថា **ឱ្យបព្វជ្ជា**, ព្រោះព្រះពុទ្ធដីកា ថា "ឱ្យកោរសក់ និងពុកមាត់ ដូច្នេះជាដើម" ។ បណ្ដាកិច្ចទាំង ៣ យ៉ាងនោះ, កិច្ច ២ ខាងចុង គឺពួកភិក្ខុគប្បីធ្វើដោយខ្លួនឯង ឬប្រើអ្នកដទៃឱ្យធ្វើក៏បាន ។*

*ពាក្យថា **លោកចូរឱ្យកុលបុត្រនេះបួសចុះ** ដូច្នេះនេះ គឺលោកអាចារ្យពោលសំដៅយក សូម្បីវិធីទាំង ៣ (គឺការកោរសក់ ១ ការស្លៀកដណ្ដប់សំពត់កាសាយៈ ១ និងការឱ្យសរណគមន៍ ១ ) ។*

*ក្នុងគម្ពីរបាចិត្យាទិយោជនា ពោលថា:*

★ **ឧបជ្ឈាយំ ឧទ្ទិស្សាតិ** ឧបជ្ឈាយស្ស វេយ្យាវច្ចករដ្ឋាននិយមំ កត្វា ។ បព្វជ្ជាកម្មេ អត្តនោ ឥស្សរិយមកត្វាតិ អត្ថោ ។ ឧបហារេន ភិក្ខុនា កេសច្ឆេទនំ កាសាយច្ឆាទនំ ទានត្តិ តីណិ កិច្ចានិ កាតព្វានិ យេវ ។

*ពាក្យថា លោកបំបួសជំនួសព្រះឧបជ្ឈាយ៍ ដូច្នេះនេះ មានសេចក្ដីថា គឺភិក្ខុធ្វើតាមទំនងនៃខ្លួន ដែលឋិតនៅក្នុងឋានៈជាវេយ្យាវច្ចករបស់ឧបជ្ឈាយ៍ ។ អធិប្បាយថា មិនធ្វើនូវខ្លួនឱ្យជាឥស្សរ គឺភាពជាធំក្នុងបព្វជ្ជាកម្មទេ ។ គឺ ភិក្ខុកំលោះគប្បីធ្វើបានពិតនូវកិច្ចទាំង ៣ យ៉ាង គឺការកោរសក់ ១ ការស្លៀកសំពត់កាសាយ: ១ ការឱ្យសរណ:១ ។*

★ កេចិ *"សរណានិ* បន សយំ *ទាតព្វានី"*តិ ចាបំ ឥធានេត្វា ឧបហារេន ភិក្ខុនា សរណានិ ន ទាតព្វានីតិ វទន្តិ ។ *អាចារ្យពួកខ្លះពោលថា ភិក្ខុកម្លោះមិនគប្បីឱ្យសរណ:ទាំងឡាយទេ, ព្រោះលោកអាចារ្យមិនបាននាំបាលីមកថា "ចំណែកឯសរណ:ទាំងឡាយ គឺភិក្ខុកំលោះគប្បីឱ្យដោយខ្លួនឯង" ។*

តំ ន គហេតព្វំ, ឧបហារស្ស ភិក្ខុត្តា, ភិក្ខូនំ

បព្វាជេតុំ លភនត្តា ច ។

ពាក្យអាចារ្យនោះ មិនគប្បីកាន់យកទេ, ព្រោះភិក្ខុកំលោះ ក៏ជាភិក្ខុផង, ព្រោះភិក្ខុទាំងឡាយ រមែងបានដើម្បីបំបួសផង ។

**អ្នកបួសជាភិក្ខុមិនកោរសក់ និងពុកមាត់ ក៏បួសឡើងដែរ**

ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:

★ ឧបជ្ឈាយោ ចេ កេសមស្សុំ ឱរោបនាទីនិ អកត្វា បព្វជេតុំ សរណានិ ទេតិ, ន រុហតិ បព្វជ្ជា ។ កម្មវាចំ សាវេត្វា ឧបសម្បទេតិ, រុហតិឧបសម្បទា ។ អប្បត្តចីវរានំ ឧបសម្បទាសិទ្ធិទស្សនតោ, កម្មវិបត្តិយា អភាវតោ ចេតំ យុជ្ជតេវាតិ ឯកេ ។ អាចារ្យពួកខ្លះពោលថា ប្រសិនបើឧបជ្ឈាយ៍មិនធ្វើនូវការកោរសក់ និងពុកមាត់ជាដើម ហើយឱ្យនូវសរណៈតែម្យ៉ាង, ដើម្បីប្រយោជន៍ដល់បព្វជ្ជា, បព្វជ្ជា រមែងមិនឡើងឡើយ ។ ចំណែកឯអាចារ្យអ្នកសូធ្យ នូវកម្មវាចា ហើយឱ្យនូវឧបសម្បទាវិញ ឧបសម្បទា រមែងឡើង ។ ព្រោះលោកសម្ដែងនូវកិរិយាសម្រេចនូវឧបសម្បទា របស់បុគ្គលដែលមិនមានបាត្រ និងចីវរផង, ព្រោះមិនមានការវិបត្តិទៅនៃកម្មផង, ពាក្យអាចារ្យនោះ ពិតជាត្រឹមត្រូវហើយ ។

*ក្នុងគម្ពីរអដ្ឋកថា ពោលទុកទៀតថាៈ*

សចេ ទហរភិក្ខុ នត្ថិ សាមណេរោបិ វត្តព្វោ ឯតំ **ខណ្ឌសីមំ នេត្វា បព្វាជេត្វា** កាសាយានិ អច្ឆាទេត្វា ឯហីតិ ។ សរណានិ បន សយំ ទាតព្វានិ ។

*បើភិក្ខុកំលោះមិនមាន, ឧបជ្ឈាយ៍គប្បីប្រាប់សាមណេរ ក៏បានថា "អ្នកចូរនាំអ្នកនេះ ទៅកាន់ខណ្ឌសីមា ហើយឱ្យបព្វជ្ជា ហើយឱ្យស្លៀកដណ្តប់សំពត់កាសាយៈស្រេចហើយ ទើបមក" ចំណែកសរណៈព្រះឧបជ្ឈាយ៍ គប្បីឱ្យដោយខ្លួនឯង ។*

ឯវំ ភិក្ខុនាវ បព្វាជិតោ ហោតិ , បុរិសំ ហិ **ភិក្ខុតោ អញ្ញោ បព្វាជេតុំ ន លភតិ** មាតុគាមំ ភិក្ខុនិតោ អញ្ញោ ។ *កុលបុត្រនោះ ជាការដែលភិក្ខុនុះឯង ឱ្យបួសហើយ ដោយប្រការដូច្នេះ ។ មែនពិត មនុស្សដទៃក្រៅអំពីភិក្ខុមិនបានដើម្បីឱ្យបុរសបួស ។ មនុស្សដទៃក្រៅអំពីភិក្ខុនី មិនបានដើម្បីឱ្យមាតុគ្រាមបួសដូចគ្នា ។*

សាមណេរោ បន សាមណេរី វា អាណត្តិយា កាសាយានិ ទាតុំ លភតិ ។ កេសោរោបនំ យេន កេនចិ កតំ សុកតំ ហោតិ ។

*ចំណែកសាមណេរ ឬសាមណេរី បានដើម្បីនឹងឱ្យសំពត់*

កាសាយៈតាមពាក្យបង្គាប់ ។ ការកោរសក់ អ្នកណាមួយធ្វើហើយ ក៏ជាការធ្វើហើយដោយល្អ ។

<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថាៈ</u>

★**ខណ្ឌសីមំ នេត្វាតិ** ភណ្ឌុកម្មាបោចនបរិហារណត្ថំ វុត្តំ ។ តេន សភិក្ខុកេ វិហារេ អញ្ញម្បិ "ឯតស្ស កេសេ ឆិន្ទា"តិ វត្តុំ ន វដ្តតិ ។ ពាក្យថា *នាំទៅកាន់ខណ្ឌសីមា* ដូច្នេះនេះ គឺលោកពោលទុក ដើម្បីជៀសវាងការប្រាប់នូវភណ្ឌុកម្ម ។ ព្រោះហេតុនោះ ការពោលសូម្បីជាមួយមនុស្សដទៃ ក្នុងវត្តដែលមានភិក្ខុ ថា "លោកចូរកោរសក់កុលបុត្រនេះ" ដូច្នេះ មិនគួរ ។

★ **បព្វាជេត្វាតិ** កេសច្ឆេទនំ សន្ធាយ វទតិ ។ ពាក្យថា *ឱ្យបព្វជ្ជា* ដូច្នេះនេះ គឺលោកពោលសំដៅដល់ការកោរសក់ ។

★ **ភិក្ខុតោ អញ្ញោ បព្វាជេតុំ ន លភតីតិ** ធានំ សន្ធាយ វុត្តំ ។ ពាក្យថា *មនុស្សដទៃក្រៅអំពីភិក្ខុមិនបាន ដើម្បីឱ្យបួសបួស* ដូច្នេះនេះ គឺលោកអាចារ្យពោលសំដៅដល់ការឱ្យសរណៈ ។

<u>*ក្នុងគម្ពីរវិនយាលង្ការដីកា ពោលថា:*</u>

★ **ឯកសីមាយញ្ច អញ្ញេបិ ភិក្ខូ អត្ថីតិ ឥមិនា** ឯកសីមាយំ ភិក្ខុម្ហិ អសតិ ភណ្ឌកម្មាបេចនកិច្ចំ នត្ថីតិ ទស្សេតិ ។ *ដោយពាក្យថា ភិក្ខុទាំងឡាយ សូម្បីដទៃមានក្នុងសីមាជាមួយគ្នា ដូច្នេះនេះ លោកអាចារ្យសម្តែងថា កាលមិនមានភិក្ខុ នៅក្នុងសីមាជាមួយគ្នាទេ កិច្ចដែលត្រូវប្រាប់ភណ្ឌកម្ម ក៏មិនមាន ។*

★ **បព្វាជេត្វាតិ** កេសាទិច្ឆេទនមេវ សន្ធាយ វុត្តំ កាសាយានិ អច្ឆាទេត្វាតិ វិសុំ វុត្តត្តា ។

*ពាក្យថា* **ឱ្យបព្វជ្ជា** *ដូច្នេះ គឺលោកពោលសំដៅយកការកោរសក់ជាដើមតែម្យ៉ាង, ព្រោះជាពាក្យដែលលោក ពោលផ្សេងគ្នាថាឱ្យស្លៀកដណ្តប់នូវសំពត់កាសាយៈទាំងឡាយដូច្នេះ ។*

<u>*ក្នុងគម្ពីរសារត្ថទីបនី និងវិមតិវិនោទនីដីកា ពោលថា:*</u>

★ **បព្វាជេតុំ ន លភតីតិ** ធានំ សន្ធាយ វុត្តំ អនុបសម្បន្នេន ភិក្ខុអាណត្តិយា ទិន្នម្បិ សរណំ ន រុហតិ ។ *ពាក្យថា (មនុស្សដទៃក្រៅអំពីភិក្ខុ) មិនបានដើម្បីឱ្យបុរសបួស ដូច្នេះនេះ គឺលោកអាចារ្យ ពោលសំដៅដល់*

*ការឱ្យសរណគមន៍, សរណគមន៍ដែលអនុបសម្បន្ន សូម្បីឱ្យហើយ តាមពាក្យប្រើរបស់ភិក្ខុ រមែងមិនឡើង ។*

**បព្វជ្ជាកថាចប់ ។**

# ៤_ភណ្ឌុកម្មកថា

<u>ក្នុងវិនយបិដក ភាគ ៦ ទំព័រ ២៥៤ ពោលថា:</u>

អនុជានាមិ ភិក្ខវេ សង្ឃំ អបលោកេតុំ ភណ្ឌុ-
កម្មាយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុ
អបលោកន៍ (ប្រាប់)សង្ឃ ហើយសឹមធ្វើភណ្ឌុកម្ម ។

## ការប្រាប់ភណ្ឌុកម្ម

<u>ក្នុងគម្ពីរព្រះអដ្ឋកថា ពោលថា:</u>

ត្រូវនិមន្តភិក្ខុទាំងឡាយ អ្នកស្ថិតនៅក្នុងសីមាឱ្យប្រជុំគ្នា
ហើយ នាំបព្វជ្ជាបេក្ខៈទៅក្នុងសីមានោះ ហើយប្រាប់៣ ដង ឬ
២ ដង ឬតែមួយដងថា:

- សង្ឃំ ភន្តេ ឥមស្ស ទារកស្ស ភណ្ឌុកម្មំ
អាបុច្ឆាមិៈ បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំសូមប្រាប់នូវភណ្ឌុកម្ម
របស់ក្មេងនេះនឹងសង្ឃ ។

- ឥមស្ស ទារកស្ស ភណ្ឌុកម្មំ អាបុច្ឆាមិ :
ខ្ញុំសូមប្រាប់នូវភណ្ឌុកម្ម របស់ក្មេងនេះ (ដល់សង្ឃ) ។

- ឥមស្ស សមណករណំ អាបុច្ឆាមិ :

ខ្ញុំសូមប្រាប់នូវការធ្វើក្មេងនេះ ឱ្យទៅសមណៈ(ដល់សង្ឃ) ។

- ឥមស្ស បព្វាជនំ អាបុច្ឆាមិ : ខ្ញុំសូមប្រាប់នូវការបំបួសរបស់ទារកនេះ ។

- អយំ សមណោ ហោតុកាមោ : ទារកនេះប្រាថ្នាដើម្បីជាសមណៈ ។

- អយំ បព្វជិតុកាមោៈ ទារកនេះប្រាថ្នាដើម្បីបព្វជ្ជា ។

★ ប្រាប់ភណ្ឌុកម្មដូច្នេះណាមួយ គួរទាំងអស់ ។

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

★ **សីមាបរិយាបន្នេតិ** ពទ្ធសីមាយ សតិ តទន្តោគធេ អសតិ ឧបចារសីមន្តោគធេតិ អត្ថោ ។

ពាក្យថា **អ្នកស្ថិតនៅក្នុងសីមា** ដូច្នេះនេះ មានសេចក្តីអធិប្បាយថាកាលព័ទ្ធសីមាមាន, គប្បីឱ្យចូលទៅក្នុងព័ទ្ធសីមានោះ, កាលព័ទ្ធសីមានោះ មិនមានទេ, គប្បីឱ្យចូលទៅខាងក្នុងឧបចារសីមា ។

ឯត្ថ ច កិញ្ចាបិ "អនុជានាមិ, ភិក្ខវេ, សង្ឃំ អបលោកេតុំ ភណ្ឌុកម្មាយា"តិ ឯត្តកមេវ វុត្តំ, ន បន អនបលោកេន្តស្ស អាបត្តិ វុត្តា, តថាបិ អដ្ឋកថាយំ "សព្វេ អាបុច្ឆិតា អម្ហេហី"តិ សញ្ញិនោ ។ បេ ។ បព្វា-

ជេន្តស្សបិ អនាបត្តី”តិ វុត្តត្តា សញ្ចិច្ច អនាបុច្ឆា គេសេ ឱហារេន្តស្ស ទុក្កដមេវាតិ ទដ្ឋព្វំ ។ ក៏ក្នុងសេចក្តីនេះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ត្រឹមតែប៉ុណ្ណោះថា “ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឱ្យភិក្ខុអបលោកន៍ (ប្រាប់) សង្ឃហើយសឹមធ្វើភណ្ឌុកម្ម” មិនបានពោលថា ជាអាបត្តិដល់ភិក្ខុកាលមិនបានប្រាប់ ក៏ពិតមែនហើយ, ទុកជាដូច្នេះ បណ្ឌិតគប្បីជ្រាបថា រមែងត្រូវអាបត្តិទុក្កដពិត ដល់ភិក្ខុកាលក្លែងមិនប្រាប់ ហើយកោរនូវសក់ទាំងឡាយ ព្រោះលោកពោលទុកក្នុងអដ្ឋកថា ថា “កាលភិក្ខុមានសេចក្តីសំគាល់ថា យើងប្រាប់អស់គ្រប់រូបហើយ ។ល ។ ជាអនាបត្តិដល់ភិក្ខុសូម្បីកាលឱ្យនូវបព្វជ្ជា” ដូច្នេះ ។

## ការបួសជាសាមណេរ ជាកម្មស្រាល

<u>ក្នុងគម្ពីរព្រះអដ្ឋកថា ពោលថា:</u>

បើស្ថានទីនៃភិក្ខុអ្នកជាសភាគ:គ្នាមាននៅ គឺឱកាសជាទីកំណាត់ប្រាកដថា “ ភិក្ខុ ១០ រូប ឬ ២០ រូប ឬ ៣០ រូបនៅ(ជាមួយគ្នា) នឹងទៅកាន់ឱកាសដែលភិក្ខុទាំងនោះឈរហើយ ឬឱកាសដែលអង្គុយហើយ ប្រាប់ដោយន័យមុននោះឯងក៏បាន ។ សូម្បីនឹងពីងពួកភិក្ខុកំលោះ ឬពួកសាមណេរ រៀរ

តែបព្វជ្ជាបេក្ខៈចេញ ឱ្យប្រាប់ដោយន័យជាដើមថា ៖

"**ឯកោ ភន្តេ បព្វជ្ជាបេក្ខោ អត្ថិ, តស្ស ភណ្ឌុកម្មំ អាបុច្ឆាម** ។ "បពិត្រលោកដ៏ចម្រើន មានបព្វជ្ជាបេក្ខៈ មួយរូប ពួកយើងសូមប្រាប់នូវភណ្ឌុកម្ម របស់បព្វជ្ជាបេក្ខៈនោះ" ដូច្នេះក៏គួរ ។ បើភិក្ខុពួកខ្លះ ចូលកាន់សេនាសនៈ ឬគុម្ពឈើជាដើម លង់លក់ក្តី ធ្វើសមណធម៌ក្តី ចំណែកភិក្ខុ សាមណេរអ្នកប្រាប់ សូម្បីតាមរកក៏មិនជួប ទើបមានសេចក្តី សម្គាល់ថា យើងប្រាប់អស់គ្រប់រូបហើយ ដែលឈ្មោះថា បព្វជ្ជាជាកម្មស្រាល ព្រោះហេតុនោះ បព្វជ្ជាបេក្ខនោះបួសហើយ ជាការបួសដោយល្អពិត, មិនជាអាបត្តិសូម្បីដល់ឧបជ្ឈាយ៍ដែលបំបួស ។ តែបើវត្តធំ ជាទីនៅរបស់ភិក្ខុច្រើនពាន់រូប សូម្បីនឹងនិមន្តភិក្ខុទាំងអស់ឱ្យប្រជុំគ្នា ក៏ធ្វើបានដោយលំបាក, មិនចាំបាច់ត្រូវពោលដល់ការប្រាប់តាមលំដាប់ទេ, ត្រូវស្ថិតនៅក្នុងខណ្ឌសីមា ឬទៅកាន់ស្ទឹង ឬសមុទ្រជាដើម ហើយទើបឱ្យបួស ។ ចំណែកអ្នកណា ជាមនុស្សកោរសក់ថ្មី ឬសឹកចេញទៅ ឬជាមនុស្សណាមួយ ក្នុងពួកអ្នកបួសមាននិគ្រន្ថជាដើម មានសក់ត្រឹម ២ ធ្នាប់ ឬខ្វះជាង ២ ធ្នាប់, កិច្ចដែលនឹងត្រូវកោរសក់របស់អ្នកនោះមិនមាន, ព្រោះហេតុនោះ សូម្បីនឹងមិនប្រាប់

ភណ្ឌុកម្មឱ្យបុគ្គលប្រាកដដូច្នោះ, ហើយបំបួសក៏គួរ ។

ទុន្ទុលាភិវិត្តកោសោ បន យោ ហោតិ អន្តមសោ **ឯកសិខាមត្តធរោបិ** សោ ភណ្ឌុកម្មំ អាបុច្ឆិត្វាវ បព្វា-ជេតព្វោ ។ ចំណែកអ្នកណា មានសក់វែងលើសជាង ២ ធ្នាប់ ដោយហោចទៅសូម្បីទុកសក់ត្រឹមតែមួយជុក អ្នកនោះ ភិក្ខុត្រូវប្រាប់ភណ្ឌុកម្មជាមុនសិន ទើបឱ្យបួសបាន ។

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថាៈ</u>

★ **ឯកសិខាមត្តធរោតិ** ឯត្ថ ឯកេន កោសេន សិខា ឯកសិខាតិ វទន្តិ ។ ឯកកោសម្បិ បន អនាបុច្ឆា ជិន្ទិតុំ ន វដ្តតិយេវ ។ ក្នុងពាក្យថា សូម្បីទុកសក់ត្រឹមតែមួយជុក ដូច្នេះនេះ អាចារ្យទាំងឡាយពោលថា ជុកតែ១ សរសៃ ឈ្មោះថា ឯកសិខា ។ ចំណែកភិក្ខុទាំងឡាយកាលមិនប្រាប់(ភណ្ឌុ-កម្ម) រមែងមិនគួរដើម្បីកាត់នូវសក់សូម្បីតែ ១ សរសៃ ។

## ស្នៀកសំពត់ដោយខ្លួនឯងបួសមិនឡើង

<u>ក្នុងគម្ពីរអដ្ឋកថា ពោលទៀតថាៈ</u>

អថាបិស្ស ហត្ថេ អទត្វា អាចរិយោ វា ឧបជ្ឈាយោ វា សយមេវ អច្ឆាទេតិ វដ្តតិ ។ សចេបិ អញ្ញំ ទហរំ វា

សាមណេរំ វា ឧបាសកំ វា អាណាបេតិ អាវុសោ ឯតានិ កាសាយានិ គហេត្វា ឯតំ អច្ឆាទេហីតិ តំយេវ វា អាណាបេតិ ឯតានិ គហេត្វា អច្ឆាទេហីតិ សព្វំ វដ្តតិ ។ សព្វំ ហេតំ តេន ភិក្ខុនាវ ទិន្នំ ហោតិ ។ *សូម្បីបើអាចារ្យ ឬឧបជ្ឈាយ៍ នឹងមិនប្រគល់ឱ្យក្នុងដៃរបស់កុលបុត្រ, ហើយស្លៀកដណ្តប់ឱ្យខ្លួនឯងតែម្តង* ***រមែងគួរ*** *។ ប្រសិនបើបង្គាប់អ្នកដទៃជាភិក្ខុក៏ដោយ សាមណេរក៏ដោយ ឧបាសកក៏ដោយថា "អ្នកមានអាយុ ចូរកាន់យកសំពត់កាសាយៈទាំងនេះទៅស្លៀកដណ្តប់ឱ្យអ្នកនេះ" ឬបង្គាប់កុលបុត្រនោះតែម្តង ថា "អ្នកចូរកាន់យកសំពត់កាសាយៈនេះ ទៅស្លៀកដណ្តប់" ដូច្នេះ* ***គួរគ្រប់យ៉ាង*** *។ មែនពិត សំពត់កាសាយៈនោះទាំងអស់ឈ្មោះថា ភិក្ខុនោះឯងឱ្យហើយ ។*

យំ បន និវាសនំ វា បារុបនំ វា អនាណត្តិយា និវាសេតិ វា បារុបតិ វា, តំ អបនេត្វា បុន ទាតព្វំ ។ ភិក្ខុនា ហិ សហត្ថេន វា អាណត្តិយា វា ទិន្នមេវ កាសាវំ វដ្តតិ, **អទិន្នំ ន វដ្តតិ**, សចេបិ តស្សេវ សន្តកំ ហោតិ, កោ បន វាទោ ឧបជ្ឈាយមូលកេ ។

*តែកុលបុត្រស្លៀកឬដណ្តប់ នូវសំពត់ស្លៀក ឬសំពត់*

ដណ្ដប់ឯណា ដោយមិនបានបន្ទាប់, គប្បីផ្លាស់សំពត់ស្បៀក ឬសំពត់ដណ្ដប់នោះចេញ ហើយឱ្យជាថ្មី ។ ព្រោះសំពត់កាសាយៈ ដែលភិក្ខុឱ្យដោយដៃរបស់ខ្លួន ឬដោយបន្ទាប់ប៉ុណ្ណោះ ទើបគួរ, ភិក្ខុមិនបានឱ្យមិនគួរ, សូម្បីសំពត់កាសាយៈនោះ នឹងជារបស់កុលបុត្រនោះឯង នឹងចាំបាច់ពោលទៅថ្វីក្នុងសំពត់កាសាយៈ ដែលមានឧបជ្ឈាយ៍ជាមូលសោត ។

<u>ក្នុងគម្ពីរវជិរពុទ្ធិ សារត្ថទីបនី និងវិមតិវិនោទនីដីកាពោលថា:</u> អទិន្នំ ន វដ្ដតីតិ ឥមិនា បព្វជ្ជា ន រុហតីតិ ទស្សេតិ ។ ដោយពាក្យថា ភិក្ខុមិនបានឱ្យ រមែងមិនគួរ ដូច្នេះ នេះ លោកអាចារ្យសម្ដែងថា បព្វជ្ជា រមែងមិនឡើង ។

**ភណ្ឌុកម្មកថាចប់ ។**

# ៥_នាសនង្គកថា

<u>ក្នុងវិនយបិដក ភាគ ៦ ទំព័រ ២៨២ ពោលថាៈ</u>

★ អនុជានាមិ ភិក្ខវេ ទសហង្គេហិ សមន្នាគតំ សាមណេរំ នាសេតុំ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឱ្យភិក្ខុញុំាងសាមណេរ ដែលប្រកបដោយអង្គទាំងឡាយ ១០ ឱ្យវិនាស ។

**នាសនង្គៈ ១០ របស់សាមណេរ**

**១-បាណាតិបាតី ហោតិ** *សាមណេរធ្វើសត្វមានជីវិតឱ្យធ្លាក់ចុះកន្លង (គឺសម្លាប់សត្វ)*

**២-អទិន្នាទាយី ហោតិ** *សាមណេរកាន់យកវត្ថុដែលគេមិនបានឱ្យ (ដោយកាយ ឬដោយវាចា)*

**៣-អព្រហ្មចារី ហោតិ** *សាមណេរប្រព្រឹត្តធម៌មិនប្រសើរ (គឺសេពមេថុនធម្ម)*

**៤-មុសាវាទី ហោតិ** *សាមណេរពោលពាក្យកុហក*

**៥-មជ្ជបាយី ហោតិ** *សាមណេរផឹកទឹកស្រវឹង*

*( គឺសុរា និង មេរ័យ )*

៦–ពុទ្ធស្ស អវណ្ណំ ភាសតិ សាមណេរពោលតិះដៀលព្រះពុទ្ធ

៧–ធម្មស្ស អវណ្ណំ ភាសតិ សាមណេរពោលតិះដៀលព្រះធម៌

៨–សង្ឃស្ស អវណ្ណំ ភាសតិ សាមណេរពោលតិះដៀលព្រះសង្ឃ

៩–មិច្ឆាទិដ្ឋិកោ ហោតិ សាមណេរមានទិដ្ឋិខុស

១០–ភិក្ខុនីទូសកោ ហោតិ សាមណេរប្រទូស្តភិក្ខុនី

**វិនាសមាន ៣ ប្រការ គឺ**

១–សំវាសនាសនា វិនាសខានបាននៅរួមជាមួយនឹងព្រះសង្ឃដោយការធ្វើកម្ម ។

២–លិង្គនាសនា វិនាសចាកភេទ គឺត្រូវផ្សឹកចេញ

៣–ទណ្ឌកម្មនាសនា វិនាសដោយត្រូវទណ្ឌកម្ម ។

★ អនុជានាមិ ភិក្ខវេ ទសហង្គេហិ សមន្នាគតំ សាមណេរំ នាសេតុន្តិ ឯត្ថ កណ្ដកសិក្ខាបទវណ្ណនាយំ វុត្តាសុ តីសុ នាសនាសុ លិង្គនាសនាវ អធិប្បេតា តស្មា យោ បាណាតិបាតាទីសុ ឯកម្បិ កម្មំ ករោតិ សោ

លិង្គនាសនាយ នាសេតព្វោ ។ យថា ច ភិក្ខូនំ បាណាតិ-បាតាទីសុ នានាអាបត្តិយោ ហោន្តិ ន តថា សាមណេរានំ ។

*បណ្តានាសនា ៣ ប្រការ ដែលពោលហើយ ក្នុងវណ្ណនានៃ កណ្ឌកសិក្ខាបទ, លិង្គនាសនាប៉ុណ្ណោះ ដែលលោកប្រាថ្នាយក ក្នុងពាក្យថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុញុំាង សាមណេរដែលប្រកបដោយអង្គទាំងឡាយ ១០ ឱ្យវិនាស" ដូច្នេះ, ព្រោះហេតុនោះ ក្នុងកម្មទាំងឡាយ មានបាណាតិបាត ជាដើម សាមណេរណា រមែងធ្វើនូវកម្មសូម្បីតែម្យ៉ាង, សាមណេរនោះ ដែលភិក្ខុគប្បីឱ្យវិនាស ដោយលិង្គនាសនា ។ ដូចជាភិក្ខុទាំងឡាយ រមែងត្រូវអាបត្តិផ្សេងៗគ្នា ព្រោះកម្មទាំងឡាយ មានបាណាតិបាតជាដើម យ៉ាងណា, សាមណេរទាំងឡាយនឹងបានជាយ៉ាងនោះ ក៏ទេ ។*

## សាមណេរដាច់ត្រៃសរណគមន៍ នៅសល់តែភេទ

★ សាមណេរោ ហិ កុន្តកិបិល្លិកម្បិ មារេត្វា មង្គុណ្ណកម្បិ ភិន្ទិត្វា នាសេតព្វតំយេវ បាបុណាតិ តាវទេវស្ស សរណ**គមនានិ** ច **ឧបជ្ឈាយគ្គហណញ្ច សេនាសនគ្គាហោ** ច **បដិប្បស្សម្ភតិ** សង្ឃលាភំ ន លភតិ **លិង្គមត្តមេវ ឯកំ អវសិដ្ឋំ ហោតិ** ។ *ព្រោះថា សាមណេរ*

*កាលញ៉ាំងស្រមោចខ្មៅ និងស្រមោចក្រហមឱ្យស្លាប់ក្តី ញ៉ាំងពងសង្កើចក្តី រមែងដល់ភាពជាអ្នកគួរឱ្យវិនាសពិត ។ សរណ-គមន៍ក្តី ការកាន់ឧបជ្ឈាយ៍ និងការកាន់សេនាសនៈរបស់លោកក្តី រមែងរម្ងាប់ក្នុងខណៈនោះ, លោករមែងមិនបានលាភសង្ឃ, សល់នៅត្រឹមតែភេទមួយប៉ុណ្ណោះ ។*

សោ សចេ អាកិណ្ណទោសោវ ហោតិ អាយតឹ សំវរេ ន តិដ្ឋតិ និក្កឌ្ឍិតព្វោ ។ អថ សហសា វិរជ្ឈិត្វា ឥទ្ធមយា កតន្តិ បុន សំវរេ ឋាតុកាមោ ហោតិ លិង្គនាសនកិច្ចំ នត្ថិ ។ *បើសាមណេរនោះ ជាអ្នកមានទោស ដោយការប្រឡូកប្រឡំ, ជាអ្នកមិនតាំងនៅក្នុងសំវរៈតទៅ ភិក្ខុគប្បីកំចាត់ចេញ ។ បើលោកខុសភ្លាំងភ្លាត់ទៅហើយ ព្រមទទួលថា "សេចក្តីអាក្រក់ គឺខ្ញុំបានធ្វើហើយ" ដូច្នេះ ជាអ្នកប្រាថ្នានឹងតាំងនៅក្នុងសំវរៈតទៅទៀត, កិច្ចគឺលិង្គនាសនារមែងមិនមាន ។*

*ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:*

☆ **"សេនាសនគ្គាហោ ច បដិប្បស្សម្ភតី"តិ** ឥមិនា វស្សច្ឆេទំ ទស្សេតិ ។ ឧបសម្បន្នានម្បិ បារាជិកសមាបត្តិយា សរណគមនាទិ សាមណេរភាវស្សាបិ

វិនស្សនតោ សេនាសនគ្គាហោ ច បដិប្បស្សម្ភតិ សង្ឃលាភម្បិ តេ ន លភន្តីតិ វេទិតព្វំ ។

*ដោយពាក្យថា* ***ការកាន់សេនាសនៈរបស់លោក រមែងរម្ងាប់*** *ដូច្នេះនេះ គឺលោកអាចារ្យសម្ដែងនូវកិរិយាដាច់វស្សា ។ បណ្ឌិតគប្បីជ្រាបថា ការកាន់យកនូវសេនាសនៈ រមែងរម្ងាប់ទៅព្រោះការត្រូវអាបត្តិបារាជិក របស់ឧបសម្បន្នក៏មាន, ព្រោះការវិនាសទៅនៃភាពជាសាមណេរ មានការទទួលនូវសរណៈជាដើមក៏មាន, ភិក្ខុនិងសាមណេរនោះ រមែងមិនបាន សូម្បីនូវលាភរបស់សង្ឃទេ ។*

## សាមណេរដាច់ត្រៃសរណគមន៍ ត្រូវរាប់វស្សាថ្មីវិញ

*ក្នុងគម្ពីរអដ្ឋកថា ពោលទៀតថា:*

★ យថានិវត្ថបារុតស្សេវ សរណានិ ទាតព្វានិ ឧប-ជ្ឈាយោ ទាតព្វោ, សិក្ខាបទានិ បន សរណគមនេនេវ ឥជ្ឈន្តិ ។ សាមណេរានញ្ហិ សរណគមនំ **ភិក្ខូនំ ឧបសម្បទកម្មវាចាសទិសំ**, តស្មា ភិក្ខូនំ វិយ ចតុបារិសុទ្ធិសីលំ, ឥមិនា ទសសីលានិ សមាទិន្នានេវ ហោន្តិ, ឯវំ សន្តេបិ ទឡ្ហីករណត្ថំ អាយតី សំវរេ

**បតិដ្ឋាបនត្ថំ បុន ធាតព្វានិ ។** *ភិក្ខុគប្បីឱ្យសរណគមន៍ទាំងឡាយ គប្បីឱ្យឧបជ្ឈាយ៍ដល់លោកដែលនៅស្លៀកដណ្តប់ដូចពីដើមនោះឯង, ចំណែកសិក្ខាបទទាំងឡាយ រមែងសម្រេចដោយសរណគមន៍នោះឯង ។ ពិតមែន សរណគមន៍របស់សាមណេរទាំងឡាយ ប្រាកដដូចគ្នានឹងកម្មវាចាក្នុងឧបសម្បទារបស់ភិក្ខុទាំងឡាយ ព្រោះហេតុនោះ សីល ១០ ជាការដែលសាមណេរសូម្បីនេះសមាទានហើយពិត ដូចចតុប្បារិសុទ្ធិសីលដែលភិក្ខុទាំងឡាយសមាទានហើយដូច្នោះ ។ សូម្បីដូច្នេះ សីល ១០ ក៏គួរឱ្យទៀតដើម្បីឱ្យមាំ គឺ ដើម្បីញុំាងសាមណេរឱ្យតាំងនៅក្នុងសំវរៈតទៅ ។*

*<u>ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:</u>*

☆ **ភិក្ខូនំ ឧបសម្បទកម្មវាចាសទិសន្តិ** ឯត្ថ "យថា ឧបសម្បន្នោ សិក្ខំ បច្ចក្ខាយ យថានិវត្ថបារុតោវ ហុត្វា បច្ឆា ឧបសម្បន្នោ, បុព្វេ អត្តនោ នវកតរស្ស សមានវស្សិកស្ស បុន វន្ទនាទីនិ ករោតិ, ឯវំ សាមណេរោបិ, បុន គហិតសរណោ តតោ បុព្វេ អត្តនោ នវកតរស្ស សមានវស្សិកស្ស សាមណេរស្ស បុន វន្ទនាទីនិ ករោតិ ។

ពាក្យថា ប្រាកដដូចជាឧបសម្បទកម្មវាចា របស់ភិក្ខុទាំងឡាយ ដូច្នេះនេះ មានសេចក្តីថា ឧបសម្បន្នជាអ្នកស្លៀកដណ្តប់យ៉ាងណា ហើយពោលលានូវសិក្ខា, ក្នុងកាលជាខាងក្រោយមកជាឧបសម្បន្ន (វិញ) តែងធ្វើនូវកិច្ចមានការថ្វាយបង្គំជាដើម ដល់ភិក្ខុដែលមានវស្សាទីជាងខ្លួន ឬស្មើនឹងខ្លួនក្នុងកាលមុនវិញយ៉ាងណា, សូម្បីសាមណេរជាអ្នកមានសរណៈគឺខ្លួនកាន់យកហើយម្តងទៀត, តពីនោះទៅ ត្រូវធ្វើនូវកិច្ចមានការថ្វាយបង្គំជាដើម ចំពោះសាមណេរ ដែលមានវស្សាទីជាងខ្លួន ឬស្មើនឹងខ្លួនក្នុងកាលមុនវិញ ក៏យ៉ាងនោះដែរ ។

**សាមណេរក៏ត្រូវចូលវស្សាដែរ**

<u>ក្នុងគម្ពីរអដ្ឋកថា ពោលទៀតថា:</u>

☆ សចេ បុរិមិកាយ បុន សរណានិ គហិតានិ បច្ឆិមិកាយ វស្សាវាសិកំ លច្ឆតិ ។ សចេ បច្ឆិមិកាយ គហិតានិ, សង្ឃេន អបលោកេត្វា លាភោ ទាតព្វោ ។

បើថាសរណគមន៍ទាំងឡាយ ដែលសាមណេរនោះទទួលទៀត ក្នុងវស្សូបនាយិកាដើម, លោកនឹងបានសំពត់ចំណាំវស្សា ក្នុងវស្សូបនាយិកាក្រោយ ។ បើសាមណេរទទួលសរណគមន៍ ក្នុងវស្សូបនាយិកាក្រោយ, លាភគឺសង្ឃគប្បី

អបលោកន៍ ឱ្យដល់លោក ។

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

☆ **បុរិមិកាយ បុន សរណានិ គហិតានីតិ** សរណគ្គហណេន សហ តទហេវស្ស វស្សូបគមនម្បិ ធស្សេតិ ។ ពាក្យថា *សរណគមន៍ទាំងឡាយដែលសាមណេរនោះ ទទួលទៀត ក្នុងវស្សូបនាយិកាដើម ដូច្នេះ គឺលោកអាចារ្យសម្តែងសូម្បីនូវការចូលវស្សារបស់សាមណេរនោះ នៅក្នុងថ្ងៃនោះឯង ជាមួយនឹងការកាន់យកនូវសរណគមន៍ ។*

☆ **បច្ឆិមិកាយ វស្សាវាសិកន្តិ** វស្សាវាសិកលាភ-គ្គហណទស្សនមត្តមេវេតំ, តតោ បុរេបិ, បច្ឆាបិ វា វស្សាវាសិកញ្ច ចីវរមាសេសុ សង្ឃេ ឧប្បន្នំ កាលចីវរញ្ច បុរិមិកាយ, ឧបគន្ត្វា អវិប្បន្នសីលោ សាមណេរោ លភតិ ឯវ ។ ពាក្យថា *សំពត់ចំណាំវស្សាក្នុងវស្សូបនាយិកាក្រោយ ដូច្នេះនេះ ពាក្យនោះត្រឹមជាការសម្តែងនូវជំណើរនៃការទទួលលាភគឺ វស្សិកសាដកប៉ុណ្ណោះ, តពីនោះទៅ សាមណេរមិនវិបត្តិបាកសីល ចូលចាំវស្សាក្នុងបុរិមិកាវស្សា រមែងបានពិត នូវសំពត់វស្សិកសាដកផង, នូវកាលចីវរផង, ដែលកើតឡើងចំពោះសង្ឃ ក្នុងខែនៃចីវរទាំងមុនទាំងក្រោយ ។*

★ **សចេ បច្ឆិមិកាយ គហិតានីតិ** បច្ឆិមិកាយ វស្សូបគមនញ្ច ឆិន្នវស្សតញ្ច ធស្សេតិ ។ តស្ស ហិ កាលចីវរេ ភាគោ ន បាបុណាតិ ។ តស្មា "អបលោកេត្វា លាភោ ទាតព្វោ"តិ វុត្តំ ។ ពាក្យថា *បើសាមណេរទទួលសរណគមន៍ក្នុងវស្សូបនាយិកាក្រោយ ដូច្នេះនេះ លោកអាចារ្យសម្ដែងនូវការចូលចាំវស្សាផង, និងការដាច់នូវវស្សាក្នុងបច្ឆិមិកាវស្សា ។ ព្រោះថា ក្នុងកាលចីវរ, ចំណែក(ចីវរ) រមែងមិនបានដល់សាមណេរនោះទេ ។ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យទើបពោលពាក្យថា "លាភគឺសង្ឃគប្បីអបលោកន៍ឱ្យ" ដូច្នេះ ។*

## សិក្ខាបទសុវាររបស់សាមណេរ ជាសចិត្តកៈ

*<u>ក្នុងគម្ពីរអដ្ឋកថា ពោលទៀតថា:</u>*

*សាមណេររមែងជាអ្នកមិនមែនសមណៈ គឺរមែងដល់នូវភាពជាអ្នកគួរឱ្យវិនាសចេញ ព្រោះអទិន្នាទានដោយវត្ថុ សូម្បីត្រឹមតែស្មៅមួយសរសៃ, ព្រោះអព្រហ្មចរិយៈ ដោយការបដិបត្តិខុសក្នុងបណ្ដាមគ្គទាំង ៣ មគ្គណាមួយ, ព្រោះមុសាវាទកាលខ្លួនពោលកុហក សូម្បីដោយភាព ជាអ្នកប្រាថ្នានឹងសើចលេង, ចំណែកក្នុងការផឹកទឹកស្រវឹង ជាអាបត្តិបាចិត្តិយ ដល់*

ភិក្ខុអ្នកសូម្បីមិនដឹង ហើយផឹកទឹកស្រវឹង ចាប់ដើមអំពីដាក់ពូជ សុរា ។ ចំណែកសាមណេរបានដឹង ហើយផឹកនូវទឹកស្រវឹង ទើបត្រូវសីលភេទ គឺបែកធ្លាយសីល, **បើមិនដឹងមិនបែកធ្លាយសីលទេ ។ ចំណែក ៥ សិក្ខាបទក្រៅពីនេះ** របស់សាមណេរនោះ កាលសិក្ខាបទពួកនោះបែកធ្លាយហើយ, សាមណេរគឺភិក្ខុមិនគប្បីឱ្យសឹកចេញឡើយ, **គប្បីដាក់ទណ្ឌកម្ម** ។ ចំណែកខាងសិក្ខាបទដែលភិក្ខុបានឱ្យទៀតក្តី នៅមិនទាន់បានឱ្យក្តី នឹងដាក់ទណ្ឌកម្ម **រមែងគួរ** ។ តែថាគប្បីពិន័យដោយទណ្ឌកម្ម ហើយសឹមឱ្យសិក្ខាបទ ដើម្បីប្រយោជន៍ដល់សេចក្តីតាំងនៅក្នុងសំវរៈតទៅ ។ ការផឹកទឹកស្រវឹង**របស់សាមណេរជាសចិត្តកៈ** ទើបជាវត្ថុនៃបារាជិក ។

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

☆ ន **អជានិត្វាតិ** "សុរា"តិ អជានិត្វា បិវតោ បាណាតិបាតាវេរមណិអាទិ សព្វសីលភេទំ, សរណ-ភេទញ្ច ន អាបជ្ជតិ, អកុសលំ បន សុរាបានវេរមណិ-សីលភេទោ ច ហោតិ, មាលាទិធារណាទីសុ វិយាតិ ទដ្ឋព្វំ ។ ពាក្យថា **បើមិនដឹង មិនបែកធ្លាយសីលទេ** ដូច្នេះ នេះ មានសេចក្តីថា សាមណេរមិនដឹងថា "ជាសុរា" ហើយ

ផឹក, រមែងមិនដល់នូវកិរិយាបែកធ្លាយនូវសីលទាំងអស់ មានបាណាតិបាតាវេរមណីជាដើមទេ, ថែមទាំងមិនដល់នូវកិរិយាបែកធ្លាយនូវសរណគមន៍ផង, ចំណែកឯការបែកធ្លាយនូវសីលសុរាបានវេរមណីដែលជាអកុសល គប្បីជ្រាបដូចក្នុងសិក្ខាបទទាំងឡាយ មានសិក្ខាបទទ្រទ្រង់នូវផ្កាកម្រងជាដើម ។

★ **ឥតរានីតិ** វិកាលភោជនាវេរមណិអាទីនិ តានិបិ ហិ សញ្ចិច្ច វីតិក្កមន្តស្ស តំ តំ ភិជ្ជតិ ឯវ ។ ពាក្យថា ចំណែក ៥ សិក្ខាបទក្រៅពីនេះ ដូច្នេះ គឺបានដល់ សិក្ខាបទទាំងឡាយមានវិកាលសិក្ខាបទជាដើម ពិតមែនកាលសាមណេរក្លែងប្រព្រឹត្តកន្លង សូម្បីនូវសិក្ខាបទទាំងនោះ សិក្ខាបទនោះៗរមែងបែកធ្លាយពិត ។

## ទណ្ឌកម្មរបស់សាមណេរ

<u>ក្នុងគម្ពីរបរមត្ថទីបនីដីកា ពោលថា:</u>

★ លិង្គនាសនំ កត្វា សរណាគមនេ ភិន្នេ សមាទានំ ភិជ្ជតិ ។ ឥតរេសុ បន យំ វីតិក្កមតិ, តស្មឹយេវ សំវរភេទោ ហោតីតិ វេទិតព្វំ ។ នាកាលកិរិយាដល់នូវត្រៃសរណគមន៍បែកធ្លាយហើយ, ព្រោះធ្វើចំ (អន្ត) នៃលិង្គនាសនា, ការសមាទាន រមែងបែកធ្លាយទៅ ។ ចំណែក

ឯក្នុងសិក្ខាបទក្រៅនេះ បណ្ឌិតគប្បីជ្រាបថា សាមណេរប្រព្រឹត្ត កន្លងនូវសិក្ខាបទណា ការបែកធ្លាយនូវសំវរ រមែងមានតែក្នុង សិក្ខាបទនោះប៉ុណ្ណោះ ។

<u>ក្នុងគម្ពីរអដ្ឋកថា បរមត្ថជោតិកា ពោលថា:</u>

★ សាមណេរានញ្ហិ ឯកស្មឹ ភិន្នេ សព្វានិបិ ភិន្នានិ ហោន្តិ ។ បារាជិកដ្ឋានិយានិ ហិ តានិ, តេសំ យន្តំ វិតិក្កន្តំ ហោតិ តេនេវ កម្មពន្ធោ ។ ក៏ក្នុងសិក្ខាបទ របស់សាមណេរទាំងឡាយ កាលសិក្ខាបទមួយបែកធ្លាយ ហើយ, សិក្ខាបទសូម្បីទាំងអស់រមែងបែកធ្លាយដែរ ។ ព្រោះថា (សិក្ខាបទទាំងអស់)នោះ ជាទីតាំងនៃវត្ថុបារាជិក, កាលប្រព្រឹត្ត កន្លង(នូវសិក្ខាបទ)របស់សាមណេរនោះណា រមែងមាន, ព្រោះ ហេតុនោះឯង ទើបជាកម្មពន្ធ(គឺការជាប់ទាក់ទងដោយកម្ម) ។

<u>ក្នុងគម្ពីរអដ្ឋកថា សិក្ខាបទវិភង្គោ ពោលថា:</u>

★ សាមណេរានំ បន ឯកស្មឹ វិតិក្កមន្តេ សព្វានិ ភិជ្ជន្តិ ។ ន កេវលញ្ច ឯតានិ, សេសសីលានិបិ ភិជ្ជន្តិយេវ ។ តេសំ បន វិតិក្កមោ ទណ្ឌកម្មវត្ថុកោ ។ "បុន ឯវរូបំ ន ករិស្សាមី"តិ ទណ្ឌកម្មេ កតេ សីលំ បរិបុណ្ណំ ហោតិ ។

ចំណែកឯសាមណេរទាំងឡាយ កាលប្រព្រឹត្តកន្លងនូវសិក្ខាបទតែមួយ, សិក្ខាបទទាំងអស់ រមែងបែកធ្លាយដែរ ។ មិនមែនតែសិក្ខាបទទាំងនោះប៉ុណ្ណោះទេ, សូម្បីសីលដ៏សេសរមែងបែកធ្លាយពិត ។ តែការប្រព្រឹត្តិកន្លងនូវសីលទាំងឡាយដ៏សេសនោះ ជាវត្ថុនៃទណ្ឌកម្ម ។ **នាកាលទណ្ឌកម្ម គឺសាមណេរធ្វើហើយដោយគិតថា "អាត្មាអញនឹងមិនធ្វើនូវអំពើកម្ម មានសភាពដូច្នេះទៀតទេ" ដូច្នេះ សីលរមែងពេញបរិបូរណ៍វិញ ។**

## សាមណេរពោលតិះដៀលព្រះរតនត្រ័យ

<u>ក្នុងអដ្ឋកថាឈ្មោះកុរុន្ទី ពន្យល់ថា:</u>

**សាមណេរ** អ្នកពោលទោសរបស់ព្រះពុទ្ធ ដោយអំណាចនៃពាក្យជាសត្រូវដល់ព្រះពុទ្ធគុណជាដើមថា "**អរហំ សម្មាសម្ពុទ្ធោ**" ក្តី, ពោលទោសរបស់ព្រះធម៌ ដោយអំណាចនៃពាក្យជាសត្រូវដល់ធម្មគុណជាដើមថា "**ស្វាក្ខាតោ**" ក្តី, ពោលទោសរបស់ព្រះសង្ឃ ដោយអំណាចនៃពាក្យជាសត្រូវ ដល់សង្ឃគុណជាដើមថា "**សុបដិបន្នោ**" ក្តី, កាលពោលនូវទោស, កាលនិន្ទា, កាលតិះដៀលនូវព្រះរតនត្រ័យ ដែលភិក្ខុទាំងឡាយមានអាចារ្យនិងឧបជ្ឈាយ៍ជាដើម គប្បីឱ្យសម្តែងទោស ក្នុងការពោលទោស ហើយគប្បីហាមប្រាមថា "អ្នកកុំពោលយ៉ាងនេះឡើយ"

*បើសាមណេរ ដែលភិក្ខុទាំងឡាយពោលដល់ ៣ ដង នៅមិនព្រមលះបង់ ភិក្ខុទាំងឡាយគប្បីឱ្យវិនាសចេញ ដោយកណ្ដកនាសនា (គឺឱ្យវិនាស ដូចកណ្ដកសាមណេរ) ។*

*<u>ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:</u>*

★ **យាវតតិយន្តិ** វុត្តត្តា " ពុទ្ធាទីនំ អវណ្ណភាសិតមត្តេន ច ទិដ្ឋិគ្គហិតមត្តេន ច សរណានិ ន ភិជ្ជន្តីតិ វុត្តំ ហោតី"តិ វទន្តិ ។ "ឯវំ សន្តេ បាណាតិបាតាទីករេន្តស្សាបិ តំ សម្ភោតី"តិ មម តក្កោ ។ " និស្សីលស្ស បុន នាសនា វុត្តា"តិ ច កេចិ វទន្តិ, តំ យុត្តំ វិយ ។ ន ហិ ភគវា សីលវន្តស្ស លិង្គនាសនំ អនុជានាតីតិ វិចារេតព្វំ ។ *ព្រោះអដ្ឋកថាចារ្យពោលថា* ***អស់វារ ៣ ដង*** *ដូច្នេះនេះ អាចារ្យទាំងឡាយពោលថា* ***"សរណៈទាំងឡាយ*** *រមែងមិនបែកធ្លាយទៅ ដោយត្រឹមតែពោលទោសចំពោះ ព្រះពុទ្ធផង, ដោយត្រឹមតែប្រកាន់យកនូវទិដ្ឋិផងទេ" ។ សេចក្ដីត្រិះរិះរបស់ខ្ញុំថា " កាលបើហេតុយ៉ាងនេះ មានមែន, សូម្បីកាលសាមណេរ ធ្វើនូវបាណាតិបាតជាដើម, ការបែកធ្លាយសរណគមន៍ រមែងមាន" ។ ក៏អាចារ្យពួកខ្លះពោលថា "ការឱ្យវិនាសគឺលោកពោលម្ដងទៀត ចំពោះបុគ្គលមិនមានសីល,*

ពាក្យរបស់អាចារ្យនោះ ដូចជាត្រូវ ។ ពិតមែន បណ្ឌិតគប្បី ពិចារណាថា ព្រះដ៏មានព្រះភាគ ទ្រង់មិនអនុញ្ញាតនូវលិង្គនាសនា ចំពោះបុគ្គលអ្នកមានសីលទេ ។

<u>ចំណែកក្នុងមហាអដ្ឋកថា ពន្យល់ថា:</u>

ប្រសិនបើសាមណេរ ដែលភិក្ខុទាំងឡាយពោលយ៉ាង នោះ ព្រមលះបង់លទ្ធិនោះ, **គប្បីឱ្យធ្វើទណ្ឌកម្មហើយសម្តែង ទោសដែលប្រព្រឹត្តកន្លង** ។ បើនៅមិនព្រមលះបង់, នៅប្រកាន់ យ៉ាងនោះដដែល គប្បីឱ្យវិនាសដោយលិង្គនាសនា ។ ពាក្យ ក្នុងមហាអដ្ឋកថានោះត្រឹមត្រូវហើយ, ព្រោះថា នាសនានេះ ប៉ុណ្ណោះ ដែលព្រះមានព្រះភាគ ទ្រង់ប្រាថ្នាក្នុងសេចក្តីនេះ ។ សូម្បីក្នុងសាមណេរអ្នកជាមិច្ឆាទិដ្ឋិ ក៏ន័យនេះឯង ។ សាមណេរដែល**មានបណ្តាសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ** ប្រភេទ ណាមួយ, បើសាមណេរដែលភិក្ខុទាំងឡាយ មានអាចារ្យ ជាដើម ដាស់តឿនហើយព្រមលះបង់ចេញបាន គប្បីធ្វើទណ្ឌកម្ម ហើយឱ្យសម្តែងទោសដែលប្រព្រឹត្តកន្លង, កាលមិនព្រមលះបង់ នោះឯង គប្បីឱ្យវិនាសចេញដូច្នេះឯង ។ អ្នកសិក្សាគប្បីជ្រាប ថា ពាក្យថា **"ភិក្ខុនីទូសកោ"** ដូច្នេះនេះ ដែលព្រះមានព្រះភាគ ត្រាស់ទុកអង្គទី ១០ ជាផ្នែកផ្សេង គឺដើម្បីសម្តែងសេចក្តីនេះថា "ពិតមែន បណ្តានាសនង្គ ១០ នេះ សាមណេរដែលប្រទូស-

រ៉ាយនាងភិក្ខុនី ដែលព្រះអង្គកាន់យកដោយអព្រហ្មចារីស័ព្ទ ក៏ពិតមែនហើយ, តែជាអព្រហ្មចារីបុគ្គល ដែលប្រាថ្នានឹងតាំងនៅក្នុងសំវរៈតទៅ រមែងសមគួរនឹងឱ្យសរណៈហើយឱ្យឧបសម្បទាបាន ។ (តែ)សាមណេរដែលប្រទូសរ៉ាយនាងភិក្ខុនី សូម្បីប្រាថ្នានឹង តាំងនៅក្នុងសំវរៈតទៅ, រមែងមិនបានសូម្បីនូវបព្វជ្ជា មិនចាំបាច់ត្រូវពោលដល់ឧបសម្បទាឡើយ ។

<u>ក្នុងគម្ពីរវជិរពុទ្ធិដីកា និងសារត្ថទីបនីដីកា ពោលថា:</u>

☆ **អច្ចយំ ទេសាបេតព្វោតិ** "អច្ចយោ មំ, ភន្តេ អច្ចាគមា"តិអាទិនា នយេន អច្ចយំ ទេសាបេតព្វោ ។

ពាក្យថា *គប្បីឱ្យសម្តែងទោស* គឺគប្បីឱ្យសម្តែងទោសដោយន័យថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ទោសកំហុសដែលប្រព្រឹត្តកន្លង គ្របសង្កត់នូវខ្ញុំព្រះករុណា តាមដែលខ្ញុំព្រះករុណា ជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស, បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកអត់នូវទោសកំហុសនោះដល់ខ្ញុំព្រះករុណា, ដើម្បីខ្ញុំព្រះករុណានឹងសង្រួមគឺថានឹងប្រព្រឹត្តឱ្យល្អតទៅ" ។

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

☆ ននុ ច កណ្ដកសាមណេរោបិ មិច្ឆាទិដ្ឋិកោ ឯវ

តស្ស ច ហេដ្ឋា ទណ្ឌកម្មនាសនាវ វុត្តា ។ ឥធ បន មិច្ឆាទិដ្ឋិកស្ស លិង្គនាសនា វុច្ចតិ, កោ ឥមេសំ ភេទោតិ ចោទនំ មនសិ និធាយាហ "សស្សតុច្ឆេទានញ្ញតរ-ទិដ្ឋិកោ"តិ ។ *ព្រះអដ្ឋកថាចារ្យកាលធ្វើទុកក្នុងចិត្តនូវការចោទថា "សូម្បីកណ្តកសាមណេរ មានទិដ្ឋិអាក្រក់ មិនមែនឬ ? (ព្រោះហេតុអ្វី) ក៏ទណ្ឌកម្មនាសនាប៉ុណ្ណោះ គឺលោកពោលខាងក្រោម(ខាងដើម) ដល់សាមណេរនោះ ។ ចំណែកលិង្គនាសនារបស់សាមណេរ ដែលជាមិច្ឆាទិដ្ឋិ លោកពោលទុកក្នុងសេចក្តីនេះវិញ, តើសេចក្តីផ្សេងគ្នា នៃមិច្ឆាទិដ្ឋិទាំងពីរនោះ ដូចម្តេចទៅ ? " ព្រោះហេតុដូច្នេះ ទើបលោកអាចារ្យពោលពាក្យថា* "សាមណេរដែលមាន *បណ្តាសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ប្រភេទណាមួយ" ដូច្នេះ ។*

★ ឯត្ថ ចាយមធិប្បាយោ យោ ហិ "អត្តា ឥស្សរោ វា និច្ចោ ធុវោ"តិអាទិនា វា "អត្តា ឧច្ឆិជ្ជិស្សតិ វិនស្សិស្សតី"តិអាទិនា វា តិត្ថិយបរិកប្បិតំ យំ កិញ្ចិ សស្សតុច្ឆេទទិដ្ឋឹ ទឡ្ហំ គហេត្វា វោហរតិ, តស្ស សា បារាជិកដ្ឋានំ ហោតិ ។ សោ ច លិង្គនាសនាយ នាសេ-តព្វោ ។ *សេចក្តីអធិប្បាយក្នុងពាក្យនោះដូចតទៅនេះ* ៖

ក៏សាមណេរណា ពោលប្រកាន់យ៉ាងមាំនូវសស្សតទិដ្ឋិ និង ឧច្ឆេទទិដ្ឋិណាមួយ, ដែលជាការកំណត់របស់ពួកតិរ្ថិយ ដោយពាក្យជាដើមថា "ខ្លួនជាឥស្សរ" ឬជាអ្នកមានសភាវទៀងទាត់, ស្ថិតស្ថេរ" ដូច្នេះ ក្តី, ដោយពាក្យជាដើមថា "ខ្លួននឹងដាច់សូន្យ ខ្លួននឹងវិនាស "ដូច្នេះ ក្តី, ទិដ្ឋិរបស់សាមណេរនោះជាទីតាំងនៃបារាជិក ។ សាមណេរនោះ សង្ឃត្រូវឱ្យវិនាស ដោយលិង្គនាសនា ។

★ យោ បន ឦទិសំ ទិដ្ឋឹ អគ្គហេត្វា សាសនិកោវ ហុត្វា កេវលំ ពុទ្ធវចនាធិប្បាយំ វិបរីតតោ គហេត្វា ភិក្ខូហិ ឱវទិយមានោបិ អប្បដិនិស្សជ្ជិត្វា វោហរតិ, តស្ស សា ទិដ្ឋិ បារាជិកំ ន ហោតិ, សោ បន កណ្ឌកនាសនាយ ឯវ នាសេតព្វោតិ ។ ចំណែកឯសាមណេរណា មិនកាន់យកនូវទិដ្ឋិមានសភាពបែបនោះទេ, ជាពុទ្ធសាសនិកពិត ហើយកាន់យកនូវសេចក្តីអធិប្បាយនៃព្រះពុទ្ធវចនៈទាំងអស់ ដោយវិបរិត, សូម្បីគឺភិក្ខុកាលទូន្មាន ក៏មិនព្រមលះបង់ចេញ ហើយនៅតែពោល, ទិដ្ឋិនោះរបស់សាមណេរនោះ មិនជាបារាជិកទេ ។ តែសាមណេរនោះ គប្បីឱ្យវិនាសដោយកណ្ឌកនាសនាពិត ។

**នាសនង្គកថាចប់ ។**

# ៦_បណ្ឌកកថា

<u>ក្នុងវិនយបិដកភាគ ៦ ទំព័រ ២៨៤ ពោលថា:</u>

★ បណ្ឌកោ ភិក្ខវេ អនុបសម្បន្នោ ន ឧបសម្បាទេតព្វោ ឧបសម្បន្នោ នាសេតព្វោ ។ ម្នាលភិក្ខុទាំងឡាយ ខ្ទើយជាអនុបសម្បន្ន សង្ឃមិនគប្បីឱ្យឧបសម្បទាឡើយ (បើ) ជាឧបសម្បន្នហើយ ត្រូវឱ្យវិនាសចេញ ។

<u>ក្នុងគម្ពីរអដ្ឋកថាពោលថា ខ្ទើយមាន ៥ គឺ:</u>

១-តត្ថ យស្ស បរេសំ អង្គជាតំ មុខេន គហេត្វា អសុចិនា អាសិត្តស្ស បរិឡាហោ វូបសម្មតិ, អយំ អាសិត្តបណ្ឌកោ ។ បណ្ដាខ្ទើយទាំងនោះ ខ្ទើយឯណាយកមាត់បៀមអង្គជាតរបស់បុរសដទៃ ត្រូវទឹកអសុចិស្រោចហើយសេចក្ដីក្ដៅក្រហាយទើបស្ងប់រម្ងាប់ទៅ ខ្ទើយនេះឈ្មោះថា អាសិត្តបណ្ឌកៈ ។

២-យស្ស បរេសំ អជ្ឈាចារំ បស្សតោ ឧស្សូយាយ ឧប្បន្នាយ បរិឡាហោ វូបសមតិ, អយំ ឧស្សូយបណ្ឌកោ ។ ខ្ទើយឯណា ឃើញអជ្ឈាចាររបស់ជនដទៃ កាលសេចក្ដី

ប្រណែនកើតឡើងហើយ សេចក្ដីក្ដៅក្រហាយ ទើបស្ងប់រម្ងាប់ទៅ ខ្ទើយនេះឈ្មោះថា **ឧសូយបណ្ឌកៈ** ។

**៣-យស្ស ឧបក្កមេន ពីជានិ អបនីតានិ, អយំ ឱបក្កមិកបណ្ឌកោ ។** ខ្ទើយឯណា មានអវយវៈ គឺពូជទាំងឡាយ ត្រូវគេគ្រៀវចេញហើយ ដោយសេចក្ដីព្យាយាម ខ្ទើយនេះឈ្មោះថា **ឱបក្កមិកបណ្ឌកៈ** ។

**៤-ឯកច្ចោ បន អកុសលវិបាកានុភាវេន កាឡបក្ខេ បណ្ឌកោ ហោតិ, ជុណ្ហបក្ខេ បនស្ស បរិឡាហោ វូបសមតិ, អយំ បក្ខបណ្ឌកោ ។** ចំណែកមនុស្សពួកខ្លះខាងរនោចជាខ្ទើយ ដោយអានុភាពនៃអកុសលវិបាក, តែខាងខ្នើត សេចក្ដីក្ដៅក្រហាយរបស់គេ រមែងស្ងប់ទៅ, ខ្ទើយនេះឈ្មោះថា **បក្ខបណ្ឌកៈ** ។

**៥-យោ បន បដិសន្ធិយំយេវ អភាវកោ ឧប្បន្នោ អយំ នបុំសកបណ្ឌកោ ។** ចំណែកខ្ទើយឯណា កើតមកមិនមានភេទក្នុងបដិសន្ធិតែម្ដង ( គឺមិនប្រាកដជាប្រុស ឬស្រីមកអំពីកំណើត) ខ្ទើយនេះ ឈ្មោះថា **នបុំសកបណ្ឌកៈ** ។

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

★ **អាសិត្តឧសូយបក្ខបណ្ឌកា តយោបិ បុរិសភាវ-**

លិង្គានិយុត្តា អហេតុកបដិសន្ធិកា, តេ ច កិលេស-បរិយុដ្ឋានស្ស ពលវតាយ នបុំសកបណ្ឌកសទិសត្តា " បណ្ឌកា"តិ វុត្តា ។ *សូម្បីក្នុងបណ្ឌកៈ ៣ ពួកនេះ គឺ អាសិត្តបណ្ឌកៈ ១ ឧសូយបណ្ឌកៈ ១ បក្ខបណ្ឌកៈ ១ ជា អហេតុកបដិសន្ធិ ដែលប្រកបដោយភេទមានភាវៈជាប្រុស, ក៏ បុគ្គលទាំងនោះ លោកហៅថា បណ្ឌកៈ ដូច្នេះ ព្រោះភាវៈនៃ បុគ្គលនោះ គឺកិលេសដ៏មានកម្លាំងខ្លាំងរួបរឹតផង ព្រោះប្រាកដ ដូចជា នបុំសកបណ្ឌកៈផង ។*

តេសុ អាសិត្តឧសូយបណ្ឌកានំ ទ្វិន្នំ កិលេស-បរិយុដ្ឋានំ យោនិសោមនសិការាទីហិ វីតិក្កមតោ និវារេតុម្បិ សក្កា, តេន តេ បព្វាជេតព្វា វុត្តា ។ *បណ្តាបណ្ឌកៈទាំងនោះ បណ្ឌកៈ ២ គឺអាសិត្តបណ្ឌកៈ និង ឧសូយបណ្ឌកៈ ដែលមានកិលេសរួបរឹតហើយ អាចដើម្បី ហាមឃាត់ចាកការប្រព្រឹត្តកន្លងបាន ដោយយោនិសោមនសិការ ជាដើម ព្រោះហេតុនោះ បណ្ឌកៈ ២ ពួកនោះ លោកពោលថា គប្បីឱ្យបព្វជ្ជាបាន ។*

បក្ខបណ្ឌកស្ស បន កាឡបក្ខេសុ ឧម្មាទោ វិយ កិលេសបរិឡាហោ អវត្ថរន្តោ អាគច្ឆតិ, វីតិក្កមំ បត្វា

ឯវំ ច និវត្តតិ ។ តស្មា សោ តស្មឹ បក្ខេ ន បញ្ញាជេតព្វោតិ វុត្តោ ។ តទេតំ វិភាគំ ទស្សេតុំ "យស្ស បរេស"ន្តិអាទិ វុត្តំ ។ ប៉ុន្តែសេចក្តីក្រៅក្រហាយ គឺកិលេស រមែងមកគ្របសង្កត់ក្នុងបក្ខខាងរនោច នៃបក្ខបណ្ឌកៈដូចជា មនុស្សឆ្កួត, លុះដល់កន្លងបក្ខខាងរនោចនោះហើយ រមែង ត្រលប់ជាប្រក្រតីវិញ ។ ព្រោះហេតុនោះ បក្ខបណ្ឌកៈនោះ ព្រះអដ្ឋកថាចារ្យពោលថា មិនគប្បីឱ្យបព្វជ្ជា ក្នុងបក្ខនោះទេ ដើម្បីសម្តែងនូវចំណែកផ្សេងគ្នានោះ លោកទើបពោលពាក្យ ជាដើមថា "យស្ស បរេសំ : បណ្តាខ្ទើយទាំងនោះ" ដូច្នេះ ។

★ តត្ថ **អាសិត្តស្សាតិ** មុខេ អាសិត្តស្ស អត្តនោបិ អសុចិមុច្ចនេន បរិឡាហោ វូបសម្មតិ ។ បណ្តាពាក្យទាំងនោះ ពាក្យថា **អាសិត្តស្ស** ដូច្នេះ មានសេចក្តីថា សេចក្តីក្តៅក្រហាយ រមែងស្ងប់រម្ងាប់ព្រោះការចេញទឹកអសុចិ សូម្បីរបស់ខ្លួន ដែលស្រោចចូលទៅក្នុងមាត់ ។

★ **ឧសូយាយ ឧប្បន្នាយាតិ** ឧសូយាយ វសេន អត្តនោ សេវេតុកាមតា រាគេ ឧប្បន្នេ អសុចិមុត្តិយា បរិឡាហោ វូបសម្មតិ ។ ពាក្យថា **កាលសេចក្តីច្រណែនកើតឡើងហើយ** ដូច្នេះ មានសេចក្តីថា កាលរាគៈកើតឡើង

ហើយ ព្រោះភាវនៃខ្លួនជាអ្នកប្រាថ្នាដើម្បីសេព ដោយអំណាចនៃសេចក្តីប្រណៃន សេចក្តីក្តៅក្រហាយ រមែងស្ងប់រម្ងាប់ទៅ ព្រោះការចេញទឹកអសុចិ (នោះ) ។

★ **"ពីជានិ អបនីតានី"តិ** វុត្តត្តា ពីជេសុ ឋិតេសុ និមិត្តមត្តេ អបនីតេ បណ្ឌកោ ន ហោតិ ។ ភិក្ខុនោបិ អនាពាធបច្ចយា តទបនយនេ ថុល្លច្ចយមេវ, ន បន បណ្ឌកត្តំ, ពីជេសុ បន អបនីតេសុ អង្គជាតម្បិ រាគេន កម្មនិយំ ន ហោតិ, បុមភាវោ វិគច្ឆតិ, មស្សុអាទិ បុរិសលិង្គម្បិ, ឧបសម្បទាបិ វិគច្ឆតិ, កិលេសបរិឡាហោបិ ទុន្និវារវីតិក្កមោ ហោតិ នបុំសកបណ្ឌកស្ស វិយ ។ តស្មា ឦទិសោ ឧបសម្បន្នោបិ នាសេតព្វោតិ វទន្តិ ។

អាចារ្យទាំងឡាយពោលថា ព្រោះពាក្យដែលព្រះអដ្ឋកថាចារ្យពោលថា "នាំនូវពូជចេញ" ដូច្នេះ មានសេចក្តីថា កាលនិមិត្តដែលឋិតនៅត្រង់ពូជគឺគេនាំចេញហើយ, ក៏មិនទៅជាបណ្ឌកៈដែរ ។ សូម្បីភិក្ខុមិនមានអាពាធជាបច្ច័យ រមែងត្រូវត្រឹមតែអាបត្តិថុល្លច្ច័យប៉ុណ្ណោះ, ព្រោះការនាំចេញនូវនិមិត្តនោះ តែមិនដល់នូវភាពជាបណ្ឌកៈទេ ។ តែថា កាលបើគេនាំនូវពូជចេញវិញ សូម្បីអង្គជាតរមែងជាអវយវៈ មិនគួរដល់ការងារ ដោយ

រាគៈ, ភាពជាបុរសរមែងប្រាសទៅ សូម្បីភេទរបស់បុរសមានពុកមាត់ជាដើមក្តី ឧបសម្បទាក្តី រមែងទៅប្រាស (គឺបួសមិនឡើង) ។ សូម្បីសេចក្តីក្តៅក្រហាយ ព្រោះកិលេស រមែងជាសភាវៈមានការប្រព្រឹត្តកន្លង គឺគេហាមឃាត់បានដោយលំបាកដូចជានបុំសកបណ្ឌកៈដែរ ។ ព្រោះហេតុនោះ សូម្បីឧបសម្បន្នមានសភាពដូច្នេះ គប្បីឱ្យវិនាសចេញ ។

អបរេ បន "បព្ពជ្ជតោ បុព្វេ ឧបក្កមេន បណ្ឌកភាវមាបន្នំ សន្ធាយ **"ឧបសម្បន្នោ នាសេតព្វោ"**តិ វុត្តំ, ឧបសម្បន្នស្ស បន បច្ឆា ឧបក្កមេន ឧបសម្បទាបិ ន វិគច្ឆតី"តិ តំ ន យុត្តំ ។ យទគ្គេន ហិ បព្ពជ្ជតោ បុព្វេ ឧបក្កមេន អភព្វោ ហោតិ, តទគ្គេន បច្ឆាបិ ហោតីតិ វីមំសិត្វា គហេតព្វំ ។ ចំណែកអាចារ្យដទៃទៀត ពោលថាពាក្យថា "ជាឧបសម្បន្នហើយ ត្រូវឱ្យវិនាសចេញ" ដូច្នេះ គឺលោកពោលសំដៅយក ការដល់នូវភាពជាបណ្ឌកៈ ដោយសេចក្តីព្យាយាមក្នុងកាលមុន, តែកាលឧបសម្បទាហើយដល់ (នូវភាពជាបណ្ឌកៈ) ដោយសេចក្តីព្យាយាមជាខាងក្រោយ សូម្បីឧបសម្បទា ក៏មិនទៅប្រាសទេ ( គឺនៅជាភិក្ខុដដែល ) " ពាក្យនោះមិនត្រឹមត្រូវទេ ។ ព្រោះថា អភព្វបុគ្គលរមែងមានដោយសេចក្តីព្យាយាមក្នុងកាលមុនអំពីកាល បួសដោយចំណែក

ណា, សេចក្តីព្យាយាមសូម្បីក្នុងចំណែកខាងក្រោយ រមែងមាន ដោយចំណែកនោះ ព្រោះហេតុនោះ បណ្ឌិតគប្បីពិចារណា ហើយកាន់យកចុះ ។

<u>ក្នុងអដ្ឋកថា ខុទ្ទកវត្ថុក្ខន្ធកៈ ពោលថា:</u>

★ **ន ភិក្ខវេ អត្តនោ អង្គជាតន្តិ** អង្គជាតំ ឆិន្ទន្តស្សេវ ថុល្លច្ចយំ ។ អញ្ញំ បន កណ្ណនាសា-អង្គុលិអាទឹ យំកិញ្ចិ ឆិន្ទន្តស្ស តាទិសំ វា ទុក្ខំ ឧប្បាទេន្តស្ស ទុក្កដំ ។ អហិដីកាទដ្ឋាទិសុ បន អញ្ញអា-ពាធបច្ចយា វា លោហិតំ វា មោចេន្តស្ស ឆិន្ទន្តស្ស វា អនាបត្តិ ។ ព្រោះព្រះពុទ្ធដីកា ព្រះអង្គត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវកាត់នូវអង្គជាតរបស់ខ្លួនទេ" ដូច្នេះនេះ មានសេចក្តីថា អាបត្តិថុល្លច្ច័យរមែងមាន ដល់ភិក្ខុកាលកាត់នូវអង្គជាតប៉ុណ្ណោះ ។ តែកាលភិក្ខុកាត់នូវអវយវៈដទៃ យ៉ាងណាមួយ មានត្រចៀក ច្រមុះ និងម្រាមដៃជាដើម ឬក៏ញ៉ាំងនូវសេចក្តីទុក្ខឱ្យកើតឡើង ដល់អវយវៈប្រាកដដូចនោះក្តី រមែងត្រូវអាបត្តិទុក្កដ ។ តែជាអនាបត្តិ ដល់ភិក្ខុកាលបង្ហូរឈាម ឬកាត់នូវអវយវៈដទៃ ព្រោះអាពាធជាបច្ច័យ ក្នុងបណ្តាអាពាធ មានសត្វពស់ចឹកជាដើម ។

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

★ **អង្គជាតន្តិ** ពីជវិរហិតំបុរិសនិមិត្តំ ។ ពីជេ ហិ ឆិន្នេ, ឱបក្កមិកបណ្ឌកោ នាម អភព្វោ ហោតីតិ វទន្តិ ។ ឯកេ បន "ពីជស្សាបិ ឆេទនក្ខណេ ទុក្កដាបត្តិ ឯវ កាមេន បុរិសិន្ទ្រិយាទិកេ អន្តរហិតេ បណ្ឌកោ នាម អភព្វោ ហោតិ តទា លិង្គនាសនាយ នាសេតព្វោ"តិ វទន្តិ ។

*ពាក្យថា **អង្គជាត** ដូច្នេះ បានដល់ និមិត្តរបស់បុរស ដែលប្រាសចាកពូជ ។ អាចារ្យទាំងឡាយពោលថា ពិតមែន កាលពូជ គឺគេកាត់ចេញហើយ រមែងជាអភព្វបុគ្គលឈ្មោះ **ឱបក្កមិកបណ្ឌក** ។ អាចារ្យពួកខ្លះពោលថា រមែងត្រូវតែអាបត្តិទុក្កដប៉ុណ្ណោះ សូម្បីក្នុងខណៈកាត់នូវពូជ, នាកាលបុរិសិន្ទ្រិយជាដើម ដែលបាត់ទៅហើយតាមលំដាប់ រមែងជាអភព្វបុគ្គលឈ្មោះថា **បណ្ឌកៈ** (ក្នុងកាលណា) ក្នុងកាលនោះ គប្បីឱ្យវិនាសដោយលិង្គនាសនា ។*

<u>ក្នុងអដ្ឋកថាកុរុន្ទី ពោលថា:</u>

តេសុ អាសិត្តបណ្ឌកស្ស ច ឧស្សូយបណ្ឌកស្ស ច បព្វជ្ជា ន វារិតា, ឥតរេសំ តិណ្ណំ វារិតា ។ តេសុបិ បក្ខបណ្ឌកស្ស យស្មិំ បក្ខេ បណ្ឌកោ ហោតិ, **តស្មិំ**

**យេវស្ស បក្ខេ បព្វជ្ជា វារិតាតិ** កុរុន្ទិយំ វុត្តំ ។

*បណ្ដាខ្ទើយ ៥ ប្រភេទនោះ អាសិត្តបណ្ឌកៈ និង ឧសូយបណ្ឌកៈ មិនហាមបព្វជ្ជា, ៣ ប្រភេទក្រៅពីនេះ គឺលោកហាម ។ សូម្បីក្នុងខ្ទើយ ៣ ប្រភេទនោះសម្រាប់ បក្ខបណ្ឌកៈ ក្នុងបក្ខណាដែលជាបណ្ឌកៈ* ***គឺលោកហាមបព្វជ្ជា*** *ដល់គេចំពោះតែក្នុងបក្ខដែលជាខ្ទើយនោះប៉ុណ្ណោះ ។*

*<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:</u>*

★ ឥត្ថិភាវោ បុម្ភាវោ វា ឆត្ថិ ឯតស្សាតិ **អភាវកោ** ។ **តស្មឹ យេវស្ស បក្ខេ បព្វជ្ជា វារិតាតិ** ឯត្ថ "អបណ្ឌកបក្ខេ បព្វាជេត្វា បណ្ឌកបក្ខេ ឆាសេតព្វោ"តិ គឹសុបិ គន្ឋិបទេសុ វុត្តំ ។ *ភាពជាស្រី ឬភាពជាប្រុស មិនមានដល់បណ្ឌកៈនោះ ព្រោះហេតុនោះ បណ្ឌកៈនោះ ទើបឈ្មោះថា* ***មិនមានភេទ*** *។*

*ក្នុងពាក្យថា គឺលោកហាមបព្វជ្ជាដល់គេ ចំពោះតែក្នុងបក្ខដែលជាខ្ទើយនោះប៉ុណ្ណោះ ដូច្នេះនេះ លោកពោលទុក ក្នុងគណ្ឋីបទទាំង ៣ ថា គប្បីឱ្យបព្វជ្ជា ក្នុងបក្ខដែលមិនមែនជាបណ្ឌកៈហើយគប្បីឱ្យវិនាសចេញ ក្នុងបក្ខដែលជាបណ្ឌកៈវិញ ។*

កោចិ បន "អបណ្ឌកបក្ខេ បព្វជិតោ សចេ

កិលេសក្ខយំ បាបុណាតិ, ន នាសេតព្វោ”តិ វទន្តិ, តំ តេសំ មតិមត្តំ, បណ្ឌកស្ស កិលេសក្ខយាសម្ភវតោ ខីណកិលេសស្ស ច បណ្ឌកភាវានុបបត្តិតោ ។

*តែអាចារ្យទាំងឡាយពួកខ្លះពោលថា បើឱ្យបួសក្នុងបក្ខដែលមិនមែនជាបណ្ឌកៈហើយ លោកដល់នូវកិរិយាអស់ទៅនៃកិលេសមិនគប្បីឱ្យវិនាសឡើយ ។ ពាក្យនោះ ត្រឹមតែជាមតិរបស់អាចារ្យទាំងនោះប៉ុណ្ណោះ ព្រោះភាវៈនៃបណ្ឌកៈ មិនមានការអស់ទៅនៃកិលេសផង, ព្រោះការអស់ទៅនៃកិលេស មិនកើតឡើងដល់បុគ្គលជាបណ្ឌកៈផង ។*

*<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>*

☆ **តស្មិំយេវស្ស បក្ខេ បព្វជ្ជា វារិតាតិ** ឯត្ថ បន អបណ្ឌកបក្ខេបិ បព្វជ្ជាមត្តមេវ លភតិ, ឧបសម្បទា បន តទាបិ ន វដ្ដតិ, បណ្ឌកបក្ខេ បន អាគតេ លិង្គនាសនាយ នាសេតព្វោតិ វេទិតព្វំ ។ *ក្នុងពាក្យថា* **គឺលោកហាមបព្វជ្ជាដល់គេ ចំពោះតែក្នុងបក្ខដែលជាខ្ទើយនោះប៉ុណ្ណោះ** *ដូច្នេះ មានសេចក្ដីថា បុគ្គលនោះរមែងបានត្រឹមតែបព្វជ្ជាតែម្យ៉ាង, សូម្បីក្នុងបក្ខដែលមិនមែនជាបណ្ឌកៈ ចំណែកឧបសម្បទារមែងមិនគួរ សូម្បីក្នុងកាល (មិនមែនជា*

បណ្ឌកៈ)នោះ ។ ក៏កាលបក្ខដែលជាបណ្ឌកៈមកដល់ហើយ ត្រូវឱ្យវិនាសចេញ ដោយលិង្គនាសនា ។

ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:

★ ឯកេ ចត្តារោបិ កិរ បុរិសាវាតិ ឯកេ ។ ឥត្ថីបិ បក្ខបណ្ឌកី ហោតីតិ ឯកេ ។ ឧបក្កមេ កតេ បណ្ឌកភាវោ អវស្សំ ហោតិ, តស្មា បព្ពជ្ជំ ន លភតិ ។ "យទិ បន កស្សចិ ន ហោតិ, បព្ពជ្ជា ន វារិតាតិ វិនិច្ឆយំ វទន្តិ"តិ វុត្តំ ។ អាចារ្យពួកខ្លះពោលថា បានឮមកថា បណ្ឌកៈសូម្បីទាំង ៤ នោះ ជាបុរសតែម្យ៉ាង ។ អាចារ្យពួកខ្លះទៀតពោលថា សូម្បីស្រីជាបក្ខបណ្ឌកី ក៏រមែងមាន ។ អាចារ្យទាំងឡាយ ពោលនូវការវិនិច្ឆ័យថា កាលសេចក្តីព្យាយាម គឺគេធ្វើហើយ ភាពជាបណ្ឌករមែងមានដោយពិត, ព្រោះហេតុនោះ រមែងមិនបាននូវបព្វជ្ជា ។ ក៏ប្រសិនបើមិនមានដល់បុគ្គលណាមួយទេ, បព្វជ្ជាគឺលោកមិនហាមឃាត់ទេ ។

ចោរាណគណ្ឋិបទេ បន មាសបណ្ឌកលេខបណ្ឌកេហិ សហ សត្ត បណ្ឌកា វុត្តា ។ តត្ថ លេខបណ្ឌកោ ណាម កិរ មន្តវសេន ឧបហតពីជោ ។ តត្ថ "ឱបក្កមិកលេខបណ្ឌកា បព្វជិតា ន ណាសេតព្វា ។ យោ

**បព្វាជេតិ, តស្ស ទុក្កដ"ន្តិ ច វុត្តំ ។**

*ចំណែកក្នុងបោរាណគណ្ឋីបទពោលថា "បណ្ឌកៈ ទាំងឡាយ គឺលោកពោលហើយថា មាន ៧ មួយអន្លើដោយមាសបណ្ឌកៈ និងលេខបណ្ឌកៈ" ។ បានឮមកថា បណ្តាបណ្ឌកៈទាំង ២ នោះ (មាសបណ្ឌកៈគឺខ្ទើយ ១ ខែ. ប្រក្រតី ១ខែ) ចំណែកបណ្ឌកៈដែលគេនាំពូជចេញ ដោយអំណាចនៃមន្ត ឈ្មោះថា* ***លេខបណ្ឌកៈ*** *។ បណ្តាបណ្ឌកៈទាំងនោះឱបក្កមិកបណ្ឌកៈ និងលេខបណ្ឌកៈ បួសហើយ មិនត្រូវឱ្យវិនាសឡើយ ។ ភិក្ខុណាបំបួសភិក្ខុនោះរមែងត្រូវអាបត្តិទុក្កដ ។*

**បណ្ឌកកថាចប់ ។**

# ៧_ថេយ្យសំវាសកកថា

*ក្នុងវិនយបិដកភាគ ៦ ទំព័រ ២៨៥ពោលថា:*

★ ថេយ្យសំវាសកោ ភិក្ខវេ អនុបសម្បន្នោ ន ឧបសម្បាទេតព្វោ ឧបសម្បន្នោ នាសេតព្វោ ។ *ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលជាថេយ្យសំវាស (លួចសំវាស) ជាឧបសម្បន្នមិនបានទេ, សង្ឃមិនគប្បីឱ្យឧបសម្បទាឡើយ (បើ) ជាឧបសម្បន្នហើយ គប្បីឱ្យវិនាសចេញ ។*

### ថេយ្យសំវាសមាន ៣ យ៉ាង

*ក្នុងគម្ពីអដ្ឋកថាពោលថា*

១- លិង្គត្ថេនកោ *មនុស្សលួចភេទ ។*

២- សំវាសត្ថេនកោ *មនុស្សលួចសំវាស ។*

៣- ឧភយត្ថេនកោ *មនុស្សលួចទាំងពីរ (ទាំងភេទទាំងសំវាស) ។*

★ *ក្នុងថេយ្យសំវាសទាំង ៣ ប្រភេទនោះ អ្នកណាបួសដោយខ្លួនឯង ហើយទៅកាន់វត្ត មិនរាប់វស្សារបស់ភិក្ខុ មិនត្រេកអរនឹងការថ្វាយបង្គំ តាមលំដាប់ចាស់ខ្ចី, មិនហាម*

ឃាត់ដោយអាសនៈ, មិនចូលទៅក្នុងសង្ឃកម្មមានឧបោសថ និងបវារណាជាដើម, អ្នកនេះឈ្មោះថា **មនុស្សលួចភេទ** ព្រោះគេលួច ត្រឹមតែភេទប៉ុណ្ណោះ ។ ចំណែកអ្នកណាជាសាមណេរដែលបានបួស អំពីសំណាក់ភិក្ខុទាំងឡាយ ហើយទៅកាន់ប្រទេសផ្សេងៗ ពោលកុហករាប់វស្សារបស់ភិក្ខុថា "ខ្ញុំមានវស្សា ១០" ឬថា "ខ្ញុំមានវស្សា ២០" ត្រេកអរនឹងការថ្វាយបង្គំតាមលំដាប់ចាស់ ខ្ចី, ហាមឃាត់ដោយអាសនៈ, ចូលទៅក្នុងសង្ឃកម្មមានឧបោសថ និងបវារណាជាដើម, អ្នកនេះឈ្មោះថា **មនុស្សលួចសំវាស** ព្រោះគេលួចត្រឹមតែសំវាសប៉ុណ្ណោះ ។ សេចក្ដីផ្សេងនៃកិរិយាសួម្បីទាំងពួង មានរាប់វស្សារបស់ភិក្ខុជាដើម អ្នកសិក្សាគួរដឹងថា "សំវាស" ក្នុងអត្ថនេះ ។ សួម្បីក្នុងបុគ្គលអ្នកលាសិក្ខាហើយ បដិបត្តិយ៉ាងនោះ ដោយគិតថា "អ្នកណាៗ រមែងមិនដឹងនូវការលាសិក្ខារបស់យើង" ក៏មានន័យដូចគ្នា ។

★ យោ បន សយំ បព្វជិត្វា វិហារំ គន្ត្វា **ភិក្ខុវស្សានិ** គណេតិ, យថាវុឌ្ឍំ វន្ទនំ សាទិយតិ អាសនេន បដិពាហតិ, ឧបោសថបវារណាទីសុ សន្ទិស្សតិ អយំ លិង្គស្ស ចេវ សំវាសស្ស ច ថេនិតត្តា ឧភយ-ត្ថេនកោ នាម ។ អយំ តិវិធោបិ ថេយ្យសំវាសកោ

អនុបសម្បន្នោ ន ឧបសម្បាទេតព្វោ ឧបសម្បន្នោ នាសេតព្វោ បុន បព្វជ្ជំ យាចន្តោបិ ន បព្វាជេតព្វោ ។ ចំណែកអ្នកណាបួសដោយខ្លួនឯង ហើយទៅកាន់វត្ត រាប់វស្សារបស់ភិក្ខុ, ត្រេកអរនឹងការថ្វាយបង្គំ តាមលំដាប់ចាស់ខ្ចីហាមឃាត់ដោយអាសនៈ, ចូលទៅក្នុងសង្ឃកម្ម មានឧបោសថនិងបវារណាជាដើម, អ្នកនេះឈ្មោះថា មនុស្សលួចទាំងពីរ ព្រោះភាវនៃខ្លួនជាអ្នកលួចទាំងភេទ ទាំងសំវាស ។ មនុស្សថេយ្យសំវាសទាំង ៣ ប្រភេទនេះ ជាអនុបសម្បន្ន មិនគួរឱ្យឧបសម្បទា, ជាឧបសម្បន្នហើយ គួរឱ្យវិនាសចេញ សូម្បីនឹងមកសូមបួសទៀត ក៏មិនគួរឱ្យបួស ។

**សូម្បីកាលរាប់វស្សារបស់សាមណេរ ក៏ជាថេយ្យសំវាសដែរ**

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

★ **"ភិក្ខុវស្សានី"តិ** ឥទំ សំវាសត្ថេនកេ វុត្តបាឋ-វសេន វុត្តំ, សយមេវ បន បព្វជិត្វា សាមណេរវស្សានិ គណេន្តោបិ ឧភយត្ថេនកោ ឯវ ។ ន កេវលញ្ច បុរិសោវ ឥត្ថីបិ ភិក្ខុនីសុ ឯវំ បដិបជ្ជតិ, ថេយ្យសំវាសិកាវ ។ អាធិកម្មិកាបិ ចេត្ថ ន មុច្ចន្តិ, ឧបសម្បន្នេសុ ឯវ

បញ្ញត្តាបត្តឹ បដិច្ច អាទិកម្មិកា វុត្តា, តេនេវេត្ថ អាទិកម្មិកោបិ ន មុត្តោ ។

*ពាក្យថា **រាប់វស្សារបស់ភិក្ខុ** ដូច្នេះនេះ គឺលោកអាចារ្យពោលហើយ ដោយអំណាចបាលី ដែលពោលហើយក្នុងការលួចសំវាសនេះ តែថាបុគ្គលណាបួសហើយដោយខ្លួនឯង **សូម្បីកាលរាប់វស្សា របស់សាមណេរជាការលួចទាំង ២ ពិត ។** មិនមែនត្រឹមតែបុរសតែម្យ៉ាងទេ, សូម្បីស្ត្រីទាំងឡាយកាលបដិបត្តិយ៉ាងនេះ ក្នុងភិក្ខុនីទាំងឡាយ, ជាថេយ្យសំវាសិកាពិត ។ សូម្បីអាទិកម្មិកបុគ្គលក៏មិនផុតក្នុងថេយ្យសំវាសនោះ អាទិកម្មិកទាំងឡាយ ដែលព្រះអង្គទ្រង់ត្រាស់ហើយ ព្រោះអាស្រ័យនូវអាបត្តិដែលទ្រង់បញ្ញត្តិចំពោះឧបសម្បន្នប៉ុណ្ណោះ ព្រោះហេតុនោះឯង ទើបអាទិកម្មិកបុគ្គលរមែងមិនរួចផុតក្នុងថេយ្យសំវាសនេះ ។*

## ការកាន់យកភេទដោយចិត្តបរិសុទ្ធ

*ក្នុងគម្ពីរអដ្ឋកថា ពោលទៀតថា:*

★ ឯត្ថ ច អសម្មោហត្ថំ ឥទំ បកិណ្ណកំ វេទិតព្វំ "រាជទុព្ភិក្ខកន្តាររោគវេរិភយេហិ វា ចីវរាហរណត្ថំ វា លិង្គំ អាទិយតីធ យោ ។ សំវាសំ នាធិវាសេតិ **យាវ**

**សោ សុទ្ធមានសោ ថេយ្យសំវាសកោ ឆាម តាវ ឯស ន វុច្ចតី"តិ ។** *ដើម្បីកុំឱ្យវង្វេងក្នុងថេយ្យសំវាសកនេះ គប្បីជ្រាប បទបកិណ្ណកៈនេះថា : ជនឯណាកាន់យកភេទ ក្នុងព្រះ-សាសនានេះ ព្រោះរាជភ័យ ទុព្ភិក្ខភ័យ កន្តារភ័យ រោគភ័យ និងវេរីភ័យក្តី ដើម្បីនឹងនាំចីវរមកក្តី ជននោះមានចិត្តបរិសុទ្ធ នៅមិនទាន់ទទួលយក ភេទត្រឹមណា ជននោះបណ្ឌិតនៅមិនទាន់ ពោលថា ជាមនុស្សថេយ្យសំវាសត្រឹមនោះ ។*

*<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>*

✯ យាវ សោ សុទ្ធមានសោតិ "ឥមិនា លិង្គេន ភិក្ខូ វញ្ចេត្វា តេហិ សំវសិស្សាមី"តិ អសុទ្ធចិត្តាភាវេន សុទ្ធចិត្តោ ។ តេន ហិ អសុទ្ធចិត្តេន លិង្គេ គហិតមត្តេ បច្ឆា ភិក្ខូហិ សហ សំវសតុ វា មា វា, លិង្គត្ថេនកោ ហោតិ ។ បច្ឆា សំវសន្តោបិ អភព្វោ ហុត្វា សំវសតិ តស្មា ឧភយត្ថេនកោបិ លិង្គត្ថេនកេឯវ បវិសតីតិ វេទិតព្វំ ។ *ពាក្យថា **ជននោះមានចិត្តបរិសុទ្ធនៅមិនទាន់ទទួល យកភេទត្រឹមណា** ដូច្នេះនេះ បណ្ឌិតគប្បីជ្រាបថា ភិក្ខុមាន ចិត្តបរិសុទ្ធ, ដោយមិនមានចិត្តមិនបរិសុទ្ធថា "អញនឹងបញ្ឆោត នូវភិក្ខុទាំងឡាយដោយភេទនេះ ហើយនឹងនៅរួមជាមួយនឹង*

ភិក្ខុទាំងឡាយនោះ” ។ ពិតមែន កាលភេទ គឺគេត្រឹមតែកាន់យកហើយ ដោយចិត្តមិនបរិសុទ្ធនោះ ជាអ្នកនៅរួមក្តី មិននៅរួមក្តី ជាមួយនឹងភិក្ខុទាំងឡាយ ក្នុងកាលជាខាងក្រោយ ក៏ជាការលួចភេទហើយ ។ សូម្បីកាលនៅរួមជាខាងក្រោយ ជាអភព្វបុគ្គលហើយទើបនៅរួម, ព្រោះហេតុនោះ សូម្បីការលួចទាំង ២ រមែងចូលទៅនៅក្នុងការលួចភេទនោះឯង ។

## ការកាន់យកភេទដោយបំណងលេង

ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:

**★ ថេយ្យសំវាសកោ នាម តាវ ឯស ន វុច្ចតី”តិ** ឯត្ថ ច ចោរាទិភយំ វិនាបិ កីឡាធិប្បាយេន លិង្គំ គហេត្វា ភិក្ខូនំ សន្តិកេ បព្វជិតាលយំ ទស្សេត្វា វន្ទនាទឹ អសាទិយន្តោបិ "សោភតិ នុ ខោ មេ បព្វជិតលិង្គ"-ន្តិអាទិនា សុទ្ធចិត្តេន គណ្ហន្តោបិ ថេយ្យសំវាសកោ ន ហោតីតិ ទដ្ឋព្វំ ។

ក្នុងពាក្យថា ជននោះ បណ្ឌិតនៅមិនទាន់ពោលថា ជាមនុស្សថេយ្យសំវាសត្រឹមនោះ ដូច្នេះនេះ បណ្ឌិតគប្បីជ្រាបថា សូម្បីបុគ្គលកាលកាន់យកនូវភេទ ដោយបំណងលេង សូម្បីវៀរចាកភ័យមានចោរភ័យជាដើម ហើយសម្តែងនូវស្រមោល

នៃបព្វជិត ក្នុងសំណាក់នៃភិក្ខុទាំងឡាយហើយ មិនត្រេកអរនូវការថ្វាយបង្គំជាដើមក្ដី កាលកាន់យកដោយចិត្ត បរិសុទ្ធមានគំនិតជាដើមថា "ភេទបព្វជិតរបស់អញសមឬហ្ន៎" ដូច្នេះក្ដី មិនជាថេយ្យសំវាសទេ ។

★ យោ បន រាជាទិភយេន សុទ្ធចិត្តោវ លិង្គំ គហេត្វា វិចរន្តោ បច្ឆា "ភិក្ខុវស្សានិ គណេត្វា ជីវិស្សាមី"តិ អសុទ្ធចិត្តំ ឧប្បាទេតិ, សោ ចិត្តុប្បាទមត្តេន ថេយ្យសំវាសកោបិ ន ហោតិ សុទ្ធចិត្តេន គហិតលិង្គត្តា ។ សចេ បន សោ ភិក្ខូនំ សន្តិកំ គន្ត្វា សាមណេរវស្សគណនាទីនិ ករោតិ, តទា សំវាសត្ថេនកោ ឧភយត្ថេនកោ វា ហោតីតិ ទដ្ឋព្វំ ។ ក៏បុគ្គលណា ជាអ្នកមានចិត្តបរិសុទ្ធតែម្យ៉ាង កាលកាន់យកនូវភេទ ព្រោះរាជភ័យហើយត្រេចទៅក្នុងកាលជាខាងក្រោយមក ញុំាងចិត្តមិនបរិសុទ្ធឱ្យកើតឡើងថា "អញនឹងរាប់នូវវស្សា របស់ភិក្ខុទាំងឡាយហើយនឹងរស់នៅ" បុគ្គលនោះ ត្រឹមតែការញុំាងចិត្តឱ្យកើតឡើងប៉ុណ្ណោះ មិនជាថេយ្យសំវាសទេ, ព្រោះការកាន់យកភេទដោយចិត្តបរិសុទ្ធ ។ ក៏ប្រសិនបើបុគ្គលនោះ ទៅកាន់សំណាក់ភិក្ខុទាំងឡាយហើយ ធ្វើនូវការរាប់វស្សារបស់សាមណេរ

ជាដើម ក្នុងកាលនោះ គប្បីជ្រាបថា ជាការលួចសំវាស ឬក៏លួចទាំង ២ ពិត ។

<u>ក្នុងគម្ពីអដ្ឋកថា ពោលទៀតថា:</u>

សចេបិស្ស លិង្គគ្គហណកាលេ ឯវំ ហោតិ "ឆាយំ កស្សចិ អារោចេស្សាមី"តិ វិហារញ្ច គតោ អារោចេតិ គហណេនេវ ថេយ្យសំវាសកោ ។ ប្រសិនបើក្នុងវេលាកាន់យកភេទ គេមានសេចក្ដីរំពឹងយ៉ាងនេះថា "យើងនឹងមិនប្រាប់ដល់អ្នកណាមួយ" ដូច្នេះ គេទៅកាន់វិហារហើយ រមែងប្រាប់ដោយការកាន់យក(ភេទ)នោះឯង គេជាមនុស្សថេយ្យសំវាស ។

អថាបិស្ស គហណកាលេ អាចិក្ខិស្សាមីតិ ចិត្តំ ឧប្បន្នំ ហោតិ ។ វិហារញ្ច គន្ត្វា កុហឹ ត្វំ អាវុសោ គតោតិ វុត្តោ ន ឥទានិ មំ ឥមេ ជានន្តីតិ វញ្ចេត្វា នាចិក្ខតិ នាចិក្ខិស្សាមីតិ សហ ធុរនិក្ខេបេន អយម្បិ ថេយ្យសំវាសកោវ ។ សូម្បីបើក្នុងវេលាកាន់យក (ភេទ) គេមានសេចក្ដីគិតកើតឡើងថា "យើងនឹងប្រាប់" តែទៅកាន់វិហារហើយ អ្នកណាប្រាស្រ័យថា "អ្នកមានអាយុ អ្នកទៅក្នុងទីណា" គិតថាឥឡូវនេះ ជនទាំងនេះមិនដឹងយើង, ទើបបញ្ឆោតមិនប្រាប់, សូម្បីអ្នកនេះក៏ឈ្មោះថា មនុស្សថេយ្យ

*សំវាសពិត ព្រមទាំងការដាក់ធុរៈ ថា "យើងនឹងមិនប្រាប់" ។*

សចេ បនស្ស គហណកាលេបិ អាចិក្ខិស្សាមីតិ ចិត្តំ ឧប្បន្នំ វិហារំ គន្ត្វាបិ អាចិក្ខតិ អយំ បុន បព្ពជ្ជំ លភតិ ។ *តែបើក្នុងវេលាកាន់យក (ភេទ) គេមានសេចក្តីគិតកើតឡើងថា "យើងនឹងប្រាប់" សូម្បីទៅកាន់វិហារហើយរមែងប្រាប់អ្នកនេះរមែងបានបព្វជ្ជាទៀត ។*

**សូម្បីមិនស្គាល់ឈ្មោះថេយ្យសំវាស ក៏ជាការលួចភេទដែរ**

*<u>ក្នុងគម្ពីអដ្ឋកថា ពោលទៀតថា៖</u>*

★ អបរោ ទហរសាមណេរោ មហន្តោ វា បន អញ្ញត្តោ សោ បុរិមនយេនេវ ឧប្បព្វជិត្វា យេ វុឌ្ឍករក្ខណាទីនិ កម្មានិ កាតុំ ន ឥច្ឆតិ, តមេនំ ញាតកា តានិយេវ កាសាយានិ អច្ឆាទេត្វា ជាលកំ វា បត្តំ វា ហត្ថេ ទត្វា "គច្ឆ សមណោវ ហោហី"តិ ឃរា នីហរន្តិ ។ សោ វិហារំ គច្ឆតិ នេវ នំ ភិក្ខូ ជានន្តិ អយំ ឧប្បព្វជិត្វា បុន សយមេវ បព្វជិតោតិ ។ នាបិ សយំ ជានាតិ យោ ឯវំ បព្វជតិ សោ ថេយ្យសំវាសកោ នាម ហោតីតិ ។ សចេ តំ បរិបុណ្ណវស្សំ ឧបសម្បា-

ទេន្តិ ស្វបសម្បន្នោ ។ ម្យ៉ាងទៀត សាមណេរកំលោះដទៃទៀតជាមនុស្សធំ តែល្ងង់មិនឈ្លាស, គេសឹកហើយដោយន័យមុននោះឯង មិនចង់ដើម្បីធ្វើកិច្ចមានឃ្វាលគោ ក្នុងផ្ទះជាដើម ។ ញាតិទាំងឡាយ(ញុំាងបុរសនោះ) ឱ្យស្លៀកដណ្តប់សំពត់កាសាយៈទាំងនោះឯង ហើយឱ្យភាជនៈ ឬបាត្រក្នុងដៃបណ្តេញចេញពីផ្ទះថា "អ្នកចូរទៅ, ចូរជាសមណៈចុះ" ។ គេក៏ទៅកាន់វិហារ ភិក្ខុទាំងឡាយមិនដឹងគេថា "អ្នកនេះសឹកហើយបួសដោយខ្លួនឯងទៀត" ។ ទាំងខ្លួនឯង ក៏មិនជ្រាបថាបុគ្គលណាបួសយ៉ាងនេះ បុគ្គលនោះឈ្មោះថាថេយ្យសំវាសបើភិក្ខុទាំងឡាយ ឱ្យឧបសម្បទាដល់គេ ជាអ្នកមានអាយុគ្រប់ ២០ ឆ្នាំ ។ គេជាការឧបសម្បន្ន ហើយយ៉ាងល្អ ។

<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:</u>

☆ **ឆាបិ សយំ ជានាតីតិ** យោ ឯវំ បព្វជតិ សោ ថេយ្យសំវាសកោ ឆាម ហោតីតិ វា ឯវំ កាតុំ ន លភតីតិ វា ឯវំ បព្វជិតោ សមណោ ន ហោតីតិ វា ន ជានាតិ ។

ពាក្យថា **ទាំងខ្លួនឯងក៏មិនជ្រាប** ដូច្នេះនេះ សេចក្តីថា មិនជ្រាបថា "អ្នកណាបួសយ៉ាងនេះ អ្នកនោះ ឈ្មោះថា ថេយ្យសំវាស" ឬថា "ខ្លួនធ្វើយ៉ាងនេះមិនបាន" ឬថា "អ្នកបួស

*យ៉ាងនេះ មិនមែនសមណៈ” ដូច្នេះ ។*

★ **យោ ឯវំ បព្វជតិ សោ ថេយ្យសំវាសកោ នាម ហោតីតិ** ឥទំ បទ និទស្សនមត្តំ ។

*ចំណែកពាក្យថា បុគ្គលណាបួសយ៉ាងនេះ បុគ្គលនោះ ឈ្មោះថា ថេយ្យសំវាស ដូច្នេះនេះ ត្រឹមតែជាតួយ៉ាង (គឺ ជាឧទាហរណ៍) ប៉ុណ្ណោះ ។*

*<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលទៀតថា:</u>*

★ **យោ ឯវំ បព្វជតិ សោ ថេយ្យសំវាសកោ នាម ហោតីតិ** ឥទំ និទស្សនមត្តំ, "ថេយ្យសំវាសកោ"តិ បទ នាមំ អជានន្តោបិ "ឯវំ កាតុំ ន វដ្ដតី"តិ វា "ឯវំ ករោន្តោ សមណោ នាម ន ហោតី"តិ វា "យទិ អារោចេស្សាមិ ឆឌ្ឌេស្សន្តិ ម"ន្តិ វា "យេន កេនចិ បព្វជ្ជា មេ ន រុហតី"តិ ជានាតិ ថេយ្យសំវាសកោ ហោតិ ។

*ពាក្យថា បុគ្គលណាបួសយ៉ាងនេះ បុគ្គលនោះ ឈ្មោះថា ថេយ្យសំវាស ដូច្នេះនេះ ពាក្យនេះត្រឹមតែជាតួយ៉ាង (គឺជាឧទាហរណ៍)ប៉ុណ្ណោះ,* ***ចំណែកបុគ្គលណា សូម្បីមិនដឹងនូវ*** *ឈ្មោះថា “ថេយ្យសំវាស” ទេ, តែដឹងថា “ការធ្វើយ៉ាងនេះ*

មិនគួរក្តី” ថា “ការធ្វើយ៉ាងនេះ មិនឈ្មោះថា ជាសមណៈក្តី” ថា “ប្រសិនបើអញនឹងប្រាប់, ភិក្ខុទាំងឡាយនឹងលះបង់ (អញ) ចោលក្តី” ថា “បព្វជ្ជារបស់អញមិនឡើង ដោយហេតុណាទីមួយក្តី ” បុគ្គលនោះ រមែងជា **ថេយ្យសំវាស** ។

**ការកាន់យកភេទជាអ្នកបួស ហើយទៅបញ្ឆោតគ្រហស្ថ**

<u>ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:</u>

☆ វិទេសំ គន្ត្វា បព្វជិតេហិ បុដ្ឋោ "ទសវស្សោ"តិអាទី ភណន្តស្ស ទោសោ ។ គិហីនំ វុត្តេ ទោសោ នត្ថីតិ កេចិ ។ រាជភយាទីហិ គហិតលិង្គានំ "គិហី មំ សមណោតិ ជានាតូ"តិ វញ្ចនចិត្តេ សតិបិ ភិក្ខូនំ វញ្ចេតុកាមតាយ, តេហិ សំវសិតុកាមតាយ ច អភាវា ទោសោ ន ជាតោ ។

(បុគ្គលកាលកាន់យកភេទហើយ) ទៅកាន់ប្រទេសដទៃ ត្រូវបព្វជិតសួរហើយ ពោលនូវពាក្យជាដើមថា “ខ្ញុំព្រះករុណាជាអ្នកមានវស្សា ១០ ហើយ” ដូច្នេះ រមែងមានទោស ។ អាចារ្យពួកខ្លះពោលថា កាលពោលប្រាប់ដល់គ្រហស្ថទាំងឡាយ ទោសរមែងមិនមាន ។ សូម្បីកាលមានចិត្តគិតបញ្ឆោតថា “គ្រហស្ថចូរដឹងថា អញជាសមណៈ” ដូច្នេះ របស់បុគ្គល

*អ្នកកាន់យកនូវភេទព្រោះរាជភ័យជាដើម ក៏មិនមានទោសដែរ ព្រោះមិនមានបំណង ដើម្បីបញ្ឆោតនូវភិក្ខុទាំងឡាយផង ព្រោះមិនមានប្រាថ្នាដើម្បីនឹងនៅរួម ជាមួយនឹងភិក្ខុទាំងឡាយផង ។*

✯ **សូបសម្បន្នោតិ** វុត្តត្ថា គហដ្ឋម្បិ សចេ ឧបសម្បាទេន្តិ សូបសម្បន្នោតិ អាបន្នំ ។

*ព្រោះព្រះអដ្ឋកថាចារ្យពោលថា "ជាការឧបសម្បទាហើយដោយល្អ" ដូច្នេះ លោកសម្រេចសេចក្តីថា ប្រសិនបើសង្ឃញុំាងបុគ្គលជាគ្រហស្ថឱ្យឧបសម្បទា ជាការឧបសម្បទាហើយដោយល្អ ។*

*<u>ក្នុងគម្ពីរអដ្ឋកថា ពោលទៀតថា:</u>*

✯ សចេ បន, **អនុបសម្បន្នកាលេយេវ** វិនយ-វិនិច្ឆយេ វត្តមានេ សុណាតិ យោ ឯវំ បព្វជតិ, សោ ថេយ្យសំវាសកោ នាម ហោតីតិ, តេន មយា ឯវំ កតន្តិ ភិក្ខូនំ អាចិក្ខិតព្វំ ឯវំ បុន បព្វជ្ជំ លភតិ, សចេ ន ធានិ មំ កោចិ ជានាតីតិ ន អារោចេតិ, ធុរេ និក្ខិត្តមត្តេ ថេយ្យសំវាសកោ ។ *តែបើក្នុងវេលាដែលខ្លួននៅជាអនុ-បសម្បន្ននោះឯង កាលការវិនិច្ឆ័យព្រះវិន័យ កំពុងប្រព្រឹត្តទៅ*

គេបានឮថា "អ្នកណាបួសយ៉ាងនេះ អ្នកនោះ រមែងជាមនុស្ស ដែលឈ្មោះថា ថេយ្យសំវាស" ដូច្នេះ គេគប្បីប្រាប់ដល់ភិក្ខុទាំងឡាយថា "ខ្ញុំបានធ្វើយ៉ាងនោះ" ។ ដោយប្រការយ៉ាងនេះ គេរមែងបានបព្វជ្ជាទៀត ។ បើមិនប្រាប់ដោយគិតថា "ឥឡូវនេះ អ្នកណាមួយមិនដឹងឃើញឡើយ" លុះមដាក់ធុរៈ គេរមែងជាមនុស្សថេយ្យសំវាស ។

<u>ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:</u>

★ **"អនុបសម្បន្នកាលេយេវា"តិ** ឥមិនា សចេ ឧបសម្បន្នកាលេ សុណាតិ, សូបសម្បន្នោ ឯវ អនាបត្តិចេតោបីតិ ធស្សេតិ ។ ដោយពាក្យថា *ដែលខ្លួននៅជាអនុបសម្បន្ននោះឯង* ដូច្នេះនេះ លោកសម្តែងថា ប្រសិនបើបានឮក្នុងកាលដែលខ្លួនឧបសម្បទាហើយ, រមែងជាឧបសម្បន្នល្អពិត, សូម្បីកាលមិនប្រាប់ ។

<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលបន្ថែមទៀតថា:</u>

★ **អនុបសម្បន្នកាលេយេវាតិ ឥមិនា** ឧបសម្បន្នកាលេ សុត្វា សចេបិ នារោចេតិ ថេយ្យសំវាសកោ ន ហោតីតិ ធីបេតិ ។ ដោយពាក្យថា *ដែលខ្លួននៅជាអនុបសម្បន្ននោះឯង* ដូច្នេះនេះ លោកអាចារ្យរមែងសម្តែងថា

លោកបានស្តាប់ក្នុងវេលា ដែលខ្លួនឧបសម្បទាហើយ សូម្បីបើនៅមិនប្រាប់ ក៏មិនជាថេយ្យសំវាសដែរ ។

<u>ក្នុងគម្ពីរអដ្ឋកថា ពោលទៀតថា:</u>

✯ ភិក្ខុ សិក្ខំ បច្ចក្ខាយ លិង្គំ អបនេត្វា ធុស្សីលកម្មំ កត្វា វា អកត្វា វា បុន សត្វំ បុព្វេ វុត្តំ វស្សគណនាទិភេទំ វិធឹ បដិបជ្ជតិ ថេយ្យសំវាសកោ ហោតិ ។ ភិក្ខុលាសិក្ខាហើយលះនូវភេទហើយ ធ្វើកម្មគឺទ្រុស្ត-សីលក៏ដោយ មិនធ្វើក៏ដោយ បដិបត្តិវិធីផ្សេងដោយប្រភេទមានការរាប់វស្សាជាដើម ដែលពោលមកហើយ ក្នុងខាងដើមទាំងអស់ រមែងជាមនុស្សថេយ្យសំវាស ។

សិក្ខំ អប្បច្ចក្ខាយ សលិង្គេ ឋិតោ មេថុនំ បដិសេវិត្វា វស្សគណនាទិភេទំ វិធឹ អាបជ្ជន្តោ ថេយ្យ-សំវាសកោ ន ហោតិ, បព្វជ្ជាមត្តំ លភតិ ។ ភិក្ខុមិនបានលាសិក្ខាតាំងនៅ ក្នុងភេទរបស់ខ្លួន សេពមេថុន ប្រើវិធីផ្សេងដោយការរាប់វស្សាជាដើម មិនជាមនុស្សថេយ្យសំវាស រមែងបានត្រឹមតែបព្វជ្ជា ។

<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:</u>

**✯ សិក្ខំ អប្បច្ចក្ខាយ ។បេ ។ ថេយ្យសំវាសកោ ន**

**ហោតីតិ** ឥធំ ភិក្ខុហិ ធិន្នលិង្គស្ស អបរិច្ចត្តា ន លិង្គថេនកោ ហោតិ លិង្គានុរូបស្ស សំវាសស្ស សាទិ-តត្តា ណាបិ សំវាសថេនកោ ហោតីតិ វុត្តំ ។

*ពាក្យថា មិនបានលាសិក្ខា តាំងនៅក្នុងភេទរបស់ខ្លួន សេពមេថុន ប្រើវិធីផ្សេងដោយប្រភេទមានការរាប់វស្សាជាដើម មិនជាមនុស្សថេយ្យសំវាស ដូច្នេះនេះ លោកអាចារ្យពោល ទុកថា រមែងមិនជាមនុស្សលួចភេទទេ ព្រោះនៅមិនបានលះ បង់ភេទ ដែលភិក្ខុទាំងឡាយឱ្យ, ទាំងមិនជាមនុស្សលួចសំវាស ព្រោះនៅត្រេកអរក្នុងសំវាស ដែលសមគួរដល់ភេទ ។*

*<u>ក្នុងគម្ពីរអដ្ឋកថាពោលថា:</u>*

★ ឯកោ ភិក្ខុ កាសាយេ សឧស្សាហោវ ឱទាតំ និវាសេត្វា មេថុនំ បដិសេវិត្វា បុន កាសាយានិ និវាសេត្វា វស្សគណនាទិភេទំ សព្វំ វិធី អាបជ្ជតិ អយម្បិ ថេយ្យសំវាសកោ ន ហោតិ បព្វជ្ជាមត្តំ លភតិ ។ *ភិក្ខុ ១ រូប នៅមានសេចក្តីអាល័យ ក្នុងសំពត់កាសាយៈ ហើយទៅ ស្លៀកសំពត់-ស រួចសេពមេថុន, ហើយត្រឡប់ស្លៀកសំពត់ កាសាយៈទៀត ប្រើវិធីទាំងពួងផ្សេងដោយប្រភេទ មានការរាប់*

*វស្សាជាដើម សូម្បីភិក្ខុនេះ មិនមែនជាមនុស្សថេយ្យសំវាសទេ (តែ) រមែងបានត្រឹមតែបព្វជ្ជា ។*

សចេ បន កាសាយេ ធុរំ និក្ខិបិត្វា នគ្គោ ហុត្វា (?)

សចេ បន កាសាយេ ធុរំ និក្ខិបិត្វា ឱទាតំ និវាសេត្វា មេថុនំ បដិសេវិត្វា បុន កាសាយានិ និវាសេត្វា វស្សគណនាទិភេទំ សព្វំ វិធឹ អាបជ្ជតិ ថេយ្យសំវាសកោ ហោតិ ។ *តែបើដាក់ធុរៈក្នុងសំពត់កាសាយៈហើយ ស្លៀកសំពត់ស, រួចសេពមេថុន ហើយត្រឡប់ស្លៀកសំពត់កាសាយៈទៀត ប្រើវិធីទាំងពួងផ្សេងដោយប្រភេទ មានការរាប់វស្សាជាដើម គេរមែងជាមនុស្សថេយ្យសំវាស ។*

សាមណេរោ សលិង្គេ ឋិតោ មេថុនាទិ អស្សមណ-ករណធម្មំ អាបជ្ជិត្វាបិ **ថេយ្យសំវាសកោ ន ហោតិ** ។ សចេបិ កាសាយេ សឧស្សាហោវ កាសាយានិ អបនេត្វា មេថុនំ បដិសេវិត្វា បុន កាសាយានិ និវាសេតិ នេវ ថេយ្យសំវាសកោ ហោតិ ។ *សាមណេរតាំងនៅក្នុងភេទរបស់ខ្លួន សូម្បីកន្លងធម៌ធ្វើឱ្យជាអ្នកមិនមែនសមណៈ មាន (ការសេព)មេថុនជាដើមហើយ រមែងមិនជាមនុស្សថេយ្យសំវាសទេ ។ ប្រសិនបើនៅមានសេចក្ដីអាល័យ ក្នុងសំពត់កាសាយៈ, ដោះចេញនូវសំពត់កាសាយៈទាំងឡាយហើយ*

*សេពមេថុន ហើយត្រឡប់ស្លៀកសំពត់កាសាយៈទៀត មិនជាមនុស្សថេយ្យសំវាសដូចគ្នា ។*

សចេ បន កាសាយេ ធុរំ និក្ខិបិត្វា នគ្គោ វា ឱទាតនិវត្ថោ វា មេថុនសេវនាទីហិ អស្សមណោ ហុត្វា កាសាយំ និវាសេតិ ថេយ្យសំវាសកោ ហោតិ ។

*តែបើដាក់ធុរៈនៅក្នុងសំពត់កាសាយៈហើយ ជាអ្នកអាក្រាត ឬស្លៀកសំពត់ស, ជាអ្នកមិនមែនសមណៈ ដោយការសេពមេថុនជាដើម ហើយត្រឡប់ស្លៀកសំពត់កាសាយៈទៀតគេ រមែងជាមនុស្សថេយ្យសំវាស ។*

*<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>*

✯ **ថេយ្យសំវាសកោ ន ហោតីតិ** ភិក្ខូហិ ទិន្នលិង្គស្ស អបរិច្ចត្តត្តា លិង្គត្ថេនកោ ន ហោតិ, ភិក្ខុបដិញ្ញាយ អបរិច្ចត្តត្តា សំវាសត្ថេនកោ ន ហោតីតិ ។ យថា ចេត្ថ ភិក្ខុ, ឯវំ សាមណេរោបិ ធារាជិកំ សមាបន្នោ សាមណេរបដិញ្ញាយ អបរិច្ចត្តត្តា សំវាសត្ថេនកោ ន ហោតីតិ វេទិតព្វោ ។ *ពាក្យថា* **មិនជាមនុស្សថេយ្យសំវាស** *ដូច្នេះនេះ មានសេចក្តីថា ការលួចភេទរមែងមិនមាន, ព្រោះភាវៈនៃភេទ ដែលភិក្ខុឱ្យហើយ គឺខ្លួនមិនបានលះបង់ចេញ ។*

ការលួចសំវាសរមែងមិនមាន, ព្រោះការប្តេជ្ញាជាភិក្ខុ គឺខ្លួនមិនទាន់លះបង់ចេញ ។ បណ្ឌិតគប្បីជ្រាបថា ក៏ក្នុងសេចក្តីនេះ ភិក្ខុយ៉ាងណា សូម្បីសាមណេរដែលដល់នូវបារាជិក រមែងមិនជាការលួចសំវាសក៏យ៉ាងនោះដែរ, ព្រោះការប្តេជ្ញាថាជាសាមណេរ គឺខ្លួនមិនទាន់លះបង់ ។

**សាមណេរប្រាថ្នាទៅជាគ្រហស្ថ ស្លៀកសំពត់ដូចគ្រហស្ថមិនគួរ**

<u>ក្នុងគម្ពីរអដ្ឋកថាពោលថា:</u>

★ សចេ គិហិភាវំ បត្ថយមានោ កាសាវំ ឱវដ្ដិកំ វា កត្វា អញ្ញេន វា អាការេន គិហិនិវាសនេន និវាសេតិ សោភតិ នុ ខោ មេ គិហិលិង្គំ ន សោភតីតិ វីមំសនត្ថំ រក្ខតិ តាវ ។ លភតីតិ សម្បដិច្ឆិត្វា បន បុន លិង្គំ សាទិយន្តោ ថេយ្យសំវាសកោ ឆាម ។ ឱទាតំ និវាសេត្វា វីមំសនសម្បដិច្ឆនេសុបិ ឯសេវ នយោ ។

បើសាមណេរប្រាថ្នានូវភាវៈជាគ្រហស្ថ ទើបស្លៀកសំពត់ដូចជាគ្រហស្ថ ធ្វើនូវសំពត់កាសាយៈចងក្បិនក្តី ដោយអាការៈយ៉ាងដទៃក្តី ដើម្បីល្បងមើលថា "ភេទជាគ្រហស្ថរបស់យើងសម ឬ មិនសម" នៅរក្សានៅឡើយ ។ តែបើព្រមទទួលថា "សមហើយ" ត្រឡប់ត្រេកអរភេទទៀត

*រមែងជាមនុស្សថេយ្យសំវាស ។ ក្នុងការស្លៀកសំពត់-ស ល្បងមើលនឹងព្រមទទួលក៏ន័យនេះឯង ។*

សចេ បន និវត្ថកាសាយស្ស ឧបរិ ឱទាតំ និវាសេត្វា វីមំសតិ វា សម្បដិច្ឆតិ វា រក្ខតិយេវ ភិក្ខុនិយាបិ ឯសេវ នយោ ។ *ក៏ប្រសិនបើស្លៀកសំពត់-ស សង្កត់ខាងលើសំពត់កាសាយៈដែលស្លៀកហើយ, ល្បងមើល ក៏ដោយ ព្រមទទួលក៏ដោយ នៅរក្សាដោយពិត ។ សូម្បីក្នុង ភិក្ខុនី ក៏មានន័យនេះដូចគ្នា ។*

*<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>*

☆ **សោភតីតិ សម្បដិច្ឆិត្វាតិ** កាសាវធារណេ ធុរំ និក្ខិបិត្វា គិហិភាវំ សម្បដិច្ឆិត្វា ។ សយមេវ បន បព្វជិត្វា សាមណេរវស្សានិ គណេន្តោបិ ឧភយត្ថេនកោ ឯវ ។ *ពាក្យថា **បើព្រមទទួលថាសមហើយ** ដូច្នេះនេះ មានសេចក្តីថា កាលសាមណេរដាក់ធុរៈ ក្នុងការទ្រទ្រង់សំពត់កាសាយៈ ហើយទទួលព្រមនូវភាពជាគ្រហស្ថ ។ ចំណែក (គ្រហស្ថ) បួសខ្លួនឯង សូម្បីរាប់វស្សារបស់សាមណេរ ក៏ឈ្មោះថា លួចទាំងពីរដែរ ។*

## សាមណេររាប់វស្សាកោង ជាមួយសាមណេរ

*ក្នុងគម្ពីរអដ្ឋកថា ពោលថា:*

*បើសាមណេររូបខ្លះ បួសឯចាស់ មិនរាប់វស្សា(ភិក្ខុ) មិនឈរនៅសូម្បីក្នុងជួរ, មកតាមផ្លូវម្ខាង, កាលដុំបាយក្នុងភាជនៈធំជាដើម ដែលគេយកវែកដួសឡើង, បង្អោនបាត្រចូលទៅទទួលយក ដូចជាខ្លែងឆាបដុំសាច់ទៅដូច្នោះ, នៅមិនជាមនុស្សថេយ្យសំវាស ។*

ភិក្ខុវស្សានិ បន គណេត្វា គណ្ហន្តោ ថេយ្យសំវាសកោ ហោតិ ។ សយំ សាមណោវ សាមណេរបដិបាដិយា កូដវស្សានិ គណេត្វា គណ្ហន្តោ ថេយ្យសំវាសកោ ន ហោតិ ។ ភិក្ខុ ភិក្ខុបដិបាដិយា កូដវស្សានិ គណេត្វា គណ្ហន្តោ ភណ្ឌគ្ឃេន ការេតព្វោ ។ *តែកាលរាប់វស្សាភិក្ខុទទួលយក ចាត់ថាជាមនុស្សថេយ្យសំវាស ។ សាមណេរនោះឯង កាលរាប់វស្សាកោងដោយលំដាប់របស់សាមណេរដោយខ្លួនឯង ហើយទទួលយកទៅ មិនចាត់ជាថេយ្យសំវាសទេ ភិក្ខុកាលរាប់វស្សាកោង ដោយលំដាប់របស់ភិក្ខុទទួលយកទៅ គប្បីកាត់តម្លៃនៃភណ្ឌ ។*

**ថេយ្យសំវាសកកថាចប់ ។**

# ៨_អនុបជ្ឈាយកានិទានកថា

*ក្នុងវិនយបិដកភាគ ៦ ទំព័រ ២៩៤ ត្រាស់ថា:*

★ ន ភិក្ខវេ អនុបជ្ឈាយកោ ឧបសម្បាទេតព្វោ យោ ឧបសម្បាទេយ្យ អាបត្តិ ទុក្កដស្ស ។ *ម្នាលភិក្ខុទាំងឡាយ សាមណេរដែលគ្មានឧបជ្ឈាយ៍ ភិក្ខុមិនគប្បីឱ្យឧបសម្បទាឡើយ ភិក្ខុណាឱ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ ។*

**ការបួសជាភិក្ខុ សូម្បីមិនមានឧបជ្ឈាយ៍ក៏ឡើង**

*ក្នុងព្រះអដ្ឋកថា ពោលថា:*

★ **ន ភិក្ខវេ អនុបជ្ឈាយកោតិ** ឧបជ្ឈំ អគាហាបេត្វា និរុបជ្ឈាយកោ ន ឧបសម្បាទេតព្វោ ។ យោ **ឧបសម្បាទេយ្យ អាបត្តិ ទុក្កដស្សាតិ** សិក្ខាបទបញ្ញត្តិតោ បដ្ឋាយ ឯវំ ឧបសម្បាទេន្តស្ស អាបត្តិ ហោតិ **កម្មំ បន ន ហោតិ** ។ កេចិ កុប្បតីតិ វទន្តិ, តំ ន គហេតព្វំ ។ សង្ឃេន ឧបជ្ឈាយេនាតិអាទីសុបិ ឧភតោព្យញ្ជនកុបជ្ឈាយបរិយោសានេសុ ឯសេវ នយោ ។

*ពាក្យថា **ម្នាលភិក្ខុទាំងឡាយ សាមណេរដែលគ្មានឧបជ្ឈាយ៍** ដូច្នេះនេះ មានសេចក្តីថា សាមណេរគ្មានឧបជ្ឈាយ៍ ព្រោះមិនបានកាន់យកនូវឧបជ្ឈាយ៍, មិនគប្បីឱ្យឧបសម្បទាទេ ។*

*ពាក្យថា **ភិក្ខុណាឱ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ** ដូច្នេះនេះ មានសេចក្តីថា ចាប់ផ្តើមអំពីកាលដែលព្រះអង្គ បញ្ញត្តិសិក្ខាបទហើយ ភិក្ខុកាលឱ្យឧបសម្បទាយ៉ាងនេះ រមែងត្រូវអាបត្តិទុក្កដ ។ **តែកម្មមិនកម្រើកឡើយ** ។ អាចារ្យពួកខ្លះពោលថាកម្មរមែងកម្រើក ។ ពាក្យអាចារ្យនោះ មិនគប្បីកាន់យកទេ ។ សូម្បីក្នុងឧបជ្ឈាយ៍ដែលជាសង្ឃជាដើម (រហូតដល់) មានឧបជ្ឈាយ៍ ជាឧភតោព្យញ្ជនកៈជាទីបំផុត ក៏មានន័យនេះដូចគ្នា ។*

*<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>*

★ **"កម្មំ បន ន កុប្បតី"តិ** ឥទំ ឧបជ្ឈាយាភាវេបិ "ឥត្ថន្នាមស្ស ឧបសម្បទាបេក្ខោ, ឥត្ថន្នាមេន ឧបជ្ឈាយេនា"តិ មតស្ស វា វិព្ភមន្តស្ស វា បុរាណឧបជ្ឈាយស្ស, អញ្ញស្ស វា យស្ស កស្សចិ អវិជ្ជមានស្សាបិ នាមេន សព្វត្ថ ឧបជ្ឈាយកិត្តនស្ស កតត្តា វុត្តំ ។

ពាក្យថា ***តែកម្មមិនកម្រើកឡើយ*** ដូច្នេះនេះ មានសេចក្តីថា សូម្បីមិនមានឧបជ្ឈាយ៍ គឺលោកពោលហើយ ព្រោះអាចារ្យ អ្នកសូត្រធ្វើការកំណត់ព្រះឧបជ្ឈាយ៍ ក្នុងទីទាំងពួង ***ដោយឈ្មោះរបស់ភិក្ខុសូម្បីកាលមិនមាន*** គឺរបស់ឧបជ្ឈាយ៍ដែលស្លាប់ទៅក្តី ឧបជ្ឈាយ៍សឹកទៅក្តី ឧបជ្ឈាយ៍មានក្នុងកាលមុនរបស់ភិក្ខុដទៃណាមួយក្តី ថា ***"នាគនេះ ជាឧបសម្បទាបេក្ខរបស់ភិក្ខុឈ្មោះនេះ ដោយមានភិក្ខុឈ្មោះនេះជាឧបជ្ឈាយ៍"*** ដូច្នេះ ។

*<u>ក្នុងវិនយបិដកភាគ ៦ ទំព័រ ២៩៥ ត្រាស់ថា:</u>*

✯ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគប្បីឱ្យឧបសម្បទាដោយមានឧបជ្ឈាយ៍ជាមនុស្សខ្ទើយ, ដោយមានឧបជ្ឈាយ៍ជាមនុស្សថេយ្យសំវាស, ដោយមានឧបជ្ឈាយ៍ជាអ្នកចូលពួកតិរ្ថិយ ។ល។ ភិក្ខុមិនគប្បីឱ្យឧបសម្បទា ដោយមានឧបជ្ឈាយ៍ជាឧភតោព្យញ្ជនក: ភិក្ខុណាឱ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ ។

*<u>ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:</u>*

✯ **បណ្ឌកាទិ ឧបជ្ឈាយេន ឧបសម្បាទេន្តិ** ឧប-សម្បាទនកាលេ អវិទិតត្តាតិ បោរាណា ។

បុរាណាចារ្យទាំងឡាយពោលថា ភិក្ខុទាំងឡាយ តែងឱ្យនូវឧបសម្បទា ដោយមានឧបជ្ឈាយ៍ ជាមនុស្សខ្ទើយជាដើម

*ព្រោះលោកមិនបានជ្រាប ក្នុងកាលដែលឱ្យនូវឧបសម្បទា ។*

*<u>ក្នុងវិនយបិដកភាគ ៦ ទំព័រ ២៩៨ ត្រាស់ថា:</u>*

★ ន ភិក្ខវេ ហត្ថច្ឆិន្នោ បព្វាជេតព្វោ យោ បព្វាជេយ្យ អាបត្តិ ទុក្កដស្ស ។ *ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវបំបួស មនុស្សកំបុតដៃ (ជាដើម) ទេ ភិក្ខុណា បំបួស ត្រូវអាបត្តិទុក្កដ ។*

**ការឱ្យសាមណេរក្នុងកម្មមិនប្រកបដោយធម៌ ព្រោះមានអន្តរាយគួរ**

*<u>ក្នុងព្រះអដ្ឋកថា ពោលថា:</u>*

★ យេសញ្ច បព្វជ្ជា បដិក្ខិត្តា, ឧបសម្បទាបិ តេសំ បដិក្ខិត្តាវ ។ សចេ បន តេ សង្ឃោ ឧបសម្បាទេតិ សព្វេបិ ហត្ថច្ឆិន្នាទយោ សូបសម្បន្នា, ការកសង្ឃោ បន អាចរិយុបជ្ឈាយា ច **អាបត្តិតោ ន មុច្ចន្តិ** ។

*ក៏បព្វជ្ជារបស់បុគ្គលណា ដែលព្រះអង្គហាមហើយ,សូម្បីឧបសម្បទារបស់បុគ្គលពួកនោះ ក៏ព្រះអង្គហាមដែរ, ប្រសិនបើសង្ឃឱ្យឧបសម្បទាដល់បុគ្គលនោះ, បុគ្គលទាំងឡាយ មានមនុស្សកំបុតដៃជាដើម សូម្បីទាំងអស់ជាការឧបសម្បទាហើយដោយល្អ, ចំណែកការកៈសង្ឃ និង អាចារ្យ ឧបជ្ឈាយ៍ មិន*

*រូបផុតចាកអាបត្តិឡើយ ។*

*<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>*

☆ **អាបត្តិតោ ន មុច្ចតីតិ** ញត្វា ករោន្តោវ ន មុច្ចតិ ។ ជីវិតន្តរាយាទិអាបទាសុ អរុចិយា កាយសាមគ្គឹ ទេន្តស្ស អនាបត្តិ ។ *ពាក្យថា* **មិនរួចផុតចាកអាបត្តិឡើយ** *ដូច្នេះនេះ មានសេចក្តីថា កាលដឹងហើយធ្វើ រមែងមិនរួចផុតចាកអាបត្តិទេ ។ តែជាអនាបត្តិដល់ភិក្ខុ កាលឱ្យនូវកាយសាមគ្គី ដោយសេចក្តីមិនពេញចិត្ត ព្រោះខ្លាចអន្តរាយ មានអន្តរាយដល់ជីវិតជាដើម ។*

*<u>ក្នុងវិនយបិដកភាគ ៦ ទំព័រ ៣៧៤ ពោលថា:</u>*

*សម័យនោះឯងពួកភិក្ខុឆព្វគ្គិយ ធ្វើកម្មមិនមែនជាធម៌ ក្នុងកណ្តាលសង្ឃ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនោះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គត្រាស់ថា :*

☆ អនុជានាមិ ភិក្ខវេ ចតូហិ បញ្ចហិ បដិក្កោសិតុំ ទ្វីហិ តីហិ ទិដ្ឋឹ អាវិកាតុំ, ឯកេន អធិដ្ឋាតុំ ន មេ តំ ខមតីតិ ។ *ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុ ៤ ឬ ៥ រូបហាមឃាត់, ឱ្យភិក្ខុ ២ ឬ ៣ រូប ប្រកាសសេចក្តីយល់ឃើញថា (កម្មនោះមិនគាប់ចិត្តដល់ខ្ញុំករុណាទេ) ឱ្យភិក្ខុ ១*

រូប អធិដ្ឋានថា "កម្មនោះមិនគាប់ចិត្តដល់អញទេ" ។

**ព្រះឧបជ្ឈាយ៍សូត្រកម្មវាចា ឱ្យសទ្ធិវិហារិករបស់ខ្លួនក៏គួរ**

<u>ក្នុងព្រះអដ្ឋកថា ពោលថា:</u>

★ សចេ បន នានាចរិយា នានុបជ្ឈាយា ហោន្តិ, តិស្សត្ថេរោ សុមនត្ថេរស្ស សទ្ធិវិហារិកំ, សុមនត្ថេរោ តិស្សត្ថេរស្ស សទ្ធិវិហារិកំ អនុស្សាវេតិ, អញ្ញមញ្ញញ្ច គណបូរកា ហោន្តិ, វដ្ដតិ ។ *ក៏ប្រសិនបើអាចារ្យ ផ្សេងៗគ្នា ឧបជ្ឈាយ៍ក៏ផ្សេងៗគ្នា, គឺព្រះតិស្សត្ថេរ សូត្រអនុស្សាវនា ឱ្យសទ្ធិវិហារិករបស់ព្រះសុមនត្ថេរ, ព្រះសុមនត្ថេរ សូត្រអនុស្សាវនា ឱ្យសទ្ធិវិហារិករបស់ព្រះតិស្សត្ថេរ, អ្នកទាំងនោះ រមែងជាគណបូរកៈ ដល់គ្នាទៅវិញទៅមក, រមែងគួរ ។*

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

★ សចេ បន ឧបជ្ឈាយោ សយមេវ អត្តនោ សទ្ធិវិហារិកំ អនុស្សាវេតីតិ ឯត្ថ វត្តព្វមេវ នត្ថិ, កម្មំ សុកតមេវ ហោតិ ។ *ក៏ប្រសិនបើឧបជ្ឈាយ៍សូត្រ(កម្មវាចា) ឱ្យសទ្ធិវិហារិក របស់ខ្លួនដោយខ្លួនឯង ដូច្នេះ មិនមានពាក្យ ដែលគប្បីពោលក្នុងសេចក្តីនោះទេ, កម្មជាការធ្វើល្អហើយពិត ។*

<u>*ក្នុងវិនយបិដកភាគ ៦ ទំព័រ ៣០៤ ពោលថាៈ*</u>

★ អនុជានាមិ ភិក្ខវេ **គោត្តេនបិ** អនុស្សាវេតុំ ។ *ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុសូត្រ អនុស្សាវនា ដោយគោត្តនាមក៏បាន ។*

**មុននឹងសូត្រកម្មវាចា ត្រូវឱ្យកាន់យកឈ្មោះសិន**

<u>*ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថាៈ*</u>

★ **គោត្តេនបីតិ** "អាយស្មតោ បិប្ផលិស្ស ឧបសម្បទាបេក្ខោ"តិ ឯវំ នាមំ អវត្វា គោត្តនាមេនបីតិ អត្ថោ, តេន "កោនាមោ តេ ឧបជ្ឈាយោ"តិ បុដ្ឋេន គោត្តនាមេន "អាយស្មា កស្សបោ"តិ វត្តព្វន្តិ សិទ្ធំ ហោតិ ។ តស្មា អញ្ញម្បិ កិញ្ចិ តស្ស នាមំ បសិទ្ធំ, តស្មឹ វា ខណេ សុខគ្គហណត្ថំ នាមំ បញ្ញាបិតំ, តំ សព្វំ គហេត្វាបិ អនុស្សាវនា កាតព្វា ។ *ពាក្យថា សូម្បីដោយគោត្រ ដូច្នេះ នេះ មានសេចក្តីថា ភិក្ខុមិនត្រូវពោលនូវឈ្មោះយ៉ាងនេះថា "អ្នកជាឧបសម្បទាបេក្ខៈ របស់ព្រះបិប្ផលិដ៏មានអាយុ" ហើយ ត្រូវពោលសូម្បីដោយគោត្រនាម, ព្រោះហេតុនោះឯង លោក ទើបសម្រេចថា កាលគេសួរដោយឈ្មោះគោត្រថា "អ្នកណា ជាឧបជ្ឈាយ៍របស់អ្នក" ដូច្នេះ គប្បីពោលថា "កស្សបដ៏មាន*

*អាយុ" ដូច្នេះ ។ ព្រោះហេតុនោះ ត្រូវសន្មតនូវឈ្មោះណាមួយ សូម្បីដទៃ ដល់បុគ្គលនោះ, ម្យ៉ាងទៀត ការបញ្ញត្តិនូវឈ្មោះ ដើម្បីកាន់យកស្រួលក្នុងខណៈនោះ, សូម្បីអនុស្សាវនា គឺភិក្ខុ ត្រូវតែកាន់យកនូវឈ្មោះទាំងអស់នោះ ហើយគប្បីពោល ។*

យថា ឧបជ្ឈាយស្ស, ឯវំ ឧបសម្បទាបេក្ខស្សបិ គោត្តាទិនាមេន, តន្ទុណិកនាមេន ច អនុស្សាវនំ កាតុំ វដ្ដតិ ។ តស្មិម្បិ ខណេ "អយំ តិស្សោ"តិ វា "នាគោ"តិ វា នាមំ ករោន្តេហិ អនុសាសកសម្មុតិតោ បឋមមេវ កាតព្វំ, ឯវំ កត្វាបិ អន្តរាយិកធម្មានុសាសនបុច្ឆន-កាលេសុ "កិន្នាមោសិ, អហំ ភន្តេ នាគោ នាម, កោនាមោ តេ ឧបជ្ឈាយោ, ឧបជ្ឈាយោ មេ ភន្តេ តិស្សោ នាមា"តិអាទិនា វិញ្ញាបេន្តេន ឧភិន្នម្បិ ចិត្តេ "មមេទំ នាម"ន្តិ យថាសញ្ញា ឧប្បជ្ជតិ, ឯវំ វិញ្ញាបេតព្វំ ។ សចេ បន តស្មឹ ខណេ បកតិនាមេន វត្វា បច្ឆា តិស្សនាមាទិ អបុព្វនាមេន អនុស្សាវេតិ, ន វដ្ដតិ ។

*ភិក្ខុអ្នកសូត្រកម្មវាចា គួរដើម្បីធ្វើនូវអនុស្សាវនា ដោយឈ្មោះ មានគោត្រជាដើមផង, ដោយតន្ទុណិកនាមផង ដល់ឧបជ្ឈាយ៍ យ៉ាងណា, សូម្បីដល់ឧបសម្បទាបេក្ខៈ ក៏យ៉ាងនោះដែរ ។*

*សូម្បីក្នុងខណៈនោះ គឺភិក្ខុកាលធ្វើនូវឈ្មោះថា "បុគ្គលនេះឈ្មោះ* តិស្ស *ឬថា បុគ្គលនេះឈ្មោះ នាគ" ដូច្នេះ គឺគប្បីធ្វើមុន ពីកាលសន្មតខ្លួនដើម្បីប្រៀនប្រដៅតែប៉ុណ្ណោះ, សូម្បីកាលធ្វើយ៉ាងនេះ សញ្ញារមែងកើតឡើងថា "នេះជាឈ្មោះរបស់អញ" ក្នុងចិត្តសូម្បីនៃឈ្មោះទាំង ២ ដោយការញ៉ាំងនាគឱ្យដឹងដោយពាក្យជាដើមថា "*កិន្នាមោសិ *: អ្នកឈ្មោះអ្វី* អហំ ភន្តេ នាគោ នាម *: បពិត្រលោកដ៏ចម្រើនខ្ញុំឈ្មោះថានាគ,* កោ នាមោ តេ ឧបជ្ឈាយោ *: ព្រះឧបជ្ឈាយ៍របស់អ្នកឈ្មោះអ្វី,* ឧបជ្ឈាយោ មេ ភន្តេ តិស្សោ នាម *: ព្រះឧបជ្ឈាយ៍របស់ខ្ញុំឈ្មោះថា តិស្ស "ក្នុងកាលសួរអន្តរាយិកធម៌និងអនុសាវនា យ៉ាងណា គប្បីញ៉ាំងនាគឱ្យដឹងយ៉ាងនោះ ។ ក៏ប្រសិនបើក្នុងខណៈនោះ អាចារ្យអ្នកសូត្រ ពោលដោយឈ្មោះប្រក្រតី ហើយសូត្រដោយឈ្មោះ ដែលមិនធ្លាប់មាន, មាន* តិស្ស *ជាដើម ក្នុងកាលជាខាងក្រោយ* រមែងមិនគួរ ។

តត្ថ ច កិញ្ចាបិ ឧបជ្ឈាយស្សេវ នាមំ អគ្គហេត្វា យេន កេនចិ នាមេន "តិស្សស្ស ឧបសម្បទាបេក្ខោ"-តិអាទិនាបិ បុគ្គលេ បរាមដ្ឋេ, កម្មំ សុកតមេវ ហោតិ អនុបជ្ឈាយកាទីនំ ឧបសម្បទាកម្មំ វិយ ឧបជ្ឈាយស្ស

អភាវេបិ អភព្វត្តេបិ កម្មវាចាយ បុគ្គលេ បរាមដ្ឋេ កម្មស្ស សិជ្ឈនតោ ។ ឧបសម្បទាបេក្ខស្ស បន យថាសកំ នាមំ វិនា អញ្ញេន នាមេន អនុស្សាវិតេ កម្មំ កុប្បតិ, សោ អនុបសម្បន្នោវ ហោតិ ។

*ក៏ក្នុងសេចក្ដីនេះ នាកាលបុគ្គលគឺអាចារ្យអ្នកសូត្រ មិនកាន់យកនូវឈ្មោះរបស់ឧបជ្ឈាយ៍ទេ, ហើយពាល់ត្រូវ (នូវឧបជ្ឈាយ៍) ដោយឈ្មោះណាមួយ, មានពាក្យជាដើមថា* "តិស្សស្ស ឧបសម្បទាបេក្ខោ : *ជាឧបសម្បទាបេក្ខៈ របស់ព្រះតិស្ស" ដូច្នេះ កម្មវមែងជាការធ្វើល្អហើយ, ដូចឧបសម្បទាកម្មរបស់បុគ្គលមិនមានឧបជ្ឈាយ៍ជាដើម, កាលបុគ្គល គឺអាចារ្យអ្នកសូត្រពាល់ត្រូវហើយក្នុងកម្មវាចា, កម្មវមែងសម្រេចទាំងបុគ្គលមិនមានឧបជ្ឈាយ៍, ទាំងបុគ្គលអ្នកមានឧបជ្ឈាយ៍ ជាអភព្វបុគ្គល, ក៏ពិតមែនហើយ ។ តែថាកម្មវមែងកម្រើក កាលអាចារ្យអ្នកសូត្រនូវកម្មវាចា សូត្រដោយឈ្មោះដទៃ វៀរចាកឈ្មោះជារបស់ខ្លួននៃឧបសម្បទាបេក្ខៈ, បុគ្គលនោះនៅជាអនុបសម្បន្នដដែល ។*

## ក្នុងកម្មសន្ធតទាំង ១៣ ក៏អាចសន្ធតខ្លួនដោយខ្លួនឯងបាន

<u>*ក្នុងវិនយបិដកភាគ ៦ ទំព័រ ៣០៩ ពោលថា:*</u>

*សួរថា តើភិក្ខុគប្បីសន្មតខ្លួនដោយខ្លួនឯងដូម្តេច ?*

*ឆ្លើយថា គឺភិក្ខុឆ្លាសប្រតិពល ត្រូវឱ្យសង្ឃយល់ថា:*

★ សុណាតុ មេ ភន្តេ សង្ឃោ (ឥត្ថន្នាមោ) (ឥត្ថន្នាមស្ស) អាយស្មតោ ឧបសម្បទាបេក្ខោ ។ យទិ សង្ឃស្ស បត្តកល្លំ អហំ (ឥត្ថន្នាមំ) អនុសាសេយ្យំ ។ *"បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បុគ្គលមានឈ្មោះនេះ ជាឧបសម្បទាបេក្ខៈរបស់លោកដ៏មានអាយុឈ្មោះនេះ ។ បើកម្មមានកាលគួរដល់សង្ឃហើយខ្ញុំគួរប្រៀនប្រដៅឧបសម្បទាបេក្ខៈឈ្មោះនេះ" ។ ភិក្ខុគប្បីសន្មតខ្លួនដោយខ្លួនឯងយ៉ាងនេះ ។*

<u>*ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:*</u>

★ ន កេវលញ្ច **ឯត្ថេវ**, អញ្ញត្រាបិ តេរសសម្មុតិ-អាទីសុ ឥមិនាវ លក្ខណេន អត្តនាវ អត្តា សម្មន្និតព្វោវ ។ អបិច សយំ កម្មារហត្តា អត្តានំ មុញ្ចិត្វា ចតុវគ្គាទិកោ គណោ សព្វត្ថ ឥច្ឆិតព្វោ ។ *ពាក្យថា ភិក្ខុគប្បីសន្មតខ្លួនដោយខ្លួនឯងយ៉ាងនេះ ដូច្នេះនេះ ព្រះដ៏មានព្រះភាគ មិនត្រាស់តែប៉ុណ្ណោះទេ, សូម្បីក្នុងទីដទៃ ដោយលក្ខណៈនេះឯង*

ក្នុងកម្មសន្មតទាំងឡាយ **មានការសន្មតទាំង ១៣ ជាដើម** សូម្បីខ្លួនឯង សន្មតដោយខ្លួនឯងក៏បានដែរ ។ ម្យ៉ាងទៀត ព្រោះតែខ្លួនជាអ្នកគួរដល់កម្ម ដោយខ្លួនឯង គប្បីវៀរខ្លួនឯង ចេញ ហើយប្រាប្ថាគណៈសង្ឃមានចតុវគ្គជាដើម ក្នុងទីទាំងពួង ។ (គឺក្នុងកម្មចតុវគ្គត្រូវមានភិក្ខុ ៥ រូបទាំងខ្លួនឯង, បើ ៤ រូប ទាំងខ្លួនឯង មិនគួរទេ) ។

**ឧបសម្បទាបេក្ខៈត្រូវតែនៅក្នុងហត្ថបាសសង្ឃ ទើបបួសឡើង**

<u>ក្នុងវិនយបិដកភាគ ៦ ទំព័រ ៣១២ ពោលថាៈ</u>

★ សុណាតុ មេ ភន្តេ សង្ឃោ **អយំ** ឥត្ថន្នាមោ ឥត្ថន្នាមស្ស អាយស្មតោ ឧបសម្បទាបេក្ខោ បរិសុទ្ធោ អន្តរាយិកេហិ ធម្មេហិ ។ ល ។ ឯវមេតំ ធារយាមីតិ ។ បពិត្រព្រះគម្ដែងសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ បុគ្គលមាន ឈ្មោះនេះជាឧបសម្បទាបេក្ខៈ របស់លោកដ៏មានអាយុឈ្មោះ នេះ, បរិសុទ្ធចាកអន្តរាយិកធម៌ទាំងឡាយហើយ ។ ល ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ដោយអាការស្ងៀមយ៉ាងនេះ ។

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថាៈ</u>

★ តត្ថ **អយន្តិ** ឧបសម្បទាបេក្ខស្ស ហត្ថបាសេ

សន្និហិតភាវទស្សនំ ។ តេន ច ហត្ថបាសេ ឋិតស្សេវ ឧបសម្បទា រុហតីតិ សិជ្ឈតិ ហត្ថបាសតោ ពហិ ឋិតស្ស "អយ"ន្តិ ន វត្តព្វតោ ។ តេនេវ អនុសាសកសម្មុតិយំ សោ ហត្ថបាសតោ ពហិ ឋិតត្តា "អយ"ន្តិ ន វុត្តោ ។ តស្មា ឧបសម្បទាបេក្ខោ អនុបសម្បន្នោ ហត្ថបាសេ ឋបេតព្វោ ។

*បណ្ដាពាក្យទាំងនោះពាក្យថា " **អយំ** " ជាការសម្ដែងនូវភាពនៃឧបសម្បទាបេក្ខៈ ដែលអាស្រ័យហើយនៅក្នុងហត្ថបាស ។ ដោយពាក្យថា "**អយំ**" ដូច្នេះនេះ លោកអាចារ្យសម្រេចថា ឧបសម្បទាបេក្ខៈ ឈរនៅខាងក្នុងហត្ថបាសប៉ុណ្ណោះ ទើបឧបសម្បទាឡើងបាន ។ កាលឈរខាងក្រៅហត្ថបាស មិនគួរពោលថា " **អយំ** " ។ ព្រោះហេតុនោះឯងឧបសម្បទាបេក្ខៈនោះ អាចារ្យអ្នកសូត្រកម្មវាចា មិនពោលពាក្យថា "**អយំ**" ក្នុងការសន្មតប្រៀនប្រដៅទេ ព្រោះគេឈរនៅខាងក្រៅហត្ថបាស, ព្រោះហេតុនោះ ឧបសម្បទាបេក្ខៈជាអនុបសម្បន្ន គឺសង្ឃឱ្យនៅក្នុងហត្ថបាសបាន ។*

**អនុបជ្ឈាយកាទិវត្ថុកថាចប់ ។**

# ៩_អនាវិតិក្កមន្តរាយិកកថា

<u>ក្នុងវិនយបិដកភាគ ៦ ទំព័រ៣៣៩ ព្រះអង្គត្រាស់ថា:</u>

ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឱ្យភិក្ខុសម្តែងនូវបាតិមោក្ខ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុសម្តែងយ៉ាងនេះ ។ គឺភិក្ខុឆ្លៀសប្រតិពល ត្រូវផ្តៀងសង្ឃថា "បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគួរធ្វើឧបោសថ គួរសម្តែងនូវបាតិមោក្ខ ។ បុព្វកិច្ចរបស់សង្ឃដូចម្តេច ។ បពិត្រលោកដ៏មានអាយុទាំងឡាយ ចូរលោកទាំងឡាយ ប្រាប់សេចក្តីបរិសុទ្ធ ។ ខ្ញុំនឹងសម្តែងនូវបាតិមោក្ខយើងទាំងឡាយ ដែលមាននៅទាំងអស់គ្នា ចូរប្រុងស្តាប់នូវបាលីនោះ ។ លោកអង្គណាមានអាបត្តិ ត្រូវលោកអង្គនោះប្រាប់ កាលមិនមានអាបត្តិទេ ត្រូវនៅឱ្យស្ងៀម ។ ខ្ញុំនឹងសំគាល់លោកមានអាយុទាំងឡាយ ថាជាបុគ្គលបរិសុទ្ធ ដោយភាវៈស្ងៀម ។ ដូចជាបុគ្គលដែលត្រូវគេសួរបញ្ហា ចំពោះរូបម្នាក់ៗតែងដោះស្រាយ យ៉ាងណាមិញ, ពាក្យដែលខ្ញុំប្រកាសឱ្យដឹងអស់វារៈ ៣ ដងយ៉ាងនេះ ក្នុងបរិស័ទមានសភាពយ៉ាងនេះក៏ដូច្នោះដែរ ។ ភិក្ខុណាមួយ កាលដែលខ្ញុំប្រកាសអស់វារៈ

*៣ ដងហើយ ទើបរលឹកឃើញ តែមិនប្រាប់អាបត្តិដែលមាន ភិក្ខុនោះ ត្រូវសម្បជានមុសាវាទ ។ បពិត្រលោកដ៏មានអាយុ ទាំងឡាយ ក៏ឯសម្បជានមុសាវាទ ព្រះមានព្រះភាគត្រាស់ថា* ***ជាធម៌ធ្វើនូវសេចក្ដីអន្តរាយមួយដែរ*** *ហេតុនោះ ភិក្ខុដែលត្រូវ អាបត្តិហើយរលឹកឃើញប្រាថ្នាសេចក្ដីបរិសុទ្ធ ត្រូវប្រាប់អាបត្តិ ដែលមាន ។ ព្រោះថាអាបត្តិដែលភិក្ខុប្រាប់ហើយជាការស្រួល ។*

*ក្នុងវិនយបិដកភាគ ៦ ទំព័រ៣៤៣ ពោលថា:*

☆ **អន្តរាយិកោ ធម្មោ វុត្តោ ភគវតាតិ** កិស្ស អន្តរាយិកោ ។ បឋមស្ស ឈានស្ស អធិគមាយ អន្តរាយិកោ, ទុតិយស្ស ឈានស្ស អធិគមាយ អន្តរាយិកោ, តតិយស្ស ឈានស្ស អធិគមាយ អន្តរាយិកោ, ចតុត្ថស្ស ឈានស្ស អធិគមាយ អន្តរាយិកោ, ឈានានំ វិមោក្ខានំ សមាធីនំ សមាបត្តីនំ នេក្ខម្មានំ និស្សរណានំ បវិវេកានំ កុសលានំ ធម្មានំ អធិគមាយ អន្តរាយិកោ ។

*ពាក្យថា* ***ព្រះមានព្រះភាគត្រាស់ថា ជាធម៌ធ្វើសេចក្ដី អន្តរាយ*** *គឺធម៌នោះធ្វើនូវសេចក្ដីអន្តរាយដល់អ្វី ? ធម៌នោះ ធ្វើនូវសេចក្ដីអន្តរាយដល់ការបានបឋមជ្ឈាន, ធ្វើនូវសេចក្ដី*

អន្តរាយដល់ការបានទុតិយជ្ឈាន, ធ្វើនូវសេចក្ដីអន្តរាយដល់ការបានតតិយជ្ឈាន, ធ្វើនូវសេចក្ដីអន្តរាយដល់ការបានចតុត្ថជ្ឈាន ធ្វើនូវសេចក្ដីអន្តរាយ ដល់ការបាននូវកុសលធម៌ទាំងឡាយ គឺ ឈាន វិមោក្ខ សមាធិ សមាបត្តិ នេក្ខម្ម ការលោះបង់ចេញចាកភព និងសេចក្ដីស្ងប់ស្ងាត់ ។

<u>ក្នុងគម្ពីរកង្ខាវិតរណីភាគ ១ ទំព័រ ៤៨ ពោលថា:</u>

✯ **អន្តរាយិកោតិ** វិប្បដិសារវត្ថុតាយ បាមោជ្ជា-ទិសម្ភវំ និវារេត្វា បឋមជ្ឈានាទីនំ អធិគមាយ អន្តរាយំ ករោតិ ។ ត្រង់ពាក្យថា ***អន្តរាយ*** ដូច្នេះ បានដល់ធម៌ដែលហាមឃាត់នូវការបាននូវគុណធម៌មានបាមោជ្ជៈជាដើម ហើយធ្វើអន្តរាយ ដល់ការត្រាស់ដឹងនូវគុណធម៌ មានបឋមជ្ឈានជាដើម ព្រោះមានសេចក្ដីក្ដៅក្រហាយជាហេតុ ។

<u>ក្នុងគម្ពីរកង្ខាវិតរណីអភិនវដីកា ពន្យល់ថា:</u>

✯ វិប្បដិសារោ នាម បច្ឆានុតាបវសេន ចិត្ត-វិប្បដិសារោ, តស្ស ការណតាយាតិ អត្ថោ ។

ដែលឈ្មោះថា ***វិប្បដិសារោ*** គឺបានដល់ សេចក្ដីក្ដៅ-ក្រហាយចិត្ត ដោយអំណាចការតាមដុតក្នុងកាលជាខាងក្រោយ,

*អធិប្បាយថា ព្រោះមានសេចក្តីក្តៅក្រហាយនោះ ជាហេតុ ។*

*ក្នុងគម្ពីរអដ្ឋកថា បរិវារៈ ពោលថា:*

★ **អន្តរាយិកាតិ** សត្តបិ អាបត្តិយោ សញ្ចិច្ច វីតិក្កន្តា សគ្គន្តរាយញ្ចេវ មោក្ខន្តរាយញ្ច ករោន្តីតិ អន្តរាយិកា ។ **អជានន្តេន វីតិក្កន្តា** បន បណ្ណត្តិវជ្ជាបត្តិ នេវ សគ្គន្តរាយំ ន មោក្ខន្តរាយំ ករោតីតិ អន្តរាយិកា ។ *ត្រង់ពាក្យថា* ***អន្តរាយ*** *ដូច្នេះ មានសេចក្តីថា អាបត្តិទាំង ៧ កងដែលភិក្ខុក្លែងកន្លងហើយ រមែងធ្វើអន្តរាយដល់សួគ៌ និងព្រះនិព្វាន, ព្រោះដូច្នោះ អាបត្តិដែលភិក្ខុក្លែងកន្លង ទើបឈ្មោះថា ធ្វើនូវសេចក្តីអន្តរាយ ។ ចំណែកអាបត្តិដែលមានទោសតាមព្រះបញ្ញត្តិ* ***ដែលភិក្ខុមិនដឹងហើយប្រព្រឹត្តកន្លងល្មើស*** *មិនធ្វើនូវអន្តរាយដល់សួគ៌ និងព្រះនិព្វានទេ, ព្រោះដូច្នោះ អាបត្តិដែលមានទោសខាងផ្លូវព្រះបញ្ញត្តិ ទើបឈ្មោះថា មិនធ្វើនូវសេចក្តីអន្តរាយ ។*

★ អន្តរាយិកំ អាបន្នស្សាបិ ទេសនាគាមិនឹ ទេសេត្វា វុដ្ឋានគាមិនិតោ វុដ្ឋាយ សុទ្ធិបត្តស្ស សាមណេរភូមិយំ ឋិតស្ស ច អវារិតោ សគ្គមោក្ខមគ្គោតិ ។

*ផ្លូវនៃសួគ៌ និងព្រះនិព្វាន (ដែលអន្តរាយិកាបត្តិ) មិនហាម*

*ហើយ សូម្បីដល់ភិក្ខុដែលត្រូវនូវអន្តរាយិកាបត្តិ (អាបត្តិដែលធ្វើនូវសេចក្តីអន្តរាយ) ហើយសម្តែងអាបត្តិដែលជាទេសនាគាមិនី, ហើយចេញចាកអាបត្តិ ដែលជាវុដ្ឋានគាមិនី, ហើយដល់នូវភាពជាបុគ្គលបរិសុទ្ធផង, និងដល់ភិក្ខុអ្នកតាំងនៅក្នុងភូមិរបស់សាមណេរ ដូច្នេះផង ។*

## ការមិនដឹងនូវបទបញ្ញត្តិ ក្តី មិនដឹងនូវវត្ថុ ក្តី ហើយប្រព្រឹត្តកន្លងនូវសិក្ខាបទ

*<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>*

✯ **អជានន្តេន វីតិក្កន្តាតិ** បណ្ណត្តឹ វា វត្ថុំ វា អជានន្តេន វីតិក្កន្តា បឋវីខណនសហសេយ្យាទិកា, សាបិ បច្ឆា អាបន្នភាវំ ញត្វា បដិកម្មំ អករោន្តស្ស អន្តរាយិកាវ ហោតិ ។ *ពាក្យថា* **មិនដឹងហើយប្រព្រឹត្តកន្លងល្មើស** *ដូច្នេះនេះមានសេចក្តីថា ភិក្ខុកាលមិនដឹងនូវបទបញ្ញត្តិក្តី មិនដឹងនូវវត្ថុក្តី ហើយប្រព្រឹត្តកន្លងនូវសិក្ខាបទ មានការជីកផែនដី និងការដេកនៅរួមជាមួយនឹងអនុបសម្បន្ន និងមនុស្សស្រីជាដើម, សូម្បីអាបត្តិនោះ កាលភិក្ខុដឹងហើយ នូវភាពនៃខ្លួនជាអ្នកត្រូវនូវអាបត្តិក្នុងកាលជាខាងក្រោយហើយ មិនសម្តែងចេញរមែងជាអន្តរាយពិត ។*

## បុគ្គលដែលមានអាបត្តិស្លាប់ទៅកើតជា នរក និងតិរច្ឆាន

*ក្នុងគម្ពីរអដ្ឋកថា អរិដ្ឋសិក្ខាបទ ពោលថា:*

★ សញ្ចិច្ច អាបន្នា អាបត្តិយោ **អាណាវីតិក្កមន្ត-រាយិកា ណាម** ។ តាបិ យាវ ភិក្ខុភាវំ វា បដិជានាតិ ន វុដ្ឋាតិ វា ន ទេសេតិ វា តាវទេវ ន តតោ បរន្តិ ។ *អាបត្តិទាំងឡាយ ដែលភិក្ខុបានក្លែងឱ្យត្រូវហើយ ឈ្មោះថា អន្តរាយិកធម៌ គឺការប្រព្រឹត្តកន្លងល្មើសនូវសិក្ខាបទ ។ សូម្បីអាបត្តិទាំងអស់នោះ (ធ្វើនូវសេចក្តីអន្តរាយ) រហូតវេលាដែល (ភិក្ខុត្រូវអាបត្តិហើយ) នៅតែប្តេជ្ញាខ្លួនថា ជាភិក្ខុក្តី មិនព្រមនៅបរិវាសក្តី ឬថាមិនសម្តែងចេញប៉ុណ្ណោះ ។ បន្ទាប់អំពីវេលា (ដែលអាបត្តិ គឺភិក្ខុសម្តែងចេញហើយ) មិនឈ្មោះថា ធ្វើនូវសេចក្តីអន្តរាយឡើយ ។*

*ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:*

★ **សញ្ចិច្ច អាបន្នា អាបត្តិយោតិ** សញ្ចិច្ច វីតិក្កន្តា សត្ត អាបត្តិក្ខន្ធា ។ សញ្ចិច្ច វីតិក្កន្តញ្ហិ អន្តមសោ ទុក្កដទុព្ភាសិតម្បិ សគ្គមគ្គផលានំ អន្តរាយំ ករោតិ ។ យាវ ភិក្ខុភាវំ បដិជានាតិ ធារាជិកំ អាបន្នោ, ន វុដ្ឋាតិ សេសគរុកាបត្តឹ អាបន្នោ, ន ទេសេតិ លហុកាបត្តឹ

អាបន្នោ ។ ពាក្យថា **អាបត្តិទាំងឡាយ ដែលភិក្ខុបានក្លែងឱ្យត្រូវហើយ** ដូច្នេះ គឺបានដល់ក្លែងប្រព្រឹត្ត កន្លងនូវអាបត្តិទាំង ៧ កង ។ ពិតមែន ភិក្ខុកាលក្លែងប្រព្រឹត្តកន្លងនូវសិក្ខាបទដោយហោចទៅ សូម្បីអាបត្តិទុក្កដ និងអាបត្តិទុព្ភាសិត រមែងធ្វើនូវសេចក្តីអន្តរាយដល់សួគ៌ មគ្គ និងផលទាំងឡាយ ។

ពាក្យថា **នៅតែប្តេជ្ញាខ្លួនថាជាភិក្ខុ** គឺបានដល់ភិក្ខុដែលត្រូវអាបត្តិបារាជិក ។ ពាក្យថា **មិនព្រមនៅបរិវាស** គឺបានដល់ភិក្ខុដែលត្រូវនូវគរុអាបត្តិដ៏សេស ។ ពាក្យថា **មិនសម្តែងចេញ** គឺបានដល់ភិក្ខុដែលត្រូវនូវអាបត្តិដែលជាលហុកាបត្តិ ។

តេនេវ សាបត្តិកស្ស ភិក្ខវេ និរយំ វទាមិ តិរច្ឆានយោនឹ វាតិ សាបត្តិកស្សេវ អបាយគាមិតា វុត្តាតិ ។

ព្រោះហេតុនោះឯង បានជាព្រះអង្គត្រាស់នូវដំណើរទៅកាន់អបាយ ចំពោះភិក្ខុដែលត្រូវអាបត្តិប៉ុណ្ណោះថា "ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវកំណើតនរកខ្លះ កំណើតសត្វតិរច្ឆានខ្លះ ចំពោះភិក្ខុដែលមានអាបត្តិជាប់ខ្លួន" ។

**អនាវិតិក្កមន្តរាយិកកថាចប់ ។**

# ១០_ឧទក្ខេបសីមាកថា

*<u>ក្នុងព្រះអដ្ឋកថា ពោលថា:</u>*

តត្ថ **យំ មជ្ឈិមស្ស បុរិសស្ស សមន្តា ឧទកុក្ខេបាតិ** យំ ឋានំ មជ្ឈិមស្ស បុរិសស្ស សមន្តតោ ឧទកុក្ខេបេន បរិច្ឆិន្នំ ។ *បណ្ដាពាក្យទាំងនោះ ពាក្យថា ទីណាដែលបុគ្គលកំណត់ដោយសាចទឹក របស់មជ្ឈិមបុរស ដោយជុំវិញ ដូច្នេះ មានសេចក្ដីថា ស្ថានទីណាកំណត់ដោយក្បង់ទឹកសាចដោយជុំវិញ នៃបុរសដែលមានកម្លាំងកណ្ដាល ។*

*<u>សួរថា:</u> ក៏ទឹកគឺភិក្ខុគប្បីក្បង់សាចយ៉ាងណា ?*

*<u>ឆ្លើយថា:</u> អ្នកលេងអង្គញ់បោះគ្រាប់អង្គញ់យ៉ាងណា មជ្ឈិមបុរស គប្បីយកដៃក្បង់ទឹក ឬក្ដាប់ខ្សាច់បាចទៅ ដោយកម្លាំងទាំងអស់ដូច្នោះ ។ ទឹកឬខ្សាច់ដែលបាចទៅយ៉ាងនោះ ធ្លាក់ចុះក្នុងឱកាសណា, ឱកាសនោះជា ១ ឧទកុក្ខេប ។ ភិក្ខុដែលលះហត្ថបាស តាំងនៅខាងក្នុងឧទកុក្ខេបនោះ រមែងធ្វើកម្មឱ្យខូច ។ បរិស័ទពង្រីកចេញត្រឹមណា សូម្បីសីមា រមែងពង្រីកចេញទៅត្រឹមនោះ ។ ចំពោះ ១ ឧទកុក្ខេប អំពីទីបំផុតដោយជុំវិញនៃបរិស័ទ ជាប្រមាណ ។ សូម្បីក្នុងជាតស្រះ និង*

ក្នុងសមុទ្រ ក៏មានន័យនេះដូចគ្នា ។

ឯត្ថ ច សចេ នទី ជាតិទីយា ហោតិ **បភវតោ បដ្ឋាយ យាវ មុខទ្វារា** សព្វត្ថ សង្ឃោ និសីទតិ **ឧទកុក្ខេបសីមាកម្មំ នត្ថិ**, សកលាបិ នទី ឯតេសំយេវ ភិក្ខូនំ បហោតិ ។ ក៏ឯបណ្តា (ស្ទឹង ជាតស្រះ និងសមុទ្រ) ទាំងនេះ បើស្ទឹងមិនវែងពេកទេ សង្ឃអង្គុយនៅក្នុងទីទាំងពួង តាំងពីដើមទឹកដរាបដល់ចុងទឹក, ឈ្មោះថា កម្មក្នុងឧទកុក្ខេប-សីមា រមែងមិនមាន, សូម្បីស្ទឹងទាំងអស់ រមែងល្មម គ្រប់គ្រាន់ដល់ភិក្ខុទាំងនោះហើយ ។

✯ ក៏ពាក្យណា ដែលព្រះមហាសុមត្ថេរ ពោលថា ស្ទឹងដែលហូរត្រឹមតែ ១ យោជន៍ ។ សូម្បីក្នុងស្ទឹងនោះ ត្រូវលះកន្លះយោជន៍ខាងលើចេញ ធ្វើកម្មក្នុងកន្លះយោជន៍ ខាងក្រោមទើបគួរ ដូច្នេះ ។ ពាក្យនោះ ព្រះមហាបទុមត្ថេរ ជំទាស់ហើយ ។

## សូម្បីមិនសាចទឹក ក៏មានឧទកុក្ខេបសីមាដែរ

<u>ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:</u>

✯ យំ មជ្ឈិមស្ស បុរិសស្ស សមន្តា ឧទកុក្ខេ-បាតិ បន ឯកិស្សា នទិយា ចតុវគ្គាទីនំ សង្ឃានំ វិសុំ

ចតុវគ្គករណីយានិ កម្មករណកាលេ សីមាបរិច្ឆេទ-ទស្សនត្ថំ វុត្តំ ។

*ពាក្យថា ទីណាដែលបុគ្គលកំណត់ដោយសាចទឹករបស់មជ្ឈិមបុរសដោយជុំវិញ ដូច្នេះនេះ គឺលោកពោលហើយដើម្បីកំណត់សីមាក្នុងកាលធ្វើកម្ម មានការធ្វើកម្មចតុវគ្គជាដើមផ្សេងគ្នានៃសង្ឃ មានសង្ឃចតុវគ្គជាដើម ក្នុងស្ទឹងតែមួយ ។*

តិចីវរេន វិប្បវាសាវិប្បវាសបរិច្ឆេទទស្សនត្ថម្បិ សត្តព្ភន្តរសីមាយ បរិច្ឆេទទស្សនំ វិយាតិ អាចរិយា, តស្មា ឧទកុក្ខេបបរិច្ឆេទាភាវេបិ អន្តោនទិយំ កម្មំ កាតុំ វដ្ដតីតិ សិទ្ធំ ។ *លោកអាចារ្យពោលថា ដូចជាការសម្ដែងនូវការកំណត់ក្នុងសត្តព្ភន្តរសីមា ដើម្បីសម្ដែងនូវការកំណត់វិប្បវាសសីមា និងអវិប្បវាសសីមាដោយចីវរ ៣ ។ ព្រោះហេតុនោះ លោកសម្រេចថា គួរដើម្បីធ្វើកម្មខាងក្នុងនៃស្ទឹង សូម្បីមិនមានការកំណត់នូវឧទកុក្ខេប គឺការសាចទឹក ។*

*<u>ក្នុងគម្ពីរវិនយាលង្ការដីកា ពោលថា:</u>*

☆ **ឧទកុក្ខេបសីមាយ កម្មំ ន វត្តតីតិ** យស្មា សព្វាបិ នទីបទេសោ ភិក្ខូហិ អជ្ឈោត្ថដោ, តស្មា សមន្តតោ នទិយា អភាវា ឧទកុក្ខេបប្បយោជនំ នត្ថិ ។

ពាក្យថា **ឈ្មោះថា កម្មក្នុងឧទកុក្ខេបសីមា រមែងមិនមាន** ដូច្នេះ មានសេចក្ដីថា ប្រទេសនៃស្ទឹងសូម្បីទាំងអស់ គឺភិក្ខុនៅពេញហើយ ព្រោះហេតុដូច្នោះ ប្រយោជន៍នៃការសាចទឹករមែងមិនមាន, ព្រោះមិនមានស្ទឹងដោយជុំវិញ ។

<u>ក្នុងមហាអដ្ឋកថា ពោលថា:</u>

ទីប្រមាណនៃស្ទឹង ព្រះមានព្រះភាគត្រាស់ទុកដូច្នេះថា "ភិក្ខុនីបិទបាំងមណ្ឌល ៣ ហើយ ឆ្លងឡើងក្នុងទីណាមួយស្បង់នៃភិក្ខុនីនោះទទឹកបាន, ទីនោះហៅថា**ស្ទឹង**" ។ តែ ១ យោជន៍ ឬកន្លះយោជន៍ មិនបានត្រាស់ទុកទេ, ព្រោះហេតុនោះស្ទឹងណាមានលក្ខណៈដូចពោលហើយ ក្នុងកាលមុន ដោយអំណាចនៃសូត្រនេះ នឹងធ្វើសង្ឃកម្មតាំងពីដើមទឹកនៃស្ទឹងនោះ**រមែងគួរ** ។

សចេ បនេត្ថ ពហូ ភិក្ខូ វិសុំ វិសុំ កម្មំ ករោន្តិ, សព្វេ អត្តនោ ច អញ្ញេសញ្ច ឧទកុក្ខេបបរិច្ឆេទស្ស អន្តរា **អញ្ញោ ឧទកុក្ខេបោ សីមន្តរិកត្ថាយ ឋបេតព្វោ** ។ តតោ អធិកំ វដ្ដតិយេវ, **ឩនកំ បន ន វដ្ដតីតិ** វុត្តំ ។

តែបើភិក្ខុច្រើនសន្ទឹកសន្ទាប់នឹងបែកគ្នា ធ្វើកម្មក្នុងស្ទឹងនោះសោត, ភិក្ខុទាំងពួងគប្បីវៀរ ១ ឧទកុក្ខេបជទៃទុកក្នុង

ចន្លោះដែនកំណត់នៃឧទកុក្ខេបរបស់ខ្លួន និងរបស់ភិក្ខុពួកដទៃ ដើម្បីប្រយោជន៍ដល់សីមន្តរិក ។ វៀរទុកលើសជាង ១ ឧទកុក្ខេបនោះ គួរពិត, តែតិចជាងនោះ មិនគួរ ។

<u>ក្នុងគម្ពីរវិនយាលង្ការដីកា ពោលថា:</u>

★ ឧទកុក្ខេបប្បមាណា សីមន្តរិកា សុវិញ្ញេយ្យតរា ហោតិ, សីមាសម្ភេទសង្កា ច ន សិយាតិ សាមីចិទស្សនត្ថំ "អញ្ញោ ឧទកុក្ខេបោ សីមន្តរិកត្ថាយ ឋបេតព្វោ"តិ វុត្តំ ។ យត្តកេន បន សីមាសម្ភេទោ ន ហោតិ, តត្តកំ ឋបេតុំ វដ្ដតិយេវ ។

ពាក្យថា ត្រូវវៀរទុក ១ ឧទកុក្ខេបដទៃដើម្បីប្រយោជន៍ដល់សីមន្តរិក ដូច្នេះ គឺលោកអាចារ្យពោលហើយ ដើម្បីសម្ដែងនូវសេចក្ដីសមគួរថា សីមន្តរិកប្រមាណ ១ ឧទកុក្ខេប គឺគេដឹងបានងាយផង, មិនមានសេចក្ដីសង្ស័យ ព្រោះការទំលាយសីមាផង ។ តែថាការទំលាយសីមា មិនមានដោយប្រមាណប៉ុណ្ណា គួរដើម្បីតម្កល់ទុកនូវសីមន្តរិកត្រឹមនោះពិត ។

★ **ឧទកំ បន ន វដ្ដតីតិ** ឥទម្បិ ឧទកុក្ខេបសីមាយ បរិសរវសេន វុត្តនតោ សីមាសម្ភេទសង្កា សិយាតិ

តន្និវារណត្ថមេវ វុត្តន្តិ វុត្តំ ។

ពាក្យថា *តែតិចជាងនេះមិនគួរ* ដូច្នេះ សូម្បីពាក្យនេះ គឺលោកអាចារ្យពោលហើយថា "សេចក្តីសង្ស័យ ព្រោះការទំលាយសីមាគប្បីមាន, ព្រោះការចម្រើន ដោយអំណាចបរិស័ទក្នុងឧទកុក្ខេបសីមា" ព្រោះហេតុនោះ លោកអាចារ្យពោលហើយ ដើម្បីរាំងនូវសេចក្តីសង្ស័យនោះប៉ុណ្ណោះ ។

<u>ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:</u>

✯ **ឩនកំ បន ន វដ្ដតីតិ** ឯត្ថ សីមាសម្ភេទ-សម្ភវតោតិ ឧបតិស្សត្ថេរោ ។

ពាក្យថា *តែតិចជាងនោះមិនគួរ* ដូច្នេះនេះ ព្រះឧបតិស្សត្ថេរពោលថា ព្រោះមានការទំលាយនូវសីមា ។

**ឧទកុក្ខេបកថាចប់ ។**

# ១១_ឆន្ទបារិសុទ្ធិកថា

<u>ក្នុងវិនយបិដកភាគ ៦ ទំព័រ ៣៨៨ ពោលថា:</u>

អនុជានាមិ ភិក្ខវេ គិលានេន ភិក្ខុនា ចារិសុទ្ធិ-ទាតុំ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុឈឺឱ្យបារិសុទ្ធិបាន ។

ត្រូវភិក្ខុឈឺនោះ ចូលទៅរកភិក្ខុមួយរូបហើយធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង រួបអង្គុយប្រហោងផ្គងអញ្ជលី ហើយនិយាយយ៉ាងនេះថា ៖

✯ **ចារិសុទ្ធឹ ទម្មិ**, ចារិសុទ្ធឹ មេ ហរ, ចារិសុទ្ធឹ មេ អារោចេហិ ។ **ខ្ញុំឱ្យបារិសុទ្ធិ**, លោកចូរនាំបារិសុទ្ធិរបស់ខ្ញុំទៅ, លោកចូរប្រាប់បារិសុទ្ធិរបស់ខ្ញុំ ។ ភិក្ខុឈឺនោះ បញ្ជាក់ដោយកាយ(ក្តី) បញ្ជាក់ដោយវាចា(ក្តី) បញ្ជាក់ដោយកាយវាចា(ក្តី) ឈ្មោះថា **ឱ្យបារិសុទ្ធិហើយ**, បើភិក្ខុឈឺនោះ មិនបញ្ជាក់ដោយកាយ មិនបញ្ជាក់ដោយវាចា មិនបញ្ជាក់ដោយកាយវាចាទេ មិនឈ្មោះថា **ឱ្យបារិសុទ្ធិទេ** ។ បើភិក្ខុនោះបានបារិសុទ្ធិទុំះយ៉ាងនេះ ការបានបារិសុទ្ធិទុំះ ជាការល្អ, បើមិនបានទេ, ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុនាំភិក្ខុឈឺដោយគ្រែ

ឬតាំង មកក្នុងកណ្ដាលសង្ឃ ហើយធ្វើឧបោសថ ។

ម្នាលភិក្ខុទាំងឡាយ បើគំនិតយ៉ាងនេះ មានដល់ភិក្ខុអ្នកបម្រើភិក្ខុឈឺថា "បើយើងទាំងឡាយ ឱ្យភិក្ខុឈឺឃ្លាតចាកទីអាពាធ ទីងរឹតតែចម្រើន ឬទីងស្លាប់" ដូច្នេះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឱ្យភិក្ខុឈឺឃ្លាតចាកទីទេ ត្រូវសង្ឃទៅធ្វើឧបោសថ ក្នុងទីនោះ ។

★ ន ត្វេវ វគ្គេន សង្ឃេន ឧបោសថោ កាតព្វោ យោ ករេយ្យ ចេ អាបត្តិ ទុក្កដស្ស ។ មិនត្រូវសង្ឃធ្វើឧបោសថដោយពួកឡើយ បើសង្ឃណាធ្វើត្រូវអាបត្តិទុក្កដ ។

## ភិក្ខុមានអាបត្តិឱ្យបារិសុទ្ធិ រមែងត្រូវអាបត្តិ

<u>ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:</u>

★ **បារិសុទ្ធឹ ទម្មីតិ** "សាបត្តិកោ ថេរានំ ទេតិ សម្បជានមុសាវាទេ ទុក្កដំ សម្ភវតី"តិ អាចរិយេន លិខិតំ ។ កឹ នុ ខោ ការណំ ? សម្បជានមុសាវាទេន ទុក្កដាបត្តិ ណាម ភគវតា វុត្តា អកិរិយ-សមុដ្ឋានា ហោតីតិ ។ ពាក្យថា ខ្ញុំឱ្យនូវបារិសុទ្ធិ ដូច្នេះ លោកអាចារ្យសរសេរថា ភិក្ខុមានអាបត្តិហើយឱ្យនូវបារិសុទ្ធិដល់ព្រះថេរៈទាំងឡាយ ទុក្កដរមែងមាន ព្រោះសម្បជានមុសា-

វាទ ។ សួរថា ហេតុនោះដូចម្ដេច ? ឆ្លើយថា ធម្មតាអាបត្តិទុក្កដ ដោយសម្បជានមុសាវាទ ជាអកិរិយសមុដ្ឋាន ព្រោះជាអាបត្តិដែលព្រះអង្គត្រាស់ហើយប៉ុណ្ណោះ ។

★ **"បារិសុទ្ធិំ ទម្មី"តិ** ឯត្ថ បន កិរិយា បញ្ញាយតិ, តស្មា សម្បជានមុសាវាទេ បាចិត្តិយំ វិយ ទិស្សតិ, សុដ្ឋុ ឧបបរិក្ខិតព្វំ ។ មហន្តា ហិ តេ អាចរិយា នាម ។

តែក្នុងពាក្យថា **"ខ្ញុំឱ្យនូវបារិសុទ្ធិ"** ដូច្នេះ ក៏កិរិយា (គឺការធ្វើ) រមែងប្រាកដ ព្រោះហេតុនោះ ឃើញហាក់ដូចជាអាបត្តិបាចិត្តិយ ព្រោះសម្បជានមុសាវាទ, អ្នកសិក្សាគប្បី ពិចារណាឱ្យល្អផងចុះ, ព្រោះថាអាចារ្យទាំងនោះ ជាអាចារ្យធំ ។

ក្នុងវិនយបិដកភាគ ៦ ទំព័រ ៣៣៨ ពោលថា:

ម្នាលភិក្ខុទាំងឡាយ កាលដែលភិក្ខុឈឺឱ្យបារិសុទ្ធិហើយ បើភិក្ខុអ្នកនាំបារិសុទ្ធិជៀសចេញចាកទីនោះទៅ ត្រូវឱ្យបារិសុទ្ធិដល់ភិក្ខុដទៃ ។

ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:

★ បាឡិយំ **អញ្ញស្ស ទាតព្វា បារិសុទ្ធីតិ** បារិ-
សុទ្ធិទាយកេន បុន អញ្ញស្ស ភិក្ខុនោ សន្តិកេ

ធាតញ្ញា ។ ក្នុងបាលីបិដក ព្រះអង្គត្រាស់ថា **គប្បីឱ្យបារិសុទ្ធិ** ដល់បុគ្គលដទៃ ដូច្នេះ មានសេចក្តីថា គឺភិក្ខុអ្នកឱ្យនូវបារិសុទ្ធិ គប្បីឱ្យក្នុងសំណាក់នៃភិក្ខុដទៃទៀត ។

## ពាក្យប្រាប់នូវឆន្ទៈ និងបារិសុទ្ធិ

ភិក្ខុអ្នកនាំឆន្ទៈនិងបារិសុទ្ធិ ទៅដល់សង្ឃហើយ ត្រូវប្រាប់សង្ឃឱ្យដឹងដោយពាក្យថា “**(វិនយធរេន) ឆន្ទបារិសុទ្ធិ ទិន្នា :** ឆន្ទៈនិងបារិសុទ្ធិ គឺភិក្ខុឈ្មោះ (វិនយធរោ) បានឱ្យហើយ” ។ បើភិក្ខុអ្នកនាំនូវឆន្ទៈ និងបារិសុទ្ធិមកដល់ហើយ សូម្បីភ្លេចមិនបានប្រាប់ដល់សង្ឃ, ឆន្ទៈនិងបារិសុទ្ធិ ក៏ឈ្មោះថា ភិក្ខុនោះបាននាំមកហើយ ។

## ពាក្យ ឱ្យនូវឆន្ទៈ

<u>ក្នុងវិនយបិដកភាគ ៦ ទំព័រ ៣៩១ ពោលថា:</u>

**អនុជានាមិ ភិក្ខវេ គិលានេន ភិក្ខុនា ឆន្ទំ ទាតុំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុឈឺឱ្យឆន្ទៈបាន ។ ត្រូវភិក្ខុឈឺនោះ ចូលទៅរកភិក្ខុមួយរូប ហើយធ្វើឧត្តរាសង្គៈ ឆៀងស្មាម្ខាង រួចអង្គុយច្រហោងផ្គងអញ្ជលី ហើយនិយាយយ៉ាងនេះថា ៖

★ ឆន្ទំ ទម្មិ, ឆន្ទំ មេ ហរ, ឆន្ទំ មេ អារោចេហិ ។

ខ្ញុំករុណាសូមឱ្យនូវឆន្ទៈ, លោកចូរនាំឆន្ទៈរបស់ខ្ញុំទៅចុះ, លោកចូរប្រាប់នូវឆន្ទៈរបស់ខ្ញុំផង ។ ន័យដ៏សេស ដូចពោលហើយក្នុងការឱ្យនូវបារិសុទ្ធិឧបោសថ ។

<u>ក្នុងវិនយបិដកភាគ ៦ ទំព័រ ៣៩៤ ពោលថា:</u>

★ អនុជានាមិ ភិក្ខវេ តទហុបោសថេ បារិសុទ្ធឹ ទេន្តេន ឆន្ទំបិ ទាតុំ សន្តិ សង្ឃស្ស ករណីយំ ។

ម្នាលភិក្ខុទាំងឡាយ បើសង្ឃមានកិច្ចត្រូវធ្វើ តថាគតអនុញ្ញាតឱ្យភិក្ខុ ដែលឱ្យបារិសុទ្ធិក្នុងថ្ងៃឧបោសថនោះ ឱ្យនូវឆន្ទៈទៀតបាន ។

**ការឱ្យនូវបារិសុទ្ធិធ្វើបានតែឧបោសថកម្មប៉ុណ្ណោះ**

<u>ក្នុងកង្ខាវិតរណី ភាគ ១ ទំព័រ ២៨ ពោលថា:</u>

★ តត្ថ បារិសុទ្ធិទានំ សង្ឃស្សាបិ អត្តនោបិ ឧបោសថករណំ សម្បាទេតិ ។ ន អវសេសសង្ឃស្ស កិច្ចំ ។ ឆន្ទទានំ បន សង្ឃស្សេវ ឧបោសថករណញ្ច សេសកិច្ចញ្ច សម្បាទេតិ ។ អត្តនោ បនស្ស ឧបោសថោ អកតោយេវ ហោតិ ។ តស្មា បារិសុទ្ធឹ ទេន្តេន ឆន្ទោបិ

ធាតុទៅ ។ ក្នុងឆន្ទៈ និងបារិសុទ្ធិនោះ, **ការឱ្យនូវបារិសុទ្ធិ** ឈ្មោះថា ញុំាងនូវការធ្វើឧបោសថរបស់សង្ឃផង របស់ខ្លួនផង ឱ្យសម្រេចបាន ។ កិច្ចរបស់សង្ឃដ៏សេស មិនបានសម្រេចឡើយ ។ **ចំណែកការឱ្យនូវឆន្ទៈ** រមែងញុំាងការធ្វើឧបោសថផង កិច្ចដ៏សេសផង របស់សង្ឃឱ្យសម្រេចពិត ។ ឯឧបោសថរបស់ខ្លួនមិនឈ្មោះថាភិក្ខុនោះបានធ្វើឡើយ ។ ព្រោះហេតុនោះ ភិក្ខុបើបានឱ្យបារិសុទ្ធិហើយ ត្រូវតែឱ្យឆន្ទៈផង ។

**✯ វុត្តំ បន បារិសុទ្ធឹ វា ឆន្ទំ វា ឥមំ វា ឆន្ទបារិសុទ្ធឹ ឯកេនពហូនម្បិ អាហរិតុំ វដ្ដតិ ។**

ក៏ពាក្យដែលលោកពោលមកហើយ ក្នុងកាលមុនថា កាលភិក្ខុមួយរូប នាំបារិសុទ្ធិក្ដី នាំឆន្ទៈក្ដី នាំទាំងឆន្ទៈនិងបារិសុទ្ធិក្ដី របស់ភិក្ខុសូម្បីច្រើនរូប ក៏គួរ ។

<u>ក្នុងព្រះអដ្ឋកថា ពោលថា:</u>

ប្រសិនបើភិក្ខុមាន ៤ រូប, ភិក្ខុ ៣ រូបនាំនូវបារិសុទ្ធិរបស់ភិក្ខុ ១ រូបមក ហើយសម្ដែងនូវបាតិមោក្ខ, ឬមានភិក្ខុ ៣ រូប, ភិក្ខុ ២ រូប នាំនូវបារិសុទ្ធិរបស់ភិក្ខុ ១ រូបមកហើយ ធ្វើនូវបារិសុទ្ធិឧបោសថក្ដី ឈ្មោះថា **កម្មជាពួក** តែប្រកបដោយធម៌ ។

*ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:*

★ **ធម្មេន វគ្គន្តិ** ឯត្ថ បារិសុទ្ធិការណំ ធម្មិកំ ។ សង្ឃស្សេវ ឆន្ទាគមនំ ន គណស្សាតិ កត្វា វគ្គំ នាម ហោតិ ។ "បញ្ចសុ ឯកស្ស ឆន្ទំ អាហរិត្វា ចតូហិ បាតិមោក្ខំ ឧទ្ទិសិតុំ វដ្ដតី"តិ វទន្តិ, តំ យុត្តំ ឆន្ទហារកោ ភិក្ខុនំ សន្តិកំ បត្តោ តេន, សង្ឃោ បហោតិ, តស្មា ឆន្ទោ សង្ឃប្បត្តោ ហោតីតិ កត្វា វុត្តំ ។

*ពាក្យថា **ឈ្មោះថាកម្មជាពួក តែប្រកបដោយធម៌** ដូច្នេះ នេះ មានសេចក្ដីថា ការធ្វើនូវបារិសុទ្ធិប្រកបដោយធម៌ ។ លោក ពោលហើយ ព្រោះធ្វើសេចក្ដីអធិប្បាយថា ការនាំនូវឆន្ទៈ រមែង មកដល់សង្ឃប៉ុណ្ណោះ, មិនមកដល់គណៈទេ ព្រោះហេតុនោះ ភិក្ខុធ្វើ (នូវកម្ម) រមែងឈ្មោះថា កម្មជាពួក ។ អាចារ្យទាំង ឡាយពោលថា "បណ្ដាភិក្ខុ ៥ រូប, ភិក្ខុ ៤ រូប នាំនូវឆន្ទៈ របស់ភិក្ខុ ១ រូប មកហើយ គួរដើម្បីសម្ដែងនូវបាតិមោក្ខបាន, ពាក្យអាចារ្យនោះ ត្រឹមត្រូវហើយ, កាលភិក្ខុអ្នកនាំនូវឆន្ទៈ ទៅ ដល់សំណាក់ភិក្ខុទាំងឡាយហើយ សង្ឃរមែងគ្រប់មួយអន្លើ ដោយភិក្ខុនោះ ។ ព្រោះហេតុនោះ ឆន្ទៈជាការនាំទៅដល់សង្ឃ ហើយ ។*

## កាលបើសង្ឃមាន លោកមានកិច្ចចូលក្នុងសីមា ធ្វើបារិសុទ្ធិឧបោសថបាន

*ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:*

✯ សចេ បន ទ្វេ សង្ឃា ឯកសីមាយ អញ្ញមញ្ញំ ឆន្ទំ អាហរិត្វា ឯកស្មឹ ខណេ វិសុំ សង្ឃកម្មំ ករេន្តិ, ឯត្ថ កថន្តិ ? កេចិ បនេតំ វដ្ដតីតិ វទន្តិ, តំ ន គហេតព្វំ វគ្គកម្មត្តា កម្មំ ករេន្តានញ្ហិ ឆន្ទបារិសុទ្ធិ អញ្ញត្ថ ន គច្ឆតិ តថាវចនាភាវា, វិសុំ វិសុំ កម្ម-ករណត្ថមេវ សីមាយ អនុញ្ញាតត្តា ចាតិ គហេតព្វំ ។

*ក៏ប្រសិនបើសង្ឃ ២ ពួក នាំនូវឆន្ទៈដល់គ្នានិងគ្នា ក្នុងសីមាតែមួយ, ហើយធ្វើនូវសង្ឃកម្មក្នុងខណៈតែមួយផ្សេងគ្នា ។ សួរថា ក្នុងសេចក្ដីនេះយ៉ាងណា ? ឆ្លើយថា អាចារ្យពួកខ្លះពោលថា ក៏កម្មនោះរមែងគួរ, ពាក្យនោះមិនគប្បីកាន់យកទេ ព្រោះកម្មជាពួក, ពិតមែន កាលភិក្ខុធ្វើនូវកម្ម ឆន្ទៈនិងបារិសុទ្ធិរមែងមិនទៅកាន់ទីដទៃ ព្រោះមិនមានពាក្យដូច្នេះ ។ គប្បីកាន់យកថា ព្រោះភាវៈនៃសីមា គឺព្រះអង្គអនុញ្ញាតហើយ ដើម្បីធ្វើនូវកម្មផ្សេងៗគ្នាប៉ុណ្ណោះ ។*

វិហារសីមាយំ បន សង្ឃេ វិជ្ជមានេបិ, កេនចិ បច្ចយេន ខណ្ឌសីមាយំ តីសុ ទ្វីសុ វា បារិសុទ្ធិឧបោសថំ ករោន្តេសុ កម្មំ ធម្មេន សមគ្គមេវ ភិន្នសីមដ្ឋត្តាតិ ទដ្ឋព្វំ ។ *តែថា សូម្បីកាលមានសង្ឃនៅក្នុងវិហារសីមា, នាកាលភិក្ខុ ២ ឬ ៣ រូប ធ្វើនូវបារិសុទ្ធិឧបោសថក្នុងខណ្ឌសីមា ព្រោះបច្ច័យឯណានីមួយ, គប្បីជ្រាបថា កម្មព្រមព្រៀងគ្នា ប្រកបដោយធម៌ពិត, ព្រោះឋិតនៅក្នុងសីមាផ្សេងគ្នាហើយ ។*

*<u>ក្នុងព្រះអដ្ឋកថា ពោលថា:</u>*

*ពាក្យថា សាមណេរោ បដិជានាតិ :* ***ប្ដេជ្ញាខ្លួនជាសាមណេរ*** *ដូច្នេះ មានសេចក្ដីថា ភិក្ខុដែលនាំបារិសុទ្ធិ ប្ដេជ្ញាយ៉ាងនេះថា "ខ្ញុំព្រះករុណាជាសាមណេរ" ឬប្រាប់នូវភាពជា****សាមណេរតាមសេចក្ដីពិត*** *ឬតាំងនៅក្នុងភូមិនៃសាមណេរ ក្នុងកាលជាខាងក្រោយ ។ ក្នុងបទទាំងពួង ក៏មានន័យនេះដូចគ្នា ។*

*<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>*

☆ **"ភូតំយេវ វា សាមណេរភាវំ អារោចេតី"តិ** វុត្តត្តា ឧនវីសតិវស្សកាលេ ឧបសម្បន្នស្ស, អន្តិមវត្ថុអជ្ឈាបន្ន-សិក្ខាបច្ចក្ខាតាទីនំ វា យាវ ភិក្ខុបដិញ្ញា វត្តតិ តាវ តេហិ

អាហាជាបិ ឆន្ទុបារិសុទ្ធិ អាគច្ឆតិ ។ យទា បន តេ អត្តនោ សាមណេរភាវំ បដិជានន្តិ, តតោ បដ្ឋាយេវ នាគច្ឆតីតិ ទស្សិតន្តិ ទដ្ឋព្វំ ។

*ព្រោះព្រះអដ្ឋកថាចារ្យពោលថា ឬប្រាប់នូវភាពជា* ***សាមណេរតាមសេចក្តីពិត*** *ដូច្នេះនេះ មានសេចក្តីថា ការប្តេជ្ញាថាជាភិក្ខុរបស់បុគ្គលដែលឧបសម្បទា ក្នុងកាលមានអាយុខ្វះ ២០ ឆ្នាំ, និងរបស់បុគ្គលទាំងឡាយ មានអ្នកត្រូវអន្តិមវត្ថុ, និងអ្នកពោលលាសិក្ខាជាដើម រមែងប្រព្រឹត្តទៅដរាបណា, ដរាបនោះ ឆន្ទៈនិងបារិសុទ្ធិដែលអ្នកនោះនាំមកហើយ ជាការនាំមកហើយ ។ តែក្នុងកាលណា ពួកគេប្តេជ្ញានូវភាពជាសាមណេរតាមសេចក្តីពិត ចាប់ផ្តើមអំពីនោះទៅឆន្ទៈ និងបារិសុទ្ធិ មិនជាការនាំមកទេ ។ អ្នកសិក្សាគប្បីជ្រាបដូច្នេះឯង ។*

★ បាឡិយម្បិ ហិ "ទិន្នាយបារិសុទ្ធិយា សង្ឃប្បត្តោ វិព្ភមតិ ។ បេ ។ បណ្ឌកោ បដិជានាតិ ។ តិរច្ឆានគតោ បដិជានាតិ ។ ឧភតោព្យញ្ជនកោ បដិជានាតិ, អាហដា ហោតិ បារិសុទ្ធី"តិ វុត្តត្តា បណ្ឌកាទីនម្បិ ភិក្ខុបដិញ្ញាយ វត្តមានកាលេសុ ឆន្ទុបារិសុទ្ធិយា អាគមនំ សិទ្ធមេវ ។ តេនាហ "ឯសនយោ សព្វត្ថា"តិ ។

ពិតមែន ព្រោះពាក្យដែលព្រះអង្គត្រាស់ទុក សូម្បីក្នុងព្រះបាលីថា "កាលបារិសុទ្ធិ ដែលភិក្ខុឈឺឱ្យហើយ អ្នកនាំបារិសុទ្ធិមកដល់សង្ឃហើយសឹកទៅ ។ល ។ ប្ដេជ្ញាថាជាបណ្ឌកក្ដី តិរច្ឆានក្ដី មនុស្សភេទពីរក្ដី បារិសុទ្ធិឈ្មោះថា **នាំមកហើយ**" ដូច្នេះ, ការនាំមកនូវឆន្ទៈ និងបារិសុទ្ធិ គឺលោកសម្រេចហើយក្នុងកាលនៃបណ្ឌកៈជាដើម ប្រព្រឹត្តទៅដោយការប្ដេជ្ញាថា ជាភិក្ខុ ។ ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលថា ក្នុងបទទាំងពួងក៏មានន័យនេះដូចគ្នា ។

**ឧម្មត្តកខិត្តចិត្តវេទនាដ្ដានំ បន បកតត្តា អន្តរាមគ្គេ ឧម្មត្តកាទិភាវេ បដិញ្ញាតេបិ តេសំ សង្ឃប្បត្តមត្តេនេវ ឆន្ទាទិ អាគច្ឆតីតិ ទដ្ឋព្វំ ។** ក៏ព្រោះភិក្ខុឆ្កួត, ភិក្ខុមានចិត្តរវើរវាយ និងភិក្ខុមានវេទនាគ្របសង្កត់ គឺជាបកតត្តភិក្ខុ កាលបើប្ដេជ្ញាថាជាភិក្ខុឆ្កួតជាដើម ក្នុងចន្លោះផ្លូវពួកភិក្ខុទាំងនោះ ត្រឹមតែមកដល់សង្ឃហើយ ឆន្ទៈនិងបារិសុទ្ធិ ក៏មកដល់ដែរ អ្នកសិក្សាគប្បីឃើញដូច្នេះឯង ។

<u>ក្នុងគម្ពីរព្រះអដ្ឋកថា ពោលថា:</u>

ក៏ឯវិនិច្ឆ័យក្នុងការនាំបារិសុទ្ធិនេះ គប្បីជ្រាបដូច្នេះ ៖

បារិសុទ្ធិរបស់ភិក្ខុច្រើនរូប ដែលភិក្ខុ ១ រូប នាំមក

ហើយ ជាការនាំមកហើយពិត ។ តែបើភិក្ខុដែលនាំមកនោះ ជួបភិក្ខុដទៃ ក្នុងទីពាក់កណ្ដាលផ្លូវ ទើបឱ្យបារិសុទ្ធិរបស់ភិក្ខុទាំងឡាយដែលខ្លួនទទួលមកផង ឱ្យនូវបារិសុទ្ធិរបស់ខ្លួនផង, បារិសុទ្ធិរបស់ភិក្ខុអ្នកនាំមកនោះប៉ុណ្ណោះ រមែងមក, ចំណែកបារិសុទ្ធិរបស់ ភិក្ខុទាំងឡាយក្រៅពីនេះ ចាត់ជាបារិសុទ្ធិ ដូចប្រវាក់បង្ហា បារិសុទ្ធិនោះ រមែងមិនមកទេ ។

## ការឱ្យបារិសុទ្ធិជាប់តគ្នា មិនគួរ

<u>ក្នុងបាចិត្យាទិយោជនា ពោលថា:</u>

**ឥទំ បនេត្ថ ឱបម្មសំសន្ទនំ : យថា សង្ខលិកាយ បឋមំ វលយំ ទុតិយំយេវ វលយំ បាបុណាតិ, ន តតិយំ ឯវមេវ បឋមំ ទិន្នា បារិសុទ្ធិ ទុតិយមេវ បាបុណាតិ ន តតិយន្តិ** ។ ក៏សេចក្ដីប្រៀបធៀប និងសេចក្ដីឧបមា ក្នុងសេចក្ដីនេះដូច្នេះ ៖

កងនៃប្រវាក់កង់ ទី ១ រមែងជាប់នឹងកងនៃប្រវាក់កង់ ទី ២ ប៉ុណ្ណោះ, រមែងមិនជាប់នឹងកងនៃប្រវាក់កង់ ទី ៣ ទេ យ៉ាងណា, បារិសុទ្ធិ និង(ឆន្ទះ)ដែលបុគ្គលទី ១ ឱ្យហើយ រមែងជាប់ដល់បុគ្គលទី ២ ប៉ុណ្ណោះ, រមែងមិនជាប់ដល់បុគ្គលទី ៣ ទេ ក៏យ៉ាងនោះដែរ ។

<u>ក្នុងវិនយបិដក ភាគ ៦ ទំព័រ ៤១៨ ត្រាស់ថា:</u>

ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀតក្នុងសាសនានេះ បើក្នុងទីអាវាស ១ មានពួកអាវាសកភិក្ខុច្រើនរូប គឺចំនួន ៤ រូប ឬច្រើនជាង ៤ រូប ឡើងទៅប្រជុំគ្នាក្នុងឧបោសថថ្ងៃនោះ ។ ភិក្ខុទាំងនោះ ដឹងថាមានពួកអាវាសកភិក្ខុដទៃមិនទាន់មកដែរ ។ ភិក្ខុទាំងនោះសំគាល់ថាជាធម៌ សំគាល់ថាជាវិន័យ, **ជាពួកសំគាល់ថាព្រមព្រៀងគ្នា** ក៏ធ្វើឧបោសថ សម្តែងបាតិមោក្ខឡើង ។ កាលភិក្ខុទាំងនោះ កំពុងសម្តែងបាតិមោក្ខ ស្រាប់តែពួកអាវាសកភិក្ខុដទៃច្រើនជាងមកដល់ ក្នុងពេលនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះត្រូវសម្តែងបាតិមោក្ខម្តងទៀតចុះ ។ ពួកភិក្ខុអ្នកសម្តែងត្រូវអាបត្តិទុក្កដ ។

## ការសូត្រញត្តិចប់ហើយមានភិក្ខុចូលក្នុងសីមា កម្មមិនខូចទេ

<u>ក្នុងគម្ពីរព្រះអដ្ឋកថា ពោលថា:</u>

★ **វគ្គា សមគ្គសញ្ញិនោតិ** តេសំ សីមំ ឱក្កន្តត្តា វគ្គា, សីមំ ឱក្កន្តភាវស្ស អជាននតោ សមគ្គសញ្ញិនោ ។

ពាក្យថា ជាពួកតែសំគាល់ថាព្រមព្រៀងគ្នា ដូច្នេះនេះមានសេចក្តីថា (អាវាសកភិក្ខុទាំងឡាយធ្វើកម្ម) ជាពួក ព្រោះភាវៈនៃអាវាសកភិក្ខុទាំងឡាយ(ដទៃ)នោះ ឈានចុះកាន់សីមា

ហើយ ។ ពួកលោកសំគាល់ថា ព្រមព្រៀងគ្នា ព្រោះមិនដឹងនូវភាវៈនៃការឈានចុះកាន់សីមា របស់អាវាសិកភិក្ខុទាំងឡាយ (ដទៃ)នោះ ។

ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:

☆ **វគ្គា សមគ្គសញ្ញិនោតិអាទិ** បន ញត្តិយា និដ្ឋិតាយ "កឹ សង្ឃស្ស បុព្វកិច្ច"ន្តិអាទីនំ វចនក្ខណេ ពហិគតានំ ភិក្ខូនំ សីមាយ បវិដ្ឋត្តា ភិក្ខូ តស្មឹ ខណេ វគ្គា ហោន្តីតិ វុត្តំ ។ តេនាហ "តេសំ សីមំ ឱក្កន្តត្តា វគ្គា"តិអាទិ, **ឯតេន បារាជិកុទ្ទេសាទិក្ខណេបិ វគ្គសញ្ញីនំ ឧទ្ទិសន្តានំ អាបត្តិ ឯវ, ញត្តិយា បន បុព្វេ និដ្ឋិតត្តា** កម្មកោបោ នត្ថីតិ ទស្សិតមេវ ហោតិ ។

ក៏ក្នុងពាក្យជាដើមថា ជាពួកតែសំគាល់ថាព្រមព្រៀងគ្នា ដូច្នេះនេះ លោកអាចារ្យពោលថា ភិក្ខុទាំងឡាយជាពួក ក្នុងខណៈនោះ ព្រោះពួកភិក្ខុអ្នកទៅខាងក្រៅ ចូលមកក្នុងសីមា ក្នុងខណៈនៃពាក្យមានពាក្យជាដើមថា "កឹ សង្ឃស្ស បុព្វ កិច្ចំ" ដូច្នេះ ព្រោះញត្តិបានសូត្របប់រួចទៅហើយ, ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលពាក្យជាដើមថា "អាវាសកភិក្ខុទាំងឡាយធ្វើកម្មជាពួក ព្រោះអាវាសកភិក្ខុដទៃនោះ ឈានចូល

កាន់សីមាហើយ” ដោយពាក្យនេះ រមែងប្រាកដថា កាល អាវាសកភិក្ខុ មានសេចក្តីសំគាល់ថាជាពួក ក៏សម្តែង បាតិមោក្ខ សូម្បីក្នុងខណៈនៃឧទ្ទេសមានបារាជិកុទ្ទេសជាដើម រមែងជាអាបត្តិពិត តែមិនមានការកម្រើកនៃកម្ម ព្រោះលោក សូធ្យញត្តិចប់មុនទៅហើយ ។

<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលទុកក្នុងបវារណាខន្ធកថា:</u>

☆ **សព្វាយ វុដ្ឋិតាយ បរិសាយ អាគច្ឆន្តិ សមសមា តេសំ សន្តិកេ បវារេតព្វន្តិ** យទិ សព្វេ វុដ្ឋហិត្វា គតា សន្និបាតេតុញ្ច ន សក្កា, ឯកច្ចេ សន្និបាតេត្វា បវារេតុំ វដ្តតិ ញត្តឹ ឋបេត្វា កត្តព្វសង្ឃកម្មាភាវា វគ្គំ ន ហោតិ ។ ឧបោសថេបិ ឯសេវ នយោ ។

ពាក្យថា កាលបរិស័ទក្រោកទាំងអស់ហើយ មានពួកអាវាសិកភិក្ខុដទៃមកដល់ មានចំនួនស្មើៗគ្នា ពួកភិក្ខុដែលមកដល់ក្រោយ គប្បីបវារណាក្នុងសំណាក់របស់លោក ដូច្នេះ មាន សេចក្តីថា បើភិក្ខុគ្រប់រូបចេញទៅអស់ហើយ មិនអាចនឹងឱ្យ ប្រជុំគ្នាបាន ក៏ឱ្យភិក្ខុពួកខ្លះប្រជុំគ្នាបវារណាបាន, កម្មមិនជាពួកទេ ព្រោះមិនជាសង្ឃកម្មដែលគប្បីតាំងញត្តិធ្វើ ។ សូម្បីក្នុង ឧបោសថ ក៏មានន័យនេះដូចគ្នា ។

<u>ចំណែកក្នុងគម្ពីរវជិរពុទ្ធិដីកាវិញ ពោលថា:</u>

★ ឯត្ថ បន ឯកច្ចេសុ គតេសុបិ, សព្វេសុ គតេសុបិ, សព្វេ សន្និបាតាបេត្វា ញត្តឹ អដ្ឋបេត្វា កេវលំ បវារេតព្វំ ។ ឯកច្ចេ សន្និបាតាបេត្វា បវារេតុំ ន វដ្ដតិ "សង្ឃំ ភន្តេ បវារេមី"តិ វចនតោ ។ "សមគ្គានំ បវារណា បញ្ញត្តា"តិ វចនេត្ថ សាធកំ ។ "ឥតោ អញ្ញថា ន វដ្ដតិ អដ្ឋកថាយំ អននុញ្ញាតា"តិ ឧបតិស្ស-ត្ថេរោ វទតិ ។ *ព្រះឧបតិស្សត្ថេរពោលថា ក៏ក្នុងសេចក្ដីនេះ សូម្បីកាលភិក្ខុពួកខ្លះទៅហើយក្ដី, សូម្បីកាលភិក្ខុ ទាំងអស់ទៅហើយក្ដី, ត្រូវឱ្យភិក្ខុទាំងអស់ប្រជុំគ្នា មិនត្រូវតាំងញត្តិឡើយ ហើយគប្បីបវារណាតែម្យ៉ាង ។ កាលឱ្យភិក្ខុពួកខ្លះ មកជួបជុំគ្នា ហើយបវារណា មិនគួរទេ, ព្រោះព្រះពុទ្ធដីកាថា "បពិត្រព្រះ-សង្ឃដ៏ចម្រើន ខ្ញុំព្រះករុណាសូមបវារណានឹងសង្ឃ" ដូច្នេះ ។ ពាក្យថា "បវារណា គឺព្រះអង្គទ្រង់បញ្ញត្តិហើយ ដល់សង្ឃ ដែលព្រមព្រៀងគ្នា"ដូច្នេះ នេះគឺជាសាធកៈ ក្នុងរឿងនេះ ។ បើកាន់យកដោយប្រការដទៃអំពីនេះ រមែងមិនគួរទេ, ព្រោះ មិនមានការអនុញ្ញាតទុកក្នុងព្រះអដ្ឋកថា ។*

*ក្នុងវិនយបិដក ភាគ ១៣ ទំព័រ ៤២២ ពោលថា:*

★ *កម្មដែលសង្ឃធ្វើដោយចតុវគ្គ បានដល់ភិក្ខុ ៤ រូប ជាបកតត្តដែលគួរដល់កម្ម ភិក្ខុជាបកតត្តដ៏សេសជាអ្នកគួរដល់ឆន្ទៈដែរ, បើសង្ឃធ្វើកម្មដល់ភិក្ខុណា ភិក្ខុនោះ ជាអ្នកមិនគួរដល់កម្ម ទាំងមិនគួរដល់ឆន្ទៈទេ, តែជាអ្នកគួរដល់កម្ម (ដែលសង្ឃធ្វើនោះ) ។*

**ភិក្ខុនៅក្នុងហត្ថបាសសង្ឃ មិនត្រូវឱ្យឆន្ទៈនិងបារិសុទ្ធិទេ**

*ក្នុងគម្ពីរព្រះអដ្ឋកថា ត្រង់កម្មវគ្គ ពោលថា:*

★ តត្ថ **បកតត្តា កម្មប្បត្តាតិ** ចតុវគ្គករណេ កម្មេ ចត្តារោ បកតត្តា អនុក្ខិត្តា **អនិស្សារិតា បរិសុទ្ធសីលា** ចត្តារោ ភិក្ខូ កម្មប្បត្តា កម្មស្ស អរហា អនុច្ឆវិកា សាមិនោ ។ ន តេហិ វិនា តំ កម្មំ ករិយតិ ន តេសំ ឆន្ទោ វា បារិសុទ្ធិ វា ឯតិ ។ អវសេសា បន សចេបិ សហស្សមត្តា ហោន្តិ, សចេ សមានសំវាសកា សព្វេ **ឆន្ទារហាវ ហោន្តិ** ។ ឆន្ទបារិសុទ្ធឹ ទត្វា អាគច្ឆន្តុ វា មា វា, កម្មំ បន តិដ្ឋតិ ។

*បណ្ដាពាក្យទាំងនោះ ពាក្យថា ជាបកតត្តដែលគួរដល់*

កម្ម ដូច្នេះ មានសេចក្តីថា ក្នុងកម្មដែលសង្ឃចតុវគ្គ គប្បីធ្វើដោយភិក្ខុ ៤ រូប **អ្នកមានខ្លួនជាប្រក្រតី** គឺអ្នកដែលសង្ឃមិនបានលើកវត្ត, ដែលសង្ឃ **មិនបានដាក់ទោស**, **អ្នកមានសីលបរិសុទ្ធ**, ភិក្ខុ ៤ រូប អ្នកគួរដល់កម្ម គឺជាអ្នកគួរអ្នកសមគួរ បានដល់អ្នកជាម្ចាស់របស់កម្ម ។ កម្មនោះវៀរពួកលោកចេញ រមែងធ្វើមិនបាន ។ ឆន្ទៈក្តី បារិសុទ្ធិក្តី របស់ពួកលោកមិនទាន់មក ។ ចំណែកភិក្ខុដ៏សេសបើសូម្បីមានប្រមាណមួយពាន់រូប ។ បើជាជាអ្នកមានសំវាសស្មើគ្នា **រមែងជាអ្នកគួរដល់ឆន្ទៈ** ទាំងអស់គ្នាតែម្តង ។ បើពួកលោកប្រគល់ឆន្ទៈ និងបារិសុទ្ធិហើយ នឹងមក ឬមិនមកក៏ដោយ, ចំណែកកម្ម រមែងតាំងនៅបាន ។

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពន្យល់ថា:</u>

★ **អនិស្សារិតាតិ** ឧបោសថដ្ឋបនាទិនា វា លិទ្ធិនានាសំវាសកកាវេន វា ន ពហិកតា ។ អដ្ឋកថាយញ្ហិ "អបកតត្តស្សាតិ" ឧក្ខិត្តស្ស វា យស្ស វា ឧបោសថបវារណា ឋបិតា ហោន្តីតិ វុត្តត្តា ឋបិតឧបោសថបវារណោ ភិក្ខុ អបកតត្តោ ឯវាតិ គហេតព្វំ ។

ពាក្យថា មិនបានដាក់ទោស ដូច្នេះនេះ គឺបានដល់ភិក្ខុ

ដែលសង្ឃ មិនបានធ្វើឱ្យនៅខាងក្រៅ ដោយការបញ្ឈប់ឧបោសថជាដើមក្តី ដោយភាពជាភិក្ខុផ្សេងគ្នាដោយលទ្ធិក្តី ។ បណ្ឌិតគប្បីជ្រាបថា ភិក្ខុដែលសង្ឃបញ្ឈប់នូវឧបោសថ និងបវារណាឈ្មោះថា ភិក្ខុ**មានខ្លួនមិនប្រក្រតីពិត**, សមដូចពាក្យដែលលោកពោលទុកក្នុងអដ្ឋកថា ថា "ពាក្យថា **ភិក្ខុមិនមានខ្លួនជាប្រក្រតី** ដូច្នេះ បានដល់ភិក្ខុដែលសង្ឃលើកវត្ត និងភិក្ខុដែលសង្ឃបញ្ឈប់នូវឧបោសថ និងបវារណា" ។

★**បរិសុទ្ធសីលាតិ** បារាជិកំ អនាបន្នា អធិប្បេតា ។

ភិក្ខុដែលមិនបានត្រូវនូវអាបត្តិបារាជិក គឺលោកបំណងយកហើយ ក្នុងពាក្យថា **មានសីលបរិសុទ្ធ** ដូច្នេះ ។

★ **ឆន្ទារហា ហោន្តីតិ** សង្ឃតោ ហត្ថបាសំ វិជហិត្វា ឋិតេ សន្ធាយ វុត្តំ ។ **អវិជហិត្វា ឋិតា បន ឆន្ទារហា ន ហោន្តិ,** តេបិ ចតុវគ្គាទិតោ អធិកា ហត្ថបាសំ វិជហិត្វាវ ឆន្ទារហា ហោន្តិ ។ តស្មា សង្ឃតោ ហត្ថបាសំ វិជហិត្វា ឋិតេនេវ ឆន្ទោ វា បារិសុទ្ធិ វា ទាតព្វា ។

ពាក្យថា **រមែងជាអ្នកគួរដល់ឆន្ទៈ**ដូច្នេះ គឺលោកអាចារ្យពោលហើយ ព្រោះសំដៅដល់ភិក្ខុ ដែលឈរលះហត្ថបាសអំពីសង្ឃ ។ ចំណែកភិក្ខុដែលឈរមិនលះហត្ថបាសអំពីសង្ឃមិនគួរដល់ឆន្ទៈទេ, ចំណែកខាងភិក្ខុទាំងអស់នោះ ត្រូវលះបង់នូវ

*ហត្ថបាសឱ្យឆ្ងាយ អំពីសង្ឃបចតុវគ្គជាដើមសិន ទើបគួរផល់ឆន្ទៈ ។ ព្រោះហេតុនោះ ភិក្ខុដែលឈរលះបង់នូវហត្ថបាសអំពីសង្ឃប៉ុណ្ណោះ គប្បីឱ្យនូវឆន្ទៈ និងបារិសុទ្ធិ ។*

**ឆន្ទបារិសុទ្ធិកថាចប់ ។**

# ១២-សង្ខិត្តេន បាតិមោក្ខុទ្ទេសកថា

**បាតិមោក្ខុទ្ទេសមាន ៥ យ៉ាង :**

*១-ភិក្ខុត្រូវសម្តែងនូវនិទានហើយ សូត្រនូវឧទ្ទេសដ៏សេសសល់ដោយសុតបទ, នេះជា* ***បាតិមោក្ខុទ្ទេសទី ១*** *។*

*២-ភិក្ខុត្រូវសម្តែងនូវនិទានហើយ សម្តែងនូវបារាជិកទាំងបួនហើយ សូត្រឧទ្ទេសដ៏សេសសល់ ដោយសុតបទ នេះជា* ***បាតិមោក្ខុទ្ទេសទី ២*** *។*

*៣-ភិក្ខុត្រូវសម្តែងនូវនិទានហើយ សម្តែងនូវបារាជិកទាំងបួន, សម្តែងនូវសង្ឃាទិសេស ១៣ ហើយសូត្រនូវឧទ្ទេសដ៏សេសសល់ ដោយសុតបទ នេះជា****បាតិមោក្ខុទ្ទេសទី ៣*** *។*

*៤-ភិក្ខុត្រូវសម្តែងនិទានហើយ សម្តែងនូវបារាជិកទាំងបួន, សម្តែងនូវសង្ឃាទិសេស ១៣, សម្តែងនូវអនិយតៈ ២, ហើយសូត្រនូវឧទ្ទេសដ៏សេសសល់ ដោយសុតបទ នេះជា បាតិមោក្ខុទ្ទេសទី ៤ ។*

*៥-ឧទ្ទេសដោយពិស្តារ ជាបាតិមោក្ខុទ្ទេសទី ៥ ។*

## ការសម្ដែងនូវបាតិមោក្ខដោយសង្ខេប

ក្នុងវិនយបិដក ភាគ ៦ទំព័រ ៣៦៧ ព្រះអង្គត្រាស់ថា:

★ ន ភិក្ខវេ សង្ខិត្តេន បាតិមោក្ខំ ឧទ្ទិសិតព្វំ យោ ឧទ្ទិសេយ្យ អាបត្តិ ទុក្កដស្ស ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសម្ដែងនូវបាតិមោក្ខដោយសង្ខេបទេ ភិក្ខុណា សម្ដែង ត្រូវអាបត្តិទុក្កដ ។

★ អនុជានាមិ ភិក្ខវេ សតិ អន្តរាយេ សង្ខិត្តេន បាតិមោក្ខំ ឧទ្ទិសិតុំ ។ ម្នាលភិក្ខុទាំងឡាយ កាលបើមានសេចក្ដីអន្តរាយ តថាគតអនុញ្ញាតឱ្យសម្ដែងនូវបាតិមោក្ខ ដោយសង្ខេបបាន ។

★ ន ភិក្ខវេ អសតិ អន្តរាយេ សង្ខិត្តេន បាតិ-មោក្ខំ ឧទ្ទិសិតព្វំ យោ ឧទ្ទិសេយ្យ អាបត្តិ ទុក្កដស្ស ។ ម្នាលភិក្ខុទាំងឡាយ កាលបើគ្មានសេចក្ដីអន្តរាយទេ ភិក្ខុមិនត្រូវសម្ដែងនូវបាតិមោក្ខដោយសង្ខេបទេ ភិក្ខុណាសម្ដែង ត្រូវអាបត្តិទុក្កដ ។

★ អនុជានាមិ ភិក្ខវេ សតិ អន្តរាយេ សង្ខិត្តេន បាតិមោក្ខំ ឧទ្ទិសិតុំ ។ ម្នាលភិក្ខុទាំងឡាយ តថាគត

អនុញ្ញាតឱ្យភិក្ខុសម្តែងនូវបាតិមោក្ខ ដោយសង្ខេបបាន ក្នុងពេលមានសេចក្តីអន្តរាយ ។

**អន្តរាយ ១០ យ៉ាង**

**១-រាជន្តរាយោ** *អន្តរាយអំពីស្តេច (គឺមានស្តេចយាងចូលមក)*

**២-ចោរន្តរាយោ** *អន្តរាយអំពីចោរ (គឺមានចោរចូលមកលុកលុយ)*

**៣-អគ្យន្តរាយោ** *អន្តរាយអំពីភ្លើង (គឺមានភ្លើងឆេះព្រៃរាលមក ឬភ្លើងវត្តុះកើតឡើង)*

**៤-ឧទកន្តរាយោ** *អន្តរាយអំពីទឹក (គឺមានភ្លៀងខ្លាំងឬទឹកជំនន់ហូរមក)*

**៥-មនុស្សន្តរាយោ** *អន្តរាយអំពីមនុស្ស (គឺមានមនុស្សច្រើនចូលមក)*

**៦-អមនុស្សន្តរាយោ** *អន្តរាយអំពីអមនុស្ស (គឺមានខ្មោចចូលភិក្ខុ)*

**៧-វាឡន្តរាយោ** *អន្តរាយអំពីសត្វសាហាវ*

**៨-សិរីសបន្តរាយោ** *អន្តរាយអំពីសត្វទីឃជាតិ*

៩-ជីវិតន្តរាយោ អន្តរាយដល់ជីវិត (គឺមានភិក្ខុកើតជម្ងឺស្លាប់ ឬមានមនុស្សមានពៀរប៉ងសម្លាប់ភិក្ខុ)

១០-ព្រហ្មចរិយន្តរាយោ អន្តរាយដល់ព្រហ្មចារ្យ (គឺមានមនុស្សមកចាប់ភិក្ខុផ្សឹក) ។

★ អនុជានាមិ ភិក្ខវេ ឯវរូបេសុ អន្តរាយេសុ សង្ខិត្តេន បាតិមោក្ខំ ឧទ្ទិសិតុំ អសតិ អន្តរាយេ វិត្ថារេន ។

ម្នាលភិក្ខុទាំងឡាយ កាលបើមានសេចក្ដីអន្តរាយទាំងឡាយបែបយ៉ាងនេះ តថាគតអនុញ្ញាតឱ្យភិក្ខុសម្ដែងនូវបាតិមោក្ខដោយសង្ខេបបាន, កាលបើមិនមានសេចក្ដីអន្តរាយទេ ឱ្យភិក្ខុសម្ដែងដោយពិស្តារ ។

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>

ក្នុងអន្តរាយមានសភាពដូច្នោះ គប្បីសម្ដែងនូវបាតិមោក្ខដោយសង្ខេបបាន ។ គប្បីសូត្រឧទ្ទេសទី ១ ឬសូត្រឧទ្ទេសទី ២, ឧទ្ទេសទី ៣, ឧទ្ទេសទី ៤ ក្នុងខាងដើម ។ ក្នុងឧទ្ទេសទាំងនោះ, បណ្ដាឧទ្ទេសទី ២ ជាដើម កាលឧទ្ទេសណា សូត្រមិនទាន់ចប់ក៏មានអន្តរាយ, សូម្បីឧទ្ទេសនោះ គប្បីសូត្រដោយសុតបទតែម្ដង ។

## <u>សុត្តបាតិមោក្ខុទ្ទេសទី ១ ថា៖</u>

★ សុណាតុ មេ ភន្តេ សង្ឃោ អជ្ជុបោសថោ (បណ្ណរសោ) យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឧបោសថំ ករេយ្យ បាតិមោក្ខំ ឧទ្ទិសេយ្យ ។ កឹ សង្ឃស្ស បុព្វកិច្ចំ ? បារិសុទ្ធឹ អាយស្មន្តោ អារោចេថ, បាតិមោក្ខំ ឧទ្ទិសិស្សាមិ, តំ សព្វេវ សន្តា សាធុកំ សុណោម មនសិករោម ។ យស្ស សិយា អាបត្តិ, សោ អាវិករេយ្យ អសន្តិយា អាបត្តិយា តុណ្ហី ភវិតព្វំ, តុណ្ហីភាវេន ខោ បនាយស្មន្តេ បរិសុទ្ធាតិ វេទិស្សាមិ ។ យថា ខោ បន បច្ចេកបុដ្ឋស្ស វេយ្យាករណំ ហោតិ, ឯវមេវំ ឯវរូបាយ បរិសាយ យាវតតិយំ អនុស្សាវិតំ ហោតិ ។ យោ បន ភិក្ខុ យាវតតិយំ អនុស្សាវិយមានេ សរមានោ សន្តឹ អាបត្តឹ នាវិករេយ្យ សម្បជានមុសាវាទោ ខោ បនាយស្មន្តោ អន្តរាយិកោ ធម្មោ វុត្តោ ភគវតា តស្មា សរមានេន ភិក្ខុនា អាបន្នេន វិសុទ្ធាបេក្ខេន សន្តី អាបត្តិ អាវិកាតព្វា អាវិកតា ហិស្ស ផាសុ ហោតិ ។ ឧទ្ទិដ្ឋំ ខោ បនាយស្មន្តោ និទានំ, តត្ថាយស្មន្តេ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ?

តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? បរិសុទ្ធេត្ថា-យស្មន្តោ, តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។ និទានុទ្ទេសោ និដ្ឋិតោ ។

*(បើសូត្រនិទានុទ្ទេសទី ១ នេះ មិនទាន់ចប់ទេ មិនត្រូវសូត្រដោយសុតបទជាដាច់ខាត, បើសូត្រនិទានុទ្ទេសទី ១ ចប់ហើយ រួចត្រូវសូត្របារាជិកុទ្ទេសទី ២ ទៀត, បើកំពុងសូត្របារាជិកុទ្ទេសទី ២, ស្រាប់តែមានអន្តរាយ, ភិក្ខុអាចសូត្រ ៤ ឧទ្ទេសដ៏សេស ដោយសុតបទបាន) គឺត្រូវសូត្រដោយសុតបទ យ៉ាងនេះថា៖*

★ ឧទ្ទិដ្ឋំ ខោ អាយស្មន្តោ និទានំ, សុតា ខោ បនាយស្មន្តេហិ ចត្តារោ បារាជិកា ធម្មា, តេរស សង្ឃាទិសេសា ធម្មា, ទ្វេ អនិយតា ធម្មា, តឹស និស្សគ្គិយា បាចិត្តិយា ធម្មា, ទ្វេ នវុតិ បាចិត្តិយា ធម្មា ចត្តារោ បាដិទេសនីយា ធម្មា, បញ្ចសត្តតិ សេខិយា ធម្មា សត្ត អធិករណសមថា ធម្មា ។ ឯត្តកំ តស្ស ភគវតោ សុត្តាគតំ សុត្តបរិយាបន្នំ អន្វឌ្ឍមាសំ ឧទ្ទេសំ អាគច្ឆតិ តត្ថ សព្វេហេវ សមគ្គេហិ សម្មោទមានេហិ អវិវទមានេហិ សិក្ខិតព្វន្តិ ។ *(ចប់បាតិមោក្ខុទ្ទេសទី ១)*

## សូត្របាតិមោក្ខុទ្ទេសទី ២ ថា:

★ សុណាតុ មេ ភន្តេ សង្ឃោ អជ្ជុបោសថោ បណ្ណរសោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឧបោសថំ ករេយ្យ បាតិមោក្ខំ ឧទ្ទិសេយ្យ ។ល ។ តស្មា សរមានេន ភិក្ខុនា អាបន្នេន វិសុទ្ធាបេក្ខេន សន្តី អាបត្តិ អាវិកាតព្វា អាវិកតា ហិស្ស ផាសុ ហោតិ ។ ឧទ្ទិដ្ឋំ ខោ បណាយស្មន្តោ និទានំ, តត្ថាយស្មន្តេ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? បរិសុទ្ធេត្ថាយស្មន្តោ, តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។ និទានុទ្ទេសោ និដ្ឋិតោ ។

★ តត្រិ មេ ចត្តារោ បារាជិកា ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។បេ ។ អយម្បិ បារាជិកោ ហោតិ អសំវាសោ ។ ឧទ្ទិដ្ឋា ខោ អាយស្មន្តោ ចត្តារោ បារាជិកា ធម្មា ។បេ ។ បារាជិកោ ហោតិ អសំវាសោ ។ តត្ថាយស្មន្តេ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? បរិសុទ្ធេត្ថា-

យស្មន្តោ តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។
បារាជិកុទ្ទេសោ និដ្ឋិតោ ។

*(បើសូត្របារាជិកុទ្ទេសទី ២ ចប់ហើយ, រួចត្រូវសូត្រសង្ឃាទិសេសុទ្ទេសទី ៣, បើកំពុងតែសូត្រសង្ឃាទិសេសុទ្ទេសទី ៣, ស្រាប់តែមានអន្តរាយ, ភិក្ខុអាចសូត្រ ៣ ឧទ្ទេសដ៏សេស ដោយសុតបទបាន) គឺ ភិក្ខុត្រូវសូត្រដោយសុតបទយ៉ាងនេះថា ៖*

★ ឧទ្ទិដ្ឋំ ខោ អាយស្មន្តោ និទានំ, ឧទ្ទិដ្ឋា ចត្តារោ បារាជិកា ធម្មា, សុតា ខោ បនាយស្មន្តេហិ តេរស សង្ឃាទិសេសា ធម្មា, ទ្វេ អនិយតា ធម្មា, តឹស និស្សគ្គិយា បាចិត្តិយា ធម្មា, ទ្វេ នវុតិ បាចិត្តិយា ធម្មា, ចត្តារោ បាដិទេសនីយា ធម្មា, បញ្ចសត្តតិ សេខិយា ធម្មា, សត្ត អធិករណសមថា ធម្មា ។ ឯត្តកំ តស្ស ភគវតោ សុត្តាគតំ សុត្តបរិយាបន្នំ អន្វឌ្ឍមាសំ ឧទ្ទេសំ អាគច្ឆតិ ។ តត្ថ សព្វេហេវ សមគ្គេហិ សម្មោទមានេហិ អវិវទមានេហិ សិក្ខិតព្វន្តិ ។

*( ចប់បាតិមោក្ខុទ្ទេសទី ២ )*

## សូត្របាតិមោក្ខុទ្ទេសទី ៣ ថា:

★ សុណាតុ មេ ភន្តេ សង្ឃោ អជ្ជុបោសថោ បណ្ណរសោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឧបោសថំ ករេយ្យ បាតិមោក្ខំ ឧទ្ទិសេយ្យ ។ល ។ តស្មា សរមានេន ភិក្ខុនា អាបន្នេន វិសុទ្ធាបេក្ខេន សន្តី អាបត្តិ អាវិកាតព្វា អាវិកតា ហិស្ស ផាសុ ហោតិ ។ ឧទ្ទិដ្ឋំ ខោ បនាយស្មន្តោ និទានំ, តត្ថាយស្មន្តេ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? បរិសុទ្ធេត្ថាយស្មន្តោ, តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។ និទានុទ្ទេសោ និដ្ឋិតោ ។

★ តត្រិមេ ចត្តារោ បារាជិកា ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។បេ ។ អយម្បិ បារាជិកោ ហោតិ អសំវាសោ ។ ឧទ្ទិដ្ឋា ខោ អាយស្មន្តោ ចត្តារោ បារាជិកា ធម្មា ។បេ ។ បារាជិកោ ហោតិ អសំវាសោ ។ តត្ថាយស្មន្តេ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ?

បរិសុទ្ធេត្ថាយស្មន្តោ, តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។ ចាតុរាជិកុទ្ទេសោ និដ្ឋិតោ ។

★ ឥមេ ខោ បនាយស្មន្តោ តេរស សង្ឃាទិសេសា ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។ប។ ឧទ្ទិដ្ឋា ខោ អាយស្មន្តោ តេរស សង្ឃាទិសេសា ធម្មា នវ បឋមាបត្តិកា ។ប។ សោ ច ភិក្ខុ អនព្ភិតោ តេ ច ភិក្ខូ គារយ្ហា ។ អយំ តត្ថ សាមីចិ ។ តត្ថាយស្មន្តេ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? បរិសុទ្ធេត្ថាយស្មន្តោ, តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។ សង្ឃាទិសេសុទ្ទេសោ និដ្ឋិតោ ។

*(បើសូត្រសង្ឃាទិសេសុទ្ទេសទី ៣ ចប់ហើយ, រូបត្រូវសូត្រអនិយតុទ្ទេសទី ៤,* ***បើកំពុងសូត្រអនិយតុទ្ទេសទី ៤*** *ស្រាប់តែមានអន្តរាយ, ភិក្ខុអាចសូត្រ ២ ឧទ្ទេសដ៏សេសដោយសុតបទបាន) គឺត្រូវសូត្រដោយសុតបទយ៉ាងនេះថា:*

★ ឧទ្ទិដ្ឋំ ខោ អាយស្មន្តោ និទានំ, ឧទ្ទិដ្ឋា ចត្តារោ បារាជិកា ធម្មា, ឧទ្ទិដ្ឋា តេរស សង្ឃាទិសេសា ធម្មា សុតា ខោ បនាយស្មន្តេហិ ទ្វេ អនិយតា ធម្មា, តីស និស្សគ្គិយា បាចិត្តិយា ធម្មា, ទ្វេ នវុតិ បាចិត្តិយា ធម្មា

ចត្តារោ បារាជិកា ធម្មា, តេរស សង្ឃាទិសេសា ធម្មា, ទ្វេ អនិយតា ធម្មា, តិំស និស្សគ្គិយា បាចិត្តិយា ធម្មា, ទ្វេនវុតិ បាចិត្តិយា ធម្មា, ចត្តារោ បាដិទេសនីយា ធម្មា, បញ្ចសត្តតិ សេខិយា ធម្មា សត្ត អធិករណសមថា ធម្មា ។ ឯត្តកំ តស្ស ភគវតោ សុត្តាគតំ សុត្តបរិយាបន្នំ អន្វឌ្ឍមាសំ ឧទ្ទេសំ អាគច្ឆតិ ។ តត្ថ សព្វេហេវ សមគ្គេហិ សម្មោទមានេហិ អវិវទមានេហិ សិក្ខិតព្វន្តិ ។

(ចប់បាតិមោក្ខុទ្ទេសទី ៣)

<u>សូត្របាតិមោក្ខុទ្ទេសទី ៤ ថា:</u>

✯ សុណាតុ មេ ភន្តេ សង្ឃោ អជ្ជុបោសថោ បណ្ណរសោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឧបោសថំ ករេយ្យ បាតិមោក្ខំ ឧទ្ទិសេយ្យ ។ល ។ តស្មា សរមានេន ភិក្ខុនា អាបន្នេន វិសុទ្ធាបេក្ខេន សន្តី អាបត្តិ អាវិកាតព្វា អាវិកតា ហិស្ស ផាសុ ហោតិ ។ ឧទ្ទិដ្ឋំ ខោ បនាយស្មន្តោ និទានំ, តត្ថាយស្មន្តេ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? បរិសុទ្ធេត្ថាយស្មន្តោ, តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។ និទានុទ្ទេសោ និដ្ឋិតោ ។

★ តត្រិមេ ចត្តារោ បារាជិកា ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។បេ ។ អយម្បិ បារាជិកោ ហោតិ អសំវាសោ ។ ឧទ្ទិដ្ឋា ខោ អាយស្មន្តោ ចត្តារោ បារាជិកា ធម្មា ។បេ ។ បារាជិកោ ហោតិ អសំវាសោ ។ តត្ថាយស្មន្តេ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? បរិសុទ្ធេត្ថា-យស្មន្តោ, តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។ បារាជិកុទ្ទេសោ និដ្ឋិតោ ។

★ ឥមេ ខោ បនាយស្មន្តោ តេរស សង្ឃាទិសេសា ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។ ប ។ ឧទ្ទិដ្ឋា ខោ អាយស្មន្តោ តេរស សង្ឃាទិសេសា ធម្មា នវ បឋមាបត្តិកា ។ ប ។ សោ ច ភិក្ខុ អនព្ភិតោ តេ ច ភិក្ខូ គារយ្ហា ។ អយំ តត្ថ សាមីចិ ។ តត្ថាយស្មន្តេ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ? បរិសុទ្ធេត្ថាយស្មន្តោ, តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។ សង្ឃាទិសេសុទ្ទេសោ និដ្ឋិតោ ។

★ ឥមេ ខោ បនាយស្មន្តោ ទ្វេ អនិយតា ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។ប ។ ឧទ្ទិដ្ឋា ខោ អាយស្មន្តោ ទ្វេ

អនិយតា ធម្មា ។ តត្ថាយស្មន្តេ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា? តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា បរិសុទ្ធេត្ថាយស្មន្តោ តស្មា តុណ្ហី ឯវមេតំ ធារយាមិ ។ អនិយតុទ្ទេសោ និដ្ឋិតោ ។ *(បើសូត្រអនិយតុទ្ទេសទី ៤ ចប់ហើយ, រួចត្រូវសូត្រវិត្ថារុទ្ទេសទី ៥, បើកំពុងតែសូត្រវិត្ថារុទ្ទេសទី៥, ស្រាប់តែមានអន្តរាយ, ភិក្ខុអាចសូត្រ១ ឧទ្ទេសដ៏សេសដោយសុតបទបាន) គឺត្រូវសូត្រដោយសុតបទ យ៉ាងនេះថា៖*

★ ឧទ្ទិដ្ឋំ ខោ អាយស្មន្តោ និទានំ, ឧទ្ទិដ្ឋា ចត្តារោ បារាជិកា ធម្មា, ឧទ្ទិដ្ឋា តេរស សង្ឃាទិសេសា ធម្មា ឧទ្ទិដ្ឋា ទ្វេ អនិយតា ធម្មា, សុតា ខោ[1] បនាយស្មន្តេហិ តឹស និស្សគ្គិយា បាចិត្តិយា ធម្មា, ទ្វេ នវុតិ បាចិត្តិយា ធម្មា, ចត្តារោ បាដិទេសនីយា ធម្មា, បញ្ចសត្តតិ សេខិយា ធម្មា, សត្ត អធិករណសមថា ធម្មា ។ ឯត្តកំ តស្ស ភគវតោ សុត្តាគតំ សុត្តបរិយាបន្នំ អន្វឌ្ឍមាសំ ឧទ្ទេសំ អាគច្ឆតិ ។ តត្ថ សព្វេហេវ សមគ្គេហិ សម្មោទមានេហិ

---

*១.បើសូត្រនិស្សគ្គិយចប់ហើយត្រូវពោលថា* "ឧទ្ទិដ្ឋា តឹស និស្សគ្គិយា បាចិត្តិយា ធម្មា" *ដូច្នេះវិញ ។ ការសូត្របាចិត្តិយជាដើមចប់ហើយ ក៏មានន័យនេះដូចគ្នា ។*

អភិវទមានេហិ សិក្ខិតព្វន្តិ ។

( ចប់បាតិមោក្ខុទ្ទេសទី ៤ )

<u>ក្នុងវិនយបិដកភាគ ៦ ទំព័រ ៣៧៥ ពោលថា:</u>

★ អនុជានាមិ ភិក្ខវេ ថេរាធិកំ បាតិមោក្ខំ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវព្រះបាតិមោក្ខ មានព្រះថេរៈជាធំ ។

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>

បើបាតិមោក្ខុទ្ទេស ៥ ឬ ៤ ឬ ៣ របស់ព្រះថេរៈចាំមិនបាន តែ ២ **ឧទ្ទេសជារបស់មិនខ្វះខាត** ជំនាញល្អ ស្ទាត់រាត់មាត់ បាតិមោក្ខគង់ជានាទីរបស់ព្រះថេរៈពិត ។ ប្រសិនបើថាសូម្បីត្រឹមតែ ២ ឧទ្ទេសប៉ុណ្ណោះ ព្រះថេរមិនអាចធ្វើឱ្យជំនាញបាន បាតិមោក្ខ រមែងជានាទីរបស់ភិក្ខុដ៏ដែលឈ្លាស ។

**មិនមានអន្តរាយតែអាចសូធ្យបាតិមោក្ខដោយសង្ខេបបាន**

<u>ក្នុងគម្ពីរខុទ្ទកសិក្ខាបុរាណដីកា ពោលថា:</u>

★ ទ្វីសុ វា តីសុ វា វិសទេសុ ថេរោវ ឥស្សរោតិ អដ្ឋកថាយំ វុត្តត្តា អវត្តន្តេបិ អន្តរាយេ

**សំខិត្តេន ឧទ្ទិសិតុំ វដ្ដតីតិ អធិប្បាយោ ។**

ព្រោះពាក្យដែលលោកពោលទុកក្នុងអដ្ឋកថា ថា "សូម្បីឧទ្ទេសពួកខ្លះ ព្រះថេរៈសូត្រមិនបានក៏ដោយ បើព្រះថេរៈអាចសូត្រត្រឹមតែ ២-៣ ឧទ្ទេស ស្ទាត់ជំនាញល្អ បាតិមោក្ខគង់ជានាទីរបស់ព្រះថេរៈពិត" ដូច្នេះ មានសេចក្ដីអធិប្បាយថា សូម្បីមិនមានអន្តរាយ រមែងគួរដើម្បីឱ្យព្រះថេរៈ សូត្រដោយសង្ខេបបាន ។

<u>ក្នុងវិនយបិដកភាគ ៦ ទំព័រ ៣៨៦ ពោលថា:</u>

ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ថ្ងៃឧបោសថនោះ មានភិក្ខុជាច្រើនរូបសុទ្ធតែល្ងង់មិនឈ្លាស នៅក្នុងអាវាសមួយ ។ ភិក្ខុទាំងនោះ មិនដឹងឧបោសថ ឬឧបោសថកម្ម បាតិមោក្ខ ឬបាតិមោក្ខុទ្ទេស ។ ម្នាលភិក្ខុទាំងឡាយ ត្រូវភិក្ខុទាំងឡាយនោះបញ្ជូនភិក្ខុ ១ រូប ទៅកាន់អាវាសជិតខាង ក្នុងថ្ងៃនោះថា **នែអាវុសោ ចូរអ្នកទៅរៀនបាតិមោក្ខដោយសង្ខេប ឬដោយពិស្ដារមក ។** បើភិក្ខុដែលបញ្ជូនទៅនោះ បានបាតិមោក្ខនោះដោយអាការៈយ៉ាងនោះ ការបាននោះ ជាការល្អ, បើមិនបានទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយក្នុងអាវាសណា ដឹងឧបោសថ ឬឧបោសថកម្ម បាតិមោក្ខ ឬបាតិមោក្ខុទ្ទេស ត្រូវ

ភិក្ខុទាំងឡាយនោះ ទៅកាន់អាវាសនោះទាំងអស់គ្នា បើមិនទៅទេ ត្រូវអាបត្តិទុក្កដ ។

ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:

★ "គច្ឆាវុសោ សំខិត្តេន វា វិត្ថារេន វា"តិ វចនតោ អសតិបិ អន្តរាយេ ថាមំ បមាណន្តិ សិទ្ធំ ហោតិ ។ ដោយព្រះពុទ្ធដីកាថា ម្នាលអាវុសោលោកចូរទៅរៀនបាតិមោក្ខដោយសង្ខេប ឬដោយពិស្តារមក ដូច្នេះនេះ លោកសម្រេចថា សូម្បីមិនមានអន្តរាយ, សមត្ថភាពជាប្រមាណ (បើភិក្ខុមានសមត្ថភាព អាចរៀនបានដោយសង្ខេបគឺអាចសូធ្យ បាតិមោក្ខដោយសង្ខេបបាន) ។

ក្នុងវិនយបិដក ភាគ ១៣ ទំព័រ ២០ ពោលថា:

★ បុគ្គលពាលមាន២ពួក គឺបុគ្គលដែលនាំភារៈ មិនទាន់មានមក ១ បុគ្គលដែលមិននាំភារៈដែលមានមកហើយ ១ ។

ក្នុងគម្ពីរអដ្ឋកថា ពោលថា:

★ ពាក្យថា បុគ្គលដែលនាំភារៈមិនទាន់មានមក ដូច្នេះមានសេចក្តីថា ភិក្ខុមិនមែនជាថេរៈទេ តែនាំភារៈមានកាន់ផ្ចិតនិងអាភពធនាឱ្យសម្តែងធម៌ជាដើម ដែលព្រះថេរៈទាំងឡាយ

នឹងគប្បីនាំ គឺផ្តើមព្យាយាមទទួលនូវភារៈនោះ ។

★ ពាក្យថា **បុគ្គលដែលមិននាំភារៈដែលមានមកហើយ** ដូច្នេះ មានសេចក្តីថា ភិក្ខុដែលជាថេរៈ តែមិនធ្វើកិច្ចរបស់ព្រះថេរៈ, អធិប្បាយថា ឱ្យសាបសូន្យនូវកិច្ចទាំងពួង មានជាដើមយ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យព្រះថេរៈសម្តែងធម៌ដោយខ្លួនឯង ឬអារាធនាភិក្ខុដទៃក៏បាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត នូវព្រះបាតិមោក្ខ មានព្រះថេរជាធំ" ។

**សង្ខិត្តេន បាតិមោក្ខុទ្ទេសកថាចប់ ។**

# ១៣-អាបត្តិទេសនាកថា

## វិធីសម្ដែងអាបត្តិ តែមួយ

*ក្នុងវិនយបិដក និងអដ្ឋកថាឧបោសថក្ខន្ធកៈ ពោលថា:*

**★ បើភិក្ខុខ្ចីវស្សា ទៅសម្ដែងអាបត្តិជាមួយនឹងភិក្ខុ មានវស្សាចាស់ជាងៈ**

*ត្រូវភិក្ខុខ្ចីពោលថា:*

អហំ ភន្តេ ( ថុល្លច្ចយំ ) អាបត្តឹ អាបន្នោ តំ តុម្ហមូលេ បដិទេសេមិ ។ *បពិត្រលោកម្ចាស់ ខ្ញុំករុណាត្រូវនូវអាបត្តិថុល្លច្ច័យ, ខ្ញុំករុណា សូមសម្ដែងនូវអាបត្តិនោះក្នុងសំណាក់របស់លោក ។*

*ត្រូវភិក្ខុចាស់សួរថា:*

បស្សសិ អាវុសោ តំ អាបត្តឹ : *ម្នាលអាវុសោ លោកឃើញនូវអាបត្តិនោះឬ ?*

*ត្រូវភិក្ខុខ្ចីឆ្លើយថា:*

អាម ភន្តេ បស្សាមិ : *ករុណាលោកម្ចាស់ ខ្ញុំព្រះករុណា ឃើញ ។*

<u>*ត្រូវភិក្ខុចាស់ពោលថា:*</u>

អាយតឹ អាវុសោ សំវរេយ្យាសិ : *ម្នាលអាវុសោ លោកគប្បីសង្រួមតទៅចុះ ។*

<u>*ត្រូវភិក្ខុខ្ចីពោលថា:*</u>

សាធុ សុដ្ឋុ សំវរិស្សាមិ : *ល្អណាស់ ខ្ញុំព្រះករុណានឹងសង្រួមឱ្យល្អតទៅ ។*

**✯ បើភិក្ខុចាស់វស្សា ទៅសម្តែងអាបត្តិជាមួយនឹងភិក្ខុមានវស្សាខ្ចីជាងវិញ :**

<u>*ត្រូវភិក្ខុចាស់ ពោលថា:*</u>

អហំ អាវុសោ ( ថុល្លច្ចយំ ) អាបត្តឹ អាបន្នោ តំ តុម្ហមូលេ **បដិទេសេមិ** ។ *ម្នាលអាវុសោ ខ្ញុំករុណាត្រូវនូវអាបត្តិថុល្លច្ច័យ, ខ្ញុំព្រះករុណា **សូមសម្តែង**នូវអាបត្តិនោះ ក្នុងសំណាក់របស់លោក ។*

<u>*ត្រូវភិក្ខុខ្ចីសួរថា:*</u>

បស្សថ ភន្តេ តំ អាបត្តឹ : *បពិត្រលោកម្ចាស់ លោកឃើញនូវអាបត្តិនោះឬ ?*

<u>*ត្រូវភិក្ខុចាស់ឆ្លើយថា:*</u>

អាម អាវុសោ បស្សាមិ : *អើអាវុសោ*

ខ្ញុំព្រះករុណាឃើញ

<u>ត្រូវភិក្ខុខ្ចី ពោលថា:</u>

អាយតឹ ភន្តេ សំវរេយ្យាថ : បពិត្រលោកម្ចាស់, សូមលោកម្ចាស់ សង្រួមតទៅចុះ ។

<u>ត្រូវភិក្ខុចាស់ ពោលថា:</u>

សាធុ សុដ្ឋុ សំវរិស្សាមិ : ល្អណាស់ ខ្ញុំព្រះករុណានឹង សង្រួមឱ្យល្អតទៅ ។

<u>ក្នុងគម្ពីរខុទ្ទកសិក្ខា ពោលអំពីការសម្ដែងអាបត្តិថា:</u>

## វិធីសម្ដែងអាបត្តិថុល្លច្ច័យ តែ ១

### ★បើភិក្ខុខ្ចីវស្សា ទៅសម្ដែងអាបត្តិជាមួយនឹងភិក្ខុមានវស្សាចាស់ជាង

<u>ត្រូវភិក្ខុខ្ចីពោលថា:</u>

អហំ ភន្តេ, ឯកំ ថុល្លច្ចយាបត្តឹ អាបជ្ជឹ, តំ តុម្ហមូលេ បដិទេសេមិ : បពិត្រលោកម្ចាស់ ខ្ញុំករុណាត្រូវនូវអាបត្តិថុល្លច្ច័យ១, ខ្ញុំករុណាសូមសម្ដែងនូវអាបត្តិនោះ ក្នុងសំណាក់របស់លោកម្ចាស់ ។

<u>ត្រូវភិក្ខុចាស់ សួរថា:</u>

បស្សសិ អាវុសោ តំ អាបត្តឹ : ម្នាលអាវុសោ លោកឃើញនូវអាបត្តិនោះឬ ?

<u>ត្រូវភិក្ខុខ្ចី ឆ្លើយថា:</u>

អាម ភន្តេ បស្សាមិ : ករុណាលោកម្ចាស់ ខ្ញុំព្រះករុណា ឃើញ ។

<u>ត្រូវភិក្ខុចាស់ ពោលថា:</u>

អាយតឹ អាវុសោ សំវរេយ្យាសិ : ម្នាលអាវុសោ លោក គប្បីសង្រួមតទៅចុះ ។

<u>ត្រូវភិក្ខុខ្ចី ពោលថា:</u>

សាធុ សុដ្ឋុ ភន្តេ សំវរិស្សាមិ : បពិត្រលោកម្ចាស់ ល្អណាស់ ខ្ញុំព្រះករុណានឹងសង្រួមឱ្យល្អតទៅ ។

## វិធីសម្តែងអាបត្តិ ថុល្លច្ច័យ ២

<u>ត្រូវភិក្ខុខ្ចីពោលថា:</u>

អហំ ភន្តេ ទ្វេ ថុល្លច្ចយាបត្តិយោ អាបជ្ជឹ, តា តុម្ហមូលេ បដិទេសេមិ ។

<u>ត្រូវភិក្ខុចាស់ សួរថា:</u>

បស្សសិ អាវុសោ តា អាបត្តិយោ ។

<u>ត្រូវភិក្ខុខ្ចីឆ្លើយថា:</u> អាម ភន្តេ បស្សាមិ ។

<u>ត្រូវភិក្ខុចាស់ពោលថា:</u> អាយតឹ អាវុសោ សំវរេយ្យាសិ ។

<u>ត្រូវភិក្ខុខ្ចីពោលថា:</u> សាធុ សុដ្ឋុ ភន្តេ សំវរិស្សាមិ ។

## វិធីសម្ដែងអាបត្តិ ថុល្លច្ច័យច្រើន

<u>ត្រូវភិក្ខុខ្ចី ពោលថា:</u>

អហំ ភន្តេ សម្ពហុលា ថុល្លច្ចយាបត្តិយោ អាបជ្ជឹ, តា តុម្ហមូលេ បដិទេសេមិ ។

<u>ត្រូវភិក្ខុចាស់ សួរថា:</u> បស្សសិ អាវុសោ តា អាបត្តិយោ ។

<u>ត្រូវភិក្ខុខ្ចី ឆ្លើយថា:</u> អាម ភន្តេ បស្សាមិ ។

<u>ត្រូវភិក្ខុចាស់ ពោលថា:</u> អាយតឹ អាវុសោ សំវរេយ្យាសិ ។

<u>ត្រូវភិក្ខុខ្ចី ពោលថា:</u> សាធុ សុដ្ឋុ ភន្តេ សំវរិស្សាមិ ។

## វិធីសម្ដែងអាបត្តិ បាចិត្តិយ តែ ១

ត្រូវភិក្ខុខ្ចីពោលថា:

អហំ ភន្តេ, ឯកំ បាចិត្តិយាបត្តឹ អាបជ្ជឹ, តំ តុម្ហមូលេ បដិទេសេមិ ។

ត្រូវភិក្ខុចាស់ពោលថា: បស្សសិ អាវុសោ តំ អាបត្តឹ ។

ត្រូវភិក្ខុខ្ចីឆ្លើយថា: អាម ភន្តេ បស្សាមិ ។

ត្រូវភិក្ខុចាស់ពោលថា: អាយតឹ អាវុសោ សំវរេយ្យាសិ ។

ត្រូវភិក្ខុខ្ចីពោលថា: សាធុ សុដ្ឋុ ភន្តេ សំវរិស្សាមិ ។

## វិធីសម្ដែងអាបត្តិ បាចិត្តិយ ២ ឬ ច្រើន

ត្រូវភិក្ខុខ្ចីពោលថា:

អហំ ភន្តេ, ទ្វេ បាចិត្តិយាបត្តិយោ អាបជ្ជឹ ។ សម្ពហុលា បាចិត្តិយាបត្តិយោ អាបជ្ជឹ ។ តា តុម្ហមូលេ បដិទេសេមិ ។

ត្រូវភិក្ខុចាស់សួរថា:

បស្សសិ អាវុសោ តា អាបត្តិយោ ។

ត្រូវភិក្ខុខ្ចីឆ្លើយថា: អាម ភន្តេ បស្សាមិ ។

ត្រូវភិក្ខុចាស់ពោលថាៈ  អាយតឹ អាវុសោ សំវរេយ្យាសិ ។

ត្រូវភិក្ខុខ្ចីពោលថាៈ  សាធុ សុដ្ឋុ ភន្តេ សំវរិស្សាមិ ។

## វិធីសម្តែងអាបត្តិ បាដិទេសនីយ

ត្រូវភិក្ខុខ្ចីពោលថាៈ

គារយ្ហំ ភន្តេ ធម្មំ អាបជ្ជឹ អសប្បាយំ បាដិទេសនីយំ, តំ បដិទេសេមិ ។

ត្រូវភិក្ខុចាស់ពោលថាៈ  បស្សសិ អាវុសោ តំ ធម្មំ ។

ត្រូវភិក្ខុខ្ចីឆ្លើយថាៈ  អាម ភន្តេ បស្សាមិ ។

ត្រូវភិក្ខុចាស់ពោលថាៈ  អាយតឹ អាវុសោ សំវរេយ្យាសិ ។

ត្រូវភិក្ខុខ្ចីពោលថាៈ  សាធុ សុដ្ឋុ ភន្តេ សំវរិស្សាមិ ។

## វិធីសម្តែងអាបត្តិ ទុក្កដ តែ ១

ត្រូវភិក្ខុខ្ចីពោលថាៈ

អហំ ភន្តេ ឯកំ ទុក្កដាបត្តឹ អាបជ្ជឹ ។ តំ តុម្ហមូលេ បដិទេសេមិ ។

ត្រូវភិក្ខុចាស់ពោលថាៈ បស្សសិ អាវុសោ តំ អាបត្តឹ ។

ត្រូវភិក្ខុទីឆ្លើយថា: អាម ភន្តេ បស្សាមិ ។

ត្រូវភិក្ខុចាស់ពោលថា:

អាយតឹ អាវុសោ សំវរេយ្យាសិ ។

ត្រូវភិក្ខុទីពោលថា: សាធុ សុដ្ឋុ ភន្តេ សំវរិស្សាមិ ។

## វិធីសម្តែងអាបត្តិ ទុក្កដ ២ ឬ ច្រើន

ត្រូវភិក្ខុទីពោលថា:

អហំ ភន្តេ, ទ្វេ ទុក្កដាបត្តិយោ អាបជ្ជឹ ។ សម្ពហុលា ទុក្កដាបត្តិយោ អាបជ្ជឹ ។ តា តុម្ហមូលេ បដិទេសេមិ ។

ត្រូវភិក្ខុចាស់សួរថា: បស្សសិ អាវុសោ តា អាបត្តិយោ ។

ត្រូវភិក្ខុទីឆ្លើយថា: អាម ភន្តេ បស្សាមិ ។

ត្រូវភិក្ខុចាស់ពោលថា: អាយតឹ អាវុសោ សំវរេយ្យាសិ ។

ត្រូវភិក្ខុទីពោលថា: សាធុ សុដ្ឋុ ភន្តេ សំវរិស្សាមិ ។

## វិធីសម្តែងអាបត្តិ ទុព្ភាសិត តែ ១

ត្រូវភិក្ខុទីពោលថា:

អហំ ភន្តេ ឯកំ ទុព្ភាសិតាបត្តឹ អាបជ្ជឹ ។ តំ តុម្ហមូលេ បដិទេសេមិ ។

ត្រូវភិក្ខុចាស់ពោលថា: បស្សសិ អាវុសោ តំ អាបត្តឹ ។

*ត្រូវភិក្ខុទីឆ្លើយថា:* អាម ភន្តេ បស្សាមិ ។

*ត្រូវភិក្ខុចាស់ពោលថា:*

អាយតឹ អាវុសោ សំវរេយ្យាសិ ។

*ត្រូវភិក្ខុទីពោលថា:* សាធុ សុដ្ឋុ ភន្តេ សំវរិស្សាមិ ។

**វិធីសម្ដែងអាបត្តិ ទុព្ភាសិត ២ ឬ ច្រើន**

*ត្រូវភិក្ខុទីពោលថា:* អហំ ភន្តេ ទ្វេ ទុព្ភាសិតាបត្តិយោ អាបជ្ជឹ ។ សម្ពហុលា ទុព្ភាសិតាបត្តិយោ អាបជ្ជឹ ។ តា តុម្ហមូលេ បដិទេសេមិ ។

*ត្រូវភិក្ខុចាស់សួរថា:*

បស្សសិ អាវុសោ តា អាបត្តិយោ ។

*ត្រូវភិក្ខុទីឆ្លើយថា:* អាម ភន្តេ បស្សាមិ ។

*ត្រូវភិក្ខុចាស់ពោលថា:*

អាយតឹ អាវុសោ សំវរេយ្យាសិ ។

*ត្រូវភិក្ខុទីពោលថា:* សាធុ សុដ្ឋុ ភន្តេ សំវរិស្សាមិ ។

**វិធីសម្ដែងអាបត្តិ ថុល្លច្ច័យ ២ មានវត្ថុផ្សេងគ្នា**

*ត្រូវភិក្ខុទីពោលថា:* អហំ ភន្តេ ទ្វេ នានាវត្ថុកា

ថុល្លច្ចយាបត្តិយោ អាបជ្ជឹ ។ តា តុម្ហមូលេ បដិទេសេមិ ។

*ត្រូវភិក្ខុចាស់សួរថា:*

បស្សសិ អាវុសោ តា អាបត្តិយោ ។

*ត្រូវភិក្ខុខ្ចីឆ្លើយថា:* អាម ភន្តេ បស្សាមិ ។

*ត្រូវភិក្ខុចាស់ពោលថា:*

អាយតឹ អាវុសោ សំវរេយ្យាសិ ។

*ត្រូវភិក្ខុខ្ចីពោលថា:* សាធុ សុដ្ឋុ ភន្តេ សំវរិស្សាមិ ។

## វិធីសម្ដែងអាបត្តិ ថុល្លច្ច័យច្រើន មានវត្ថុផ្សេងគ្នា

**★ បើភិក្ខុខ្ចីវស្សាទៅសម្ដែងអាបត្តិជាមួយនឹងភិក្ខុមានវស្សាចាស់ជាង**

*ត្រូវភិក្ខុខ្ចីពោលថា:* អហំ ភន្តេ សម្ពហុលា នានាវត្ថុកា ថុល្លច្ចយាបត្តិយោ អាបជ្ជឹ, តា តុម្ហមូលេ បដិទេសេមិ ។

*ត្រូវភិក្ខុចាស់សួរថា:* បស្សសិ អាវុសោ តា អាបត្តិយោ ។

*ត្រូវភិក្ខុខ្ចីឆ្លើយថា:* អាម ភន្តេ បស្សាមិ ។

*ត្រូវភិក្ខុចាស់ពោលថា:* អាយតឹ អាវុសោ សំវរេយ្យាសិ ។

*ត្រូវភិក្ខុខ្ចីពោលថា:* សាធុ សុដ្ឋុ ភន្តេ សំវរិស្សាមិ ។

## ✯ បើភិក្ខុចាស់វស្សាទៅសម្ដែងអាបត្តិជាមួយនឹងភិក្ខុមានវស្សាខ្ចីជាងវិញ

ត្រូវភិក្ខុចាស់ពោលថា: អហំ អាវុសោ សម្ពហុលា នានាវត្ថុកា ថុល្លច្ចយាបត្តិយោ អាបជ្ជឹ, តា តុម្ហមូលេ បដិទេសេមិ ។ ម្នាលអាវុសោ ខ្ញុំករុណាត្រូវនូវអាបត្តិថុល្លច្ច័យជាច្រើន ដែលមានវត្ថុផ្សេងៗគ្នា ខ្ញុំករុណាសូមសម្ដែងនូវអាបត្តិទាំងនោះ ក្នុងសំណាក់របស់លោក,

ត្រូវភិក្ខុខ្ចីសួរថា: បស្សថ ភន្តេ តា អាបត្តិយោ : បពិត្រលោកម្ចាស់ លោកឃើញនូវអាបត្តិទាំងនោះឬ ?

ត្រូវភិក្ខុចាស់ឆ្លើយថា: អាម អាវុសោ បស្សាមិ : អើអាវុសោ ខ្ញុំព្រះករុណាឃើញ

ត្រូវភិក្ខុខ្ចីពោលថា: អាយតឹ ភន្តេ សំវរេយ្យាថ : បពិត្រលោកម្ចាស់ សូមលោកម្ចាស់ គប្បីសង្រួមតទៅចុះ ។

ត្រូវភិក្ខុចាស់ពោលថា: សាធុ សុដ្ឋុ សំវរិស្សាមិ : ល្អណាស់ ខ្ញុំព្រះករុណា នឹងសង្រួមឱ្យល្អតទៅ ។

## វិធីសម្ដែងអាបត្តិ បាចិត្តិយច្រើន មានវត្ថុផ្សេងគ្នា

ត្រូវភិក្ខុខ្ចីពោលថា: អហំ ភន្តេ, សម្ពហុលា នានាវត្ថុកា បាចិត្តិយាបត្តិយោ អាបជ្ជឹ ។ តា តុម្ហមូលេ បដិទេសេមិ ។

<u>*ត្រូវភិក្ខុចាស់សួរថា:*</u> បស្សសិ អាវុសោ តា អាបត្តិយោ ។
<u>*ត្រូវភិក្ខុខ្ចីឆ្លើយថា:*</u> អាម ភន្តេ បស្សាមិ ។
<u>*ត្រូវភិក្ខុចាស់ពោលថា:*</u> អាយតឹ អាវុសោ សំវរេយ្យាសិ ។
<u>*ត្រូវភិក្ខុខ្ចីពោលថា:*</u> សាធុ សុដ្ឋុ ភន្តេ សំវរិស្សាមិ ។

## វិធីសម្តែងអាបត្តិទុក្កដច្រើន មានវត្ថុផ្សេងគ្នា

<u>*ត្រូវភិក្ខុខ្ចីពោលថា:*</u> អហំ ភន្តេ, សម្ពហុលា នានាវត្ថុកា ទុក្កដាបត្តិយោ អាបជ្ជឹ ។ តា តុម្ហមូលេ បដិទេសេមិ ។

<u>*ត្រូវភិក្ខុចាស់សួរថា:*</u> បស្សសិ អាវុសោ តា អាបត្តិយោ ។
<u>*ត្រូវភិក្ខុខ្ចីឆ្លើយថា:*</u> អាម ភន្តេ បស្សាមិ ។
<u>*ត្រូវភិក្ខុចាស់ពោលថា:*</u> អាយតឹ អាវុសោ សំវរេយ្យាសិ ។
<u>*ត្រូវភិក្ខុខ្ចីពោលថា:*</u> សាធុ សុដ្ឋុ ភន្តេ សំវរិស្សាមិ ។

## ការសម្តែងអាបត្តិដោយភាសាណាមួយក៏បាន

<u>*ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:*</u>

☆ **បដិទេសេមីតិ** យាយ កាយចិ ភាសាយ វុត្តេ ទេសនា ច បដិគ្គហោ ច ហោតិយេវ, ធិដ្ឋាវិកាម្មេន វិសុទ្ធិយា វុត្តត្តាតិ កេចិ ។ *អាចារ្យពួកខ្លះពោលថា ពាក្យថា ខ្ញុំករុណាសូមសម្តែង ដូច្នេះ កាលភិក្ខុពោលដោយភាសា*

ណាមួយក៏បាន, ការសម្តែងក្តី ការទទួលក្តី រមែងមានពិត ព្រោះសេចក្តីបរិសុទ្ធិ គឺលោកពោលហើយដោយការសម្តែង ។

## ការសម្តែងអាបត្តិមិនជាច់

ក្នុងវិនយបិដក ភាគ ១៣ ទំព័រ ២៧៨ ពោលថាៈ

★ ម្នាកឧបាលិ ការប្រាប់សេចក្តីយល់ឃើញ មិនប្រកប ដោយធម៌នេះមាន ៥ យ៉ាងៈ

**១-អនាបត្តិយា ទិដ្ឋឹ អាវិករោតិ** ភិក្ខុប្រាប់សេចក្តី យល់ឃើញ ដោយអនាបត្តិ ។

**២-អទេសនាគាមិនិយា អាបត្តិយា ទិដ្ឋឹ អាវិករោតិ** ភិក្ខុប្រាប់សេចក្តីយល់ឃើញ ដោយអាបត្តិមិនមែនជាទេសនាគាមិនី

**៣-ទេសិតាយ អាបត្តិយា ទិដ្ឋឹ អាវិករោតិ** ភិក្ខុ ប្រាប់សេចក្តីយល់ឃើញ ដោយអាបត្តិដែលសម្តែងហើយ ។

**៤-ចតូហិ បញ្ចហិ ទិដ្ឋឹ អាវិករោតិ** ភិក្ខុប្រាប់ សេចក្តីយល់ឃើញ ជាមួយភិក្ខុ ៤ រូប ឬ ៥ រូប ។

**៥-មនោមានសេន ទិដ្ឋឹ អាវិករោតិ** ភិក្ខុប្រាប់សេចក្តី យល់ឃើញដោយគិតតែក្នុងចិត្ត (គឺសម្តែងអាបត្តិ ដោយមិន បញ្ចេញវចីភេទ) ។

## មាន ៥ យ៉ាងដទៃទៀត

១-នានាសំវាសកស្ស សន្តិកេ ទិដ្ឋឹ អាវិកពេតិ ភិក្ខុប្រាប់សេចក្តីយល់ឃើញ ក្នុងសំណាក់ភិក្ខុមានសំវាសផ្សេងគ្នា ។

២-នានាសីមាយ ឋិតស្ស សន្តិកេ ទិដ្ឋឹ អាវិកពេតិ ភិក្ខុប្រាប់សេចក្តីយល់ឃើញ ក្នុងសំណាក់ភិក្ខុដែលឋិតនៅក្នុងសីមាផ្សេងគ្នា ។

៣-អបកតត្តស្ស សន្តិកេ ទិដ្ឋឹ អាវិកពេតិ ភិក្ខុប្រាប់សេចក្តីយល់ឃើញ ក្នុងសំណាក់ភិក្ខុមិនមែនជាបកតត្ត ។

៤-ចតូហិ បញ្ចហិ ទិដ្ឋឹ អាវិកពេតិ ភិក្ខុប្រាប់សេចក្តីយល់ឃើញ ជាមួយនឹងភិក្ខុ ៤ រូប ឬ ៥ រូប ។

៥-មនោមានសេន ទិដ្ឋឹ អាវិកពេតិ ភិក្ខុប្រាប់សេចក្តីយល់ឃើញ ដោយគិតតែក្នុងចិត្ត ( គឺសម្តែងអាបត្តិដោយមិនបញ្ចេញវចីភេទ ) ។

<u>ក្នុងគម្ពីរអដ្ឋកថា ពន្យល់ថា:</u>

★ **ទិដ្ឋាវិកម្មាតិ** ទិដ្ឋីនំ អាវិកម្មានិ លទ្ធិប្បកាសនានិ អាបត្តិទេសនាសង្ខាតានំ វិនយកម្មានមេតំ អធិវចនំ ។

ពាក្យថា ការប្រាប់សេចក្តីយល់ឃើញ ដូច្នេះ ពាក្យនោះ

*គឺជាឈ្មោះរបស់វិនយកម្ម* ***ពោលគឺការសម្តែងអាបត្តិ*** *ប្រកាសនូវលទ្ធិ ដែលជាការប្រាប់នូវសេចក្តីយល់ឃើញ ។*

★ **អនាបត្តិយា ទិដ្ឋី អាវិកភោតីតិ** អនាបត្តិមេវ អាបត្តីតិ ទេសេតីតិ អត្ថោ ។

*ពាក្យថា* ***ភិក្ខុប្រាប់សេចក្តីយល់ឃើញ ដោយអនាបត្តិ*** *ដូច្នេះ មានសេចក្តីថា សម្តែងអនាបត្តិពិតៗ ថាជាអាបត្តិ ។*

★ **អទេសនាគាមិនិយាតិ** គរុកាបត្តិយា ទិដ្ឋី អាវិកភោតិ សង្ឃាទិសេសញ្ច បារាជិកញ្ច ទេសេតីតិ អត្ថោ ។

*ពាក្យថា* ***ដោយអាបត្តិមិនមែនជាទេសនាគាមិនី*** *ដូច្នេះ គឺបានដល់ប្រាប់សេចក្តីយល់ឃើញ ក្នុងគរុកាបត្តិ អធិប្បាយថា សម្តែងអាបត្តិសង្ឃាទិសេស និងអាបត្តិបារាជិក ។*

★ **ទេសិតាយាតិ** លហុកាបត្តិយាបិ ទេសិតាយ ទិដ្ឋី អាវិកភោតិ ទេសិតំ បុន ទេសេតីតិ អត្ថោ ។

*ពាក្យថា* ***ដោយអាបត្តិដែលសម្តែងហើយ*** *ដូច្នេះ បានដល់ប្រាប់សេចក្តីយល់ឃើញ សូម្បីក្នុងលហុកាបត្តិ ដែលសម្តែងហើយ, អធិប្បាយថា សម្តែងអាបត្តិ ដែលសម្តែងហើយដដែលទៀត ។*

## ការសម្តែងអាបត្តិ ២-៣ រូប ក្នុងទីជាមួយគ្នាបាន

*<u>ក្នុងគម្ពីរអដ្ឋកថា ពោលទៀតថា:</u>*

★ **ចតូហិ បញ្ចហិ ទិដ្ឋិន្តិ** យថា ចតូហិ បញ្ចហិ ទិដ្ឋី អាវិកតា ហោតិ ឯវំ អាវិករោតិ ចត្តារោ បញ្ច ជនា ឯកតោ អាបត្តឹ ទេសេន្តីតិ អត្ថោ ។

*ពាក្យថា ប្រាប់សេចក្តីយល់ឃើញជាមួយនឹងភិក្ខុ ៤ រូប ឬ ៥ រូប ដូច្នេះ សេចក្តីថា ភិក្ខុ ៤ ឬ ៥ រូប ប្រាប់សេចក្តីយល់ឃើញយ៉ាងណា, អធិប្បាយថា ភិក្ខុទាំងឡាយ ៤ រូប ឬ ៥ រូប ប្រាប់សេចក្តីយល់ឃើញ គឺថា សម្តែងអាបត្តិក្នុងទីជាមួយគ្នា ។*

*<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:</u>*

★ **ចតូហិ បញ្ចហីតិ** វចនតោ ទ្វីហិ វា តីហិ វា ឯកតោ ទេសេតុំ វដ្ដតិ, តតោ បរំ ន វដ្ដតិ ។ *ព្រោះព្រះបាលីថា " ៤ ឬ ៥ រូប " ដូច្នេះ មានសេចក្តីថា ភិក្ខុ ២ រូប ឬ ៣ រូបសម្តែង (អាបត្តិ) ក្នុងទីជាមួយគ្នា រមែងគួរ តែច្រើនជាងនោះ* **មិនគួរ** *។*

*<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>*

★ ឯវំ ទេសេន្តោ ច អត្តនា សទ្ធឹ តយោ វា

ចត្តារោ វា ភិក្ខូ គហេត្វា ឯកស្ស សន្តិកេ ទេសេតិ ។ ឯវំ ទេសេតុំ ន វដ្ដតិ ។ ទេសិតា ច អាបត្តិ ន វុដ្ឋាតិ ទេសនាបច្ចយា ទុក្កដញ្ច ហោតិ ។ ទ្វិន្នំ តិណ្ណំ បន ឯកតោ ទេសេតុំ វដ្ដតិ ។ ក៏កាលភិក្ខុសម្ដែងយ៉ាងនេះ ត្រូវកាន់យកនូវភិក្ខុទាំងឡាយ ៣ ឬ ៤ រូប ជា មួយនឹងខ្លួន ហើយសម្ដែងក្នុងសំណាក់របស់ភិក្ខុមួយរូប ។ ការសម្ដែងយ៉ាងនេះ **មិនគួរទេ** ។ ក៏អាបត្តិដែលសម្ដែងហើយ មិនជាការចេញចាកឡើយ, ថែមទាំងត្រូវ**អាបត្តិទុក្កដ** ព្រោះការសម្ដែងជាបច្ច័យទៀតផង ។ តែភិក្ខុ ២ ឬ ៣ រូប សម្ដែងក្នុងទីជាមួយគ្នា **រមែងគួរ** ។

ក្នុងគម្ពីរអដ្ឋកថា ពោលទៀតថា:

★ **មនោមានសេនាតិ** មនសង្ខាតេន មានសេន ទិដ្ឋឹ អាវិករោតិ វចីភេទំ អកត្វា ចិត្តេនេវ អាបត្តឹ ទេសេតីតិ អត្ថោ ។ ពាក្យថា **ដោយចិត្ត** ដូច្នេះ, មានសេចក្ដីថាប្រាប់សេចក្ដីយល់ឃើញដោយទឹកតែក្នុងចិត្ត ពោលគឺគិតទុក, អធិប្បាយថា សម្ដែងអាបត្តិដោយចិត្តប៉ុណ្ណោះ មិនបានបញ្ចេញវាចា ។

★ **នានាសំវាសកស្សាតិ** លទ្ធិនានាសំវាសកស្ស វា កម្មនានាសំវាសកស្ស វា សន្តិកេ ទិដ្ឋឹ អាវិករោតិ អាបត្តឹ

ទេសេតីតិ អត្ថោ ។ ពាក្យថា **មានសំវាសផ្សេងគ្នា** ដូច្នេះ មានសេចក្ដីថា ប្រាប់សេចក្ដីយល់ឃើញ គឺសម្ដែងអាបត្តិ ក្នុងសំណាក់ភិក្ខុអ្នកមានសំវាសផ្សេងគ្នា ដោយលទ្ធិ ឬភិក្ខុអ្នកមានសំវាសផ្សេងគ្នា ដោយកម្ម ។

## ភិក្ខុនៅក្នុងសីមាផ្សេងគ្នា សម្ដែងអាបត្តិ មិនជាប់ទេ

★**នានាសីមាយាតិ** សមានសំវាសកស្សាបិ, នានាសីមាយ ឋិតស្ស សន្តិកេ អាវិករោតិ ។ មាឡកសីមាយ ហិ ឋិតេន សីមន្តរិកាយ ឋិតស្ស សីមន្តរិកាយ វា ឋិតេន អវិប្បវាសសីមាយ ឋិតស្សាបិ អាបត្តឹ ទេសេតុំ ន វដ្ដតិ ។ ពាក្យថា **ក្នុងសីមាផ្សេងគ្នា** ដូច្នេះ មានសេចក្ដីថា ភិក្ខុសម្ដែងអាបត្តិក្នុងសំណាក់ភិក្ខុ សូម្បីជាអ្នកមានសំវាសស្មើគ្នា, តែឋិតនៅក្នុងសីមាផ្សេងគ្នា ។ ពិតមែន កាលដែលភិក្ខុឋិតនៅក្នុង**មាលកសីមា** សម្ដែងអាបត្តិក្នុងសំណាក់ភិក្ខុឋិតនៅក្នុង**សីមន្តរិកក្ដី** កាលដែលភិក្ខុឋិតនៅក្នុងសីមន្តរិក សម្ដែងអាបត្តិក្នុងសំណាក់ភិក្ខុសូម្បីឋិតនៅ ក្នុង**អវិប្បវាសសីមាក្ដី** មិនគួរ ។

<u>ក្នុងគម្ពីរបាចិត្យាទិយោជនា ពោលថា:</u>

★ **មាឡកសីមាយាតិ** ខណ្ឌសីមាយ អន្តោ ។

**អវិប្បវាសសីមាយាតិ** មហាសីមាយ ឋិតស្សាបិ សន្តិកេតិ ។ បិសទ្ទេន "ខណ្ឌសីមាយ ឋិតស្សបី"តិ អត្ថំ សម្បិណ្ឌេតិ ។

ពាក្យថា **មាលកសីមា** ដូច្នេះ គឺបានដល់ ក្នុងលាននៃខណ្ឌសីមា ។ ពាក្យថា **អវិប្បវាសសីមា** ដូច្នេះ គឺបានដល់ (ការសម្តែងអាបត្តិ) ក្នុងសំណាក់ភិក្ខុសូម្បីឋិតនៅក្នុងមហាសីមា ។ ដោយ បិ សព្ទ ក្នុងពាក្យថា (**ឋិតស្សាបិ**)លោករមែងប្រមូលនូវសេចក្តីថា "សូម្បីភិក្ខុនៅក្នុងខណ្ឌសីមា" ។

<u>ក្នុងវិនយបិដក ភាគ ១៣ ទំព័រ ១៣៣ ពោលថា:</u>

★ សង្ឃាទិសេស២៣, អនិយត២, និស្សគ្គិយ៤២ បាចិត្តិយ១៨៨, បាដិទេសនីយ១២, សេក្ខិយ៧៥, (ទាំងសិក្ខាបទភិក្ខុ និងភិក្ខុនី) ត្រូវរម្ងាប់ដោយសមថៈ ៣ យ៉ាង គឺ សម្មុខាវិន័យ ១, បដិញ្ញាតករណៈ ១, តិណវត្ថារកៈ ១ ។

<u>ក្នុងវិនយបិដកភាគ ១០ ទំព័រ ៥៩... ពោលថា:</u>

★ អាបត្តាធិករណ៍ បានដល់អាបត្តិទាំង ៥ កង ក៏មានអាបត្តិទាំង ៧ កង ក៏មាន ។ អាបត្តាធិករណ៍ រម្ងាប់ដោយសមថៈ ៣ យ៉ាងគឺ សម្មុខាវិន័យ ១, បដិញ្ញាតករណៈ ១ តិណវត្ថារកៈ ១ ក៏មាន ។ រម្ងាប់ដោយសមថៈ ២ យ៉ាង គឺ សម្មុខាវិន័យ ១, បដិញ្ញាតករណៈ ១, ក៏មាន ។ រម្ងាប់ដោយ

សមថៈ ២ យ៉ាងគឺ សម្មុខាវិន័យ ១, តិណវត្ថារកៈ ១ ក៏មាន ។

<u>ក្នុងគម្ពីរអដ្ឋកថាបរិវារៈ ពោលថាៈ</u>

★ "អាបត្តិទាំងអស់បើវៀរចាក **សម្មុខាវិន័យ** (គឺនៅក្នុងទីចំពោះមុខ) ចេញហើយ មិនអាចរម្ងាប់ គឺថា សម្តែងមិនដាច់ឡើយ" ។ (ដូច្នេះ ការសម្តែងអាបត្តិ មិនមែន មានតែអង្គ ៣ នោះទេ, ព្រោះសូម្បីភិក្ខុសម្តែងអាបត្តិ ជាមួយគ្នានៅក្នុងសីមាជាមួយគ្នាក៏ដោយ បើមិនសម្តែងនៅក្នុងចំពោះមុខគ្នាទេ ក៏សម្តែងអាបត្តិ មិនដាច់ដែរ) ។

<u>ក្នុងគម្ពីរអដ្ឋកថា ពោលទៀតថាៈ</u>

★ **អបកតត្តស្សាតិ** ឧក្ខិត្តកស្ស វា យស្ស វា ឧបោសថបវារណា ឋបិតា ហោន្តិ តស្ស សន្តិកេ ទេសេ-តីតិ អត្ថោ ។ បទថា **មិនមែនជាបកតត្ត** ដូច្នេះមានសេចក្តីថា សម្តែងក្នុងសំណាក់ភិក្ខុដែលសង្ឃលើកវត្ត ឬភិក្ខុត្រូវសង្ឃឃាត់ឧបោសថ និងបវារណា ។

**ភិក្ខុសម្តែងអាបត្តិប្រកបដោយឧស្សាហ៍ឱ្យត្រូវទៀត មិនដាច់ទេ**

<u>ក្នុងព្រះអដ្ឋកថាបរិវារៈ ពោលថាៈ</u>

★ អាបត្តិណា ដែលភិក្ខុធ្វើនូវការដាក់ធុរៈ សម្តែងចេញ

*ដោយតាំងចិត្តថា "យើងនឹងមិនត្រូវនូវអាបត្តិនោះទៀតទេ" អាបត្តិនោះ ឈ្មោះថា* ***អាបត្តិដែលខ្លួនសម្តែងហើយ*** *ជាអាបត្តិគួរដល់កិរិយារាប់បាន (គឺសម្តែងដាច់) ។ អាបត្តិណាដែលភិក្ខុមិនបានធ្វើនូវការដាក់ធុរៈ គឺសម្តែងដោយចិត្ត ដែលនៅមានការ* ***ប្រកបដោយឧស្សាហ៍*** *មិនបរិសុទ្ធតែម្តង, អាបត្តិនោះ ឈ្មោះថា* ***អាបត្តិដែលខ្លួនសម្តែងហើយ*** *តែមិនគួរដល់កិរិយារាប់ទេ (គឺសម្តែងមិនដាច់ទេ) ។ ពិតមែន អាបត្តិនោះ សូម្បីសម្តែងហើយក៏មិនឈ្មោះថា* ***ជាការសម្តែងដែរ*** *។*

***ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថាៈ***

★ សឧស្សាហោនេវាតិ បុនបិ តំ អាបត្តឹ អាបជ្ជិតុកាមតាចិត្តេន, ឯវំ ទេសិតាបិ អាបត្តិ ន វុដ្ឋាតីតិ អធិប្បាយោ ។ ធុរនិក្ខេបំ អកត្វា អាបជ្ជនេ សិក្ខាបច្ចក្ខានស្សាបិ ធុរនិក្ខេបំ អកត្វា "អជ្ជមេ វត្ថុស្មិំ ភិក្ខុនិយា បារាជិកមេវា"តិ ។ ន កេវលញ្ច ភិក្ខុនិយាឯវ ភិក្ខុនម្បិ ធុរនិក្ខេបំ អកត្វា ថោកំ ថោកំ សប្បិអាទិកំ ថេយ្យាយ គណ្ហន្តានំ បាទគ្ឃនកេ បុណ្ណេ បារាជិកមេវ ។

*ពាក្យថា* ***ប្រកបដោយឧស្សាហ៍*** *ដូច្នេះនេះ មានសេចក្តីអធិប្បាយថា (គឺភិក្ខុសម្តែងនូវអាបត្តិ) ដោយចិត្តប្រាថ្នាដើម្បី*

ឱ្យត្រូវនូវអាបត្តិនោះ សូម្បីម្តងទៀត, សូម្បីកាលសម្តែង យ៉ាងនេះ អាបត្តិមិនឈ្មោះថា ជាការចេញចាកទេ ។ ព្រះ-អដ្ឋកថាចារ្យ កាលសម្តែងនូវទោស ដែលដល់នូវទីបំផុតក្នុង កាលដែលភិក្ខុនី មិនធ្វើនូវការដាក់ធុរៈហើយត្រូវអាបត្តិ, ទើប ពោលថា "ជាបារាជិកពិតដល់ភិក្ខុនីក្នុងវត្ថុទី ៨" ដូច្នេះ ។ មិនមែនតែភិក្ខុនីតែម្យ៉ាងប៉ុណ្ណោះទេ, សូម្បីភិក្ខុកាលមិនធ្វើនូវ ការដាក់ធុរៈហើយ លួចនូវសម្បិបន្តិចម្តងៗ ដោយថេយ្យចិត្ត កាលគ្រប់តម្លៃ ១ បាទ ជាបារាជិក ដូចគ្នា ។

<u>ក្នុងគម្ពីរសារត្ថទីបនី និងវជិរពុទ្ធិដីកា ពោលថា:</u>

★"បុនបិ អាបជ្ជិស្សាមី"តិ សឧស្សាហេនេវ ចិត្តេន ។

ភិក្ខុសម្តែងអាបត្តិ ដោយចិត្តដែលប្រកបដោយឧស្សាហ៍ ថា "អាត្មាអញនឹងត្រូវនូវអាបត្តិនេះ សូម្បីម្តងទៀង" ដូច្នេះ (ការសម្តែងអាបត្តិ មិនដាច់ឡើយ) ។

## ដីកាវិមតិច្ឆេទនីអចិត្តកសិក្ខាបទក្នុងខន្ធកៈ

<u>ក្នុងវិនយបិដក ភាគ ៦ ទំព័រ ៤០៣ ពោលថា:</u>

★ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ភិក្ខុតែមួយរូប នៅក្នុងអាវាសមួយក្នុងថ្ងៃឧបោសថ ។ ត្រូវភិក្ខុនោះ ក្រាលនូវ

អាសនៈជាដើម ហើយត្រូវអង្គុយផងចាំ ។ បើមានភិក្ខុដទៃមក ត្រូវភិក្ខុនោះធ្វើឧបោសថ ជាមួយនឹងភិក្ខុទាំងឡាយនោះចុះ បើមិនមានភិក្ខុដទៃមកទេ ត្រូវភិក្ខុនោះ អធិដ្ឋានឧបោសថថា "អជ្ជ មេ ឧបោសថោ : ថ្ងៃនេះជាថ្ងៃឧបោសថរបស់អញ" នោ ចេ អធិដ្ឋហេយ្យ អាបត្តិ ទុក្កដស្ស" បើមិនអធិដ្ឋានទេ ត្រូវអាបត្តិទុក្កដ ។

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

★ **បាឡិយំ នោ ចេ អធិដ្ឋហេយ្យ, អាបត្តិ ទុក្កដស្សាតិ** ឯត្ថ អសញ្ចិច្ច អសតិយា អនាបត្តិ ។ យថា ចេត្ថ, ឯវំ ឧបរិបិ ។ យត្ថ បន អចិត្តកាបត្តិ អត្ថិ, តត្ថ វក្ខាម ។ ក្នុងបាលីបិដក ព្រះអង្គត្រាស់ថា ***បើមិនអធិដ្ឋានទេ ត្រូវអាបត្តិទុក្កដ*** ដូច្នេះ មានសេចក្តីថា ជាអនាបត្តិដល់ភិក្ខុ ដែលមិនក្លែង និងគ្មានសតិ ។ ក៏ក្នុងសេចក្តីនេះយ៉ាងណា សូម្បីន័យខាងលើក៏យ៉ាងនោះដែរ ។ ចំណែកឯអចិត្តកាបត្តិ (អាបត្តិដែលជាអចិត្តកៈ) មានក្នុងទីណា យើងនឹងប្រាប់ក្នុងទីនោះ ។

## ការសម្តែងអាបត្តិជាសភាគៈគ្នា ជាអចិត្តកៈសិក្ខាបទ

*ក្នុងវិនយបិដក ភាគ ៦ ទំព័រ ៤០៥ ពោលថាៈ*

★ ន ភិក្ខវេ សភាគា អាបត្តិ ទេសេតព្វា យោ ទេសេយ្យ អាបត្តិ ទុក្កដស្ស ។ *ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសម្តែងអាបត្តិសភាគៈគ្នាទេ ភិក្ខុណាសម្តែង ត្រូវអាបត្តិទុក្កដ ។*

★ ន ភិក្ខវេ សភាគា អាបត្តិ បដិគ្គហេតព្វា យោ បដិគ្គណ្ហេយ្យ អាបត្តិ ទុក្កដស្ស ។ *ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទទួលអាបត្តិជាសភាគៈគ្នាទេ ភិក្ខុណាទទួលត្រូវអាបត្តិទុក្កដ ។*

*ក្នុងគម្ពីរអដ្ឋកថា ពោលថាៈ*

★ យាបិ ចាយំ វត្ថុសភាគា, សាបិ ទេសិតា សុទេសិតាវ ។ អញ្ញំ បន ទេសនប្បច្ចយា ទេសកោ បដិគ្គហណប្បច្ចយា បដិគ្គហកោ ចាតិ ឧភោបិ ទុក្កដំ អាបជ្ជតិ, តំ នានាវត្ថុកំ ហោតិ, តស្មា អញ្ញមញ្ញំ ទេសេតុំ វដ្ដតិ ។ *ក៏អាបត្តិណា ជាវត្ថុសភាគៈគ្នា, អាបត្តិសូម្បីមានវត្ថុសភាគៈគ្នានោះ ការដែលលោកសម្តែងហើយ ជាការសម្តែង*

ហើយដោយល្អពិត ។ តែរមែងត្រូវអាបត្តិទុក្កដដទៃ សូម្បីទាំង ២ រូប គឺអ្នកសម្តែង រមែងត្រូវអាបត្តិ ព្រោះការសម្តែងជាបច្ច័យ, អ្នកទទួលរមែងត្រូវអាបត្តិ ព្រោះការទទួលជាបច្ច័យ ។ អាបត្តិនោះ រមែងមានវត្ថុផ្សេងៗគ្នា, ព្រោះហេតុនោះ ការសម្តែងនូវអាបត្តិនោះ ជាមួយគ្នានិងគ្នា រមែងគួរ ។

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

★ **ឧភោបិ ទុក្កដន្តិ** ឯត្ថ សភាគាបត្តិភាវំ អជានិត្វា កេវលំ អាបត្តិនាមេនេវ ទេសេន្តស្ស បដិគ្គណ្ហន្តស្ស អចិត្តកមេវ ទុក្កដំ ហោតីតិ វទន្តិ ។ ក្នុងពាក្យថា ជាទុក្កដសូម្បីទាំង ២ រូប ដូច្នេះ អាចារ្យទាំងឡាយ ពោលថា កាលភិក្ខុមិនដឹងនូវសភាគាបត្តិ ហើយសម្តែង និងទទួលដោយឈ្មោះអាបត្តិតែម្យ៉ាងប៉ុណ្ណោះ, រមែងត្រូវអាបត្តិទុក្កដ ដែលជាអចិត្តកៈពិត ។

★ យថា សង្ឃោ សភាគាបត្តឹ អាបន្នោ ញត្តឹ ឋបេត្វា ឧទ្ទោសជំ កាតុំ លភតិ, ឯវំ តយោបិ "សុណន្តុ មេ, អាយស្មន្តា, ឥមេ ភិក្ខូ សភាគំ អាបត្តឹ អាបន្នា"តិអាទិនា វុត្តនយានុសារេនេវ គណញត្តឹ, ឋបេត្វា

ទ្វីហិ អញ្ញមញ្ញំ អារោចេត្វា ឧបោសថំ កាតុំ វដ្ដតិ ។ ឯកេន បន សាបត្តិកេន ទ្វេ គន្ត្វាបិ បដិកាតុមេវ វដ្ដតិ, អសម្បាបុណន្តេន "ភិក្ខុំ លភិត្វា បដិការិស្សាមី"តិ ឧបោសថោ កាតព្វោ, បដិការិត្វា ច បុន ឧបោសថោ កាតព្វោ ។ *សង្ឃត្រូវសភាគាបត្តិ រមែងបានដើម្បីតាំងញត្តិ ហើយធ្វើនូវឧបោសថបានយ៉ាងណា, សូម្បីភិក្ខុ ៣ រូប តាំងញត្តិ តាមលំអាននៃន័យ ដែលលោកពោលទុកដោយពាក្យថា "សូមលោកដ៏មានអាយុទាំងឡាយស្ដាប់ខ្ញុំ ភិក្ខុទាំងនេះត្រូវហើយនូវសភាគាបត្តិ, ក្នុងកាលណា នឹងឃើញនូវភិក្ខុដទៃ មិនមានអាបត្តិ, ក្នុងកាលនោះ យើងនឹងសម្ដែងអាបត្តិនោះចេញ" ដូច្នេះ, សូម្បីភិក្ខុ ២ រូបប្រាប់ដល់គ្នានិងគ្នា ហើយធ្វើនូវឧបោសថ* **រមែងគួរ** *។ តែចំពោះភិក្ខុតែមួយអង្គឯង អ្នកមានអាបត្តិសូម្បីទៅឆ្ងាយ ធ្វើការសម្ដែងអាបត្តិចេញសិន ទើបគួរ ។ ការទៅមិនទាន់ដល់គិតថា "អញបាននូវភិក្ខុ ហើយនឹងសម្ដែងនូវអាបត្តិចេញ" ហើយគប្បីធ្វើនូវឧបោសថ ក៏ភិក្ខុកាលសម្ដែងហើយ, ត្រូវធ្វើឧបោសថម្ដងទៀត ។*

*<u>ក្នុងវិនយបិដក ភាគ ៦ ទំព័រ ៤០៧ ពោលថា:</u>*

★ *ម្នាលភិក្ខុទាំងឡាយ បើសង្ឃទាំងអស់ត្រូវអាបត្តិ*

ដែលជាសភាគៈគ្នា ត្រូវភិក្ខុដែលឆ្លាសប្រតិពល ឱ្យសង្ឃជ្រាបថា: "សុណាតុ មេ ភន្តេ សង្ឃោ អយំ សព្វោ សង្ឃោ សភាគំ អាបត្តឹ អាបន្នោ, យទា អញ្ញំ ភិក្ខុំ សុទ្ធំ អនាបត្តិកំ បស្សិស្សតិ តទា តស្ស សន្តិកេ តំ អាបត្តឹ បដិករិស្សតីតិ" ។ "បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ សង្ឃទាំងអស់នេះត្រូវនូវអាបត្តិសភាគៈគ្នា, ក្នុងកាលណា នឹងឃើញនូវភិក្ខុដ៏ទៃ បរិសុទ្ធមិនត្រូវអាបត្តិ សង្ឃនឹងសម្តែងអាបត្តិនោះ ក្នុងសំណាក់ភិក្ខុនោះ ក្នុងកាលនោះ" លុះពោលយ៉ាងនេះហើយ ត្រូវសង្ឃធ្វើឧបោសថត្រូវសម្តែងបាតិមោក្ខ មិនត្រូវសង្ឃធ្វើអន្តរាយដល់ឧបោសថ ព្រោះហេតុប៉ុណ្ណោះទេ ។

<u>ក្នុងគម្ពីរកង្ខាវិតរណីបុរាណដីកា ពោលថា:</u>

★ "សភាគវត្ថុនា លហុកាបត្តិ"ន្តិ វុត្តត្តា សភាគសង្ឃាទិសេសំ អារោចេតុំ វដ្ដតីតិ ចេ ? ន វដ្ដតិ ទេសនាគាមិនី សន្ធាយ ឥធ វុត្តត្តា ។ បើមានពាក្យសួរថា ការភិក្ខុប្រាប់ (គឺបើក) នូវអាបត្តិសង្ឃាទិសេសដែលជាសភាគៈគ្នា គួរដែរឬទេ, ព្រោះអដ្ឋកថាចារ្យពោលថា "លហុកាបត្តិដែលជាវត្ថុសភាគៈ" ដូច្នេះ ឆ្លើយថា មិនគួរទេ

*ព្រោះលោកពោលទុកក្នុងទីនេះ ព្រោះសំដៅនូវអាបត្តិដែលជាទេសនាគាមនី ។*

តស្មា ឯវ សមុច្ចយក្ខន្ធកេ "សភាគសង្ឃាទិសេសំ អាបន្នស្ស បន សន្តិកេ អាវិកាតុំ ន វដ្តតិ ។ សចេ អាវិករោតិ, អាបត្តិ អាវិកតា ហោតិ, ទុក្កដា បន ន មុច្ចតី"តិ វុត្តំ ។ *ព្រោះហេតុនោះឯង ទើបលោកពោលទុកក្នុងអដ្ឋកថា សមុច្ចយក្ខន្ធកៈថា "ការបើកនូវអាបត្តិសង្ឃាទិសេស នៅក្នុងសំណាក់ភិក្ខុដែលត្រូវអាបត្តិសង្ឃាទិសេស ដែលជាសភាគៈគ្នា រមែងមិនគួរ ។ បើសិនជាបើកអាបត្តិឈ្មោះថាជាការបើក, តែថាភិក្ខុរមែងមិនរួចចាកអាបត្តិទុក្កដឡើយ" ។*

★ ឯកេនាបិ " បរិសុទ្ធំ លភិត្វា បដិករិស្សាមី"តិ អាភោគំ កត្វា ឧបោសថំ កាតុំ វដ្តតីតិ ។

*សូម្បីភិក្ខុមានតែ ១ រូបធ្វើនូវអាភោគចិត្តថា "អញបាននូវភិក្ខុបរិសុទ្ធហើយ នឹងធ្វើតប" ដូច្នេះ ហើយធ្វើនូវឧបោសថរមែងគួរ ។*

"យទា អញ្ញំ សុទ្ធំ ភិក្ខុំ អនាបត្តិកំ បស្សិស្សតិ, តទា តស្ស សន្តិកេ"តិ វុត្តត្តា លហុកស្សេវ អនុញ្ញាតត្តា សមុច្ចយក្ខន្ធកេ វុត្តត្តា សភាគសង្ឃាទិសេសំ បន

ញត្តិយា អារោចេត្វា ឧបោសថំ កាតុំ ន វដ្តតិ ។ *ព្រោះពាក្យដែលព្រះអដ្ឋកថាចារ្យពោលថា "យើងឃើញនូវភិក្ខុដទៃដែលបរិសុទ្ធ មិនមានអាបត្តិក្នុងកាលណា ក្នុងកាលនោះ (យើងនឹងធ្វើតប) ក្នុងសំណាក់របស់ភិក្ខុនោះ" ដូច្នេះ មានសេចក្តីថា កាលដែលភិក្ខុប្រាប់នូវអាបត្តិសង្ឃាទិសេស ដែលជាសភាគៈគ្នាដោយញត្តិហើយ ធ្វើនូវឧបោសថ មិនគួរ ព្រោះលោកពោលហាមទុក ក្នុងសមុច្ចយក្ខន្ធកៈផង និងព្រោះលហុកាបត្តិប៉ុណ្ណោះ ដែលព្រះអង្គអនុញ្ញាតហើយ ។*

ឥទំ បុព្វកិច្ចំ អកត្វា ឧបោសថកម្មំ ករោន្តោ សង្ឃោ បុគ្គលោ វា ថបនក្ខេត្តាតិក្កមេ អាបជ្ជតិ ។ តស្មិំ ហិ ខេត្តេ អតិក្កន្តេ សម្មជ្ជនាទិករណោ អាបត្តិមោក្ខោ ន ហោតិ ឧបោសថកម្មតោ បុព្វេ កត្តព្វកម្មាករណាបច្ចយត្តា តស្សា អាបត្តិយា ។ *សង្ឃក្តី បុគ្គលក្តី កាលមិនធ្វើនូវបុព្វកិច្ចនេះហើយ ធ្វើនូវឧបោសកម្ម រមែងដល់នូវការឈានកន្លងខេត្ត ដែលលោកតាំងទុក ។ ពិតមែន កាលភិក្ខុប្រព្រឹត្តកន្លងនូវខេត្តនោះ ការរួចផុតចាកអាបត្តិក្នុងកិរិយាធ្វើនូវការបោសសំអាតជាដើម* ***រមែងមិនមាន***, *ព្រោះភាវនៃអាបត្តិនោះមានការមិនធ្វើនូវកម្ម ដែលខ្លួនគប្បីធ្វើមុនអំពីឧបោសថកម្ម*

ជាបច្ច័យ ។

<u>*ក្នុងគម្ពីរកង្ខាវិតរណីអភិនវដីកា ពោលថា:*</u>

★ យទិ បន សព្វោ សង្ឃោ សភាគំ សង្ឃាទិ-សេសំ អាបន្នោ ហោតិ, ញត្តឹ ឋបេត្វា ឧបោសថំ កាតុំ ន វដ្ដតិ, ឧបោសថស្ស អន្តរាយោវ ហោតិ ។ *ក៏ប្រសិនបើសង្ឃទាំងអស់ ត្រូវនូវអាបត្តិសង្ឃាទិសេស ដែលជាសភាគៈ-គ្នា តាំងញត្តិហើយធ្វើនូវឧបោសថមិនគួរទេ, រមែងជាអន្តរាយដល់ឧបោសថពិត ។*

**ការបើកអាបត្តិជាលហុកាបត្តិ ដែលជាសភាគៈគ្នា**

<u>*ក្នុងគម្ពីរវជិរពុទ្ធិដីកា ក្នុងសមុច្ចយក្ខន្ធកៈ ពោលថា:*</u>

★ "សភាគសង្ឃាទិសេសំ អាបន្នស្ស បន សន្តិកេ អាវិ កាតុំ ន វដ្ដតី"តិ បសង្គតោ ឥធេវ បកាសិតំ ។ លហុកេសុ បដិក្ខេបោ នត្ថិ ។ តត្ថ ញត្តិយា អាវិ កត្វា ឧបោសថំ កាតុំ អនុញ្ញាតត្តា លហុកសភាគំ អាវិ កាតុំ វដ្ដតីតិ ។ សភាគសង្ឃាទិសេសំ បន ញត្តិយា អារោចនំ ន វដ្ដតីតិ កិរ ។ "តស្ស សន្តិកេ តំ អាបត្តឹ បដិករិស្សតី"តិ វុត្តត្តា លហុកស្សេវាយមនុញ្ញាតា ន ហិ

សក្កា សុទ្ធស្ស ឯកស្ស សន្តិកេ សង្ឃាទិសេសស្ស បដិករណំ កាតុ"ន្តិ លិខិតំ ។

*ព្រះអដ្ឋកថាប្រកាសហើយ ក្នុងទីនេះប៉ុណ្ណោះ ដោយសេចក្តីមាំទាំថា "ភិក្ខុបើកអាបត្តិក្នុងសំណាក់ភិក្ខុ ដែលត្រូវអាបត្តិសង្ឃាទិសេស ដែលជាសភាគៈគ្នា* ***រមែងមិនគួរ*** *" ដូច្នេះមានសេចក្តីថា* ***លោកមិនបានបដិសេធ*** *ក្នុងលហុកាបត្តិទេ ។ បណ្តាអាបត្តិទាំង ២ នោះ លោកសរសេរទុកថា "បានឮថាការបើកនូវលហុកាបត្តិដែលជាសភាគៈគ្នា* ***រមែងគួរ*** *, ព្រោះព្រះ-អង្គអនុញ្ញាតឱ្យបើកដោយញត្តិហើយ ធ្វើឧបោសថបាន ។ តែការប្រាប់ (គឺបើក) នូវសង្ឃាទិសេស សភាគៈគ្នា ដោយញត្តិមិនគួរ, ព្រោះការបើកនេះ ព្រះអង្គអនុញ្ញាតចំពោះលហុកាបត្តិប៉ុណ្ណោះ, ព្រោះលោកពោលថា ត្រូវសម្តែងអាបត្តិនោះ ក្នុងសំណាក់ភិក្ខុនោះ ។ ព្រោះថា ភិក្ខុមិនអាចសម្តែងអាបត្តិសង្ឃាទិសេស ក្នុងសំណាក់ភិក្ខុ១ រូបដែលបរិសុទ្ធិបានទេ ។*

✯ លហុកេសុបិ សភាគំ អាវិ កាតុំ ន វដ្តតីតិ, តស្មា ឯវ ហិ ញត្តិយា អាវិករណំ អនុញ្ញាតំ, ឥតរថា តំ និរត្ថកំ សិយា ។ អញ្ញមញ្ញារោចនស្ស វដ្តតិ, តតោ ន វដ្តតីតិ ធីបនត្ថមេវ ញត្តិយាអាវិករណមនុញ្ញាតំ

តេនេវ ឥធ " សភាគសង្ឃាទិសេសំ អាបន្នស្សា"តិអាទិ វុត្តំ ។ *(អាចារ្យមួយទៀតពោលថា) ការបើកនូវអាបត្តិដែលជាសភាគៈគ្នា សូម្បីក្នុងលហុកាបត្តិ* **មិនគួរ**, *ព្រោះហេតុនោះការបើកដោយញត្តិប៉ុណ្ណោះ គឺព្រះអង្គអនុញ្ញាតហើយ ។ បើកាន់យកក្រៅពីនេះ មានតែពាក្យនោះមិនមានប្រយោជន៍ ។ ការអនុញ្ញាតធ្វើនូវការបើកនូវអាបត្តិដោយញត្តិ ដើម្បីបំភ្លឺសេចក្តីនេះថា "ការប្រាប់ (គឺបើក) នូវអាបត្តិដល់គ្នានិងគ្នា* **រមែងគួរ**, *តពីនោះទៅ* **មិនគួរ** *"ព្រោះហេតុនោះឯង បានជាព្រះអដ្ឋកថាចារ្យ ពោលទុកក្នុងសមុច្ចយក្ខន្ធកនេះ ដោយពាក្យជាដើមថា "ភិក្ខុត្រូវនូវអាបត្តិ សង្ឃាទិសេសដែលជាសភាគៈ-គ្នា" ដូច្នេះ ។*

អយមត្ថោ " ឯត្តាវតា តេ ទ្វេ និរាបត្តិកា ហោន្តិ, តេសំ សន្តិកេ សេសេហិ សភាគាបត្តិយោ ទេសេតព្វា"តិ វចនេន កង្ខាវិតរណិយំ បកាសិតោវ ។ សង្ឃាទិសេសំ បន ញត្តិយា អារោចេត្វា ឧបោសថំ កាតុំ វដ្តតិ ។ តស្សា ញត្តិយា អយមត្ថោ យទា សុទ្ធំ ភិក្ខុំ បស្សិស្សតិ, តស្ស សន្តិកេ អារោចនវសេន បដិករិស្សតិ ។ ឯវំ បដិកតេ "ន ច ភិក្ខវេ, សាបត្តិកេន បាតិមោក្ខំ

សោតព្វំ, យោ សុណេយ្យ, អាបត្តិ ទុក្កដស្សា"តិ វុត្តាបត្តិតោ មោក្ខោ ហោតីតិ, តស្មា "គរុកំវា ហោតុ លហុកំ វា, ញត្តិយា អាវិ កាតុំ វដ្ដតី"តិ វុត្តំ, ឧភោសុ ឆយេសុ យុត្តតរំ គហេតព្វំ ។ *សេចក្តីនេះ លោកពោល ហើយពិតក្នុងកង្ខាវិតរណី ដោយពាក្យថា "ដោយហេតុមាន ប្រមាណប៉ុណ្ណេះ ភិក្ខុទាំងឡាយ ២ រូប ជាអ្នកមិនមានអាបត្តិ ភិក្ខុទាំងឡាយដ៏សេស ត្រូវសម្តែងសភាគាបត្តិ ក្នុងសំណាក់ នៃភិក្ខុទាំងនោះ" ។* ***ក៏ការប្រាប់ (គឺបើក) នូវសង្ឃាទិសេស ដោយញត្តិ ហើយធ្វើឧបោសថ រមែងគួរ*** *។ សេចក្តីអធិប្បាយ នៃញត្តិនោះដូច្នេះ ភិក្ខុឃើញភិក្ខុដែលបរិសុទ្ធ ក្នុងកាលណា ក្នុងកាលនោះ* ***ត្រូវសម្តែងដោយអំណាចការប្រាប់*** *ក្នុងសំណាក់ ភិក្ខុនោះ កាលសម្តែងយ៉ាងនេះ រមែងរួចផុតចាកអាបត្តិ តាម ដែលលោកពោលហើយថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុមាន អាបត្តិ មិនត្រូវស្តាប់បាតិមោក្ខទេ ភិក្ខុណាស្តាប់ត្រូវ***អាបត្តិទុក្កដ***" ដូច្នេះ ។ ព្រោះហេតុនោះ លហុកាបត្តិក្តី គរុកាបត្តិក្តី ចូរ លើកទុកចុះ លោកពោលថាការបើកអាបត្តិដោយញត្តិ* ***រមែង គួរ*** *។ បណ្តាន័យទាំង ២ នេះ គប្បីកាន់យកន័យណាដែល ត្រឹមត្រូវជាងចុះ ។*

*ក្នុងគម្ពីរខុទ្ទកសិក្ខាបុរាណដីកា ពោលថា:*

★ អហំ អាវុសោ ឥត្ថន្នាមំ អាបត្តឹ អាបជ្ជឹ តំ ឥតោ វុដ្ឋហិត្វា បដិករិស្សាមីតិ អញ្ញស្ស វចនំ អាវិកម្មំ ណាម ។ *ពាក្យដែលពោលចំពោះអ្នកដទៃថា "ម្នាលអាវុសោ ខ្ញុំត្រូវនូវអាបត្តិឈ្មោះនេះ ខ្ញុំចេញអំពីទីនេះទៅ នឹងធ្វើតបនូវអាបត្តិនោះ" ដូច្នេះ ឈ្មោះថា* ***ជាការបើកអាបត្តិ*** *។*

**មិនមែនរួចផុតចាកអាបត្តិ ដោយការសឹកទេ**

*ក្នុងវិនយបិដក ភាគ ៦ ទំព័រ ៣២១ ពោលថា:*

★ *ម្នាលភិក្ខុទាំងឡាយ បើមានភិក្ខុនៅក្នុងសាសនានេះ ត្រូវសង្ឃលើកវត្ត ព្រោះមិនធ្វើតបអាបត្តិ* ***ហើយសឹកទៅ*** *។ បើអ្នកនោះ ត្រឡប់មកសូមឧបសម្បទាម្តងទៀត ត្រូវភិក្ខុទាំងឡាយ និយាយនឹងអ្នកនោះថា អ្នកនឹងធ្វើតបនូវអាបត្តិនោះឬទេ, បើគេធ្វើតបចូរបំបួសចុះ* ***តែបើគេមិនធ្វើតបទេ*** *មិនត្រូវបំបួសគេទេ ។*

*ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:*

★ កិញ្ចា ភិយ្យោ បដិបត្តិក្កមតោវ អាបត្តិតោ សុទ្ធិ ហោតិ, **ន វិព្ភមេន**, តស្មា ឧបសម្បន្នោ ភិក្ខុ អន្តមសោ

ទុព្ភាសិតម្បិ អាបជ្ជិត្វា អបរភាគេ វិព្ភមិត្វា អាគតោ ឧបសម្បជ្ជតិ, តំ អាបត្តឹ ទេសេត្វាវ សុជ្ឈតិ, ន អញ្ញថាតិ ឧបសម្បន្នស្ស សុទ្ធិក្កមទស្សនត្ថំ ។

*សេចក្តីបរិសុទ្ធិចាកអាបត្តិ រមែងមានដោយដំណើរនៃការបដិបត្តិប៉ុណ្ណោះ ជាយ៉ាងក្រៃលែង,* ***មិនមែនបរិសុទ្ធិដោយការសឹកទេ,*** *ព្រោះហេតុនោះ ភិក្ខុដែលជាឧបសម្បន្ន ត្រូវនូវអាបត្តិ ដោយហោចទៅសូម្បីអាបត្តិទុព្ភាសិត សឹកហើយត្រលប់មកឧបសម្បទាវិញ ក្នុងកាលជាខាងក្រោយ, ត្រូវសម្តែងអាបត្តិនោះចេញហើយសិន ទើបបរិសុទ្ធបាន, មិនមែនបរិសុទ្ធដោយប្រការដទៃឡើយ, (ពាក្យនេះ គឺលោកពោលហើយ) ដើម្បីសម្តែងនូវដំណើរ នៃសេចក្តីបរិសុទ្ធរបស់ឧបសម្បន្ន ។*

**អាបត្តិទេសនាកថាចប់ ។**

# ១៤_វស្សច្ឆេទកថា

*ក្នុងវិនយបិដកភាគ ៧ ទំព័រ ៣ ត្រាស់ថា:*

★ ន ភិក្ខវេ វស្សំ ឧបគន្ត្វា បុរិមំ វា តេមាសំ បច្ឆិមំ វា តេមាសំ អវសិត្វា ចារិកា បក្កមិតព្វា **យោ បក្កមេយ្យ** អាបត្តិ ទុក្កដស្ស ។ *ម្នាលភិក្ខុទាំងឡាយ ភិក្ខុចូលវស្សាហើយ មិននៅចាំបុរិមិកាវស្សាអស់ ៣ ខែ ឬ បច្ឆិមិកាវស្សាអស់ ៣ ខែទេ, មិនត្រូវជៀសចេញទៅកាន់ចារិកឡើយ ភិក្ខុណាជៀសចេញទៅ ត្រូវអាបត្តិទុក្កដ ។*

*ក្នុងព្រះអដ្ឋកថា ពោលថា:*

★ **យោ បក្កមេយ្យាតិ** ឯត្ថ អនបេក្ខគមនេន វា អញ្ញត្ថ អរុណំ ឧដ្ឋាបនេន វា អាបត្តិ វេទិតព្វា ។ *ក្នុងពាក្យថា ភិក្ខុណាជៀសចេញទៅ ដូច្នេះនេះ បណ្ឌិតគប្បីជ្រាបថា រមែងត្រូវនូវអាបត្តិ ព្រោះការទៅដោយមិនមានអាល័យ, ឬព្រោះការញ៉ាំងអរុណឱ្យរះឡើងក្នុងទីដទៃ ។*

*ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:*

★ អនបេក្ខគមនេន ឧបចារាតិក្កមេ អាបត្តិ

វេទិតព្វា សាបេក្ខគមនេន អញ្ញត្ថ អរុណុដ្ឋាបនេន អាបត្តិ វេទិតព្វា ។ បណ្ឌិតគប្បីជ្រាបថា រមែងត្រូវនូវអាបត្តិ ព្រោះកន្លងនូវឧបចារៈ ព្រោះទៅដោយមិនមានអាល័យ, គប្បីជ្រាបថា រមែងត្រូវនូវអាបត្តិ ព្រោះការញ៉ាំងអរុណឱ្យរះឡើង ក្នុងទីដទៃ សូម្បីនៅមានអាល័យ ។

<u>ក្នុងព្រះអដ្ឋកថា ពោលថាៈ</u>

✯ អយំ បនេត្ថ បាឡិមុត្តករត្តិច្ឆេទវិនិច្ឆយោ "ធម្មស្សវនត្ថាយ អនិមន្តិតេន គន្តុំ ន វដ្តតិ ។ សចេ បន ឯកស្មឹ មហាវាសេ បឋមំយេវ កតិកា កតា ហោតិ អសុកទិវសំ នាម សន្និបតិតព្វន្តិ និមន្តិតោយេវ នាម ហោតិ គន្តុំ វដ្តតិ ។

✯ *នេះជាសេចក្តីវិនិច្ឆ័យក្នុងការដាច់រាត្រី ដែលផុតចាកព្រះបាលិថា ៖*

*ភិក្ខុដែលទាយកមិនបាននិមន្ត ដើម្បីប្រយោជន៍ដល់ការស្តាប់ធម៌ មិនគួរទៅ ។ ក៏ប្រសិនបើទាយក បានធ្វើការកំណត់គ្នាទុកហើយ ក្នុងអាវាសធំមួយកន្លែងថា "ភិក្ខុទាំងឡាយ គប្បីមកប្រជុំគ្នា ក្នុងថ្ងៃឈ្មោះឯណោះ" ដូច្នេះ ក៏ឈ្មោះថា ជាអ្នកដែលទាយកនិមន្តហើយ ភិក្ខុគួរដើម្បីទៅបាន ។*

*ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:*

★ **រត្តិច្ឆេទវិនិច្ឆយោតិ** សត្តាហករណីយេន គន្ត្វា ពហិទ្ធា អរុណុដ្ឋាបនសង្ខាតស្ស រត្តិច្ឆេទស្ស វិនិច្ឆយោ ។

*ពាក្យថា* ***សេចក្ដីវិនិច្ឆ័យក្នុងការដាច់រាត្រី*** *ដូច្នេះនេះ មានសេចក្ដីថា ជាការវិនិច្ឆ័យចំពោះភិក្ខុដែលទៅ* ***ដោយសត្តាហ-ករណីយ*** *ហើយឱ្យដាច់រាត្រី ពោលគឺការញ៉ាំងអរុណឱ្យរះឡើងនៅខាងក្រៅ (ឧបចារវត្ត) ។*

*ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:*

★ **អនិមន្តិតេន គន្តុំ ន វដ្ដតីតិ** តស្ស រត្តិច្ឆេទោ ច ទុក្កដាបត្តិ ច ហោតិ, តំ "វស្សច្ឆេទោ" ច វទន្តិ ។

*ពាក្យថា* ***ភិក្ខុដែលទាយកមិនបាននិមន្តមិនគួរទៅ*** *ដូច្នេះនេះ មានសេចក្ដីថា ការដាច់រាត្រីផង អាបត្តិទុក្កដផង រមែងមានដល់ភិក្ខុនោះ, ក៏ពាក្យថា* ***ការដាច់រាត្រីនោះ*** *លោកអាចារ្យទាំងឡាយពោលថា "ជាការដាច់នូវវស្សា" ។*

*ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:*

★ **អនិមន្តិតេន គន្តុំ ន វដ្ដតីតិ** ឯត្ថ អនិមន្តិតត្តា សត្តាហកិច្ចំ អធិដ្ឋហិត្វា គច្ឆន្តស្សបិ វស្សច្ឆេទោ ចេវ

ទុក្កដញ្ច ហោតីតិ វេទិតព្វំ ។ យថាវុត្តញ្ហិ រត្តិច្ឆេទ-ការណំ វិនា តិរោវិហារេ វសិត្វា អាគច្ឆិស្សាមីតិ គច្ឆតោបិ វស្សច្ឆេទំ វទន្តិ ។ ក្នុងពាក្យថា *ភិក្ខុដែលទាយក មិនបាននិមន្តមិនគួរទៅ* ដូច្នេះនេះ បណ្ឌិតគប្បីជ្រាបថា "សូម្បីភិក្ខុអធិដ្ឋាននូវកិច្ច ទាក់ទងនឹងសត្តាហករណីយៈ ហើយទៅ រមែងដាច់នូវវស្សាផង ត្រូវអាបត្តិទុក្កដផង ព្រោះទាយកមិនបាននិមន្ត ។ សមដូចពាក្យដែលលោកពោលថា "អាចារ្យទាំងឡាយពោលនូវការដាច់វស្សា សូម្បីដល់ភិក្ខុដែលនៅខាងក្រៅវិហារ វៀរចាកហេតុនៃការដាច់រាត្រី ហើយទៅដោយគិតថា "អញនឹងត្រលប់មកវិញ" ដូច្នេះ ។

<u>ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:</u>

✯ **និមន្តិតោយេវ គន្តុំ ហោតីតិ** ឯត្ថ ឧបាសកេហិ "ឥមស្មឹ ឆាម ទិវសេ ទានាទីនិ ករោម, សព្វេ សន្និបតន្តូតិ" កតាយបិ កតិកាយ គន្តុំ វដ្តតិ ។

ក្នុងពាក្យថា *ក៏ឈ្មោះថា ជាអ្នកដែលទាយកនិមន្តហើយ* ដូច្នេះនេះ សូម្បីឧបាសកនិងឧបាសិកាទាំងឡាយ ធ្វើហើយនូវកតិកាថា "ក្នុងថ្ងៃឈ្មោះឯណោះ យើងទាំងឡាយ នឹងថ្វាយនូវទានជាដើម, សូមភិក្ខុទាំងអស់មកជួបជុំគ្នា" ដូច្នេះ ភិក្ខុគួរ

*ដើម្បីទៅបាន ។*

*ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:*

**★គន្តុំ វដ្ដតីតិ** សត្តាហករណីយេន គន្តុំ វដ្ដតិ ។ ឯវំ គច្ឆន្តេន ច អន្តោ ឧបចារសីមាយំ ឋិតេនេវ អន្តោ សត្តាហេ អាគច្ឆិស្សាមីតិ អាភោគំ កត្វា គន្តព្វំ ។ សចេ អាភោគំ អកត្វា ឧបចារសីមំ អតិក្កមតិ ឆិន្នវស្សោវ ហោតីតិ វេទិតព្វំ ។ *ពាក្យថា ភិក្ខុគួរដើម្បី ទៅបាន ដូច្នេះ មានសេចក្ដីថា គួរដើម្បីទៅដោយសត្តាហក រណីយកិច្ចបាន ។ ក៏កាលភិក្ខុទៅយ៉ាងនេះ ត្រូវឋិតនៅខាងក្នុងឧបចារសីមា គប្បីធ្វើនូវអាភោគចិត្តថា "អន្តោ សត្តាហេ អាគច្ឆិស្សាមិ : អាត្មាអញនឹងត្រលប់មកវិញ ក្នុងខាងក្នុងរវាង ៧ ថ្ងៃ" ហើយ សិនសីមទៅ ។ បើមិនធ្វើនូវអាភោគចិត្តទេ ហើយឈានកន្លង នូវឧបចារសីមាទៅ បណ្ឌិតគប្បីជ្រាបថា* ***ការដាច់វស្សា រមែងមានពិត ។***

*ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:*

**★ គន្តុំ វដ្ដតីតិ** អន្តោ ឧបចារសីមាយំ ឋិតេនេវ សត្តាហករណីយនិមិត្តំ សល្លក្ខេត្វា ឥមិនា និមិត្តេន

គន្ត្វា "អន្តោ សត្តាហេ អាគច្ឆិស្សាមី"តិ អាភោគំ កត្វា គន្តុំ វដ្ដតិ ។ ពាក្យថា ភិក្ខុគួរដើម្បីទៅបាន ដូច្នេះនេះ មានសេចក្ដីថា ភិក្ខុត្រូវឋិតនៅខាងក្នុងឧបចារសីមាប៉ុណ្ណោះ ហើយកំណត់នូវនិមិត្ត នៃសត្តាហករណីយកិច្ចហើយទៅ ដោយនិមិត្តនោះ រួចធ្វើនូវអាភោគចិត្តថា "អន្តោ សត្តាហេ អាគច្ឆិស្សាមិ : អាត្មាអញនឹងត្រលប់មកវិញ ក្នុងខាងក្នុងរវាង ៧ ថ្ងៃ " ដូច្នេះ ហើយសិនទើបគួរទៅបាន ។

បុរិមក្ខណេ អាភោគំ កត្វា គមនក្ខណេ វិស្សរិត្វា គតេបិ គោសោ នត្ថិ សករណីយោ បក្កមតីតិ វុត្តត្តា ។ សព្វថា បន អាភោគំ អកត្វា គតស្ស វស្សច្ឆេទោតិ វទន្តិ ។ ភិក្ខុធ្វើអាភោគចិត្តក្នុងខណៈខាងដើម ហើយស្រាប់តែភ្លេចក្នុងខណៈដែលទៅ, ហើយក៏ទៅមិនមានទោសទេ, ព្រោះព្រះមានព្រះភាគត្រាស់ថា "ភិក្ខុមានករណីយកិច្ច ជៀសចេញទៅ ។ អាចារ្យទាំងឡាយពោលថា "ក៏ការដាច់វស្សា រមែងមានដល់ភិក្ខុដែលមិនធ្វើអាភោគចិត្តដោយប្រការទាំងពួង ហើយជៀសចេញទៅ ។

✯យោ បន សត្តាហករណីយនិមិត្តាភាវេបិ សត្តាហព្ភន្តរេ អាគមិស្សាមីតិ អាភោគំ កត្វា គន្ត្វា សត្តា-

ហព្ភន្តរេ អាគច្ឆតិ តស្ស អាបត្តិយេវ វស្សច្ឆេទោ នត្ថិ សត្តាហស្ស សន្និវត្តត្តាតិ វទន្តិ ។ វិមំសិត្វា គហេតព្វំ ។ *អាចារ្យទាំងឡាយពោលថា "ក៏ភិក្ខុណាធ្វើនូវ អាភោគចិត្តថា "អាត្មាអញនឹងត្រឡប់មកវិញ ក្នុងខាងក្នុងរវាង ៧ ថ្ងៃ" ដូច្នេះ សូម្បីមិនមានហេតុនៃសត្តាហករណីយ ហើយ ទើបទៅ, រូបក៏ត្រឡប់មកវិញក្នុងចន្លោះ ៧ ថ្ងៃមែន, ភិក្ខុនោះ ត្រូវតែអាបត្តិប៉ុណ្ណោះ, តែវស្សាមិនដាច់ទេ ព្រោះលោកត្រឡប់មកវិញក្នុងរវាង ៧ ថ្ងៃមែន ។ ពាក្យរបស់អាចារ្យនោះ* គប្បីពិចារណាសិន សឹមកាន់យក ។

*ក្នុងព្រះអដ្ឋកថា ពោលថា:*

★ ភណ្ឌកំ ធោវិស្សាមីតិ គន្តុំ ន វដ្ដតិ ។ សចេ បន អាចរិយុបជ្ឈាយា បហិណន្តិ វដ្ដតិ ។ នាតិទូរេ វិហារោ ហោតិ តត្ថ គន្ត្វា "អជ្ជេវ អាគមិស្សាមីតិ" សម្បាបុណិតុំ ន សក្កោតិ វដ្ដតិ ។ *ភិក្ខុនឹងទៅដោយគិតថា "យើងនឹងជ្រលក់ចីវរ"* មិនគួរទេ ។ *តែបើអាចារ្យនិងឧបជ្ឈាយ៍ប្រើទៅ* រមែងគួរ ។ *វត្តមាននៅក្នុងទីមិនឆ្ងាយ លោកទៅក្នុងវត្តនោះ ដោយតាំងចិត្តគិតថា* "អជ្ជេវ អាគមិស្សាមិ : *អញនឹងត្រលប់មកវិញ ក្នុងថ្ងៃនេះឯង"* តែមិនអាច

*នឹងមកទាន់បាន រមែងគួរ ។*

<u>*ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:*</u>

★ **សម្បាបុណិតុំ ន សក្កោតិ វដ្ដតីតិ** ឯត្ថ "អជ្ជេវ អាគមិស្សាមី"តិ សាមន្តវិហារំ គន្ត្វា បុន អាគច្ឆន្តស្ស អន្តរាមគ្គេ សចេ អរុណុគ្គមនំ ហោតិ វស្សច្ឆេទោបិ ន ហោតិ រត្តិច្ឆេទទុក្កដញ្ច នត្ថីតិ វទន្តិ ។

*ពាក្យថា **តែមិនអាចនឹងមកទាន់បាន រមែងគួរ** ដូច្នេះនេះ លោកអាចារ្យទាំងឡាយពោលថា "កាលភិក្ខុទៅកាន់វត្តជិតខាង ដោយចិត្តគិតថា "អញនឹងត្រលប់មកវិញ ក្នុងថ្ងៃនេះឯង" ហើយកំពុងដើរមក, **ប្រសិនបើអរុណរះឡើង ក្នុងចន្លោះផ្លូវ សូម្បីការដាច់វស្សា ក៏មិនមាន**, ទាំងការដាច់រាត្រី និងការត្រូវអាបត្តិទុក្កដ ក៏មិនមានដែរ ។*

<u>*ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:*</u>

★ **សម្បាបុណិតុំ ន សក្កោតិ វដ្ដតីតិ** តទហេវ អាគមនេ សឧស្សាហត្តា វស្សច្ឆេទោ វា អាបត្តិ វា ន ហោតីតិ អធិប្បាយោ ។ *ពាក្យថា **តែមិនអាចនឹងមកទាន់បាន រមែងគួរ** ដូច្នេះនេះ មានសេចក្ដីអធិប្បាយថា "ការដាច់*

*វស្សាក្តី ការត្រូវអាបត្តិក្តី រមែងមិនមាន, ព្រោះ (ភិក្ខុនោះ) មានឧស្សាហ៍ត្រលប់មកវិញ ក្នុងថ្ងៃនោះឯង" (មិនដាច់វស្សា ព្រោះញ៉ាំងអរុណឱ្យរះឡើង នៅខាងក្រៅឧបចារវត្តទេ) ។*

*<u>ក្នុងព្រះអដ្ឋកថា ពោលថា:</u>*

★ ឧទ្ទេសបរិបុច្ឆាទីនំ អត្ថាយបិ គន្តុំ ន វដ្តតិ ។ **អាចរិយំ បស្សិស្សាមីតិ បន គន្តុំ លភតិ** ។ សចេ បន នំ អាចរិយោ "អជ្ជ មា គច្ឆា"តិ **វទតិ វដ្តតិ** ។ ឧបដ្ឋាកកុលំ វា ញាតិកុលំ វា ទស្សនត្ថាយ គន្តុំ ន លភតិ ។ *ភិក្ខុទៅសូម្បីដើម្បីប្រយោជន៍ដល់ឧទ្ទេស និងបរិបុច្ឆា ជាដើម មិនគួរទេ ។ ក៏ភិក្ខុទៅដោយគិតថា "យើងនឹងជួប នូវអាចារ្យ (សួរសុខទុក្ខលោក) ទើបបាន ។ បើអាចារ្យ ពោលនឹងលោកថា "លោកកុំទៅក្នុងថ្ងៃនេះឡើយ" ដូច្នេះ នឹង មិនត្រឡប់មក ក៏គួរ ។ ភិក្ខុទៅដើម្បីឃើញនូវត្រកូលឧបដ្ឋាក ឬត្រកូលរបស់ញាតិ មិនបានទេ ។*

*<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:</u>*

★ **អាចរិយំ បស្សិស្សាមីតិ** បន គន្តុំ លភតីតិ "អគិលានម្បិ អាចរិយំ ឧបជ្ឈាយំ វា បស្សិស្សាមី"តិ សត្តាហករណីយេន គន្តុំ លភតិ ។ *ពាក្យថា ក៏ភិក្ខុទៅ*

*ដោយគិតថា "យើងនឹងជួបអាចារ្យ (សួរសុខទុក្ខលោក) ទើបបាន ដូច្នេះនេះ មានសេចក្ដីថា រមែងបានដើម្បីនឹងទៅ ដោយសត្តាហករណីយកិច្ច ដោយគិតថា "យើងនឹងជួបអាចារ្យ ឬឧបជ្ឈាយ៍ (សួរសុខទុក្ខលោក) សូម្បីលោក មិនមានជម្ងឺ (ក៏ដោយ)" ។*

★ **សចេ បន នំ អាចរិយោ "អជ្ជ មា គច្ឆា"តិ វទតិ វដ្ដតីតិ** ឯវំ សត្តាហករណីយេន គតំ អន្តោ-សត្តាហេយេវ បុន អាគច្ឆន្តំ សចេ អាចរិយោ ឧបជ្ឈាយោ វា "អជ្ជ មា គច្ឆា"តិ វទតិ វដ្ដតិ សត្តាហាតិក្កមេបិ អនាបត្តីតិ អធិប្បាយោ, វស្សច្ឆេទោ បន ហោតិយេវាតិ ឧជុតំ សត្តាហស្ស ពហិទ្ធា វីតិនាមិតត្តា ។ *ពាក្យថា បើអាចារ្យពោលនឹងលោកថា "លោកកុំទៅក្នុងថ្ងៃនេះឡើយ" ដូច្នេះ នឹងមិនត្រលប់មក ក៏គួរ ដូច្នេះនេះ មានសេចក្ដីថា ភិក្ខុដែលទៅដោយ សត្តាហករណីកិច្ចយ៉ាងនេះ ហើយកំពុងត្រលប់មកវិញ ក្នុងខាងក្នុងរវាង ៧ ថ្ងៃនោះឯង, បើអាចារ្យ ឬឧបជ្ឈាយ៍ ពោលថា "លោកកុំទៅក្នុងថ្ងៃនេះឡើយ"* ***រមែងគួរ,*** *អធិប្បាយថា ជាអនាបត្តិសូម្បីកន្លងហួស ៧ ថ្ងៃទៅ, តែគប្បីជ្រាបថា វស្សា រមែងដាច់ពិត ព្រោះលោក (ធ្វើ) ៧ ថ្ងៃ*

ឱ្យកន្ទង់ទៅខាងក្រៅ ។

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

★ **អាចរិយន្តិ** អតិលានម្បិ និស្សយាចរិយញ្ច ធម្មាចរិយញ្ច បគេវ ឧបសម្បទាចរិយឧបជ្ឈាយេសុ ។

ពាក្យថា **អាចារ្យ** ដូច្នេះ គឺបានដល់និស្សយាចារ្យក្តី ធម្មាចារ្យក្តី សូម្បីមិនមានជម្ងឺក៏ដោយ, ចាំបាច់ពោលទៅថ្វីដល់ឧបសម្បទាចារ្យ និងព្រះឧបជ្ឈាយ៍ទេ ។

★ **វទតិ វដ្ដតីតិ** សត្តាហាតិក្កមេ អាបត្តិអភាវំ សន្ធាយ វុត្តំ, វស្សច្ឆេទោ បន ហោតិ ឯវ ។ ពាក្យថា **បើអាចារ្យពោលថាមែងគួរ** ដូច្នេះ លោកអាចារ្យពោលសំដៅយកនូវភាពមិនមានអាបត្តិ ក្នុងការកន្លងហួស ៧ ថ្ងៃទៅ តែការដាច់វស្សាមែងមានពិត ។

## ក្នុងថ្ងៃបវារណាក៏ដោយ ត្រូវតែលើកសត្តាហៈទៅ

<u>ក្នុងវិនយបិដកភាគ ៧ ទំព័រ ៥៧ ត្រាស់ថា:</u>

ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ បើភិក្ខុបានទទួលពាក្យប្តេជ្ញាថា នៅចាំវស្សាដោយបុរិមិកាវស្សាហើយ ។ ភិក្ខុនោះកាលនឹងដើរទៅកាន់អាវាសនោះ ក៏ធ្វើឧបោសថខាងក្រៅលុះដល់ថ្ងៃ ១ រោច ចូលទៅឯវិហារ ក្រាលសេនាសនៈ រួច

តម្កល់ទឹកឆាន់និងទឹកប្រើប្រាស់ បោសប្រាស់ទីបវារណា ។ សោ សត្តាហំ អនាគតាយ បវារណាយ សករណីយោ បក្កមតិ ។ អាគច្ឆេយ្យ វា សោ ភិក្ខវេ ភិក្ខុ តំ អាវាសំ ន វា អាគច្ឆេយ្យ ។ តស្ស ភិក្ខវេ ភិក្ខុនោ បុរិមិកា ច បញ្ញាយតិ បដិស្សវេ ច អនាបត្តិ ។

*ភិក្ខុនោះកាលបើនៅខ្វះ ៧ ថ្ងៃទៀត នឹងដល់ថ្ងៃបវារណា ក៏ប្រកដោយកិច្ចដែលត្រូវធ្វើហើយថយចេញទៅ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះបានមកកាន់អាវាសនោះក្តី មិនបានមកកាន់អាវាសនោះក្តី ។ ម្នាលភិក្ខុទាំងឡាយ ឯបុរិមិកាវស្សារបស់ភិក្ខុនោះ ក៏ប្រាកដផង, ភិក្ខុនោះមិនត្រូវអាបត្តិ ព្រោះការទទួលពាក្យប្តេជ្ញាផង ។*

<u>*ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:*</u>

★ បាឡិយំ " សោ សត្តាហំ អនាគតាយ បវារណាយ សករណីយោ បក្កមតីតិ" វុត្តត្តា បវារណាទិវសេបិ សត្តាហករណីយំ វិនា គន្តុំ ន វដ្តតីតិ វេទិតព្វំ ។ *ព្រោះពាក្យដែលព្រះអង្គត្រាស់ទុក ក្នុងបាលីថា "ភិក្ខុនោះកាលបើនៅខ្វះ ៧ ថ្ងៃទៀត នឹងដល់ថ្ងៃបវារណា ក៏ប្រកបដោយកិច្ច ដែលត្រូវធ្វើហើយជៀសចេញទៅ" ដូច្នេះ*

នេះ បណ្ឌិតគប្បីជ្រាបថាសូម្បីក្នុងថ្ងៃបវារណាក៏ដោយ បើវៀរ ចាកសត្តាហករណីយហើយ ភិក្ខុមិនគួរដើម្បីទៅឡើយ ។

**វស្សច្ឆេទកថាចប់ ។**

# ១៥~ឧបាហនកថា

## ពន្យល់ពាក្យថា ស្បែកជើង និងទ្រនាប់ជើង

*ក្នុងគម្ពីរអភិធានវណ្ណនា ពោលថា:*

★ ឧបាហនា : *ស្បែកជើង (ឧបបុព្វបទ, អាបុព្វបទ ហនធាតុ ចុះក្នុងអត្ថថា "ចង" អបច្ច័យ) វិគ្គហថា:* ឧបនយ្ហតេ ពន្ធីយតេតិ ឧបាហនោ : *គឺជនតែងចូលទៅចង គឺថាចង នូវវត្ថុនោះ ព្រោះហេតុនោះ វត្ថុនោះឈ្មោះថា* **ឧបាហនោ** ។

*ម្យ៉ាងទៀត* ឧបាហនា : *មកពី (ឧបបុព្វបទ, អាបុព្វបទ ហនធាតុ ចុះក្នុងអត្ថថា "ចូលទៅ" អបច្ច័យ) វិគ្គហថា :* ឧបគច្ឆតិ អនេនាតិ ឧបាហនំ *ជនតែងចូលទៅដោយវត្ថុនោះ ព្រោះហេតុនោះ វត្ថុនោះ ឈ្មោះថា* **ឧបាហនំ** ។

★ **បាទុកា** : *ទ្រនាប់ជើង (បទធាតុ ចុះក្នុងអត្ថថា "ទៅ" ណុកបច្ច័យ, អាឥត្ថីលិង្គ) វិគ្គហថា:* បជ្ជតេ ឯតេនាតិ បាទុកា ។ *ជនតែងទៅដោយវត្ថុនោះ ព្រោះហេតុនោះ វត្ថុនោះ ឈ្មោះថា* **បាទុកា** ។

*ក្នុងវិនយបិដកភាគ ៤ ត្រង់បទភាជនីយ៍ ពោលថា:*

★ ន បាទុកា រុឡ្ហស្ស អគិលានស្ស ធម្មោ

ទេសេតព្វោ ។ យោ អនាទរិយំ បដិច្ច **អក្កន្តស្ស** វា បដិមុក្កស្ស វា ឱមុក្កស្ស វា អគិលានស្ស ធម្មំ ទេសេតិ អាបត្តិ ទុក្កដស្ស ។ *ភិក្ខុមិនត្រូវសម្ដែងធម៌ដល់មនុស្សគ្មានជំងឺពាក់ទ្រនាប់ជើងទេ ។ ភិក្ខុណា អាស្រ័យសេចក្ដីមិនអើពើ សម្ដែងធម៌ដល់មនុស្សគ្មានជម្ងឺ* ***ជាន់ទ្រនាប់ជើងក្ដី*** *ពាក់ក្ដី ដោះបង្ហើបកែងបន្តិចក្ដី ត្រូវអាបត្តិទុក្កដ ។*

*ក្នុងអដ្ឋកថា សេខិយវត្ត ពោលថា:*

★ **អក្កន្តស្សាតិ** ឆត្តទណ្ឌកេ អង្គុលន្តរំ អប្បវេសេត្វា កេវលំ បាទុកំ អក្កមិត្វា ឋិតស្ស ។ *ពាក្យថា* ***ជាន់ទ្រនាប់ជើង*** *ដូច្នេះនេះ មានសេចក្ដីថា គឺគេឈរជាន់នូវបាទុកា (ទ្រនាប់ជើង) តែម៉្យាង, មិនបានស៊កបញ្ចូលទៅនូវចន្លោះម្រាម ត្រង់ដងឆត្រទេ ។*

**បាទុកាដែលធ្វើមកអំពីស្បែក ក៏មានដែរ**

*ក្នុងវចនានុក្រមខ្មែរ ទំព័រ ៥៦៣ ពោលថា:*

★ *បាទុកា ប្រែថា ទ្រនាប់ជើង (ដែលធ្វើដោយឈើ ឬស្មៅ ឬក៏ធ្វើពីអ្វីផ្សេងៗ* ***ក្រៅពីស្បែក****) ។ ពាក្យនេះ ដូចជាមិនសមជាមួយនឹងគម្ពីរបាចិត្យាទិយោជនាទេ ។*

<u>*ក្នុងបាចិត្យាទិយោជនា និងអភិធានប្បទីបិកាដីកា ពោលថា:*</u>

★ **បាទុកាន្តិ** ឧបាហនវិសេសោ ។ សោ ហិ បជ្ជតេ ឥមាយតិ បាទុកាតិ វុច្ចតិ, **សា ពហុបដលា ចម្មមយា វា ហោតិ កដ្ឋមយា វា** ។ *ឧបាហនាដ៏វិសេស ឈ្មោះថា បាទុកា ។ ពិតមែន ឧបាហនាដ៏វិសេសនោះ លោកហៅថា បាទុកា ព្រោះវិគ្គហថា : "ជនតែងទៅ ដោយឧបាហនានោះ ព្រោះហេតុនោះ ឧបាហនានោះ ឈ្មោះថា បាទុកា" ។* ***បាទុកា*** *(ទ្រនាប់ជើង) នោះមានច្រើនជាន់ ដែលសម្រេចមកពីស្បែកខ្លះ សម្រេចមកពីឈើខ្លះ ។*

<u>*ក្នុងវចនានុក្រមខ្មែរ ទំព័រ ១៨១១ ពោលថា:*</u>

★ *បាទុកា ប្រែថា ទ្រនាប់ជើង, វដ្តយើងសព្វថ្ងៃមិនសូវប្រើ ព្រោះពួខេកខ្លោកពុំជាបើ ស្រាប់តែលែងប្រើឯងទៅ ។*

**ភិក្ខុមិនត្រូវពាក់ស្បែកជើងចូលស្រុកទេ**

<u>*ក្នុងវិនយបិដកភាគ ៧ ទំព័រ ២០៣ ពោលថា:*</u>

★ ន ភិក្ខវេ សឧបាហនេន គាមោ បវិសិតព្វោ យោ បវិសេយ្យ អាបត្តិ ទុក្កដស្ស ។ *ម្នាលភិក្ខុទាំងឡាយ ភិក្ខុ*

មិនត្រូវពាក់ស្បែកជើង ចូលទៅកាន់ស្រុកទេ ភិក្ខុណា (ពាក់) ចូលទៅ ត្រូវអាបត្តិទុក្កដ ។

★ អនុជានាមិ ភិក្ខវេ គិលានេន ភិក្ខុនា សឧបាហនេន គាមំ បវិសិតុំ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុដែលមានជម្ងឺ ពាក់ស្បែកជើងចូលទៅកាន់ស្រុកបាន ។

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>

★ គិលានេន ភិក្ខុនា សឧបាហនេនាតិ ឯត្ថ គិលានោ នាម យោ ន សក្កោតិ អនុបាហនោ គាមំ បវិសិតុំ ។ ក្នុងពាក្យថា ឱ្យភិក្ខុដែលមានជម្ងឺ ពាក់ស្បែកជើង ដូច្នេះនេះ បណ្ឌិតគប្បីជ្រាបថា ភិក្ខុណាមិនពាក់ស្បែកជើង មិនអាចនឹងចូលទៅកាន់ស្រុកបាន ភិក្ខុនោះឈ្មោះថា អ្នកមានអាពាធ ។

**ភិក្ខុពាក់ស្បែកជើង ២-៣ ជាន់មិនគួរ ត្រឹមតែ ១ ជាន់គួរ**

<u>ក្នុងគម្ពីរវិនយសង្គហដ្ឋកថា ពោលថា:</u>

★ "អនុជានាមិ ភិក្ខវេ ឯកបលាសិកំ ឧបាហនំ, ន ភិក្ខវេ ទិគុណា ឧបាហនា ធារេតព្វា, ន តិគុណា ឧបាហនា ធារេតព្វា, ន គុណង្គុណូបាហនា ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្សា"តិ វចនតោ ឯកបដ-

លាយេវ ឧបាហនា វដ្ដតិ, ទ្វិបដលា បន តិបដលា ន វដ្ដតិយេវ ។ ដោយព្រះពុទ្ធដីកាថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវស្បែកជើង ១ ជាន់, ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវពាក់ស្បែកជើង ២ ជាន់ទេ, ភិក្ខុមិនត្រូវពាក់ស្បែកជើង ៣ ជាន់ទេ, ភិក្ខុមិនត្រូវពាក់ស្បែកជើង ៤ ជាន់ទេ, ភិក្ខុណាពាក់ ត្រូវអាបត្តិទុក្កដ" ដូច្នេះ មានសេចក្ដីថា ស្បែកជើង ១ ជាន់ប៉ុណ្ណោះ រមែងគួរ, ចំណែកឯស្បែកជើង ២ ជាន់ និងស្បែកជើង ៣ ជាន់ មិនគួរទេ ។

★ ឯកបដលា បន បរិភុត្តា វា ហោតុ អបរិភុត្តា វា សព្វត្ថ វដ្ដតិ ។ ចំណែកឯស្បែកជើងតែ ១ ជាន់ ទោះបីគេប្រើប្រាស់ហើយក្ដី មិនបានប្រើប្រាស់ហើយក្ដី ចូរលើកទុកចុះ, រមែងគួរ ក្នុងទីទាំងពួង (គឺក្នុងមជ្ឈិមប្រទេស និងបច្ចន្តប្រទេស) ។

<u>ព្រះអង្គបញ្ញត្តិចំពោះមជ្ឈិមជនបទ ថា៖</u>

★ ន ភិក្ខវេ នវា គុណង្គុណូបាហនា ធារេតព្វា យោ ធារេយ្យ អាបត្តិ ទុក្កដស្ស ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវពាក់ស្បែកជើង ៤ ជាន់ឡើងទៅដែលជាស្បែកជើងថ្មីទេ, ភិក្ខុណាពាក់ត្រូវអាបត្តិទុក្កដ ។

<u>ព្រះអង្គអនុញ្ញាតចំពោះ បច្ចន្តិមជនបទ ថា:</u>

★ អនុជានាមិ ភិក្ខវេ សព្វប្បច្ចន្តិមេសុ ជនបទេសុ គុណង្គុណូបាហនំ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងបច្ចន្តិមជនបទទាំងអស់ តថាគតអនុញ្ញាតនូវស្បែកជើង ៤ ជាន់ឡើងទៅ ។

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>

★ អនុជានាមិ ភិក្ខវេ សព្វប្បច្ចន្តិមេសុ ជនបទេសុ គុណង្គុណូបាហនន្តិ ឯត្ថ មនុស្សចម្មំ ឋបេត្វា យេន កេនចិ ចម្មេន ឧបាហនា វដ្ដតិ ។ ឧបាហនកោសកសត្ថកោសកកុញ្ចិកកោសកេសុបិ ឯសេវ នយោ ។

ក្នុងពាក្យថា ម្នាលភិក្ខុទាំងឡាយ ក្នុងបច្ចន្តិមជនបទទាំងអស់តថាគតអនុញ្ញាតនូវស្បែកជើង ៤ ជាន់ឡើងទៅ ដូច្នេះ សេចក្ដីថា ស្បែកជើងដែលធ្វើដោយស្បែកប្រភេទណាមួយ វៀរស្បែកមនុស្សចេញ រមែងគួរ, សូម្បីក្នុងថង់ស្បែកជើង ស្រោមកាំបិត និងស្រោមសោរ ក៏មានន័យនេះដូចគ្នា ។

<u>ក្នុងគម្ពីរខុទ្ទកសិក្ខាអភិនវដីកា ពោលថា:</u>

★ **ឆវាតិ** ឥមិនា អនវា មជ្ឈទេសេបិ ។ ឥមិនា បន វាគៀន មជ្ឈទេសេបិ ឯកវារម្បិ បដិមុក្កា, អញ្ញត្ថ តុ

សព្វាបិ គុណង្គុណូបាហនា វដ្ដន្តិ, ន សេសាតិ អាបន្នំ តថាបិ "អនុជានាមិ ភិក្ខវេ, ឯកបលាសិកំ ឧបាហន"ន្តិ វុត្តត្តា ឯកបដលិកាបិ វដ្ដតីតិ វេទិតព្វំ ។ *ដោយពាក្យថា ថ្មី ដូច្នេះ សេចក្ដីថា បើស្បែកជើងមិនថ្មីទេ (រមែងគួរ) សូម្បីក្នុងមជ្ឈិមប្រទេស ។ ក៏ដោយពាក្យនេះ ស្បែកជើងដែលគេពាក់សូម្បីអស់វារៈម្ដង (រមែងគួរ) សូម្បីក្នុងមជ្ឈិមប្រទេស, តែក្នុងប្រទេសដទៃ* ***ស្បែកជើងចាប់ពី ៤ ជាន់ឡើងទៅ*** *គួរទាំងអស់ បានសេចក្ដីថា ស្បែកជើងដ៏សេស (ខុសពី ៤ ជាន់ឡើងទៅនោះ) រមែងមិនគួរ, ទុកជាដូច្នោះក៏ដោយ បណ្ឌិតគប្បីជ្រាបថា* ***ស្បែកជើង ១ ជាន់ រមែងគួរ***, *ព្រោះព្រះពុទ្ធដីកាថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវស្បែកជើង ១ ជាន់" ដូច្នេះ ។*

## ភិក្ខុមិនឈឺអាចពាក់ស្បែកជើងក្នុងអារាមបាន

<u>*ក្នុងគម្ពីរខុទ្ទកសិក្ខាបុរាណដីកា ពោលថា:*</u>

★ "អនុជានាមិ ភិក្ខវេ អជ្ឈារាមេ ឧបាហនំ ធារេតុំ ឧក្កំ បទីបំ កត្តរទណ្ឌក"ន្តិ វចនតោ អជ្ឈារាមេ អគិលានស្សបិ ឧបាហនំ ធារេតុំ វដ្ដតិ ។ *ដោយពាក្យថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុពាក់ស្បែកជើង*

កាន់គប់ភ្លើង កាន់ប្រទីប និងឈើច្រត់ ក្នុងអារាមបាន" ដូច្នេះ មានសេចក្ដីថា សូម្បីភិក្ខុមិនឈឺ រមែងគួរដើម្បីពាក់ស្បែកជើង ក្នុងអារាមបាន ។

<u>ក្នុងគម្ពីរខុទ្ទកសិក្ខា ពោលថា:</u>

★ មជ្ឈទេសេ ន កប្បន្តិ, គុណង្គុណូបាហនា នវា សព្វស្ស កប្បន្តារាមេ, សព្វត្ថាគិលានស្ស ច ។ ស្បែកជើងថ្មី ៤ ជាន់ឡើងទៅ (រមែងមិនគួរក្នុងមជ្ឈិមប្រទេស) ក្នុងអារាម រមែងគួរដល់ភិក្ខុទាំងអស់, ចំណែកភិក្ខុឈឺគួរក្នុងទីទាំងពួង ។

<u>ក្នុងគម្ពីរខុទ្ទកសិក្ខាបុរាណដីកា ពោលថា:</u>

★ **សព្វស្សាតិ** គិលានស្សាបិ អគិលានស្សាបីតិ អត្ថោ ។ មជ្ឈិមទេសេបិ បច្ចន្តិមទេសេបិ អារាមេ អារាមូ-បចារេ គិលានស្សាបិ អគិលានស្សាបិ "អនុជានាមិ ភិក្ខវេ, អជ្ឈារាមេ ឧបាហនំ ធារេតុ"ន្តិ វុត្តត្តា កប្បិយន្តិ អត្ថោ ។ ពាក្យថា **ភិក្ខុទាំងអស់នេះ** មានសេចក្ដីអធិប្បាយថា ទាំងភិក្ខុឈឺនិងភិក្ខុមិនឈឺ ។ លោកអធិប្បាយថា ក្នុងមជ្ឈិម-ប្រទេសក្ដី ក្នុងបច្ចន្តប្រទេសក្ដី ភិក្ខុឈឺក្ដី មិនឈឺក្ដី គួរពាក់នូវ (ស្បែកជើង)ក្នុងអារាម និងឧបចារនៃអារាមបាន ព្រោះព្រះអង្គ

អនុញ្ញាតថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យពាក់ស្បែកជើង ក្នុងអារាមបាន" ដូច្នេះ ។

ឯត្ថ បន មជ្ឈិមទេសេ គិលានស្ស គុណង្គុណូ-បាហនា បរិភុញ្ជិតុំ អារាមេបិ គាមេបិ វដ្ដតិ, បច្ចន្តិម-ទេសេ អបរិភុត្តាបិ ។ បណ្ដាប្រទេសទាំង ២ នោះ ក៏នៅក្នុងមជ្ឈិមប្រទេស ស្បែកជើង ៤ ជាន់ដែលប្រើប្រាស់ហើយប៉ុណ្ណោះ, រមែងគួរដល់ភិក្ខុដែលមានជម្ងឺ ទាំងនៅក្នុងអារាម ទាំងនៅក្នុងស្រុក ។ ចំណែកក្នុងបច្ចន្តប្រទេស សូម្បីមិនបានប្រើប្រាស់ ក៏គួរដែរ ។

មជ្ឈិមទេសេបិ បច្ចន្តិមទេសេបិ ភគវតា គិលាន-ស្សេវ ឧបាហនា អនុញ្ញាតា "អនុជានាមិ, ភិក្ខវេ, យស្ស បាទា វា ទុក្ខា, បាទា វា ផលិតា, បាទខិលោ វា អាពាធោ, ឧបាហនំ ធារេតុ"ន្តិ ច "អនុជានាមិ, ភិក្ខវេ គិលានេន ភិក្ខុនា សឧបាហនេន គាមំ បវិសិតុ"ន្តិ វុត្តត្តា ច ។ ស្បែកជើង គឺព្រះអង្គទ្រង់អនុញ្ញាតហើយ ដល់ភិក្ខុដែលឈឺប៉ុណ្ណោះ, ទាំងក្នុងមជ្ឈិមប្រទេស ទាំងបច្ចន្តប្រទេស ព្រោះព្រះអង្គត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ (បើ) ភិក្ខុណាមានជើងឈឺក្តី មានជើងបែកក្តី មានរោគដំបៅលេចនៅបាទជើងក្តី

តថាគតអនុញ្ញាតឱ្យភិក្ខុនោះពាក់ស្បែកជើងបាន ដូច្នេះ” ផង ។ និងព្រោះព្រះអង្គត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុដែលមានជម្ងឺពាក់ស្បែកជើង ចូលទៅកាន់ស្រុកបាន” ដូច្នេះផង ។

មជ្ឈិមទេសេ ច គិលានោ នវំ គុណង្គុណូបាហនំ ធារេតុំ យទិ លភតិ, កថំ បទេសបញ្ញត្តិ ហោតីតិ ? សព្វត្ថ បន ភគវតា គិលានស្សេវ ឧបាហនា អនុញ្ញាតា តស្មា មជ្ឈិមទេសេ គិលានោ នវំ គុណង្គុណូបាហនំ លភតីតិ គហេតព្វន្តិ វទន្តិ ។ អាចារ្យទាំងឡាយពោលថា បើមានពាក្យសួរថា ក៏នៅក្នុងមជ្ឈិមប្រទេស ភិក្ខុឈឺរមែងបានដើម្បីពាក់នូវស្បែកជើង ៤ ជាន់ ដែលនៅថ្មីបាន, តើប្រទេសបញ្ញត្តិ រមែងប្រាកដដូចម្តេចទៅ ? ឆ្លើយថា ស្បែកជើងគឺព្រះអង្គទ្រង់អនុញ្ញាតហើយ ដល់ភិក្ខុមានជម្ងឺប៉ុណ្ណោះក្នុងទីទាំងពួង, ព្រោះហេតុនោះ បណ្ឌិតគប្បីកាន់យកថា នៅក្នុងមជ្ឈិមប្រទេស ភិក្ខុឈឺ រមែងបានដើម្បីពាក់នូវស្បែកជើង ៤ ជាន់ថ្មីបាន ។

## ស្បែកជើងមានពណ៌អកប្បិយ ជូតមិនចេញក៏អាចប្រើបាន

*ក្នុងគម្ពីរព្រះអដ្ឋកថា ពោលថា:*

ឯតេសុ យំកិញ្ចិ លភិត្វា **រជនំ** ចោឡកេន បុញ្ឆិត្វា វណ្ណំ ភិន្ទិត្វា ធារេតុំ វដ្ដតិ ។ អប្បមត្តកេបិ ភិន្នេ វដ្ដតិយេវ ។ *បណ្ដាស្បែកជើង មានពណ៌ខៀវជាដើមនោះ ភិក្ខុបានប្រភេទណាមួយមកហើយ* ***យកសំពត់ជូតទឹកថ្នាំទំលាយ*** *ពណ៌ចេញហើយពាក់ រមែងគួរ, សូម្បីទំលាយពណ៌ចេញត្រឹមតែបន្តិច ក៏គួរ ។*

*ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:*

★ **រជនន្តិ** ឧបលិត្តំ នីលាទិវណ្ណំ សន្ធាយ វុត្តំ ។ តេនាហ "ចោឡកេន បុញ្ឆិត្វា"តិ ។ តញ្ហិ តថា បុញ្ឆិតេ វិគច្ឆតិ ។ យំ បន ចម្មស្ស ទុគ្គន្ធាបនយនត្ថំ កាឡរត្តាទិរជនេហិ រញ្ជិតត្តា កាឡរត្តាទិវណ្ណំ ហោតិ, តំ ចោឡាទីហិ អបនេតុំ ន សក្កា ចម្មគតិកមេវ, តស្មា តំ វដ្ដតីតិ ទដ្ឋព្វំ ។ *ពាក្យថា* ***ទឹកថ្នាំ*** *ដូច្នេះនេះ គឺលោកពោលសំដៅនូវទឹកថ្នាំមានពណ៌ខៀវជាដើម ដែលគេលាប ។ ព្រោះហេតុនោះ ទើបអដ្ឋកថាចារ្យពោលថា "យកសំពត់ជូត" ដូច្នេះ ។ ពិតមែន វត្ថុមានសភាពដូច្នោះ កាលជូតរមែងជ្រះបាន ។*

*តែវត្ថុណាមានពណ៌ខ្មៅ និងពណ៌ក្រហមជាដើម ព្រោះភាវៈនៃស្បែកគឺគេជ្រលក់នូវទឹកថ្នាំមានពណ៌ខ្មៅ និងក្រហមជាដើម ដើម្បីប្រយោជន៍បំបាត់ក្លិនអាក្រក់, វត្ថុនោះ មិនអាចនាំចេញដោយវត្ថុមានសំពត់ជាដើមបានទេ គឺមានគតិជាស្បែកពិត ។ ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបថា* ***ស្បែកជើងនោះគួរ*** *។*

*<u>ក្នុងគម្ពីរខុទ្ទកសិក្ខាអភិនវដីកា ពោលថា:</u>*

★ ឱទាតាយ ចាឡិយា អដ្ឋកថាយ ច អភាវេបិ អនុលោមវសេនេត្ថ វុត្តំ វិយ ទិស្សតិ ។

*សូម្បីស្បែកជើងពណ៌-ស មិនមានក្នុងបាលី និងអដ្ឋកថាក៏ដោយ ក៏រមែងប្រាកដដូចជាលោកពោលហើយ នៅក្នុងសេចក្តីនេះ ដោយអំណាចការអនុលោម ។*

*<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>*

★ **ចាលិគុណ្ឋិមាតិ** បលិគុណ្ឋិត្វា កតា, យា ឧបរិ ចាទមត្តមេវ បដិច្ឆាទេតិ, ន ជង្ឃំ ។ *ពាក្យថា ស្បែកជើងដែលបិទខ្នងជើង ដូច្នេះនេះ បានដល់ ស្បែកជើងដែលគេរុំព័ទ្ធហើយធ្វើ, អធិប្បាយថា ស្បែកជើងណា ដែលបិទត្រឹមតែខាងលើខ្នងជើងប៉ុណ្ណោះ មិនបានបិទស្មងជើងទេ ។*

*<u>ក្នុងបាចិត្យាទិយោជនា ពោលថា:</u>*

☆ **បាលិគុណ្ឋិមាតិ** ឧបរិ សមន្តតោ វេឋេត្វា ។ *ពាក្យថា ស្បែកជើងដែលបិទខ្នងជើង មានសេចក្តីថា ស្បែកជើងដែលរុំដោយជុំវិញអំពីខាងលើ ។*

**ឧបាហនកថាចប់ ។**

# ១៦_កប្បិយភូមិកថា

*ក្នុងវិនយបិដកភាគ ៧ ទំព័រ ៣៤៣ ពោលថា:*

★ អនុជានាមិ ភិក្ខវេ សម្មតិកំ កប្បិយភូមឹ បរិភុញ្ជិតុំ ។ អនុជានាមិ ភិក្ខវេ ចតស្សោ កប្បិយ-ភូមិយោ ឧស្សាវនន្តិកំ គោនិសាទិកំ គហបតិកំ សម្មតិកំ ។ *ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យអ្នកទាំងឡាយ ប្រើប្រាស់នូវកប្បិយភូមិ ដែលសង្ឃសន្មតឱ្យ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតនូវកប្បិយភូមិ ៤ យ៉ាង គឺ ឧស្សាវនន្តិកា ១ គោនិសាទិកា ១ គហបតិកា ១ សម្មតិកា ១ ។*

*ក្នុងគម្ពីរអដ្ឋកថា ពោលថា:*

*ក្នុងបទថា* ឧស្សាវនន្តិកំជាដើម *គប្បីជ្រាបដូច្នេះ ៖ កប្បិយភូមិ ឈ្មោះឧស្សាវនន្តិកា គប្បីធ្វើមុនយ៉ាងនេះគឺ កុដិណាគេធ្វើលើសសរទាំងឡាយ ឬក្នុងជើងជញ្ជាំងថ្មដែលវាងជើងសសរខាងក្រោមនៃកុដិនោះ មានគតិដូចផែនដីពិត ។ ក៏ឯកាលនឹងតម្កល់សសរជាដំបូង ឬជើងជញ្ជាំងជាដំបូង ភិក្ខុច្រើន-*

រូប គប្បីឈរព័ទ្ធជុំវិញបញ្ចេញវាចាថា "**កប្បិយកុដី កករោម**" ប្រែថា យើងធ្វើកប្បិយកុដិ, កាលមនុស្សទាំងឡាយ ជួយគ្នាលើកឡើងឱ្យតម្កល់ចុះ គប្បីពោលត្រូវ ឬលើកខ្លួនឯង ក៏បាននូវសសរ ឬជញ្ជាំងហើយតម្កល់ចុះ ។ ចំណែកក្នុងកុរុន្ទី និងមហាបច្ចរី ពោលទុកថា "ភិក្ខុទាំងឡាយ គប្បីពោលថា **កប្បិយកុដី កប្បិយកុដី** ។ តែក្នុងអធិការពោលដោយការធ្វើកប្បិយភូមិឈ្មោះឧស្សាវនន្តិកានេះ មានលក្ខណៈទូទៅដូច្នេះ **ខណៈដែលសសរតាំងចុះ និងខណៈដែលចប់ពាក្យ ជាពេលព្រមគ្នា ទើបប្រើបាន** ។ តែបើកាលពាក្យនៅមិនទាន់ចប់សសរធ្លាក់ចុះមុន, ឬកាលសសរនោះ នៅមិនទាន់ដាក់ចុះ ពាក្យចប់មុន កប្បិយកុដិ **មិនជាការបានធ្វើ** ។ ព្រោះហេតុនោះឯងក្នុងមហាបច្ចរី លោកទើបពោលថា "ភិក្ខុច្រើនរូប គប្បីឈរព័ទ្ធជុំវិញហើយពោល ។ ព្រោះថា ការចប់ពាក្យនិងការដាក់ចុះនៃសសររបស់ភិក្ខុមួយរូប ក្នុងចំណោមភិក្ខុទាំងនេះ នឹងមានព្រមគ្នាបានដោយពិត ។ ក៏ឯក្នុងកុដិទាំងឡាយ ដែលមានជញ្ជាំងធ្វើដោយឥដ្ឋ ថ្ម ឬដី នឹង-កឡើងក៏ដោយ, មិន-កឡើងក៏ដោយ ភិក្ខុទាំងឡាយប្រាថ្នានឹងបណ្ដុះជញ្ជាំងឡើងអំពីឥដ្ឋ ឬថ្មដុំដីណា គប្បីកាន់យកឥដ្ឋ ឬថ្ម ឬដុំដីនោះជាដំបូងបង្អស់ ធ្វើកប្បិយកុដិ តាមន័យដែលពោលហើយនោះឯង, តែឥដ្ឋជាដើម

*ដែលក-ឡើងលើផែនដីខាងក្រោមនៃដុំឥដ្ឋដំបូងជាដើម នៃជញ្ជាំង មិនគួរ (ព្រោះជារបស់លិចនៅក្នុងដី) ។* ***ចំណែកសសរ រមែង ឡើងខាងលើ ព្រោះហេតុនោះ រមែងគួរ ។***

*ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថាៈ*

★ **យតោ បដ្ឋាយាតិ** យតោ ឥដ្ឋកាទិតោ បដ្ឋាយ យំ អាទឹ កត្វា ភិត្តិំ ឧដ្ឋាបេតុកាមាតិ អត្ថោ ។

*ពាក្យថា* ***អំពីឥដ្ឋ ឬថ្ម ដុំដីណា*** *ដូច្នេះ មានសេចក្តីថា ចាប់ផ្តើមអំពីឥដ្ឋជាដើមណា, អធិប្បាយថា មានប្រាថ្នាដើម្បី ធ្វើនូវឥដ្ឋណាឱ្យជាខាងដើម ហើយតម្កល់ទុកនូវជញ្ជាំង ។*

★ **"ថម្ភា បន ឧបរិ ឧគ្គច្ឆន្តិ, តស្មា វដ្ដន្តី"តិ** ឯតេន ឥដ្ឋកបាសាណា ហេដ្ឋា បតិដ្ឋាបិតាបិ យទិ ថម្ភតោ ភូមិតោ វា ឯកង្គុលមត្តម្បិ ឧគ្គតា តិដ្ឋន្តិ, វដ្ដន្តីតិ សិទ្ធំ ហោតិ ។ *ដោយពាក្យនេះថា* ***"ចំណែកសសរ រមែងឡើង ទៅលើ ព្រោះហេតុនោះ រមែងគួរ"*** *ដូច្នេះ លោកសម្រេចថា ប្រសិនបើឥដ្ឋ និងថ្មទាំងឡាយ សូម្បីដែលតម្កល់ទុកហើយ ខាងក្រោមដោយការក-ឡើង, ឬថារមែងតាំងនៅខ្ពស់អំពីផែនដី សូម្បីត្រឹមតែ ១ អង្គុលី រមែងគួរ ។*

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>

★ គោនិសាទិកំ ទុវិធំ អារាមគោនិសាទិកា វិហារគោនិសាទិកាតិ ។ តាសុ យត្ថ នេវ **អារាមោ** ច **សេនាសនានិ** បរិក្ខិត្តានិ ហោន្តិ, អយំ "អារាមគោ-និសាទិកា" នាម ។ យត្ថ សេនាសនានិ សព្វានិ វា ឯកច្ចានិ វា បរិក្ខិត្តានិ អារាមោ អបរិក្ខិត្តោ អយំ **"វិហារគោនិសាទិកា" នាម** ។ ឥតិ ឧភយត្រាបិ អារាមស្ស អបរិក្ខិត្តភាវោយេវ បមាណំ ។ អារាមោ បន **ឧបឌ្ឍបរិក្ខិត្តោបិ** ពហុតរំ បរិក្ខិត្តោបិ បរិក្ខិត្តោ-យេវ នាមាតិ កុរុន្ទិមហាបច្ចរិយាទីសុ វុត្តំ ។ ឯត្ថ **កប្បិយកុដី លទ្ធុំ វដ្ដតិ** ។ *កប្បិយកុដិ ឈ្មោះគោនិសាទិកា មានពីរយ៉ាងគឺ អារាមគោនិសាទិកា ១ វិហារ-គោនិសាទិកា ១ ។ ក្នុងពីរយ៉ាងនោះ ក្នុងវត្តណា* ***អារាម*** *ក៏មិនបានព័ទ្ធព័ទ្ធ, សេនាសនៈទាំងឡាយ ក៏មិនបានព័ទ្ធព័ទ្ធ វិហារនេះឈ្មោះថា* ***អារាមគោនិសាទិកា****, ក្នុងវត្តណា* ***សេនាសនៈ*** *ព័ទ្ធព័ទ្ធទាំងអស់ ឬព័ទ្ធព័ទ្ធខ្លះ អារាមមិនបានព័ទ្ធព័ទ្ធ វិហារនេះឈ្មោះថា* ***វិហារគោនិសាទិកា*** *។ ភាវៈនៃអារាមដែលមិនបានព័ទ្ធព័ទ្ធនោះឯង ជាប្រមាណក្នុងគោនិសាទិកាទាំងពីរយ៉ាង ដោយ*

*ប្រការដូច្នេះ ។ តែក្នុងកុរុន្ទី និងមហាបច្ចរីពោលថា "អារាម ដែលព័ទ្ធព័ទ្ធពាក់កណ្តាលក្តី ឡោមព័ទ្ធច្រើនជាងពាក់កណ្តាលក្តី ចាត់ជាអារាមដែលឡោមព័ទ្ធបាន" ។ ក្នុងអារាមដែលឡោមព័ទ្ធ ពាក់កណ្តាលជាដើមនេះ គួរនឹងបានជាកប្បិយកុដិ ។*

<u>*ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:*</u>

★ អារាមោតិ ឧបចារសីមាបរិច្ឆិន្នោ សកលោ វិហារោ ។ *ពាក្យថា **អារាម** ដូច្នេះ បានដល់ វិហារទាំងមូល ដែលបិទបាំងដោយឧបចារៈសីមា ។*

★ **សេនាសនានីតិ** វិហារស្ស អន្តោ តិណកុដិ-អាទិកានិ សង្ឃស្ស និវាសគេហានិ ។ *ពាក្យថា **សេនាសនៈ** ដូច្នេះ បានដល់ កុដិជាទីនៅនៃសង្ឃ មានកុដិស្មៅ ជាដើម ដែលនៅខាងក្នុងនៃវិហារ ។*

★ **វិហារគោនិសាទិកា នាមាតិ** សេនាសនគោនិ-សាទិកា ។ សេនាសនានិ ហិ សយំ បរិក្ខិត្តានិបិ អារាមបរិក្ខេបាភាវេន "គោនិសាទិកានី"តិ វុត្តានិ ។

*សេនាសនគោនិសាទិកា ឈ្មោះថា វិហារគោនិសាទិកា ។ ព្រោះថា សេនាសនទាំងឡាយ សូម្បីឡោមព័ទ្ធហើយដោយ ខ្លួនឯង លោកហៅថា **គោនិសាទិកា** ព្រោះមិនមានការឡោម*

ព័ទ្ធនូវអារាម ។

★ **"ឧបឌ្ឍបរិក្ខិត្តោបី"តិ** ឥមិនា តតោ ឩនបរិក្ខិត្តោ យេភុយ្យេន អបរិក្ខិត្តោ នាម, តស្មា អបរិក្ខិត្តសង្ខ្យមេវ គច្ឆតីតិ ទស្សេតិ ។ ដោយពាក្យថា *សូម្បីឡោមព័ទ្ធពាក់កណ្តាល* ដូច្នេះ លោកអាចារ្យសម្តែងថា បើឡោមព័ទ្ធតិចជាងពាក់កណ្តាលនោះ ឈ្មោះថា មិនបានឡោមព័ទ្ធដោយច្រើន ព្រោះហេតុនោះ រមែងដល់នូវការរាប់ថា មិនបានឡោមព័ទ្ធពិត ។

★ **កប្បិយកុដឹ លទ្ធុំ វដ្តតីតិ** គោនិសាទិយា អភាវេន សេសកប្បិយកុដីសុ តីសុ យា កាចិ កប្បិយកុដិ កាតព្វាតិ អត្ថោ ។ ពាក្យថា *រមែងគួរដើម្បីបាននូវកប្បិយកុដិ* ដូច្នេះ មានសេចក្តីអធិប្បាយថា បណ្តាកប្បិយកុដិបីដ៏សេស គឺភិក្ខុគប្បីធ្វើនូវកប្បិយកុដិណាមួយ ព្រោះកប្បិយកុដិឈ្មោះ គោនិសាទិកា មិនមាន ។

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>

បទថា **គហបតិ** មានសេចក្តីថា មនុស្សទាំងឡាយ ធ្វើអាវាសហើយពោលថា "**កប្បិយកុដឹ ទេម, បរិភុញ្ជថ**" "ខ្ញុំព្រះករុណា ប្រគេនកប្បិយកុដិ, សូមលោកម្ចាស់ប្រើប្រាស់ចុះ" កប្បិយកុដិនេះ ឈ្មោះថា **គហបតិកុដិ** ។ សូម្បីគេពោល

ថា "កប្បិយកុដី កាតុំ ធេម" "ខ្ញុំម្ចាស់ប្រគេនដើម្បីធ្វើកប្បិយកុដិ" ដូច្នេះ **រមែងគួរដូចគ្នា** ។ ចំណែកក្នុងអដ្ឋកថាកែថា "វត្ថុដែលទទួលអំពីដៃរបស់សហធម្មិកៈដ៏សេស វៀរភិក្ខុចេញផង វត្ថុដែលទទួលអំពីដៃរបស់ទេវតា និងមនុស្សទាំងពួងផង វត្ថុជាសន្និធិ និងវត្ថុជាអន្តោវុត្ថផង ដែលជារបស់សហ-ធម្មិកដ៏សេស និងជារបស់ទេវតាមនុស្សទាំងនោះ, រមែងគួរដល់ភិក្ខុ ព្រោះហេតុនោះ **ផ្ទះនៃជនទាំងនោះ** ឬកប្បិយកុដិដែលជនទាំងនោះប្រគេន ទើបហៅថា **"គហបតិ"** ។ មិនតែប៉ុណ្ណោះទេលោកពោលទៀតថា "**វៀរតែវិហាររបស់ភិក្ខុសង្ឃចេញ** ទីលំនៅរបស់ពួកនាងភិក្ខុនី ឬពួកអារាមិកបុរស ឬពួកតិរ្ថិយ ឬរបស់ពួកទេវតា ឬរបស់ពួកនាគ ឬសូម្បីវិមានរបស់ពួកព្រហ្ម រមែងជាកប្បិយកុដិបាន" ពាក្យនោះលោក ពោលប្រពៃហើយ, ព្រោះថា**កុដិជារបស់សង្ឃក្ដី ជារបស់ភិក្ខុក្ដី** ជាកុដិរបស់គហបតិ**មិនបាន** ។ កប្បិយកុដិដែលភិក្ខុសូធ្យប្រកាសធ្វើដោយកម្មវាចាឈ្មោះថា **សម្មតិកា** ដូច្នេះឯង ។

### កប្បិយភូមិមាន ៥ ព្រោះថែម ១ ទៀត

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

★ **តេសំ គេហានីតិ** ឯត្ថ ភិក្ខូនំ វាសត្ថាយ

កតម្បិ យាវ ន ទេន្តិ, តាវ តេសំ សន្តកាំយេវ ភវិស្សតីតិ ធម្ពត្តំ ។ *ក្នុងពាក្យថា* ***ផ្ទះរបស់ជនទាំងឡាយនោះ*** *ដូច្នេះ បណ្ឌិតគប្បីជ្រាបថា សូម្បីជនទាំងឡាយ គេធ្វើហើយ ដើម្បីប្រយោជន៍ដល់ការនៅរបស់ភិក្ខុទាំងឡាយ តែមិនទាន់ប្រគេនដរាបណា ទីនជារបស់ជនទាំងឡាយនោះ ដរាបនោះដដែល ។*

✯ **វិហារំ ឋបេត្វាតិ** ឧបសម្បន្នានំ វាសត្ថាយ កតគេហំ ឋបេត្វាតិ អត្ថោ ។ *ពាក្យថា* ***វៀរតែវិហារ*** *ដូច្នេះ មានសេចក្តីអធិប្បាយថា វៀរលែងតែកុដិដែលគេធ្វើហើយ ដើម្បីប្រយោជន៍ដល់ការនៅរបស់ឧបសម្បន្នទាំងឡាយ ។*

✯ **គេហាន្តិ** និវាសគេហំ, តតញ្ញំ បន ឧបោសថាគារាទិ សព្វំ អនិវាសគេហំ ចតុកប្បិយភូមិវិមុត្តា បញ្ចមីកប្បិយភូមិ ។ សង្ឃសន្តកេបិ ហិ ឯតាទិសេ គេហេ សុដ្ឋុ បរិក្ខិត្តារាមត្តេបិ អព្ភោកាសេ វិយ អន្តោវុត្ថាទិ ទោសោ នត្ថិ ។ *ពាក្យថា* ***កុដិ*** *ដូច្នេះ បានដល់កុដិ សម្រាប់នៅ, តែថា កុដិមិនមែនជាទីនៅទាំងអស់ មានរោងឧបោសថជាដើម ដទៃអំពីទីសម្រាប់នៅនោះចេញ* ***រមែងជាកប្បិយភូមិទី ៥*** *ព្រោះរួចផុតចាកអំពីកប្បិយភូមិទាំង ៤ ។ ព្រោះថាក្នុងកុដិ*

មានសភាពដូច្នោះ សូម្បីជារបស់សង្ឃ ទោសមានអន្តោវុត្ថជាដើម រមែងមិនមានទេ ដូចជាទុកក្នុងទីកណ្តាលវាលដែរ សូម្បីក្នុងអារាមដែលគេឡោមព័ទ្ធហើយដោយល្អ ។

ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថាៈ

★ **សង្ឃសន្តកមេវាតិ** វាសត្ថាយ កតំ សង្ឃិក-សេនាសនំ សន្ធាយ វទតិ ។ ពាក្យថា **របស់សង្ឃ** ដូច្នេះ គឺលោកអាចារ្យពោលសំដៅយក នូវសេនាសនៈរបស់សង្ឃ ដែលគេធ្វើហើយដើម្បីប្រយោជន៍ដល់ការនៅ ។

★ **ភិក្ខុសន្តកន្តិ** វាសត្ថាយ ឯវ កតំ ភិក្ខុស្ស បុគ្គលិកសេនាសនំ ។ ពាក្យថា **របស់ភិក្ខុ** ដូច្នេះ បានដល់ សេនាសនៈចំណែកបុគ្គល របស់ភិក្ខុដែលគេធ្វើហើយដើម្បីប្រយោជន៍ដល់កាលនៅប៉ុណ្ណោះ ។

ក្នុងគម្ពីរអដ្ឋកថា ពោលថាៈ

អាមិសណា ទុកដាក់នៅក្នុងកប្បិយភូមិទាំង ៤ នេះ, អាមិសទាំងអស់មិនរាប់ថាជា **អន្តោវុត្ថទេ** ។ ព្រោះថា កប្បិយ-កុដិ ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតដើម្បីឱ្យរួចពី **អន្តោវុត្ថ** និង **អន្តោបក្ក** របស់ភិក្ខុ និងភិក្ខុនីទាំងឡាយ ។ ចំណែកក្នុង អកប្បិយភូមិ អាមិសណាជារបស់សង្ឃក្តី ជារបស់បុគ្គលក្តី

ជារបស់ភិក្ខុ ឬភិក្ខុនីក្តី ដែលទុកដាក់ខាងក្នុងកុដិ ដែលល្មមនឹងឱ្យកើតអាបត្តិ ព្រោះសហសេយ្យបាន សូម្បីតែមួយរាត្រី, អាមិសនោះជាអន្តោវុត្ថ, និងអាមិសដែលចំអិនក្នុងកុដិនោះរមែងចាត់ជាអន្តោបក្កៈ, អាមិសនោះ មិនគួរ ។ តែរបស់ដែលជា សត្តាហកាលិក និង យាវជីវិក គួរ ។

វិនិច្ឆ័យក្នុងអន្តោវុត្ថ និងអន្តោបក្កៈនោះ បណ្ឌិតគប្បីជ្រាបដូច្នេះ ៖ សាមណេរនាំអាមិសមានអង្ករជាដើម របស់ភិក្ខុមកទុកដាក់ក្នុងកប្បិយកុដិ ព្រឹកឡើងចំអិនមកប្រគេនអាមិសនោះមិនជាអន្តោវុត្ថទេ ។ សាមណេរយកវត្ថុណាមួយមានសប្បិជា-ដើមដែលទុកដាក់ក្នុងអកប្បិយកុដិ ដាក់ចុះក្នុងអាមិសមានបាយជាដើមនោះ ប្រគេនអាមិសនោះចាត់ជាមុខសន្និធិ ។ តែក្នុងមហាបច្ចរីពោលថា "អាមិសនោះ ជាអន្តោវុត្ថ" ។ ការធ្វើផ្សេង-គ្នាក្នុងមុខសន្និធិ និងអន្តោវុត្ថនោះ ក៏ត្រឹមតែឈ្មោះប៉ុណ្ណោះ ។

## មុខសន្និធិ តែជាអាបត្តិទុក្កដ

<u>ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:</u>

★ "មុខសន្និធិ នាម ភោជនកាលេ សន្និធី"តិ លិខិតំ ។ មុខសន្និធិតិ តស្ស នាមំ ។ "យទិ សន្និធិ ហោតិ, បាចិត្តិយំ ករេយ្យ, មុខសន្និធិ បន ទុក្កដំ, តស្មា

សន្និធិ អនធិប្បេតា"តិ វុត្តំ ។ លោកសរសេរទុកថា "សន្និធិ ក្នុងកាលបរិភោគ ឈ្មោះថា **មុខសន្និធិ**" ។ ពាក្យថា **មុខសន្និធិ** ដូច្នេះ ជាឈ្មោះនៃការបរិភោគនោះ ។ លោកពោលទុកថា "ប្រសិនបើជាសន្និធិ គប្បីត្រូវអាបត្តិបាចិត្តិយ, តែមុខសន្និធិនេះ ជាអាបត្តិទុក្កដ ព្រោះហេតុនោះ សន្និធិ (ដែលជាអាបត្តិបាចិត្តិយ) គឺលោកមិនបំណងយកទេ ។

## សត្តាហកាលិកជាដើម ចំអិនលាយនឹងអាមិស

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>

ភិក្ខុយកសប្បិ ដែលទុកដាក់ក្នុងអកប្បិយកុដិ និងស្លឹកឈើដែលជាយាវជីវិក ចំអិនជាមួយគ្នាហើយឆាន់របស់នោះ ជារបស់ប្រាស់ចាកអាមិស គួរឆាន់បាន ៧ ថ្ងៃ ។ បើភិក្ខុឆាន់លាយប្រឡំនិងអាមិស របស់នោះជាអន្តោវុត្ថផង ជាសាមបក្កៈផង ។ ការលាយប្រឡំគ្នានៃកាលិកគ្រប់យ៉ាង គប្បីជ្រាបដោយឧបាយនេះ ។

សួរថា ក៏កប្បិយកុដិទាំងនេះ កាលណានឹងលះវត្ថុសោត ឆ្លើយថា គួរជ្រាបឧស្សាវនន្តិកាមុន, កប្បិយកុដិណា ដែលគេធ្វើលើសសរ ឬក្នុងជើងជញ្ជាំង កប្បិយកុដិនោះ នឹងលះវត្ថុចំពោះកាលសសរ និងជើងជញ្ជាំងទាំងពួងត្រូវរើចេញហើយ ។

តែបើមនុស្សទាំងឡាយផ្លាស់សសរ ឬជើងជញ្ជាំងចេញសសរ ឬជើងជញ្ជាំងណាឋិតនៅ កប្បិយកុដិ រមែងឋិតនៅក្នុងសសរ ឬជើងជញ្ជាំងនោះ, តែរមែងលះវត្ត ចំពោះកាលដែលសសរ ឬជើងជញ្ជាំង ត្រូវប្តូរហើយទាំងអស់ ។ កប្បិយកុដិដែល-ក ដោយឥដ្ឋជាដើម រមែងលះវត្ត ក្នុងវេលាដែលវត្ថុផ្សេងៗជា ដើមថា ឥដ្ឋ ឬថ្ម ឬដុំដី ដែលដាក់ទុកដើម្បីរេងជញ្ជាំងលើទី ដែល-កឡើង ជារបស់វិនាសទៅហើយ ។ ចំណែកកប្បិយកុដិ ដែលអធិដ្ឋានដោយឥដ្ឋជាដើមទាំងឡាយណា កាលឥដ្ឋជាដើម ទាំងនោះសូម្បីត្រូវរើចេញហើយ តែឥដ្ឋជាដើមដទៃអំពីឥដ្ឋដើម នោះមាននៅសល់, កប្បិយកុដិនៅមិនទាន់លះវត្តទេ ។ កប្បិយ កុដិឈ្មោះ **គោនិសាទិកា** រមែងលះវត្ត ចំពោះកាលគេធ្វើការ ព័ទ្ធព័ទ្ធដោយកំពែងជាដើម ។ ភិក្ខុគួរបានកប្បិយកុដិ ក្នុង អារាមនោះទៀត (គឺត្រូវធ្វើកប្បិយកុដិ ៣ ដ៏សេសទៀត) ។

**អារាមដែលមិនបានឡោមព័ទ្ធច្រើនជាងពាក់កណ្តាល**

**ទើបហៅថាជា គោនិសាទិកា**

<u>ក្នុងគម្ពីរអដ្ឋកថា ពោលទៀតថា:</u>

សចេ បន បុនបិ ឞាការាទយោ តត្ថ **តត្ថ ខណ្ឌា ហោន្តិ**, តតោ តតោ គាវោ បវិសន្តិ, បុន កប្បិយកុដិ

ហោតិ ។ ឥតរា បន ទ្វេ គោបានសីមត្ថំ ឋបេត្វា សព្វត្ថ ឆនេន វិនដ្ឋេ ជហិតវត្ថុកា ហោន្តិ ។ សចេ គោបានសីនំ ឧបរិ ឯកម្បិ បក្ខបាសកមណ្ឌលំ អត្ថិ រក្ខតិ ។ *តែបើគ្រឿងឡោមព័ទ្ធមានកំពែងជាដើម ជារបស់បាក់ទៅក្នុងទីនោះៗសូម្បីទៀត គោទាំងឡាយរមែងចូលទៅតាមផ្លូវបាក់នោះៗ កុដិនោះ រមែងត្រឡប់ជាកប្បិយកុដិទៀត ។ ចំណែកកប្បិយកុដិពីរប្រភេទក្រៅនេះ នឹងលះវត្ថុចំពោះកាលគ្រឿងប្រក់ទាំងពួងអស់ទៅ សល់ត្រឹមតែបង្កង់ ។ បើលើបង្កង់ទាំងឡាយ នៅមានគ្រឿងប្រក់ជាចំណែកជាប់គ្នាជាកណ្ដុបសូម្បីមួយ ក៏នៅរក្សា ។*

*<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>*

★ **តត្ថ តត្ថ ខណ្ឌា ហោន្តីតិ** ឧបឡោ អធិកាំ ខណ្ឌា ហោន្តិ ។ *ពាក្យថា រមែងដាច់ទៅក្នុងទីនោះៗ ដូច្នេះមានសេចក្ដីថា រមែងដាច់ទៅច្រើនជាងពាក់កណ្ដាល ។*

**បើគ្មានកប្បិយភូមិ ត្រូវឱ្យដល់សាមណេរ**

*<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>*

★ យត្រ បនិមា ចតស្សោបិ កប្បិយភូមិយោ នត្ថិ

តត្ថ កឹ កាតព្វំ ។ **អនុបសម្បន្នស្ស ទត្វា តស្ស** សន្តកំ កត្វា បរិភុញ្ជិតព្វំ ។

*<u>សួរថា:</u> ក៏ក្នុងវត្តណាមិនមានកប្បិយភូមិទាំង ៤ នេះ ក្នុងវត្តនោះឯង គប្បីធ្វើយ៉ាងណា ?*

*<u>ឆ្លើយថា:</u> ភិក្ខុគប្បីឱ្យដល់អនុបសម្បន្ន ធ្វើឱ្យជារបស់លោក ហើយឆាន់ចុះ ។*

*<u>ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:</u>*

★ **អនុបសម្បន្នស្ស ទត្វាតិ** អនបេក្ខវិស្សជ្ជនេន អនុបសម្បន្នស្ស ទត្វា ។ ចីវរវិកប្បនំ វិយ សាបេក្ខ-វិស្សជ្ជនម្បិ វដ្ដតីតិ វទន្តិ ។ *ពាក្យថា ឱ្យដល់អនុបសម្បន្ន ដូច្នេះ មានសេចក្ដីថា ឱ្យដល់អនុបសម្បន្ន ដោយមិនមានសេចក្ដីអាល័យ ។ អាចារ្យទាំងឡាយពោលថា សូម្បីលះបង់ដោយមានសេចក្ដីអាល័យ* **រមែងគួរ** *ដូចជាការវិកប្បនូវចីវរ (គឺវិកប្បហើយ, ក្រោយមកទៅយកវិញ) ។*

*<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>*

★ **អនុបសម្បន្នស្ស ទាតព្វោ អស្សាតិអាទិនា** អកប្បិយកុដិយំ វុត្ថម្បិ អនុបសម្បន្នស្ស ទិន្នេ កប្បិយំ ហោតិ, សាបេក្ខទានញ្ចេត្ថ វដ្ដតិ, បដិគ្គហណំ វិយ ន

ហោតីតិ ឥស្សេតិ ។

*ដោយពាក្យជាដើមថា* ***គប្បីឱ្យដល់អនុបសម្បន្ន*** *ធ្វើឱ្យជារបស់លោក ដូច្នេះនេះ មានសេចក្ដីថា* ***កាលភិក្ខុឱ្យដល់អនុបសម្បន្នហើយ*** *សូម្បីទុកហើយក្នុងអកប្បិយកុដិ រមែងជាកប្បិយ ។ លោកអាចារ្យសម្ដែងថា ការឱ្យដោយមានសេចក្ដីអាល័យ* ***រមែងគួរ*** *ក្នុងសេចក្ដីនេះ, ដូចជាការទទួលរមែងមិនមាន ។*

**កប្បិយភូមិកថាចប់ ។**

# ១៧_អកប្បិយសមាទបេតព្វកថា

ក្នុងវិនយបិដកភាគ ៧ ទំព័រ ៣៧៦ ពោលថា:

★ ន ភិក្ខវេ បព្វជិតេន **អកប្បិយេ សមាទបេតព្វំ** យោ សមាទបេយ្យ អាបត្តិ ទុក្កដស្ស ។ ម្នាលភិក្ខុទាំងឡាយ បព្វជិតមិនត្រូវបបួលគេ ឱ្យធ្វើក្នុងអំពើដែលមិនគួរទេ បព្វជិតណាបបួល ត្រូវអាបត្តិទុក្កដ ។

ក្នុងគម្ពីរខុទ្ទកសិក្ខាបុរាណដីកា ពោលថា:

★ អកប្បិយសមាទានេតិ ភិក្ខុ វា សាមណេរាទិកេ សហធម្មិកេ វា អកប្បិយេ និយោជេន្តស្ស ទុក្កដមេវ ។ ន ភិក្ខវេ បព្វជិតេន អកប្បិយេ សមាទបេតព្វំ យោ សមាទបេយ្យ អាបត្តិ ទុក្កដស្សាតិ ហិ វុត្តំ ។ ពាក្យថា បបួលគេឱ្យធ្វើក្នុងអំពើដែលមិនគួរ ដូច្នេះ មានសេចក្តីថា ជាទុក្កដដល់ភិក្ខុកាលបបួលនូវភិក្ខុក្តី នូវសហធម្មិកមានសាមណេរជាដើមក្តី ក្នុងអំពើដែលមិនគួរ ។ ព្រោះព្រះមានព្រះភាគ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ បព្វជិតមិនត្រូវបបួលគេឱ្យធ្វើ ក្នុងអំពើដែលមិនគួរទេ បព្វជិតណាបបួល ត្រូវអាបត្តិទុក្កដ" ដូច្នេះ ។

ក្នុងគម្ពីរកង្ខាវិតរណី ភាគ១ ទំព័រ៦៥ ពោលថា:

អាណាតិយា អនាបជ្ជិតព្វតោ អនាណត្តិកំ ។ ភិក្ខុ

**បន អាណាបេន្តោ អកប្បិយសមាទានាបត្តិយា ន មុច្ចតិ ។**
បឋមបារាជិកសិក្ខាបទនេះ ជាអនាណត្តិក ព្រោះមិនបានត្រូវអាបត្តិដោយការបង្គាប់ឡើយ ។ តែថា ភិក្ខុកាលបង្គាប់ រមែងមិនរួចផុតចាកអាបត្តិ ព្រោះអកប្បិយសមាទានឡើយ ។

<u>ក្នុងព្រះអដ្ឋកថា ចីវរសិព្វនសិក្ខាបទ ពោលថា:</u>

★ អាចារ្យ និងឧបជ្ឈាយ៍ ប្រើឱ្យពួកអន្តេវាសិកឱ្យដេរ (ចីវរ) ដើម្បីពួកភិក្ខុនី អ្នកជាញាតិរបស់ខ្លួន, ជាទុក្កដ ដល់អាចារ្យ និងឧបជ្ឈាយ៍ ។ ជា**បាចិត្តិយ** ដល់ពួកអន្តេវាសិក ។ ពួកអន្តេវាសិក និមន្តឱ្យអាចារ្យ និងឧបជ្ឈាយ៍ ឱ្យជួយដេរ (ចីវរ) ដើម្បីពួកភិក្ខុនី ជាញាតិរបស់ខ្លួន, សូម្បីក្នុងការដែលអន្តេវាសិកនិមន្តឱ្យអាចារ្យ និងឧបជ្ឈាយ៍ឱ្យជួយដេរនោះ ក៏មានន័យដូចគ្នា ។ ចីវរជារបស់ភិក្ខុនី អ្នកជាញាតិទាំងចំណែកអន្តេវាសិក ទាំងចំណែកអាចារ្យនិងឧបជ្ឈាយ៍ ។ **តែអាចារ្យនិងឧបជ្ឈាយ៍បញ្ឆោត**ពួកអន្តេវាសិកឱ្យដេរ (ចីវរ) ជាទុក្កដ ដល់អ្នកទាំង ២ ចំណែក ។ ព្រោះហេតុអ្វី? ព្រោះចីវរពួកអន្តេវាសិកដេរ ដោយសេចក្តីសម្គាល់ថា មិនមែនញាតិ(និង) ព្រោះអាចារ្យនិងឧបជ្ឈាយ៍ក្រៅនេះ **ដឹកនាំក្នុងវត្ថុដែលមិនគួរ** ។

<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:</u>

★ **អាចរិយុបជ្ឈាយានំ ទុក្កដន្តិ** អកប្បិយសមាទានវសេន ទុក្កដំ ។ ពាក្យថា ជាទុក្កដដល់អាចារ្យ និងឧបជ្ឈាយ៍ ដូច្នេះនេះ មានសេចក្តីថា ជាទុក្កដដោយអំណាចការបបួលក្នុងអំពើដែលមិនគួរ ។

<u>ក្នុងគម្ពីរសារត្ថទីបនី និងវិមតិវិនោទនីដីកា ពោលថា:</u>

★ **វញ្ចេត្វាតិ** "តវ ញាតិកាយោ"តិ អវត្វា "ឯកិស្សា ភិក្ខុនិយា"តិ ឯតកមេវ វត្វា ។ ឯកិស្សា ភិក្ខុនិយាតិ សុត្វា តេ អញ្ញាតិកសញ្ញិនោ ភវេយ្យុន្តិ អាហ អកប្បិយេ និយោជិតត្តាតិ ។ ពាក្យថា **បញ្ឆោត** ដូច្នេះនេះ មានសេចក្តីថា អាចារ្យមិនពោលថា "នេះជាចីវររបស់ភិក្ខុនីដែលជាញាតិរបស់លោក" ដូច្នេះទេ, ពោលត្រឹមតែប៉ុណ្ណេះថា "នេះជាចីវររបស់ភិក្ខុនី ១ រូប" ដូច្នេះ អន្តេវាសិកនោះ បានស្តាប់ថា "របស់ភិក្ខុនី ១ រូប" ដូច្នេះ ហើយបានជាអ្នកមានសេចក្តីសំគាល់ថា "មិនមែនជាញាតិ" ព្រោះហេតុនោះ ទើបអដ្ឋកថា-ចារ្យ ទើបពោលថា ព្រោះលោកអាចារ្យ និងឧបជ្ឈាយ៍បបួលក្នុងកម្មដែលមិនគួរ ។

**អកប្បិយសមាទបេតព្វកថាចប់ ។**

# ១៨-បល្លង្កាសនកថា

<u>ក្នុងវិនយបិដកភាគ ៧ ទំព័រ១៩៧ ត្រាស់ថា:</u>

★ ន ភិក្ខវេ បល្លង្កោ ធារេតព្វោ, យោ ធារេយ្យ អាបត្តិ ទុក្កដស្ស ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវប្រើគ្រែដែលមានជើងវិចិត្រ ដោយរូបសត្វសាហាវទេ, ភិក្ខុណាប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

<u>ក្នុងវិនយបិដកភាគ ១០ ទំព័រ៣៣៨ ព្រះអង្គត្រាស់ថា:</u>

★ អនុជានាមិ, ភិក្ខវេ, បល្លង្កស្ស វាឡេ ភិន្ទិត្វា បរិភុញ្ជិតុំ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យទំលាយរូបសត្វសាហាវ នៃគ្រែមានជើងវិចិត្រ ដោយរូបសត្វសាហាវ ហើយសឹមប្រើប្រាស់ ។

<u>ក្នុងវិនយបិដកភាគ ៥ ទំព័រ ២៦៧ ពោលថា:</u>

★ បល្លង្កោ នាម អាហរិមេហិ វាឡេហិ កតោ ។ ដែលហៅថា បល្លង្ក គឺ បានដល់វត្ថុដែលគេធ្វើ ដោយរូបសត្វសាហាវ ដែលនាំទៅមកបាន ។

<u>*ក្នុងគម្ពីរវិនយសង្គហដ្ឋកថា ពោលថា:*</u>

★ **បល្លង្កោតិ** ធាតេសុ វាឡរូបានិ ឋបេត្វា កតោ ។ *ដែលហៅថា បល្លង្ក គឺបានដល់វត្ថុដែលគេធ្វើដោយការតម្កល់ទុកនូវរូបសត្វសាហាវ ត្រង់ជើងទាំងឡាយ ។*

<u>*ក្នុងគម្ពីរសីលក្ខន្ធវគ្គអភិនវដីកា ពោលថា:*</u>

★ វាឡរូបានីតិ អាហរិមានិ សីហព្យគ្ឃាទិវាឡ-រូបានិ ។ វុត្តញ្ហិ ភិក្ខុនីវិភង្គេ "បល្លង្កោ នាម អាហរិមេហិ វាឡេហិ កតោ"តិ វុត្តំ ។ *ពាក្យថា **រូបសត្វសាហាវ** ដូច្នេះ គឺបានដល់រូបសត្វសាហាវ មានសីហៈនិងខ្លាធំជាដើម ដែលនាំទៅមកបាន ។ សមដូចពាក្យដែលលោកពោលទុក ក្នុងភិក្ខុនីវិភង្គថា "ដែលហៅថា **បល្លង្ក** គឺបានដល់ វត្ថុដែលគេធ្វើដោយរូបសត្វសាហាវ ដែលនាំទៅមកបាន" ។*

<u>*ក្នុងគម្ពីរខុទ្ទកសិក្ខាបុរាណដីកា ពោលថា:*</u>

★ បល្លង្កោ នាម អាហរិមេហិ វាឡេហិ កតោតិ វុត្តោ ។ តត្ថេវ សីហរូបាទី ធរេត្វា កតោ បន វដ្ដតីតិ វទន្តិ ។ *ដែលឈ្មោះថា **បល្លង្ក** ដូច្នេះ គឺលោកពោលហើយថាធ្វើដោយរូបសត្វសាហាវដែលនាំទៅបាន ។ អាចារ្យទាំងឡាយ*

ពោលថា "តែបើសម្ដែងនូវរូបសត្វសីហៈជាដើម ហើយធ្វើទុកត្រង់ជើងនោះឯង រមែងគួរ" ។

<u>ក្នុងគម្ពីរខុទ្ទកសិក្ខាបុរាណដីកា ពោលទៀតថា:</u>

★ វាឡមិគគ្គហណេន វុត្តាវសេសា អន្តមសោ គោមហឹសាទយោ គហិតាតិ វេទិតព្វា ។ បណ្ឌិតគប្បីជ្រាបថា សត្វម្រឹគដ៏សេស អំពីលោកពោលហើយ ដោយហោចទៅសូម្បីសត្វគោក្របីជាដើម គឺលោកកាន់យកហើយ ដោយសព្ទថា វាឡមិគ : គឺសត្វម្រឹគសាហាវ ។

<u>ក្នុងគម្ពីរវិនយវិនិច្ឆយដីកា ពោលថា:</u>

★ "បល្លង្កោ ឆាម អាហរិមេហិ វាឡេហិ កតោ"តិ វចនតោ បមាណយុត្តោបិ ឯវរូបោ ន វដ្ដតិ ។ អាហរិត្វា យថាឆូរូបដ្ឋានេ ឋបេតព្វវាឡរូបានិ អាហរិមវាឡា ឆាម, សំហរិមវាឡរូបយុត្តោតិ វុត្តំ ហោតិ ។ ដោយពាក្យដែលលោកពោលថា "ដែលហៅថា បល្លង្ក គឺបានដល់ វត្ថុដែលគេធ្វើ ដោយរូបសត្វសាហាវ ដែលនាំទៅមកបាន" ដូច្នេះ (ជើងគ្រែ) មានសភាពយ៉ាងនេះ សូម្បីប្រកបដោយប្រមាណក៏មិនគួរដែរ ។ រូបសត្វសាហាវដែលនាំទៅមកបាន ដែលគេគប្បីតម្កល់ទុកក្នុងទីតាមសមគួរ, ឈ្មោះថា រូប

*សត្វសាហាវ ដែលគេនាំទៅមកបាន, ការប្រកបដោយរូបសត្វសាហាវដែលនាំទៅមកបានជាពាក្យដែលលោកពោលហើយ ។*

*ក្នុងគម្ពីរបាចិត្យាទិយោជនា ពោលថា:*

★ **វាឡរូបានីតិ** សីហព្យគ្ឃាទិវាឡរូបានិ ។ បាទេសុ វាឡរូបានិ បរិច្ឆិន្ទិត្វា អត្ថីយតិ លក្ខីយតីតិ បល្លង្កោ ។

*ពាក្យថា រូបសត្វសាហាវ ដូច្នេះ គឺបានដល់រូបសត្វសាហាវមានសីហៈនិងខ្លាធំជាដើម ។ វត្ថុដែលគេកំណត់ (ឆ្លាក់)នូវរូបសត្វសាហាវ ត្រង់ជើងទាំងឡាយ ឱ្យជាគ្រឿងកំណត់សំគាល់ ឈ្មោះថា បល្លង្ក ។*

*ក្នុងគម្ពីរវិនយវិនិច្ឆយដីកា ក្នុងចម្មក្ខន្ធកៈ ពោលថា:*

★ បល្លង្កោតិ បាទេសុ អាហរិមានិ វាឡរូបានិ ឋបេត្វា កតោ, ឯកស្មឹយេវ ទារុម្ហិ កដ្ឋកម្មវសេន ឆិន្ទិត្វា កតានិ អសំហារិមានិ តត្រដ្ឋានេវ វាឡរូបានិ យស្ស បាទេសុ សន្តិ, ឯវរូបោ បល្លង្កោ កប្បតីតិ "អាហរិមេណា"តិ ឥមិនាវ ទីបិតំ ។ *ដែលហៅថា បល្លង្ក ដូច្នេះ គឺបានដល់វត្ថុដែលគេធ្វើការតម្កល់ទុក នូវរូបសត្វសាហាវដែលនាំទៅមកបាន ត្រង់ជើងទាំងឡាយ ។ រូបសត្វសាហាវ*

ដែលនាំទៅមកមិនបាន ដែលគេកាត់ដោយអំណាចនៃកដ្ឋកម្ម ក្នុងឈើតែមួយប៉ុណ្ណោះ ហើយធ្វើក្នុងទីនោះឯង រមែងមានត្រង់ជើងទាំងឡាយណា, (ជើងគ្រែ)មានសភាពដូច្នោះ រមែងគួរ, ព្រោះលោកសម្តែង ដោយពាក្យនេះប៉ុណ្ណោះ ថា "នាំទៅមកបាន" ។

<u>ចំណែកក្នុងគម្ពីរកង្ខាវិតរណីភាគ ៤ ទំព័រ ១០៣</u>

<u>ពោលថា:</u>

★ បល្លង្កោ នាម អសំហារិមេន វាឡេន កតោតិ វុត្តោ ។ ដែលហៅថា បល្លង្ក បានដល់បល្លង្ក ដែលគេធ្វើដោយរូបសត្វសាហាវ ដែលនាំទៅមកមិនបាន ។

**រូបសត្វសាហាវដែលឆ្លាក់ជាប់នឹងជើងគ្រែក៏មិនគួរ**

<u>ក្នុងគម្ពីរវជិរពុទ្ធិដីកា ពន្យល់ថា:</u>

★ "អាហារិមេហិ វាឡេហី"តិ "អសំហារិមេនា"តិ ច ទ្វិធោ បាឋោ ។ "វិសុំ កត្វា បច្ឆា សង្ឃិ តេហិ វាឡេហី"តិ លិខិតំ ។ យថា តថា វាឡរូបេ ឧដ្ឋបេត្វា កតបាទំ "បល្លង្ក"ន្តិ វុច្ចតិ,អនាបត្តិវារេ "អសំហារិមេហិ វាឡេហិ កតំ បរិភុញ្ជតី"តិ វចនាភាវតោ ។ បាលីមាន ២ ប្រការ គឺ "ដោយរូបសត្វសាហាវ ដែលនាំទៅមកបាន ១

ដែលនាំទៅមកមិនបាន១” ។ លោកសរសេរទុកថា (ជើងគ្រែ) ដែលគេធ្វើឱ្យផ្សេងៗគ្នា ហើយ(យកមកភ្ជាប់) មួយអន្លើដោយសត្វសាហាវពួកនោះ ក្នុងកាលជាខាងក្រោយ ។ ជើង (គ្រែ) ដែលគេញ៉ាំងនូវរូបសត្វសាហាវ យ៉ាងណា មួយក៏ដោយ ឱ្យតាំងឡើងប្រាកដ ហើយធ្វើ លោកហៅថា បល្លង្ក, ព្រោះមិនមានពាក្យក្នុងអនាបត្តិថា “ប្រើប្រាស់នូវ (គ្រែ) ដែលគេធ្វើដោយរូបសត្វសាហាវ ដែលនាំទៅមកមិនបានទេ” ។

<u>ក្នុងអនាបត្តិវារៈ ព្រះអង្គត្រាស់ថា:</u>

**១-បល្លង្កស្ស វាឡេ ភិន្ទិត្វា បរិភុញ្ជតិ** ដល់(ភិក្ខុ) ភិក្ខុនីដែលទំលាយនូវរូបសត្វសាហាវ ហើយប្រើប្រាស់ ១ ។

**២-ឧម្មត្តិកាយ** ដល់(ភិក្ខុ)ភិក្ខុនី ឆ្កួត ១ ។

**៣-អាទិកម្មិកាយ** ដល់(ភិក្ខុ)ភិក្ខុនីដើមបញ្ញត្តិ១ ។

<u>ក្នុងព្រះអដ្ឋកថា ពោលថា:</u>

សិក្ខាបទនេះ បណ្ឌិតគប្បីជ្រាបថា ជាអាបត្តិច្រើនដោយការរាប់ប្រយោគ ក្នុងការអង្គុយឬដេកលើ (គ្រែ) ដែលគេធ្វើដោយរូបសត្វសាហាវ ។ ជាអចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម ។

**បល្លង្កាសនកថាចប់ ។**

# ១៩-កាលិកសំសដ្ឋកថា

<u>ក្នុងវិនយបិដកភាគ ៧ ទំព័រ៣៧៨ ព្រះអង្គត្រាស់ថា:</u>

★ យាវកាលិកេន ភិក្ខវេ យាមកាលិកំ តទហុប្បដិគ្គហិតំ កាលេ កប្បតិ វិកាលេ ន កប្បតិ ។ ម្នាលភិក្ខុទាំងឡាយ វត្ថុជាយាមកាលិក ប្រឡំដោយវត្ថុជាយាវកាលិក ដែលភិក្ខុទទួលក្នុងថ្ងៃនោះ គួរបានតែក្នុងកាល មិនគួរក្នុងវេលាវិកាលទេ ។

★ យាវកាលិកេន ភិក្ខវេ សត្តាហកាលិកំ តទហុប្បដិគ្គហិតំ កាលេ កប្បតិ វិកាលេ ន កប្បតិ ។ ម្នាលភិក្ខុទាំងឡាយ វត្ថុជាសត្តាហកាលិកប្រឡំ ដោយវត្ថុជាយាវកាលិក ដែលភិក្ខុទទួលក្នុងថ្ងៃនោះ គួរបានតែក្នុងកាល មិនគួរក្នុងវេលាវិកាលទេ ។

★ យាវកាលិកេន ភិក្ខវេ យាវជីវិកំ តទហុប្បដិគ្គហិតំ កាលេ កប្បតិ វិកាលេ ន កប្បតិ ។ ម្នាលភិក្ខុទាំងឡាយ វត្ថុជាយាវជីវិក ប្រឡំដោយវត្ថុជាយាវកាលិក ដែលភិក្ខុទទួលក្នុងថ្ងៃនោះ គួរបានតែក្នុងកាល មិនគួរ ក្នុងវេលាវិកាលទេ ។

★ យាមកាលិកេន ភិក្ខវេ សត្តាហកាលិកំ តទហុប្បដិគ្គហិតំ យាមេ កប្បតិ យាមាតិក្កន្តេ ន កប្បតិ ។ ម្នាលភិក្ខុទាំងឡាយ វត្ថុជាសត្តាហកាលិក ប្រឡំដោយវត្ថុជាយាមកាលិក ដែលភិក្ខុទទួលក្នុងថ្ងៃនោះ គួរបានតែក្នុងយាម កន្លងយាមទៅហើយ មិនគួរទេ ។

★ យាមកាលិកេន ភិក្ខវេ យាវជីវិកំ តទហុប្បដិគ្គហិតំ យាមេ កប្បតិ យាមាតិក្កន្តេ ន កប្បតិ ។ ម្នាលភិក្ខុទាំងឡាយ វត្ថុជាយាវជីវិក ប្រឡំដោយវត្ថុជាយាមកាលិក ដែលភិក្ខុទទួលក្នុងថ្ងៃនោះ គួរបានតែក្នុងយាម កន្លងយាមទៅហើយ មិនគួរទេ ។

★ សត្តាហកាលិកេន ភិក្ខវេ យាវជីវិកំ តទហុប្បដិគ្គហិតំ សត្តាហំ កប្បតិ សត្តាហាតិក្កន្តេ ន កប្បតិ ។ ម្នាលភិក្ខុទាំងឡាយ វត្ថុជាយាវជីវិក ប្រឡំដោយវត្ថុជាសត្តាហកាលិក ដែលភិក្ខុទទួលក្នុងថ្ងៃនោះ គួរអស់៧ថ្ងៃ ហួស ៧ ថ្ងៃទៅហើយ មិនគួរទេ ។

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>

★ ពាក្យថា ដែលភិក្ខុទទួលក្នុងថ្ងៃនោះ គួរបានតែក្នុងកាលជាដើម ព្រះមានព្រះភាគត្រាស់សំដៅយករស ដែល

លាយគ្នាគ្រប់យ៉ាង ។ ក៏បើថា ទឹកបាន ជារបស់ដែលទទួលប្រគេនលាយនឹងផ្លែដូងទាំងផ្លែ នៅមិនទាន់បានបកសំបកចេញយកផ្លែដូងចេញហើយ ទឹកបាននោះ គួរសូម្បីក្នុងពេលវិកាល ។

ឧបរិ សប្បិបិណ្ឌំ ឋបេត្វា សីតលបាយាសំ ទេន្តិ, យំ បាយាសេន អសំសដ្ឋំ សប្បិ, តំ អបនេត្វា សត្តាហំ បរិភុញ្ជិតុំ វដ្ដតិ ។ ឋទ្ធមធុផាណិតាទីសុបិ ឯសេវ នយោ ។ ពួកទាយកទាំងឡាយ ថ្វាយបាយបាយាសត្រជាក់ដាក់ដុំសប្បិខាងលើ, សប្បិណា ដែលមិនលាយគ្នានឹងបាយបាយាស ការដែលភិក្ខុយកសប្បិ នោះចេញទុកឆាន់ គួរបាន ៧ ថ្ងៃ ។ សូម្បីក្នុងសត្តាហកាលិកដ៏សេស មានទឹកឃ្មុំដែល ស្អិតនិងស្ករអំពៅជាដើម ក៏មានន័យនេះដូចគ្នា ។

តក្កោលជាតិផលាទីហិបិ អលង្កិរិត្វា បិណ្ឌបាតំ ទេន្តិ តានិ ឧទ្ធរិត្វា ធោវិត្វា យាវជីវំ បរិភុញ្ជិតព្វានិ ។ យាគុយំ បក្ខិបិត្វា ទិន្នសិង្គិវេរាទីសុបិ តេលាទីសុ បក្ខិបិត្វា ទិន្នលដ្ឋិមធុកាទីសុបិ ឯសេវ នយោ ។ ពួកទាយកថ្វាយបិណ្ឌបាត ប្រដាប់ដោយក្រវាញ និងផ្លែច័ន ជាដើមខ្លះ, ក្រវាញនិងផ្លែច័នជាដើមនោះ គប្បីលើកចេញលាងទុកឆាន់បាន រហូតអស់ជីវិត ។ ក្នុងខ្ទឹដែលគេដាក់ក្នុងយាគូថ្វាយជាដើមក្ដី ក្នុងឈើអែមដែលគេដាក់ សូម្បីក្នុងប្រេង

ជាដើម ហើយថ្វាយជាដើមក្តី ក៏មានន័យនេះដូចគ្នា ។

ឯវំ យំ យំ អសម្ភិន្នរសំ ហោតិ, តំ តំ ឯកតោ បដិគ្គហិតម្បិ យថា សុទ្ធំ ហោតិ ។ តថា ធោវិត្វា វា តច្ចេត្វា វា តស្ស តស្ស កាលវសេន បរិភុញ្ជិតុំ វដ្ដតិ ។ សចេ បន សម្ភិន្នរសំ ហោតិ សំសដ្ឋំ, ន វដ្ដតិ ។ កាលិកណាៗ ជារបស់មានរសមិនបានលាយគ្នាយ៉ាងនេះ, កាលិកនោះៗ សូម្បីទទួលប្រគេនរួមគ្នា លាង ចិតបោល បរិសុទ្ធហើយឆាន់ ដោយអំណាចនៃកាលរបស់កាលិកនោះៗ រមែងគួរ ។ តែបើកាលិកណា ជារបស់មានរសលាយប្រឡំគ្នាបាន, កាលិកដែលលាយចូលគ្នា(នោះ) រមែងមិនគួរ ។

យាវកាលិកញ្ហិ អត្តនា សទ្ធឹ សម្ភិន្នរសានិ តីណិបិ យាមកាលិកាទីនិ អត្តនោ សភាវំ ឧបនេតិ ។ យាមកាលិកំ ទ្វេបិ សត្តាហកាលិកាទីនិ អត្តនោ សភាវំ ឧបនេតិ ។ សត្តាហកាលិកម្បិ អត្តនា សទ្ធឹ សំសដ្ឋំ យាវជីវិកំ អត្តនោ សភាវំ យេវ ឧបនេតិ ។ តស្មា តេន តទហុបដិគ្គហិតេន សទ្ធឹ តទហុបដិគ្គហិតំ វា បុរេបដិគ្គហិតំ វា យាវជីវិកំ សត្តាហំ កប្បតិ ទ្វីហបដិគ្គហិតេន ឆាហំ, តីហបដិគ្គហិតេន បញ្ចាហំ ។បេ ។

សត្តាហបដិគ្គហិតេន តទហេវ កប្បតីតិ វេទិតព្វំ ។

មែនពិត យាវកាលិក រមែងទាញកាលិកទាំង ៣ មានយាមកាលិកជាដើម ដែលមានរសលាយនឹងខ្លួន ចូលកាន់សភាពរបស់ខ្លួន, យាមកាលិក ក៏ទាញកាលិកសូម្បីទាំង ២ មានសត្តាហកាលិកជាដើម ចូលកាន់សភាពរបស់ខ្លួន, សត្តាហកាលិកសោត រមែងទាញយាវជីវិក ដែលប្រឡំនឹងខ្លួន ចូលកាន់សភាពរបស់ខ្លួនដូចគ្នា, ព្រោះដូច្នោះ គប្បីជ្រាបសន្និដ្ឋានថា "យាវជីវិកដែលទទួលប្រគេន ក្នុងថ្ងៃនោះក្តី ទទួលប្រគេនក្នុងថ្ងៃមុនៗក្តី លាយនឹងសត្តាហកាលិកនោះ ដែលទទួលប្រគេនក្នុងថ្ងៃនោះ គួរត្រឹម ៧ ថ្ងៃ, លាយនឹងសត្តាហកាលិកដែលទទួលប្រគេនទុក ២ ថ្ងៃ គួរត្រឹម ៦ ថ្ងៃ, លាយនឹងសត្តាហកាលិកដែលទទួលប្រគេនទុក ៣ ថ្ងៃ គួរត្រឹម ៥ ថ្ងៃ ។ល។ លាយនឹងសត្តាហកាលិក ដែលទទួលប្រគេនទុក ៧ ថ្ងៃ គួរក្នុងថ្ងៃនោះប៉ុណ្ណោះ" ។

តស្មាយេវ ហិ សត្តាហកាលិកេន ភិក្ខវេ យាវជីវិកំ តទហុបដិគ្គហិតន្តិ, អវត្វា បដិគ្គហិតំ សត្តាហំ កប្បតីតិ វុត្តំ ។ ក៏ព្រោះហេតុនោះឯង ព្រះមានព្រះភាគទើបមិនត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ យាវជីវិកដែលទទួលប្រគេនក្នុងថ្ងៃនោះ លាយនឹងសត្តាហកាលិកៈ" ដូច្នេះ ហើយ

ត្រាស់ថាយាវជីវិក ដែលទទួលប្រគេនហើយ (លាយនឹងសត្តា-កាលិក) គួរ ៧ ថ្ងៃ” ។

★ កាលយាមសត្តាហាតិក្កមេសុ ចេត្ថ វិកាលភោជនសន្និធិភេសជ្ជសិក្ខាបទានំ វសេន អាបត្តិយោ វេទិតព្វា ។ ក៏កាលកាលិក ៣ នេះ, បើកន្លងកាល យាម និង ៧ ថ្ងៃទៅ គប្បីជ្រាបអាបត្តិដោយអំណាចវិកាលភោជនសិក្ខាបទ សន្និធិសិក្ខាបទ និងភេសជ្ជៈសិក្ខាបទ ។

★ ឥមេសុ ច បន ចតូសុ កាលិកេសុ យាវកាលិកំ យាមកាលិកន្តិ ឥទមេវ ទ្វយំ អន្តោវុត្ថកញ្ចេវ សន្និធិការកញ្ច ហោតិ, សត្តាហកាលិកញ្ច យាវជីវិកញ្ច អកប្បិយកុដិយំ និក្ខិបិតុម្បិ វដ្ដតិ, សន្និធិម្បិ ន ជនេតីតិ ។ ក៏ឯក្នុងកាលិក ៤ នេះ កាលិក ២ គឺ (យាវ-កាលិក ១ យាមកាលិក ១) នេះប៉ុណ្ណោះ ជាអន្តោវុត្ថផង ជាសន្និធិការកៈផង, តែសត្តាហកាលិក និងយាវជីវិក សូម្បីរក្សាទុកក្នុងអកប្បិយកុដិ ក៏គួរ, ទាំងមិនឱ្យកើតសន្និធិផង ដូច្នេះឯង ។

<u>ក្នុងគម្ពីរវិនយសង្គហដ្ឋកថា ពោលថា:</u>

★ បណ្ឌិតគប្បីជ្រាបថា កាលិកមាន ៤ យ៉ាង គឺ យាវ-

កាលិក១, យាមកាលិក១, សត្តាហកាលិក១, យាវជីវិក១ ។ បណ្ដាលកាលិកទាំង ៤ នោះ ខាទនីយនិងភោជនីយយ៉ាងណាមួយ ដែលទទួលក្នុងបុរេភត្ត ហើយឆាន់ដរាបដល់ថ្ងៃត្រង់ ឈ្មោះថា **យាវកាលិក** ។ ទឹកអដ្ឋបាន ៨ យ៉ាង មួយអន្លើដោយវត្ថុអនុលោម ដែលត្រូវឆាន់ដរាបដល់បច្ឆិមយាម នៃរាត្រី ឈ្មោះថា **យាមកាលិក** ។ ភេសជ្ជៈ ៥ យ៉ាងមាន **សប្បិៈ** ទឹកដោះថ្លា, **នវនីតៈ** ទឹកដោះខាប់, **តេលំៈ** ប្រេង, **មធុៈ** ទឹកឃ្មុំ, **ផាណិតៈ** ស្ករអំពៅ, ដែលភិក្ខុទទួលប្រគេន អាចទុកដាក់បាន ៧ ថ្ងៃ ឈ្មោះថា **សត្តាហកាលិក** ។ វត្ថុសូម្បីទាំងអស់ដ៏សេស វៀរតែទឹកចេញ ដែលភិក្ខុទទួលហើយ អាចទុកបានដរាបអស់ជីវិត, កាលមានហេតុ គប្បីឆាន់ ឈ្មោះថា **យាវជីវិក** ។

ក្នុងកាលិកទាំង ៤ នោះ ដែលឈ្មោះថា **ភោជនីយៈនោះ** បានដល់ ភោជនទាំង ៥ យ៉ាង គឺ បាយ ១ នំស្រស់ ១ នំក្រៀម ១ ត្រី ១ សាច់ ១ ។ ដែលឈ្មោះថា **ខាទនីយៈនោះ** បានដល់ របស់ទាំងអស់ វៀរលែងភោជន ៥ យ៉ាង និងវត្ថុជា យាមកាលិក សត្តាហកាលិក យាវជីវិកចេញ ។

ក្នុងគម្ពីរវិនយាលង្ការដីកា ពោលថា:

★ "យោ បន ភិក្ខុ អទិន្នំ មុខទ្វារំ អាហារំ អាហារេយ្យ អញ្ញត្រ ឧទកទន្តបោណា បាចិត្តិយ"ន្តិ វចនតោ ននុ ឧទកំ អប្បដិគ្គហិតព្វំ អថ កស្មា "ឋបេត្វា ឧទកំ អវសេសំ សព្វម្បិ បដិគ្គហិត"ន្តិ វុត្តន្តិ ? សច្ចំ បរិសុទ្ធឧទកំ អប្បដិគ្គហិតព្វំ កទ្ទមាទិស-ហិតំ បន បដិគ្គហេតព្វំ ហោតិ ។ ដោយព្រះពុទ្ធដីកាថា "ភិក្ខុណាមួយ ឆាន់អាហារដែលគេមិនបានប្រគេន ឱ្យចូលតាមទ្វារមាត់ទៅ វៀរតែទឹកនិងឈើស្ទន់ ត្រូវអាបត្តិបាចិត្តិយ" ដូច្នេះ សួរថា: ក្រែងទឹកជាវត្ថុមិនគប្បីប្រគេនមិនមែនឬ ? ព្រោះហេតុអ្វីទើបលោកពោលថា "វត្ថុសូម្បីទាំងអស់ដ៏សេស វៀរតែទឹកចេញត្រូវទទួលប្រគេន" ? ឆ្លើយថា សេចក្តីនេះ ពិតដូច្នោះហើយ ទឹកបរិសុទ្ធ គឺភិក្ខុមិនគប្បីទទួលប្រគេនទេ, តែទឹកដែលលាយដោយភក់ជាដើម ជាទឹកដែលភិក្ខុត្រូវទទួលប្រគេន ។

ក្នុងអដ្ឋកថា ពោលថា:

ឧទកំ បន អកាលិកត្តា អប្បដិគ្គហិតំ វដ្ដតិ ។ ចំណែកទឹក មិនទទួលប្រគេន ក៏គួរ ព្រោះវាមិនមែនជាកាលិក ។

<u>*ក្នុងគម្ពីរបាចិត្យាទិយោជនា ពោលថា:*</u>

ឧទកំ បនាតិ គេហនចិ អសំសត្ថំ បសន្នោទកំ បន ។ *ពាក្យថា ចំណែកទឹកដូច្នេះ គឺបានដល់ ទឹកដែលថ្លាស្អាត មិនលាយឡំដោយវត្ថុណាមួយ ។*

<u>*ក្នុងអដ្ឋកថាវិកាលសិក្ខាបទ ពោលថា:*</u>

★ *ឫស ឬមើមប្រភេទណាមួយ សម្រេចប្រយោជន៍ដល់ខាទនីយៈ និងប្រយោជន៍ដល់ភោជនីយៈ* ***របស់ពួកមនុស្ស ដោយអំណាចនៃអាហារតាមប្រក្រតី*** *ក្នុងជនបទនោះៗ ឫស ឬមើមនោះ គប្បីជ្រាបថា* ***ជាយាវកាលិក,*** *ឫសឬមើមក្រៅនេះ គប្បីជ្រាបថា* ***ជាយាវជីវិក*** *។*

<u>*ក្នុងគម្ពីរវិនយាលង្ការដីកា ពោលថា:*</u>

★ **បកតិអាហារវសេនាតិ** អញ្ញេហិ យាវកាលិកេហិ អយោជិតំ អត្តនោ បកតិយាវ អាហារកិច្ចករណវសេន ។ *ពាក្យថា* ***ដោយអំណាចអាហារតាមប្រក្រតី*** *ដូច្នេះ សេចក្តីថា ដោយអំណាចការធ្វើនូវអាហារកិច្ច តាមប្រក្រតីរបស់ខ្លួនប៉ុណ្ណោះ, មិនបានផ្សំលាយជាមួយយាវកាលិកដទៃទេ ។*

<u>*ក្នុងបាចិត្យាទិយោជនា ពោលថា:*</u>

★ **មនុស្សានន្តិ** ឥមិនា អញ្ញេសំ តិរច្ឆានាទីនំ ខាទនីយភោជនីយត្ថំ ជរមានម្បិ ន បមាណន្តិ ទស្សេតិ ។ *ដោយពាក្យថា **របស់មនុស្សទាំងឡាយ** ដូច្នេះនេះ លោកសម្តែងថា សូម្បីការផ្សាយទៅដើម្បីជាប្រយោជន៍ដល់ខាទនីយនិងភោជនីយនៃសត្វតិរច្ឆានដទៃ មិនជាប្រមាណទេ ។*

★ **បកតិអាហារវសេនាតិ** អញ្ញេហិ យាវកាលិក-សត្តាហកាលិកេហិ អមិស្សំ អត្តនោ បកតិយាវ អាហារកិច្ចករណវសេន ។ *ពាក្យថា **ដោយអំណាចអាហារជាប្រក្រតី** ដូច្នេះនេះ គឺលោកពោលដោយអំណាចនៃការធ្វើជាអាហារកិច្ច តាមប្រក្រតីរបស់ខ្លួនតែម្យ៉ាង ដែលមិនប្រកបផ្សំដោយយាវកាលិក និងសត្តាហកាលិកដទៃទេ ។*

<u>*ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:*</u>

★ **តេសុ តេសុ ជនបទេសូតិ** ឯត្ថ "ឯកស្មឹ ជនបទេ អាហារកិច្ចំ សាធេន្តំ សេសជនបទេសុបិ ន កប្បតី"តិ វទន្តិ ។ *ក្នុងពាក្យថា **ក្នុងជនបទនោះៗ** ដូច្នេះ លោកអាចារ្យទាំងឡាយរមែងពោលថា កាលឱ្យសម្រេចជាអាហារកិច្ច ក្នុងជនបទមួយ មិនសម្រេចក្នុងជនបទដ៏សេសទាំងឡាយ ។*

ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:

★ ឯកស្មឹ ទេសេ អាហារកិច្ចំ សាធេន្តំ វា អញ្ញស្មឹ ទេសេ ឧដ្ឋិតភូមិរសាទិភេទេន អាហារកិច្ចំ អសាធេន្តម្បិ វា សម្ភវេយ្យាតិ អាហ "តេសុ តេសុ ជនបទេសូ"តិអាទិ ។ កេចិ បន "ឯកស្មឹ ជនបទេ អាហារកិច្ចំ សាធេន្តំ សេសជនបទេសុបិ វិកាលេ ន កប្បតិ ឯវាតិ ទស្សនត្ថំ ឥទំ វុត្ត"ន្តិបិ វទន្តិ ។ ក្នុងប្រទេសមួយ រមែងសម្រេចជាអាហារកិច្ច តែក្នុងប្រទេសដទៃ មិនសម្រេចជាអាហារកិច្ចក៏មាន, ព្រោះផ្សេងដោយរសនៃផែនដីជាដើម ដែលតាំងឡើង ព្រោះហេតុនោះ អដ្ឋកថាទើបពោលថា ក្នុងជនបទនោះៗ ជាដើម ។ តែអាចារ្យទាំងឡាយពួកខ្លះ ពោលថា ពាក្យថា ក្នុងជនបទនោះៗ គឺលោកពោលហើយ ដើម្បីសម្តែងថា ក្នុងជនបទមួយសម្រេចជាអាហារកិច្ច, សូម្បីក្នុងជនបទទាំងឡាយដ៏សេស រមែងមិនគួរពិត ក្នុងវេលាវិកាល ដូច្នេះ ។

**ភិក្ខុមានហេតុឆាន់យាមកាលិក និង សត្តាហកាលិក ជាដើម**

ក្នុងអនាបត្តិ បឋមបវារណាសិក្ខាបទព្រះអង្គត្រាស់ថា:

★ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ សតិបច្ចយេ បរិភុញ្ជតិ : ភិក្ខុដែលឆាន់របស់ជាយាមកាលិក

*សត្តាហកាលិកយាវជីវិក* **ដោយមានហេតុ** ។

*ក្នុងគម្ពីរអដ្ឋកថា ពោលថា:*

★ **សតិ បច្ចយេតិ** យាមកាលិកំ បិបាសាយ សតិ បិបាសច្ឆេទនត្ថំ, សត្តាហកាលិកំ យាវជីវិកញ្ច តេន តេន ឧបសមេតព្វកេ អាពាធេ សតិ, តស្ស ឧបសមនត្ថំ អនាបត្តិ ។ *ពាក្យថា សតិបច្ចយេ* **ដោយមានហេតុ** *ដូច្នេះ មានសេចក្តីថា ភិក្ខុឆាន់យាមកាលិក ដើម្បីកម្ចាត់បង់នូវសេចក្តីស្រេកឃ្លាន ក្នុងកាលមានសេចក្តីស្រេកឃ្លាន, ឆាន់សត្តាហ-កាលិក និងយាវជីវិក ដើម្បីរម្ងាប់អាពាធនោះ ក្នុងកាលមានអាពាធ ដែលនឹងគប្បីឱ្យរម្ងាប់បាន ដោយកាលិកនោះៗ (គឺដោយសត្តាហកាលិក និងយាវជីវិក) មិនជាអាបត្តិ ។*

*ក្នុងបាចិត្យាទិយោជនា ពោលថា:*

★ **សតិ បច្ចយេតិ** ឯត្ថ បច្ចយស្ស សរូបំ ទស្សេតុំ បិបាសាយ សតីតិ ច អាពាធេ សតីតិ ច វុត្តំ ។

*ក្នុងពាក្យថា* **មានហេតុ** *ដូច្នេះ មានសេចក្តីថា កាលមានសេចក្តីស្រេកឃ្លាន ដូច្នេះផង, កាលមានអាពាធ ដូច្នេះផង គឺលោកពោលហើយ ដើម្បីសម្តែងសមគួរដល់បច្ច័យ ។ (គឺ*

ភិក្ខុឆាន់យាមកាលិក ដើម្បីកម្ចាត់បង់នូវសេចក្តីស្រេកឃ្លាន ឆាន់សត្តាហកាលិក និងយាវជីវិក ដើម្បីរម្ងាប់អាពាធ) ។

<u>*នៅក្នុងខុទ្ទកសិក្ខាអភិនវដីកា ពោលថា*</u>

**សតិ បច្ចយេតិ** តីសុ យាមកាលិកំ បិបាសាធិ-ការណោ សតិ, សត្តាហកាលិកំ យាវជីវិកញ្ច គេលញ្ញ-ការណោ សតីតិ អត្ថោ ។

*ពាក្យថា* ***ដោយមានហេតុ*** *ដូច្នេះ មានសេចក្តីអធិប្បាយថា ក្នុងបណ្តាកាលិកទាំង ៣ ភិក្ខុឆាន់យាមកាលិក កាលមានហេតុ មានសេចក្តីស្រេកជាដើម, ឆាន់សត្តាហកាលិក និងយាវជីវិក កាលមានហេតុ មានជំងឺអាពាធ ។*

<u>*ក្នុងគម្ពីរអដ្ឋកថា សន្និធិសិក្ខាបទ ពោលថា:*</u>

យាមកាលិកំ សតិ បច្ចយេ អជ្ឈោហរតោ បាចិត្តិយំ ។ *ភិក្ខុ* ***កាលមានហេតុ*** *លេបចូលនូវយាមកាលិកដែលជាសន្និធិ ត្រូវអាបត្តិបាចិត្តិយ ។*

<u>*ក្នុងបាចិត្យាទិយោជនា ពន្យល់ថា:*</u>

**សតិ បច្ចយេតិ** បិបាសសង្ខាតេ បច្ចយេ សតិ ។ *ពាក្យថា* ***កាលមានហេតុ*** *ដូច្នេះ មានសេចក្តីថា កាលមានហេតុ ពោលគឺសេចក្តីស្រេកឃ្លាន ។*

<u>នៅក្នុងកង្ខាវិតរណី ភាគ ៣ ទំព័រ ៣៤ ពោលថា</u>

★ កាលេ កាលសញ្ញិនោ យាមកាលិកាទីនិ សតិ បច្ចយេ បរិភុញ្ជន្តស្ស ឧម្មត្តកាទីនញ្ច អនាបត្តិ ។ ជាអនាបត្តិដល់ភិក្ខុ ដែលសម្គាល់ចំពោះកាលថា កាលមែន, ដល់ភិក្ខុដែលមានហេតុហើយ បរិភោគនូវយាមកាលិកជាដើម និងភិក្ខុឆ្កួត ។

<u>នៅក្នុងគម្ពីរកង្ខាវិតរណី អភិនវដីកា ពន្យល់ថា</u>

★ **សតិ បច្ចយេតិ** បិបាសាទិការណេ វិជ្ជមានេ ។ ពាក្យថា ដែលមានហេតុ ដូច្នេះនេះ មានសេចក្តីថា កាលមានហេតុ មានសេចក្តីស្រេកឃ្លានជាដើម ។

<u>តែនៅក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា</u>

**សតិ បច្ចយេតិ** ឯត្ថ សតិបច្ចយតា គិលាគិលានវសេន ទ្វិធា វេទិតព្វា ។ វិកាលភោជនសិក្ខាបទស្ស ហិ អនាបត្តិវារេ យាមកាលិកាទីនំ តិណ្ណម្បិ អវិសេសេន សតិបច្ចយតា វុត្តា ។ ក្នុងពាក្យថា កាលមានហេតុ ដូច្នេះ បណ្ឌិតគប្បីជ្រាបថា មានពីរយ៉ាង ដោយអំណាចការមានអពាធ និងមិនមានអាពាធ ព្រោះមានសតិជាបច្ច័យ ។ មែនពិត នៅក្នុងអនាបត្តិវារៈ នៃវិកាលសិក្ខាបទ លោកពោលហើយដោយ

សេចក្ដីមិនប្លែកគ្នា សូម្បីទាំង ៣ មានយាមកាលិកជាដើម ថា មានសតិជាបច្ច័យ ។

ឥមស្មឹ ខន្ធកេ អនុជានាមិ ភក្ខវេ គិលានស្ស គុឡំ អគិលានស្ស គុឡោទកំ ។ អនុជានាមិ ភក្ខវេ គិលានស្ស លោណសោវីរកំ អគិលានស្ស ឧទកសម្ភិន្នន្តិ វុត្តំ ។ ព្រះអង្គត្រាស់ទុក ក្នុងភេសជ្ជខន្ធកនេះថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដុំស្ករអំពៅ ដល់ភិក្ខុឈឺ ទឹកស្ករអំពៅ ដល់ភិក្ខុមិនមានជំងឺ" ។ "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតថ្នាំឈ្មោះលោណសោវីរកៈ ដល់ភិក្ខុឈឺ និងថ្នាំឈ្មោះលោណសោវីរកៈ ដែលលាយទឹក ដល់ភិក្ខុមិនមានជំងឺ" ។

តស្មា សិទ្ធំ សតិបច្ចយតា គិលានាគិលានវសេន ទុវិធាតិ ។ អញ្ញថា អសតិ បច្ចយេ គុឡោទកាទីសុ អាបជ្ជតិ ។ ព្រោះហេតុនោះ លោកសម្រេចថា មានពីរយ៉ាង ដោយអំណាចការមានអពាធ និងមិនមានអាពាធ ព្រោះមានសតិជាបច្ច័យ ។ បើកាន់យកដោយប្រការដទៃ កាលមិនមានហេតុ រមែងត្រូវនូវទោស ក្នុងសត្តាហកាលិកទាំងឡាយ មានទឹកស្ករអំពៅជាដើម ។

## ក្នុងបុរេភត្ត មិនពិចារណានូវគិលានប្បច្ច័យ មិនជាអាបត្តិ

*ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា*

★ បុរេភត្តញ្ហិ អប្បច្ចវេក្ខិត្វាបិ គិលានប្បច្ចយំ បរិភុញ្ជន្តស្ស អនាបត្តិ ។ *ពិតមែន ទុកជាភិក្ខុមិនបាន ពិចារណាក្នុងបុរេភត្តហើយ បរិភោគនូវគិលានប្បច្ច័យ មិនជា អាបត្តិ ។*

*ក្នុងគម្ពីរអដ្ឋកថា ភេសជ្ជសិក្ខាបទ ពោលថា:*

សត្តាហំ បន អនតិក្កាមេត្វា គិលានេនបិ អគិលានេនបិ វុត្តនយេនេវ យថាសុខំ បរិភុញ្ជិតព្វំ ។ តានិ បដិគ្គហេត្វា តទហុបុរេភត្តំ យថាសុខំ បច្ឆាភត្តតោ បដ្ឋាយ សតិ បច្ចយេ វុត្តនយេនេវ សត្តាហំ បរិភុញ្ជិតុំ ។ *ក៏ភេសជ្ជៈទាំង ៥ នេះ នៅមិនទាន់កន្លង ៧ ថ្ងៃទៅ ភិក្ខុអ្នក អាពាធក្តី មិនមានអាពាធក្តី គួរបរិភោគតាមសប្បាយ តាមន័យ ដូចពោលហើយ ។ ភិក្ខុទទួលភេសជ្ជទាំង ៥ នោះឆាន់តាម សប្បាយក្នុងបុរេភត្តក្នុងថ្ងៃនោះ ចាប់ផ្តើមពីបច្ឆាភត្តទៅ កាល មានហេតុ គួរដើម្បីឆាន់អស់ ៧ ថ្ងៃ តាមន័យដូចពោលមក ហើយនោះឯង ។*

## ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា

បច្ឆាភត្តតោ បដ្ឋាយ សតិ បច្ចយេតិ វុត្តត្តា បដិគ្គហិតភេសជ្ជានិ ទុតិយទិវសតោ បដ្ឋាយ បុរេភត្តម្បិ សតិ បច្ចយេ បរិភុញ្ជិតព្វានិ, ន អាហារត្ថំ ភេសជ្ជត្ថាយ បដិគ្គហិតត្តាតិ វទន្តិ ។ *ព្រោះពាក្យដែលអដ្ឋកថាចារ្យពោលថា ចាប់ផ្តើមពីបច្ឆាភត្តទៅកាលមានហេតុ ដូច្នេះនេះ អាចារ្យទាំងឡាយពោលថា ភេសជ្ជដែលភិក្ខុទទួលទុកហើយ ចាប់ផ្តើមពីថ្ងៃទី ២ ទៅ កាលមានហេតុ គប្បីឆាន់ សូម្បីក្នុងបុរេភត្ត, ព្រោះទទួលដើម្បីប្រយោជន៍ដល់ភេសជ្ជៈ មិនមែនដើម្បីប្រយោជន៍ជាអាហារទេ ។*

## ក្នុងវិនយបិដកភាគ ៤ ទំព័រ១៣៨ ព្រះអង្គសម្តែងថា:

★ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ អាហារត្ថាយ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ ទុក្កដស្ស ។ *ភិក្ខុទទួលនូវយាមកាលិក សត្តាហកាលិក និង យាវជីវិក ដើម្បីប្រយោជន៍ជាអាហារត្រូវអាបត្តិទុក្កដ ។ ត្រូវអាបត្តិទុក្កដ គ្រប់ៗខណៈដែលលេបចូល ។*

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>

ពាក្យថា សត្តាហកាលិកំ យាវជីវិកំ អាហារត្ថាយ (ទទួលវត្ថុជា) សត្តាហកាលិក និងយាវជីវិក ដើម្បីប្រយោជន៍ជាអាហារ ដូច្នេះ មានសេចក្តីថា កាលភិក្ខុទទួលប្រគេនដើម្បីប្រយោជន៍ជាអាហារ **ជាអាបត្តិទុក្កដ** ព្រោះការទទួលប្រគេន**ជាបច្ច័យមុន** ។ តែកាលលេបចូលទៅ បើជារបស់មិនមានអាមិស ជាអាបត្តិទុក្កដ គ្រប់ម៉ាត់ដែលលេបចូល ។

<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:</u>

☆ **បដិគ្គហណបច្ចយា តាវ ទុក្កដន្តិ** ឯត្ថ សន្និហិតត្តា បុរេភត្តម្បិ ទុក្កដមេវ ។ សតិ បច្ចយេ បន សន្និហិតម្បិ សត្តាហកាលិកំ យាវជីវិកំ ភេសជ្ជត្ថាយ គហេត្វា ភុញ្ជន្តស្ស បរិភុញ្ជន្តស្ស ច អនាបត្តិយេវ ។

ក្នុងពាក្យថា ត្រូវអាបត្តិទុក្កដ ព្រោះការទទួលជាបច្ច័យមុន ដូច្នេះនេះ សេចក្តីថា ជាអាបត្តិទុក្កដពិត សូម្បីក្នុងបុរេភត្ត ព្រោះជាវត្ថុដែលខ្ទនទុកដាក់ហើយ ។ តែបើមានហេតុ ជាអនាបត្តិដល់ភិក្ខុកាលទទួលក្តី បរិភោគក្តី នូវសត្តាហកាលិក និងយាវជីវិក សូម្បីដែលទុកដាក់ហើយ ដើម្បីប្រយោជន៍ដល់ថ្នាំ ។

<u>ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:</u>

★ **អាហារត្ថាយាតិ** វិកាលេ ឯវាតិ ឯកេ ។ ពាក្យថា ដើម្បីប្រយោជន៍ជាអាហារ ដូច្នេះ អាចារ្យពួកខ្លះ ពោលថា សំដៅយក ពេលវេលាវិកាល ។

<u>ក្នុងបាចិត្យាទិយោជនា ពោលថា:</u>

★ អនាហារត្ថាយាតិ បិបាសច្ឆេទនអាពាធវូបសម-ត្ថាយ ។ ពាក្យថា មិនមែនដើម្បីប្រយោជន៍ជាអាហារ ដូច្នេះ មានសេចក្ដីថា គឺដើម្បីប្រយោជន៍ កំចាត់បង់នូវការស្រេកឃ្លាន និងដើម្បីរម្ងាប់នូវអាពាធ ។

**កាលិកសំសដ្ឋកថាចប់ ។**

# ២០_សាមណេរានិសង្សកថា

*ក្នុងគម្ពីរអដ្ឋកថា ពោលថា:*

*ក្នុងមហាបច្ចរីពោលថា សួរថា អ្នកណាគួរក្រាលកឋិន អ្នកណាមិនគួរក្រាលកឋិន ? ឆ្លើយថា:*

គណាននេសេន តាវ, បច្ឆិមកោដិយា បញ្ច ជនា លភន្តិ ឧទ្ធំ សតសហស្សម្បិ, បញ្ចន្នំ ហេដ្ឋា ន លភន្តិ ។

*បើពោលដោយអំណាចនៃគណបូរកៈ, ភិក្ខុ ៥ រូប ជាយ៉ាងតិច រមែងបានក្រាលកឋិន, យ៉ាងច្រើនសូម្បីភិក្ខុមួយសែនរូប ក៏បាន តិចជាង ៥ រូប មិនបាន ។*

*ក្នុងគម្ពីរវិនយាលង្ការដីកា ពោលថា:*

☆ **បញ្ចជនា លភន្តីតិ** បញ្ច ជនា សាធេន្តិ ។ កឋិនទុស្សស្ស ហិ ទាយកា បច្ឆិមកោដិយា ចត្តារោ ហោន្តិ, ឯកោ បដិគ្គាហកោតិ ។ តត្រ ភិក្ខវេ, យ្វាយំ ចតុវគ្គោ ភិក្ខុសង្ឃោ ឋបេត្វា តីណិ កម្មានិ ឧបសម្បទំ បវារណំ អព្ភានន្តិ ធម្មេន សមគ្គោ សព្ពកម្មេសុ កម្មប្បត្តោតិ វុត្តត្តា ន បញ្ចវគ្គ-ករណីយន្តិ គហេតព្វំ ។

ពាក្យថា ភិក្ខុ ៥ រូបយ៉ាងតិច រមែងបានក្រាលកឋិន ដូច្នេះនេះ មានសេចក្ដីថា ភិក្ខុ ៥ រូប ទើបសម្រេចបាន ។ ព្រោះថា ភិក្ខុអ្នកប្រគល់ឱ្យនូវសម្ពត់កឋិន យ៉ាងតិចត្រូវមាន ៤ រូប, និងភិក្ខុអ្នកទទួល ១ រូប ។ តែមិនត្រូវកាន់យកថាជាកិច្ចត្រូវធ្វើដោយសង្ឃបញ្ចវគ្គទេ, ព្រោះព្រះអង្គត្រាស់ក្នុងចម្មេយ្យក្ខន្ធកៈថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុសង្ឃចតុវគ្គនេះ រមែងធ្វើកម្មបានទាំងអស់, វៀរតែកម្ម ៣ យ៉ាង គឺឧបសម្បទាកម្ម, បវារណាកម្ម និងអព្ភានកម្ម" ។

<u>ក្នុងគម្ពីរអដ្ឋកថា ពោលទៀតថា:</u>

**វុដ្ឋវស្សាវសេន, បុរិមិកាយ វស្សំ ឧបគន្ត្វា បឋមបវារណាយ បវារិតា លភន្តិ ។ ឆិន្នវស្សា វា បច្ឆិមិកាយ ឧបគតា វា ន លភន្តិ ។ អញ្ញស្មឹ វិហារេ វុដ្ឋវស្សាបិ ន លភន្តីតិ មហាបច្ចរិយំ វុត្តំ ។**

បើពោលដោយអំណាចភិក្ខុដែលចាំវស្សា, ភិក្ខុដែលចាំវស្សា ក្នុងបុរិមិកាវស្សា បវារណាក្នុងថ្ងៃបឋមបវារណាហើយ រមែងបានក្រាលកឋិន, ភិក្ខុដែលមានវស្សាដាច់ ឬចាំវស្សាក្នុងបច្ឆិមិកាវស្សា រមែងមិនបានក្រាលកឋិន, សូម្បីភិក្ខុដែលចាំវស្សាក្នុងវត្តដទៃ រមែងមិនបាន ។

*ក្នុងគម្ពីរវិនយាលង្ការដីកា ពោលថា:*

★ **អញ្ញស្មឹ វិហារេ វុត្ថវស្សាបិ ន លភន្តីតិ** ឆានា-សីមាយ អញ្ញស្មឹ វិហារេ វុត្ថវស្សា ឥមស្មឹ វិហារេ កាឋិនត្ថារំ ន លភន្តីតិ អត្ថោ ។ *ពាក្យថា សូម្បីភិក្ខុដែលចាំវស្សាក្នុងវត្តដទៃ រមែងមិនបាន* ដូច្នេះ មានសេចក្តីអធិប្បាយ *ថា ភិក្ខុដែលចាំវស្សាក្នុងវត្តដទៃ ដែលនៅក្នុងសីមាផ្សេងគ្នា រមែងមិនបានដើម្បីក្រាលកឋិននៅក្នុងវិហារនេះ ។*

*ចំណែកនៅក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:*

★ **អញ្ញស្មឹ វិហារេ វុត្ថវស្សាបិ ន លភន្តីតិ** ឯកសីមស្មឹ វា ឆានាសីមស្មឹ វា ឆានូបចារេ អញ្ញស្មឹ វិហារេ វុត្ថវស្សាបិ ន លភន្តីតិ អធិប្បាយោ វេទិតព្វោ ។

*ពាក្យថា សូម្បីភិក្ខុដែលចាំវស្សាក្នុងវត្តដទៃ រមែងមិនបាន ដូច្នេះ បណ្ឌិតគប្បីជ្រាបសេចក្តីអធិប្បាយថា "ភិក្ខុដែលចាំវស្សាក្នុងវត្តដទៃ ដែលនៅក្នុងឧបចារផ្សេងគ្នា ទោះជានៅក្នុងសីមាជាមួយគ្នាក្តី ក្នុងសីមាផ្សេងគ្នាក្តី រមែងមិនបាន (ដើម្បីក្រាលកឋិនទេ) ។*

ក្នុងគម្ពីរអដ្ឋកថា ពោលថា:

★ បុរិមិកាយ ឧបគតានំ បន សព្វេ គណបូរកា ហោន្តិ, អានិសំសំ ន លភន្តិ, អានិសំសោ ឥតរេសំយេវ ហោតិ ។ *ចំណែកភិក្ខុទាំងអស់ អ្នកចាំវស្សាក្រោយ រមែងជាគណបូរកៈ របស់ភិក្ខុដែលចាំវស្សាដើមបាន, តែពួកលោកមិនបានអានិសង្សទេ, អានិសង្សរមែងសម្រេច ដល់ពួកភិក្ខុក្រៅនេះប៉ុណ្ណោះ ។*

## ពាក្យថា អានិសង្សរបស់កឋិន

ក្នុងគម្ពីរវិនយាលង្ការដីកា ពោលថា:

★ **សព្វេតិ** ឆិន្នវស្សាទយោ, អនុបគតាបិ តត្ថេវ សង្គហិតា ។ *ពាក្យថា ភិក្ខុទាំងអស់ គឺលោកសំដៅយកភិក្ខុដាច់វស្សាជាដើម, សូម្បីភិក្ខុដែលមិនបានចូលវស្សា ក៏លោកសង្គ្រោះចូលក្នុងពាក្យថា ភិក្ខុទាំងអស់នេះដែរ ។*

★ **អានិសំសន្តិ** កឋិនានិសំសចីវរំ ។ ឯកំ អត្ថតចីវរំយេវ ហិ កឋិនចីវរំ នាម ហោតិ អវសេសានិ ចីវរានិ វា សាដកា វា **កឋិនានិសំសានេវ នាម** ។ **ឥតរេសន្តិ** បុរិមិកាយ ឧបគតានំ ។

ពាក្យថា **អានិសង្ស** ដូច្នេះ គឺលោកសំដៅយកចីវរដែលជាអានិសង្សរបស់កឋិន ៗ ពិតមែន ដែលហៅថា កឋិនចីវរ គឺចំពោះតែចីវរមួយផ្ទាំង ដែលភិក្ខុក្រាលកឋិនប៉ុណ្ណោះ, ចីវរសល់ពីនោះទាំងប៉ុន្មានក្តី សំពត់សាដកទាំងប៉ុន្មានក្តី ហៅថាអានិសង្សរបស់កឋិនទាំងអស់ ៗ ពាក្យថា **ពួកភិក្ខុក្រៅនេះ** គឺបានដល់ ភិក្ខុដែលចូលចាំបុរិមិកាវស្សា ៗ

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>

សចេ បុរិមិកាយ ឧបគតា ចត្តារោ វា ហោន្តិ តយោ វា ទ្វេ វា ឯកោ វា, ឥតរេ គណបូរកេ កត្វា កឋិនំ អត្ថរិតព្វំ ។ បើភិក្ខុដែលចាំវស្សាដើមមាន ៤ រូប ឬ ៣ រូប ឬ ២ រូប ឬតែមួយរូប, គប្បីនិមន្តភិក្ខុដែលចាំវស្សាក្រោយ មកបន្ថែមឱ្យគ្រប់គណៈ ហើយក្រាលកឋិនចុះ ៗ

អថ ចត្តារោ ភិក្ខូ ឧបគតា ឯកោ បរិបុណ្ណវស្សោ សាមណេរោ សោ ចេ បច្ឆិមិកាយ ឧបសម្បជ្ជតិ គណបូរកោ ចេវ ហោតិ អានិសំសញ្ច លភតិ ។ តយោ ភិក្ខូ ទ្វេ សាមណេរា, ទ្វេ ភិក្ខូ តយោ សាមណេរា, ឯកោ ភិក្ខុ ចត្តារោ សាមណេរាតិ ឯត្ថាបិ ឯសេវ នយោ ។

បើភិក្ខុដែលចាំវស្សាដើម ៤ រូប មានសាមណេរអាយុគ្រប់មួយរូប បើសាមណេរនោះ ឧបសម្បទាក្នុងវស្សាក្រោយ លោកជាគណបូរកៈបានផង **ទាំងបានអានិសង្សផង** ។ សូម្បីក្នុងពាក្យថា "មានភិក្ខុ ៣ សាមណេរ ២, មានភិក្ខុ ២ សាមណេរ ៣, មានភិក្ខុ ១ រូប សាមណេរ ៤ រូប" ដូច្នេះនេះ ក៏មានន័យយ៉ាងនេះដូចគ្នា ។

<u>ក្នុងគម្ពីរអត្ថយោជនា ពោលថា</u>

★ **អានិសំសញ្ច លភតីតិ** អនាមន្តចារាទិកំ កឋិ-នានិសំសំ លភតិ ។ ពាក្យថា **ទាំងបានអានិសង្សផង** ដូច្នេះមានសេចក្ដីថា រមែងបាននូវអានិសង្សរបស់កឋិន មាន**អនាមន្ត-ចារៈ** គឺការត្រេចទៅណាមិនបាច់លានូវភិក្ខុផងគ្នាជាដើម ។ (លោកពោលយ៉ាងនេះ ព្រោះលោកអាងនៅក្នុង កង្ខាវិតរណី អភិនវដីកា) ។

<u>ក្នុងគម្ពីរកង្ខាវិតរណី ភាគ ២ ទំព័រ ៥ ពោលថា:</u>

★ តស្មា យត្ថ ចត្តារោ វា តយោ វា ទ្វេ វា ឯកោ វា បុរិមវស្សំ ឧបគតោ តត្ថ បច្ឆិមវស្សូបគតេ គណបូរកេ កត្វា អត្ថរិតព្វំ ។ តេ ច គណបូរកោវ ហោន្តិ អានិសំសេ ន លភន្តិ ។ ព្រោះហេតុនោះ ក្នុង

*វត្តណាមានភិក្ខុចូលចាំបុរិមិកាវស្សា ៤ រូបក្តី ៣ រូបក្តី ២ រូបក្តី ១ រូបក្តី គប្បីធ្វើនូវភិក្ខុ ដែលចូលចាំវស្សាក្រោយ ឱ្យជាគណបូរកៈហើយ ក្រាលនូវកឋិនចុះ ។ ចំណែកភិក្ខុទាំងឡាយនោះ រមែងបានជាគណបូរកៈតែប៉ុណ្ណោះ, តែមិនបាននូវអានិសង្សទាំងឡាយទេ ។*

*<u>ក្នុងគម្ពីរកង្ខាវិតរណីអភិនវដីកា ពន្យល់ថា:</u>*

☆ **អានិសំសេតិ** អនាមន្តចារាទិកេ កឋិនានិសំសេ ។ អថ បន ចត្តារោ ភិក្ខូវស្សំ ឧបគតា ឯកោ បរិបុណ្ណ-វស្សោ សាមណេរោ សចេ បច្ឆិមិកាយ ឧបសម្បជ្ជតិ គណបូរកោ ចេវ ហោតិ អានិសំសញ្ច លភតិ ។ តយោ ភិក្ខូ ទ្វេ សាមណេរា, ទ្វេ ភិក្ខូ តយោ សាមណេរា, ឯកោ ភិក្ខុ ចត្តារោ សាមណេរាតិ ឯត្ថាបិ ឯសេវ នយោ ។ *ពាក្យថា នូវអានិសង្សទាំងឡាយ ដូច្នេះ បានដល់នូវអានិសង្សកឋិនទាំងឡាយមាន***អនាមន្តចារោ** *គឺការត្រេចទៅណា មិនបាច់លានូវភិក្ខុផងគ្នាជាដើម ។ តែបើភិក្ខុដែលចាំវស្សាដើម ៤ រូប មានសាមណេរអាយុគ្រប់មួយរូប, បើសាមណេរនោះ ឧបសម្បទាក្នុងវស្សាក្រោយ លោកជាគណ-*

បូរកៈបានផង ទាំងបានអានិសង្សផង ។ សូម្បីក្នុងពាក្យថា "មានភិក្ខុ ៣ សាមណេរ ២, មានភិក្ខុ ២ សាមណេរ ៣, មានភិក្ខុ ១ រូប សាមណេរ ៤ រូប" ដូច្នេះនេះ ក៏មានន័យយ៉ាងនេះដូចគ្នា ។

<u>ចំណែកន័យក្នុងគម្ពីរវិនយវិនិច្ឆយដីកា ពោលថាៈ</u>

★ អានិសំសលាភំ សន្ធាយ វុត្តំ ។ ពាក្យថា អានិសង្សនេះ គឺលោកពោលសំដៅយកអានិសង្សលាភ ។

<u>ចំណែកនៅក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថាៈ</u>

★ "បច្ឆិមិកាយ ឧបសម្បន្នោ បឋមបវារណាយ បវារេតុម្បិ លភតិ, វស្សិកោ ច ហោតិ អានិសំសញ្ច លភតីតិ សាមណេរានំ វស្សូបគមនំ អនុញ្ញាតំ ហោតិ សាមណេរា កឋិនានិសំសំ លភន្តី"តិ វទន្តិ ។ អាចារ្យទាំងឡាយពោលថា (សាមណេរ)ដែលឧបសម្បទា ក្នុងបច្ឆិមិកាវស្សា រមែងបានដើម្បីបវារណា ក្នុងថ្ងៃបឋមបវារណា, និងជាអ្នកមានវស្សាផង, រមែងបាននូវអានិសង្សផង ព្រោះហេតុនោះ ការចូលចាំវស្សារបស់សាមណេរទាំងឡាយ ជាការដែលព្រះអង្គទ្រង់អនុញ្ញាតហើយ, សាមណេរទាំងឡាយ រមែងបាននូវអានិសង្សរបស់កឋិន ។

*ក្នុងគម្ពីរវិនយាលង្ការដីកា ពោលថា:*

★ សោ ចេ បច្ឆិមិកាយ ឧបសម្បជ្ជតិ, គណបូរកោ ចេវ ហោតិ, អានិសំសញ្ច លភតីតិ ឥមិនា សាមណេរានំ វស្សូបគមនំ អនុញ្ញាតំ ហោតិ ។ សោ ហិ បុរិមិកាយ វស្សូបគតត្តា អានិសំសំ លភតិ បច្ឆិមិកាយ បន ឧបសម្បជ្ជិតត្តា គណបូរកោ ហោតិ ។ *ដំណើរដែលសាមណេរទាំងឡាយ ត្រូវចូលវស្សា ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតដោយរឿងនេះ ។ ពិតមែន ភិក្ខុថ្មីនោះ ត្រូវបានអានិសង្ស ព្រោះបានចូលបុរិមិកាវស្សា ពីសាមណេរមកហើយ, ដែលគួរយកជាគណបូរកៈបាន ព្រោះបានឧបសម្បទាឡើងជាភិក្ខុក្នុងរវាងបច្ឆិមិកាវស្សានោះ ។*

*ក្នុងវិនយបិដកភាគ ៨ ទំព័រ ១៤៨ ពោលថា:*

*ម្នាលភិក្ខុទាំងឡាយ បើភិក្ខុក្នុងសាសនានេះ នៅចាំវស្សាតែម្នាក់ឯង ។ ក្នុងទីនោះពួកមនុស្ស ប្រគេនចីវរទាំងឡាយដោយពាក្យថា* "សង្ឃស្ស ទេមាតិ : *យើងទាំងឡាយប្រគេនចីវរចំពោះសង្ឃ" ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតចីវរទាំងនោះដល់ភិក្ខុនោះឯង កំណត់ត្រឹមកឋិនដោះ ។*

<u>ក្នុងអដ្ឋកថាចីវរក្ខន្ធកៈ ពោលថាៈ</u>

ពិតមែន ពាក្យថា ចីវរទាំងនោះដល់ភិក្ខុនោះឯង កំណត់ត្រឹមកឋិនដោះ ដូច្នេះនេះ មានលក្ខណៈដូច្នេះ ៖

សំពត់ដែលកើតឡើងដល់សង្ឃ ដោយអាការៈយ៉ាងណាមួយក៏ដោយ, រមែងដល់ភិក្ខុដែលក្រាលកឋិនហើយរហូត ៥ ខែ ដល់ភិក្ខុដែលមិនបានក្រាលកឋិន បានត្រឹមចីវរមាស ១ ខែ ប៉ុណ្ណោះ ។

✯ យំ "សង្ឃស្ស ទេមាតិ"វា វទន្តិ, "សង្ឃំ ឧទ្ទិស្ស ទេមាតិ" វា ទេន្តិ, "វស្សំវុត្ថសង្ឃស្ស ទេមាតិ" វា ទេន្តិ "វស្សាវាសកំ ទេមាតិ" វា ទេន្តិ, សចេបិ មតកចីវរំ អវិភជិត្វា តំ វិហារំ បវិសន្តិ, តំ សព្វំ តស្សេវ ភិក្ខុនោ ហោតិ ។ សំពត់ណាដែលទាយកថ្វាយថា "យើងទាំងឡាយសូមថ្វាយដល់សង្ឃ" ដូច្នេះក្តី, ថា "យើងទាំងឡាយ សូមថ្វាយឧទ្ទិស្សចំពោះសង្ឃ" ដូច្នេះក្តី, ថា "ខ្ញុំប្រគេនដល់សង្ឃដែលចាំវស្សា" ដូច្នេះក្តី, ថា "ខ្ញុំប្រគេនសំពត់ចំណាំវស្សា" ដូច្នេះក្តី, ប្រសិនបើមានចីវររបស់ភិក្ខុដែលស្លាប់ ដែលមិនទាន់ចែកគ្នា ហើយចូលទៅកាន់វិហារនោះ (ក្តី) សំពត់ទាំងអស់នោះ រមែងជារបស់ភិក្ខុនោះប៉ុណ្ណោះ ។

★ **យំ បន** ឥទំ ឥធ "វស្សំវុត្ថសង្ឃស្ស ទេមាតិ" វា "វស្សាវាសិកំ ទេមាតិ" វា វត្វា ទិន្នំ, តំ អនត្ថត-កឋិនស្សាបិ បញ្ចមាសេ បាបុណាតិ ។ *ចំណែកសំពត់នេះណាដែលទាយកប្រគេនថា "ខ្ញុំប្រគេនដល់សង្ឃដែលចាំវស្សាក្នុងវត្តនេះ" ឬថា "ខ្ញុំប្រគេនសំពត់ចំណាំវស្សា" សំពត់នោះរមែងដល់សូម្បីភិក្ខុ ដែលមិនបានក្រាលកឋិនរហូត ៥ ខែ ។*

**លាភនៃការចាំវស្សា សូម្បីមិនបានក្រាលកឋិន ក៏បានដែរ**

*<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពន្យល់ថា:</u>*

★ "វស្សាវាសិកលាភវសេន វា មតកចីវរវសេន វា តត្រុប្បាទវសេន វា អញ្ញេន វា កេនចិ អាការេន សង្ឃំ ឧទ្ទិស្ស ឧប្បន្នចីវរំ, សព្វំ តស្សេវ អត្ថតកឋិនស្ស បញ្ច មាសេ, អនត្ថតកឋិនស្ស ឯកំ ចីវរមាសំ បាបុណាតី"តិ អវិសេសតោ វត្វាបិ បុន វស្សាវាសិកលាភវសេន ឧប្បន្នេ លព្ភមានវិសេសំ ទស្សេតុំ "យំ បន ឥធ"ន្តិអាទិ អារទ្ធំ ។ *ព្រះអដ្ឋកថាចារ្យ សូម្បីពោលហើយ ដោយមិនមានសេចក្តីប្លែកថា "ចីវរដែលកើតឡើងចំពោះ សង្ឃដោយអំណាចលាភ*

នៃការចាំវស្សាក្តី ដោយអំណាចនៃចីវររបស់ភិក្ខុស្លាប់ក្តី ដោយអំណាចនៃចីវរដែលកើតអំពីទ្រព្យ ដែលវេយ្យាវច្ចករបានមកពីចម្ការដូនជាដើម ដែលកើតក្នុងវត្តនោះក្តី ដោយអាការៈណាមួយដទៃក្តី, ចីវរទាំងអស់នោះ រមែងបានដល់ភិក្ខុដែលបានក្រាលកឋិននោះប៉ុណ្ណោះ អស់ ៥ ខែ, រមែងបានដល់ភិក្ខុដែលមិនបានក្រាលកឋិន ១ ខែ" ហើយប្រារព្ធនូវពាក្យជាដើមទៀតថា "**ចំណែកសំពត់នេះណា**" ដូច្នេះ ដើម្បីសម្តែងនូវសេចក្តីប្លែកគ្នា ការបាននូវចីវរដែលកើតឡើងដោយអំណាចលាភនៃការចាំវស្សា ។

☆ តត្ថ **ឥធាតិ** អភិលាបមត្តមេតំ ។ "វស្សំវុត្ថសង្ឃស្ស ទេមា"តិ វុត្តេបិ សោយេវ នយោ ។ បណ្តាពាក្យទាំងនោះ ពាក្យថា "ឥធ" ក្នុងវត្តនេះ ដូច្នេះ ត្រឹមតែជាវោហារប៉ុណ្ណោះ ។ សូម្បីកាលពោលថា "ខ្ញុំសូមថ្វាយដល់សង្ឃដែលនៅចាំវស្សា" ដូច្នេះ ក៏មានន័យដូចគ្នា ។

☆ **អនត្ថតកឋិនស្សាបិ បញ្ច មាសេ បាបុណាតីតិ** វស្សាវាសិកលាភវសេន ឧប្បន្នវត្ថំ អនត្ថតកឋិនស្សាបិ វុត្ថវស្សស្ស បញ្ច មាសេ បាបុណាតិ ។ ពាក្យថា រមែងដល់សូម្បីភិក្ខុដែលមិនបានក្រាលកឋិន អស់ ៥ ខែ ដូច្នេះ

*មានសេចក្តីថា រមែងដល់ភិក្ខុដែលចាំវស្សាហើយ សូម្បីមិនបានក្រាលកឋិន៥ ខែ, ព្រោះភាវៈនៃចីវរនោះ កើតឡើងហើយដោយអំណាចនៃការចាំវស្សា ។*

## ភិក្ខុមិនបានក្រាលកឋិន បានអានិសង្សត្រឹមតែ៤ ក្នុងរដូវកឋិន

*<u>ក្នុងគម្ពីរកង្ខាវិតរណីអភិនវដីកា ពោលថា:</u>*

★ អនត្ថតកឋិនា បន ឥមេសុ បញ្ចសុ អានិសំសេសុ ចីវរមាសេ អសមាទានចីវរំ ឋបេត្វា សេសានិសំសេ លភន្តិ ។ *ចំណែកភិក្ខុដែលមិនបានក្រាលកឋិន បណ្តាអានិសង្សទាំង ៥ នោះ វៀរលែងតែ អសមា ទានចីវរោ គឺការត្រេចទៅណាមិនបាច់យកចីវរទាំងអស់ទៅជាមួយចេញ រមែងបានអានិសង្សដ៏សេស ក្នុងខែនៃចីវរ (គឺក្នុងរដូវកឋិន) ។*

## ភិក្ខុប្រាប់ពេលទាយកសួរពីការថ្វាយកឋិនចីវរ

*<u>ក្នុងគម្ពីរអដ្ឋកថាកឋិនក្ខន្ធកៈ ពោលថា:</u>*

*បើទាយកសួរថា "កឋិនគួរថ្វាយយ៉ាងណាលោកម្ចាស់" ភិក្ខុគប្បីប្រាប់គេយ៉ាងនេះថា "គួរថ្វាយសំពត់ល្មមធ្វើត្រៃចីវរផ្ទាំងណាមួយបាន, ក្នុងវេលាអរុណរះ គួរដើម្បីថ្វាយថា "យើងទាំងឡាយ សូមប្រគេននូវសំពត់កឋិន" ដូច្នេះ ហើយគួរ*

ប្រគេនម្ជុលប៉ុណ្ណោះ អំបោះប៉ុណ្ណោះ ទឹកជ្រលក់ប៉ុណ្ណោះ ដើម្បីធ្វើចីវរនោះ និងប្រគេនយាគូ និងភត្ត ដល់ពួកភិក្ខុដែលជួយធ្វើប៉ុណ្ណោះរូប ។

<u>ក្នុងគម្ពីរវិនយាលង្ការដីកា ពោលថា:</u>

★ **កឋិនចីវរំ ទេមាតិ ធាតុំ វត្តតីតិ** ឯត្ថ សង្ឃស្ស កឋិនចីវរំ ទេមាតិ វត្តព្វំ ។ ឯវញ្ហិ សតិ ឥមំ សង្ឃស្ស កឋិនទុស្សំ ឧប្បន្នន្តិ កម្មវាចាយ សមេតិ ។

ក្នុងពាក្យថា គួរដើម្បីថ្វាយថា "យើងទាំងឡាយសូមប្រគេននូវសម្ពត់កឋិន" ដូច្នេះ មានសេចក្តីថា គប្បីពោលថា "សង្ឃស្ស កឋិនចីវរំ ទេម : យើងទាំងឡាយថ្វាយនូវសម្ពត់កឋិនចំពោះសង្ឃ" ។ ពិតមែន កាលមានគេថ្វាយយ៉ាងនេះ ក៏រមែងសមដោយកម្មវាចានេះថា "ឥមំ សង្ឃស្ស កឋិនទុស្សំ ឧប្បន្នំ " ដូច្នេះជាដើម ។

<u>ក្នុងគម្ពីរអដ្ឋកថាកឋិនក្ខន្ធក: ពោលថា:</u>

ភិក្ខុជាអ្នកក្រាល គប្បីកាន់យកសំពត់កឋិន ដែលធ្វើសម្រេចស្រេចហើយក្រាលកឋិន តាមវិធីដែលលោកពោលទុកក្នុងគម្ពីរបរិវារៈ មានពាក្យជាដើមថា បើ(ភិក្ខុអ្នកក្រាល) ចង់

ក្រាលកឋិនដោយសង្ឃាដី ត្រូវដកសង្ឃាដីចាស់ចេញ អធិដ្ឋានសង្ឃាដីថ្មីឡើង គប្បីបញ្ចេញវាចាថា "ខ្ញុំព្រះករុណា ក្រាលកឋិនដោយសង្ឃាដីនេះ" ។

ក្នុងគម្ពីរវិនយាលង្ការដីកា ពោលថា:

★ **ឥមាយ សង្ឃាដិយា កឋិនំ អត្ថរាមីតិ** វាចា ភិន្ទិតព្វាតិ កឹ ឯត្តកេន វចីភេទេន កឋិនំ អត្ថតំ ហោតិ ឧទាហុ អញ្ញោ កោចិ កាយវិការោ កាតព្វោ ? ន កាតព្វោ ។ ឯត្តកេនេវ ហិ វចីភេទេន អត្ថតំ ហោតិ កឋិនំ ។ ពាក្យថា គប្បីបញ្ចេញនូវវាចាថា "អាត្មាអញក្រាលនូវកឋិនដោយសង្ឃាដីនេះ" ដូច្នេះ សួរថា: តើការក្រាលនូវកឋិនគប្បីធ្វើដោយវចីភេទតែម្យ៉ាងឬ? ឬថា គប្បីធ្វើនូវកាយវិការណាមួយដែរ ? ឆ្លើយថា: មិនត្រូវធ្វើដោយកាយវិការណាមួយទេ ។ ព្រោះថា កឋិនជាការដែលភិក្ខុក្រាលហើយ ដោយវចីភេទតែម្យ៉ាងប៉ុណ្ណោះ ។

ក្នុងគម្ពីរវិនយាលង្ការដីកា ពោលទៀតថា:

★ បរិក្ខារចោឡា អធិដ្ឋានេន អធិដ្ឋិតំ ចីវរំ ឥមំ បច្ចុទ្ធរាមីតិ សាមញ្ញតោ បច្ចុទ្ធរិតព្វំ ន ឥមំ សង្ឃាដឹ បច្ចុទ្ធរាមីតិ វិសេសតោ បច្ចុទ្ធរិតព្វំ ។ កស្មា ? បុព្វេ

អលទ្ធនាមត្តា ។ ចីវរដែលអធិដ្ឋានហើយ ដោយការអធិដ្ឋានជាបរិក្ខារចោឡ គប្បីដកដោយសាមញ្ញថា "អាត្មាអញដកនូវសំពត់បរិក្ខារនេះ" មិនគប្បីដកដោយវិសេសថា "អាត្មាអញដកនូវសង្ឃាដីនេះ" ដូច្នេះទេ ព្រោះហេតុអ្វី? ព្រោះសំពត់នេះមិនបានមានឈ្មោះ (ដូច្នោះ) ក្នុងកាលពីមុន ។

**សាមណេរានិសង្សកថាចប់ ។**

## ២១_សទ្ធាទេយ្យវិនិបាតនកថា

*ក្នុងវិនយបិដកភាគ ៨ ទំព័រ១៨៥ ត្រាស់ថា:*

★ *សម័យនោះឯង ចីវរកើតឡើងដល់ភិក្ខុមួយរូប ។ ឯភិក្ខុនោះបង់ឱ្យចីវរនោះដល់មាតានិងបិតា ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនោះ ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គត្រាស់ថា:* មាតាបិតរោតិ ខោ ភិក្ខវេ ទទមានេ កឹ វទេយ្យាមិ ។ អនុជានាមិ ភិក្ខវេ មាតាបិតូនំ ទាតុំ, **ន ច ភិក្ខវេ សទ្ធាទេយ្យំ** វិនិបាតេតព្វំ យោ វិនិបាតេយ្យ អាបត្តិ ទុក្កដស្សាតិ ។ *ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុឱ្យចីវរដោយគិតថា "មាតានិងបិតា" ដូច្នេះ តថាគតនឹងថាដូចម្ដេចបាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុឱ្យចីវរដល់មាតាបិតាបាន, ម្នាលភិក្ខុទាំងឡាយ តែថាភិក្ខុមិនត្រូវធ្វើទានដែលទាយកឱ្យដោយសទ្ធា ឱ្យធ្លាក់ចុះឡើយ ភិក្ខុណាឱ្យធ្លាក់ចុះ ត្រូវអាបត្តិទុក្កដ ។*

*ក្នុងព្រះអដ្ឋកថា ពោលថា:*

★ **ន ច ភិក្ខវេ សទ្ធាទេយ្យន្តិ** ឯត្ថ សេសញាតីនំ ទេន្តោ វិនិបាតេតិយេវ ។ មាតាបិតរោ បន សចេ រជ្ជេ

**ឋិតេ បគ្គេន្តិ ធាតព្វំ ។** ក្នុងពាក្យថា *តែថាភិក្ខុមិនត្រូវធ្វើទាន ដែលទាយកឱ្យដោយសទ្ធា* ដូច្នេះនេះ មានសេចក្តីថា កាលភិក្ខុ ឱ្យដល់ញាតិដ៏សេស រមែងជាការញ៉ាំងសទ្ធាទេយ្យ (ទានដែល ទាយកឱ្យដោយសទ្ធា) ឱ្យធ្លាក់ចុះពិត ។ តែចំពោះមាតា និងបិតា ប្រសិនបើគាត់តាំងនៅក្នុងរាជសម្បត្តិក៏ដោយ បើគាត់ ប្រាថ្នា ភិក្ខុគប្បីឱ្យ ។

### ភិក្ខុដាក់អាហារក្នុងភាជនៈជារបស់សង្ឃហើយ ឱ្យដល់មាតា

<u>ក្នុងព្រះអដ្ឋកថា តតិយបារាជិក ពោលថាៈ</u>

<u>សួរថាៈ</u> អនាមដ្ឋបិណ្ឌបាត គួរឱ្យដល់អ្នកណា? មិនគួរ ឱ្យដល់អ្នកណា?

<u>ឆ្លើយថាៈ</u> **មាតាបិតូនំ តាវ ធាតព្វំ ។** មុនដំបូង ត្រូវឱ្យដល់មាតាបិតា ។ ក៏បើបិណ្ឌបាតនោះ ជារបស់មានតម្លៃ ទាំងពាន់កហាបណៈ ក៏មិនចាត់ជាការញ៉ាំងសទ្ធាទេយ្យឱ្យ ធ្លាក់ចុះទេ ។

**មាតាបិតុឧបដ្ឋានំ, វេយ្យាវច្ចករស្ស, បណ្ឌុបលាស-ស្សាតិ ឯតេសំបិ ធាតព្វា ។** គួរឱ្យសូម្បីដល់មនុស្សពួកនេះ គឺអ្នកបម្រើមាតា និងបិតា, វេយ្យាវច្ចករ បណ្ឌុបលាស ។

**តត្ថ បណ្ឌុបលាសស្ស ថាលកេ និក្ខិបិត្វា ធាតុំ**

វដ្ដតិ ។ តំ ថបេត្វា អញ្ញេសំ អាគារិកានំ មាតាបិតូនម្បិ ន វដ្ដតិ ។បព្វជិតបរិភោគោ ហិ អាគារិកានំ ចេតិយ-ដ្ឋានិយោ ។ បណ្ដាមនុស្សទាំងនោះ សម្រាប់បិណ្ឌបលាស ភិក្ខុដាក់ក្នុងភាជនៈឱ្យក៏គួរ ។ រៀបបណ្ឌបលាសនោះចេញ ដាក់ក្នុងភាជនៈ ឱ្យដល់គ្រហស្ថដទៃ សូម្បីជាមាតាបិតា ក៏មិនគួរ ។ ព្រោះគ្រឿងបរិភោគរបស់បព្វជិតទាំងឡាយ តាំងនៅក្នុងឋានជាចេតិយរបស់គ្រហស្ថ ។

## ពាក្យថា អនាមដ្ឋបិណ្ឌបាត

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា និងវិនយាលង្ការដីកា ពោលថា:</u>

★ **អនាមដ្ឋបិណ្ឌបាតោតិ** អគ្គហិតអគ្គោ, អបរិ-ភុត្តោតិ អត្ថោ ។ ពាក្យថា **អនាមដ្ឋបិណ្ឌបាត** ដូច្នេះ បានដល់កំពូលបាយ ដែលគេមិនទាន់ចាប់យក, អធិប្បាយថា បិណ្ឌបាតដែលគេមិនទាន់បានបរិភោគ ។

★ **ថាលកេតិ** សង្ឃិកេ កំសាទិមយេ ថាលកេ បត្តោបិ ឯត្ថ សង្គយ្ហតិ ។ ពាក្យថា **ដាក់ក្នុងភាជនៈ**ដូច្នេះ មានសេចក្ដីថា ភាជនៈដែលសម្រេចអំពីសំរិតជាដើម ដែលជារបស់សង្ឃ ។ សូម្បីបាត្រ ក៏លោកសង្គ្រោះចូលក្នុងភាជនៈ

នេះដែរ ។ (ក្នុងសារត្ថទីបនីក៏ពោលដោយន័យនេះដូចគ្នា) ។

★ **ន វដ្តតីតិ** ឥមិនា ទុក្កដន្តិ ទស្សេតិ ។ ដោយពាក្យថា មិនគួរ គឺលោកអាចារ្យសម្ដែងថា ត្រូវអាបត្តិទុក្កដ ។

<u>ក្នុងព្រះអដ្ឋកថា តតិយបារាជិក ពោលទៀតថា:</u>

★ អបិច អនាមដ្ឋបិណ្ឌបាតោ នាមេស សម្បត្តស្ស ទាមរិកចោរស្សាបិ ឥស្សរស្សាបិ ទាតព្វោ ។ ម្យ៉ាងទៀត ឈ្មោះថា អនាមដ្ឋបិណ្ឌបាតនេះ គប្បីឱ្យដល់ចោរល្បីឈ្មោះ ដល់ឥស្សរជនអ្នកចូលមកដល់(វត្ត) ។ ព្រោះហេតុអ្វី? ព្រោះថាជនទាំងនោះ សូម្បីកាលមិនឱ្យ ក៏ក្រោធខឹងថា "មិនឱ្យ" សូម្បីកាលប៉ះពាល់ហើយទើបឱ្យ ក៏ក្រោធថា "ឱ្យរបស់សំណល់" ។ ជនទាំងនោះក្រោធហើយ រមែងផ្ដាច់ចាកជីវិតខ្លះ រមែងធ្វើអន្តរាយដល់ព្រះសាសនាខ្លះ ។

<u>សួរថា:</u> ក្នុងបដិសន្ថារៈ គួរធ្វើដល់បុគ្គលណា? មិនគួរធ្វើដល់បុគ្គលណា ?

<u>ឆ្លើយថា:</u> បដិសន្ថារោ នាម វិហារំ សម្បត្តស្ស យស្ស កស្សចិ អាគន្តុកស្ស វា ទលិទ្ទស្ស វា ចោរស្ស វា ឥស្សរស្ស វា កាតព្វោយេវ ។ ឈ្មោះថា បដិសន្ថារៈដែលភិក្ខុគប្បីធ្វើដល់បុគ្គលណាមួយ ដែលមកដល់វិហារ ជា

*មនុស្សអាគន្តុកៈក្តី ជាមនុស្សកំសត់ក្តី ជាចោរក្តី ជាឥស្សរជនក្តី ។*

*<u>សួរថាៈ</u> គប្បីធ្វើយ៉ាងណា ?*

*<u>ឆ្លើយថាៈ</u> ភិក្ខុឃើញអាគន្តុកៈដែលអស់ស្បៀងមកដល់វិហារ គប្បីឱ្យទឹកផឹកមុនដោយពោលថា "អញ្ជើញផឹកទឹកចុះ" ។ គប្បីឱ្យប្រេងលាបជើង ។ អាគន្តុកៈមកក្នុងកាល, គប្បីឱ្យយាគូនិងភត្ត ។ អាគន្តុកៈមកក្នុងវេលាវិកាល, បើមានអង្ករ គប្បីឱ្យអង្ករ ។ មិនគួរនិយាយថា "លោកមកដល់ក្នុងគ្រាមិនមែនវេលា ចូរទៅវិញចុះ" ។ គប្បីឱ្យគេដេក ។*

សព្វំ អប្បច្ចាសីសន្តេនេវ កាតព្វំ ។ មនុស្សា ឆាមចតុប្បច្ចយទាយកា ឯវំ សង្គហេ ការិយមានេ បុនប្បុនំ បសីទិត្វា ឧបការំ ការិស្សន្តីតិ ចិត្តំ ន ឧប្បាទេតព្វំ ។ ចោរានំ បន សង្ឃិកម្បិ ទាតព្វំ ។

*ភិក្ខុមិនប្រាថ្នាសេចក្តីតបស្នងវិញឡើយ គួរធ្វើគ្រប់យ៉ាង ។ មិនគួរឱ្យការគិតកើតឡើងថា "ធម្មតាមនុស្សដែលឱ្យនូវបច្ច័យ ៤ កាលយើងធ្វើការសង្គ្រោះយ៉ាងនេះ នឹងជ្រះថ្លាហើយនឹងធ្វើនូវឧបការៈរឿយៗ ។ ចំណែកវត្ថុសូម្បីជារបស់សង្ឃក៏គួរឱ្យដល់ពួកចោរបាន ។*

*<u>ក្នុងគម្ពីរវិនយាលង្ការដីកា ពោលថា:</u>*

★ **"វិហារំ សម្បត្តស្ស បន យស្ស កស្សចិ អាគន្តុកស្ស វា"** ឥច្ចាទិវក្ខមានត្តា វិហារំ សម្បត្តានំ ញាតកានម្បិ អាគន្តុកសាមញ្ញេន ទាតុំ វដ្ដតីតិ ច ។

*ភិក្ខុគួរដើម្បីឱ្យសូម្បីដល់ញាតិ ដែលមកដល់វត្ត ដោយសាមញ្ញថា **ជាអាគន្តុកៈ** ព្រោះពាក្យដែលលោកអាចារ្យពោលថា "បុគ្គលណាមួយដែលមកដល់វិហារ ជាមនុស្ស-អាគន្តុកៈក្តី" ដូច្នេះ ជាដើម ។*

## ភិក្ខុមិនមានបំណងឱ្យតបស្នងក៏ដោយ ក៏មិនត្រូវឱ្យ ដល់ជនដែលព្រះមិនអនុញ្ញាតដែរ

*<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>*

★ **"អបច្ចាសីសន្តេនា"តិ** វត្វា បច្ចាសីសនប្បការំ ទស្សេតុំ **មនុស្សា នាមា**តិអាទិ វុត្តំ ។ អននុញ្ញាតានំ បន អបច្ចាសីសន្តេនាបិ ទាតុំ ន វដ្ដតិ **សទ្ធាទេយ្យវិនិបាតត្តា**, បច្ចាសីសាយ បន សតិ កុលទូសនម្បិ ហោតិ ។ *ព្រះអដ្ឋកថាចារ្យពោលថា "ភិក្ខុមិនប្រាថ្នានូវ សេចក្តីតបស្នងវិញឡើយ" ដូច្នេះ ហើយពោលនូវពាក្យជាដើមថា "ធម្មតាមនុស្ស*

*ទាំងឡាយ” ដូច្នេះ ដើម្បីសម្ដែងនូវបការដែលភិក្ខុមានសេចក្ដីប្រាថ្នានឹងឱ្យតបស្នងវិញ ។ ក៏កាលភិក្ខុដែលមិនមានបំណងឱ្យតបស្នងទេ, ក៏មិនគួរឱ្យដល់ជនដែលព្រះអង្គមិនបានអនុញ្ញាតទេ ព្រោះជាសទ្ធាទេយ្យ ។ ក៏កាលភិក្ខុប្រាថ្នាឱ្យតបស្នងវិញ សូម្បីការទ្រុស្តត្រកូល ក៏រមែងមាន ។*

*<u>ក្នុងគម្ពីរអដ្ឋកថាពោលទៀតថា:</u>*

*ភិក្ខុគួរធ្វើថ្នាំដល់មនុស្ស ៥ ពួកនេះគឺ មាតា១, បិតា១, អ្នកបំរើមាតាបិតានោះ១, វេយ្យាវច្ចករណ៍របស់ខ្លួន១, បណ្ឌុ-បលាស១ ។*

បណ្ឌុបលាសោ ណាម យោ បព្ពជ្ជាបេក្ខោ យាវ បត្តចីវរំ បដិយាទិយតិ តាវ វិហារេ វសតិ ។ *ដែលឈ្មោះថា បណ្ឌុបលាស: បានដល់ អ្នកបំណងបព្វជ្ជា ដែលនៅក្នុងវិហាររហូតពេលដែលនៅត្រៀមបាត្រ និងចីវរ ។*

✯ តេសុ សចេ មាតាបិតរោ ឥស្សរា ហោន្តិ, ន បច្ចាសីសន្តិ, អកាតុំ វដ្ដតិ ។ សចេ បន រជ្ជេបិ ឋិតា បច្ចាសីសន្តិ, អកាតុំ ន វដ្ដតិ ។ *បណ្ដាជនទាំង ៥ ពួកនោះ បើមាតាបិតាជាធំមិនប្រាថ្នាតបស្នងទេ ភិក្ខុមិនធ្វើតបក៏គួរ ។ តែបើអ្នកទាំងពីរ តាំងនៅក្នុងរាជសម្បត្តិ នៅតែប្រាថ្នា*

តបស្នង ការភិក្ខុមិនធ្វើការតបស្នង **មិនគួរ** ។

<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:</u>

★ **អកាតុំ ន វដ្តតីតិ** ឯត្ថ ទុក្កដំ វទន្តិ ។ ក្នុងពាក្យថា **ការភិក្ខុមិនធ្វើការតបស្នងមិនគួរ** ដូច្នេះ អាចារ្យទាំងឡាយពោលថា ជាអាបត្តិទុក្កដ ។

<u>តែក្នុងគម្ពីរវិមតិវិនោទនី និងវិនយាលង្ការដីកា ពោលថា:</u>

★ **អកាតុំ ន វដ្តតីតិ** ឯត្ថ ទុក្កដំ វទន្តិ អយុត្តតាវសេនេវ បនេត្ថ អករណបដិក្ខេបោ យុត្តោ, ន អាបត្តិវសេនាតិ គហេតព្វំ ។ ក្នុងពាក្យថា **ការភិក្ខុមិនធ្វើការតបស្នងមិនគួរ** ដូច្នេះ អាចារ្យទាំងឡាយពោលថា ជាអាបត្តិទុក្កដ ។ តែក្នុងសេចក្តីនេះ ការបដិសេធនូវការមិនធ្វើតប ដោយអំណាចការមិនសមគួរប៉ុណ្ណោះ ត្រឹមត្រូវហើយ, មិនគប្បីកាន់យកដោយអំណាចនៃអាបត្តិទេ ។

<u>ក្នុងវិន័យវណ្ណនា ពោលថា:</u>

★ របស់ឆាន់ដែលភិក្ខុបានមកថ្មី នៅមិនទាន់បានឆាន់សោះ ឈ្មោះថា **"អនាមដ្ឋបិណ្ឌបាត"** ។ អនាមដ្ឋបិណ្ឌបាតនេះ ក៏ឈ្មោះថា **ជាសទ្ធាទេយ្យ** (របស់ដែលគេឱ្យដោយសទ្ធា) ។ ក្នុងរឿងការធ្វើថ្នាំ ព្រះអដ្ឋកថាចារ្យលើកយកអនាមដ្ឋបិណ្ឌបាត

*មួយជំពូកមកពោលឡើង ហាក់ដូចជានឹងបង្អួលឱ្យជាប្រធាន ក្នុងបច្ច័យដ៏សេស អ្នកមានបញ្ញាគប្បីពិចារណាមើលផងចុះ ។*

*<u>ក្នុងគម្ពីរខុទ្ទកសិក្ខាអភិនវដីកា ពោលថា:</u>*

✯ **សទ្ធាទេយ្យំ** សទ្ធាយ ទាតព្វំ **ចីវរញ្ច**, ច-សទ្ទេន អវសេសម្បិ វិនិបាតេតុំ នាសេតុំ ន លព្ភំ, បិតុនំ លព្ភន្តិ សម្ពន្ធោ ។ *សេចក្ដីសម្ព័ន្ធថា ក៏ចីវរដែលគប្បីឱ្យដោយសទ្ធា ឈ្មោះថា **សទ្ធាទេយ្យ**, ដោយ ច-សព្ទ គឺភិក្ខុរមែងមិនបានដើម្បីញុំាងបច្ច័យ សូម្បីដែលនៅសល់ (គឺបិណ្ឌបាត្របច្ច័យ សេនា-សនៈ និងគិលានភេសជ្ជៈបច្ច័យ) ឱ្យធ្លាក់ចុះ, ឱ្យវិនាសទេ (បច្ច័យទាំងឡាយ) រមែងបានដល់បិតា ។*

**ការពោលជាមួយជនមិនមែនជាញាតិ ជាសទ្ធាទេយ្យៈ**

*<u>ក្នុងព្រះអដ្ឋកថា កយវិក្កយសិក្ខាបទ ពោលថា:</u>*

✯ តត្រាយំ វិនិច្ឆយោ: *វិនិច្ឆ័យក្នុងការផ្លាស់ប្ដូរដូច្នេះ៖*

វត្ថេន វា វត្ថំ ហោតុ , ភត្តេន វា ភត្តំ , យំ កិញ្ចិ កប្បិយំ "ឥមិនា ឥមំ ទេហី"តិ វទតិ, ទុក្កដំ ។ ឯវំ វត្វា មាតុយាបិ អត្តនោ ភណ្ឌំ ទេតិ , ទុក្កដំ ។

*សម្ពត់និងសម្ពត់ក្ដី, ភត្តនិងភត្តក្ដី ចូរលើកទុកចុះ, ភិក្ខុពោល*

ដល់កប្បិយភ័ណ្ឌណាមួយ ដោយពាក្យថា "ញោម ចូរឱ្យវត្ថុនេះ ដោយរបស់នេះ" រមែងត្រូវអាបត្តិទុក្កដ ។ លុះពោលយ៉ាងនេះរួចហើយ ឱ្យនូវភណ្ឌៈរបស់ខ្លួន សូម្បីដល់មាតា ក៏ត្រូវអាបត្តិទុក្កដ ។

"ឥមិនា ឥមំ ទេហី"តិ វុត្តោ វា "ឥមំ ទេហិ, ឥមំ តេ ទស្សាមី"តិ វត្វា វា មាតុយាបិ ភណ្ឌំ អត្តនា គណ្ហាតិ ទុក្កដំ ។ អត្តនោ ភណ្ឌេ បរហត្ថំ បរភណ្ឌេ ច អត្តនោ ហត្ថំ សម្បត្តេ និស្សគ្គិយំ ។ ភិក្ខុពោលថា "ញោមចូរឱ្យនូវវត្ថុនេះ ដោយវត្ថុនេះ" ឬពោលថា "ញោមចូរឱ្យនូវវត្ថុនេះ, អាត្មានឹងឱ្យនូវវត្ថុនេះដល់ញោម" ហើយកាន់យកនូវភណ្ឌៈសូម្បីរបស់មាតាដោយខ្លួនឯង រមែងត្រូវអាបត្តិទុក្កដ ។ កាលបើភណ្ឌៈរបស់ខ្លួន ដល់ដៃគាត់ កាលបើភណ្ឌៈរបស់គាត់ ដល់ដៃខ្លួន ជានិស្សគ្គិយបាចិត្តិយ ។

★ មាតរំ បិតរំ វា "ឥមំ ទេហី"តិ វទតោ វិញ្ញត្តិ ន ហោតិ ។ ភិក្ខុកាលពោលជាមួយនឹងមាតា ឬបិតា ថា "ញោម ចូរឱ្យនូវវត្ថុនេះ" មិនជាវិញ្ញត្តិទេ ។

"ឥមំ គណ្ហាតី"តិ វទតោ សន្ទាទេយ្យំ ន ហោតិ ។ ភិក្ខុកាលពោលជាមួយនឹងមាតា ឬបិតាថា "ញោមចូរកាន់យក

នូវវត្ថុនេះ" មិនជាសទ្ធាទេយ្យទេ ។

★ អញ្ញាតកំ "ឥមំ ទេហី"តិ វទតោ វិញ្ញត្តិ ហោតិ ។ ភិក្ខុកាលពោលជាមួយនឹងជនដែលមិនមែនជាញាតិ ថា "អ្នកចូរឱ្យនូវវត្ថុនេះ" រមែងជាវិញ្ញត្តិ ។

"ឥមំ គណ្ហាតី"តិ វទតោ សទ្ធាទេយ្យំ ហោតិ ។ ភិក្ខុកាលពោលជាមួយនឹងជនដែលមិនមែនជាញាតិ ថា "អ្នកចូរកាន់យកនូវវត្ថុនេះ" រមែងជាសទ្ធាទេយ្យ ។

★ "ឥមិនា ឥមំ ទេហី"តិ កយវិក្កយំ អាបជ្ជតោ និស្សគ្គិយំ ។ តស្មា កប្បិយកណ្ឌំ បរិវត្តេន្តេន មាតា-បិតូហិបិ សទ្ធិំ កយវិក្កយំ, អញ្ញាតកេហិ សទ្ធិំ តិស្សោ អាបត្តិយោ មោចេន្តេន បរិវត្តព្វំ ។ កាលភិក្ខុដល់ការទិញដូរថា "ញោមចូរឱ្យនូវវត្ថុនេះ ដោយវត្ថុនេះ" ដូច្នេះ រមែងជានិស្សគ្គិយ ។ ព្រោះហេតុនោះ កាលភិក្ខុផ្លាស់ប្តូរកប្បិយភ័ណ្ឌគប្បីផ្លាស់ប្តូរជាមួយនឹងមាតាបិតាក្តី ជាមួយនឹងជនមិនមែនជាញាតិក្តី ត្រូវផ្លាស់ប្តូរឱ្យរួចផុតចាកអាបត្តិទាំង ៣ ។

<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:</u>

★ **តិស្សោ អាបត្តិយោតិ** អញ្ញាតកវិញ្ញត្តិសទ្ធា-ទេយ្យវិនិបាតនកយវិក្កយាបត្តិសង្ខាតា តិស្សោ អាបត្តិ-

**យោ** ។ *ពាក្យថា* **អាបត្តិ** *៣ ដូច្នេះនេះ បានដល់ អាបត្តិ ៣ ពោលគឺអាបត្តិព្រោះការចេញមាត់សូម ចំពោះបុគ្គលមិនមែនជាញាតិ ១, អាបត្តិព្រោះធ្វើសន្ធាទេយ្យឱ្យធ្លាក់ចុះ ១, និងអាបត្តិព្រោះការទិញដូរ១ ។*

**សទ្ធាទេយ្យវិនិបាតនកថាចប់ ។**

# ២២-អារាមនច្ចាទិទស្សនកថា

ក្នុងវិនយបិដកភាគ ១០ ទំព័រ១៣៤ ព្រះអង្គត្រាស់ថា:

★ ន ភិក្ខវេ នច្ចំ វា គីតំ វា វាទិតំ វា ទស្សនាយ គន្តព្វំ ។ យោ គច្ឆេយ្យ អាបត្តិ ទុក្កដស្ស ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវទៅមើលរាំ ស្តាប់ចម្រៀង ឬភ្លេងប្រគំទេ ភិក្ខុណាទៅត្រូវអាបត្តិទុក្កដ ។

ក្នុងគម្ពីរអដ្ឋកថា ពោលថា:

★ ភិក្ខុដែលទៅ ដើម្បីមើលការរាំយ៉ាងណាមួយ ដោយហោចទៅ សូម្បីការរាំនៃសត្វក្ងោក ក៏ត្រូវអាបត្តិទុក្កដ ។ ភិក្ខុរាំសូម្បីដោយខ្លួនឯងក្តី ប្រើឱ្យអ្នកដទៃរាំក្តី ក៏ត្រូវអាបត្តិទុក្កដដូចគ្នា ។ សូម្បីចម្រៀងយ៉ាងណាមួយ ជាចម្រៀងរបស់អ្នករបាំក៏ដោយ ជាចម្រៀងដែលល្អ (គឺជាប់ដោយអនិច្ចតាធម៌ជាដើម) ក៏ដោយ, ដោយហោចទៅ សូម្បីច្រៀងដោយធ្មេញក៏មិនគួរ ។ ភិក្ខុគិតថា "យើងនឹងច្រៀង" ហើយស្រែកសំឡេងទទេ ក្នុងចំណោកខាងដើមភ្លេងច្រៀង សូម្បីការស្រែកសំឡេងទទេនោះ ក៏មិនគួរ ។ ភិក្ខុច្រៀងខ្លួនឯងក្តី ប្រើឱ្យអ្នកដទៃឱ្យច្រៀងក្តី ក៏ត្រូវអាបត្តិទុក្កដដូចគ្នា ។ សូម្បីការប្រគំយ៉ាងណា

មួយ ក៏មិនគួរ ។ តែកាលធុញទ្រាន់ ឬឋិតនៅក្នុងទីគួររង្កៀស ទើបផ្ទាត់ម្រាមដៃ ឬទះដៃ ក្នុងហេតុទាំងនោះ មិនជាអាបត្តិ ។

សព្វំ អន្តរាកមេ ឋិតស្ស បស្សតោ អនាបត្តិ ។ **មិនជាអាបត្តិដល់ភិក្ខុដែលនៅខាងក្នុងវត្ត មើលការលេងគ្រប់យ៉ាងមានការរាំជាដើម ។** កាលភិក្ខុចេញចាកវត្ត ទៅកាន់វត្ត (ដទៃ) ដោយតាំងចិត្តថា "យើងនឹងមើល" ដូច្នេះ ជាអាបត្តិពិត ។ ភិក្ខុអង្គុយនៅ**លើអាសនៈសាលា**ហើយឃើញ, មិនជាអាបត្តិ ។ ភិក្ខុក្រោកដើរទៅដោយគិតថា "យើងនឹងមើល" ជាអាបត្តិ, សូម្បីឋិតនៅលើផ្លូវថ្នល់ហើយ ងាក-កមើល ជាអាបត្តិដូចគ្នា ។

<u>ក្នុងបាចិត្យាទិយោជនា ពោលថា:</u>

★ **បស្សតោតិ** បស្សន្តស្ស ច សុណន្តស្ស ច ។ សវនម្បិ ហិ ឯកសេសេន វា សាមញ្ញនិទ្ទេសេន វា បស្សនេនេវ សង្គហិតំ ។ **វិហារតោតិ** អនច្ចអគីតអវា-ធិតដ្ឋានវិហារតោ ។ **វិហារន្តិ** នច្ចគិតវាធិតដ្ឋានវិហារំ ។ **អាសនសាលាយាតិ** គាមេ ឋិតាយ អាសនសាលាយ ។

ពាក្យថា **មើល** ដូច្នេះ គឺបានដល់ការមើលផង ការស្តាប់ផង ។ ព្រោះសូម្បីការស្តាប់ ក៏លោកសង្គ្រោះចូលដោយពាក្យថាមើល, ដោយឯកសេសន័យ ឬដោយការសម្តែងជាសាមញ្ញ ។

ពាក្យថា **ភិក្ខុចេញចាកវត្ត ទៅកាន់វត្ត(ដទៃ)** ដូច្នេះ គឺលោកចេញពីវត្ត ដែលជាទីមិនមានការច្រៀង ការរាំ និងការប្រគំ, ទៅកាន់វត្តដែលជាទីកន្លែងមានការច្រៀង ការរាំ និងការប្រគំ ។ ពាក្យថា **លើអាសនៈសាលា** ដូច្នេះ គឺបានដល់អាសនៈសាលា ដែលតាំងនៅខាងក្នុងស្រុក ។

<u>ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:</u>

★ "គីតុបសញ្ហិតំ បន ធម្មំ សោតុំ វដ្ដតីតិ ទីឃនិកាយដ្ឋកថាយំ វុត្ត"ន្តិ វុត្តំ ។ បោរាណគណ្ឋិបទេ បន "ធម្មគិតម្បិ ន វដ្ដតី"តិ វត្វា, "ពុទ្ធស្ស គាយាម វាទេមាតិ វុត្តេ សម្បដិច្ឆិតុំ ន វដ្ដតិ, ទុក្កដំ ហោតី"តិ វុត្តំ, "បូជំ ករោម, ជាតកំ វា វត្តុំ វា ទេសេមាតិ វុត្តេ "សាធូ"តិ សម្បដិច្ឆិតុំ វដ្ដតី"តិ ច វុត្តំ ។

*ក្នុងអដ្ឋកថាទីឃនិកាយពោលថា* "ភិក្ខុគួរដើម្បីស្តាប់នូវធម៌សូម្បីប្រកបដោយចម្រៀង" ។ **តែនៅក្នុងបោរាណគណ្ឋិបទ** ពោលថា "ភិក្ខុមិនគួរដើម្បីស្តាប់នូវចម្រៀងដែលប្រកបដោយ

ធម៌ទេ” ។ កាលជនទាំងឡាយពោលថា “យើងទាំងឡាយនឹងច្រៀង នឹងប្រគំថ្វាយចំពោះព្រះពុទ្ធ” ដូច្នេះ **មិនគួរដើម្បីទទួលទេ** (កាលទទួល) លោកពោលថា **ត្រូវអាបត្តិទុក្កដ** ។ កាលជនទាំងឡាយពោលថា “យើងទាំងឡាយ នឹងធ្វើនូវការបូជានឹងសម្ដែងនូវព្រះជាតក (មានអបណ្ណកជាតកជាដើម) ឬសម្ដែងនូវរឿង (វិមានវត្ថុ និងបេតវត្ថុ)” ដូច្នេះ លោកពោលថា **គួរដើម្បីទទួលព្រមថា សាធុ** ដូច្នេះ ។

ក្នុងគម្ពីរកង្ខាវិតរណីអភិនវដីកា ពោលថា:

★ តថា ហិ វុត្តំ បរមត្ថជោតិកាយ ខុទ្ទកដ្ឋកថាយ "ធម្មូបសំហិតំ គីតំ វដ្ដតិ, គីតូបសំហិតោ បន ធម្មោ ន វដ្ដតី"តិ ។ ពិតមែន លោកពោលទុក ក្នុងព្រះអដ្ឋកថាខុទ្ទក-និកាយ ឈ្មោះបរមត្ថជោតិកា (ក្នុងបច្ឆិមបញ្ចសិក្ខាបទសូត្រ) ថា “ចម្រៀងដែលប្រកបដោយធម៌ រមែងគួរ, តែធម៌ដែលប្រកបដោយបទថា ចម្រៀង មិនគួរ” ។

ក្នុងគម្ពីរសីលខន្ធវគ្គដីកា ពោលថា:

★ យញ្ច សក្កបញ្ហសុត្តវណ្ណនាយំ សេវិតព្វាសេវិតព្វ-សទ្ទំ និទ្ធារេន្តេន "យំ បន អត្ថនិស្សិតំ ធម្មនិស្សិតំ កុម្ភទាសិគីតម្បិ សុណន្តស្ស បសាទោ វា ឧបជ្ជតិ

និព្ពិធា វា សន្ទាតិ, ឯវរូបេ សទ្ទេ សេវិតព្វោតិ" វុត្តំ តំ អសមាទានសិក្ខាបទស្ស សេវិតព្វតាមត្តបរិយាយេន វុត្តំ ។ សមាទានសិក្ខាបទស្ស ហិ ឯវរូបំ សុណន្តស្ស សិក្ខាបទសំវរំ ភិជ្ជតិ គីតភាវតោតិ វេទិតព្វំ ។

*ក៏ពាក្យឯណា ដែលលោកពោលហើយ ដោយការបញ្ចេញនូវសំលេង* ***គួរសេព និងមិនគួរសេព*** *ក្នុងអដ្ឋកថាសក្កបញ្ហសូត្រថា "ក៏កាលភិក្ខុស្តាប់នូវចម្រៀងណា ដែលអាស្រ័យអត្ថ អាស្រ័យធម៌ សូម្បីចម្រៀងដែលនាងកុម្ភទាសីច្រៀងហើយ កើតសេចក្តីជ្រះថ្លា ឬថាសេចក្តីនឿយណាយរមែងតាំងនៅបាន, សំលេងមានសភាពបែបនោះ គួរសេព" ដូច្នេះ ពាក្យនោះ គឺលោកពោលហើយដោយបរិយាយ ត្រឹម*

***តែភាវៈនៃសិក្ខាបទ ដែលបុគ្គលមិនបានសមាទាន គួរសេព*** *ប៉ុណ្ណោះ ។ តែថាបុគ្គលដែលមានសិក្ខាបទសមាទាន ហើយស្តាប់នូវចម្រៀង មានសភាពបែបនោះ បណ្ឌិតគប្បីជ្រាបថា* ***ការសង្រួមក្នុងសិក្ខាបទ រមែងបែកធ្លាយទៅ*** *ព្រោះភាពជាចម្រៀង ។* តថា ហិ វិនយដ្ឋកថាសុ វុត្តំ, គីតន្តិ នដាទីនំ វា គីតំ ហោតុ, អរិយានំ បរិនិព្វានកាលេ រតនត្តយ-

គុណូបសំហិតំ សាធុគីឡិតគីតំ វា អសំយតភិក្ខូនំ ធម្មភាណកគីតំ វា អន្តមសោ ធន្តគីតម្បិ, យំ គាយិស្សាមាតិ បុព្វភាគេ ឱក្កូជិតំ ករោន្តិ សព្វមេតំ គីតំ ណាម ។ *សមដូចជាពាក្យដែល លោកពោលទុកក្នុងអដ្ឋកថាព្រះវិន័យថា "ពាក្យថា* ***ចម្រៀង*** *បានដល់ ការច្រៀងរបស់អ្នករបាំជាដើម ឬការច្រៀងកីឡា ឱ្យសម្រេចប្រយោជន៍ដែលប្រកបដោយការសរសើរគុណនៃព្រះរតនត្រៃ ក្នុងកាលដែលព្រះអរិយៈទាំងឡាយបរិនិព្វាន ឬការច្រៀងទំនងសូធ្យធម៌សរភញ្ញ របស់ភិក្ខុអ្នកមិនសង្រួមក្តី ដោយហោចទៅសូម្បីការច្រៀងដោយធ្មេញ, ភិក្ខុគិតថាយើងនឹងច្រៀង ហើយស្រែកនូវសំឡេងទទេ ក្នុងចំណែកខាងដើម អាការៈសូម្បីទាំងអស់នោះឈ្មោះថា "ការច្រៀង" ។*

<u>*ក្នុងគម្ពីរសីលខន្ធវគ្គដីកា ពោលថា:*</u>

☆ ន ភិក្ខវេ គីតស្សរេន ធម្មោ គាយិតព្វោ យោ គាយេយ្យ អាបត្តិ ទុក្កដស្សាតិ ហិ ទេសនាយ ឯវ បដិក្ខេបោ **ន សរញាយ** ។ ឥមស្ស ច សិក្ខាបទស្ស វិសុំ វិញ្ញាបនតោ វិញ្ញាយតិ " គីតស្សរេន ទេសិតោបិ

ធម្មោ ន គីតោតិ” ។ ពិតមែន ព្រះអង្គទ្រង់បញ្ញត្តិថា “ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវច្រៀងធម៌ ដោយសំឡេងច្រៀងដ៏វែងៗទេ ភិក្ខុណា ច្រៀងត្រូវអាបត្តិទុក្កដ” ដូច្នេះ គឺព្រះអង្គទ្រង់ហាមឃាត់ហើយ ដោយការសម្ដែងប៉ុណ្ណោះ មិនមែនហាមឃាត់ដោយការស្ដាប់ទេ ។ ក៏សិក្ខាបទនេះ រមែងដឹងច្បាស់ដោយការឱ្យដឹងផ្សេងគ្នាថា “ធម៌សូម្បីសម្ដែងហើយ ដោយសំឡេងដ៏វែងៗ ក៏មិនឈ្មោះថា ជាចម្រៀង” ។

### ការមើល និងការស្ដាប់ចម្រៀងក្នុងអារាម

<u>ក្នុងវិនយបិដកភាគ ៥ ទំព័រ ១៧៨ ព្រះអង្គត្រាស់ថា:</u>

អារាមេ ឋិតា បស្សតិ វា សុណាតិ វា : (ជាអនាបត្តិ)ដល់ភិក្ខុ និងភិក្ខុនីឈរមើល ឬស្ដាប់ក្នុងអារាម ។

ភិក្ខុនិយា ឋិតោកាសំ វា និសិន្នោកាសំ វា និបន្នោកាសំ វា អាគន្ត្វា នច្ចន្តិ វា គាយន្តិ វា វាទេន្តិ វា : ជនទាំងឡាយ មកកាន់កន្លែងដែលភិក្ខុ ឬភិក្ខុនី ឈរនៅ ឬអង្គុយ ឬសឹង ហើយរាំក្តី ច្រៀងក្តី ប្រគំក្តី ។

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>

✯ **អារាមេ ឋិតាតិ** អារាមេ ឋត្វា អន្តរារាមេ វា

ពហិអារាមេ វា ឋត្វាធីនិ បស្សតិ វា សុណាតិ វា អនាបត្តិ ។ ពាក្យថា *ភិក្ខុ ឬភិក្ខុនីឈរក្នុងអារាម* ដូច្នេះ មានសេចក្តីថា ភិក្ខុឬភិក្ខុនីឈរក្នុងអារាមនោះឯង ហើយមើល ឬស្តាប់នូវល្បែងមានការរាំជាដើម ខាងក្នុងអារាមក្តី ខាងក្រៅអារាមក្តី មិនជាអាបត្តិ ។

<u>ក្នុងគម្ពីរវជិរពុទ្ធិដីកា, អភិនវដីកា, សារត្ថទីបនីដីកា ពោលថា:</u>

★ " **អារាមេ ឋត្វាតិ** ន កេវលំ ឋត្វា, តតោ តតោ គន្ត្វាបិ សត្តិរិយាបថេហិ លភតិ ។ "**អារាមេ ឋិតា**"**តិ** បន អារាមបរិយាបន្នភាវទស្សនត្ថំ វុត្តំ ។ ឥតរថា និសិន្នាបិ ន លភេយ្យា"តិ តីសុបិ គណ្ឋិបទេសុ វុត្តំ, តំ សុលិខិតមេវ ។ លោកពោលទុកក្នុងគណ្ឋិបទទាំង ៣ ថា "ពាក្យថា **ឈរនៅក្នុងអារាម** ដូច្នេះ មានសេចក្តីថា មិនមែនតែឈរនៅតែម្យ៉ាងប៉ុណ្ណោះទេ, សូម្បីទៅអំពីទីនោះៗ រមែងបានដោយឥរិយាបថទាំងពួង ។ ក៏ព្រះអដ្ឋកថាចារ្យពោលថា **ឈរនៅក្នុងអារាម** ដូច្នេះ គឺលោកពោលហើយដើម្បីសម្តែងនូវភាវៈនៃការរាប់បញ្ចូលក្នុងអារាម ។ បើកាន់យកសេចក្តីដោយប្រការ

*ដទៃទៀត សូម្បីការអង្គុយ រមែងមិនបាន” (ព្រោះហេតុដូច្នោះ) ពាក្យក្នុងគណ្ឌីបទទាំង ៣ នោះ គឺលោកសសេរទុកល្អហើយ ។*

*<u>តែក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>*

★ **អារាមេ ឋត្វាតិ** ឋិតនិសន្នដ្ឋានេ ឯវ ឋត្វា សមន្តតោ គីវំ បរិវត្តេត្វាបិ បស្សតិ, អនាបត្តិ ។ ឋិតដ្ឋានតោ គន្ត្វា បស្សិតុំ ន វដ្ដតិ ។ កេចិ បន "វដ្ដតី"តិ វទន្តិ ។ តំ បន "ទស្សនាយ គច្ឆេយ្យ បាចិត្តិយ"ន្តិ សាមញ្ញតោ គមនស្ស បដិក្ខិត្តត្តា អនាបត្តិយម្បិ គមនាយ អវុត្តត្តា ច ន គហេតព្វំ ។

*ពាក្យថា **ឈរនៅក្នុងអារាម** ដូច្នេះនេះ មានសេចក្តីថា ភិក្ខុឈរនៅក្នុងទីដែលខ្លួនឈរនៅ ឬអង្គុយនៅប៉ុណ្ណោះ, សូម្បីបង្វិលនូវក ដោយជុំវិញហើយមើល **ជាអនាបត្តិ** ។ (តែ) **មិនគួរដើម្បីទៅអំពីទីដែលខ្លួនឈរនៅ ហើយមើលទេ** ។ តែអាចារ្យពួកខ្លះពោលថា គួរ ។ **ក៏ពាក្យអាចារ្យទាំងនោះ មិនគប្បីកាន់យកទេ** ព្រោះការធ្វើដំណើរទៅ គឺព្រះអង្គទ្រង់ហាមឃាត់ហើយដោយសាមញ្ញថា “ទៅដើម្បីមើលជាអាបត្តិបាចិត្តិយ (ភិក្ខុត្រូវអាបត្តិទុក្កដ)” ដូច្នេះផង ព្រោះព្រះអង្គមិនបានត្រាស់ទុកសូម្បីក្នុងអនាបត្តិ ដោយការដើរទៅផង ។*

<u>ក្នុងអដ្ឋកថា ពោលបន្ថែមទៀតថាៈ</u>

★ ពាក្យថា ជាអនាបត្តិដល់ ភិក្ខុឈរនៅខាងក្នុងអារាម ហើយមើល ដូច្នេះនេះ មានសេចក្ដីថា ជនទាំងឡាយកសាងព្រះរាជវាំងជាដើម ជិតអារាម ជាទីនៅរបស់ភិក្ខុ និងភិក្ខុនី មិនជាអាបត្តិដល់ភិក្ខុ និងភិក្ខុនី ដែលទៅមើលនូវព្រះរាជវាំងជាដើមនោះ ។

<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថាៈ</u>

★ "អជ្ឈារាមេ រាជាគារាទីនិ ករោន្តិ តានិ បស្សន្តិយា អនាបត្តី"តិ វចនតោ "អន្តោ អារាមេ តត្ថ តត្ថ គន្ត្វា នច្ចាទីនិ បស្សិតុំ លភតី"តិបិ សិទ្ធំ ។

ដោយពាក្យថា "ជនទាំងឡាយធ្វើនូវព្រះរាជវាំងជាដើម នៅក្នុងអារាម កាល(ភិក្ខុនិងភិក្ខុនី) មើលនូវព្រះរាជវាំងជាដើម នោះជាអនាបត្តិ" ដូច្នេះ លោកសម្រេចថា "ភិក្ខុ និងភិក្ខុនី រមែងបានដើម្បីទៅក្នុងទីនោះៗ ហើយមើលនូវការរាំជាដើម ក្នុងខាងក្នុងអារាមបាន" ។

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថាៈ</u>

★ សិក្ខាបទនេះ សមុដ្ឋានជាដើម ប្រាកដដូចជាឯឡក-លោមសិក្ខាបទ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ លោកវជ្ជៈ

កាយកម្ម អកុសលចិត្ត មានវេទនា ៣ ដូច្នេះឯង ។

<u>*ក្នុងគម្ពីរកង្ខាវិតរណីអភិនវដីកា ពោលថា:*</u>

★ **សមុដ្ឋានាទីនិ ឯឡកលោមសទិសានីតិ** បន មាតិកាគតបាចិត្តិយស្សេវ វសេន វុត្តំ, សព្វេសំ វសេន បន ឆសមុដ្ឋានន្តិ គហេតព្វំ ។ *ពាក្យថា* **សមុដ្ឋានជាដើម** *ប្រាកដដូចជាឯឡកលោមសិក្ខាបទ ដូច្នេះ គឺព្រះអដ្ឋកថាចារ្យ ពោលហើយ ដោយអំណាចនៃអាបត្តិបាចិត្តិយ ដែលមកហើយ ក្នុងបទមាតិកា, តែគប្បីកាន់យកថា មានសមុដ្ឋាន ៦ ដោយ អំណាចនៃ (បទមាតិកា និងអដ្ឋកថា)ទាំងអស់ ។*

<u>*ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:*</u>

★ "អចិត្តកានិ លោកវជ្ជានី"តិ វុត្តត្តា "នច្ច"ន្តិ វា "គន្ធោ"តិ វា អជានិត្វាបិ ទស្សនេន, វិលិម្បនេន វា អាបជ្ជនតោ វត្ថុអជាននចិត្តេន អចិត្តកានិ ។ "នច្ច"ន្តិ វា "គន្ធោ"តិ វា ជានិត្វា បស្សន្តិយា, វិលិម្បន្តិយា ច អកុសលត្តា ឯវ លោកវជ្ជានិ ។ *ព្រោះអដ្ឋកថាចារ្យ ពោលថា ជាអចិត្តកៈ និងលោកវជ្ជៈ ដូច្នេះ មានសេចក្ដីថា ជាអចិត្តកៈ ដោយចិត្តដែលមិនដឹងវត្ថុ, កាលភិក្ខុសូម្បីមិនដឹង*

ថាជាចម្រៀង ឬក៏គ្រឿងក្រអូបក្តី រមែងត្រូវអាបត្តិដោយការមើល, ឬថាដោយការលោប ។ កាលភិក្ខុដឹងថាជាចម្រៀង ឬក៏ដឹងថាជាគ្រឿងក្រអូប ដូច្នេះហើយទៅមើល ឬក៏លាបជាលោកវជ្ជៈពិត ព្រោះជាអកុសលចិត្ត ។

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

**សិក្ខាបទនេះមានអង្គ៣គឺ**

១-នច្ចាទិតា : ល្បែងមានរាំជាដើម

២-អននុញ្ញាតការណា គមនំៈ ទៅដោយមិនមានហេតុ ដែលព្រះអង្គអនុញ្ញាត

៣-ទស្សនាទិ : បានមើលជាដើម ។

**អារាមនច្ចាទិទស្សនកថាចប់ ។**

# ២៣_ឯកភាជនាទិកថា

## ១_ការឆាន់ភោជននៅក្នុងភាជនៈតែមួយ

<u>*ក្នុងវិនយបិដកភាគ ១០ ទំព័រ ១៨៥ ពោលថាៈ*</u>

✯ ន ភិក្ខវេ ឯកភាជនេ ភុញ្ជិតព្វំ ន ឯកថាលកេ បាតព្វំ ន ឯកមញ្ចេ តុវដ្ដិតព្វំ ន ឯកត្ថរណេ តុវដ្ដិតព្វំ ន ឯកបាវុរណេ តុវដ្ដិតព្វំ ន ឯកត្ថរណបាវុរណេ តុវដ្ដិតព្វំ យោ តុវដ្ដេយ្យ អាបត្តិ ទុក្កដស្ស ។ *ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវ(ឆាន់ភោជន) រួមភាជន៍ជាមួយគ្នា មិនត្រូវផឹកទឹករួមផ្តិលជាមួយគ្នា មិនត្រូវដេកលើគ្រែជាមួយគ្នា មិនត្រូវដេកលើកម្រាលជាមួយគ្នា មិនត្រូវដេកដណ្តប់ជាមួយគ្នា មិនត្រូវដេកលើកម្រាល និងដណ្តប់ជាមួយគ្នាទេ ភិក្ខុណាដេក ត្រូវអាបត្តិទុក្កដ ។*

**ការឆាន់ផ្លែឈើក្នុងភាជនៈតែមួយជាមួយគ្នា មិនគួរ**

<u>*ក្នុងគម្ពីរអដ្ឋកថា ពោលថាៈ*</u>

✯ **ឯកភាជនេតិ** ឯត្ថ **សចេ បន** ឯកោ ភិក្ខុ ភាជនតោ ផលំ វា បូវំ វា គហេត្វា គច្ឆតិ តស្មិ

អបគតេ ឥតរស្ស សេសកំ ភុញ្ជិតុំ វដ្ដតិ ។ ឥតរស្សាបិ តស្មឹ ខីណេ បុន គហេតុំ វដ្ដតិ ។

*ពាក្យថា **រួមភាជន៍ជាមួយគ្នា** ដូច្នេះនេះ គប្បីជ្រាបថា ប្រសិនបើ ភិក្ខុមួយរូបកាន់យកផ្លែឈើឬនំអំពីភាជន៍ទៅ កាលភិក្ខុនោះជៀសចេញទៅហើយ ការដែលភិក្ខុក្រៅនេះឆាន់ផ្លែឈើឬនំដែលនៅសស់ រមែងគួរ ។ ឯភិក្ខុក្រៅនេះ កាលនំនោះអស់ទៅហើយ នឹងមកកាន់យកទៀត ក៏គួរ ។*

*<u>ក្នុងគម្ពីរវិនយាលង្ការដីកា ពោលថា:</u>*

★ ឯកតោ ភាជនំ ឆាម ឯកភាជនស្មឹ ឯកក្ខ-ណេយេវ សហភុញ្ជនំ ន ឆាឆាភាជនេ ។ ឯកភាជ-នស្មឹបិ ន ឆាឆាក្ខណេតិ អាហ "សចេ បឆាតិ"អាទិ ។ បឋមំ គហិតវត្ថុស្ស ខីណត្តា បុន គហេតុំ វដ្ដតិ ។ ឥមិនា សហអភុញ្ជនភាវំ ទស្សេតិ ។ *ការឆាន់ជាមួយគ្នាក្នុងភាជន៍តែមួយ ក្នុងខណៈតែមួយ មិនមែនក្នុងភាជន៍ផ្សេងគ្នាទេ, សូម្បីក្នុងភាជន៍តែមួយ ក៏មិនមែន ក្នុងខណៈផ្សេងគ្នាដែរ ឈ្មោះថា **ជាការឆាន់រួមភាជន៍ជាមួយគ្នា** ។ ព្រោះហេតុនោះ ទើបព្រះអដ្ឋកថាចារ្យពោលថា "ប្រសិនបើភិក្ខុមួយរូប កាន់យកផ្លែឈើ ឬនំ អំពីភាជន៍ហើយទៅ ភិក្ខុដទៃគួរដើម្បីឆាន់នូវ*

វត្ថុដ៏សេសបាន ព្រោះភិក្ខុនោះ លោកជៀសចេញទៅហើយ” ដូច្នេះ ។ ភិក្ខុគួរដើម្បីកាន់យកឆាន់បានទៀត ព្រោះភាវៈនៃវត្ថុដែលខ្លួនកាន់យកទៅជាដំបូងអស់ទៅហើយ ។ ដោយពាក្យថា (ភិក្ខុគួរដើម្បីកាន់យកឆាន់បានទៀត ព្រោះភាវៈនៃវត្ថុដែលខ្លួនកាន់យកទៅជាដំបូងអស់ទៅហើយ) ដូច្នេះនេះ គឺលោកអាចារ្យសម្តែងនូវភាពនៃការមិនឆាន់ជាមួយគ្នា ។

## ការដេកលើគ្រែតែមួយជាមួយគ្នា

ក្នុងវិនយបិដកភាគ ៥ ទំព័រ ២៣៦ពោលថា:

★ ពាក្យថា (ភិក្ខុ) ២ រូបដេកលើគ្រែមួយ(ជាមួយគ្នា) សេចក្តីថា កាលភិក្ខុម្នាក់ដេកនៅហើយ មានភិក្ខុដទៃទៅដេកដែរ ត្រូវអាបត្តិទុក្កដ ។ ម្យ៉ាងទៀត (ភិក្ខុ) ២ រូបដេកព្រមគ្នាត្រូវអាបត្តិទុក្កដ ។ ភិក្ខុទាំង ២ រូបក្រោកឡើង ហើយដេកទៅវិញៗ ត្រូវអាបត្តិទុក្កដ ។ វារៈដែលមិនត្រូវអាបត្តិ គឺភិក្ខុម្នាក់ដេក ភិក្ខុដទៃអង្គុយ ឬភិក្ខុទាំង ២ រូប អង្គុយ ១ ភិក្ខុទាំង ២ រូបនោះ ឆ្កួត ១, ភិក្ខុទាំង ២ រូបនោះខាងដើម បញ្ញត្តិ ១ ។

ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:

★ ឥមស្ស អនាបត្តិវារេ “វវត្ថានំ ឧស្សេត្វា”តិ ឧត្តិ

តស្មា ឞវត្ថានំ កត្វា និបជ្ជិតុំ ន វដ្ដតីតិ ឯកេ ។ វិបុលតរេ វដ្ដតីតិ ឯកេ ។ "អន្តរំ កត្វា និបជ្ជិតុំ វដ្ដតី"តិ បោរាណគណ្ឋិបទេ លិខិតំ ។ អាចារ្យពួកខ្លះ ពោលថា ក្នុងអនាបត្តិវារៈនៃសិក្ខាបទ "ដេកលើគ្រែមួយជាមួយគ្នានេះ" មិនមានពាក្យថា "សម្ដែងនូវការកំណត់(គឺឃាំង) ទេ" ព្រោះហេតុនោះ ភិក្ខុធ្វើនូវការកំណត់(គឺឃាំង) ហើយដេក រមែងមិនគួរ ។ អាចារ្យខ្លះទៀត ពោលថា (គ្រែ)ដែលទូលាយ រមែងគួរ ។ លោកសរសេរទុកក្នុងបោរាណគណ្ឋីបទថា "ភិក្ខុធ្វើនូវចន្លោះហើយដេក រមែងគួរ" ។ សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខាបទ ជាកិរិយា នោសញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។

## ការដេកលើក្រម្រាលតែមួយជាមួយគ្នា

ក្នុងវិនយបិដកភាគ ៥ ទំព័រ ២៣៨ ពោលថា:

★ ទ្វេ ឯកត្ថរណបាវុរណា តុវដ្ដេយ្យុន្តិ តញ្ញេវ អត្ថរិត្វា តញ្ញេវ បារុបន្តិ អាបត្តិ ទុក្កដស្ស ។

ពាក្យថា ភិក្ខុ ២ រូប មានសម្ពត់សម្រាប់ក្រាល និងសម្រាប់ដណ្ដប់តែមួយដេកជាមួយគ្នានោះ សេចក្ដីថា ភិក្ខុ ២

រូប ក្រាលនូវសម្ពត់នោះឯង ហើយដណ្តប់នូវសម្ពត់នោះដដែល ត្រូវ**អាបត្តិទុក្កដ** ។ ភិក្ខុដេកលើកម្រាលជាមួយគ្នា តែដណ្តប់សម្ពត់ផ្សេងគ្នា ត្រូវ**អាបត្តិទុក្កដ** ។ ភិក្ខុដេកលើកម្រាលផ្សេងគ្នា តែដណ្តប់សម្ពត់ជាមួយគ្នា ត្រូវ**អាបត្តិទុក្កដ** ។

វារៈដែលមិនត្រូវអាបត្តិគឺ ពួកភិក្ខុសម្តែងនូវទីកំណត់ហើយដេក ១, ពួកភិក្ខុឆ្កួត ១, ពួកភិក្ខុដើមបញ្ញត្តិ ១ ។

<u>ក្នុងគម្ពីអដ្ឋកថា ពោលថា:</u>

សំពត់ក្រាលទីដេក និងសំពត់ដណ្តប់របស់ភិក្ខុ ២ រូបនេះមួយផ្ទាំងរួមគ្នា ព្រោះដូច្នោះ អ្នកទាំង ២ នោះ ទើបឈ្មោះថា **មានសំពត់សម្រាប់ក្រាល និងដណ្តប់តែមួយដេកជាមួយគ្នា** ។

ពាក្យថា **ដណ្តប់សម្ពត់ជាមួយគ្នា** ដូច្នេះនេះ ជាឈ្មោះនៃ(ភិក្ខុ) ២ រូប ក្រាលជាយម្ខាងនៃសំពត់បាវារ, សំពត់ក្រាលដេក និងកន្ទេលផែងជាដើម ដែលឃ្លាតចាកទីបានហើយដេកដណ្តប់ជាយម្ខាង ។

ពាក្យថា **ការសម្តែងនូវទីកំណត់** (គឺឃាំង) ដូច្នេះនេះ មានសេចក្តីថា មិនជាអាបត្តិដល់ភិក្ខុទាំងពីររូប ជាអ្នកសឹងដាក់សំពត់កាសាយៈ ឬឈើច្រត់ ដោយហោចទៅសូម្បីវត្តពន្ធចង្កេះទុកត្រង់កណ្តាល ។

<u>*ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:*</u>

☆ **វវត្ថានំ ឧស្សេត្វាតិ** ឯត្ថ ឧបរិ ចារុបនម្ហិ មជ្ឈេ ឱភោគំ កត្វា ឧភិន្នំ អន្តរេ ឱតារេតិ, វដ្ដតីតិ ឯកេ ។ វវត្ថានញ្ច យថា ឋានេ ន តិដ្ឋតិ, តថា អតិក្កមិត្វា តុវដ្ដេន្តិយា អាបត្តិយេវាតិ ។ "កិរិយាកិរិយ"ន្តិ ច បោរាណគណ្ឋិបទេ វុត្តំ ។ *(ក្នុងសិក្ខាបទដេកលើកម្រាលមួយជាមួយគ្នានេះ លោកពន្យល់ថា) ក្នុងពាក្យថា* ***ការសម្ដែងនូវការកំណត់*** *(គឺយាំង) ដូច្នេះនេះ អាចារ្យពួកខ្លះ ពោលថា ភិក្ខុធ្វើនូវការយាំងត្រង់កណ្ដាល, សូម្បីជណ្ដប់ខាងលើហើយ ឱ្យឆ្លងចុះត្រង់ចន្លោះនៃភិក្ខុទាំងពីររូប* ***រមែងគួរ*** *។ លោកពោលទុកក្នុងបោរាណគណ្ឋីបទថា ក៏ការសម្ដែងនូវការកំណត់ (គឺការយាំង) រមែងមិនតាំងនៅក្នុងកន្លែងដើម យ៉ាងណា រមែងជាអាបត្តិពិត ដល់ភិក្ខុកាលដេក, ព្រោះឈានកន្លង (ទីដែលយាំងទុក) យ៉ាងនោះ ។ សិក្ខាបទនេះ ជាកិរិយាផង ជាអកិរិយាផង ។ សិក្ខាបទនេះ មានសមុដ្ឋានដូចឯឡកលោមសិក្ខា-បទ ជាកិរិយា សញ្ញាវិមោក្ខ អចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម មានចិត្ត ៣ មានវេទនា ៣ ដូច្នេះឯង ។*

**ឯកភាជនាទិកថាចប់ ។**

# ២៤-លោមសំហារកថា

ក្នុងវិនយបិដកភាគ ១០ ទំព័រ២១៦ ព្រះអង្គត្រាស់ថា:

★ ន ភិក្ខវេ លោមំ សំហរាបេតព្វំ យោ សំហរាបេយ្យ អាបត្តិ ទុក្កដស្ស ។ អនុជានាមិ ភិក្ខវេ អាពាធប្បច្ចយា សម្ពាធេ លោមំ សំហរាបេតុំ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឱ្យគេនាំចេញ នូវរោមក្នុងទីចង្អៀតទេ ភិក្ខុណាឱ្យគេនាំចេញត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ បើមានអាពាធជាហេតុ តថាគតអនុញ្ញាតឱ្យភិក្ខុឱ្យគេនាំចេញ នូវរោមក្នុងទីចង្អៀតបាន ។

ក្នុងបទភាជនីយ៍ពន្យល់ថា

★ សម្ពាធោ នាម ឧភោ ឧបកច្ឆកា, មុត្តករណំ ។ សំហរាបេយ្យាតិ ឯកម្បិ លោមំ សំហរាបេតិ, អាបត្តិ បាចិត្តិយស្ស ។ ពហុកេបិ លោមេ សំហរាបេតិ, អាបត្តិ បាចិត្តិយស្ស ។ ពាក្យថា **រោមក្នុងទីចង្អៀត** ដូច្នេះ គឺបានដល់ រន្ធក្លៀកទាំង ២ និងជុំវិញទ្វារនោម ។

ពាក្យថា **ឱ្យគេនាំចេញ** ដូច្នេះ គឺបានដល់ឱ្យគេនាំចេញ នូវរោមសូម្បីតែ ១ សរសៃ ក៏ត្រូវអាបត្តិបាចិត្តិយ (ចំពោះ

ភិក្ខុត្រូវអាបត្តិទុក្កដ) ។ ឱ្យគេនាំចេញនូវរោម សូម្បីច្រើន ក៏ត្រូវអាបត្តិបាចិត្តិយ (ចំពោះភិក្ខុត្រូវអាបត្តិទុក្កដ) ។

<u>ក្នុងព្រះអដ្ឋកថា ពោលថា:</u>

✯ អាពាធប្បច្ចយា សម្ពាធេ លោមន្តិ គណ្ឌវណ-រុធិអាទិ អាពាធប្បច្ចយា ។ ពាក្យថា **បើមានអាពាធជាហេតុ** តថាគតអនុញ្ញាតឱ្យភិក្ខុឱ្យគេនាំចេញនូវរោមក្នុងទីចង្អៀតបាន ដូច្នេះ មានសេចក្តីថា តថាគតអនុញ្ញាតឱ្យនាំចេញនូវរោមក្នុងទីចង្អៀត ព្រោះមានអាពាធជាបច្ច័យ មានរោគបូស, ដំបៅធំនិងបូសតូចជាដើម ។ ដើម្បីសម្តែងថែក ឱកាសដែលចង្អៀតនោះ ទើបលោកពោលថា **រន្ធក្លៀកទាំង២ និងជុំវិញទ្វារនោម** ។

<u>ក្នុងព្រះអដ្ឋកថា ពោលទៀតថា:</u>

ពាក្យថា **សូម្បីតែរោមមួយសរសៃ** ដូច្នេះ មានសេចក្តីថា ភិក្ខុឱ្យគេនាំចេញនូវរោមតែមួយសរសៃ ឬច្រើនសរសៃ ដោយប្រយោគតែមួយដោយកន្ត្រៃក្តី ដោយដង្កៀបក្តី ឬដោយរបស់មុតយ៉ាងណាមួយក្តី ជាបាចិត្តិយច្រើន (ភិក្ខុជាទុក្កដ) ដោយការរាប់ប្រយោគ មិនមែនរាប់សរសៃរោមទេ ។

## រោមក្នុងទីចង្អៀតនាំចេញដោយខ្លួនឯងមិនគួរ

### ក្នុងគម្ពីរវិនយវិនិច្ឆយដីកា ពោលថា

☆ **សម្ពាធេតិ** ឧបកច្ឆកមុត្តករណសង្ខាតេ សម្ពាធដ្ឋានេ ។ លោមំ សំហរាបេយ្យាតិ សត្ថេន វា សណ្ឌាសេន វា អញ្ញេន យេន កេនចិ បរេន ឆិន្ទាបេយ្យ សយំ វា ឆិន្ទេយ្យ ។ *ពាក្យថា* ***ក្នុងទីចង្អៀត*** *ដូច្នេះ គឺបានដល់ក្នុងទីចង្អៀត ពោលគឺរន្ធក្លៀកទាំង ២ និងជុំវិញទ្វារនោម ។ ពាក្យថា* ***នាំចេញនូវរោម*** *ដូច្នេះ មានសេចក្តីថា ភិក្ខុប្រើអ្នកដទៃឱ្យនាំចេញក្តី* ***នាំចេញដោយខ្លួនឯងក្តី*** *ដោយសស្ត្រាក្តី ដោយសណ្ឌាសក្តី ឬដោយរបស់មុតយ៉ាងណាមួយក្តី ។*

☆ *ក្នុងសិក្ខាបទនេះ ជាអនាបត្តិដល់ ភិក្ខុអាពាធ ១ ភិក្ខុឆ្កួត១, ភិក្ខុខាងដើមបញ្ញត្តិ១ ។ ជាអចិត្តកៈ បណ្ណត្តិវជ្ជៈ កាយកម្ម និងវចីកម្ម ។*

**លោមសំហរកថាចប់ ។**

# ២៥-អវន្ទិយវន្ទិយកថា

*ក្នុងវិនយបិដកភាគ ១០ ទំព័រ ៣១៤ ពោលថា:*

✯ អនុជានាមិ ភិក្ខវេ យថាវុឌ្ឍំ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ, សាមីចិកម្មំ អគ្គាសនំ អគ្គោទកំ អគ្គបិណ្ឌំ ។ ។ ភិក្ខវេ សង្ឃិកំ យថាវុឌ្ឍំ បដិពាហិតព្វំ យោ បដិពាហេយ្យ អាបត្តិ ទុក្កដស្ស : *ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតការថ្វាយបង្គំ ការក្រោកទទួល អញ្ជលីកម្ម សាមីចិកម្ម អាសនៈប្រសើរ ទឹកប្រសើរ និងដុំបាយប្រសើរ ដល់ភិក្ខុតាមលំដាប់ចាស់ទុំ, ម្នាលភិក្ខុទាំងឡាយ តែថាវត្ថុជារបស់សង្ឃ ភិក្ខុមិនត្រូវឃាត់ខាំងតាមលំដាប់ចាស់ទុំទេ, ភិក្ខុណាឃាត់ខាំង ត្រូវអាបត្តិទុក្កដ ។*

**អវន្ទិយបុគ្គល ១០ ពួក**

១-បច្ឆា ឧបសម្បន្នោ : *ភិក្ខុដែលបានឧបសម្បទាក្រោយ*

២-អនុបសម្បន្នោ : *អនុបសម្បន្ន*

៣-នានាសំវាសកោ វុឌ្ឍតរោ អធម្មវាទី : *ភិក្ខុចាស់ដែលមានសំវាសផ្សេងគ្នា ជាអធម្មវាទី ។*

៤-មាតុគ្គាមោ : មាតុគ្រាម

៥-បណ្ឌកោ : មនុស្សខ្ទើយ

៦-ធារិវាសិកោ : ភិក្ខុកំពុងនៅបរិវាស

៧-មូលាយបដិកស្សនារហោ : ភិក្ខុដែលគួរទាញមក
កាន់មូលាបត្តិ ។

៨-មានត្តារហោ : ភិក្ខុដែលគួរដល់មានត្ត

៩-មានត្តចារិកោ : ភិក្ខុដែលកំពុងប្រព្រឹត្តមានត្ត

១០-អព្ភានារហោ : ភិក្ខុដែលគួរដល់អព្ភានកម្ម ។

**វន្ទិយបុគ្គល ៣ ពួក**

១- បុរេ ឧបសម្បន្នោ ភិក្ខុដែលបានឧបសម្បទាមុន

២- នានាសំវាសកោ វុឌ្ឍតរោ ធម្មវាទី ភិក្ខុចាស់ជាង
ដែលមានសំវាសផ្សេងគ្នា ជាធម្មវាទី

៣- តថាគតោ អរហំ សម្មាសម្ពុទ្ធោ ព្រះតថាគត
អរហន្តសម្មាសម្ពុទ្ធ ។

**បុគ្គលដែលភិក្ខុមិនគួរ សំពះ មាន ២៥ ប្រភេទ គឺ**

ក្នុងវិនយបិដកភាគ ១៣ ទំព័រ ៣៥៦ ពោលថា:

១-អន្តរឃរំ បវិដ្ឋោ ភិក្ខុកំពុងចូលទៅកាន់ចន្លោះស្រុក

២-រថ្ថំ គតោ ភិក្ខុកំពុងដើរទៅតាមប្រកផ្លូវ

៣-ឱតមសិកោ ភិក្ខុនៅក្នុងទីងងឹត

៤-អសមន្នាហរន្តោ ភិក្ខុកំពុងខ្វល់ខ្វាយដោយការងារ មិនបានអើពើនឹងការសំពះ

៥-សុត្តោ ភិក្ខុកំពុងដេកលក់

៦-យាគុបានេ ភិក្ខុកំពុងឆាន់បបរ

៧-ភត្តគ្គេ ភិក្ខុនៅក្នុងរោងភត្ត

៨-ឯកាវត្តោ ភិក្ខុងាកទៅក្នុងទីម្ខាង គឺបុគ្គលមានពៀរនឹងគ្នា ជាវិសភាគបុគ្គល

៩-អញ្ញាវិហិតោ ភិក្ខុបញ្ចូនចិត្តទៅកាន់អារម្មណ៍ដទៃ គឺកំពុងគិតហេតុដទៃ

១០-នគ្គោ ភិក្ខុអាក្រាត

១១-ខាទន្តោ ភិក្ខុកំពុងឆាន់បង្អែម

១២-ភុញ្ជន្តោ ភិក្ខុកំពុងឆាន់ចំអាប

១៣-ឧច្ចារំ ករោន្តោ ភិក្ខុកំពុងបន្ទោបង់ឧច្ចារៈ

១៤-បស្សាវំ ករោន្តោ ភិក្ខុកំពុងបន្ទោបង់បស្សាវៈ

១៥-ឧក្ខិត្តកោ ភិក្ខុដែលសង្ឃលើកវត្ត

១៦-បច្ឆា ឧបសម្បន្នោ ភិក្ខុដែលបានឧបសម្បទាក្រោយ

១៧-អនុបសម្បន្នោ *អនុបសម្បន្ន*

១៨-នានាសំវាសកោ វុឌ្ឍតរោ អធម្មវាទី *ភិក្ខុមាន*

*សំវាសផ្សេងគ្នា ទោះបីចាស់ជាងតែជាអធម្មវាទី*

១៩-មាតុគាមោ *មាតុគ្រាម*

២០-បណ្ឌកោ *បណ្ឌកៈ*

២១-បារិវាសិកោ *ភិក្ខុដែលកំពុងនៅបរិវាស*

២២-មូលាយបដិកស្សនារហោ *ភិក្ខុដែលគួរទើងទាញមក*

*ដាក់ក្នុងមូលាបត្តិ*

២៣-មានត្តារហោ *ភិក្ខុដែលគួរដល់មានត្ត*

២៤-មានត្តចារិកោ *ភិក្ខុកំពុងប្រព្រឹត្តមានត្ត*

២៥-អព្ភានារហោ *ភិក្ខុគួរដល់អព្ភានកម្ម ។*

*ក្នុងគម្ពីរអដ្ឋកថា ពោលថាៈ*

★ ឧច្ចារញ្ច បស្សាវញ្ច ករោន្តោ អវោកាសគតត្តា អវន្ទិយោ ។ *ភិក្ខុកំពុងបន្ទោបង់ឧច្ចារៈ និងបស្សាវៈ ឈ្មោះថា ដែលភិក្ខុមិនគួរសំពះ ព្រោះជាអ្នកនៅក្នុងឱកាសមិនសមគួរ ។*

★ **ឧក្ខិត្តកោតិ** តិវិធេនបិ ឧក្ខេបនីយកម្មេន ឧក្ខិត្តកោ អវន្ទិយោ ។ តជ្ជនីយាទិកម្មកតា បន ចត្តារោ

វន្ទិតព្វា ។ ឧបោសថបវារណាបិ តេហិ សទ្ធឹ លព្ភន្តិ ។ ពាក្យថា ភិក្ខុដែលសង្ឃលើកវត្ត ដូច្នេះ មានសេចក្តីថា ភិក្ខុដែលសង្ឃលើកវត្តដោយឧក្ខេបនីយកម្ម សូម្បីទាំង ៣ យ៉ាង (ភិក្ខុដែលសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិ ១, ព្រោះមិនសម្តែងអាបត្តិ ១, ព្រោះមិនលះបង់ទិដ្ឋិ អាក្រក់១, ដែលលោកហៅថា ជាកម្មនានាសំវាសកភិក្ខុ) មិនគួរសំពះ ។ តែបុគ្គល ៤ ពួក ដែលសង្ឃធ្វើតជ្ជនីយកម្មជាដើម គួរសំពះ ។ សូម្បីឧបោសថ និងបវារណា រមែង(ធ្វើ)បានជាមួយភិក្ខុនោះ ។

★ អាទិតោ បដ្ឋាយ ច វុត្តេសុ អវន្ទិយេសុ នគ្គញ្ច ឧក្ខិត្តកញ្ច វន្ទន្តស្ស អាបត្តិ ។ ឥតរេសំ បន អសារុប្បដ្ឋេន ច អន្តរា វុត្តការណេន ច វន្ទនា បដិក្ខិត្តា ក៏ក្នុងបណ្តាបុគ្គលដែលមិនគួរសំពះ ដែលពោលហើយ តាំងអំពីដើម (ចាប់ដើមពីទី១ ដល់ទី ១៥) ជាអាបត្តិដល់ភិក្ខុដែលសំពះភិក្ខុអាក្រាតកាយ និងភិក្ខុដែលសង្ឃលើកវត្តប៉ុណ្ណោះ ។ ចំណែកការសំពះបុគ្គលក្រៅអំពីនោះ ដែលព្រះអង្គហាម ក៏ព្រោះផល គឺការមិនសមគួរ និងព្រោះហេតុដែលពាលហើយក្នុងចន្លោះ ។

★ ឥតោ បរំ បច្ឆា ឧបសម្បន្នាទយោទសបិ អាបត្តិវត្ថុភាវេនេវ អវន្ទិយា ។ តេ វន្ទន្តស្ស ហិ និយមេនេវ

អាបត្តិ ។ តអំពីនោះទៅ បុគ្គលសូម្បីទាំង ១០ ពួក មានភិក្ខុដែលបានឧបសម្បទាក្រោយជាដើម ចាត់ជាអ្នកមិនគួរសំពះ ព្រោះជាវត្ថុនៃអាបត្តិដោយពិត ។ មែនពិត រមែងជាអាបត្តិដល់ភិក្ខុសំពះនូវបុគ្គលទាំងនោះដោយវិន័យដែលកំណត់ទុកតែម្តង ។

★ ឥតិ ឥមេសុ បញ្ចសុ បញ្ចកេសុ តេរស ជនេ វន្ទន្តស្ស អនាបត្តិ ទ្វាទសន្នំ វន្ទនាយ អាបត្តិ ក្នុងបញ្ចកៈ ៥ ពួកនេះ ជាអនាបត្តិ ដល់ភិក្ខុសំពះនូវជន ១៣ ពួក ។ ជាអាបត្តិដល់ភិក្ខុសំពះជន ១២ ពួកដោយប្រការដូច្នេះ ។

<u>ក្នុងគម្ពីរវិនយវិនិច្ឆយដីកា និងវិនយាលង្ការដីកា</u>

<u>ពោលថា:</u>

★ **ឯកាវត្តោតិ** ឯកតោ អាវត្តោ សបត្តបក្ខេ ឋិតោ វេរី វិសភាគបុគ្គលោ ។ អយញ្ហិ វន្ទិយមានោ បាទេនបិ បហរេយ្យ ។ ពាក្យថា ភិក្ខុដែលងាកទៅក្នុងទីម្ខាង គឺបានដល់ភិក្ខុដែលងាកទៅក្នុងទីម្ខាង ដែលឋិតនៅក្នុងចំណែកជាសត្រូវមានពៀរនឹងគ្នា ជាវិសភាគបុគ្គល ។ ព្រោះថាបុគ្គលនេះកាលយើងទៅថ្វាយបង្គំ រមែងប្រហារសូម្បីដោយជើង ។

★ **"នានាសំវាសកោ វុឌ្ឍតរោ អធម្មវាទី អវន្ទិយោ"តិ** វចនតោ ច លទ្ធិនានាសំវាសកោ ឥធ "នានា-

សំវាសកោ"តិ គហិតោតិ វេទិតព្វោ ។ ក៏ដោយពាក្យដែលលោកពោលថា "ភិក្ខុមានសំវាសផ្សេងគ្នា ទោះបីចាស់ជាង តែជាអធម្មវាទី មិនគួរថ្វាយបង្គំ" ដូច្នេះ បណ្ឌិតគប្បីជ្រាបថា ភិក្ខុដែលមានសំវាសផ្សេងគ្នាដោយលទ្ធិ គឺលោកកាន់យកហើយ ក្នុងពាក្យនេះថា "មានសំវាសផ្សេងគ្នា" ដូច្នេះ ៗ

★ **គរុកដ្ឋា ច បញ្ចាតិ** បារិវាសិកមូលាយបដិក-ស្សនារហ-មានត្តារហ- មានត្តចារិក-អព្ភានារហសង្ខាតា បញ្ច គរុកដ្ឋា ច ។ ឥមេ បន អញ្ញមញ្ញស្ស យថាវុឌ្ឍំ វន្ទនាទីនិ លភន្តិ, បកតត្តេន អវន្ទិយត្តា អវន្ទិយេសុ គហិតា ។ ពាក្យថា *ភិក្ខុទាំង ៥ រូប ដែលតាំងនៅក្នុងការគោរព* ដូច្នេះ គឺបានដល់ភិក្ខុទាំង ៥ រូប ពោលគឺភិក្ខុកំពុងនៅបរិវាស ១, ភិក្ខុគួរដល់មូលាយបដិ-កស្សនា១, ភិក្ខុគួរដល់មានត្ត១, ភិក្ខុដែលកំពុងប្រព្រឹត្តមានត្ត១, ភិក្ខុដែលគួរដល់អព្ភាន១, តាំងនៅក្នុងការគោរព ៗ ក៏ភិក្ខុទាំង ៥ រូបនេះ រមែងបាននូវការថ្វាយបង្គំជាដើម ដល់គ្នាទៅវិញទៅមកតាមលំដាប់ចាស់ទុំ ៗ ភិក្ខុដែលជាបកតត្ត គឺលោកកាន់យកហើយក្នុងអវន្ទិយបុគ្គល ព្រោះភាពជាបុគ្គលមិនគួរថ្វាយបង្គំតែម្យ៉ាង ៗ

<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:</u>

★ **អន្តរា វុត្តការណេនាតិ** តំ ហិ វន្ទន្តស្ស មញ្ចបាទាទីសុបិ នលាដំ បដិហញ្ញេយ្យាតិអាទិនា វុត្ត-ការណេន ។ ពាក្យថា *ព្រោះហេតុដែលពោលហើយ ក្នុងចន្លោះ ដូច្នេះ គឺបានដល់ ព្រោះហេតុដែលលោកពោលហើយដោយពាក្យថា "ពិតមែន កាលភិក្ខុថ្វាយបង្គំ បុគ្គលនៅក្នុងទីងងឹតនោះ ថ្ងាស់នឹងគប្បីប៉ះខ្ទប់ត្រង់ជើងគ្រែជាដើម" ។*

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

★ **មញ្ចបាទាទីសុបិ នលាដំ បដិហញ្ញេយ្យាតិ** អន្ធការេ ច ខណ្ឌំ បញ្ញបេត្វា វន្ទិតុំ ឱនមន្តស្ស នលាដំ វា អក្ខិ វា មញ្ចាទីសុ បដិហញ្ញតិ ។ ឯតេន វន្ទតោបិ អាបត្តិអភាវំ វត្វា វន្ទនាយ សព្វថា បដិក្ខេបា-ភាវញ្ច ទីបេតិ ។ *ពាក្យថា "កាលភិក្ខុថ្វាយបង្គំក្នុងទីងងឹត ថ្ងាស់នឹងគប្បីប៉ះខ្ទប់ត្រង់ជើងគ្រែជាដើម ដូច្នេះ មានសេចក្តីថា កាលភិក្ខុក្រាលនូវប្រមខណ្ឌ (កំណាត់ស្បែក) ក្នុងទីងងឹត ហើយក្រាបចុះថ្វាយបង្គំ ថ្ងាស់ ឬភ្នែក រមែងប៉ះទង្គិចត្រង់គ្រែជាដើម ។ ដោយហេតុនោះ លោកពោលនូវភាពមិនមានអាបត្តិសូម្បីដោយការថ្វាយបង្គំ ហើយសម្តែងនូវភាពមិនមានការ*

បដិសេធ ដោយប្រការទាំងពួង ក្នុងការថ្វាយបង្គំ ។

<u>ក្នុងវិនយបិដកភាគ ១៣ ទំព័រ ៣៥៨ ពោលថាៈ</u>

**វន្ទិយបុគ្គលមាន ៥ ពួក**

១–បុរេ ឧបសម្បន្នោ ភិក្ខុដែលបានឧបសម្បទាមុន

២–នានាសំវាសកោ វុឌ្ឍតរោ ធម្មវាទី ភិក្ខុដែល
មានសំវាសផ្សេងគ្នា ដែលចាស់ជាងជាធម្មវាទី

៣–អាចរិយោ ភិក្ខុជាអាចារ្យ

៤–ឧបជ្ឈាយោ ភិក្ខុជាឧបជ្ឈាយ៍

៥–តថាគតោ អរហំ សម្មាសម្ពុទ្ធោ ព្រះតថាគត
អរហន្តសម្មាសម្ពុទ្ធ ។

<u>ក្នុងព្រះអដ្ឋកថាបរិវារៈ ពោលទុកថា</u>

★ អាចរិយោ វន្ទិយោតិ បព្វជ្ជាចរិយោ ឧបសម្បទាចរិយោ, និស្សយាចរិយោ ឧទ្ទេសាចរិយោ ឱវាទាចរិយោ អយំ បញ្ចវិធោបិ អាចរិយោ វន្ទិយោ ។

ពាក្យថា អាចារ្យជាវន្ទិយបុគ្គល ដូច្នេះ មានសេចក្តីថា អាចារ្យទាំង ៥ ពួកនេះគឺ បព្វជ្ជាចារ្យ ឧបសម្បទាចារ្យ និស្សយាចារ្យ ឧទ្ទេសាចារ្យ ឱវាទាចារ្យ ដែលភិក្ខុគួរសំពះ ។

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

★ វន្ទិតព្វេសុ ឧទ្ទេសាចរិយោ និស្សយាចរិយោ ច យស្មា នវកាបិ ហោន្តិ, តស្មា "តេ វុឌ្ឍា ឯវ វន្ទិយាតិ វន្ទិតព្វា"តិ ។ ក្នុងបុគ្គលដែលត្រូវថ្វាយបង្គំនោះ ក៏ឧទ្ទេសាចារ្យ និងនិស្សយាចារ្យ សូម្បីជាភិក្ខុមានវស្សាខ្ចីជាង ក៏មាន, ព្រោះហេតុនោះ គប្បីជ្រាបថា អាចារ្យទាំងនោះ ជាភិក្ខុចាស់វស្សាជាង ប៉ុណ្ណោះ ដែលត្រូវថ្វាយបង្គំ ។

**ភិក្ខុខ្ចីជាងថ្វាយបង្គំបាទាភិក្ខុចាស់ជាង**

<u>ក្នុងវិនយបិដក ភាគ១៣ ទំព័រ៣៥៩ ទ្រង់ត្រាស់ថា:</u>

ភិក្ខុខ្ចីជាង កាលនឹងថ្វាយបង្គំបាទាភិក្ខុចាស់ជាង ត្រូវតម្កល់ធម៌ ៥ យ៉ាង ទុកខាងក្នុងទើបថ្វាយបង្គំចំពោះបាទា ៖

១-នវកតរេនុបាលិ ភិក្ខុនា វុឌ្ឍតរស្ស ភិក្ខុនោ បាទេ វន្ទន្តេន ឯកំសំ ឧត្តរាសង្គំ ករិត្វា ម្នាលឧបាលិ ភិក្ខុខ្ចីជាងកាលនឹងថ្វាយបង្គំបាទាភិក្ខុចាស់ជាង ត្រូវធ្វើឧត្តរាសង្គឆៀងស្មាម្ខាង ។

២-អញ្ជលឹ បគ្គហេត្វា ផ្គងនូវអញ្ជលី ។

៣-ឧភោហិ បាណិតលេហិ បាទានិ បរិសម្ពាហន្តេន

ប្របាច់បាទាដោយបាតដៃទាំងគូ ។

៤-បេមំ តម្កល់សេចក្ដីស្រឡាញ់ទុក

៥-គារវំ ឧបដ្ឋាបេត្វា តម្កល់សេចក្ដីគោរព ។

ក្នុងវិនយបិដកភាគ ១៣ ទំព័រ ៣៨៧ ពោលថា:

★ បុគ្គលដែលមិនគួរអភិវាទ និងបុគ្គលដែលមិនគួរធ្វើអញ្ជលិកម្ម និងសាមីចិកម្ម មានប៉ុន្មានពួក? អាបត្តិទុក្កដ មានដល់បុគ្គលប៉ុន្មានពួក? ឆ្លើយថា :

ទស បុគ្គលោ នាភិវាទេតព្វា អញ្ជលិសាមិចេន ច ទសន្នំ ទុក្កដំ ហោតិ : បុគ្គលដែលមិនគួរអភិវាទ និងបុគ្គលដែលមិនគួរធ្វើអញ្ជលិកម្ម និងសាមីចិកម្ម មាន ១០ ពួក អាបត្តិទុក្កដ មានដល់បុគ្គល ១០ ពួក ។

ក្នុងគម្ពីរអដ្ឋកថា ពោលថា:

ពាក្យថា បុគ្គលដែលមិនគួរសំពះ ១០ ពួក ដូច្នេះនេះ គឺបានដល់ បុគ្គល (ដែលមិនគួរសំពះ) ១០ ពួក ដែលព្រះអង្គទ្រង់ត្រាស់ទុកក្នុងសេនាសនក្ខន្ធកៈ ។

★ **អញ្ជលិសាមិចេន ចាតិ** សាមីចិកម្មេន សទ្ធឹ អញ្ជលិ ច តេសំ ន កាតព្វោ, នេវ ធានិយាបុច្ឆន-

តាលវណ្ដគ្គហណាទិ ខន្ធកវត្តំ តេសំ ធស្សេតុំ, ន អញ្ជលិ បគ្គណ្ហិតព្វោតិ អត្ថោ ។

ពាក្យថា **អញ្ជលីកម្ម ព្រមទាំងសាមីចិកម្ម** ដូច្នេះ មានសេចក្ដីថា អញ្ជលីកម្ម ព្រមទាំងសាមីចិកម្ម ដែលភិក្ខុមិនគប្បីធ្វើដល់បុគ្គល ១០ ពួកនោះ ។ អធិប្បាយថា ក្នុងខន្ធកៈវត្តមានសួរដោយទឹកសម្រាប់ឆាន់ និងចាប់យកផ្លិតស្លឹកត្នោតជាដើម ដែលភិក្ខុមិនគប្បីសម្ដែងដល់បុគ្គល ១០ ពួកនោះ, អញ្ជលីកម្មក៏មិនគប្បីផ្គងឡើង ។ (ជាអាបត្តិទុក្កដ ដល់ភិក្ខុដែលធ្វើយ៉ាងនោះ ដល់បុគ្គល ១០ ពួកនោះឯង) ។

## ការថ្វាយបង្គំប្រកបដោយអង្គ ៥ តាមដីកាវិនយា

<u>ក្នុងគម្ពីរវិនយាលង្ការដីកា ពោលថា:</u>

★ កថំ បញ្ចបតិដ្ឋិតសរូបំ កាជិតំ ? ឥធ ឯកំសំ ឧត្តរាសង្គំ ករិត្វាតិ ឯកំ, អញ្ជលិំ បគ្គហេត្វាតិ ឯកំ, ឧភោហិ ចាណិតលេហិ បាទានិ បរិសម្ពាហន្តេនាតិ ឯកំ, បេមញ្ច ឧបដ្ឋាបេត្វាតិ ឯកំ, គារវញ្ច ឧបដ្ឋាបេត្វាតិ ឯកំ, ឯវំ បញ្ចបតិដ្ឋិតសរូបំ កាជិតំ ហោតិ ។ <u>សួរថា</u> ការសរុបនូវការថ្វាយបង្គំ ដោយតាំងទុកអវយវៈ ៥ យ៉ាង តើលោកពោលដូចម្ដេចទៅ ? <u>ឆ្លើយថា</u> ការសរុបនូវការ

*ថ្វាយបង្គំ ដោយតាំងទុកអវយវៈ ៥ យ៉ាង ជាការដែលលោកពោលទុកហើយ ក្នុងទីនេះយ៉ាងនេះថា: "ត្រូវធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង ជាអង្គ១, ផ្គងអញ្ជលី ជាអង្គ១, ប្របាច់បាទាដោយបាតដៃទាំងគូ ជាអង្គ១, តម្កល់សេចក្តីស្រឡាញ់ទុកជាអង្គ១, តម្កល់សេចក្តីគោរព ជាអង្គ១ " ។*

## ការថ្វាយបង្គំប្រកបដោយអង្គ ៥ ដែលមកតាមប្រវេណី

☆ ឥទានិ បន អាចរិយា អភិនវអាគតានំ ទហរានញ្ច សាមណេរានញ្ច វន្ទនានយំ សិក្ខន្តា ន ឥមំ អាហច្ចភាសិតំ បាឡឹ គហេត្វា សិក្ខន្តិ, អថ ខោ បវេណីអាគតនយំយេវ គហេត្វា សិក្ខន្តិ ។ កថំ ?

☆ យទិ ឋត្វា វន្ទថ, ទ្វេ បាទតលានិ សមំ ភូមិយំ បតិដ្ឋាបេត្វា ទ្វេ ហត្ថតលានិ សមំ ផុសាបេត្វា នលាដេ បតិដ្ឋាបេត្វា វន្ទិតព្វាភិមុខំ ឱនមិត្វា វន្ទថាតិ ។

*តែឥឡូវនេះ អាចារ្យទាំងឡាយកាលឱ្យសាមណេរ និងភិក្ខុកំម្លោះដែលមកបួសថ្មី ឱ្យថ្វាយបង្គំ មិនបានកាន់យកនូវបាលីភាសិត ដែលមានមកនេះ ហើយឱ្យសិក្សាទេ, បែរជាកាន់យកនូវន័យដែលមកតាមប្រវេណី ហើយឱ្យសិក្សាវិញ ។ សួរថា តើប្រវេណីនោះដូចម្តេច? ឆ្លើយថា ប្រវេណីនោះ គឺ :*

<u>*បើឈរសំពះ*</u> *ត្រូវដាក់បាតជើងទាំងពីរ លើផ្ទៃផែនដីដ៏ស្មើ ហើយញាំងបាតដៃទាំងពីរ ឱ្យប៉ះខ្ទប់ស្មើគ្នា រួចដាក់ទុកនៅលើថ្ងាស់ ហើយបង្អោនមុខឆ្ពោះទៅកាន់ទីដែលខ្លួនត្រូវសំពះ ហើយសំពះ ។*

ឥធ បន ទ្វេ បាទតលានិ, ទ្វេ ហត្ថតលានិ នលាដញ្ចាតិ បញ្ចសុ បតិដ្ឋិតានីតិ សរូបំ វេទិតព្វំ ។ *ក៏ក្នុងសេចក្ដីនេះ អាចារ្យទាំងឡាយ ពោលនូវការសរុបថា* ***តាំងនៅក្នុងអង្គ ៥*** *គឺបាតជើងទាំងពីរ, បាតដៃទាំងពីរ ហើយនិងថ្ងាស់មួយ ។*

✯ យទិ និសីទិត្វា វន្ទេយ្យ, បឋមំ ទ្វេ បាទតលានិ ភូមិយំ សមំ បតិដ្ឋាបេត្វា ទ្វេ ជាណុមណ្ឌលានិ សមំ ឧស្សាបេត្វា ទ្វេ កបរានិ ទ្វិន្នំ ជាណូនំ ឧបរិ សមំ ឋបេត្វា ទ្វេ ហត្ថតលានិ សមំ ផុសិតានិ កត្វា អញ្ជលិសង្ខាតំ ករបុដំ សិរសង្ខាតេ នលាដេ បតិដ្ឋាបេត្វា វន្ទេយ្យ ។ តតោ ឱនមិត្វា ទ្វេ ជាណុមណ្ឌលានិ ច ទ្វេ កប្បរានិ ច ភូមិយំ សមំ បតិដ្ឋាបេត្វា ទ្វេ ហត្ថតលានិ បសារេត្វា សមំ ភូមិយំ ឋបេត្វា សីសំ ឧភិន្នំ ហត្ថបិដ្ឋីនំ ឧបរិ កត្វា ភូមិយំ បតិដ្ឋាបេត្វា

វន្ទជាតិ ។ ឯត្ថ តុ ទ្វេ បាទតលានិ ឯកំ កត្វា តថា ទ្វេ ជាណុមណ្ឌលានិ ឯកំ, ទ្វេ កប្បរានិ ឯកំ ទ្វេ ហត្ថតលានិ ឯកំ, សីសំ ឯកំ កត្វា បញ្ចបតិដ្ឋិត-សរូបំ កថេន្តិ ។ ឯស នយោ បាឡិអដ្ឋកថាដីកាសុ ន ទិដ្ឋោ ។ <u>បើអង្គុយថ្វាយបង្គំ</u> មុនដំបូងត្រូវដាក់បាតជើងទាំងពីរលើផែនដីដ៏ស្មើ ហើយលើកឡើងនូវជង្គង់ទាំងពីរឱ្យស្មើ រួចដាក់នូវជុំដៃទាំងពីរ នៅខាងលើជង្គង់ដែលស្មើ ហើយធ្វើបាតដៃទាំងពីរឱ្យប៉ះស្មើគ្នា រួចដាក់នៅក្រពុំអញ្ជលី ត្រង់ថ្ងាស់ពោលគឺក្បាល ហើយថ្វាយបង្គំ ។ តពីនោះ ត្រូវឱនចុះហើយដាក់ក្បាលជង្គង់ទាំងពីរ និងជុំដៃទាំងពីរ នៅលើផែនដីដ៏ស្មើ ហើយ លានូវបាតដៃទាំងពីរ ដាក់នៅលើផែនដីដ៏ស្មើ ហើយដាក់ក្បាលនៅលើខ្នងដៃទាំងពីរ ឱ្យតាំងនៅលើផែនដី ថ្វាយបង្គំ ។ ចំណែកឯក្នុងសេចក្តីនេះ អាចារ្យទាំងឡាយពោល **សរុបអង្គ ៥** ព្រោះធ្វើនូវបាតជើងទាំងពីរ ជាអង្គ ១, ក្បាលជង្គង់ទាំងពីរ ជាអង្គ១, ជុំដៃទាំងពីរ ជាអង្គ១, បាតដៃទាំងពីរ ជាអង្គ១ ហើយធ្វើនូវក្បាល ជាអង្គ១ ។ ន័យដែលមកតាមប្រវេណីនេះ មិនបានឃើញក្នុងបាលិ, អដ្ឋកថា និងដីកាឡើយ ។

★ បវេណីអាគតនយតោ បាលិនយោ ពលវតរោ

តស្មា ភគវតោ អាណំ គរុំ ករោន្តេហិ សប្បុរិសេហិ បាលិនយោ សមាសេវិតព្វោតិ អម្ហាកំ ខន្តិ , វិមំសិត្វា គហេតព្វំ ។ *តាមសេចក្តីគាប់ចិត្តរបស់ខ្ញុំថា "ន័យក្នុងព្រះបាលីមានកម្លាំងជាងន័យដែលមកតាមប្រវេណី, ព្រោះហេតុនោះ ន័យក្នុងព្រះបាលី គឺសប្បុរសទាំងឡាយ កាលធ្វើនូវសេចក្តីគោរពក្នុងអាជ្ញារបស់ព្រះមានព្រះភាគ គប្បីសេពដោយល្អ, ត្រូវពិចារណាសិន សឹមកាន់យក ។*

## ការថ្វាយបង្គំប្រកបដោយអង្គ ៥ តាមន័យក្នុងបរមត្ថទីបនី

*<u>ចំណែកនៅក្នុងបរមត្ថទីបនីដីកា ពោលថា:</u>*

✯ វន្ទនា បន តិវិធា កាយវន្ទនាទិវសេន ។ យថាហ តិស្សោ ឥមា ភិក្ខវេ វន្ទនា កតមា តិស្សោ ។ កាយេន វន្ទតិ វាចាយ វន្ទតិ មនសា វន្ទតីតិ ។ *ក៏ការថ្វាយបង្គំមាន ៣ ប្រការគឺ ដោយអំណាចការថ្វាយបង្គំដោយកាយជាដើម ។ សមដូចពាក្យដែលព្រះអង្គត្រាស់ទុកក្នុងអង្គុត្តរនិកាយ តិកនិបាត ថា "ម្នាលភិក្ខុទាំងឡាយ ការថ្វាយបង្គំនេះមាន ៣ យ៉ាង តើ ៣ យ៉ាងនោះដូចម្តេច? គឺ ការថ្វាយបង្គំដោយកាយ ១ ដោយវាចា ១, និងដោយចិត្ត ១" ។*

★ តត្ថ សេដ្ឋចិត្តំ បច្ចុបដ្ឋាបេត្វា ជាណុទ្វយ កប្បរទ្វយ ឆលាដ សង្ខាតានិ បញ្ច អង្គានិ ភូមិយំ បតិដ្ឋាបេត្វា វន្ទនេយ្យានំ អភិមុខំ និប្បជ្ជន្តោ កាយេន វន្ទតិ ឆាម ។ យំ សន្ធាយ បញ្ចបតិដ្ឋិតេន វន្ទិត្វាតិ តត្ថ តត្ថ វុត្តំ ។ *បណ្ដាការថ្វាយបង្គំនោះ បុគ្គលញ៉ាំងចិត្តដ៏ប្រសើរឱ្យតាំងនៅចំពោះ ហើយញ៉ាំងអវយវៈទាំង ៥ ពោលគឺក្បាល-ជង្គង់ទាំង ២, ជុំដៃទាំង ២, និងថ្ងាស់ ១ ឱ្យតាំងនៅលើផែនដី ហើយឱនចុះទៅថ្វាយបង្គំ ចំពោះមុខបុគ្គលដែលគួរថ្វាយបង្គំ ឈ្មោះថា* ថ្វាយបង្គំតាមផ្លូវកាយ *។ សមដូចដែលលោកពោលទុក ក្នុងទីនោះៗ (គឺក្នុងអដ្ឋកថា និងដីកាចារ្យទាំងឡាយ) ថា* “បញ្ចបតិដ្ឋិតេន វន្ទិត្វា *: ថ្វាយបង្គំដោយការតាំងអង្គ ៥ យ៉ាងទុក” ។*

**អវន្ទិយវន្ទិយកថាចប់ ។**

# ២៦_បដិភាណចិត្តកម្មកថា

## ក្នុងវិនយបិដកភាគ ១០ ទំព័រ ២៧៩ ពោលថា:

*សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឱ្យគេគូរគំនូរជារូបស្ត្រី និងរូបបុរសក្នុងវិហារ ។ ព្រះអង្គទ្រង់ត្រាស់ថា* **ន ភិក្ខវេ បដិភាណចិត្តំ ការាបេតព្វំ ឥត្ថីរូបកំ បុរិសរូបកំ យោ ការាបេយ្យ អាបត្តិ ទុក្កដស្ស ។ អនុជានាមិ ភិក្ខវេ មាលាកម្មំ លតាកម្មំ មករទន្តកំ បញ្ចបដិកំ ។** *ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឱ្យគេគូរគំនូរ ជារូបស្រី និងរូបបុរសទេ ភិក្ខុណាឱ្យគេគូរ ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគំនូរផ្ទៃផ្កា និងគំនូរផ្ទៃវល្លិ និងក្បាច់ធ្មេញមករ និងក្បាច់មានស្រទាប់ ៥ ។*

## ក្នុងគម្ពីរអដ្ឋកថា ពោលថា:

★ **ន ភិក្ខវេ បដិភាណចិត្តន្តិ ឯត្ថ ន កេវលំ ឥត្ថីបុរិសរូបមេវ តិរច្ឆានរូបំ អន្តមសោ គណ្ឌុប្បាទរូបម្បិ ភិក្ខុនោ សយំ កាតុំ វា ការាបេតុំ វា ន វដ្ដតិ ឧបាសកទ្វារបាលំ ការាបេតិ វត្តុម្បិ ន លព្ភតិ ។ ជាតក-ប្បករណអសទិសទានាទីនិ បន បសាទនីយានិ និព្វិទា-**

បដិសំយុត្តានិ វា វត្ថូនិ បរេហិ ការាបេតុំ លព្ភតិ ។ មាលាកម្មាទីនិ សយម្បិ កាតុំ លព្ភតិ ។ ក្នុងពាក្យថា *ភិក្ខុមិនត្រូវឱ្យគេគួរគំនូរ* ដូច្នេះនេះ គប្បីជ្រាបថារូបស្រ្តី និងបុរសម្យ៉ាងប៉ុណ្ណោះ ដែលភិក្ខុមិនគួរ ឱ្យគូរក៏ទេ, រូបសត្វតិរច្ឆាន, ដោយហោចទៅសូម្បីរូបសត្វជន្លេន ភិក្ខុមិនគួរគូរដោយខ្លួនឯង ឬបង្គាប់គេថា "លោកចូរគូរ" ។ *រមែងមិនបានសូម្បីដើម្បីពោលថា "នែឧបាសក លោកចូរគូរអ្នករក្សាទ្វារ" ។ តែរមែងប្រើអ្នកដទៃឱ្យគូររូបទាំងឡាយដែលគួរជ្រះថ្លា មានបករណ៍ជាតក និងអសទិសទានជាដើម ឬរឿងដែលប្រកបដោយសេចក្តីនឿយនាយបាន ។ តែរមែងបានទឹងធ្វើខ្លួនឯងនូវមាលាកម្មជាដើម ។*

### ភិក្ខុគួររូបព្រះសម្មាសម្ពុទ្ធ ដោយខ្លួនឯងមិនគួរទេ

<u>*ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:*</u>

★ **"ការាបេតី"តិ** វត្ថុម្បិ ន លព្ភតីតិ អាណត្តិយា ឯវ បដិក្ខិត្តត្តា ទ្វារបាលំ ករី ន ការេសីតិអាទិនា បរិយាយេន វត្តុំ វដ្តតិ ។ ពាក្យថា **រមែងមិនបានដើម្បីពោលថា "អ្នកចូរគូរ"** ដូច្នេះនេះ មានសេចក្តីថា កាលដែលភិក្ខុពោលដោយបរិយាយ ដោយពាក្យជាដើមថា "ហេតុអ្វី បាន

*ជាអ្នកមិនគួរនូវអ្នករក្សាទ្វារ" ដូច្នេះ **រមែងគួរ,** ព្រោះព្រះអដ្ឋកថាចារ្យបដិសេធហើយ ដោយការបន្ទាប់ប៉ុណ្ណោះ ។*

★ **ជាតកបករណន្តិ** ជាតកបដិសំយុត្តំ ឥត្ថិបុរិសាទិ យំ កិញ្ចិ *រូបំ* អធិប្បេតំ ។ *ពាក្យថា* **បករណ៍ ជាតក** *ដូច្នេះ* មានសេចក្តីថា *ប្រើគេឱ្យគូរនូវរូបណាមួយ* មាន *រូបប្រុស និងស្រីជាដើម ដែលប្រកបដោយជាតក គឺលោកបំណាងយកហើយ ។*

★ **"បរេហិ ការាបេតុ"ន្តិ** *វុត្តត្តា* ពុទ្ធរូបម្បិ សយំ កាតុំ ន លភតិ ។ *ព្រោះពាក្យដែលអដ្ឋកថាចារ្យពោលថា **ប្រើអ្នកដទៃឱ្យគួរ** ដូច្នេះនេះ* មានសេចក្តីថា *(ភិក្ខុ និងសាមណេរ) **រមែងមិនបានដើម្បីគូរនូវរូប សូម្បីរូបរបស់ព្រះសម្មាសម្ពុទ្ធដោយខ្លួនឯងទេ ។***

*<u>ក្នុងគម្ពីរវិនយវិនិច្ឆយ ពោលថា:</u>*

★ ជាតកំ បន វត្ថុំ វា, ការាបេតុំ បរេហិ វា មាលាកម្មំ លតាកម្មំ, សយំ កាតុម្បិ វដ្ដតិ ។ *ក៏ជាតកក្តី* ***រឿងរាវក្តី*** *ភិក្ខុប្រើអ្នកដទៃឱ្យគូរ (រមែងគួរ) គំនូរផ្ទើផ្កា និងគំនូរផ្ទើវល្លិ ភិក្ខុគួរដើម្បីធ្វើសូម្បីដោយខ្លួនឯងបាន ។*

<u>ក្នុងគម្ពីរវិនយវិនិច្ឆយដីកា ពោលថា:</u>

★ **ជាតកាទិ** អបណ្ណកជាតកាទិជាតកញ្ច ។

ពាក្យថា ជាតក ដូច្នេះ បានដល់ជាតក មានអបណ្ណក-ជាតកជាដើម ។

★ **វត្ថូទិ** វិមានវត្ថុអាទិកំបសាទជនកំ វា បេត-វត្ថុអាទិកំ សំវេគជនកំ វា វត្ថុំ ។

ពាក្យថា រឿងរ៉ាវ ដូច្នេះ បានដល់រឿងដែលនាំឱ្យកើតសេចក្ដីជ្រះថ្លា មានវិមានវត្ថុជាដើម និងរឿងនាំឱ្យកើតសេចក្ដីសង្វេគ មានបេតវត្ថុជាដើម ។

★ **បរេហិ វាតិ** ឯត្ថ វា-សទ្ទោ អវធារណោ, តេន បរេហិការាបេតុមេវ វដ្ដតិ, ន សយំ កាតុន្តិ ទីបេតិ ។ វា ស័ព្ទ ក្នុងពាក្យថា ប្រើអ្នកដទៃ ដូច្នេះនេះ ចុះក្នុងអត្ថ អវធារណៈ, ព្រោះហេតុនោះ លោកសម្ដែងថា ភិក្ខុប្រើអ្នកដទៃប៉ុណ្ណោះ ទើបគួរ, គួរទូរគំនូរដោយខ្លួនឯង **មិនគួរទេ** ។

**បដិភាណចិត្តកម្មកថា ចប់ ។**

# ២៧_សេនាសនៈកថា

<u>ក្នុងវិនយបិដកភាគ ១០ ទំព័រ ៣៣៤ ពោលថា:</u>

★ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុ ២ សម្តែង (វិន័យ) អង្គុយលើអាសនៈស្មើគ្នាក៏បាន, ខ្ពស់ជាង ក៏បាន ដោយសេចក្តីគោរពក្នុងធម៌ និងអនុញ្ញាតឱ្យភិក្ខុជាថេរៈ ដែលនិមន្តភិក្ខុ ២ ឱ្យសម្តែងវិន័យ អង្គុយលើអាសនៈស្មើគ្នា ក៏បាន ទាបណាស់ទៅក៏បាន ដោយសេចក្តីគោរពក្នុងធម៌ ។

★ **អនុជានាមិ ភិក្ខវេ សមានាសនិកេហិ សហ និសីទិតុំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យពួកភិក្ខុដែលមានអាសនៈស្មើគ្នា អង្គុយជាមួយគ្នាបាន ។

★ **អនុជានាមិ ភិក្ខវេ តិវស្សន្តរេន សហ និសីទិតុំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យភិក្ខុដែលមានវស្សារវាង ៣ អង្គុយជាមួយគ្នាបាន ។

★ **អនុជានាមិ ភិក្ខវេ ទុវគ្គស្ស មញ្ចំ ទុវគ្គស្ស បីឋំ ។** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគ្រែមួយដល់ភិក្ខុ ២ រូប តាំងមួយដល់ភិក្ខុ ២ រូប ។

*ក្នុងគម្ពីរអដ្ឋកថា ពោលថា:*

★ **តិវស្សន្តរេនាតិ** ឯត្ថ តិវស្សន្តរោ នាម យោ ទ្វីហិ វស្សេហិ មហន្តតរោ វា ទហរតរោ វា ហោតិ ។ *ភិក្ខុណា ជាអ្នកចាស់ជាងគ្នា ឬជាអ្នកខ្ចីជាងគ្នាត្រឹម ២ វស្សា ភិក្ខុនោះ ឈ្មោះថា **អ្នកមានវស្សារវាង ៣** ក្នុងពាក្យថា តិវស្សន្តរេន : **មានវស្សារវាង ៣** ដូច្នេះ ។*

យោ បន ឯកេន វស្សេន មហន្តតរោ វា ទហរតរោ វា ហោតិ, យោ វា បន សមានវស្សោ តត្ថ វត្តព្វមេវ នត្ថិ ។ ឥមេ ច សព្វេ ឯកស្មឹ មញ្ចេ វា បីឋេ វា ទ្វេ ទ្វេ ហុត្វា និសីទិតុំ លភន្តិ ។ *ចំណែកភិក្ខុណា ជាអ្នកចាស់ជាងគ្នា ឬជាអ្នកខ្ចីជាងគ្នា ត្រឹមតែមួយវស្សា ឬថា ភិក្ខុណាមានវស្សាស្មើគ្នា, មិនមានពាក្យដែលគប្បីពោល ក្នុងភិក្ខុនោះឡើយ ។ មែនពិត ភិក្ខុទាំងអស់នេះ រមែងបានដើម្បីអង្គុយពីរៗ រួបលើគ្រែ ឬលើតាំង ជាមួយគ្នាបាន ។*

*ក្នុងគម្ពីរវិនយវិនិច្ឆយដីកា ពោលថា:*

★ "សត្តវស្សេន បញ្ចវស្សោ"តិ ឥទំ ទ្វីហិ វស្សេហិ វុឌ្ឍនវកានំ សមានាសនិកត្តេ ឧទាហរណំ ។ "ឆ វស្សេន បញ្ចវស្សោ"តិ ឥទំ ឯកវស្សេន វុឌ្ឍនវកានំ សមានាស-

និកាត្ថេ ឧទាហរណំ ។ ពាក្យថា ភិក្ខុមានវស្សា ៥ (អង្គុយជាមួយ) ភិក្ខុមានវស្សា ៧ ដូច្នេះនេះ គឺជាឧទាហរណ៍ក្នុងវស្សាស្មើគ្នា នៃភិក្ខុដែលចាស់ ខ្ចីជាងគ្នា ២ វស្សា ។

ពាក្យថា ភិក្ខុមានវស្សា ៥ (អង្គុយជាមួយ) ភិក្ខុមានវស្សា ៦ ដូច្នេះនេះ គឺជាឧទាហរណ៍ ក្នុងវស្សាស្មើគ្នា នៃភិក្ខុដែលចាស់ ខ្ចីជាងគ្នា ១ វស្សា ។

<u>ក្នុងវិនយបិដកភាគ ១០ ទំព័រ ៣៣៦ ពោលថា:</u>

✯ អនុជានាមិ ភិក្ខវេ ឋបេត្វា បណ្ឌកំ មាតុគ្គាមំ ឧភតោព្យញ្ជនំ អសមានាសនិកេហិ សហ ទីឃាសនេ និសីទិតុំ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យអង្គុយលើអាសនៈវែង ជាមួយនឹងភិក្ខុដែលមានអាសនៈមិនស្មើគ្នាបាន, វៀរលែងតែមនុស្សខ្ទើយ មាតុគ្រាម និងមនុស្សមានភេទពីរ ។

✯ អនុជានាមិ ភិក្ខវេ **យំ តិណ្ណន្នំ** បហោតិ ឯត្តកំ បច្ឆិមំ ទីឃាសនំ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតអាសនៈវែង ដែលមានទីបំផុតល្មមភិក្ខុ ៣ រូប អង្គុយបាន ។

*ក្នុងគម្ពីរអដ្ឋកថា ពោលថា:*

★ យំ តិណ្ណន្នំ បហោតិ តំ សំហារិមំ វា ហោតុ អសំហារិមំ វា តថារូបេ អបិ ផលកខណ្ឌេ អនុប-សម្បន្នេនាបិ សទ្ធឹ និសីទិតុំ វដ្ដតិ ។ *ទីអង្គុយណាល្មមដល់ ៣ នាក់, ទីអង្គុយនោះ នឹងជារបស់ឃ្លាតចាកទីបាន ឬឃ្លាតចាកទីមិនបានក៏ដោយ រមែងបានដើម្បីអង្គុយលើទីអង្គុយមានសភាពដូច្នោះ បើទុកជាលើផែនក្ដារ នឹងអង្គុយរួមសូម្បីជាមួយនឹងអនុបសម្បន្ន ក៏គួរ ។*

*ក្នុងគម្ពីរវិនយវិនិច្ឆយដីកា ពោលថា:*

★ ឧភតោព្យញ្ជនកំ ឥត្ថឹ, បណ្ឌកំ ថបេត្វា សព្វេហិបិ គហដ្ឋេហិ, បព្វជិតេហិ វា បុរិសេហិ សហ ទីឃាសនេ និសីទិតុំ អនុញ្ញាតន្តិ យោជនា ។ *យោជនាថា : វៀរលែងតែមនុស្សខ្ទើយ មាតុគ្រាម និងមនុស្សមានភេទពីរចេញ ព្រះអង្គអនុញ្ញាតដើម្បីអង្គុយលើអាសនៈវែង ជាមួយនឹងគ្រហស្ថសូម្បីទាំងអស់បាន, ម្យ៉ាទៀត ព្រះអង្គអនុញ្ញាតដើម្បីអង្គុយលើអាសនៈវែង ជាមួយនឹងបុរសដែលជាបព្វជិតបាន ។*

★ យំ តិណ្ណំ និសីទិតុំ បហោតិ, តំ ហេដ្ឋា ទីឃាសនំ នាមាតិ យោជនា ។ *យោជនាថា : ទីអង្គុយណា ល្មមដល់ ៣ នាក់, ទីអង្គុយនោះ ឈ្មោះថា* ***អាសនៈវែងយ៉ាងទាប*** *។*

<u>*ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:*</u>

★ ទីឃាសនំ នាម មញ្ចបីឋវិនិមុត្តំ យំ កិញ្ចិ ឯកតោ សុខំ និសីទិតុំ បហោតិ ។ *ដែលឈ្មោះថា* ***អាសនៈវែង*** *បានដល់ អាសនៈយ៉ាងណាមួយ ដែលផុតអំពីគ្រែនិងតាំង ល្មមនឹងអង្គុយយ៉ាងសប្បាយរួមគ្នាបាន ។*

## ភិក្ខុអង្គុយលើគ្រែនិងតាំង ជាមួយគ្នាបានតែ ២ រូប

<u>*ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:*</u>

★ យំ តិណ្ណំ បហោតីតិ មញ្ចបីឋវិនិមុត្តំ យំ អាសនំ តិណ្ណំ សុខំ និសីទិតុំ បហោតិ, ឥទំ បច្ឆិមទីឃាសនំ ។ ឯត្ថ មញ្ចបីឋរហិតេសុ អសមានាសនិកាបិ តយោ និសីទិតុំ លភន្តិ ។ មញ្ចបីឋេសុ បន ទ្វេ ។ អទីឃាសនេសុ មញ្ចបីឋេសុ សមានាសនិកាឯវ ទ្វេ

និសីទិតុំ លភន្តិ ទុវគ្គស្សេវ អនុញ្ញាតត្តា ។

ពាក្យថា **ទីអង្គុយណាល្មមដល់ ៣ នាក់** ដូច្នេះ មានសេចក្តីថា ទីអង្គុយដែលផុតចាកគ្រែនិងតាំង ដែលល្មមដើម្បីអង្គុយជាសុខ ៣ រូបបាន, ទីអង្គុយនេះ ឈ្មោះថា **អាសនៈវែងយ៉ាងទាប ។** ក្នុងសេចក្តីនេះ សូម្បីភិក្ខុ ៣ រូប ដែលមានអាសនៈមិនស្មើគ្នា រមែងបានដើម្បីអង្គុយក្នុងទីមិនមែនជាគ្រែនិងតាំង ។ តែបើលើគ្រែនិងតាំង បានតែ ២ រូប ប៉ុណ្ណោះ ។ ភិក្ខុ ២ រូបដែលមានអាសនៈស្មើគ្នាប៉ុណ្ណោះ រមែងបានដើម្បីអង្គុយលើគ្រែនិងតាំង ដែលជាអាសនៈខ្លីបាន ព្រោះព្រះអង្គអនុញ្ញាតត្រឹមតែ ២ រូប ប៉ុណ្ណោះ ។

<u>ក្នុងគម្ពីរមូលសិក្ខាដីកា ពោលថា:</u>

✯ យោ ភិក្ខុ រស្សាសនេ មញ្ចេ វា បីឋេ វា អសមានាសនិកេន ឯកតោ សយេយ្យ, តស្ស ទុក្កដំ សិយាតិ អត្ថោ ។ សេចក្តីអធិប្បាយថា ភិក្ខុណាគប្បីដេកលើអាសនៈខ្លី ដែលជាគ្រែក្តី តាំងក្តី ក្នុងទីជាមួយគ្នា ដោយវស្សាដែលមិនស្មើគ្នា, ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។

## ការប្តូរថាវរវត្ថុ និង ថាវរវត្ថុ

*ក្នុងគម្ពីរអដ្ឋកថា ពោលថា :*

*ភិក្ខុនឹងយក* **ថាវរវត្ថុ ឬជាមួយនឹងថាវរវត្ថុ** *និងគរុភណ្ឌ ឬជាមួយនឹងគរុភណ្ឌ រមែងគួរ ។ ចំណែកក្នុងថាវរវត្ថុ បែបនេះគឺ* **ស្រែ ចម្ការ បឹង ប្រឡាយ** *ភិក្ខុនឹងចាត់ចែកក្តី ទទួលព្រមក្តី ទទួលទុកក្តី ជំនួសសង្ឃមិនគួរទេ ។ ថាវរវត្ថុនោះ ដែលកប្បិយការកៈចាត់ចែងហើយ, កប្បិយភណ្ឌដែលបានមកពីថាវរវត្ថុទាំងនោះ* **រមែងគួរ** *។ មួយទៀត នឹងយកអារាម ដូរថាវរវត្ថុទាំង ៤ យ៉ាងនេះ គឺអារាម អារាមវត្ថុ វិហារ វិហារវត្ថុ* **រមែងគួរ** *។*

*ក្នុងគម្ពីរសារត្ថទីបនី និងវិមតិវិនោទនីដីកា ពោលថា:*

**★ ថាវរេន ច ថាវរន្តិអាទិសុ បញ្ចសុ កោដ្ឋាសេសុ បុរិមទ្វយំ ថាវរំ, បច្ឆិមត្តយំ គរុភណ្ឌន្តិ វេទិតព្វំ ។**

*ក្នុងពាក្យជាដើមថា* **ថាវរវត្ថុ ឬជាមួយនឹងថាវរវត្ថុ** *ដូច្នេះនេះ គប្បីជ្រាបថា ក្នុងចំណែកទាំង ៥ នោះ, ពីរចំណែកខាងដើម ជា* **ថាវរវត្ថុ**, *បីចំណែកខាងចុងជា* **គរុភណ្ឌ** *។ (ទៅមើល ក្នុងគរុភណ្ឌទាំង ២៥) ។*

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថាៈ</u>

✯ ន័យក្នុងការផ្លាស់ប្តូរទូវថាវរវត្ថុទាំង ៤ យ៉ាងដូច្នេះ៖ ចម្ការដូងរបស់សង្ឃនៅឆ្ងាយ ទាំងពួកកប្បិយការកៈស៊ីអស់ច្រើន, សូម្បីមិនបានស៊ី ក៏ត្រូវឱ្យថ្លៃឈ្នួលរទេះអំពីវត្ថុទាំងនោះអស់, នាំមកថ្វាយតែតិចតួច ។ ចំណែកពួកមនុស្សដទៃដែលនៅស្រុកមិនឆ្ងាយពីចម្ការនោះ មានចម្ការនៅជិតវត្ត ។ គេចូលទៅរកសង្ឃ សូមយកចម្ការរបស់ខ្លួន ប្តូរយកចម្ការនោះ សង្ឃគប្បីអបលោកន៍ថា "រុច្ចតិ សង្ឃស្ស" ហើយ សិនសឹមទទួល ។ សូម្បីចម្ការរបស់ពួកភិក្ខុមានដើមឈើ ១ ពាន់ដើម សួនរបស់អ្នកស្រុកមានដើមឈើ ៥ រយដើម ។ មិនគួរពោលថា ចម្ការរបស់អ្នកឯងតូចទេ ។ ពិតមែន ចម្ការនេះតូចក៏ពិត តែថាចម្ការនេះ រមែងឱ្យផ្លែច្រើនជាងចម្ការក្រៅពីនេះ សូម្បីចម្ការនោះ **ឱ្យផលស្មើៗគ្នា**, សូម្បីយ៉ាងនេះ នឹងព្រមទទួលដោយបំណងថា អាចដើម្បីបរិភោគបានគ្រប់ខណៈ ដែលខ្លួនត្រូវការ គប្បីទទួលពិត ។ តែបើចម្ការរបស់អ្នកស្រុក មានដើមឈើច្រើនជាង **គប្បីពោលថា ដើមឈើរបស់ពួកលោកមានច្រើនជាងមិនមែនឬ ?** បើគេឆ្លើយថា ចំណែកដែលលើសពីនោះទៅ ចូរជាបុណ្យរបស់ពួកខ្ញុំ, ពួកខ្ញុំថ្វាយសង្ឃ ។ គប្បី**ឱ្យជ្រាប** ហើយសឹមទទួលទុក ។

## ការផ្លាស់ប្ដូរដោយថេយ្យចិត្ត ជាបារាជិក

*ក្នុងគម្ពីរវិមតិវិនោទនីដីកាពោលថា:*

★ **សមកាមេវ ទេតីតិ** ឯត្ថ ឩនកំ ទេន្តម្បិ វិហារវត្ថុសាមន្តំ គហេត្វា ទូរតរំ ទុក្ខគោបំ វិស្សជ្ជេតុំ វដ្ដតីតិ ទដ្ឋព្វំ ។ វក្ខតិ ហិ "ភិក្ខូនំ ចេ មហគ្ឃតរំ ។បេ ។ សម្បដិច្ឆិតុំ វដ្ដតី"តិ ។ *ក្នុងពាក្យថា ឱ្យផលស្មើៗគ្នា ដូច្នេះនេះ គប្បីជ្រាបថា សូម្បីចម្ការរបស់អ្នកស្រុកឱ្យផលតិចជាង ក៏គួរដើម្បីកាន់យកនូវចម្ការអ្នកស្រុកដែលនៅជិតវត្ត, ហើយលះបង់នូវចម្ការដែលនៅឆ្ងាយ ដែលលំបាករក្សាបាន ។ សមដូចពាក្យដែលអដ្ឋកថាចារ្យ ពោលថា "ប្រសិនបើកុដិរបស់ភិក្ខុមានតម្លៃច្រើនជាង ។ល ។ ក៏គួរដើម្បីទទួល" ដូច្នេះ ។*

★ "ននុ តុម្ហាកំ ពហុតរា រុក្ខាតិ វត្តតព្វោ"តិ ឥទំ សាមិកេសុ អត្តនោ ភណ្ឌស្ស មហគ្ឃតំ អជានិត្វា ទេន្តេសុ តំ ញត្វា ថេយ្យចិត្តេន គណ្ហតោ អវហារោ ហោតីតិ វុត្តំ ។ *ពាក្យនេះថា គប្បីពោលថា "ដើមឈើរបស់ពួកលោកមានច្រើនជាង មិនមែនឬ" ដូច្នេះនេះ គឺលោក*

អាចារ្យពោលហើយថា "កាលម្ចាស់គេមិនដឹងនូវភណ្ឌៈរបស់ខ្លួន ថាមានតម្លៃច្រើនជាង ហើយឱ្យ ភិក្ខុកាលដឹងនូវភណ្ឌៈនោះហើយ ទទួលយកដោយថេយ្យចិត្ត **រមែងជាអវហារ ។**

*ក្នុងគម្ពីរសារត្ថទីបនី និងវិមតិវិនោទនីដីកា ពោលថា:*

☆ **ជាណាបេត្វាតិ** ភិក្ខុសង្ឃស្ស ជាណាបេត្វា អបលោកេត្វាតិ អត្ថោ ។ ពាក្យថា **គប្បីឱ្យជ្រាប** ដូច្នេះ មានសេចក្ដីអធិប្បាយថា គប្បីញ៉ាំងភិក្ខុសង្ឃឱ្យជ្រាបហើយសិនសឹមអបលោកន៍ ។

*តែក្នុងបាចិត្យាទិយោជនា ពោលថា:*

☆ **ជាណាបេត្វាតិ** "សង្ឃេ ទិន្នំ មហប្ផល"ន្តិ សង្ឃស្ស ទិន្នទានស្ស អានិសំសំ មនុស្សានំ ជាណាបេត្វា ។ ពាក្យថា **ឱ្យជ្រាប** ដូច្នេះនេះ មានសេចក្ដីថា ភិក្ខុញ៉ាំងមនុស្សទាំងឡាយ ឱ្យជ្រាបនូវអានិសង្សនៃការថ្វាយទានចំពោះព្រះសង្ឃថា "ការថ្វាយទានចំពោះសង្ឃ រមែងមានផលច្រើន" ដូច្នេះ ។

## ភិក្ខុយកកុដិមានតម្លៃច្រើន ដូរជាមួយផ្ទះគ្រហស្ថ

*ក្នុងគម្ពីរអដ្ឋកថា ពោលថា:*

វិហារនិងវិហារ តើគប្បីប្ដូរយ៉ាងណា ? ឆ្លើយថា វិហារ

របស់សង្ឃមាននៅខាងក្នុងស្រុក ប្រាសាទរបស់អ្នកស្រុក មាននៅខាងក្នុងវត្ត, វត្ថុទាំង ២ មានតម្លៃស្មើគ្នា ។ បើអ្នកស្រុកសូមយកនូវប្រាសាទនោះ ប្តូរជាមួយកុដិនោះ រមែងសមគួរដើម្បីទទួល ។ ប្រសិនបើកុដិរបស់ភិក្ខុមានតម្លៃច្រើនជាង, កាលភិក្ខុពោលថា កុដិរបស់ពួកយើង មានតម្លៃច្រើនជាង, អ្នកស្រុកឆ្លើយថា កុដិរបស់ពួកលោកម្ចាស់ មានតម្លៃច្រើនជាងក៏ពិតមែន, តែថា មិនសមគួរដល់បព្វជិតទាំងឡាយ (បព្វជិ–តាធំ អសារុប្បាធំ), បព្វជិតមិនអាចនៅក្នុងកុដិនោះបាន (ពាក្យនេះមិនបានសំដៅយកកុដិជានិស្សគ្គិយទេ) ចំណែកប្រាសាទរបស់ខ្ញុំនេះ សមគួរ, សូមលោកម្ចាស់ទាំងឡាយទទួលយកចុះ, សូម្បីយ៉ាងនេះ ក៏គួរដើម្បីទទួល ។ បើផ្ទះអ្នកស្រុកមានតម្លៃច្រើនជាង ភិក្ខុគប្បីពោលថា ផ្ទះរបស់ពួកលោកមានតម្លៃច្រើនមិនមែនឬ? តែកាលគេឆ្លើយថា ណ្ហើយចុះលោកម្ចាស់ដ៏ចម្រើននឹងជាបុណ្យរបស់ពួកខ្ញុំ, សូមលោកម្ចាស់ទទួលយកចុះ រមែងគួរដើម្បីទទួល ។ **វិហារ និងវិហារ** គប្បីប្តូរយ៉ាងនេះ ។

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

★ **វិហារេន វិហារោ បរិវត្តេតព្វោតិ** សវត្ថុកេន អញ្ញេសំ ភូមិយំ កតបាសាទាទិនា អវត្ថុកេន វា សវត្ថុកំ

**បរិវត្តេតព្វំ ។ អវត្ថុកំ បន អវត្ថុកោនេវ បរិវត្តេតព្វំ ។** ពាក្យថា *វិហារនិងវិហារ គប្បីប្តូរយ៉ាងនេះ* ដូច្នេះ មានសេចក្តីថា ភិក្ខុគប្បីដូរនូវវិហារព្រមទាំងដី ដោយវិហារព្រមទាំងដីក្តី ដោយវិហារដែលមិនមានដី មានប្រាសាទជាដើម ដែលភិក្ខុធ្វើហើយលើផែនដីរបស់អ្នកដទៃក្តី ។ តែគប្បីផ្លាស់ប្តូរនូវផ្ទៃដីមិនមានកុដិ ដោយផ្ទៃដីមិនមានកុដិប៉ុណ្ណោះ ។

**ការទទួលគ្រែអកប្បិយ ដែលគេថ្វាយចំពោះវិហារ គួរ**
<u>*ក្នុងគម្ពីរអដ្ឋកថា ពោលថា:*</u>

★ ប្រសិនបើព្រះរាជា និងរាជមហាមាត្យជាដើមថ្វាយនូវគ្រែទាំងរយក្តី គ្រែទាំងពាន់ក្តី ដោយត្រឹមតែមួងប៉ុណ្ណោះ គ្រែដែលជាកប្បិយទាំងអស់ គប្បីទទួលទុក ។ គ្រាទទួលទុកហើយគប្បីចែកតាមលំដាប់នៃភិក្ខុចាស់ ដោយពាក្យថា "សូមលោកម្ចាស់ប្រើប្រាស់ ដោយគ្រឿងប្រើប្រាស់ជារបស់សង្ឃចុះ" មិនត្រូវឱ្យដោយ អំណាចការប្រើប្រាស់ជារបស់បុគ្គលទេ ។ គ្រែមានតម្លៃច្រើនរាប់រយរាប់ពាន់ រាប់សែន កហាបណៈ នឹងប្តូរយកគ្រែដទៃបានរាប់រយគ្រែ, គួរប្តូរយកទុក ។ មិនមែនតែគ្រែប៉ុណ្ណោះទេ សូម្បីអារាម អារាមវត្ថុ វិហារ វិហារវត្ថុ តាំង

ពូក និងខ្នើយ ក៏គួរដើម្បីប្ដូរបាន ។ សូម្បីតាំង ពូក និងខ្នើយ ក៏មានន័យនេះដូចគ្នា ។

<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:</u>

★ **"កប្បិយមញ្ច សម្បដិច្ឆិតព្វា"តិ** "សង្ឃស្ស ទេមា"តិ ទិន្នំ សន្ធាយ វុត្តំ ។ សចេ បន "វិហារស្ស ទេមា"តិ វទន្តិ សុវណ្ណរជតមយានិ អកប្បិយមញ្ចេបិ សម្បដិច្ឆិតុំ វដ្ដតិ ។ ពាក្យថា គ្រែដែលជាកប្បិយទាំងអស់គប្បីទទួលទុកដូច្នេះនេះ គឺលោកអាចារ្យពោលហើយ ព្រោះសំដៅយកនូវពាក្យដែលទាយកថ្វាយដោយពាក្យថា "យើងទាំងឡាយ សូមថ្វាយចំពោះសង្ឃ" ។ ក៏ប្រសិនបើទាយកថ្វាយថា "យើងទាំងឡាយ សូមថ្វាយចំពោះវិហារ" ដូច្នេះ ភិក្ខុទទួលសូម្បីនូវគ្រែដែលជាអកប្បិយ មានសម្រេចអំពីមាសនិងប្រាក់ជាដើម រមែងគួរ ។

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

★ **"កប្បិយមញ្ច សម្បដិច្ឆិតព្វោ"តិ** ឥមិនា សុវណ្ណាទិវិចិត្តំ អកប្បិយមញ្ចំ "សង្ឃស្សា"តិ វុត្តេបិ សម្បដិច្ឆិតុំ ន វដ្ដតីតិ ទស្សេតិ ។ "វិហារស្ស ទេមា"តិ

វុត្តំ, សង្ឃស្ស វដ្ដតិ, ន បុគ្គលស្ស ខេត្តាទិ វិយាតិ ធដ្ឋព្វំ ។ ដោយពាក្យថា ត្រៃដែលជាកប្បិយទាំងអស់ គប្បីទទួលទុក ដូច្នេះនេះ សូម្បីកាលទាយកថ្វាយថា "ខ្ញុំព្រះករុណាសូមថ្វាយដល់សង្ឃ" ដូច្នេះ លោកសម្ដែងថា ភិក្ខុមិនគួរដើម្បីទទួលនូវត្រៃដែលជាអកប្បិយដែលវិចិត្រ ដោយវត្ថុទាំងឡាយ មានមាសជាដើម ។ (តែ)កាលទាយកថ្វាយថា "ខ្ញុំព្រះករុណាសូមថ្វាយដល់វិហារ" ដូច្នេះ គប្បីជ្រាបថា រមែងគួរដល់សង្ឃ, តែមិនគួរដល់បុគ្គលទេ ដូចជាស្រែជាដើម ។

<u>ក្នុងគម្ពីរអដ្ឋកថា ពោលទៀតថា:</u>

✯ សូម្បី តាំង ពូក និងខ្នើយទាំងអស់នោះ វត្ថុដែលជាកប្បិយនិងអកប្បិយ មានន័យដូចពោលមកហើយនោះឯង ។ ក្នុងកប្បិយ និងអកប្បិយនោះ វត្ថុដែលជាអកប្បិយ មិនគួរប្រើប្រាស់ ។ វត្ថុដែលជាកប្បិយ គប្បីប្រើប្រាស់ជាគ្រឿងប្រើប្រាស់ជារបស់សង្ឃ ។ វត្ថុអកប្បិយក្តី វត្ថុកប្បិយដែលមានតម្លៃច្រើនក្តី គប្បីផ្លាស់ប្តូរ ហើយកាន់យកតាមន័យដែលពោលហើយ ។

<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:</u>

✯ **អកប្បិយំ វា មហគ្ឃំ កប្បិយំ វាតិ ឯត្ថ**

អកប្បិយំ ឆាម សុវណ្ណមយមញ្ចាទិ អកប្បិយភិសិ-
ពិម្ពោហនាទិ ច ។ មហគ្ឃំ កប្បិយំ ឆាម ឧន្ទមយ-
មញ្ចាទិ ធាវាកាទិកប្បិយអត្ថរណាទីនិ ច ។

*ក្នុងពាក្យថា **វត្ថុអកប្បិយក្តី** វត្ថុកប្បិយដែលមានតម្លៃច្រើនក្តី ដូច្នេះនេះ មានសេចក្តីថា វត្ថុមានគ្រែជាដើម ដែលសម្រេចអំពីមាសផង វត្ថុមានពូក និងខ្នើយជាដើម ដែលជាអកប្បិយផង ឈ្មោះថា **វត្ថុអកប្បិយ** ។ វត្ថុទាំងឡាយមានគ្រែដែលសម្រេចអំពីភ្លុកជាដើមផង វត្ថុមានសំពត់បាវរជាដើម និងកម្រាលដែលជាកប្បិយជាដើមផង ឈ្មោះថា **វត្ថុកប្បិយដែលមានតម្លៃច្រើន** ។*

*<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>*

★ **មហគ្ឃំ កប្បិយំ វាតិ** សុវណ្ណាទិវិចិត្តំ កប្បិ-
យវោហារេន ទិន្នំ ។ *ពាក្យថា **វត្ថុកប្បិយដែលមានតម្លៃច្រើនក្តី** ដូច្នេះ មានសេចក្តីថាវត្ថុដែលគេវិចិត្រដោយវត្ថុទាំងឡាយមានមាសជាដើម ដែលទាយកថ្វាយដោយកប្បិយវោហារ ។*

## **បាត្រជាដើមដែលជាលហុភណ្ឌ គួរចែកបាន**

*<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>*

★ "ធាទភណ្ឌកកោ អនតិរិត្តប្បមាណោ បន

យជកោ បត្តំ ថាលកំ កញ្ចនកំ កុណ្ឌិកាតិ" ឥទមេត្ថ ភាជនីយភណ្ឌំ ។ យថា ច មត្តិកាភណ្ឌំ, ឯវំ លោហភណ្ឌបិ ។ *ក្នុងភណ្ឌដីនេះគឺ ឆ្នាំង បាត្រ ភាជនៈ កន្ថោមាត់ធំ កុណ្ឌីទឹក មានខ្នាតមិនលើសជាងចំណុះទឹក ១ បាត្រ គួរចែកគ្នាបាន ។ ក៏ក្នុងភណ្ឌដីនេះយ៉ាងណា សូម្បីក្នុងភណ្ឌលោហៈ ក៏យ៉ាងនោះដែរ ។*

★ បត្តោ (អយបត្តោ) អយថាលកំ តម្ពលោហកថាលកន្តិ ឥមានិ បន ភាជនីយានិ ។ កំសលោហវដ្ដលោហភាជនវិកតិ សង្ឃិកបរិភោគេន វា គិហិវិកដា វា វដ្ដតិ, បុគ្គលិកបរិភោគេន ន វដ្ដតិ ។ កំសលោហាទិភាជនំ សង្ឃស្ស ទិន្នម្បិ ហិ ធារិហារិយំ ន វដ្ដតិ ។ គិហិវិកដនិហារេនេវ បរិភុញ្ជិតព្វន្តិ មហាបច្ចរិយំ វុត្តំ ។ *ភណ្ឌទាំងនេះ គឺបាត្រដែក (បាត្រតូច ចំណុះទឹកប៉ុន ៥ នាឡិ ដោយនាឡិមគធៈ, បាត្រធំជាងនោះ គឺជាគរុភណ្ឌ) ភាជនៈដែកតូច និងភាជនៈទង់ដែង ជារបស់គួរចែកបាន ។ ក្នុងមហាបច្ចរីពោលថា ភាជនៈដែលគេតាក់តែង ដែលធ្វើអំពីសំរិត ឬទង់ដែងប្រើប្រាស់ជាគ្រឿងប្រើប្រាស់ជារបស់សង្ឃ*

ឬជាគិហិវិកដ័ រមែងគួរ, តែមិនគួរប្រើប្រាស់ជារបស់បុគ្គល ។ ភាជនៈសំរិតជាដើម ដែលគេថ្វាយដល់សង្ឃ នឹងរក្សាទុកប្រើប្រាស់តែឯងមិនគួរ ។ គប្បីប្រើប្រាស់ជាគិហិវិកដ័ប៉ុណ្ណោះ ។

## ការប្រើប្រាស់ជារបស់សង្ឃ និងការប្រើជារបស់បុគ្គល

<u>ក្នុងគម្ពីរវិនយាលង្ការដីកា ពោលថា:</u>

★ **សង្ឃិកបរិភោគេនាតិ** អាគន្តុកានំ វុឌ្ឍតរានំ ទត្វា បរិភោគេន ។ ពាក្យថា ប្រើប្រាស់ជារបស់សង្ឃ ដូច្នេះនេះ មានសេចក្ដីថា គឺភិក្ខុបានឱ្យដល់អាគន្តុកៈទាំងឡាយដែលចាស់ជាង ហើយប្រើប្រាស់ ។

★ **បុគ្គលិកបរិភោគេន ន វដ្ដតីតិ** អាគន្តុកានំ អទត្វា អត្តនោ សន្តកំ វិយ គហេត្វា បរិភុញ្ជិតុំ ន វដ្ដតិ ។ ពាក្យថា ប្រើប្រាស់ជារបស់បុគ្គលមិនគួរ ដូច្នេះនេះ មានសេចក្ដីថា ភិក្ខុមិនបានឱ្យដល់អាគន្តុកៈទាំងឡាយ ហើយកាន់យកមកប្រើប្រាស់ ដូចជារបស់នៃខ្លួន រមែងមិនគួរ ។

<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:</u>

★ **បារិហារិយំ ន វដ្ដតីតិ** អត្តនោ សន្តកំ វិយ គហេត្វា បរិហរិតុំ ន វដ្ដតិ ។

★ **គិហិវិកតនិយាមេនេវ បរិភុញ្ជិតព្វន្តិ** ឥមិនា សចេ អារាមិកាទយោ បដិសាមេត្វា បដិទេន្តិ បរិភុញ្ជិតុំ វដ្ដតីតិ ទស្សេតិ ។ *ពាក្យថា* **ទឹងរក្សាទុកប្រើប្រាស់តែឯង មិនគួរ** *ដូច្នេះនេះ មានសេចក្ដីថា ភិក្ខុកាន់យក (នូវភាជនៈ សំរិតជាដើម)ហើយរក្សាទុកប្រើប្រាស់ ដូចជារបស់ខ្លួនមិនគួរ ។*

*ដោយពាក្យថា* **គប្បីប្រើប្រាស់ជាគិហិវិកដ៏ប៉ុណ្ណោះ** *ដូច្នេះ នេះ លោកអាចារ្យសម្ដែងថា បើពួកអ្នកធ្វើការផារវត្តជាដើម រក្សាទុកហើយប្រគេន, ភិក្ខុប្រើប្រាស់រមែងគួរ ។*

*<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>*

★ **ធារិហារិយំ ន វដ្ដតីតិ** បត្តាទិបរិក្ខារំ វិយ សយមេវ បដិសាមេត្វា បរិភុញ្ជិតុំ ន វដ្ដតិ ។ គិហិ-សន្តកំ វិយ អារាមិកាទយោ ចេ សយមេវ គោបេត្វា វិនិយោគកាលេ អានេត្វា បដិនេន្តិ, បរិភុញ្ជិតុំ វដ្ដតិ ។ "បដិសាមេត្វា ភិក្ខូនំ ទេថាតិ វត្តុម្បិ វដ្ដតី"តិ ។

*ពាក្យថា* **ទឹងរក្សាទុកប្រើប្រាស់ តែឯងមិនគួរ** *ដូច្នេះនេះ មានសេចក្ដីថា ភិក្ខុរក្សាទុកដាក់ (នូវភាជនសំរិតជាដើម) ដោយខ្លួនឯងតែម្យ៉ាង ហើយប្រើប្រាស់ដូចជាបរិក្ខារមានបាត្រជាដើម*

រមែងមិនគួរ ។ ប្រសិនបើអារាមិកជនជាដើម រក្សាទុកដោយខ្លួនឯង ហើយនាំទៅវិនិយោគ ហើយនាំត្រលប់មកវិញ គួរប្រើប្រាស់ដូចជារបស់គ្រហស្ថ ។ សូម្បីទាយកពោលថា "អ្នកទាំងឡាយចូររក្សាទុកដាក់ ហើយថ្វាយដល់ភិក្ខុទាំងឡាយ" រមែងគួរ ។

## វត្ថុជារបស់សេនាសនៈគួរគ្រប់យ៉ាង

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថាៈ</u>

★ ក៏បំពង់ថ្នាំជក់ ភាជនៈលោហៈ គោមមានជង គោម-តាំង គោមព្យួរ រូបស្រី រូបប្រុស និងរូបសត្វតិរច្ឆាន ឬវត្ថុលោហៈពួកដទៃ ដែលគួរព្យួរទុកត្រង់ជញ្ជាំង ឬដំបូល ឬថាត្រង់ទ្វារជាដើម, វត្ថុលោហៈទាំងពួង ដោយហោចទៅ សូម្បីដែកគោល រមែងជាគរុភណ្ឌដូចគ្នា, **សូម្បីខ្លួនឯងបានមក** ក៏មិនគួររក្សាទុកប្រើប្រាស់ ដូចជាគ្រឿងប្រើប្រាស់ ចំណែកបុគ្គល ។ គួរប្រើប្រាស់ ដូចជាគ្រឿងប្រើប្រាស់ របស់សង្ឃ ឬប្រើប្រាស់ជារបស់គិហិវិកដ ។ សូម្បីសំណ ក៏មានន័យដូចគ្នា ។ **ភាជនៈមាស** ប្រាក់ ទុំហូ និងកែវផលិក ជា **គិហិវិកដ ក៏មិនគួរ**, មិនចាំបាច់ពោលទៅថ្វី ដោយការបរិភោគប្រើប្រាស់ជារបស់សង្ឃ ឬដោយការបរិភោគប្រើប្រាស់ជា

របស់បុគ្គលទេ ។

★ សេនាសនបរិភោគេ បន អាមាសម្បិ អនាមាសម្បិ សព្វំ វដ្ដតិ ។ តែការប្រើប្រាស់ជារបស់សេនាសនៈ វត្ថុគ្រប់យ៉ាងដែលជាអាមាសក្តី ជាអនាមាសក្តី រមែងគួរគ្រប់យ៉ាង ។

ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:

★ **អត្តនា លទ្ធានិបីតិអាទិនា** បដិគ្គហណេ ទោសោ នត្ថិ, បរិហរិត្វា បរិភោគោវ អាបត្តិករោតិ ទស្សេតិ ។

ដោយពាក្យជាដើមថា **សូម្បីខ្លួនឯងបានមក** ដូច្នេះនេះ លោកសម្តែងថា ទោសក្នុងការទទួលរមែងមិនមានទេ, ការនាំមកប្រើប្រាស់ប៉ុណ្ណោះ រមែងត្រូវនូវអាបត្តិ ។

★ **អនាមាសម្បីតិ** សុវណ្ណាទិមយម្បិ សព្វំ តំ អាមសិត្វាបិ បរិភុញ្ជិតុំ វដ្ដតិ ។ ពាក្យថា **អនាមាសក្តី** ដូច្នេះនេះ មានសេចក្តីថា វត្ថុទាំងអស់ដែលសម្រេចអំពីមាសជាដើម ភិក្ខុសូម្បីប៉ះពាល់នូវវត្ថុនោះ ហើយប្រើប្រាស់រមែងគួរ ។

ក្នុងគម្ពីរបាចិត្យាទិយោជនា ពោលថា:

★ **សព្វន្តិ** សុវណ្ណរជតាតិ សព្វំ ។ **វដ្ដតីតិ** សង្ឃ-

គណៈបុគ្គលានំ វត្តតិ ។ ពាក្យថា វត្តគ្រប់យ៉ាង ដូច្នេះ មានសេចក្ដីថា វត្តគ្រប់យ៉ាង មានមាសនិងប្រាក់ជាដើម ។

ពាក្យថា រមែងគួរ ដូច្នេះនេះ មានសេចក្ដីថា រមែងគួរ ដល់សង្ឃ គណៈ និងបុគ្គលទាំងឡាយ ។

<u>ក្នុងវិនយបិដកភាគ ១០ ទំព័រ ៣៥៧ ត្រាស់ថា:</u>

★ ន ភិក្ខវេ អធោតេហិ បាទេហិ សេនាសនំ អក្កមិតព្វំ ។ យោ អក្កមេយ្យ អាបត្តិ ទុក្កដស្ស ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុឥតលាងជើង មិនត្រូវដើរជាន់សេនាសនៈទេ ភិក្ខុណាជាន់ ត្រូវអាបត្តិទុក្កដ ។

★ ន ភិក្ខវេ អល្លេហិ បាទេហិ សេនាសនំ អក្កមិតព្វំ ។ យោ អក្កមេយ្យ អាបត្តិ ទុក្កដស្ស ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវដើរជាន់សេនាសនៈទាំងជើងទទឹកទេ ភិក្ខុណាជាន់ត្រូវអាបត្តិទុក្កដ ។

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>

★ **អល្លេហិ បាទេហីតិ** យេហិ អក្កន្តដ្ឋានេ ឧទកំ បញ្ញាយតិ, ឯវរូបេហិ បាទេហិ បរិភណ្ឌកតភូមិ វា សេនាសនំ វា ន អក្កមិតព្វំ ។ សចេ បន ឧទកសិ-

នេហមត្តមេវ បញ្ញាយតិ, ន ឧទកំ វដ្ដតិ ។ ធាទបុញ្ជនី បន អល្លធាទេហិបិ អក្ខមិតុំ វដ្ដតិយេវ ។

*ពាក្យថា* ***ទាំងជើងទទឹក*** *ដូច្នេះ សេចក្ដីថា ទឹករមែង ប្រាកដក្នុងទីដែលជើងជាន់ហើយ យ៉ាងណា ផ្ទៃផែនដីដែលធ្វើ ដោយការបូកលាបក្ដី សេនាសនៈក្ដី គឺភិក្ខុមិនគប្បីជាន់ដោយជើង មានសភាពដូច្នោះទេ ។ តែប្រសិនបើប្រាកដត្រឹមតែស្នាមទឹក ព្រាលៗ ប៉ុណ្ណោះ ទឹកមិនប្រាកដទេគួរនឹងជាន់បាន ។ម្យ៉ាងទៀត នឹងជាន់សំពត់ជូតជើងសូម្បីដោយជើងដែលសើម ក៏គួរដូចគ្នា ។*

*<u>ក្នុងគម្ពីរសារត្ថទីបនី និងវិមតិវិនោទនីដីកា ពោលថា:</u>*

★ **បរិភណ្ឌកតភូមិ** ឆាម សណ្ហមត្តិកាហិ កកតា កាឡវណ្ណាទិភូមិ ។ **សេណាសនំ** វាតិ មញ្ចបីឋាទិ វា ។ *ផ្ទៃផែនដីមានពណ៌ខ្មៅជាដើម ដែលគេធ្វើហើយ ដោយដីស្អិត ដែលល្អិត ឈ្មោះថា* ***ផ្ទៃផែនដីដែលធ្វើដោយការបូកលាប*** *។*

*ពាក្យថា* ***សេនាសនៈក្ដី*** *គឺបានដល់សេនាសនៈមានគ្រែ និងតាំងជាដើម ។*

*<u>ក្នុងវិនយបិដកភាគ ១០ ទំព័រ ៣៥៧ ត្រាស់ថា:</u>*

★ ន ភិក្ខវេ សឧបាហនេន សេណាសនំ អក្កមិតព្វំ ។ យោ អក្កមេយ្យ អាបត្តិ ទុក្កដស្ស ។ ម្នាលភិក្ខុទាំងឡាយ

ភិក្ខុពាក់ស្បែកជើង មិនត្រូវដើរជាន់សេនាសនៈទេ ភិក្ខុណា ជាន់ត្រូវអាបត្តិទុក្កដ ។

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>

✯ សឧបាហនេន ធោតបាទេហិ អក្កមិតព្វដ្ឋានេ យេវ ន វដ្ដតិ ។ ភិក្ខុពាក់ស្បែកជើង មិនគួរជាន់ក្នុងទីដែលទឹងគប្បីជាន់ដោយជើងដែលលាងហើយទេ ។

<u>ក្នុងគម្ពីរខុទ្ទកសិក្ខា ពោលថា:</u>

✯ អធោតអល្លបាទេហិ នក្កមេ សយនាសនំ
សុធោតបាទកំ វាបិ តថេវ សឧបាហនោ ។

ភិក្ខុដែលមានជើងមិនបានលាងក្តី មានជើងទទឹកក្តី មិនគប្បីជាន់នូវទីដេកនិងទីអង្គុយទេ, មួយទៀត ភិក្ខុពាក់ស្បែកជើង មិនត្រូវជាន់នូវទីសេនាសនៈដែលគេគប្បីជាន់ ដោយជើងដែលលាងហើយជាដាច់ខាត ។ (ប្រែតាមដីកាពន្យល់) ។

ក្នុងវិនយបិដកភាគ ១០ ទំព័រ ៣៥៨ ត្រាស់ថា:

✯ អនុជានាមិ ភិក្ខវេ ចោឡកេន បលិវេឋេតុំ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឱ្យរុំ (ជើងគ្រែនិងជើងតាំង) ដោយកំណាត់សំពត់ ។

ក្នុងគម្ពីរអដ្ឋកថា ពោលថា:

★ ចោឡកេន បលិវេឋេតុន្តិ សុធាភូមិយំ វា បរិភណ្ឌភូមិយំ វា សចេ តដ្ដិកា វា កដសារកោ វា នត្ថិ, ចោឡកេន បាទា វេឋេតព្វា, តស្មឹ អសតិ បណ្ណម្បិ អត្ថរិតុំ វដ្ដតិ ។ កិញ្ចិ អនត្ថរិត្វា ឋបេន្តស្ស បន ទុក្កដំ ។ យទិ បន តត្ថ នេវាសិកា អនត្ថតាយបិ ភូមិយា ឋបេន្តិ អធោតបាទេហិបិ វឡញ្ជេន្តិ, តថេវ វឡញ្ជេតុំ វដ្ដតិ ។

*ពាក្យថា ឱ្យរុំ (ជើងគ្រែនិងជើងតាំង) ដោយកំណាត់សំពត់ ដូច្នេះ មានសេចក្ដីថា បើនៅលើផ្ទៃដែល បូកដោយកំបោរ-សក្ដិ លើផ្ទៃដែលបូកលាបក្ដី, មិនមានកន្ទេលទន់ និងកន្ទេលផែងទេ គឺភិក្ខុគប្បីយកសំពត់រុំជើង (គ្រែនិងតាំង) ។ កាលសំពត់នោះ មិនមាន សូម្បីស្លឹកឈើ ក៏គួរក្រាល ។ តែជាអាបត្តិទុក្កដ ដល់ភិក្ខុអ្នកមិនក្រាលអ្វីៗឡើយ ហើយដាក់ចុះទៅ ។ ក៏ប្រសិនបើ ភិក្ខុអ្នកជាម្ចាស់ក្នុងអាវាសនោះ តម្កល់ទុកលើផ្ទៃ ផែនដីសូម្បីមិនបានក្រាល, ថែមទាំងប្រើប្រាស់ដោយជើង ដែលមិនបានលាង (អាវាសកភិក្ខុដទៃ)គួរដើម្បីប្រើប្រាស់ យ៉ាងនោះដែរ ។*

ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:

★ **តថេវ វឡញ្ជេតុំ វដ្ដតីតិ** អញ្ញេហិ អាវាសិកេហិ ភិក្ខូហិ បរិភុត្តនីហារេន បរិភុញ្ជិតុំ វដ្ដតិ ។ "នេវាសិកា បកតិយា អនត្ថតាយ ភូមិយា ឋបេន្តិ ចេ, តេសម្បិ អនាបត្តិយេវា"តិ គណ្ឋិបទេសុ វុត្តំ ។

*ពាក្យថា (អាវាសកភិក្ខុដទៃ) គួរដើម្បីប្រើប្រាស់យ៉ាងនោះដែរ ដូច្នេះ សេចក្ដីថា កាលដែលអាវាសិកភិក្ខុដទៃ ប្រើប្រាស់តាមទំនងដែលភិក្ខុម្ចាស់អាវាស ប្រើប្រាស់ហើយ រមែងគួរ ។ លោកពោលទុកក្នុងគណ្ឋីបទថា "បើភិក្ខុម្ចាស់អាវាសទាំងឡាយ តម្កល់ទុកលើផែនដីតាមប្រក្រតី ដោយមិនបានក្រាល ជាអនាបត្តិពិត សូម្បីដល់ភិក្ខុទាំងឡាយនោះ" ។*

ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:

★ **តថេវ វឡញ្ជេតុំ វដ្ដតីតិ** ឥមិនា នេវាសិកេហិ ធោតបាទាទីហិ វឡញ្ជនដ្ឋានេ សញ្ចិច្ច អធោតបាទាទីហិ វឡញ្ជន្តស្សេវ អាបត្តិ បញ្ញត្តាតិ ទស្សេតិ ។ *ដោយពាក្យនេះថា (អាវាសកភិក្ខុដទៃ) គួរដើម្បីប្រើប្រាស់យ៉ាងនោះ ដែរ ដូច្នេះ លោកអាចារ្យសម្ដែងថា អាបត្តិ គឺព្រះអង្គបញ្ញត្តិហើយ*

ដល់ភិក្ខុដែលក្លែងហើយប្រើប្រាស់ ដោយជើងដែលមិនបាន លាងជាដើម ក្នុងទីដែលភិក្ខុម្ចាស់អាវាស ប្រើប្រាស់ដោយ ជើងដែលលាងហើយជាដើម ។

<u>ក្នុងវិនយបិដកភាគ ១០ ទំព័រ៣៥៨ ត្រាស់ថា:</u>

★ **ន ភិក្ខវេ បរិកម្មកតា ភិត្តិ** អបស្សេតព្វា យោ អបស្សេយ្យ អាបត្តិ ទុក្កដស្ស, អនុជានាមិ ភិក្ខវេ អបស្សេនផលកំ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវផ្អែក ទីងជញ្ជាំងដែលគេលាប (ថ្នាំផ្សេងៗ)ទេ ភិក្ខុណាផ្អែក ត្រូវ អាបត្តិទុក្កដ, ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតផែនក្តារ សម្រាប់ផ្អែក ។

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>

★ ន ភិក្ខវេ បរិកម្មកតា ភិត្តីតិ សេតភិត្តិ វា ចិត្តកម្មកតា វា ។ ន កេវលញ្ច ភិត្តិមេវ, ទ្វារម្បិ វាតបានម្បិ អបស្សេនផលកម្បិ បាសាណត្ថម្ភម្បិ រុក្ខត្ថម្ភម្បិ ចីវរេន វា កោនចិ វា អប្បដិច្ឆាទេត្វា អបស្សយិតុំ ន លព្ភតិយេវ ។ ពាក្យថា ភិក្ខុមិនត្រូវផ្អែក ទីងជញ្ជាំងដែលគេលាប ដូច្នេះ មានសេចក្តីថា ជញ្ជាំងដែល

លាបដោយកំបោរ-សក្តិ ជញ្ជាំងដែលធ្វើចិត្តកម្មក្តី មិនគួរផ្អែកទេ ។ ភិក្ខុមិនគួរផ្អែកទីងជញ្ជាំងតែម្យ៉ាងប៉ុណ្ណោះក៏ទេ សូម្បីទ្វារក្តី បង្អួចក្តី បង្អែកផែនក្តារក្តី សសរថ្មក្តី សសរឈើក្តី ភិក្ខុមិនទ្រាប់ដោយចីវរ ឬរបស់ណាមួយហើយ រមែងមិនបានដើម្បីទីងផ្អែកដូចគ្នា ។

**ការផ្អែកនឹងជញ្ជាំងដែលគេមិនបានលាប ជាអចិត្តកៈ**

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

★ **ទ្វារម្បីតិអាធិនា** សាមញ្ញតោ វុត្តត្តា ទ្វារវាត-បានាទយោ អបរិកម្មកតាបិ ឥធ អបស្សយិតព្វា ។ អជានិត្វា អបស្សយន្តស្សបិ, ឥធ លោមគណនាយ អាបត្តិ ។ ភិក្ខុមិនត្រូវផ្អែកនូវទ្វារនិងបង្អួចជាដើម សូម្បីមិនបានធ្វើបរិកម្មដោយពណ៌ផ្សេងៗ ព្រោះភាវៈនៃពាក្យដែលព្រះ-អដ្ឋកថាចារ្យ ពោលដោយសាមញ្ញថា "សូម្បីទ្វារក្តី" ជាដើម ។ ក្នុងអធិការនេះ សូម្បីភិក្ខុមិនដឹងហើយផ្អែក រមែងត្រូវអាបត្តិដោយរាប់តាមចំនួនរោម ។

<u>ក្នុងវិនយបិដកភាគ ១០ ទំព័រ ៣៥៩ ត្រាស់ថា:</u>

★ អនុជានាមិ ភិក្ខវេ បច្ចត្ថរិត្វា និបជ្ជិតុំ ។ ម្នាល

ភិក្ខុទាំងឡាយ តថាគតអនុញ្ញាតក្រាលកម្រាលរួចសឹមសឹង ។

## ការយកកម្រាលរបស់សង្ឃ មកក្រាលសឹងមិនគួរ

ក្នុងគម្ពីរអដ្ឋកថា ពោលថា:

★ **បច្ចត្ថរិត្វាតិ** បរិភណ្ឌកតំ ភូមឹ វា ភូមត្ថរណ-សេនាសនំ វា សង្ឃិកមញ្ចបីឋំ វា អត្តនោ សន្តកេន បច្ចត្ថរណេន បច្ចត្ថរិត្វា និបជ្ជិតព្វំ ។

ពាក្យថា ក្រាលកម្រាល ដូច្នេះនេះ មានសេចក្ដីថា ផ្ទៃផែនដីដែលបូកលាបក្ដី សេនាសនៈមានគ្រឿងទ្រាប់ផ្ទៃផែនដីក្ដី គ្រែនិងតាំងរបស់សង្ឃក្ដី ត្រូវយកកម្រាលជារបស់ខ្លួនក្រាលទ្រាប់រួចជាមុនសិន ហើយសឹមសឹង ។

សចេ និទ្ទាយតោបិ បច្ចត្ថរណោ សង្កុដិតោ កោចិ សរីរាវយវោ មញ្ចំ វា បីឋំ វា ផុសតិ អាបត្តិយេវ ។ លោមេសុ បន លោមគណនាយ អាបត្តិយេវ ។ បរិភោគ-សីសេន អបស្សយន្តស្សាបិ ឯសេវ នយោ ។ ហត្ថតល-បាទតលេហិ បន ផុសិតុំ វា អក្កមិតុំ វា វដ្ដតិ ។ មញ្ចបីឋំ នីហរន្តស្ស កាយេ បដិហញ្ញតិ អនាបត្តិ ។ បើសូម្បីកាលភិក្ខុកំពុងសឹងលក់ កម្រាលរសាត់ចេញទៅ អវយវៈនៃសរីរៈចំណែកខ្លះ ពាល់ត្រូវគ្រែឬតាំង ជាអាបត្តិដូចគ្នា ។ តែ

កាលពោមពាល់ត្រូវជាអាបត្តិតាមចំនួនរោម ។ សូម្បីកាលផ្អែកដោយប្រាថ្នាប្រើប្រាស់ជាធំ ក៏មានន័យនេះដូចគ្នា ។ តែទីងពាល់ត្រូវ ឬជាន់ដោយបាទដៃ បាទជើង រមែងគួរ ។ គ្រែនិងតាំងប៉ះខ្ទប់កាយរបស់ភិក្ខុកំពុងនាំទៅ **មិនជាអាបត្តិ** ។

<u>ក្នុងបាចិត្យាទិយោជនា ពោលថា:</u>

★ បរិភណ្ឌកូមិយន្តិ គោមយកសាវបរិភណ្ឌកូមិយំ ។ "អត្តនោ សន្តកេនា"តិ ឥមិនា សង្ឃិកេន បច្ចត្ថរណេន បច្ចត្ថរណំ បដិក្ខិបតិ ។ "បរិភោគសីសេនា"តិ ឥមិនា បរិភោគំ អកត្វា កេនចិ កម្មេន សរីរាវយវេន ផុសន្តស្ស អនាបត្តីតិ ទស្សេតិ ។ "បរិភោគសីសេនា"តិ បទស្ស អត្ថំ ទស្សេន្តោ អាហ "មញ្ចបីឋំ នីហរន្តស្សា"តិអាទិ ។

ពាក្យថា **លើផ្ទៃផែនដី ដែលបូកលាប** ដូច្នេះនេះ មានសេចក្តីថា លើផ្ទៃផែនដីដែល គេបូកលាបដោយអាចម៍គោ និងទឹកបត់ ។ ដោយពាក្យថា **កម្រាលជារបស់ខ្លួន** ដូច្នេះ គឺព្រះ-អដ្ឋកថាចារ្យ លោករមែងហាមឃាត់នូវកម្រាលដែលជាកម្រាលរបស់សង្ឃ ។ ពាក្យថា **ដោយប្រាថ្នាប្រើប្រាស់ជាធំ** ដូច្នេះ លោកអាចារ្យសម្តែងថា កាលភិក្ខុមិនធ្វើនូវការប្រើប្រាស់ហើយពាល់ត្រូវនូវសរីរាវយវៈ ដោយការងារឯណានីមួយជាអនាបត្តិ

ព្រះអដ្ឋកថាចារ្យ កាលសម្ដែងនូវសេចក្ដីនៃបទថា "ប្រាថ្នាប្រើប្រាស់ជាធំ" ដូច្នេះ ទើបពោលនូវពាក្យមានពាក្យ ជាដើមថា "គ្រែនិងតាំងប៉ះខ្នងកាយរបស់ភិក្ខុកំពុងនាំទៅ" ដូច្នេះ ។

ក្នុងគម្ពីរខុទ្ទកសិក្ខាបុរាណដីកា ពោលថា:

★ អនុជានាមិ ភិក្ខវេ បច្ចត្ថរិត្វា និបជ្ជិតុន្តិ វុត្តត្តា បរិភណ្ឌកតំ ភូមឹ វា ភូមត្ថរណសេនាសនំ វា សង្ឃិកំ មញ្ចបីឋំ វា អត្តនោ សន្តកេន បច្ចត្ថរណេន បច្ចត្ថរិត្វាវ និបជ្ជិតព្វំ ។ ព្រោះព្រះពុទ្ធដីកាព្រះអង្គត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតក្រាលកម្រាលរួចសិន សឹមសឹង" ដូច្នេះ មានសេចក្ដីថា ភិក្ខុត្រូវក្រាលដោយកម្រាលជារបស់ខ្លួនហើយសិន សឹមសឹង នៅលើផែនដីដែលគេធ្វើបរិកម្មក្ដី នៅលើសេនាសនៈដែលក្រាលនៅលើផែនដីក្ដី នៅលើគ្រែ និងតាំង ដែលជារបស់សង្ឃក្ដី ។

ក្នុងគម្ពីរវិនយវិនិច្ឆយដីកា ពោលថា:

★ ធាយកេហិ "កាយេ ផុសិត្វា យថាសុខំ បរិភុញ្ជថា"តិ ទិន្នសេនាសនំ មញ្ចបីឋាទិញ្ច ធាយកេន វុត្តនិយាមេន បរិភុញ្ជន្តស្ស ទោសោ នត្ថីតិ មាតិ-

កដ្ឋកថាយ សីហឡគណ្ឋិបទេ វុត្តត្តា តថា បរិភុញ្ជន្តស្ស អនាបត្តិ ។ *ព្រោះពាក្យដែលលោកពោលទុក ក្នុងគណ្ឋិបទសីហឡក្នុងមាតិកដ្ឋកថា ថា "ទីសេនាសនៈក្តី គ្រែនិងតាំង ជាដើមក្តី ដែលទាយកថ្វាយហើយដោយពាក្យថា "សូមលោកម្ចាស់ប្រើប្រាស់ប៉ះពាល់នូវកាយតាមសប្បាយចុះ" ដូច្នេះ ទោសរមែងមិនមាន ដល់ភិក្ខុកាលប្រើប្រាស់តាមទំនង ដែលទាយកពោលហើយ" ដូច្នេះ ជាអនាបត្តិដល់ភិក្ខុកាល ប្រើប្រាស់ដោយប្រការដូច្នោះ ។*

*<u>ក្នុងបាចិត្យាទិយោជនា ពោលថា:</u>*

★ **មញ្ចបីឋាទីនន្តិ** អាទិសទ្ទេន ភិសិអាទយោ សង្គណ្ហាតិ ។ *ដោយអាទិសព្ទក្នុងពាក្យថា "មញ្ចបីឋាទីនំ" ដូច្នេះនេះ គឺលោកសង្គ្រោះយក ពូកជាដើមផងដែរ ។*

*<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:</u>*

★ មញ្ចបីឋំ ភិសី ពិម្ពោហនន្តិ ឥទំ មញ្ចបីឋសេ–នាសនំ នាម ។ *វត្ថុទាំងនេះគឺ គ្រែ តាំង ពូក ខ្នើយ ឈ្មោះថា សេនាសនៈ គឺគ្រែនិងតាំង ។*

**សេនាសនៈកថាចប់ ។**

# ២៨_លទ្ធិនានាសំវាសកកថា

**ភូមិនៃភិក្ខុមានសំវាសផ្សេងគ្នា មាន ២ យ៉ាង:**

*<u>ក្នុងវិនយបិដកភាគ ១៣ ទំព័រ ១៥ ពោលថា:</u>*

*១-អត្តនា អត្តានំ នានាសំវាសកំ ករោតិ ។ ភិក្ខុធ្វើខ្លួនឱ្យមានសំវាសផ្សេងគ្នា ដោយខ្លួនឯង (នេះគឺជាលទ្ធិនានាសំវាសកភិក្ខុ ) ។*

*២-សមគ្គោ នំ សង្ឃោ ឧក្ខិបតិ អទស្សនេ វា អប្បដិកម្មេ វា អប្បដិនិស្សគ្គេ វា ។ សង្ឃព្រមព្រៀងគ្នាលើកវត្តភិក្ខុនោះ ព្រោះមិនឃើញអាបត្តិក្តី ព្រោះមិនសម្តែងអាបត្តិក្តី ព្រោះមិនលះបង់ (ទិដ្ឋិអាក្រក់) ក្តី (នេះគឺជាកម្មនានាសំវាសកភិក្ខុ) ។*

*<u>ក្នុងព្រះអដ្ឋកថា ពន្យល់លទ្ធិនានាសំវាសក ថា:</u>*

★ *ពាក្យថា អត្តនា វា អត្តានំ នានាសំវាសកំ ករោតិ ភិក្ខុធ្វើខ្លួនឱ្យមានសំវាសផ្សេងគ្នា ដោយខ្លួនឯង ដូច្នេះនេះមានសេចក្តីថាកាលសង្ឃ ២ ពួក, អង្គុយក្នុងសីមាជាមួយគ្នាភិក្ខុអង្គុយក្នុងពួកម្ខាង, ហើយកាន់យកលទ្ធិរបស់ ភិក្ខុពួកម្ខាងទៀត, ខ្លួនអង្គុយហើយក្នុងបក្ខណា ឈ្មោះថា ខ្លួនឯងធ្វើខ្លួនឯង*

ឱ្យជានានាសំវាសកៈ របស់ភិក្ខុទាំងឡាយពួកនោះ ។ ខ្លួន អង្គុយហើយ ក្នុងសំណាក់របស់ភិក្ខុពួកណា សូម្បីជាគណបូរកៈ របស់ភិក្ខុពួកនោះ, ឈ្មោះថា **រមែងញុំាងកម្មឱ្យកម្រើក**, កម្ម របស់ភិក្ខុមួយពួកទៀត រមែងកម្រើកដែរ ព្រោះខ្លួនមិនចូល មកកាន់ហត្ថបាស ។ សូម្បីក្នុងសមានសំវាសកៈ ក៏មានន័យ ដូចគ្នា ។ ពិតមែន ភិក្ខុនោះពេញចិត្ត លទ្ធិរបស់ភិក្ខុពួកណា រមែងជាអ្នកមានសំវាសស្មើគ្នាជាមួយ ពួកភិក្ខុទាំងនោះ និង ជាអ្នកមានសំវាសផ្សេងគ្នា ជាមួយនឹងពួកភិក្ខុមួយទៀត ។

<u>ក្នុងវិនយបិដកភាគ ៦ ទំព័រ ៤៣៣ ពោលថា:</u>

★ ក្នុងសាសនានេះ បើមានអាគន្តុកភិក្ខុ ឃើញអាវាសិក ភិក្ខុមានសំវាសផ្សេងគ្នា ពួកលោកយល់ឃើញថាមានសំវាស ស្មើគ្នា ហើយក៏មិនបានសួរនូវលទ្ធិរបស់ភិក្ខុទាំងនោះ លុះមិន បានសួរហើយ ក៏ធ្វើនូវវត្តតូចនិងវត្តធំ ហើយធ្វើឧបោសថ ជាមួយគ្នា មិនត្រូវអាបត្តិអ្វីឡើយ ។ បើសួរហើយ មិនអាច ឱ្យលោកលះបង់នូវលទ្ធិនោះបានទេ កាលធ្វើឧបោសថជាមួយ ត្រូវអាបត្តិទុក្កដ ។

<u>ក្នុងគម្ពីរសារត្ថទីបនី និងវិមតិវិនោទនីដីកា ពោលថា:</u>

★ **ឆាឆាសំវាសកការវត្ថិ** លទ្ធិឆាឆាសំវាសកការំ ។

ពាក្យថា *ភាវៈនៃភិក្ខុមានសំវាសផ្សេងគ្នា* គឺបានដល់ ភាពជាភិក្ខុមានសំវាសផ្សេងគ្នា ដោយលិទ្ធិ ។

**ការធ្វើកម្មជាមួយភិក្ខុដែលផ្សេងគ្នា ដោយលិទ្ធិត្រូវទុកក្នុង**

<u>ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:</u>

★ កម្មនានាសំវាសកញ្ហិ ទិដ្ឋី បដិនិស្សជ្ជាបេត្វា តស្ស ឱសារណាកម្មំ កាតព្វំ ។ ឯវញ្ហិ កតេ តេន សទ្ធឹ ឧបោសថំ កាតុំ វដ្តតិ ។ ឥតរេន លទ្ធិនិស្សជ្ជនមត្តេន កាតុន្តិ វុត្តំ ។ អាបត្តិយា អទស្សនេ អប្បដិកម្មេ ឧក្ខិត្តកញ្ច ទិដ្ឋិយា អប្បដិនិស្សគ្គេ ឧក្ខិត្តកញ្ច ជានិត្វា តេន សទ្ធឹ ករោន្តស្ស បាចិត្តិយំ, តស្មា ឥមេ ឧក្ខិត្តានុវត្តកាតិ វេទិតព្វាតិ ឯកេ ។

ពិតមែន ភិក្ខុដែលជា*កម្មនានាសំវាសកៈ* ឱ្យលោកលះបង់ទិដ្ឋិហើយ ត្រូវធ្វើឱសារណាកម្មដល់លោកផង ។ កាលធ្វើយ៉ាងនេះ ទើបគួរដើម្បីធ្វើឧបោសថកម្ម ជាមួយលោកបាន ។ ភិក្ខុក្រៅនេះ *(គឺលិទ្ធិនានាសំវាសកៈ)* លោកពោលថា ត្រឹមតែឱ្យលោកលះបង់នូវទិដ្ឋិចេញហើយ *រមែងគួរធ្វើឧបោសថ* ជាមួយលោកបាន ។ អាចារ្យពួកខ្លះពោលថា កាលភិក្ខុដឹង(នូវភិក្ខុ

ដទៃ) ដែលសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិក្តី មិនសម្តែងអាបត្តិក្តី និងភិក្ខុដែលសង្ឃលើកវត្ត ព្រោះមិនលះបង់នូវទិដ្ឋិក្តី ធ្វើកម្មជាមួយឧក្ខិត្តកភិក្ខុ ៣ ពួកនោះ **រមែងត្រូវអាបត្តិបាចិត្តិយ** ។ ព្រោះហេតុនោះ ភិក្ខុទាំងនោះ (គឺភិក្ខុដែលមានសំវាសផ្សេងគ្នាក្នុងបិដក) បណ្ឌិតត្រូវជ្រាបថា **ជាភិក្ខុដែលប្រព្រឹត្តតាមភិក្ខុដែលសង្ឃលើកវត្ត** (គឺលិទ្ធិនានាសំវាសកភិក្ខុ) ។

<u>ក្នុងគម្ពីរអដ្ឋកថា ចម្បេយ្យក្ខន្ធកៈ ពោលថាៈ</u>

★ តត្ថ ឧក្ខិត្តកគ្គហណេន កម្មនានាសំវាសកោ គហិតោ នានាសំវាសកគ្គហណេន លទ្ធិនានាសំវាសកោ ។ បណ្តាបុគ្គលទាំងនោះ បុគ្គលដែលមានសំវាសផ្សេងគ្នា ព្រោះកម្ម គឺព្រះមានព្រះភាគទ្រង់សំដៅយក **ដោយឧក្ខិត្តកៈស័ព្ទ** ។ បុគ្គលដែលផ្សេងគ្នាព្រោះលទ្ធិ គឺព្រះអង្គសំដៅយក ដោយ **នានាសំវាសកៈស័ព្ទ** ។

<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថាៈ</u>

★ ឧក្ខេបនីយកម្មកតោ កម្មនានាសំវាសកោ ឧក្ខិត្តានុវត្តកោ លទ្ធិនានាសំវាសកោ ។ បុគ្គលដែលត្រូវសង្ឃដាក់ឧក្ខេបនីយកម្ម (ទាំង៣) ឈ្មោះថា **កម្មនានាសំវាសកភិក្ខុ** (គឺភិក្ខុមានសំវាសផ្សេងគ្នាដោយកម្ម) ។ បុគ្គលដែលប្រព្រឹត្ត

តាមភិក្ខុដែលសង្ឃលើកវត្ត ឈ្មោះថា **លិង្គនានាសំវាសកភិក្ខុ** (គឺភិក្ខុផ្សេងគ្នាដោយលិង្គ) ។

<u>ក្នុងវិនយបិដកភាគ ៦ ទំព័រ៣២៣ ពោលថា:</u>

★ (ភិក្ខុដែលសង្ឃលើកវត្ត ព្រោះមិនឃើញអាបត្តិក្តី មិនសម្តែងអាបត្តិក្តី មិនលះបង់នូវទិដ្ឋិក្តី ប្រសិនបើលោកមកបួសវិញ) លុះភិក្ខុទាំងឡាយឱ្យឧបសម្បទាហើយ ត្រូវសួរថា លោកនឹងលះបង់នូវទិដ្ឋិអាក្រក់នោះទេ ។ បើភិក្ខុនោះ និយាយថា "ខ្ញុំករុណានឹងមិនលះបង់ទេ" មិនត្រូវសូត្រឱសារណាកម្មទេ បើលោកនិយាយថា "ខ្ញុំករុណានឹងលះបង់" **ត្រូវភិក្ខុទាំងឡាយសូត្រឱសារណាកម្មចុះ** ។ លុះភិក្ខុទាំងឡាយ សូត្រឱសារណាកម្មហើយ ត្រូវនិយាយនឹងភិក្ខុនោះថា ចូរលោកលះបង់នូវទិដ្ឋិអាក្រក់នោះទៅ ។ បើភិក្ខុនោះព្រមលះបង់ ការលះបង់នោះជាការល្អ បើមិនព្រមលះទេ កាលបើភិក្ខុទាំងឡាយ បាននូវសេចក្តីព្រមព្រៀងគ្នា ត្រូវលើកវត្តម្តងទៀត បើមិនបានសេចក្តីព្រមព្រៀងគ្នាទេ **មិនមានអាបត្តិ** ព្រោះការបរិភោគរួម និងការនៅរួមឡើយ ។

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

★ **"ឱសារេតព្វោ"តិ** ឥមិនា បុរិមោ ឧក្ខិត្តកភាវោ

វិត្ថមិត្វា បុន លទ្ធូបសម្បទម្បិ ន មុញ្ចតិ ។ តេន ច សម្ភុញ្ជនាទីសុបិ ភិក្ខូនំ បាចិត្តិយមេវាតិ ទស្សេតិ ។ ដោយពាក្យថា ត្រូវភិក្ខុទាំងឡាយសូត្រ ឱសារណាកម្មចុះ ដូច្នេះ មានសេចក្តីថា ភាពជាឧក្ខិត្តកភិក្ខុខាងដើម រមែងមិនរួច សូម្បី ដល់ភិក្ខុដែលសឹកទៅហើយ ត្រលប់មកបួសជាភិក្ខុវិញទេ ។ ក៏ព្រោះហេតុនោះ លោកពោលថា ជាអាបត្តិបាចិត្តិយពិត ដល់ភិក្ខុទាំងឡាយ ដែលបរិភោគរួមជាមួយនឹងភិក្ខុនោះ ។

★ **ឯត្ថចាយមធិប្បាយោ "យស្មា អយំ ឱសារិតត្តា បកតត្តោ, តស្មា ឧក្ខិត្តសម្ភោគាទិបច្ចយេន បាចិត្តិយេ-នេត្ថ អនាបត្តីតិ ។**

*សេចក្តីអធិប្បាយក្នុងសេចក្តីនេះ មានដូចតទៅ ភិក្ខុដែលសង្ឃលើកវត្តនោះ ជាបកតត្តហើយព្រោះភាវនៃលោក គឺសង្ឃបានធ្វើឱសារណាហើយ, ព្រោះហេតុណា ហេតុនោះ ក្នុងសេចក្តីនេះ ទើបជាអនាបត្តិ ដោយអនាបត្តិបាចិត្តិយ ព្រោះការបរិភោគរួមជាមួយភិក្ខុដែលសង្ឃលើកវត្តជាបច្ច័យ ។*

*<u>ក្នុងព្រះអដ្ឋកថា ពោលថា:</u>*

★ **អលព្ភមានាយ សាមគ្គិយា អនាបត្តិ សម្ភោគេ សំវាសេតិ** យាវ តស្ស ឧក្ខេបនីយកម្មករណាត្ថាយ

សាមគ្គឹ ន លព្ភតិ ។ តាវ តេន សទ្ធឹ សំភោគេ ច ឧបោសថបវារណាទិករណភេទេ សំវាសេ ច អនាបត្តីតិ ។

*ពាក្យថា កាលមិនបានសេចក្ដីព្រមព្រៀងគ្នា ជាអនាបត្តិក្នុងការបរិភោគរួម និងការនៅរួម ដូច្នេះនេះ មានសេចក្ដីថា សេចក្ដីព្រមព្រៀងដើម្បីប្រយោជន៍ ដល់ការធ្វើឧក្ខេបនីយកម្ម រមែងមិនបានដល់ភិក្ខុនោះ ដរាបណា, ដរាបនោះមិនជាអាបត្តិ ព្រោះការបរិភោគរួមផង និងការនៅរួម ផ្សេងដោយប្រភេទមានឧបោសថ និងបវារណាជាដើម ជាមួយនឹងភិក្ខុនោះផង ។*

<u>*ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:*</u>

☆ **អនាបត្តិ សម្ភោគេតិ** ឧក្ខិត្តកេន សម្ភោគេ អនាបត្តិ ។ កស្មា ? ឧក្ខិត្តកកម្មស្ស គហដ្ឋ-ភាវេនបដិប្បស្សទ្ធត្តា តេនេវ "អលព្ភមានាយ សាមគ្គិ-យា"តិ វុត្តំ ។ *ពាក្យថា **ជាអនាបត្តិក្នុងការបរិភោគ** ដូច្នេះនេះ មានពាក្យសួរថាហេតុអ្វី បានជាមិនត្រូវអាបត្តិ ក្នុងការបរិភោគរួមជាមួយនឹងភិក្ខុដែលសង្ឃលើកវត្ត ? ឆ្លើយថា ព្រោះភាវៈនៃឧក្ខិត្តកកម្ម (កម្មគឺការលើកវត្ត ) ស្ងប់រម្ងាប់ហើយ ដោយភាពជាគ្រហស្ថ, ព្រោះហេតុនោះឯង ទើបព្រះអដ្ឋកថាចារ្យពោលថា " កាលមិនបានសេចក្ដីព្រមព្រៀងគ្នា " ដូច្នេះ ។*

*ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:*

★ **សម្ភោគេតិ** ធម្មសម្ភោគេ អាមិសសម្ភោគេ ចាតិ ។

*ពាក្យថា ការបរិភោគរួម ដូច្នេះ បានដល់ការបរិភោគរួម ដោយធម៌ផង ដោយអាមិសផង ។*

★ **អនាបត្តិ សម្ភោគេ សំវាសេតិ** ឯត្ថ ច អយមធិប្បាយោ យស្មា អយំ ឧក្ខេបនីយកម្មស្ស កតត្តា បកតត្តដ្ឋានេ ឋិតោ, តស្មា ន ឧក្ខិត្តកេន សទ្ធឹ សម្ភោគាទិបច្ចយា បាចិត្តិយំ, ណាបិ អលជ្ជិនា សទ្ធឹ បរិភោគបច្ចយា ទុក្កដំ អលជ្ជីលក្ខណានុបបត្តិតោ ។

*ពាក្យថា ជាអនាបត្តិក្នុងការបរិភោគរួម និងការនៅរួម ដូច្នេះនេះ មានសេចក្តីអធិប្បាយតទៅនេះ ភិក្ខុនេះ រមែងតាំងនៅក្នុងឋានៈជាបកតត្ត ព្រោះឧិសារណាកម្ម គឺសង្ឃបានធ្វើហើយ ព្រោះហេតុណា ហេតុនោះ ទើបមិនត្រូវអាបត្តិបាចិត្តិយ ព្រោះការបរិភោគរួមជាមួយភិក្ខុដែលសង្ឃលើកវត្តជាបច្ច័យ, ទាំងមិនជាទុក្កដ ព្រោះការបរិភោគរួមជាមួយអលជ្ជី ព្រោះលោកមិនទាន់ដល់លក្ខណៈជាអលជ្ជី ។*

★ យោ ហិ ឧច្ចុរសកសដានំ សត្តាហកាលិកយាវជីវិកត្តា វដ្តតិ វិកាលេ ឧច្ចុ ខាទិតុន្តិ សញ្ញាំ

ឧប្បាទេត្វា តំ ខាទិត្វា តប្បច្ចយា បាចិត្តិយំ ន បស្សតិ "វដ្ដតី"តិ តថាសញ្ញិតាយ, យោ វា បន អាបត្តិមាបន្នភាវំ បជានិត្វា "ន បដិករោមី"តិ អភិនិវិសតិ អយំ "សញ្ចិច្ច អាបត្តឹ អាបជ្ជតិ, អាបត្តឹ បរិគូហតិ ។ អគតិគមនញ្ច គច្ឆតិ, ឯទិសោ វុច្ចតិ អលជ្ជីបុគ្គលោ"តិ វុត្តលក្ខណោ អបតនតោ អលជ្ជី នាម ន ហោតិ ។

*ពិតមែនបុគ្គលណា ញុំាងសេចក្ដីសំគាល់ ឱ្យកើតឡើងថា ការឆាន់ដើមអំពៅក្នុងវេលាវិកាលគួរ, ព្រោះទឹកអំពៅ ជាសត្តាហកាលិក និងព្រោះកាកអំពៅជាយាវជីវិក ហើយឆាន់នូវដើមអំពៅនោះ មិនឃើញនូវអាបត្តិបាចិត្តិយ ព្រោះការឆាន់នូវដើមអំពៅ ក្នុងវេលាវិកាលនោះជាបច្ច័យទេ, ព្រោះសំគាល់ថា គួរដូច្នេះ ។ ម្យ៉ាងទៀត បុគ្គលណា ប្ដេជ្ញានូវភាវៈនៃខ្លួនជាអ្នកត្រូវអាបត្តិហើយ ប្រកាន់យ៉ាងមាំថា "ខ្ញុំនឹងមិនធ្វើតប" ដូច្នេះ បុគ្គលនេះមិនឈ្មោះថា **ជាអលជ្ជីទេ** ព្រោះប្រាសចាកលក្ខណៈដែលលោកពោលហើយថា "ភិក្ខុក្លែងត្រូវអាបត្តិក្តី ក្លែងបិទបាំងអាបត្តិក្តី ក្លែងលុះក្នុងអគតិក្តី បុគ្គលមានសភាពបែបនេះលោកហៅថា **ជាអលជ្ជីបុគ្គល**" ។*

★ តស្មា យថា បុត្តោ យាវ ឧក្ខេបនីយកម្មំ កតំ តាវ

តេន សទ្ធឹ សម្ភោគេ សំវាសេ ច អនាបត្តិ ឯវមិធាបីតិ សព្វថា អនាបត្តិដ្ឋានេយេវ អនាបត្តិ វុត្តាតិ វេទិតព្វំ ន ហិ ភគវា អលជ្ជិនា សទ្ធឹ សម្ភោគបច្ចយា អាបត្តិសម្ភវេ សតិ "អនាបត្តិ សម្ភោគេ សំវាសេ"តិ វទតិ ៖ *ព្រោះហេតុនោះ ឧក្ខេបនីយកម្មដែលសង្ឃធ្វើហើយ ក្នុងកាលមុន នៅមានដរាបណា, ដរាបនោះមិនជាអាបត្តិក្នុងការបរិភោគរួមផង និងការនៅរួមផង ជាមួយនឹងភិក្ខុដែលសង្ឃលើកវត្តនោះ ។ សូម្បីក្នុងសេចក្ដីនេះ បណ្ឌិតគប្បីជ្រាបថា គឺលោកពោលអនាបត្តិ ក្នុងឋានៈជាអនាបត្តិ ក្នុងទីទាំងពួង, ព្រោះថា កាលបើមានអាបត្តិព្រោះការបរិភោគរួមជាមួយនឹងអលជ្ជី ជាបច្ច័យមែន ព្រះមាន-ព្រះភាគ ទ្រង់មិនត្រាស់ថា ជាអនាបត្តិក្នុងការបរិភោគរួម និងការនៅរួមទេ ។*

★ តតោ យមេត្ថ កេនចិ "អនាបត្តិ សម្ភោគេ-សំវាសេ"តិ ឥមិនា ធាចិត្តិយេន អនាបត្តិ វុត្តា "អលជ្ជីបរិភោគបច្ចយា ទុក្កដំ បន អាបជ្ជតិយេវា"តិ វត្វា ពហុធា បបញ្ចិតំ, ន តំ សារតោ បច្ចេតព្វំ ។

*ក៏ពាក្យណា ដែលអាចារ្យពួកខ្លះ ពោលក្នុងសេចក្ដីនេះ ថា ដោយពាក្យថា ជាអនាបត្តិក្នុងការបរិភោគរួម និងការ*

នៅរួម ដូច្នេះនេះ គឺលោកពោលថា ជាអនាបត្តិ ដោយអាបត្តិបាចិត្តិយ, តែជាអាបត្តិទុក្កដ ព្រោះការបរិភោគរួមជាមួយអលជ្ជីជាបច្ច័យ, ហើយពោលពាក្យដ៏ច្រើនទៀត, ពាក្យនោះ បណ្ឌិតមិនគប្បីជឿ ដោយសារឡើយ ។

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

★ យោ បន អាបត្តិដ្ឋានេ អនាបត្តិទិដ្ឋិតាយ អាបត្តឹ ន បស្សតិ, តេនេវ បដិកម្មម្បិ ន ករោតិ, សោ យស្មា ឯត្តាវតា អលជ្ជី នាម ន ហោតិ ។ បណ្ណត្តឹ ញត្វា វីតិក្កមំ ករោន្តោ ឯវ ហិ អលជ្ជី នាម ហោតិ ។ "សញ្ចិច្ច អាបត្តឹ អាបជ្ជតី"តិអាទិ ហិ វុត្តំ ។ ក៏ភិក្ខុណា មិនឃើញនូវអាបត្តិ ព្រោះយល់ឃើញថា ជាអនាបត្តិក្នុងឋានៈ ដែលជាអាបត្តិ, ព្រោះហេតុនោះ ទើបមិនធ្វើតបនូវអាបត្តិនោះ ភិក្ខុនោះជាអលជ្ជីដោយហេតុមានប្រមាណប៉ុណ្ណោះ មិនមានទេ ។ ព្រោះហេតុណា ហេតុនោះ ភិក្ខុកាលដឹងនូវបទបញ្ញត្តិហើយ ប្រព្រឹត្តកន្លង រមែងឈ្មោះថា ជាអលជ្ជីពិត ។ ព្រោះហេតុនោះ ទើបលោកពោលហើយនូវពាក្យជាដើមថា "ភិក្ខុក្លែងត្រូវអាបត្តិ" ដូច្នេះ ។

★ តស្មា ឯត្ថ អលជ្ជិសម្ភោគាទិបច្ចយាទុក្កដាបត្តិ-

និយមោ នត្ថិ ។ តេន សាបេត្ថ អាបត្តិ ន វុត្តាតិ ទដ្ឋព្វំ ។ យោ បនេត្ថ ឥមំ អធិប្បាយំ អសល្លក្ខេន្តេន កេនចិ "អនាបត្តិ សម្ភោគេ សំវាសេ"តិ ឥមិនា បាចិត្តិយេន អនាបត្តិ វុត្តា, អលជ្ជិសម្ភោគបច្ចយា ទុក្កដំ បន អាបជ្ជតិ ឯវាតិ អាបត្តិ និយមោ វុត្តោ, សោ អលជ្ជិត្តេ សតិ ឯវ វុត្តោ, នាសតីតិ ទដ្ឋព្វំ ។ *ព្រោះហេតុនោះ ក្នុងសេចក្តីនេះ ការកំណត់អាបត្តិទុក្កដ ព្រោះការបរិភោគរួមជាមួយអលជ្ជីមិនមានទេ ។ តែក្នុងសេចក្តីនេះ អាចារ្យពួកខ្លះ កាលមិនកំណត់នូវសេចក្តីអធិប្បាយនេះ ទើបពោលថា ជាអនាបត្តិដោយអាបត្តិបាចិត្តិយ ព្រោះពាក្យនេះថា "ជាអនាបត្តិ ក្នុងការបរិភោគរួមនិងការនៅរួម" ដូច្នេះ ហើយពោលកំណត់អាបត្តិថា "តែត្រូវអាបត្តិទុក្កដពិត ព្រោះការបរិភោគរួមជាមួយអលជ្ជីជាបច្ច័យ" ។ បើភិក្ខុនោះ ជាអលជ្ជីមានពិត គឺលោកពោលហើយ, បណ្ឌិតគប្បីជ្រាបថា **មិនមែនជាអលជ្ជីទេ** ។*

**លិទ្ធិនានាសំវាសកកថាចប់ ។**

# ២៩_អបលោកនកម្មកថា

## អបលោកនកម្មដល់នូវឋាន ៥ យ៉ាង:

*ក្នុងវិនយបិដកភាគ ១៣ ទំព័រ ៤២៧ ពោលថា:*

១-និស្សារណា ការបណ្តេញចេញ

២-ឱសារណា ការហៅចូលមក

៣-ភណ្ឌុកម្ម ការកោរសក់

៤-ព្រហ្មទណ្ឌ អាជ្ញាដ៏ប្រសើរ

៥-កម្មលក្ខណា លក្ខណ:គឺកម្មនោះឯង ។

*ក្នុងព្រះអដ្ឋកថាបរិវារ: ពោលថា:*

★ អប្បលោកនកម្មំ នាម សីមដ្ឋកសង្ឃំ សោធេត្វា ឆន្ទារហានំ ឆន្ទំ អាហរិត្វា សមគ្គស្ស សង្ឃស្ស អនុមតិយា តិក្ខត្តុំ សាវេត្វា កត្តព្វំ កម្មំ ។ កម្មដែលភិក្ខុគប្បីជម្រះនូវសង្ឃដែលមាននៅខាងក្នុងសីមា ហើយនាំនូវឆន្ទ: របស់បុគ្គលដែលគួរដល់ឆន្ទ: ហើយសូធ្យអស់វារ:៣ ដង តាមអនុមតិរបស់សង្ឃ ដែលព្រមព្រៀងគ្នា ហើយធ្វើ ឈ្មោះថា អបលោកនកម្ម ។

<u>ក្នុងគម្ពីរវិនយាលង្ការដីកា ពន្យល់ថា:</u>

★ **សីមដ្ឋកសង្ឃំ សោធេត្វាតិ** អវិប្បវាសសង្ខាត-
មហាសីមដ្ឋកំ សង្ឃំ សោធេត្វា ។ ន ហិ ខណ្ឌសីមាយ
សន្និបតិតេ សង្ឃេ សោធេតព្វកិច្ចំ អត្ថិ, អវិប្ប-
វាសសីមាសង្ខាតាយ មហាសីមាយ បន វិត្ថារត្តា ពហូនំ
ភិក្ខូនំ វសនដ្ឋានត្តា សមគ្គការត្ថំ សោធេតព្វំ ហោតិ ។

*ពាក្យថា គប្បីជម្រះនូវសង្ឃ ដែលមាននៅខាងក្នុងសីមា ដូច្នេះ គឺត្រូវជម្រះនូវសង្ឃ ដែលនៅក្នុងមហាសីមា ពោលគឺអវិប្បវាស សីមា ។ ព្រោះថាកិច្ចដែលគប្បីជម្រះនូវសង្ឃដែលប្រជុំគ្នា នៅ ខាងក្នុងខណ្ឌសីមា រមែងមិនមាន, តែនៅក្នុងមហាសីមា ពោល គឺ អវិប្បវាសសីមា ត្រូវតែជម្រះដើម្បីភាពព្រមព្រៀងគ្នា ព្រោះ ភាវនៃមហាសីមា ជាសីមាឆ្ងាយធំទូលាយ និងព្រោះជាទីកន្លែង ចូលទៅនៃភិក្ខុទាំងឡាយជាច្រើន ។*

★ **ឆន្ទារហានំ ឆន្ទំ អាហរិត្វាតិ** តិស្សំ សីមាយំ
ចតុវគ្គាទិគណំ បូរេត្វា ហត្ថបាសំ អវិជហិត្វា ឋិតេហិ
ភិក្ខូហិ អញ្ញេសំ ហត្ថបាសំ អនាគតានំ បកតត្តភិក្ខូនំ
ឆន្ទំ អាហរិត្វា ។ វុត្តញ្ហិ "ចតុវគ្គករណេ កម្មេ ចត្តារោ

ភិក្ខូ បកតត្តា កម្មប្បត្តា, អវសេសា បកតត្តា ឆន្ទារហា"តិ ។ *ពាក្យថា* ***នាំនូវឆន្ទៈរបស់បុគ្គលដែលគួរដល់ឆន្ទៈ*** *ដូច្នេះ មានសេចក្ដីថា ភិក្ខុដែលឋិតនៅក្នុងសីមានោះ ត្រូវបំពេញគណៈ មានសង្ឃចតុវគ្គជាដើម ហើយកុំលះបង់នូវហត្ថបាស, រូបត្រូវនាំឆន្ទៈរបស់បកតត្តភិក្ខុដទៃ ដែលមិនបានមកកាន់ហត្ថបាស ។ សមដូចពាក្យដែលលោកពោលថា "ក្នុងកម្មដែលគប្បីធ្វើដោយសង្ឃចតុវគ្គ ភិក្ខុ ៤ រូប អ្នកមានខ្លួនជាប្រក្រតី (បកតត្ត) ជាអ្នកគួរដល់កម្ម, ភិក្ខុទាំងឡាយដ៏សេស អ្នកមានខ្លួនជាប្រក្រតី (បកតត្ត) គឺថា ជាអ្នកគួរដល់ឆន្ទៈ" ។*

✯ **សមគ្គស្ស សង្ឃស្ស អនុមតិយាតិ** ឆន្ទស្ស អាហរិតត្តា ហត្ថបាសំ អាគតាបិ អនាគតាបិ សព្វេ ភិក្ខូ សមគ្គាយេវ ហោន្តិ, តស្មា សមគ្គស្ស សង្ឃស្ស អនុមតិយា ។ *ពាក្យថា* ***តាមអនុមតិរបស់សង្ឃដែលព្រមព្រៀងគ្នា*** *ដូច្នេះ មានសេចក្ដីថា ភិក្ខុទាំងអស់ ដែលបានមកកាន់ហត្ថបាសក្ដី មិនបានមកកាន់ហត្ថបាសក្ដី រមែងជាការព្រមព្រៀងគ្នាពិត ព្រោះឆន្ទៈលោកបាននាំមកហើយ ។*

✯ **តិក្ខត្តុំ សាវេត្វាតិ** "សុណាតុ មេ, ភន្តេ

សង្ឃោ"តិអាទិនា កម្មវាចំ អភណិត្វា "វុច្ចតិ សង្ឃស្ស ។ ទុតិយម្បិ, តតិយម្បិ, វុច្ចតិ សង្ឃស្សា"តិ តិក្ខត្តុំ សាវេត្វា កាតព្វកម្មំ អបលោកនកម្មំ នាមាតិ យោជនា ។

*ពាក្យថា សូធ្យ ៣ ដង ដូច្នេះនេះ មានយោជនាថា កម្មដែលភិក្ខុមិនត្រូវសូត្រកម្មវាចា ដោយពាក្យថា "សុណាតុ មេ ភន្តេ សង្ឃោ" ជាដើមទេ, ហើយធ្វើការសូធ្យអស់វារៈ ៣ ដងថា "... វុច្ចតិ សង្ឃស្ស ។ ទុតិយម្បិ... វុច្ចតិ សង្ឃស្ស ។ តតិយម្បិ... វុច្ចតិ សង្ឃស្ស" ដូច្នេះ ឈ្មោះថា អបលោកនកម្ម ។*

## សីមាដែលត្រូវធ្វើអបលោកនកម្ម

*<u>ក្នុងគម្ពីរវិនយាលង្ការដីកា ពោលទៀតថា:</u>*

★ "ឥមិស្សា ឧបចារសីមាយ សង្ឃស្ស ឧម្មិតិ ទិន្នំ បន ខណ្ឌសីមសីមន្តរិកាសុ ឋិតានម្បិ ធាបុណាតី"តិ វុត្តំ ។ តេន ញាយតិ "ឧបចារសីមាយ អន្តោ ឋិតា ពទ្ធសីមា ឧបចារសីមាបិ នាម ហោតី"តិ ។ ហោតុ, ឯវំ សតិ អន្តោ ឧបចារសីមាយំ ពទ្ធសីមាយ សតិ តត្ថេវ កាឋិនធានកម្មវាចំ វាចាបេត្វា តត្ថេវ កឋិនំ អត្ថរិតព្វំ

ភវេយ្យ ។ ក៏ក្នុងអដ្ឋកថាពោលថា សម្ពត់ដែលទាយកថ្វាយថា "ខ្ញុំសូមថ្វាយដល់សង្ឃ ក្នុងឧបចារសីមានេះ" ដូច្នេះ រមែងសម្រេចដល់ភិក្ខុ សូម្បីដែលនៅខាងក្នុងខណ្ឌសីមា និងសីមន្តរិក ។ ព្រោះហេតុនោះ បណ្ឌិតគប្បីដឹងថា **"ព័ទ្ធសីមាដែលនៅខាងក្នុងឧបចារសីមា ក៏មានឈ្មោះថា ឧបចារសីមាដែរ"** ។ កាលមានសីមាយ៉ាងនេះចូរលើកទុកចុះ, កាលព័ទ្ធសីមាមាននៅក្នុងខាងក្នុងឧបចារសីមា ភិក្ខុគប្បីសូត្រកម្មវាចាប្រគល់ឱ្យនូវសម្ពត់កឋិន ក្នុងឧបចារសីមានោះឯង ហើយគប្បីក្រាលកឋិនក្នុងសីមានោះឯង ។

ឯវំ សន្តេ "បរិនិដ្ឋិតបុព្វករណមេវ, ចេ ទាយកោ សង្ឃស្ស ទេតិ, សម្បដិច្ឆិត្វា កម្មវាចាយ ទាតព្វំ ។ តេន ច តស្មឹយេវ សីមមណ្ឌលេ អធិដ្ឋហិត្វា អត្ថរិត្វា សង្ឃោ អនុមោទាបេតព្វោ"តិ វុត្តេន វជិរពុទ្ធិដីកាវចនេន វិរុជ្ឈតីតិ ? ននុ អវោចុម្ហ "កម្មវាចាភណនសីមា ពទ្ធ-សីមាភូតា កឋិនត្ថារសីមា ឧបចារសីមាភូតា"តិ ។ តស្មា វជិរពុទ្ធិដីកាវចនេន ន វិរុជ្ឈតិ ។ សួរថា កាលបើហេតុយ៉ាងនេះមាន, រមែងខុសពីពាក្យវជិរពុទ្ធិដីកា ដែលពោលថា "បើទាយកធ្វើបុព្វករណស្រេចហើយ ទើបថ្វាយដល់សង្ឃ, ភិក្ខុគប្បីទទួលហើយប្រគល់ឱ្យដោយកម្មវាចា ។ ក៏ព្រោះហេតុនោះ ភិក្ខុ

គប្បីអធិដ្ឋានក្នុងមណ្ឌលសីមានោះឯង ហើយក្រាលរូបហើយ ញ៉ាំងសង្ឃឱ្យអនុមោទនា" ដូច្នេះ មិនមែនឬ? ឆ្លើយថា ក្រែង លោកបានពោលហើយថា "សីមាដែលសូត្រកម្មវាចា ជាព័ទ្ធសីមា សីមាដែលក្រាលកឋិន ជាឧបចារសីមា" ។ ព្រោះហេតុនោះ ទើបមិនខុសពីពាក្យរបស់វជិរពុទ្ធិដីកា ។

★ អដ្ឋកថាយម្បិ "អបលោកនកម្មំ នាម ។បេ ។ កត្តព្វំ កម្ម"ន្តិ អបលោកនកម្មស្សាបិ **ពទ្ធសីមាយ- មេវ កត្តព្វភាវោ វុត្តោ, ន ឧបចារសីមាយំ ។** ន ហិ តត្ថ សីមដ្ឋកសង្ឃសោធនញ្ច ឆន្ទារហានញ្ច អត្ថិ, អញ្ញោ សីមំ បរិវជ្ជបរិវជ្ជានំ សង្ឃលាភោ ធាតព្វោយេវ ហោតិ ។ *ភាព នៃអបលោកនកម្ម គឺភិក្ខុគប្បីធ្វើ* ***នៅក្នុងព័ទ្ធសីមាប៉ុណ្ណោះ*** *គឺ លោកពោលទុកហើយ សូម្បីនៅក្នុងអដ្ឋកថា ថា "កម្មដែលភិក្ខុ គប្បីជម្រះនូវសង្ឃ ។ល ។ ហើយធ្វើ, ឈ្មោះថា* ***អបលោក នកម្ម*** *" ដូច្នេះ,* ***មិនមែននៅក្នុងឧបចារសីមាទេ*** *។ ព្រោះថាការ ជម្រះនូវសង្ឃដែលមាននៅក្នុងសីមាផង ការនាំនូវឆន្ទៈផង ក្នុង ខណ្ឌសីមានោះ រមែងមិនមាន, លាភរបស់សង្ឃ គឺជាលាភ ដែលភិក្ខុត្រូវឱ្យពិត ដល់ភិក្ខុដែលចូលមកហើយៗ កាន់ខាង ក្នុងសីមា ។*

តស្មា "ញត្តិកម្មភូតំ ឧបោសថបវារណាកម្មំ អពទ្ធសីមវិហារេបិ កត្តព្វ"ន្តិ គណ្ឋន្តានំ អាចរិយានំ វាទោបិ "ញត្តិទុតិយកម្មភូតំ កឋិនទានកម្មំ ឧបចារសីមាយមេវ កត្តព្វ"ន្តិ គណ្ឋន្តានំ អាចរិយានំ វាទោបិ បាឡិវិរោធោ អដ្ឋកថាវិរោធោ ច ហោតីតិ វេទិតព្វោ ។ យមេត្ថ វត្តព្វំ, តំ ឧបោសថបវារណកថាវណ្ណនាយញ្ច កឋិនកថាវណ្ណនាយញ្ច វុត្តំ, អត្ថិកេហិ តត្ថ សុដ្ឋុ ឱលោកេត្វា សំសយោ វិនោទេតព្វោ ។ *ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបថា សូម្បីវាទអាចារ្យទាំងឡាយ កាលកាន់យកថា "ឧបោសថកម្ម និង បវារណាកម្ម ដែលជាញត្តិកម្ម គឺភិក្ខុគប្បីធ្វើសូម្បីក្នុងវិហារ ដែលជាអពទ្ធសីមា" ទាំងវាទរបស់អាចារ្យទាំងឡាយ កាលកាន់ យកថា "កម្មគឺការសូត្រប្រគល់ឱ្យនូវសម្ពត់កឋិន ដែលជាញត្តិទុតិយកម្ម គឺភិក្ខុគប្បីធ្វើនៅក្នុងឧបចារសីមាពិត"* ***រមែងជាពាក្យខុសចាកទាំងបាលី ខុសចាកទាំងអដ្ឋកថា*** *។ ពាក្យណា ដែល ខ្ញុំត្រូវពោលក្នុងសេចក្ដីនេះ, ពាក្យនោះគឺលោកពោលហើយ ក្នុង អដ្ឋកថាឧបោសថ និងបវារណាខន្ធកៈផង ក្នុងអដ្ឋកថាកឋិនក្ខន្ធកៈផង ។ បុគ្គលដែលមានសេចក្ដីប្រាថ្នា គប្បីក្រលេកមើលឱ្យល្អ ក្នុងអដ្ឋកថានោះ ហើយគប្បីបន្ទោបង់នូវសេចក្ដីសង្ស័យចេញ ។*

(តែចំពោះភណ្ឌុកម្ម ១ សូម្បីមិនបានប្រមូលសង្ឃ ក៏អាចធ្វើបានដែរ ព្រោះជាកម្មស្រាល ។ សូម្បីសាមណេរ ក៏ធ្វើបាន, សមដូចពាក្យដែលលោកពោលទុក **ក្នុងអដ្ឋកថា មហាខន្ធកៈថា** "សូម្បីនឹងពឹងពួកភិក្ខុកំលោះ ឬពួកសាមណេរ រៀវតែបព្វជ្ជាបេក្ខៈចេញ ឱ្យប្រាប់ដោយន័យជាដើមថា "**ឯកោ ភន្តេ បព្វជ្ជាបេក្ខោ អត្ថិ តស្ស ភណ្ឌុកម្មំ អាបុច្ឆាម** : បពិត្រលោកដ៏ចម្រើន មានបព្វជ្ជាបេក្ខៈមួយរូប ពួកយើងសូមប្រាប់នូវភណ្ឌុកម្ម របស់បព្វជ្ជាបេក្ខៈនោះ" ដូច្នេះ ក៏គួរ ។)

ក្នុងព្រះអដ្ឋកថាបរិវារៈ ពោលថា:

★ **យញ្ហិ ភិក្ខុសង្ឃោ សលាកគ្គយាគគ្គភត្តគ្គឧបោសថគ្គេសុ អបលោកនកម្មំ ករោតិ ឯតម្បិ កម្មលក្ខណមេវ** ។ ពិតមែនភិក្ខុសង្ឃធ្វើអបលោកនកម្មណា ក្នុងរោងស្លាក រោងយាគូ រោងភត្ត និងរោងឧបោសថ អបលោកនកម្មសូម្បីនោះ ជាកម្មលក្ខណៈពិត ។

ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:

★ **សលាកទានដ្ឋានំ សលាកគ្គំ នាម ។ យាគុភត្តានំ ភាជនដ្ឋានានិ យាគគ្គភត្តគ្គានិ នាម** ។

*ទីកន្លែងសម្រាប់ឱ្យទានឈ្មោះថា* ***រោងស្លាក*** *។ ទីកន្លែងសម្រាប់ចែកនូវយាគូ និងភត្តទាំងឡាយ ឈ្មោះថា* ***រោងយាគូ និងរោងភត្ត*** *។*

ឯតេសុបិ ហិ ឋានេសុ សព្វោ សង្ឃោ ឧបោសថេ វិយ សន្និបតិតោ, កម្មញ្ច វគ្គកម្មំ ន ហោតិ, "មយមេតំ ន ជានិម្ហា"តិ បច្ឆា ខិយ្យន្តាបិ ន ហោន្តិ ។ ខណ្ឌសីមាយ បន កាតេ ខិយ្យន្តិ ។ *ពិតមែនក្នុងទី (មានរោងស្លាកជាដើម)នោះ សង្ឃទាំងអស់ត្រូវប្រជុំគ្នា ដូចក្នុងឧបោសថ ចំណែកឯកម្ម មិនមែនជាកម្មជាពួកទេ, សូម្បីកាលតិះដៀលជាខាងក្រោយថា "យើងទាំងឡាយមិនដឹងនូវកម្មនោះទេ" ដូច្នេះ រមែងមិនមាន ។ តែកាលភិក្ខុធ្វើ (នូវអបលោកនកម្ម) នៅក្នុងខណ្ឌសីមា ភិក្ខុទាំងឡាយ រមែងតិះដៀល ។*

★ សង្ឃិកបច្ចយញ្ហិ អច្ឆិន្នចីវរាទីនំ ធាតុំ អបលោកេន្តេហិ ឧបចារសីមដ្ឋានំ សព្វេសំ អនុមតិំ គហេត្វាវ កាតព្វំ ។ យោ បន វិសភាគបុគ្គលោ ធម្មិកំ អបលោកនំ បដិពាហតិ, តំ ឧបាយេន ពហិឧបចារសីមាគតំ វា កត្វា ខណ្ឌសីមំ វា បវិសិត្វា កាតុំ វដ្ដតិ ។ *ពិតមែន*

បច្ច័យដែលជារបស់សង្ឃ គឺភិក្ខុត្រូវកាន់យកតាមអនុមតិរបស់សង្ឃទាំងអស់ ដែលឋិតនៅខាងក្នុងឧបចារសីមា ហើយគប្បីធ្វើដោយអបលោកនកម្ម ដើម្បីឱ្យនូវចីវរដល់ភិក្ខុទាំងឡាយដែលត្រូវចោរលួចយកចីវរទៅជាដើម ។ តែថា បើបុគ្គលដែលជាវិសភាគៈ (ភិក្ខុជាសត្រូវនឹងគ្នា) ណា ហាមឃាត់នូវអបលោកនកម្ម ដែលប្រកបដោយធម៌, ភិក្ខុធ្វើនូវបុគ្គលដែលជាវិសភាគៈគ្នានោះ ឱ្យចេញទៅខាងក្រៅសីមា ដោយឧបាយក្តី ឬថាត្រូវចូលទៅកាន់ក្នុងខណ្ឌសីមា (ដោយខ្លួនឯង) ហើយធ្វើរមែងគួរ ។

<u>ក្នុងព្រះអដ្ឋកថាបរិវារៈ ពោលថាៈ</u>

✯ អច្ឆិន្នចីវរជិណ្ណចីវរនដ្ឋចីវរានញ្ហិ សង្ឃំ សន្និបាតេត្វា ព្យត្តេន ភិក្ខុនា យាវតតិយំ សាវេត្វា អបលោកនកម្មំ កត្វា ចីវរំ ធាតុំ វដ្ដតិ ។ កាលភិក្ខុអ្នកឈ្លាសប្រតិពល ឱ្យប្រជុំសង្ឃហើយ សូត្រប្រកាសត្រឹម ៣ ដងធ្វើអបលោកនកម្ម ឱ្យចីវរដល់ភិក្ខុទាំងឡាយ ដែលមាន ចីវរត្រូវចោរដណ្តើមយកក្តី ដែលមានចីវរចាស់គ្រាំគ្រាក្តី ដែលមានចីវរវិនាសទៅក្តី រមែងគួរ ។

✯ តែរបស់បន្ទិចបន្តួច មានម្ជុលជាដើម មានប្រភេទ

ដូចពោលហើយ ក្នុងអដ្ឋកថា សេនាសនក្ខន្ធក: **គឺភិក្ខុអ្នកចែករបស់បន្ទិចបន្តួច** សូម្បីមិនត្រូវអបលោកន៍ ក៏អាចឱ្យដល់ភិក្ខុ**អ្នកធ្វើចីវរបាន** ។ ភិក្ខុអ្នកចែករបស់បន្តិចបន្តួចនោះប៉ុណ្ណោះ ជាធំក្នុងការឱ្យរបស់ បន្តិចបន្តួចទាំងនោះ ។ កាលនឹងឱ្យរបស់ដែលច្រើនជាងនោះ ត្រូវអបលោកន៍ហើយឱ្យ ។ ព្រោះថាសង្ឃជាម្ចាស់របស់ ក្នុងការឱ្យរបស់ដែលច្រើននោះ ។ សូម្បីគិលានភេសជ្ជៈ ដែលមានប្រការដូចពោលហើយ ក្នុងអដ្ឋកថាសេនាសនក្ខន្ធក:នោះ ដែលភិក្ខុអ្នកចែករបស់បន្តិចបន្តួច គប្បីឱ្យខ្លួនឯងក៏បាន ។ តែគប្បីអបលោកន៍ ឱ្យដល់ភិក្ខុអ្នកដែលត្រូវការច្រើន ។

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

★ យំ សន្ធាយ "អបលោកនកម្មំ ករោតី"តិ សាមញ្ញតោ ឥស្សេតិ, តំ អបលោកនកម្មំ សរូបតោ ឥស្សេតុមាហ "អច្ឆិន្នចីវរំ"តច្ចាតិ ។ យតិ អបលោកេត្វា ចីវរំ ទាតព្វំ, កឹ បន អប្បមត្តកវិស្សជ្ជកសម្មតិយាតិ អាហ "អប្បមត្តកវិស្សជ្ជនកេន បនា"តិអាទិ ។

ព្រះអដ្ឋកថាចារ្យ សម្តែងដោយសាមញ្ញថា "រមែងធ្វើនូវ

អបលោកនកម្ម” ដូច្នេះ ព្រោះសំដៅនូវអបលោកនកម្មណា ដើម្បីសម្ដែងនូវអបលោកនកម្មនោះ ទើបព្រះអដ្ឋកថាចារ្យពោល នូវពាក្យជាដើមថា “ចីវរដែលត្រូវចោរដណ្ដើម” ដូច្នេះ ។ ដើម្បី ដោះស្រាយនូវបញ្ហាដែលគេសួរថា ប្រសិនបើភិក្ខុត្រូវអបលោក ហើយសិនទើបឱ្យនូវចីវរ ចុះហេតុដូចម្ដេច ចាំបាច់ត្រូវសន្មត អប្បមត្តកវិស្សជ្ជកៈភិក្ខុទៀត? ព្រោះហេតុនោះ ទើបព្រះអដ្ឋកថា ចារ្យពោលពាក្យថា “អប្បមត្តកវិស្សជ្ជនកោន បនាតិ : តែ... គឺភិក្ខុអ្នកចែករបស់បន្តិចបន្តួច” ដូច្នេះជាដើម ។

## មិនត្រូវធ្វើអបលោកន៍ជាប់ដោយអំណាចសង្ឃទេ

<u>ក្នុងព្រះអដ្ឋកថា សេនាសនក្ខន្ធកៈ ពោលថាៈ</u>

★ យំ បនេត្ថ បិណ្ឌបាតត្ថាយ គិលានបច្ចយ-ត្ថាយ វា ឧទ្ទិស្ស ទិន្នំ តំ ចីវរេ ឧបនាមេន្តេហិ សង្ឃសុដ្ឋុតាយ អបលោកេត្វា ឧបនាមេតព្វំ ។ សេនា-សនត្ថាយ ឧទ្ទិស្ស ទិន្នំ គរុភណ្ឌំ ហោតិ ។

ចំណែកវត្ថុណាដែលទាយក ឱ្យក្នុងដៃនៃកប្បិយការកៈ ដើម្បីប្រយោជន៍ដល់បិណ្ឌបាត ឬដើម្បីប្រយោជន៍ដល់គិលាន-បច្ច័យ វត្ថុនោះកាលភិក្ខុទាំងឡាយ នឹងបង្អោនចូលទៅក្នុងចីវរ

គប្បីអបលោកន៍ ដើម្បីឃើញប្រពៃដល់សង្ឃ ហើយទើបចាំបង្អោនទៅ ។ វត្ថុដែលគេថ្វាយដើម្បីប្រយោជន៍ដល់សេនាសនៈ រមែងជា គរុភណ្ឌ ។ (គរុភណ្ឌទាំងអស់មាន ២៥ ដែលសម្តែងទុកក្នុងសេនាសនក្ខន្ធកៈ គឺភិក្ខុមិនគួរបង្អោនទៅដើម្បីប្រយោជន៍ដល់ចីវរ បិណ្ឌបាត និងភេសជ្ជៈទេ) ។

★ ចីវរវសេនេវ ចតុបច្ចយវសេន វា ទិន្នំ ចីវរឧបនាមេន្តានំ អបលោកនកម្មកិច្ចំ នត្ថិ, អបលោកនកម្មំ ករោន្តេហិ, ច **បុគ្គលវសេនេវ** កាតព្វំ **សង្ឃវសេន** ន កាតព្វំ ។ (ចំណែកវត្ថុ) ដែលគេថ្វាយទុកចំពោះតម្លៃចីវរ ឬជាតម្លៃបច្ច័យ ៤ កាលនឹងបង្អោនចូលទៅក្នុងចីវរ មិនមានកិច្ចត្រូវធ្វើដោយអបលោកនកម្ម ។ ក៏ភិក្ខុកាលធ្វើនូវអប្បលោកនកម្ម គួរធ្វើឱ្យជាប់ដោយបុគ្គលប៉ុណ្ណោះ មិនគួរធ្វើឱ្យជាប់ដោយអំណាចសង្ឃឡើយ ។

★ ជាតរូបរជតវសេនាបិ អាមកធញ្ញវសេន វា អបលោកនកម្មំ ន វដ្ដតិ ។ កប្បិយភណ្ឌវសេន ចីវរតណ្ឌុលាទិវសេនេវ ច វដ្ដតិ ។ ភិក្ខុមិនគួរធ្វើអបលោកនកម្មសូម្បីជាប់ដោយអំណាចមាស និងប្រាក់ ឬជាប់ដោយស្រូវ ។ (តែ) គួរធ្វើ (អបលោកនកម្ម) ជាប់ដោយអំណាចកប្បិយ-

*ភណ្ឌ និងដោយអំណាចចីវរ និងអង្ករជាដើមប៉ុណ្ណោះ ។*

**តំ បន ឯវំ កត្តព្វំ** : *ក៏ឯអបលោកនកម្មនោះ គឺភិក្ខុត្រូវធ្វើយ៉ាងនេះ ។*

★ ឥធានិ សុភិក្ខំ សុលភបិណ្ឌំ ភិក្ខូ ចីវរេន កិលមន្តិ ឯត្តកំ ឆាម តណ្ឌុលភាគំ ភិក្ខូនំ ចីវរំ កាតុំ រុច្ចតិ ។ *ឥឡូវនេះភិក្ខារកបានងាយ បិណ្ឌបាតរកបានងាយ ភិក្ខុទាំងឡាយ លំបាកដោយចីវរ ភិក្ខុទាំងឡាយពេញចិត្ត នឹងបង្អោនចំណែកអង្ករប៉ុណ្ណោះធ្វើចីវរ ។*

គិលានបច្ចយោ សុលភោ គិលានោ វា នត្ថិ ឯត្តកំ ឆាម តណ្ឌុលភាគំ ភិក្ខូនំ ចីវរំ កាតុំ រុច្ចតិ ។ *គិលានបច្ច័យរកបានងាយ, មួយទៀតភិក្ខុអ្នកអាពាធ ក៏មិនមាន, ភិក្ខុទាំងឡាយ ពេញចិត្តនឹងបង្អោនចំណែកអង្ករប៉ុណ្ណោះធ្វើជាចីវរ ។*

*<u>ក្នុងបាចិត្យាទិយោជនា ពោលថា:</u>*

★ **បុគ្គលវសេនេវាតិ** "ភិក្ខូ ចីវរេន កិលមន្តិ ឯត្តកំ ឆាម តុណ្ឌុលភាគំ ភិក្ខូនំ ចីវរំ កាតុំ រុច្ចតិ សង្ឃស្សា"តិអាទិនា បុគ្គលំ បរាមសិត្វា បុគ្គល-វសេនេវ ។ *ពាក្យថា ជាប់ដោយបុគ្គលប៉ុណ្ណោះ ដូច្នេះនេះ*

មានសេចក្ដីថា ភិក្ខុ (ធ្វើនូវអបលោកន៍) ជាប់ដោយអំណាចបុគ្គលពិត, ព្រោះប៉ះពាល់នូវបុគ្គល ដោយពាក្យជាដើមថា "ភិក្ខុទាំងឡាយលំបាកដោយចីវរ ការបង្អោននូវចំណែកអង្គរមានប្រមាណប៉ុណ្ណេះ ធ្វើជាចីវររបស់ភិក្ខុទាំងឡាយ គាប់ចិត្តដល់សង្ឃដែរឬ ?" ។

☆ **សង្ឃវសេនាតិ** "សង្ឃោ ចីវរេន កិលមតី"តិ-អាទិនា សង្ឃវសេន ន កាតព្វន្តិ ។ ឯវំ អបលោក-នកម្មស្ស អកត្តព្វតំ ទស្សេត្វា ឥទានិ វត្ថុវសេន តស្សេវ អកត្តព្វតំ ទស្សេន្តោ អាហ "ជាតរូបរជតវសេនាបី"តិ-អាទិ ។ ពាក្យថា *ដោយអំណាចសង្ឃ* ដូច្នេះ មានសេចក្ដីថា ភិក្ខុមិនត្រូវធ្វើ (អបលោកន៍) ជាប់ដោយអំណាចសង្ឃ ដោយពាក្យជាដើមថា "ព្រះសង្ឃលំបាកដោយចីវរ" ដូច្នេះ ។ ព្រះ-អដ្ឋកថាចារ្យ កាលសម្ដែងនូវអបលោកនកម្ម ដែលភិក្ខុមិនត្រូវធ្វើជាប់ដោយអំណាច(សង្ឃ) យ៉ាងនេះហើយ ឥឡូវនេះកាលសម្ដែងនូវអបលោកនកម្មនោះឯង ដែលភិក្ខុមិនត្រូវធ្វើដោយអំណាចវត្ថុ ទើបពោលពាក្យជាដើមថា "*សូម្បីជាប់ដោយអំណាចមាស និងប្រាក់*" ដូច្នេះ ។

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

★ **បុគ្គលវសេនាតិ** "ភិក្ខូ ចីវរេន ភិលមន្តី"តិ ឯវំ បុគ្គលបរាមាសវសេន, ន "សង្ឃោ ភិលមន្តី"តិ ឯវំ សង្ឃបរាមាសវសេន ។ ពាក្យថា **ជាប់ដោយអំណាចបុគ្គល** ដូច្នេះ មានសេចក្ដីថា ភិក្ខុ (ធ្វើនូវអបលោកន៍) ជាប់ដោយអំណាចការប៉ះពាល់នូវបុគ្គលយ៉ាងនេះថា "ភិក្ខុទាំងឡាយលំបាកដោយចីវរ" ដូច្នេះ ។ មិនត្រូវ(ធ្វើនូវអបលោកន៍) ជាប់ដោយអំណាចការប៉ះពាល់នូវសង្ឃយ៉ាងនេះថា "ព្រះសង្ឃលំបាកដោយចីវរ" ដូច្នេះទេ ។

★ បុគ្គលវសេនេវ កប្បិយភណ្ឌវសេន ច អបលោកនប្បការំ ទស្សេតុំ "**តំ បន ឯវំ កត្តព្វន្តិ**"អាទិ វុត្តំ ។ ព្រះអដ្ឋកថាចារ្យ ពោលហើយនូវពាក្យជាដើមថា "**ក៏ឯអបលោកនកម្មនោះ ត្រូវធ្វើយ៉ាងនេះ**" ដូច្នេះ ដើម្បីសម្ដែងនូវការធ្វើអបលោកនកម្ម ជាប់ដោយអំណាចបុគ្គលផង ដោយអំណាចកប្បិយភណ្ឌផង ។

## ការសន្មតភិក្ខុច្រើនអង្គ ក្នុងទីជាមួយគ្នាតែម្ដងក៏បាន

<u>ក្នុងព្រះអដ្ឋកថាសេនាសនក្ខន្ធក: ពោលទៀតថា:</u>

កាលកំណត់យ៉ាងនេះហើយ គប្បីសន្មតសេនាសនគ្គាហាបកភិក្ខុ ក្នុងកាលជាទីឱ្យកាន់យកសេនាសនៈ កាលសង្ឃបាន

*ប្រកាសប្រជុំគ្នាហើយ ។*

★ សម្មន្នន្តេន ច ទ្វេ សន្និតព្វាតិ **វុត្តំ** ។ ឯវញ្ហិ នវកោ វុឌ្ឍតរស្ស វុឌ្ឍោ ច នវកស្ស គាហេស្សតិ ។ មហន្តេ បន មហាវិហារសទិសេ វិហារេ តយោ ចត្តារោ ជនា សម្មន្និតព្វា ។ កុរុន្ទិយំ បន "អដ្ឋបិ សោឡសបិ ជនេ សម្មន្និតុំ វដ្ដតី"តិ វុត្តំ ។ តេសំ សម្មុតិ កម្មវាចាយបិ អបលោកនេនបិ វដ្ដតិយេវ ។

*<u>ក្នុងមហាអដ្ឋកថា ពោលថាៈ</u> "ក៏ឯកាលនឹងសន្មតគប្បីសន្មត ២ រូប ។ ព្រោះថា កាលសន្មតយ៉ាងនេះ ភិក្ខុខ្ចី នឹងឱ្យភិក្ខុចាស់កាន់សេនាសនៈ ចំណែកភិក្ខុចាស់ នឹងឱ្យភិក្ខុខ្ចីកាន់សេនាសនៈ ដូច្នេះឯង ។ ចំណែកក្នុងវត្តធំដូចក្នុងមហាវិហារ គួរសន្មតទុក ៣-៤ រូប ។ តែក្នុងកុរុន្ទីពោលថា* ***នឹងសន្មតទុក ៨ រូបខ្លះ ១៦ រូបខ្លះ ក៏គួរ*** *។ ការសន្មតភិក្ខុទាំងនោះ នឹងធ្វើដោយកម្មវាចាក៏បាន អបលោកនកម្មក៏បាន គួរទាំងអស់ ។*

**សេនាសនគ្គាហាបកៈភិក្ខុ កាន់យកសេនាសនៈ**
**ដោយខ្លួនឯងមិនគួរទេ**

*<u>ក្នុងវិមតិវិនោទនីដីកា ពោលថាៈ</u>*

★ **នវកោ វុឌ្ឍតរស្ស វុឌ្ឍោ ច នវកស្សាតិ** ឥទំ សេនាសនគ្គាហស្ស អត្តនោ អត្តនោ គហណំ អសារុប្បន្តិ វុត្តំ, ទេ្វ អញ្ញមញ្ញំ គាហេសន្តីតិ អធិប្បាយោ ។ *ពាក្យថា ភិក្ខុខ្ចីនឹងឱ្យភិក្ខុចាស់កាន់សេនាសនៈ ចំណែកភិក្ខុចាស់ នឹងឱ្យភិក្ខុខ្ចីកាន់សេនាសនៈ* ដូច្នេះនេះ មានសេចក្តីអធិប្បាយថា *ការកាន់យកសេនាសនៈ របស់ខ្លួននៃសេនាសនគ្គាហបកៈភិក្ខុដោយខ្លួនឯង គឺលោកអាចារ្យពោល ហើយថា មិនសមគួរទេ ។ ភិក្ខុទាំង ២ រូបនោះឯង ត្រូវញ៉ាំងគ្នានឹងគ្នាឱ្យកាន់យក(នូវសេនាសនៈទៅវិញទៅមក) ។*

★ **អដ្ឋបិ សោឡសបិ ជនេ សម្មន្និតុំ វដ្ដតីតិ** ឯកកម្មវាចាយ សព្វេបិ ឯកតោ សម្មន្និតុំ វដ្ដតិ ។ និគ្គហកម្មមេវ ហិ សង្ឃោ សង្ឃស្ស ន ករោតិ ។ តេនេវ សត្តសតិក្ខន្ធកេ ឧព្វាហិកកម្មសម្មុតិយំ អដ្ឋបិ ជនា ឯកតោវ សម្មតាតិ ។ *ពាក្យថា* **នឹងសន្មតទុក ៨ រូបខ្លះ ១៦ រូបខ្លះក៏គួរ** *ដូច្នេះនេះ មានសេចក្តីថា គួរដើម្បីសន្មតសូម្បីនូវភិក្ខុទាំងឡាយ ដោយកម្មវាចា ក្នុងទីជាមួយគ្នាបាន ។ ពិតមែន កម្មគឺការផ្ចាញ់ផ្ចាលប៉ុណ្ណោះ ដែលសង្ឃធ្វើកម្មដល់សង្ឃ* **មិនគួរ** *។ ព្រោះហេតុនោះឯង ទើបលោក*

ពោលក្នុងការសន្ទូតនូវឧញាហិកកម្ម ក្នុងសត្តសតិក្កខន្ធកៈថា ជនទាំងឡាយសូម្បីទាំង ៨ ត្រូវសន្ទូតក្នុងទីជាមួយគ្នាប៉ុណ្ណោះ ។

**សង្ឃជួយដោះបំណុលភិក្ខុអ្នកមានសីល ដោយអបលោកនកម្ម គួរ**

<u>*ក្នុងព្រះអដ្ឋកថាបរិវារៈ ពោលថា:*</u>

✯ បេសលស្ស ភិក្ខុនោ តត្រុប្បាទតោ ឥណបលិពោធម្បិ ពហុស្សុតស្ស សង្ឃភារនិត្ថារកស្ស ភិក្ខុនោ អនុដ្ឋាបនីយសេនាសនម្បិ សង្ឃកិច្ចំ ករោន្តានំ កប្បិយការកាទីនំ ភត្តវេតនម្បិ អបលោកនកម្មេន ទាតុំ វដ្ដតិ ។ *ដើម្បីដោះកង្វល់គឺបំណុល ដល់ភិក្ខុអ្នកមានសីលជាទីស្រឡាញ់ក្តី នឹងឱ្យសេនាសនៈដែលមិនត្រូវផ្លាស់ប្តូរ ដល់ភិក្ខុដែលជាពហុស្សូត ជួយភារៈរបស់សង្ឃក្តី និងឱ្យប្រាក់ថ្លៃឈ្នួលដល់អារាមិកជន មានកប្បិយការកៈជាដើម ដែលធ្វើកិច្ចការរបស់សង្ឃក្តី អំពីតម្លៃដែលកើតក្នុងអាវាសនោះ គួរឱ្យដោយអបលោកនកម្ម ។ ដើមឈើមានផ្លែទាំងឡាយណាសូម្បីដែលដាំទុកក្នុងវត្ត ជារបស់ដែលសង្ឃហួងហែង រមែងបានការទំនុកបំរុង ។ ភិក្ខុទាំងឡាយ រមែងវាយរគាំងហើយចែកគ្នាឆាន់នូវផ្លែទាំងឡាយ នៃដើមឈើទាំងឡាយណា ក្នុង*

ដើមឈើទាំងនោះ មិនគួរធ្វើអបលោកនកម្ម ។ ចំណែកដើមឈើមានផ្លែទាំងឡាយណា ដែលសង្ឃមិនហួងហែង ក្នុងដើមឈើទាំងនោះឯង គួរធ្វើអបលោកនកម្ម ។

★ តំ បន សលាកគ្គយាគគ្គភត្តគ្គអន្តរសន្និបាតេសុបិ កាតុំ វដ្តតិ ។ ឧបោសថគ្គេ បន វដ្តតិយេវ ។ តត្ថ ហិ អនាគតានម្បិ ឆន្ទបារិសុទ្ធិំ អាហរិយតិ តស្មា តំ សុវិសោធិតំ ហោតិ ។ ក៏អបលោកនកម្មនោះ គួរធ្វើសូម្បីក្នុងរោងស្លាក រោងយាគូរ រោងភត្ត និងទីប្រជុំដទៃ ម្យ៉ាងទៀតក្នុងរោងឧបោសថ ក៏គួរធ្វើពិត ។ ព្រោះថាឆន្ទៈ និងបារិសុទ្ធីរបស់ភិក្ខុទាំងឡាយ សូម្បីមិនបានមកក្នុងរោងឧបោសថ នោះ (គឺភិក្ខុមួយរូប)រមែងនាំមក ។ ព្រោះហេតុនោះ អបលោកនកម្មនោះ រមែងជាកម្មដែលត្រូវជម្រះឱ្យម៉ត់ចត់ល្អហើយ ។

ក៏ឯកាលនឹងធ្វើ គប្បីធ្វើយ៉ាងនេះ ៖ ភិក្ខុដែលឆ្លាតគប្បីសូធ្យប្រកាសដោយអនុមតិរបស់ភិក្ខុសង្ឃ ថា "បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំសួរសង្ឃថា វត្ថុណាជារបស់សង្ឃមានឫស សំបក ស្លឹក ពន្លក ផ្កា និងផ្លែ ដែលគួរទំពាឆាន់បានជាដើម មាននៅក្នុងសីមាវត្តនេះ, ការដែលភិក្ខុទាំងឡាយមកហើយៗ បរិភោគវត្ថុទាំងពួងនោះ តាមសប្បាយ

*គាប់ចិត្តដល់សង្ឃឬ?” គប្បីសួរ ៣ ដង ។*

*<u>ក្នុងព្រះអដ្ឋកថា ពោលទៀតថា:</u>*

★ ចតូហិ បញ្ចហិ ភិក្ខូហិ កតំ សុកតមេវ ។ យស្មឹ វិហារេ ទ្វេ តយោ ជនា វសន្តិ, តេហិ និសីទិត្វា កតម្បិ សង្ឃេន កតសទិសមេវ ។ យស្មឹ បន វិហារេ ឯកោ ភិក្ខុ ហោតិ, តេន ភិក្ខុនា ឧបោសថទិវសេ បុព្វករណបុព្វកិច្ចំ កត្វា និសន្នេន កតម្បិ កតិកាវត្តំ សង្ឃេន កតសទិសមេវ ហោតិ ។ *អបលោកន៍ដែលភិក្ខុ ៤-៥ រូប ធ្វើហើយ ជាការធ្វើល្អពិត ។ ក្នុងវត្តណាមានភិក្ខុ ២-៣ រូបអាស្រ័យនៅ, សូម្បីភិក្ខុនោះអង្គុយធ្វើហើយ ប្រាកដដូចជាសង្ឃធ្វើពិត ។ តែក្នុងវត្តណាមានតែភិក្ខុ ១ រូប, កតិកាវត្ត សូម្បីគឺភិក្ខុនោះអង្គុយធ្វើបុព្វកិច្ច និងបុព្វករណៈ ក្នុងថ្ងៃឧបោសថ ហើយធ្វើរមែងប្រាកដដូចជាសង្ឃធ្វើហើយពិត ។*

*<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពន្យល់ថា:</u>*

★ **ឧបោសថទិវសេតិ** និទស្សនមត្តំ, យស្មឹ កិស្មិញ្ចិ ទិវសេបិ កតំ សុកតមេវ ហោតិ ។ ករោន្តេន "យំ

ឥមស្មឹំ វិហារេ អន្តោសីមាយ សង្ឃសន្តកំ ។បេ ។ យថាសុខំ បរិភុញ្ជិតុំ មយ្ហំ រុច្ចតី"តិ ឯវំ កតិកា កាតព្វា, តថា ទ្វិហិ តីហិបិ "អាយស្មន្តានំ រុច្ចតី"តិ វចនមេវ ហេត្ថ វិសេសោ ។ *ពាក្យថា* ***ក្នុងថ្ងៃឧបោសថ*** *ដូច្នេះ ត្រឹមតែជានិទស្សនៈទេ, សូម្បីលោកធ្វើហើយ ក្នុងថ្ងៃណាមួយ ជាការធ្វើល្អហើយ ។ ភិក្ខុ១រូបកាលធ្វើកតិកា គប្បីធ្វើយ៉ាងនេះថា "វត្ថុណាដែលជារបស់សង្ឃមាននៅក្នុងខាងក្នុងវិហារនេះ ។ល ។ ឆាន់តាមសប្បាយ រមែងគាប់ចិត្តដល់យើងដែរឬ" ។ សូម្បីភិក្ខុ ២-៣ រូប ក៏ដូចគ្នាដែរ ប្លែកត្រឹមតែពាក្យថា "រមែងគាប់ចិត្ត ដល់លោកមានអាយុទាំងឡាយដែរឬ? ប៉ុណ្ណោះ" ។*

## បាលីអបលោកន៍ចង្ហាន់តាមន័យនៅក្នុងអដ្ឋកថាបរិវារៈ

## ភិក្ខុ ៤ ឬ ៥ រូប ធ្វើអបលោកនកម្ម

✯ សុណាតុ មេ ភន្តេ សង្ឃោ, យំ វត្ថុ ឥធ ឋានេ សង្ឃសន្តកំ (ខាទនិយភោជនិយាទីនិ) អត្ថិ, យថាសុខំ ភិក្ខូនំ អាគតាគតានំ បរិភុញ្ជិតុំ, រុច្ចតិ សង្ឃស្ស ។ ទុតិយម្បិ ភន្តេ សង្ឃំ បុច្ឆាមិ, យំ វត្ថុ ។បេ ។ រុច្ចតិ សង្ឃស្ស ។ តតិយម្បិ ភន្តេ សង្ឃំ បុច្ឆាមិ, យំ

វត្ថុ ។ បេ ។ វុច្ចតិ សង្ឃស្ស ។ បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំករុណាសូមសួរសង្ឃថា វត្ថុណាដែលជារបស់សង្ឃ មានខាទនីយៈនិងភោជនីយៈជាដើម មានក្នុងទីនេះ, កាលដែលភិក្ខុទាំងឡាយដែលមកហើយៗ ឆាន់តាមសប្បាយ គាប់ចិត្តដល់សង្ឃដែរឬ ? ត្រូវពោលអស់វារៈ ៣ ដង ។

**អធិប្បាយតាមន័យនៅក្នុងដីកាវិមតិវិនោទនី**

**ភិក្ខុ ១ រូប ធ្វើកតិកា**

"យំ ឥមស្មឹ វិហារេ អន្តោសីមាយ សង្ឃសន្តកំ មូលតចបត្តអង្កុរបុប្ផផលខាទនិយាទិ អត្ថិ, សព្វំ អាគតាគតានំ ភិក្ខូនំ យថាសុខំ បរិភុញ្ជិតុំ មយ្ហំ រុច្ចតី"តិ ។ វត្ថុណាជារបស់សង្ឃ មានឫស សំបក ស្លឹក ពន្លក ផ្កា និងផ្លែ ដែលគួរទំពាឆាន់បានជាដើម មាននៅក្នុងសីមាវត្តនេះ, ការដែលភិក្ខុទាំងឡាយមកហើយៗ បរិភោគវត្ថុទាំងពួងនោះតាមសប្បាយ គាប់ចិត្តដល់យើងដែរឬ ?

**ភិក្ខុ ២ ឬ ៣ រូប ធ្វើកតិកា**

"យំ ឥមស្មឹ វិហារេ អន្តោសីមាយ សង្ឃសន្តកំ មូលតចបត្តអង្កុរបុប្ផផលខាទនិយាទិ អត្ថិ, សព្វំ អាគតា-

គតានំ ភិក្ខូនំ យថាសុខំ បរិភុញ្ជិតុំ អាយស្មន្តានំ រុច្ចតី"តិ ។ វត្ថុណាជារបស់សង្ឃ មានឫស សំបក ស្លឹក ពន្លក ផ្កា និងផ្លែ ដែលគួរទំពាឆាន់បានជាដើម មាននៅក្នុងសីមាវត្តនេះ, ការដែលភិក្ខុទាំងឡាយមកហើយៗ បរិភោគវត្ថុទាំងពួងនោះ តាមសប្បាយ គាប់ចិត្តដល់លោកដ៏មានអាយុទាំងឡាយដែរឬ ?

## បាលីអបលោកចង្ហាន់មួយបែបទៀត

(ភិក្ខុជាអ្នកឈ្លាសប្រតិពល គប្បីសូត្រប្រកាសតាមអនុមតិរបស់សង្ឃថា :

★ សង្ឃំ ភន្តេ បុច្ឆាមិ ឥទានិ បិណ្ឌបាតោ សបរិក្ខារោ សង្ឃស្ស ឧប្បន្នោ, អាគតាគតានំ ភិក្ខូនំ យថាសុខំ បរិភុញ្ជិតុំ រុច្ចតិ សង្ឃស្សាតិ ។ ទុតិយម្បិ ភន្តេ សង្ឃំ បុច្ឆាមិ ។បេ ។ រុច្ចតិ សង្ឃស្សាតិ ។ តតិយម្បិ ភន្តេ សង្ឃំ បុច្ឆាមិ ។បេ ។ រុច្ចតិ សង្ឃស្សាតិ ។

បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំសូមសួរសង្ឃថា "ឥឡូវនេះ បិណ្ឌបាតព្រមទាំងគ្រឿងបរិក្ខារ កើតឡើងដល់សង្ឃ កាលភិក្ខុទាំងឡាយដែលមកហើយៗ ឆាន់តាមសប្បាយ គាប់ចិត្តដល់សង្ឃឬទេ? ។ ត្រូវពោលអស់វារៈ ៣ ដង ។

ពាក្យនេះ គឺលោកអ្នកបេះបាលី តែងមកតាមន័យព្រះអដ្ឋកថា ។)

## ក្នុងវិនយបិដក ភាគ ១៣ ទំព័រ ៤១៨ ពោលថា

កម្ម ៤ យ៉ាង វិបត្តិដោយអាការ ៥ យ៉ាងគឺ ដោយវត្ថុ ដោយញត្តិ ដោយអនុស្សាវនា ដោយសីមា និងដោយបរិស័ទ ។

## អបលោកនកម្ម វិបត្តិដោយអាការ ៣ យ៉ាង

១-វត្ថុតោ ដោយវត្ថុ គឺកម្មគួរធ្វើចំពោះមុខ បែរទៅធ្វើកំបាំងមុខជាដើម ។

២-សីមតោ ដោយសីមា គឺបានដល់ សីមាវិបត្តិ ១១ ប្រការ ។

៣-បរិសតោ ដោយបរិស័ទ គឺភិក្ខុនៅក្នុងសីមាជាមួយគ្នា មិនចូលមកកាន់ហត្ថបាស និងមិនបានឱ្យឆន្ទៈជាដើម ។

## ភិក្ខុធ្វើការចែកសប្បិរបស់សង្ឃឱ្យទៅជាបុគ្គល

<u>ក្នុងអដ្ឋកថាសេនាសនក្ខន្ធកៈ ពោលថា</u>

★ បើមានទាយកគេថ្វាយសប្បិជាដើមដល់សង្ឃ ត្រូវបែកគ្នាថា ឥធំ មហាថេរស្ស ទាបុណាតិ, អវសេសំ អម្ហាកំ ទាបុណាតិ, វត្តតិ ។ "សប្បិនេះ រមែងដល់ព្រះមហាថេរៈ សប្បិដែលនៅសល់ រមែងដល់ពួកយើង" ដូច្នេះ រមែងគួរ ។

**ភិក្ខុធ្វើការចែកចីវរ**

<u>ក្នុងអដ្ឋកថាចីវរក្ខន្ធកៈ ពោលថា</u>

★ បើមានទាយកគេថ្វាយចីវរដល់សង្ឃថា "ឧស វត្ថានិ សង្ឃស្ស ទេមា"តិ "សំពត់ទាំងឡាយ ១០ ផ្ទាំងនេះ យើងទាំងឡាយសូមថ្វាយដល់សង្ឃ" ដូច្នេះ ត្រូវលើក១ ចំណែកហើយឱ្យដល់ព្រះសង្ឃត្ថេរៈថា ឥធំ តុម្ហាកំ ទាបុណាតិ សេសានិ អម្ហាកំ ទាបុណន្តិ ។ "ចីវរនេះ ដល់លោកម្ចាស់, ចីវរដែលនៅសល់ ដល់យើងទាំងឡាយ" ដូច្នេះ គួរកាន់យកបាន ។

**ភិក្ខុធ្វើការអធិដ្ឋានចីវរជារបស់សង្ឃឱ្យទៅជាបុគ្គល**

★ បើមានទាយកគេថ្វាយចីវរដល់សង្ឃ ត្រូវអធិដ្ឋានថា: "មយ្ហិមានិ ចីវរានិ ទាបុណន្តិ ៖ ចីវរទាំងឡាយនេះ រមែងសម្រេចដល់អាត្មាអញ ។

*ឬធ្វើទុកក្នុងចិត្តថា: "អញ្ញោ កោចិ ឥធ នត្ថិ, មយ្ហំ (ឥមានិ ចីវរានិ) បាបុណន្តិ" ក្នុងទីនេះមិនមានអ្នកណាមួយទេ, ចីវរទាំងឡាយនេះ សម្រេចដល់អាត្មាអញ" ។*

**ភិក្ខុមានតែ១ រូបអាចអធិដ្ឋានចីវររបស់សង្ឃ ក្នុងចន្លោះស្រុកបាន**

<u>*ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:*</u>

★ **មតកចីវរំ អធិដ្ឋាតីតិ** ឯត្ថ មគ្គំ គច្ឆន្តោ តស្ស កាលកិរិយំ សុត្វា អវិហារដ្ឋានេ ចេ ទ្វាទសហត្ថព្ភន្តរេ អញ្ញេសំ ភិក្ខូនំ អភាវំ ញត្វា "ឥទំ ចីវរំ មយ្ហំ បាបុណាតីតិ" អធិដ្ឋាតិ ស្វាធិដ្ឋិតំ ។

*ក្នុងពាក្យថា **អធិដ្ឋាននូវចីវររបស់ភិក្ខុដែលស្លាប់** ដូច្នេះ មានសេចក្តីថា កាលភិក្ខុដើរទៅតាមផ្លូវ បានឮនូវការធ្វើកាលកិរិយារបស់ភិក្ខុនោះ, ប្រសិនបើក្នុងទីដែលមិនមែនជាវត្ត គប្បីអធិដ្ឋានថា "**ចីវរនេះ រមែងដល់យើង**" ដូច្នេះ ជាការអធិដ្ឋានដ៏ល្អ ព្រោះលោកដឹងនូវភាវៈនៃភិក្ខុទាំងឡាយដទៃ **មិនមានទៅក្នុងរវាង ១២ ហត្ថ** ។*

*(សេចក្តីនេះ លោកពន្យល់ត្រង់ចីវររបស់ដែលភិក្ខុស្លាប់*

ទៅហើយ ចីវរនោះក្លាយទៅជារបស់សង្ឃ) ។

**អបលោកនកម្មកថាចប់ ។**

# ៣០~អលជ្ជិបុគ្គលកថា

<u>*ក្នុងវិនយបិដកភាគ ១៣ ទំព័រ១៦ ព្រះអង្គត្រាស់ថា:*</u>

★ *ភិក្ខុមិនត្រូវនៅអាស្រ័យនឹងបុគ្គលពីរពួកគឺ:*

១-អលជ្ជិស្ស *បុគ្គលដែលជាអលជ្ជី*

២-ពាលស្ស *បុគ្គលដែលជាមនុស្សល្ងង់ ។*

★ *ភិក្ខុមិនត្រូវឱ្យនិស្ស័យដល់បុគ្គលពីរពួកគឺ*

១-អលជ្ជិស្ស *បុគ្គលដែលជាអលជ្ជីតែមិនបានសូម*

២-លជ្ជិស្ស *បុគ្គលដែលជាលជ្ជីតែមិនបានសូម ។*

★ *ភិក្ខុត្រូវឱ្យនិស្ស័យដល់បុគ្គលពីរពួកគឺ:*

១-ពាលស្ស *បុគ្គលដែលជាមនុស្សល្ងង់ដែលបានសូម*

២-លជ្ជិស្ស *បុគ្គលដែលជាលជ្ជីដែលបានសូម ។*

<u>*ក្នុងគម្ពីរអដ្ឋកថា ពោលថា:*</u>

★ អលជ្ជិស្ស ច ពាលស្ស ចាតិ អលជ្ជី សចេបិ តេបិដកោ ហោតិ, ពាលោ ច សចេបិ សដ្ឋិវស្សោ ហោតិ, ឧភោបិ និស្សាយ ន វត្តព្វំ ។

*ពាក្យថា បុគ្គលដែលជាអលជ្ជី ១, បុគ្គលដែលជាមនុស្ស*

ល្ងង់១ ដូច្នេះនេះ មានសេចក្តីថា ភិក្ខុដែលជាអលជ្ជីសូម្បីថា ជាអ្នកទ្រទ្រង់ព្រះត្រៃបិដក (ដោយការធ្វើឱ្យស្ទាត់ជំនាញ) ចំណែកឯបុគ្គលល្ងង់សូម្បីថា ជាបុគ្គលមានវស្សា៦០, បុគ្គលសូម្បីទាំងពីររូបនេះ គឺភិក្ខុដទៃមិនគប្បីនៅអាស្រ័យជាមួយឡើយ(គឺមិនត្រូវយកលោកធ្វើជានិស្សយាចារ្យ ឬជាឧបជ្ឈាយ៍ឡើយ) ។

★ ពាលស្ស ច លជ្ជិស្ស ចាតិ ឯត្ថ ពាលស្ស "ត្វំ និស្សយំ គណ្ហា"តិ អាណាយបិ និស្សយោ ទាតព្វោ លជ្ជិស្ស បន យាចន្តស្សេវ ។ ក្នុងពាក្យថា បុគ្គលដែលជាមនុស្សល្ងង់១ បុគ្គលដែលជាលជ្ជី១ ដូច្នេះនេះ មានសេចក្តីថា និស្ស័យគឺភិក្ខុអ្នកឱ្យនូវនិស្ស័យ គប្បីឱ្យសូម្បីដោយការបង្គាប់ដល់ភិក្ខុល្ងង់ (ដែលជាលជ្ជីប៉ុណ្ណោះ ដែលមិនដឹងនូវវិធីកាន់យកនូវនិស្ស័យ)ថា"លោកចូរកាន់យកនូវនិស្ស័យ" ដូច្នេះ តែគប្បីឱ្យនូវនិស្ស័យដល់ភិក្ខុដែលជាលជ្ជីកាលមកសូមប៉ុណ្ណោះ,

## ក្នុងវិនយបិដក មហាខន្ធកៈ ព្រះអង្គត្រាស់ថាៈ

★ ន ភិក្ខវេ អលជ្ជីនំ និស្សយោ ទាតព្វោ ។ យោ ទទេយ្យ អាបត្តិ ទុក្កដស្ស ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវឱ្យនិស្ស័យដល់ភិក្ខុអលជ្ជីទេ ភិក្ខុណាឱ្យត្រូវអាបត្តិទុក្កដ ។

## អលជ្ជីដោយហេតុ ៣ យ៉ាង

<u>*ក្នុងវិនយបិដកភាគ១៣ ទំព័រ១៧៣ និងកង្ខាវិតរណីសម្តែងថា*</u>

សញ្ចិច្ច អាបត្តឹ អាបជ្ជតិ អាបត្តឹ បរិគូហតិ

អគតិគមនញ្ច គច្ឆតិ ឯទិសោ វុច្ចតិ អលជ្ជិបុគ្គលោ ។

*បុគ្គលក្លែងត្រូវអាបត្តិ ១ ក្លែងបិទបាំងអាបត្តិ ១ ក្លែងលុះតាមអំណាចអគតិ ១ បុគ្គលយ៉ាងនេះ ព្រះមានព្រះភាគត្រាស់ហៅថា* ***អលជ្ជី*** *។*

★ *តែអាចារ្យពួកខ្លះ ប្រែថា បុគ្គលមានចិត្តក្លែងត្រូវអាបត្តិ រួចបិទបាំងអាបត្តិទុកក្តី លុះតាមអំណាចអគតិក្តី បុគ្គលយ៉ាងនេះ ព្រះមានព្រះភាគត្រាស់ហៅថា* ***អលជ្ជី*** *។ តាមការប្រែនេះ បានសេចក្តីថា ភិក្ខុក្លែងត្រូវអាបត្តិហើយ មិនទាន់ឈ្មោះថា ជាអលជ្ជីទេ, ទាល់តែបិទបាំងទៀត ទើបឈ្មោះថាជាអលជ្ជី, ការប្រែយ៉ាងនោះ មិនសមគួរទេ ។ ព្រោះខុសសេចក្តីពន្យល់ នៅក្នុងគម្ពីរយោជនា ។*

<u>*ក្នុងគម្ពីរបាចិត្យាទិយោជនា ពន្យល់ថាៈ*</u>

★ **សញ្ចិច្ចាតិ** បទំ តីសុ វាក្យេសុ យោជេតព្វំ ។ សញ្ចិច្ច អាបត្តឹ អាបជ្ជតិ, សញ្ចិច្ច អាបត្តឹ បរិគូហតិ

សញ្ចិច្ច អគតិគមនញ្ច គច្ឆតីតិ អត្ថោ ។

ពាក្យថា **សញ្ចិច្ច** (ក្លែង) គប្បីប្រកបចូលក្នុងវាក្យទាំង ៣ ។ មានសេចក្តីអធិប្បាយថា ភិក្ខុក្លែងត្រូវអាបត្តិ ១, ក្លែងបិទបាំងអាបត្តិ ១, ក្លែងលុះតាមអំណាចអគតិ ១ ។

ក្នុងគម្ពីរកង្ខាវិតរណីបុរាណដីកា ពោលថា:

★ **សញ្ចិច្ច អាបត្តឹ អាបជ្ជតីតិ** ឯត្ថ អនាទរិយវសេន អាបជ្ជន្តោ ឯវ អលជ្ជី ហោតិ ឥតរោតិ ។

ក្នុងពាក្យថា **ភិក្ខុក្លែងត្រូវអាបត្តិ** សេចក្តីថា ភិក្ខុកាលត្រូវ (អាបត្តិ) ដោយអំណាច នៃការមិនអើពើប៉ុណ្ណោះ ឈ្មោះថាជាអលជ្ជី មិនមែនជាយ៉ាងដទៃទេ ។

ក្នុងគម្ពីរកង្ខាវិតរណីអភិនវដីកា ពោលថា:

★ **សញ្ចិច្ចាតិ** សញ្ចេតេត្វា អកប្បិយភាវំ ជានន្តោយេវ វីតិក្កមចិត្តំ បេសេត្វា អត្ថោ ។ ពាក្យថា ក្លែង ដូច្នេះ គឺបានដល់ការបំពាន, អធិប្បាយថា ភិក្ខុដឹងច្បាស់ថា វត្ថុនោះមិនគួរពិតប្រាកដ នៅតែបញ្ជូនចិត្តឱ្យប្រព្រឹត្តកន្លង ។

★ **បរិគូហតីតិ** និគូហតិ ន ទេសេតិ ន វុដ្ឋាតិ ។ លជ្ជាយ បរិគូហន្តោ អលជ្ជី ន ហោតិ, "កឹ ឥមិនា"តិ

អនាទរិយេន បរិគូហន្តោ ហោតីតិ ធស្សេតិ ។

ពាក្យថា **បិទបាំង** គឺបិទបាំង, មិនសម្តែង មិនចេញចាក ។ លោកអាចារ្យសម្តែងថា ភិក្ខុកាលបិទបាំងដោយសេចក្តីអៀន-ខ្មាស់ មិនជាអលជ្ជីទេ, តែបិទបាំងដោយសេចក្តីមិនអើពើ ថា "ប្រយោជន៍អ្វីដោយការសម្តែង ឬចេញចាកអាបត្តិនេះ" ទើបឈ្មោះថា ជាបុគ្គលអលជ្ជី ។

⋆ **អគតិគមនញ្ច គច្ឆតីតិ** ភណ្ឌភាជនីយដ្ឋានាទីសុ ឆន្ទាគតិអាទិភេទំ អគតិគមនញ្ច គច្ឆតិ ។

ពាក្យថា **ដល់នូវការលុះអគតិ** ដូច្នេះ សេចក្តីថា គឺដល់នូវការលុះអគតិ ផ្សេងដោយអគតិ មានឆន្ទាគតិជាដើម ក្នុងទីកន្លែងដែលគប្បីចែកនូវភណ្ឌៈជាដើម ។

⋆ **អលជ្ជីបុគ្គលោតិ** អជ្ឈត្តិកសមុដ្ឋានលជ្ជាវិរហិតោ បុគ្គលោ ។ បុគ្គលដែលប្រាសចាកភាពជាលជ្ជី ដែលតាំងនៅខាងក្នុងសន្តាន ឈ្មោះថា អលជ្ជីបុគ្គល ។

<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:</u>

ចាឡីយំ សញ្ចិច្ច អាបត្តិន្តិអាទិ អលជ្ជិលជ្ជិលក្ខណំ ភិក្ខុភិក្ខុនីនំ វសេន វុត្តំ, តេសញ្ញេវ សព្វប្បការតោ

សិក្ខាបទាធិការត្ថា ។ សាមណេរាធីនម្បិ សាធារណាវសេន បន សព្ពិច្ច យថាសកំ សិក្ខាបទវីតិក្កមនាធិកំ អលជ្ជិ-លជ្ជិលក្ខណំ វេទិតព្វំ ។ លក្ខណៈនៃអលជ្ជី និងលជ្ជី គឺទ្រង់សម្តែងហើយក្នុងព្រះបាលី មានពាក្យថា "ក្លែងត្រូវអាបត្តិ" ជួច្នេះជាដើម ដោយអំណាចនៃភិក្ខុនិងភិក្ខុនី, ព្រោះភិក្ខុ និងភិក្ខុនីទាំងនោះឯង ត្រូវធ្វើឱ្យក្រៃលែងក្នុងសិក្ខាបទដោយ ប្រការទាំងពួង ។ តែអ្នកសិក្សាគប្បីជ្រាបថា លក្ខណៈនៃអលជ្ជី និងលជ្ជី មានកិរិយាក្លែងប្រព្រឹត្តកន្លងសិក្ខាបទជាដើម តាមសមគួរដល់សិក្ខាបទរបស់ខ្លួន ដោយអំណាចជាសាធារណៈ ដល់សហ-ធម្មិកៈ ៣ ពួកក្រៅនេះ មានសាមណេរជាដើមផងដែរ ។

## ការធ្វើកម្មជាមួយអលជ្ជី តែមិនត្រូវទោស

ក្នុងវិនយបិដកភាគ ១៣ ទំព័រ ២៦៤ ព្រះអង្គត្រាស់ថាៈ

⋆ ម្នាលឧបាលិ បើសង្ឃធ្វើកម្មទាំងឡាយដែលសង្ឃគប្បីធ្វើដោយសេចក្តីព្រមព្រៀងគ្នា, ម្នាលឧបាលិ បើមានភិក្ខុមិនគាប់ចិត្តនឹងកម្មនោះ ភិក្ខុនោះត្រូវធ្វើនូវទិដ្ឋិឱ្យច្បាស់ប្រាកដសិនសឹមតម្កល់នូវសាមគ្គី ។ សេចក្តីនោះតើព្រោះហេតុអ្វី ។ ព្រោះថា ភិក្ខុនោះ ត្រូវតម្កល់សាមគ្គីដោយគិតថា "អាត្មាអញ

មិនត្រូវមានខ្លួនបែកចេញអំពីសង្ឃទេ” ។

<u>ក្នុងព្រះអដ្ឋកថាបរិវារៈ ពោលថា:</u>

☆ **តត្រ ចេតិ** សចេ តាទិសេ កម្មេ ភិក្ខុនោ ឧក្ខមតិ **ធិដ្ឋាវិកម្មម្បិ កត្វា** តថារូបា សាមគ្គី ឧបេតព្វា, ឯវំ វិលោមគ្គាហោ ន គណ្ហិតព្វោ ។ យត្រ ចេ បន ឧទ្ធម្មំ ឧព្វិនិយំ សត្ថុ សាសនំ ទីបេន្តិ, តត្ថ ធិដ្ឋាវិកម្មំ ន វដ្ដតិ បដិពាហិត្វា បក្កមិតព្វំ ។

ពាក្យថា បើក្នុងកម្មនោះ ដូច្នេះនេះ មានសេចក្ដីថា ប្រសិនបើក្នុងកម្មបែបនោះ មិនពេញចិត្តដល់ភិក្ខុនោះសោត គប្បីធ្វើនូវទិដ្ឋិឱ្យច្បាស់ហើយសិន សឹមតម្កល់ នូវសេចក្ដីព្រមព្រៀងបែបនោះទុក ។ សេចក្ដីប្រកាន់ខុសយ៉ាងនោះ គឺភិក្ខុមិនគួរកាន់យក ។ ក៏ក្នុងកម្មណា ភិក្ខុសម្ដែងព្រះសាសនា ខុសចាកធម៌ ចាកវិន័យ ក្នុងកម្មនោះ សូម្បីភិក្ខុធ្វើនូវទិដ្ឋិឱ្យច្បាស់ហើយក៏មិនគួរ ។ ព្រោះដូច្នោះ លោកគប្បីហាមហើយជៀសចេញទៅ ។

*<u>ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថាៈ</u>*

★ **ធិដ្ឋាវិកម្មម្បិ កត្វាតិ** "ន មេ តំ ខមតី"តិ សភាគស្ស ភិក្ខុនោ អត្តនោ ធិដ្ឋឹ អាវិកត្វា ។

*ពាក្យថា **គប្បីធ្វើនូវទិដ្ឋិឱ្យច្បាស់** ដូច្នេះនេះ មានសេចក្ដីថា ភិក្ខុត្រូវបើកនូវទិដ្ឋិរបស់ខ្លួន ចំពោះភិក្ខុដែលជាសភាគៈគ្នា ថា "កម្មនោះ មិនគាប់ចិត្តដល់ខ្ញុំករុណាទេ" ។*

★ **ឧបេតព្វាតិ** សាសនហានិយា អភាវា សាមគ្គី អកោបេត្វា កាយសាមគ្គី ទាតព្វា, ឦទិសេ ឋានេ អលជ្ជិបរិភោគោ អាបត្តិករោ ន ហោតិ, វដ្ដតិយេវ ។ យេ បន សាសនវិនាសាយ បដិបន្នា, តេហិ សហ ន វត្តតិ, អាបត្តិឯវ ហោតិ សាសនវិនាសោ ច ។ តេនាហ "យត្រ បន ឧទ្ធម្ម"ន្តិអាទិ ។ *ពាក្យថា **គប្បីតម្កល់** ដូច្នេះ នេះមានសេចក្ដីថា មិនគប្បីញ៉ាំងកាយសាមគ្គីឱ្យកម្រើក ហើយ ឱ្យនូវកាយសាមគ្គី, ព្រោះមិនមានការវិនាសទៅនៃព្រះសាសនា ការធ្វើនូវការបរិភោគ រួមជាមួយអលជ្ជី ក្នុងឋានមានសភាព ដូច្នេះ មិនមានអាបត្តិទេ, រមែងគួរពិត ។ តែបុគ្គលណាធ្វើកម្ម ដើម្បីញ៉ាំងព្រះសាសនាឱ្យវិនាស (ដូចភិក្ខុវជ្ជីបុត្រ) មិនត្រូវ*

ប្រព្រឹត្តជាមួយនឹងបុគ្គលនោះទេ, កាលប្រព្រឹត្តជាអាបត្តិពិត និង ជាការធ្វើសាសនាឱ្យវិនាសផង ។ ព្រោះហេតុនោះ ព្រះអដ្ឋកថា-ចារ្យ ទើបពោលពាក្យជាដើមថា "ក៏ក្នុងកម្មណា ភិក្ខុសម្តែងព្រះសាសនាខុសចាកធម៌ ចាកវិន័យ" ដូច្នេះ ។

## ប្រើបុគ្គលជាអលជ្ជីឱ្យធ្វើហត្ថកម្មឱ្យមិនគួរ

ក្នុងគម្ពីរអដ្ឋកថា កុដិការសិក្ខាបទ ពោលថា:

★ ភិក្ខុទាំងឡាយដែលធ្វើភត្តកិច្ចឯបន្ទប់ឆាន់ ឬសេនាសនៈ ក្នុងព្រៃក្តី ស្លឹកឈើ ឬផ្លែឈើ ដែលគួរស៊ីជាមួយនឹងឧត្តរិភង្គយ៉ាងណាមួយ ដែលមិនមានអ្នកហួងហែង កើតក្នុងទីនោះ, បើពួកលោកនឹងឱ្យអ្នកធ្វើការងារយ៉ាងណាមួយនាំមក, គួរនឹងឱ្យនាំមក ដោយអំណាច នៃហត្ថកម្មហើយឆាន់, តែមិនគួរប្រើពួកភិក្ខុ ឬសាមណេរដែលជាអលជ្ជីឱ្យធ្វើហត្ថកម្មទេ ។

ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:

★ "អលជ្ជីហិ បន ភិក្ខូហិ វា សាមណេរេហិ វា ហត្ថកម្មំ ន ការេតព្វ"ន្តិ សាមញ្ញតោ វុត្តត្តា អត្តនោ អត្ថាយ យំកិញ្ចិ ហត្ថកម្មំ ការេតុំ ន វដ្ដតិ ។ យំ បន

អលជ្ជី និវារិយមានោបិ ពីជនាទី ករោតិ, តត្ថ ទោសោ នត្ថិ ។ ចេតិយកម្មាទីនិ បន តេហិ ការាបេតុំ វដ្ដតិ ។ ការប្រើនូវភិក្ខុ ឬសាមណេរអលជ្ជី ឱ្យធ្វើហត្ថកម្មយ៉ាងណាមួយ ដើម្បីប្រយោជន៍ដល់ខ្លួន រមែងមិនគួរ, ព្រោះលោកពោលដោយពាក្យសាមញ្ញថា "មិនគប្បីប្រើពួកភិក្ខុ ឬសាមណេរ ដែលជាអលជ្ជី ឱ្យធ្វើនូវហត្ថកម្ម" ដូច្នេះ ។ តែភិក្ខុឬសាមណេរ អលជ្ជីឯណា សូម្បីខ្លួនហាមហើយ ក៏នៅតែធ្វើកិច្ចមានការបក់ផ្លិតជាដើម, ទោស នៅក្នុងកិច្ចនោះមិនមានទេ ។ តែកម្មទាំងឡាយមានចេតិយកម្មជាដើម គួរដើម្បីប្រើភិក្ខុ ឬសាមណេរអលជ្ជីនោះបាន ។

<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:</u>

★ **អលជ្ជីហិ... ន ការេតព្វន្តិ** ឥទំ ឧត្តរិភង្គាធិការត្តា អជ្ឈោហរណីយំ សន្ធាយ វុត្តំ ។ ពាហិរបរិភោគេសុ បន អលជ្ជីហិបិ ហត្ថកម្មំ ការេតុំ វដ្ដតីតិ ។

ពាក្យថា "មិនគប្បីប្រើពួកភិក្ខុឬសាមណេរ ដែលជាអលជ្ជី ឱ្យធ្វើនូវហត្ថកម្ម" ដូច្នេះ ពាក្យនេះលោកពោលសំដៅយកនូវវត្ថុដែលគប្បីលេបចូលទៅ ព្រោះលោកអាចារ្យ ធ្វើឱ្យក្រៃលែង

ថា សមូឧគ្គតិភង្គ ។ តែប្រើពួកអលជ្ជីឱ្យធ្វើហត្ថកម្ម ក្នុងវត្ថុសម្រាប់បរិភោគខាងក្រៅ រមែងគួរ ។

## ពាក្យថាទ្រុស្តសីលនិងពាក្យថាអលជ្ជី របស់ភិក្ខុនិងសាមណេរ

ក្នុងគម្ពីរបរមត្ថទីបនីដីកា សម្តែងថា :

★ តត្ថ សីលំ ណាម ភិក្ខុសីលំ ភិក្ខុនិសីលំ សាមណេរសីលំ គហដ្ឋសីលន្តិ ចតុព្វិធំ ហោតិ ។ តត្ថ បុរិមានំ ទ្វិន្នំ សមាទានកិច្ចំ កម្មវាចាយ សិទ្ធំ ហោតិ ។ ដែលឈ្មោះថា សីលមាន ៤ ប្រការ គឺ សីលរបស់ភិក្ខុ ១ សីលរបស់ភិក្ខុនី ១ សីលរបស់សាមណេរ ១ សីលរបស់គ្រហស្ថ ១ ។ បណ្តាសីលទាំង ៤ នោះ, សីល ២ ខាងដើម កិច្ចនៃការសមាទាន រមែងសម្រេចដោយកម្មវាចា ។

★ អន្តិមវត្ថុអជ្ឈាបន្នេន វា សិក្ខាបច្ចក្ខានេន វា កម្មវាចាយ ភិន្នាយ សព្វំ សមាទានំ ភិន្នំ ហោតិ ។ សព្វានិ ឧបសម្បន្នសីលានិ ភិន្នានិ ហោន្តិ ។ ការសមាទានទាំងពួងរមែងបែកធ្លាយ ព្រោះការបែកធ្លាយនៃកម្មវាចា ដោយការត្រូវនូវអន្តិមវត្ថុ ឬដោយការពោលលាសិក្ខា ។ សីលរបស់ឧបសម្បន្នទាំងអស់ ឈ្មោះថា ជាការបែកធ្លាយដែរ ។

★ តទា ភិក្ខុបដិញ្ញំ អវិជហិត្វា ឋិតោ **ទុស្សីលោ នាម ហោតិ** ។ ឋបេត្វា បន អន្តិមវត្ថុំ អញ្ញសិក្ខាបទានិ វីតិក្កមន្តស្ស យំ វីតិក្កមតិ ។ តស្មិំយេវ សំវរភេទោ ហោតិ ។ ន សមាទានភេទោ ។ *ក្នុងគ្រានោះ កាលមិនលះបង់ការប្តេជ្ញាថាជាភិក្ខុហើយនៅ (គឺនៅតែប្តេជ្ញាថាជាភិក្ខុដដែល) ឈ្មោះថា **ជាភិក្ខុទ្រុស្តសីល** ។ តែបើវៀរចាកនូវអន្តិមវត្ថុចេញ កាលភិក្ខុប្រព្រឹត្តិកន្លងសិក្ខាបទដទៃ, ភិក្ខុប្រព្រឹត្តកន្លងសិក្ខាបទណា, ការបែកធ្លាយសំវរ រមែងមាន តែក្នុងសិក្ខាបទនោះប៉ុណ្ណោះ ។ មិនមានការបែកធ្លាយនូវការសមាទានទេ ។*

★ ន ហិ តំ បុន កម្មវាចាយ សមាទាតព្វន្តិ អត្ថីតិ ។ បដិកម្មំ ករោន្តស្ស សំវរោ បាកតិកោ ហោតិ ។ សញ្ចិច្ច វីតិក្កមន្តោ វា បដិកម្មំ អករោន្តោ វា **អលជ្ជី នាម ហោតិ** ។ ន ទុស្សីលោតិ ។ ឯស នយោ សាមណេរសីលេបិ ។ *ព្រោះថា ការបែកធ្លាយសិក្ខាបទនោះ មិនមានកិច្ចថា គប្បីសមាទានដោយកម្មវាចាម្តងទៀតទេ ។ កាលបើសម្តែងចេញហើយ សំវររមែងតាំងនៅ តាមប្រក្រតីដូចដើមវិញ ។ កាលភិក្ខុក្លែងប្រព្រឹត្តកន្លងក្តី មិនសម្តែងចេញក្តី ឈ្មោះថា*

ជាអលជ្ជី ។ តែមិនឈ្មោះថា ជាអ្នកទ្រុស្តសីលទេ ។ សូម្បីក្នុងសីលរបស់សាមណេរ ក៏មានន័យនេះ ដូចគ្នា ។

តត្ថ បន សរណគមនេនេវ សមាទានំ សិទ្ធំ ហោតិ ។ លិង្គនាសនង្គំ កត្វា សរណគមនេ ភិន្នេ សព្វំ សមាទានំ ភិជ្ជតិ ។ តែក្នុងសីលរបស់សាមណេរនោះ ការសមាទាន រមែងសម្រេចហើយ ដោយសរណគមន៍ប៉ុណ្ណោះ ។ នាកាលសរណគមន៍ បែកធ្លាយហើយ ព្រោះធ្វើចំអង្គលិង្គ-នាសនៈ ទើបសមាទានទាំងពួង បែកធ្លាយទៅ ។

ឥតរេសុ បន យំ វីតិក្កមតិ តស្មឹយេវ សំវរភេទោ ហោតីតិ វេទិតព្វំ ។ តែក្នុងសិក្ខាបទទាំងឡាយក្រៅនេះ សាមណេរប្រព្រឹត្តកន្លងសិក្ខាបទណា, ការបែកធ្លាយសំវរ មានតែក្នុងសិក្ខាបទនោះតែម្យ៉ាង អ្នកសិក្សាគប្បីជ្រាបដូច្នេះឯង ។

<u>ក្នុងគម្ពីរអដ្ឋកថា រូបិយសិក្ខាបទ ពោលថា:</u>

**ការបរិភោគ ៤ យ៉ាងគឺ**

១-លជ្ជីបរិភោគៈ ការបរិភោគរួមជាមួយលជ្ជី

២-អលជ្ជីបរិភោគៈ ការបរិភោគរួមជាមួយអលជ្ជី

**៣-ធម្មិយបរិភោគៈ** ការបរិភោគប្រកបដោយធម៌

**៤-អធម្មិយបរិភោគៈ** ការបរិភោគមិនប្រកបដោយធម៌ ។

បណ្ដាការបរិភោគ ៤ យ៉ាងនោះ ការបរិភោគរបស់អលជ្ជីភិក្ខុ **រួមនឹងលជ្ជីភិក្ខុ** រមែងសមគួរ ។ មិនគប្បីពិន័យអាបត្តិ ចំពោះលោក ។ ការបរិភោគរបស់លជ្ជីភិក្ខុ រួមនឹងអលជ្ជីភិក្ខុ រមែងគួរក្នុងវេលាដែលលោកមិនទាន់ដឹង ។ ព្រោះថា **ធម្មតាភិក្ខុដែលជាអលជ្ជីមកពីដំបូងមិនមាន** ។ ព្រោះដូច្នោះ លោកដឹងនូវភាវៈនៃភិក្ខុនោះជាអលជ្ជី ក្នុងកាលណា គប្បីពោលក្នុងកាលនោះថា "លោកប្រព្រឹត្តល្មើសក្នុងកាយទ្វារ និងវចីទ្វារ, ការធ្វើនោះ មិនសមគួរទេ, លោកកុំធ្វើយ៉ាងនេះឡើយ" ។ បើលោកមិនអើពើ នៅចចេសធ្វើដដែលទៀត, បើនៅតែធ្វើការបរិភោគ រួមនឹងអលជ្ជីនោះ, សូម្បីលោកក៏ជាអលជ្ជីដែរ ។ ចំណែកភិក្ខុណា ធ្វើការបរិភោគរួមនឹងអលជ្ជី អ្នកដែលជាភារៈ (សិទ្ធិវិហារិកជាដើម)របស់ខ្លួន, សូម្បីភិក្ខុនោះ ដែលភិក្ខុដទៃឃើញ គប្បីហាម, **បើលោកមិនព្រមវៀរចាក, ភិក្ខុសូម្បីរូបនេះក៏ជាអលជ្ជី ដូចគ្នា** ។ អលជ្ជីភិក្ខុសូម្បីតែមួយរូប រមែងធ្វើឱ្យភិក្ខុជាអលជ្ជី បានសូម្បីទាំងរយរូបយ៉ាងនេះ ។ ឈ្មោះថាអាបត្តិក្នុងការបរិភោគរួមគ្នា រវាងអលជ្ជីនិងអលជ្ជី រមែងមិនមាន ។ ការបរិភោគរួមរវាងលជ្ជីនិងលជ្ជី ដូចគ្នានឹងឧត្តិយ-

កុមារពីរព្រះអង្គ សោយរួមគ្នា ក្នុងសុវណ្ណភាជន៍ ។ ការបរិភោគប្រកបដោយធម៌ និងមិនប្រកបដោយធម៌ អ្នកសិក្សាគប្បីជ្រាបដោយអំណាចនៃបច្ច័យនុ៎ះឯង ។

<u>ក្នុងគម្ពីរវិនយាលង្ការដីកា ពោលថា:</u>

★ លជ្ជិនា សទ្ធឹ បរិភោគោ នាម លជ្ជិស្ស សន្តកំ គហេត្វា បរិភោគោ ។ អលជ្ជិនា សទ្ធិន្តិ ឯត្ថាបិ ឯសេវ នយោ ។ ការកាន់យករបស់លជ្ជីភិក្ខុ ហើយបរិភោគ ឈ្មោះថា ការបរិភោគរួមជាមួយនឹងលជ្ជី ។ សូម្បីក្នុងពាក្យថា ការបរិភោគរួមជាមួយនឹងអលជ្ជី ក៏មានន័យដូចគ្នានេះដែរ ។

★ **អាទិតោ បដ្ឋាយ ហិ អលជ្ជី នាម នត្ថីតិ** ឥមិនា ទិដ្ឋទិដ្ឋេសុយេវ អាសង្កា ន កាតព្វាតិ ទស្សេតិ ។ អត្តនោ សទ្ធិវិហារិកាទយោបិ អលជ្ជិភាវតោ និវារេតព្វា ។ អលជ្ជីហិ សទ្ធិវិហារិកាទីហិ ឯកសម្ភោគំ ករោន្តា អញ្ញេបិ និវារេតព្វាវ ។ ដោយពាក្យថា ព្រោះថា ធម្មតាភិក្ខុដែលជាអលជ្ជីមកពីដំបូងមិនមាន ដូច្នេះនេះ លោកសម្ដែងថា ភិក្ខុមិនត្រូវធ្វើនូវសេចក្ដីរង្កៀសក្នុងការឃើញហើយៗ ប៉ុណ្ណោះទេ ។ សូម្បីភិក្ខុទាំងឡាយ មានសទ្ធិវិហារិក របស់ខ្លួនជាដើម

*ដែលមានសភាពជាអលជ្ជី គឺ(ព្រះឧបជ្ឈាយ៍) គប្បីហាម ។ សូម្បីភិក្ខុដទៃ កាលធ្វើនូវការបរិភោគរួមជាមួយសទ្ធិវិហារិក ជាដើម ដែលជាអលជ្ជី គឺ(ព្រះឧបជ្ឈាយ៍) គប្បីហាម ។*

★ **សចេ ន ឱរមតិ, អយម្បិ អលជ្ជីយេវ ហោតីតិ** ឯត្ថ ឯវំ និវារិតោ សោ បុគ្គលោ អលជ្ជិនា សទ្ធឹ បរិភោគតោ ឱរមតិ វិរមតិ, ឥច្ចេតំ កុសលំ ។ នោ ចេ ឱរមតិ, អយម្បិ អលជ្ជីយេវ ហោតិ, តេន សទ្ធឹ បរិភោគំ ករោន្តោ សោបិ អលជ្ជីយេវ ហោតីតិ អត្ថោ ។

*ក្នុងពាក្យថា បើលោកមិនព្រមវៀរចាក, ភិក្ខុសូម្បីរូបនេះ* ***ក៏ជាអលជ្ជីដូចគ្នា*** *ដូច្នេះ មានសេចក្តីថា បុគ្គលនោះ ដែលភិក្ខុដទៃហាមឃាត់ហើយយ៉ាងនេះ រមែងវៀរចាកឆ្ងាយអំពីការបរិភោគរួមជាមួយអលជ្ជី, ការវៀរចាកឆ្ងាយនោះជាការល្អ ។ បើលោកមិនព្រមវៀរចាកទេ, ភិក្ខុសូម្បីរូបនេះ ក៏ជាអលជ្ជីដូចគ្នា, សូម្បីភិក្ខុនោះ កាលធ្វើការបរិភោគរួមជាមួយនឹងភិក្ខុនោះ ក៏ជាអលជ្ជីដូចគ្នា ។*

## ការដឹងថាលោកជាអលជ្ជីហើយមិនគួរបរិភោគជាមួយ

*ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:*

★ **លជ្ជិនា សទ្ធឹ បរិភោគោតិ** ធម្មាមិសវសេន

មិស្សីភាវោ ។ អលជ្ជិនា សទ្ធិន្តិ ឯត្ថាបិ ឯសេវ នយោ ។

ពាក្យថា **ការបរិភោគរួមជាមួយនឹងលជ្ជី** ដូច្នេះ សេចក្តីថា ភាពជាអ្នកលាយគ្នា ដោយអំណាចការបរិភោគរួមធម៌ និង អាមិស ។ សូម្បីក្នុងពាក្យថា **ការបរិភោគរួមជាមួយនឹងអលជ្ជី** ដូច្នេះ ក៏មានន័យនេះដូចគ្នាដែរ ។

★ **អាទិតោ បដ្ឋាយ ហិ អលជ្ជី នាម នត្ថីតិ** ឥមិនា ទិដ្ឋទិដ្ឋេសុ អាសង្កា នាម ន កាតព្វា, ទិដ្ឋសុ-តាទិការណេ សតិ ឯវ កាតព្វាតិ ទស្សេតិ ។

ដោយពាក្យថា **ព្រោះថាធម្មតា ភិក្ខុដែលជាអលជ្ជីមកតាំង ពីដំបូងមិនមាន** ដូច្នេះនេះ លោកសម្តែងថា ឈ្មោះថា សេចក្តីរង្កៀស គឺភិក្ខុមិនត្រូវធ្វើក្នុងការឃើញហើយៗទេ, តែកាលហេតុមានការឃើញនិងការឮជាដើម មាន, គឺភិក្ខុគប្បីធ្វើពិត ។

★ **សចេ ន ឱរមតីតិ** អគតិគមនវសេន ធម្មាមិស-បរិភោគតោ ន ឱរមតិ ។ ក្នុងពាក្យថា **បើលោកមិនព្រមវៀរចាក**, ដូច្នេះ មានសេចក្តីថា លោកមិនព្រមវៀរចាក អំពីការបរិភោគរួមធម៌ និងអាមិស ដោយអំណាចការលុះនូវអគតិ ។

★ **អាបត្តិ នាម នត្ថីតិ** ឥទំ អលជ្ជីនំ ធម្មានុប្ប-

ន្នបច្ចយំ ធម្មកម្មញ្ច សន្ធាយ វុត្តំ ។ តេសម្បិ ហិ កុលទូសនាទិសមុប្បន្នំ បច្ចយំ បរិភុញ្ជន្តានំ វគ្គកម្មាទីនិ ករោន្តានញ្ច អាបត្តិ ឯវ ។ ពាក្យថា *ឈ្មោះថា អាបត្តិ រមែងមិនមាន* ដូច្នេះ ពាក្យនេះ គឺលោកពោលហើយ ព្រោះ សំដៅយកនូវបច្ច័យដែលកើតឡើងដោយធម៌ផង នូវកម្មប្រកប ដោយធម៌ផង របស់អលជ្ជីទាំងឡាយ ។ ព្រោះថា អាបត្តិរមែង មានពិត សូម្បីដល់ភិក្ខុទាំងនោះ កាលបរិភោគនូវបច្ច័យ ដែល កើតឡើង មានកុលទូសកកម្មជាដើមផង, កាលធ្វើនូវកម្មទាំង ឡាយ មានកម្មជាពួកជាដើមផង ។

<u>ក្នុងគម្ពីរអដ្ឋកថា ពោលថា:</u>

★ បើសូម្បីបុគ្គលក៏ជាអលជ្ជី សូម្បីបិណ្ឌបាតក៏មិនប្រកប ដោយធម៌, គួររង្កៀសទាំង ២ ចំណែក ។ បុគ្គលជាអលជ្ជី តែបិណ្ឌបាតប្រកបដោយធម៌, ភិក្ខុទាំងឡាយ រង្កៀសបុគ្គល ហើយ មិនគប្បីទទួលបិណ្ឌបាត ។ តែក្នុងមហាបច្ចរី លោក ពោលទុកថា អ្នកទ្រស្តសីល បានឧទ្ទេសភត្តជាដើម អំពីសង្ឃ ហើយ ប្រគេនដល់សង្ឃនុ៎ះឯង, ឧទ្ទេសភត្តជាដើមនេះ រមែង គួរ ព្រោះប្រព្រឹត្តទៅ តាមដែលគេប្រគេននុ៎ះឯង ។ បុគ្គលជា លជ្ជី, បិណ្ឌបាតមិនប្រកបដោយធម៌, បិណ្ឌបាតគួររង្កៀស មិន

គួរទទួលយក ។ បុគ្គលជាលជ្ជី សូម្បីបិណ្ឌបាតក៏ប្រកបដោយធម៌ រមែងសមគួរ ។

<u>ក្នុងគម្ពីរសារត្ថទីបនីដីកា ពោលថា:</u>

★ **សង្ឃស្សេវ ទេតីតិ** ភត្តំ អគ្គហេត្វា អត្តនា លទ្ធសលាកំយេវ ទេតិ ។ ត្រង់ពាក្យថា **ឱ្យដល់សង្ឃ វិញ** គឺមិនបានទទួលនូវភត្ត ហើយឱ្យនូវសលាកភត្ត ដែលខ្លួនបានប៉ុណ្ណោះ ។

<u>ក្នុងគម្ពីរវជិរពុទ្ធិដីកា ពោលថា:</u>

★ **យថាឋានមេវ គតត្តាតិ** ឯត្ថ អត្តនោ ហត្ថេន ចេ ទេតិ ន វដ្ដតីតិ វុត្តំ ។

ក្នុងពាក្យថា **ព្រោះប្រព្រឹត្តទៅតាមដែលគេប្រគេនទុកឯង** ដូច្នេះនេះ គឺលោកពោលហើយថា ប្រសិនបើឱ្យដោយដៃរបស់ខ្លួនមិនគួរ ។

អតិរេកភាគំ គហេត្វា បុនទិវសេ អត្តនោ អត្ថាយ ឧទ្ធដភាគំ ឥតរេ ទាបេតិ វដ្ដតីតិ ច ។ បរិវត្តកំ ទេតិ ធម្មិយញ្ច វដ្ដតិ ។ នោ អធម្មិយំ ។ (ភិក្ខុអលជ្ជី) កាន់យកចំណែកដែលលើស ហើយប្រើគេឱ្យ

ក្នុងថ្ងៃនោះឯង នូវចំណែកដែលលើកឡើង ដើម្បីប្រយោជន៍ដល់ខ្លួនក្នុងថ្ងៃស្អែករមែងគួរ ។ **បើលោកឱ្យនូវភត្ត ដែលប្រកបដោយធម៌ ជាការផ្លាស់ប្តូរ គួរ ។** បើភត្តមិនប្រកបដោយធម៌ មិនគួរទេ ។

## **ភិក្ខុលជ្ជីពោលសរសើរភិក្ខុអលជ្ជី មិនគួរ**

## ក្នុងគម្ពីរអដ្ឋកថា ពោលថា:

★ នៅមានការលើកតម្កើង ២ យ៉ាង និងការបរិភោគ ២ យ៉ាងទៀត គឺការលើកតម្កើងលជ្ជី ១, ការលើកតម្កើងអលជ្ជី ១, ធម្មបរិភោគ ១, អាមិសបរិភោគ ១, ក្នុងការលើកតម្កើងនិងការបរិភោគនោះ ការលើកតម្កើងលជ្ជី របស់អលជ្ជី សមគួរ ។ **មិនគួរពិន័យអាបត្តិលោក ។** ក៏បើថា លជ្ជីលើកតម្កើងអលជ្ជី រមែងនិមន្តដោយអនុមោទនា, និមន្តដោយធម្មកថាឧបត្ថម្ភក្នុងត្រកូលទាំងឡាយ, សូម្បីអលជ្ជីក្រៅនេះ ក៏ពោលសរសើរលោកក្នុងបរិស័ទថា អាចារ្យរបស់ពួកយើង រមែងជាអ្នកដូច្នេះនិងដូច្នេះ, ភិក្ខុនេះបណ្ឌិតគប្បីជ្រាបថា រមែងធ្វើព្រះសាសនា ឱ្យសាបសូន្យចុះ គឺឱ្យអន្តរធានទៅ ។

<u>*ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:*</u>

★ **ធម្មបរិភោគោតិ** ឯកកម្មំ ឯកុទ្ទេសោតិអាទិនា វុត្តសំវាសោ ចេវ និស្សយគ្គហណាទានាទិកោ សព្វោ និរាមិសបរិភោគោ ច វេទិតព្វោ ។ *សំវាសដែលលោកពោលហើយថា (ធ្វើ) នូវកម្មជាមួយគ្នា មានឧទ្ទេសជាមួយគ្នាជាដើម និងបរិភោគប្រាសចាកអាមិសទាំងអស់ មានការទទួលនិងការឱ្យនិស្ស័យជាដើម គប្បីជ្រាបថា **ជាធម្មបរិភោគ** ។*

★ **ន សោ អាបត្តិយា ការេតព្វោតិ** វុត្តត្តា លជ្ជិនោ អលជ្ជិបគ្គហេ អាបត្តីតិ វេទិតព្វំ ។

*ព្រោះពាក្យដែលព្រះអដ្ឋកថាចារ្យ ពោលថា **មិនគប្បីពិន័យអាបត្តិលោក** ដូច្នេះ អ្នកសិក្សាគប្បីជ្រាបថា ជាអាបត្តិដល់លជ្ជីភិក្ខុសរសើរអលជ្ជីភិក្ខុ ។*

<u>*ក្នុងគម្ពីរអដ្ឋកថា ពោលថា:*</u>

★ *ក៏បណ្ដាធម្មបរិភោគ និងអាមិសបរិភោគ, អាមិសបរិភោគក្នុងបុគ្គលណាសមគួរ, **សូម្បីធម្មបរិភោគ ក្នុងបុគ្គលនោះ ក៏សមគួរ** ។ លោកពោលទុក(ក្នុងអដ្ឋកថាទាំងឡាយ)ថា ក៏គម្ពីរណាតាំងនៅក្នុងចុងបន្តស់ នឹងវិនាសទៅដោយកាល*

*កន្លងទៅនៃបុគ្គលនោះ នឹងរៀនយកគម្ពីរនោះ ដើម្បីអនុគ្រោះ ដល់ធម៌ រមែងគួរ ។*

*__ក្នុងគម្ពីរវិមតិវិនោទនីដីកា ពោលថា:__*

★ "ធម្មបរិភោគោបិ តត្ថ វដ្តតី"តិ ឥមិនា អាមិស-បរិភោគតោ ធម្មបរិភោគោវ គរុកោ, តស្មា អតិវិយ អលជ្ជិវិវេកេន កាតព្វោតិ ទស្សេតិ ។ *ដោយពាក្យថា សូម្បី ធម្មបរិភោគក្នុងបុគ្គលនោះ ក៏គួរដែរ ដូច្នេះ សេចក្តីថា ធម្មបរិភោគហ្នឹងឯងធ្ងន់ជាងអាមិសបរិភោគ ព្រោះហេតុនោះ គឺភិក្ខុគប្បីធ្វើដោយការពិចារណា នូវភាពជាអលជ្ជី ឲ្យក្រៃលែង ។*

★ **"ធម្មានុគ្គហេន ឧគ្គណ្ហិតុំ វដ្តតី"តិ** វុត្តត្តា អលជ្ជុស្សន្នតាយ សាសនេ ឱសក្កន្តេ, លជ្ជីសុ ច អប្បហោន្តេសុ អលជ្ជិម្បិ បកតត្តំ គណបូរកំ គហេត្វា ឧបសម្បទាទិកិរណេន ចេវ កេចិ អលជ្ជិនោ ធម្មាមិស-បរិភោគេន សង្គហេត្វា សេសាលជ្ជិគណស្ស និគ្គហេន ច សាសនំ បគ្គណ្ហិតុំ វដ្តតិ ឯវ ។ *ព្រោះលោកពោលថា ការរៀនយកដើម្បីអនុគ្រោះធម៌ រមែងគួរ ដូច្នេះ សេចក្តីថា កាលសាសនាឱនថយចុះ ព្រោះច្រើនដោយអលជ្ជី, ក៏នាកាល*

*ភិក្ខុលជ្ជីមិនគ្រប់ គួរដើម្បីកាន់យកសូម្បីភិក្ខុអលជ្ជី ដែលជាបកតត្តធ្វើជាគណបូរកៈ ហើយលើកឡើងនូវព្រះសាសនា ដោយការធ្វើនូវឧបសម្បទាជាដើមផង ដោយការសង្គ្រោះដោយធម៌ និងអាមិសដល់អលជ្ជីពួកខ្លះ ហើយផ្ចាញ់ផ្ចាលដល់អលជ្ជីដ៏សេសផង រមែងគួរពិត ៗ*

✯ កេចិ បន "កោដិយំ ឋិតោ គន្ថោតិ វុត្តត្តា គន្ថបរិយាបុណនមេវ ធម្មបរិភោគោ ន ឯកកម្មាទិ ។ តស្មា អលជ្ជីហិបិ សទ្ធឹ ឧបោសថាទិកំ កម្មំ កាតុំ វដ្ដតិ អាបត្តិ នត្ថី"តិ វទន្តិ, តំ ន យុត្តំ, ឯកកម្មាទីសុ ពហូសុ ធម្មបរិភោគេសុ អលជ្ជិនាបិ សទ្ធឹ កត្តព្វាវត្ថាយុត្តំ ធម្មបរិភោគំ ឋបេត្វា ឥធ និទស្សនវសេន គន្ថស្សេវ សមុទ្ធដត្តា ។ *តែអាចារ្យពួកខ្លះពោលថា ព្រោះពាក្យដែលអដ្ឋកថាចារ្យពោលថា "**កោដិយំ ឋិតោ គន្ថោ** : គម្ពីរឋិតនៅទីបំផុត" ដូច្នេះ ការធ្វើកម្មជាមួយគ្នាជាដើម មិនឈ្មោះថា ធម្ម-បរិភោគទេ ។ ព្រោះហេតុនោះ ភិក្ខុគួរដើម្បីធ្វើកម្ម មានឧបោ-សថជាដើម ជាមួយអលជ្ជីភិក្ខុបាន មិនមានអាបត្តិទេ ។ ពាក្យរបស់អាចារ្យទាំងនេះមិនត្រឹមត្រូវទេ, ព្រោះព្រះអដ្ឋកថាចារ្យ*

លើកគន្ថ (ការរៀនយកនូវគម្ពីរ) តែម្យ៉ាងគត់ឡើងមក ដោយអំណាចនៃនិទស្សនៈ (ការសម្តែងចេញជាឧទាហរណ៍) ក្នុងធម្មបរិភោគនេះ ដើម្បីសម្តែងធម្មបរិភោគ ដែលមិនសមគួរ, មិនជាទីតាំង ដែលភិក្ខុលជ្ជីត្រូវធ្វើ ក្នុងធម្មបរិភោគ ទាំងឡាយជាច្រើន មានការធ្វើកម្មជាមួយគ្នាជាដើម ជាមួយភិក្ខុអលជ្ជីទេ ។

★ ន ហិ ឯកកម្មាទិកោ វិធិ ធម្មបរិភោគោ ន ហោតីតិ សក្កា, វត្តុំ អនាមិសត្តា ធម្មាមិសេសុ អបរិយាបន្នស្ស កស្សចិ អភាវា ។ ក៏អ្នកណាៗ មិនអាចពោលថា វិធីមានការធ្វើកម្មជាមួយគ្នាជាដើម មិនឈ្មោះថា ជាធម្មបរិភោគដូច្នេះបានទេ, ព្រោះវិធីមានការធ្វើកម្មជាមួយគ្នាជាដើមនោះ មិនមែនជាអាមិស (ថែមទាំង) វត្ថុណាមួយ មិនរាប់បញ្ចូលក្នុងធម៌ និងអាមិស ក៏មិនមាន ។

តេនេវ អដ្ឋសាលិនិយំ ធម្មបដិសន្ថារកថាយំ "កម្មដ្ឋានំ កថេតព្វំ, ធម្មោ វាចេតព្វោ ។បេ ។ អព្ភានវុដ្ឋានមានត្តបរិវាសាទាតព្វា, បព្វជ្ជារហោ, បព្វាជេតព្វោ ឧបសម្បទារហោ ឧបសម្បាទេតព្វោ ។បេ ។ អយំធម្មបដិសន្ថារោ នាមា"តិ ឯវំ សង្ឃកម្មាទិបិ ធម្មកោដ្ឋាសេ

ធសិ្សតំ ។ ព្រោះហេតុនេះ សូម្បីសង្ឃកម្មជាដើម ក៏ព្រះអដ្ឋ-កថាចារ្យ សម្ដែងក្នុងចំណែកនៃធម៌យ៉ាងនេះ **ក្នុងអដ្ឋសាលិនី** **ត្រង់បដិសណ្ឋារកថា** ថា "គប្បីប្រាប់កម្មដ្ឋាន, គប្បីបង្រៀនធម៌ ។ បេ ។ គប្បីឱ្យបរិវាស មានត្ត និងការចេញចាកដោយអព្ភាន, គប្បីឱ្យបព្វជ្ជា ដល់បុគ្គលដែលគួរបព្វជ្ជា, គប្បីឱ្យឧបសម្បទា ដល់បុគ្គលដែលគួរឧបសម្បទា ។ បេ ។ នេះឈ្មោះថា **ធម្មបដិសណ្ឋារៈ** ដូច្នេះ ។

★ យោ បន មហាអលជ្ជី ឧទ្ធម្មំ ឧព្វិនយំ សត្ថុសាសនំ ករោតិ, តស្ស សទ្ធិវិហារិកាទីនំ ឧបសម្បទាទិឧបការកម្មម្បិ ឧគ្គហបរិបុច្ឆាទានាទិ ច កាតុំ ន វដ្ដតិអាបត្តិ ឯវហោតិ, និគ្គហកម្មមេវ កាតព្វំ ។ តេនេវអលជ្ជិបគ្គហោបិ បដិក្ខិត្តោ ។ ក៏មហាអលជ្ជីណា ធ្វើនូវព្រះសាសនារបស់ព្រះសាស្ដាឱ្យខុសធម៌ ខុសវិន័យ មហាអលជ្ជីនោះ ធ្វើនូវកម្មជាឧបការៈមាន(ឱ្យ)ឧបសម្បទាជាដើម និងធ្វើនូវកិច្ចមានឱ្យនូវឧគ្គហៈ(ការរៀនបាលី) និងបរិបុច្ឆា (អដ្ឋកថា)ជាដើម ដល់ពួកសទ្ធិវិហារិកជាដើម **មិនគួរទេ**, អាបត្តិ រមែងមានពិត, សង្ឃគប្បីធ្វើកម្ម គឺការសង្កត់សង្កិន (ចំពោះ

លោក) ។ ព្រោះហេតុនោះឯង បានជាអដ្ឋកថាចារ្យ ហាមឃាត់ សូម្បីនូវការសរសើរអលជ្ជីភិក្ខុ ។

**អលជ្ជិបុគ្គលកថាចប់ ។**

## បកិណ្ណកវិនយកថា ចប់

## ទោសរបស់ភិក្ខុភ្លេចស្មារតីមិនដឹងខ្លួន
## ដេកលក់ទៅមាន ៥ យ៉ាងៈ

១. ទុក្ខំ សុបតិ ភិក្ខុនោះដេកលក់លំបាក
២. ទុក្ខំ បដិពុជ្ឈតិ ភ្ញាក់ឡើងក៏លំបាក
៣. បាបកំ សុបិនំ បស្សតិ ឃើញសុបិនអាក្រក់
៤. ទេវតា ន រក្ខន្តិ ទេវតាមិនរក្សា
៥. អសុចិ មុច្ចតិ អសុចិឃ្លាតចេញ ។

## អានិសង្សរបស់ភិក្ខុមានស្មារតីដឹងខ្លួន
## ដេកលក់ទៅមាន ៥ យ៉ាងៈ

១. សុខំ សុបតិ ភិក្ខុនោះដេកលក់ស្រួល
២. សុខំ បដិពុជ្ឈតិ ភ្ញាក់ឡើងក៏ស្រួល
៣. ន បាបកំ សុបិនំ បស្សតិ មិនឃើញសុបិនអាក្រក់
៤. ទេវតា រក្ខន្តិ ទេវតាតែងរក្សា
៥. អសុចិ ន មុច្ចតិ អសុចិមិនឃ្លាតចេញ ។

# បកិណ្ណកវិនយកថា

វត្តនិគ្រោធវ័ន

រៀបរៀងដោយ

ភិក្ខុ វិនយធរោ គុន-ប៊ុនសាយ

ព.ស. ២៥៥៥

(សម្រាប់ជាធម្មទាន)